german cooperation
DEUTSCHE ZUSAMMENARBEIT

Published by:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

សៀវភៅបណ្តុះបណ្តាលស្តីពី

ដំណោះស្រាយលើទិដ្ឋភាពសង្គម ក្នុងការអភិវឌ្ឍថាមពលវារីអគ្គិសនី

បណ្តាញអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី ប្រកបដោយចីរភាព នៃបណ្តាប្រទេសទន្លេមេគង្គ (NSHD-M)

សៀវភៅបណ្តុះបណ្តាលស្តីពី

ដំណោះស្រាយលើទិដ្ឋភាពសង្គម ក្នុងការអភិវឌ្ឍជាមពលខារីអគ្គិសនី

អារម្ភកថា

កិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេសតាមដងទន្លេមេគង្គ និង ប្រទេសដែលស្ថិតក្នុងចំណុះនៃទន្លេនេះ បានចាប់ផ្តើមនាឆ្នាំ១៩៥៧ នៅពេលដែលអង្គការសហប្រជាជាតិ បានបង្កើតឡើងនូវគណៈកម្មការទន្លេមេគង្គ (MRC) ។ ក្នុងពេលជាមួយគ្នានោះ **ទន្លេមេគង្គ**គឺជាទន្លេមួយដ៏ធំជាងគេក្នុងចំណោមទន្លេដទៃទៀតក្នុងពិភពលោក ដែលមិនទាន់ត្រូវបានធ្វើនិយតកម្មនៅឡើយ រីឯគណៈកម្មការទន្លេមេគង្គមានតួនាទីប្រមូលប្រាក់ទុនដែលបានពីសក្តានុពលសេដ្ឋកិច្ចនៃទន្លេនេះ។ តាមរយៈកិច្ចព្រមព្រៀងមេគង្គនាឆ្នាំ១៩៩៥ គណៈកម្មការទន្លេមេគង្គត្រូវបានបង្កើតឡើងក្នុងគោលដៅលើកកម្ពស់ និង សម្របសម្រួលដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍ទឹក និងធនធានពាក់ព័ន្ធដទៃទៀតប្រកបដោយចីរភាព សម្រាប់ផលប្រយោជន៍រួមនៃបណ្តាប្រទេសស្ថិតនៅតាមដងទន្លេមេគង្គ និងសុខមាលភាពរបស់ប្រជាជននៃប្រទេសទាំងនេះ តាមរយៈការអនុវត្តកម្មវិធីជាយុទ្ធសាស្ត្រ និងសកម្មភាពនានា ក៏ដូចជាការផ្តល់ព័ត៌មានបែបវិទ្យាសាស្ត្រ និងសេចក្តីណែនាំជាគោលការណ៍។ កិច្ចព្រមព្រៀងមេគង្គនេះ ក៏បានកំណត់ផងដែរថា គណៈកម្មការទន្លេមេគង្គត្រូវស្ថិតក្រោមការទទួលខុសត្រូវដោយផ្ទាល់ពីប្រទេសជាសមាជិកទាំងបួនរួមមាន ៖ ប្រទេសថៃ ឡាវ កម្ពុជា និងវៀតណាម។ ចំណែកប្រទេសធំៗពីរ ដែលស្ថិតនៅផ្នែកភាគលើនៃដងទន្លេមេគង្គ គឺប្រទេសចិន និងភូមា ដែលជាប្រទេសមានទឹកទន្លេមេគង្គហូរកាត់ដែរនោះ ត្រូវបានកំណត់ថា ជាប្រទេសដៃគូរបស់គណៈកម្មការទន្លេមេគង្គ។

ការអភិវឌ្ឍធនធានទឹកទន្លេមេគង្គ និង តំបន់ដែលស្ថិតក្នុងចំណុះទន្លេនេះ ត្រូវបានកត់សម្គាល់ឃើញថា មានការស្ថាបនាឡើងនូវទំនប់វារីអគ្គិសនីធំៗជាច្រើន នៅក្នុងបណ្តាប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ ។ ទំនប់វារីអគ្គិសនីទាំងនេះ ត្រូវបានស្ថាបនាឡើងក្នុងគោលបំណងជាច្រើនរួមមាន ៖ ការការពារទឹកជំនន់ ការស្រោចស្រព និងថាមពលវារីអគ្គិសនី ។ ទំនប់ទាំងនេះត្រូវបានសាងសង់ឡើងដោយភាពចម្រូងចម្រាស់នៃផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថានធម្មជាតិ និង សង្គមនៃប្រទេសជាប់ព្រំដែនគ្នា ដែលជាហេតុធ្វើឲ្យប្រទេសជាសមាជិកមួយចំនួន តួយ៉ាងប្រទេសថៃបានបញ្ឈប់នូវការសាងសង់ទំនប់វារីអគ្គិសនីនានានៅក្នុងទឹកដីរបស់ខ្លួន។

នៅក្នុងឆ្នាំ២០០០ គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ហៅកាត់ថា (WCD) បានចេញផ្សាយនូវរបាយការណ៍របស់ខ្លួនដែលមានចំណងជើងថា *ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ៖ បទដ្ឋានថ្មីសម្រាប់ធ្វើការសម្រេចចិត្ត*។ គណៈកម្មការនេះបានដាក់ចេញនូវយុទ្ធសាស្ត្រមួយដោយផ្អែកទៅតាមការទទួលស្គាល់នូវសិទ្ធិ និង ការវាយតម្លៃហានិភ័យនានា ជាពិសេសទាក់ទងនឹងសិទ្ធិក្នុងការទទួលបាននូវគុណតម្លៃសមភាព ប្រសិទ្ធភាព ការចូលរួមក្នុងការសម្រេចចិត្ត និរន្តរភាព និងគណនេយ្យភាព។ បន្ថែមពីលើនេះ គណៈកម្មការនេះ បានកំណត់នូវយុទ្ធសាស្ត្រជាអាទិភាពចំនួន ៧ ឬករួមទាំងគោលការណ៍នានាចំនួន ២៦ សម្រាប់ធ្វើជាផ្លូវក្នុងការអនុវត្តឆ្ពោះទៅមុខ។

បន្ទាប់ពីបំពេញការងាររបស់ខ្លួនរួចមក គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ក៏ត្រូវបានបញ្ចប់អាណត្តិរបស់ខ្លួន។ ដើម្បីរក្សានូវសារណាសញ្ញាដែលបានបង្កើតឡើងដោយគណៈកម្មការនេះ និងដើម្បីរក្សានូវតួនាទីអព្យាក្រិតក្នុងការផ្សព្វផ្សាយរបាយការណ៍របស់គណៈកម្មការនេះ ក៏ដូចជាដើម្បីបន្ត

ត្រូតពិនិត្យនូវអនុសាសន៍នានាដែលបានស្នើឡើងនៅក្នុងក្របខ័ណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈកិច្ចប្រជុំពិភាក្សាក្នុងរង្វង់ភាគីពាក់ព័ន្ធ ទើបគម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP) បានព្រមព្រៀងដាក់ចេញនូវគម្រោងផ្តួចផ្តើមគំនិតមួយ ឲ្យមានការបន្តអនុវត្តការងារនេះ មានឈ្មោះថា " គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) " ។ លទ្ធផលមួយក្នុងចំណោមលទ្ធផលនានានៃដំណើរការរបស់គម្រោងនេះ គឺការចងក្រង*ឯកសារស្តីពីការអនុវត្តលើសេចក្តីសម្រេចចិត្ត ដែលមានលក្ខណៈល្អប្រសើរពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន ។*

តាមរយៈសកម្មភាពការងារនៃគម្រោង (DDP) និងតាមរយៈជំនួយពីគម្រោង (UNEP) និង ជំនួយរបស់(GIZ) ដែលពីមុនមានឈ្មោះថា InWEnt- ការកសាងសមត្ថភាពថ្នាក់អន្តរជាតិនៃប្រទេសអាល្លឺម៉ង់ ទើបអង្គការសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង ជាមួយអង្គការសហគមន៍អាហ្វ្រិកខាងកើត បានផលិតសៀវភៅបណ្តុះ-បណ្តាលចំនួន ៣ គ្របដណ្តប់លើប្រធានបទសំខាន់ៗដូចជា (ផែនការគ្រប់គ្រងបរិស្ថាន សេដ្ឋកិច្ច បែបសម្រិត-សម្រាំង ការទូទាត់សំណង និងការបែងចែកផលប្រយោជន៍ និងការវាយតម្លៃតាមជម្រើសដែល មានលក្ខណៈទូលំទូលាយ) ដែលត្រូវបានដាក់បញ្ចូលទៅក្នុង*ឯកសារស្តីពីការអនុវត្តលើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈល្អប្រសើរ ពាក់ព័ន្ធនឹងទំនប់វារី និងជម្រើសដែលអាចជំនួសបាន ។* ការបណ្តុះបណ្តាល ត្រូវបានធ្វើឡើងដោយជោគជ័យចាប់តាំងពីឆ្នាំ២០០៩ អនុវត្តដោយនាយកដ្ឋានគ្រប់គ្រងទឹកនៃសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (SADC Water Division) សំដៅបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់របស់ប្រទេសជាសមាជិកនីមួយ។

ដោយសារតែគម្រោងអភិវឌ្ឍន៍ធនធានទឹកដែលមានពីមុនមក ភាគច្រើនដំណើរការទៅប្រកបដោយភាពអវិជ្ជមាន និងដោយសារការយល់ឃើញថា ការជួបប្រឈមនានាមានការវិវត្តន៍ជាបន្តបន្ទាប់ដោយសារការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសការកើនឡើងមិនធ្លាប់មាននៃតម្រូវការថាមពលកែច្នៃប្រកបដោយនិរន្តរភាព (ជាពិសេសថាមពលវារីអគ្គិសនីនៅក្នុងបណ្តាប្រទេសទន្លេមេគង្គ) ទើបគណៈកម្មការទន្លេមេគង្គ (MRC) និងគម្រោងកម្មវិធីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ GIZ បានព្រមព្រៀងលើតម្រូវការក្នុងការសម្របសម្រួលឲ្យមានការសិក្សាទៅលើបទពិសោធន៍រវាងបណ្តាប្រទេសជាសមាជិក ដើម្បីជម្រុញឲ្យមានកិច្ចអភិវឌ្ឍន៍ធនធានទឹកទន្លេមេគង្គប្រកបដោយនិរន្តរភាព តាមរយៈការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និង ការការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព។ ការព្រមព្រៀងនេះបាននាំទៅដល់ការបង្កើតបណ្តាញអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី ប្រកបដោយចីរភាពនៃបណ្តាប្រទេសទន្លេមេគង្គ (NSHD-M) ក្នុងចំណោមអ្នកជំនាញការជាន់ខ្ពស់ និង អ្នកស្រាវជ្រាវនៃបណ្តាប្រទេសជាសមាជិករបស់ប្រទេសជាសមាជិកទាំងនេះ។ គួនាទីចម្បងរបស់បណ្តាញនេះ គឺការអភិវឌ្ឍន៍ធនធានមនុស្ស ការបណ្តុះបណ្តាលជាន់ខ្ពស់ កិច្ចពិភាក្សា និង ការចងក្រងបណ្តាញថ្នាក់តំបន់សម្រាប់ចែករំលែកព័ត៌មាន និងបទពិសោធន៍អនុវត្តល្អៗ។

គួនាទីនេះអាចសម្រេចបានតាមរយៈការចែករំលែកព័ត៌មានលើប្រធានបទសំខាន់ៗចំនួន៧ ៖

- ការធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ីនៃអាងទន្លេ
- ការវាយតម្លៃតាមជម្រើសដែលមានលក្ខណៈទូលំទូលាយ

- ដំណោះស្រាយលើទិដ្ឋភាពសង្គម
- ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី និងសេដ្ឋកិច្ច
- ការអនុវត្តន៍ជាវិធាន និងការតាមដានត្រួតពិនិត្យ
- ការផ្តល់សុវត្ថិភាព និងការការពារគ្រោះមហន្តរាយ
- ការរៀបចំផែនការទាក់ទងនឹងបញ្ហាឆ្លងព្រំដែន និងជំនួបពិភាក្សា។

ប្រធានបទខាងលើនេះត្រូវបានចងក្រងនៅក្នុងសៀវភៅបណ្តុះបណ្តាលចំនួន ៥ ដែលគាំទ្រដោយករណីសិក្សាជាក់ស្តែងតាមប្រទេសនានា ដែលរៀបចំចងក្រងដោយអ្នកជំនាញការជាន់ខ្ពស់ និង អ្នកស្រាវជ្រាវនៃបណ្តាប្រទេសជាសមាជិក។ សៀវភៅបណ្តុះបណ្តាលនេះ មានបង្ហាញពីដំណោះស្រាយលើទិដ្ឋភាពសង្គម។

សៀវភៅបណ្តុះបណ្តាលនីមួយៗត្រូវបានរៀបចំឡើងជា៣ជំហាន រួមមានការចងក្រងសៀវភៅបណ្តុះបណ្តាលតាមប្រភេទនៃវិសាលភាពល្មម និងស៊ីជម្រៅ ការយកលំនាំសៀវភៅបណ្តុះបណ្តាលតាមប្រភេទនេះឲ្យស្របទៅតាមបទដ្ឋានច្បាប់ជាក់លាក់ និងស្ថាប័នរបស់ប្រទេសដែលមានអាងទន្លេមេគង្គរួមគ្នា និងលក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គម ព្រមទាំងការយកលំនាំតាមដទៃទៀត ដែលតម្រូវឲ្យមានជាចាំបាច់ រួមមានការបកប្រែសៀវភៅបណ្តុះបណ្តាលទាំងនោះជាភាសាជាតិរៀងៗខ្លួន ។ ការបកប្រែនេះត្រូវបានយកមករួមផ្សំគ្នាចេញជាសៀវភៅ បណ្តុះបណ្តាលតាមប្រភេទ ដែលមានចំណងជើងថា " ដំណោះស្រាយលើទិដ្ឋភាពសង្គម " ។

អង្គការ GIZ លើកកម្ពស់ និង គាំទ្រការសិក្សាដោយមានការចូលរួម និង អនុវត្តវិធីសាស្ត្រនៃការសិក្សារបស់មនុស្សពេញវ័យ ដោយមានការចូលរួម (PALA) ។ ការអប់រំមនុស្សពេញវ័យដោយមានការចូលរួមត្រូវបានបង្កើតឡើង ដោយសំអាងលើកត្តាសិទ្ធិរបស់ប្រជាពលរដ្ឋចំពោះឥទ្ធិពលនៃការសម្រេចចិត្តដែលជាប់ទាក់ទងនឹងជីវភាពរស់នៅរបស់ពួកគាត់ ហើយដែលមនុស្សពេញវ័យជាអ្នកសិក្សាសុទ្ធសឹងតែមានគោលដៅ និ ងគំនិតល្អៗទាក់ទងនឹងវិស័យអប់រំ ។ ដូច្នេះកម្មវិធីអប់រំនានាត្រូវផ្សារភ្ជាប់ជាមួយអ្នកសិក្សាផ្ទាល់ ដើម្បីឲ្យពួកគេអាចធ្វើការសម្រេចចិត្តអំពីការសិក្សារៀនសូត្ររបស់ខ្លួន ជាពិសេសតាមរយៈសកម្មភាពដែលត្រូវបានជ្រើសរើស និងកំណត់ដោយអ្នកសិក្សាទាំងនោះឯង។ ជាលទ្ធផលទទួលបានមកវិញ គឺអាចបញ្ជាក់បានអំពីចំណេះដឹង និងតម្រូវការរបស់អ្នកសិក្សា ធ្វើឲ្យប្រសើរឡើងនូវការសម្រេចបានជោគជ័យកម្រិតខ្ពស់ ព្រមទាំងធ្វើឲ្យលេចចេញជារូបរាងឡើងនូវវិសាលភាព ដែលសិក្ខាកាមអាចអនុវត្តលំហាត់នៅក្នុងថ្នាក់រៀន នៅក្នុងជីវភាពរស់នៅ និងក្នុងសហគមន៍របស់ខ្លួនបាន ។ យោងទៅតាមអ្នកជំនាញការខាងអប់រំយុវវ័យបានឲ្យដឹងថា ការអប់រំដោយមានការចូលរួមមានគោលបំណង លើកកម្ពស់ដល់អ្នកសិក្សាឲ្យមានស្វ័យតភាព គំនិតត្រិះរិះ ភាពជាអ្នកដឹកនាំ និងក្លាយជាពលរដ្ឋសកម្ម ។

អ្វីដែលត្រូវបានបង្ហាត់បង្រៀន គឺមានសារៈសំខាន់ដែលអាចយកទៅអនុវត្តបាន នៅក្នុងជីវភាពរស់នៅជាក់ស្តែង។ អាស្រ័យហេតុនេះ ការរៀបចំសិក្ខាសាលា គួរតែផ្តល់ឱកាសដល់សិក្ខាកាមជាមនុស្សពេញវ័យ ឲ្យទទួលបាននូវអ្វីដែលសមស្របទៅតាមស្ថានភាពជីវភាព និងតាមតម្រូវការទីផ្សារការងារផង

ដែរ ។ គួរតែលើកទឹកចិត្តដល់សិក្ខាកាមឲ្យចែករំលែកបទពិសោធន៍របស់ពួកគេ និង ដំណោះស្រាយលើបញ្ហាដែលអាចធ្វើទៅរួច ដើម្បីធ្វើឲ្យសិក្ខាសាលានោះមានលក្ខណៈសហការល្អក្នុងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក។

មនុស្សពេញវ័យមានបទពិសោធន៍ផ្សេងៗគ្នាក្នុងជីវិតរស់នៅ ដែលអាចឈានទៅដល់ការប្រមូលផ្តុំនៃចំណេះដឹង ។ បទពិសោធន៍មួយចំនួនបានមកពីការសិក្សាកន្លងមក រីឯមួយចំនួនទៀតបានពីជីវិតជាក់ស្តែងក្នុងសង្គម និងជីវិតការងារ។ បទពិសោធន៍ទាំងនេះ គឺជាធនធានព័ត៌មានដ៏មានសារៈសំខាន់មួយដែលអាចយកមកប្រើប្រាស់បាននៅក្នុងដំណើរការសិក្សា បូករួមទាំងបទពិសោធន៍ និងជំនាញរបស់សិក្ខាកាមដែលអាចជួយដល់អ្នកដទៃបាន ។ ការចងក្រងចំណេះដឹង ដែលមានស្រាប់ពីសិក្ខាកាមទាំងនោះ និង ការជម្រុញលើកទឹកចិត្តឲ្យពួកគេអាចចែករំលែកចំណេះដឹងរបស់ខ្លួនដល់អ្នកដទៃ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ។ សិក្ខាកាមអាចសិក្សាបន្ថែមតាមរយៈការស្តាប់ និងចូលរួមយ៉ាងសកម្ម ជាជាងការកត់ត្រាលម្អិត ។ សិក្ខាកាមត្រូវចូលរួមយ៉ាងសកម្ម សំដៅទទួលបាននូវការសិក្សាមួយដែលគាប់ប្រសើរ។ នៅក្នុងការសិក្សាដោយមានការចូលរួមអ្នកសិក្សាត្រូវចូលរួមយ៉ាងសកម្ម ដើម្បីកំណត់ឲ្យបានច្បាស់ថាតើពួកគេរៀនអំពីអ្វី និង រៀនដោយរបៀបណា ។ ការសិក្សាបែបនេះអាចរួមបញ្ចូលទាំងគោលបំណង ចំណេះដឹង ជំនាញ និងអកប្បកិរិយា ឬ វិធីសាស្ត្រនៃការបង្រៀនជាដើម។ ការរៀនសូត្រ ជាលក្ខណៈប្រពៃណី ត្រូវបានអនុវត្តឡើងតាមតែគ្រូជាអ្នកផ្តល់ឲ្យ ។ ចំណែកឯការសិក្សាដោយមានការចូលរួមវិញ ត្រូវបានអនុវត្តឡើងដោយរបៀបសកម្ម ដែលអ្នកសិក្សាត្រូវអនុវត្តតាមលំនាំមួយ និងសិក្សាស្វែងយល់ពីលំនាំនោះតែម្តង ។

វិធីសាស្ត្រសិក្សាដោយមានការចូលរួម ត្រូវបានជម្រុញឲ្យអនុវត្ត ស្របពេលដែលតម្រូវការព័ត៌មានក៏ត្រូវធ្វើការបង្ហាញដល់អ្នកសិក្សាផងដែរ ។ ឧទាហរណ៍នៃវិធីសាស្ត្រនេះរួមមាន ការផ្តល់សេចក្តីណែនាំ ការផ្តល់ ដំបូន្មាន ឬ យោបល់ ការសង្ខេប ការពន្យល់ពីអ្វីមួយ ឬ ការបង្ហាញពីអ្វីមួយ ។ អ្វីដែលជាការប្រឈម គឺការផ្តល់ព័ត៌មានដោយមិនធ្វើឲ្យមនុស្សមានការធុញថប់ ។

មធ្យោបាយផ្សេងៗទៀត ដែលអាចយកមកអនុវត្តបានទាក់ទងនឹងការសិក្សាដោយមានការចូលរួម រួមមាន ការងារជាក្រុម ការពិភាក្សាជាក្រុម ការបំផុសគំនិត ការសម្តែងតួ កម្មសិក្សានៅទីវាល សំនួរ និង ចម្លើយ។

គោលដៅនៃការបណ្តុះបណ្តាលដែលត្រូវធ្វើឡើង គឺពឹងផ្អែកលើសម្ភារៈដែលមានបង្ហាញនៅក្នុងសៀវភៅបណ្តុះបណ្តាលនេះ ដែលនឹងជាការបណ្តុះបណ្តាលដោយមានការចូលរួមតាមលក្ខណៈធម្មជាតិ ដោយការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវផលប្រយោជន៍ នៃវិធីសាស្ត្រនៃការសិក្សារបស់មនុស្សពេញវ័យដោយមានការចូលរួម (PALA)។

ការអនុវត្តវិធីសាស្ត្រសិក្សាទំនើបរបស់មនុស្សពេញវ័យ នៅក្នុងព្រឹត្តិការណ៍សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល នៅទីក្រុងភ្នៀងចាន់ ប្រទេសឡាវ ខែធ្នូ ឆ្នាំ២០១៣

តារាងមាតិកា

អារម្ភកថា.....
តារាងមាតិកា .....
តារាងគំនូសសម្គាល់.....
បញ្ជីតារាង .....
តារាងប្រអប់អត្ថបទ .....
ពាក្យបំព្រួញ និងអក្សរកាត់.....
១. សាថតា និងបរិបទ.....
១.១ កិច្ចប្រជុំកំពូលស្តីពីផែនដី និងគោលដៅអភិវឌ្ឍន៍ផែនដី .....
១.១.១ កិច្ចក្រជុំកំពូលស្តីពីផែនដីរីយ៉ូ (Rio Earth Summit).....
១.១.២ កិច្ចប្រជុំរីយ៉ូបូក១០ (Rio+10).....
១.១.៣ កិច្ចប្រជុំរីយ៉ូបូក២០ (Rio+20) .....
១.២ គោលដៅអភិវឌ្ឍន៍ផែនដី.....
១.៣ ថាមពលវារីអគ្គិសនីនៅអាងទន្លេមេគង្គក្រោម (LMB) .....
១.៣.១ គម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលវារីអគ្គិសនី ប្រកបដោយចីរភាព.....
១.៤ ការអភិវឌ្ឍធនធានទឹករួមផ្សំ ដោយពឹងផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍសម្រាប់អាងទន្លេមេគង្គក្រោម..
១.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ .....
១.៤.២ យុទ្ធសាស្ត្រគ្រប់គ្រងអាងទន្លេ .....
១.៤.៣ ការអនុវត្តយុទ្ធសាស្ត្រ.....
១.៤.៤ ស្ថានភាពយុទ្ធសាស្ត្រ.....
១.៥ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសអាងទន្លេមេគង្គក្រោម .....
១.៥.១ ចំណេះដឹងសំខាន់ស្តីពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុក្នុងតំបន់ .....
១.៥.២ ចំណេះដឹងសំខាន់ស្តីពីអំពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុក្នុងប្រទេស.....
១.៥.៣ ការឆ្លើយតបថ្នាក់ជាតិចំពោះការប្រែប្រួលអាកាសធាតុ.....
១.៥.៤ ការវិភាគអំពីភាពចន្លោះប្រហោង និអនុសាសន៍នានា .....
១.៦ សរុបសេចក្តី.....
២. រចនាសម្ព័ន្ធនៃសៀវភៅបណ្តុះបណ្តាល និងឯកសារដែលជាប្រភពសំខាន់.....
២.១ រចនាសម្ព័ន្ធ.....
២.២ សម្ភារៈដែលជាប្រភពចាំបាច់.....
៣. សេចក្តីផ្តើមស្តីពីកិច្ចពិភាក្សាទៅលើទំនប់ខ្ពាតធំ និងសំណង់អគារថាមពលវារីអគ្គិសនី.....
៣.១ វគ្គ ៣-១សារគា.....
៣.១.១ ការគម្រោមកំហែងទៅលើបរិស្ថាន .....

៣.១.២ ទស្សន:នៃការធ្វើឲ្យមាននិរន្តរភាព.....
៣.១.៣ គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD).....
៣.១.៤ គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) និងឯកសារអនុវត្ត (Compendium).....
៣.១.៥ ការគម្រាមកំហែងទីលើថាមពលវារីអគ្គិសនី.....
៣.១.៦ ជម្រើសដែលអាចជំនួសបានទាក់ទងនឹងទឹក: WCD+10.....
៣.១.៧ អាងទន្លេមេគង្គ.....
៤. ការវាយតម្លៃហេតុប៉ះពាល់សង្គម.....
៤.១ វគ្គ៤.១-សេចក្តីផ្តើម.....
៤.២ វគ្គ៤.២-បទដ្ឋានជានិយាម.....
៤.២.១ សារៈសំខាន់ៗនៃបទដ្ឋានជានិយាមនានា.....
៤.៣ វគ្គ៤.៣-ការវាយតម្លៃហេតុប៉ះពាល់សង្គម និងរយៈវេលានៃការអនុវត្តគម្រោង.....
៤.៤ វគ្គ៤.៤-នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់សង្គម និងធាតុផ្សំនានា.....
៤.៤.១ សេចក្តីផ្តើម.....
៤.៤.២ ការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ.....
៤.៤.៣ ការកំណត់ឲ្យឃើញច្បាស់លាស់ និងការគិតគូរលើជម្រើសដែលអាចជំនួសបាន.....
៤.៤.៤ ការរៀបចំឲ្យមានជាទម្រង់លក្ខខ័ណ្ឌជាមូលដ្ឋាន.....
៤.៤.៥ ការកំណត់ពីវិសាលភាព.....
៤.៤.៦ ការព្យាករណ៍លើផលប៉ះពាល់នានា.....
៤.៤.៧ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ.....
៥. ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត.....
៥.១ វគ្គ៥.១-សេចក្តីផ្តើម និងបទដ្ឋានជានិយាម.....
៥.២ វគ្គ៥.២-តម្រូវការចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី.....
៥.២.១ ការតម្រូវឲ្យមានជាទូទៅ.....
៥.២.២ ការផ្លាស់ទីជម្រកជាលក្ខណៈរូបវន្ត.....
៥.៣ វគ្គ៥.៣-ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី.....
៥.៣.១ ប្រភេទនៃការតាំងទីលំនៅថ្មី.....
៥.៣.២ ធាតុផ្សំសំខាន់ៗនៃផែនការសកម្មភាពស្តីពីការតាំងទៅលំនៅថ្មី.....
៥.៤ វគ្គ៥.៤-ការអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត.....
៥.៤.១ ការត្រៀមរៀបចំ.....
៥.៤.២ ការអនុវត្ត.....
៥.៤.៣ កំណត់ត្រានានា.....
៥.៤.៤ ការរៀបចំផែនការត្រៀមបង្ការជាមុន/ផែនការនានា.....

៥.៤.៥ ការគាំទ្រក្រោយពេលតាំងទីលំនៅថ្មី .....
៥.៤.៦ ការបិតបញ្ចប់.....**បកប្រែបញ្ចប់ជំហានទី១!**
៦. គោលការណ៍ទូទាត់សំណង និងការបែងចែកផលប្រយោជន៍.....
៦.១ វគ្គ៦.១-សាវតា .....
៦.១.១ តម្រូវការចំពោះការទូទាត់សំណងដ៏ប្រសើរសម្រាប់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត
៦.១.២ បទដ្ឋានជានិយាម.....
៦.២ វគ្គ៦.២-គោលនយោបាយស្តីពីការទូទាត់សំណង-គោលការណ៍នានា .....
៦.២.១ ការធានាដល់ជីវភាពរស់នៅដ៏ប្រសើររបស់ប្រជាពលរដ្ឋរងផលប៉ះពាល់.....
៦.២.២ ការអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍.....
៦.២.៣ ការទូទាត់សំណងជាក់ស្តែងនៅនឹងកន្លែងជំនួសដោយការសងជាសាច់ប្រាក់.....
៦.២.៤ ការទូទាត់សំណងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ដែលពុំមានកម្មសិទ្ធិដីធ្លីស្រប ច្បាប់.....
៦.៣ វគ្គ៦.៣-ប្រភេទនៃយន្តការទូទាត់សំណង.....
៦.៤ វគ្គ៦.៤-យន្តការមិនមែនបែងចែកផលប្រយោជន៍ជារូបិយវត្ថុ .....
៦.៤.១ ទ្រឹស្តី/ទស្សនៈជាគំរូ .....
៦.៤.២ ឧទាហរណ៍នានាជាករណីសិក្សា .....
៦.៥ វគ្គ៦.៥-យន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ.....
៦.៥.១ ការទូទាត់សំណងបន្ថែម សម្រាប់រយៈពេលវែងដល់ពលរដ្ឋរងផលប៉ះពាល់ពីគម្រោង .....
៦.៥.២ ការបង្កើតមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ សម្រាប់រយៈពេលវែង.....
៦.៥.៣ ការបង្កើតភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងប្រជាសហគមន៍ .....
៦.៦ វគ្គ៦.៦-ប្រាក់ឈ្នួលសេដ្ឋកិច្ច និងការដាក់កម្រិតហិរញ្ញវត្ថុ.....
៦.៧ វគ្គ៦.៧-ប្រសិទ្ធភាព ការចូលរួម និងគណនេយ្យភាព.....
៦.៧.១ ការសម្រុះសម្រួលគោលដៅរបស់ភាគីពាក់ព័ន្ធ.....
៦.៧.២ ការធានាប្រសិទ្ធភាពនៃការបែងចែកសារជាថ្មីនូវផលប្រយោជន៍រូបិយវត្ថុ .....
៦.៧.៣ ការធានាការចូលរួមពីសហគមន៍មូលដ្ឋាន .....
៦.៧.៤ ការធានាគណនេយ្យភាពនៃភ្នាក់ងារដែលបានប្រគល់សិទ្ធិក្នុងការបែងចែកផលប្រយោជន៍ .....
៧. បញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ.....
៧.១ ការណែនាំពីបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ .....
៧.១.១ ហេតុផលក្នុងការដោះស្រាយលើបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ.....
៧.២ វគ្គ៧.២-របៀបដោះស្រាយលើបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ.....
៧.២.១ មូលនិធិសម្រាប់ដោះស្រាយ និងទម្រង់ផ្សេងៗទៀតនៃការទូទាត់សំណង .....
៧.២.២ នីតិវិធីនៃបណ្តឹងតវ៉ា (សារទុក្ខ).....
៧.២.៣ ការទូទាត់សំណង.....

៧.២.៤ នីតិវិធីផ្លូវច្បាប់.....
៨. ការចូលរួមរបស់ភាគីពាក់ព័ន្ធ.....
៨.១ វគ្គ៨.១-សាវតា និយមន័យ និងទស្សន:គន្លឹះ .....
៨.១.១ និយមន័យ និងការពិភាក្សាអំពីទស្សន:យល់ឃើញនានា .....
៨.១.២ ទស្សន:អំពីសមាគមន៍អន្តរជាតិសម្រាប់ការចូលរួមជាសាធារណៈ (IAP2) .....
៨.១.៣ គំរូសម្រេចចិត្ត ប្រកាស ការពារ (DAD).....
៨.១.៤ ការធ្វើការសម្រេចចិត្ត ក្នុងអំឡុងពេលរយៈកាលដំណើរការគម្រោង .....
៨.១.៥ ការទទួលបានការយល់ព្រមជាសាធារណៈ គឺជាលទ្ធផលមួយនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ
៨.១.៦ បញ្ហាពាក់ព័ន្ធដទៃទៀត .....
៨.២ វគ្គ៨.២-យន្តការនៃការចូលរួម .....
៨.២.១ ការវិភាគរបស់ភាគីពាក់ព័ន្ធ និងផែនការចូលរួម .....
៨.២.២ បច្ចេកទេស និងឧបករណ៍នានា .....
៨.៣ វគ្គ៨.៣-បទដ្ឋាននានាសម្រាប់ស្ថាប័ន.....
៨.៣.១ អន្តរជាតិ.....
៨.៣.២ ជាតិ .....
៨.៣.៣ ស្ថាប័នក្រុមហ៊ុន .....
៨.៤ វគ្គ៨.៤-ទិដ្ឋភាព និងការពិនិត្យពិច័យផ្សេងៗ.....
៨.៤.១ ការកំណត់ពេលវេលា.....
៨.៤.២ កម្រិត និងវិសាលភាពនៃការចូលរួម.....
៨.៤.៣ ការធ្វើហិរញ្ញប្បទាន.....
៨.៤.៤ គោលការណ៍អនុវត្តល្អស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ .....
៩. ឯកសារយោងសំខាន់ៗ .....
១០. សាថតានៃកម្មវិធីកិច្ចសហប្រតិបត្តិការរបស់អង្គការ GIZ .....

តារាងគំនូសសម្គាល់

តារាងគំនូសសម្គាល់១.១ ទំនប់វារីអគ្គិសនីដែលកំពុងដំណើរការ និងស្ថិតក្នុងដែនការសាងសង់ក្នុងទន្លេមេគង្គក្រោម.....
តារាងគំនូសសម្គាល់៦.១ ប្រភេទ និង ឧទហរណ៍នៃផលប្រយោជន៍ដែលលេចចេញពីគម្រោងទំនប់វារីអគ្គិសនីខ្នាតធំ (SADC គ្មានចុះកាលបរិច្ឆេទ).....
តារាងគំនូសសម្គាល់៦.២ ការអនុវត្តជាទ្រឹស្តីបទនៃការស្វែងរកផលប្រយោជន៍នៅក្នុងកំរិតអាង និងអនុ-អាង (SADC គ្មានចុះកាលបរិច្ឆេទ).....
តារាងគំនូសសម្គាល់៨.១ ដំណើរការ និងលទ្ធផលរបស់គម្រោងបានពីការចូលរួមរបស់ភាគីពាក់ព័ន្ធ និងសហគមន៍.....

បញ្ជីតារាង

បញ្ជីតារាង៤.១ តារាងគំរូស្តីពីបទដ្ឋានជានិយាមអន្តរជាតិ ដែលគ្របដណ្តប់លើការវាយតម្លៃហេតុប៉ះពាល់សង្គម.....
បញ្ជីតារាង៤.២ តារាងគំរូស្តីពីបទដ្ឋានជានិយាមប្រទេសនីមួយៗ ដែលគ្របដណ្តប់លើការវាយតម្លៃហេតុប៉ះពាល់សង្គម.....
បញ្ជីតារាង៤.៣ ចំណាប់អារម្មណ៍ជាទូទៅស្តីពីការវាយតម្លៃហេតុប៉ះពាល់សង្គម និង រយៈកាល អនុវត្តគម្រោង.....
បញ្ជីតារាង៤.៤ គំរូឧទាហរណ៍នៃការអនុវត្ត ដែលត្រូវបានប្រើប្រាស់នៅក្នុងការវាយតម្លៃផល ប៉ះពាល់ដែលអាចកើតមាន/អត្ថប្រយោជន៍នានា.....
បញ្ជីតារាង៦.១ យន្តការមិនមែនបែងចែកផលប្រយោជន៍ជារូបិយវត្ថុ.....
បញ្ជីតារាង៦.២ ករណីសិក្សាស្តីពីយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ.....
បញ្ជីតារាង៨.១ គំរូឧទាហរណ៍នៃសំនួរជាក់លាក់ ដែលអាចតម្រូវឲ្យមានការសម្រេចចិត្តតាមដំណាក់កាលខុសៗគ្នានៃរយៈកាលអនុវត្តគម្រោង.....
បញ្ជីតារាង៨.២ ឧបករណ៍ដែលប្រើប្រាស់ជាញឹកញាប់បំផុតសម្រាប់គម្រោងធំៗ ដែលបានឡើង (ដូចជាទំនប់ និងសំណង់អាគារវារីអគ្គិសនី).....

តារាងប្រអប់អត្ថបទ

(អ្នករៀបរៀងគួរពិនិត្យឡើងវិញ ស្របតាមទៅតាមទំព័រជាក់ស្តែង)

តារាងប្រអប់អត្ថបទ៣.១ បញ្ហាគន្លឹះត្រូវដោះស្រាយតាមរយៈឯកសារ (Compendium) .....

តារាងប្រអប់អត្ថបទ៣.២ គោលការណ៍ពិធីសារស្តីពីការវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី.....

តារាងប្រអប់អត្ថបទ៣.៣ សាវតា-ទិដ្ឋភាពគន្លឹះ .....

តារាងប្រអប់អត្ថបទ៤.១ ការគ្រប់គ្រងបរិស្ថានចម្រុះ .....

តារាងប្រអប់អត្ថបទ៤.២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន .....

តារាងប្រអប់អត្ថបទ៤.៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចជួយដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត ភ្នាក់ងារ ឬ អ្នកធ្វើសំណើគម្រោង .....

តារាងប្រអប់អត្ថបទ៤.៤ សេចក្តីផ្តើម-ទិដ្ឋភាពគន្លឹះ.....

តារាងប្រអប់អត្ថបទ៤.៥ បទដ្ឋានជានិយាម-ទិដ្ឋភាពគន្លឹះ .....

តារាងប្រអប់អត្ថបទ៤.៦ ការវាយតម្លៃហេតុប៉ះពាល់សង្គម និងរយៈកាលអនុវត្តគម្រោង-ទិដ្ឋភាពគន្លឹះ .....

តារាងប្រអប់អត្ថបទ៤.៧ គម្រោងការពារជំនន់នៅអាងទន្លេអូដ្រា នៅប្រទេសប៉ូឡូញ.....

តារាងប្រអប់អត្ថបទ៤.៨ ដំណើរការនៃការចូលរួមជាសាធារណៈ ក្នុងប្រទេសឡាវ.....

តារាងប្រអប់អត្ថបទ៤.៩ នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ កិច្ចពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងជាមុន (PNPCA).....

តារាងប្រអប់អត្ថបទ៤.១០ ប្រព័ន្ធត្រួតពិនិត្យទូលំទូលាយលើការតាំងទីលំនៅថ្មី ក្នុងប្រទេសចិន .....

តារាងប្រអប់អត្ថបទ៤.១១ គម្រោងអភិវឌ្ឍន៍ធនធានទឹកទន្លេអូលីហ្វង់ នៅអាហ្វ្រិកខាងត្បូង.....

តារាងប្រអប់អត្ថបទ៤.១២ គម្រោងវារីអគ្គិសនីប៊ុមបុណា នៅសេរ៉ាឡេអូន .....

តារាងប្រអប់អត្ថបទ៤.១៣ ទំនប់វារីអគ្គិសនីដ្រាយកូពីស នៅអាហ្វ្រិកខាងត្បូង.....

តារាងប្រអប់អត្ថបទ៤.១៤ ទំនប់វារីអគ្គិសនីកាន់ដាដជី នៅប្រទេសនីហ្សេរីយ៉ា.....

តារាងប្រអប់អត្ថបទ៤.១៥ គម្រោងទឹកធុកិឡា នៅអាហ្វ្រិកខាងត្បូង.....

តារាងប្រអប់អត្ថបទ៤.១៦ គម្រោងទំនប់វារីអគ្គិសនីណាំធឿន២ ក្នុងប្រទេសឡាវ.....

តារាងប្រអប់អត្ថបទ៤.១៧ គម្រោងទំនប់វារីអគ្គិសនីទុយយៀនហ្គាំង និង ការការពារទឹកជំនន់ នៅប្រទេសវៀតណាម .....

តារាងប្រអប់អត្ថបទ៤.១៨ គម្រោង Brilliant Expansion នៅប្រទេសកាណាដា .....

តារាងប្រអប់អត្ថបទ៤.១៩ នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់សង្គម-ទិដ្ឋភាពគន្លឹះ .....

តារាងប្រអប់អត្ថបទ៤.២០ ករណីសិក្សានៅប្រទេសឡាវ ៖ ទំហំ និងផលប៉ះពាល់ដែលត្រូវការផែនការតាំងទីលំនៅថ្មី.....

តារាងប្រអប់អត្ថបទ៤.១៨ គម្រោងស្តុកវារីអគ្គិសនីសេតិ នៅប្រទេសនេប៉ាល់

តារាងប្រអប់អត្ថបទ៥.១ គោលនយោបាយជាសង្ខេបរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មី.....
តារាងប្រអប់អត្ថបទ៥.២ សេចក្តីផ្តើម និងបទដ្ឋានជានិយាម-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៥.៣ ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី សម្រាប់គម្រោងថាមពលវារីអគ្គិសនី ណាំ ញ៉ុំ២ ក្នុងប្រទេសឡាវ.....
តារាងប្រអប់អត្ថបទ៥.៤ ការជំរឿនរយៈពេលឆាប់-ដំណោះស្រាយទៅលើអ្នកឆក់ឱកាស ក្នុងការតាំងទីលំនៅ.....
តារាងប្រអប់អត្ថបទ៥.៥ ការតម្រូវឲ្យមានជាចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី-ទិដ្ឋភាពគន្លឹះ .....
តារាងប្រអប់អត្ថបទ៥.៦ ការទូទាត់សំណងជាដី និងដី.....
តារាងប្រអប់អត្ថបទ៥.៧ ករណីសិក្សាលើទំនប់វារីអគ្គិសនីចំនួន២ គឺទំនប់ស៊ុយគូ និង ទំនប់យ៉ាន់តាន់ ការតាំងទីលំនៅ និងការស្តារប្រាក់ចំណូលបានល្អប្រសើរ ក្នុងប្រទេសចិន.....
តារាងប្រអប់អត្ថបទ៥.៦ គំរូឧទាហរណ៍នៃយន្តការសាទុក្ខ-គម្រោងឧស្ម័នធម្មជាតិសាសុល នៅប្រទេសមូសាំប៊ិក.....
តារាងប្រអប់អត្ថបទ៥.៧ ការតាំងទីលំនៅដែលមានការផ្លាស់ប្តូរ-ការអនុវត្តល្អពីខេត្តយុនណាន ក្នុងប្រទេស ចិន .....
តារាងប្រអប់អត្ថបទ៥.៨ ធាតុសំខាន់ៗនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ក្នុងប្រទេសចិន.....
តារាងប្រអប់អត្ថបទ៥.៩ ធាតុសំខាន់ៗនៃផែនការសកម្មភាព ស្តីពីការតាំងទីលំនៅថ្មីក្នុងប្រទេសឡាវ.....
តារាងប្រអប់អត្ថបទ៥.១០ ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៥.១១ ប្រទេសចិនចាត់ទុកការតាំងទីលំនៅថ្មី ជាឱកាសសម្រាប់ការការអភិវឌ្ឍ..
តារាងប្រអប់អត្ថបទ៥.២ គម្រោងឧស្ម័នធម្មជាតិ សាសុល នៅប្រទេសមូសាំប៊ិក.....
តារាងប្រអប់អត្ថបទ៥.៨ ការអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៦.១ សាវតា និងបទដ្ឋានជានិយាម-ទិដ្ឋភាពគន្លឹះ .....
តារាងប្រអប់អត្ថបទ៦.២ គោលការណ៍ទាក់ទងនឹងគោលនយោបាយ ស្តីពីការទូទាត់សំណង-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៦.៣ យន្តការចម្បងជាគោលការណ៍ស្តីពីការទូទាត់សំណង សម្រាប់ការតាំងទី-លំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត .....
តារាងប្រអប់អត្ថបទ៦.៤ ប្រភេទនៃយន្តការទូទាត់សំណង-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៦.៥ ទំនប់វារីអគ្គិសនីសលតូកាស៊ីយ៉ាស ក្នុងប្រទេសប្រេស៊ីល.....
តារាងប្រអប់អត្ថបទ៦.៦ ស្ថានីយ៍បង្កើតថាមពលអគ្គិសនី ឡាហ្វក១ ក្នុងប្រទេសកាណាដា.....

តារាងប្រអប់អត្ថបទ៦.៧ ទំនប់វារីអគ្គិសនីស៊ុយគូ ក្នុងប្រទេសចិន.....
តារាងប្រអប់អត្ថបទ៦.៨ ទំនប់វារីអគ្គិសនីម៉ាគុយហ្គា ក្នុងប្រទេសស្វាស៊ីឡេន.....
តារាងប្រអប់អត្ថបទ៦.៩ យន្តការមិនមែនបែងចែកផលប្រយោជន៍ជារូបិយវត្ថុ-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៦.១០ ការតាក់តែងច្បាប់របស់ប្រទេសន័រវេ ទាក់ទងនឹងការយកពន្ធដារ និងតម្លៃចេញ អាជ្ញាប័ណ្ណ .....
តារាងប្រអប់អត្ថបទ៦.១១ ការតាក់តែងច្បាប់របស់ប្រទេសចិនស្តីពីក្រោយការតាំងទីលំនៅថ្មី និងមូលនិធិស្តារឡើងវិញ .....
តារាងប្រអប់អត្ថបទ៦.១២ គម្រោងថាមពលអគ្គិសនីមីណាសទុក ៖ យុទ្ធសាស្ត្រភាពជាដៃគូខាងវារីអគ្គិសនីជាមួយសហគមន៍ជនជាតិដើមនៃប្រទេសកេបិក .....
តារាងប្រអប់អត្ថបទ៦.១៣ យន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៦.១៤ ប្រាក់ឈ្នួលសេដ្ឋកិច្ច និងការដាក់កំហិតហិរញ្ញវត្ថុ-ទិដ្ឋភាពគន្លឹះ .....
តារាងប្រអប់អត្ថបទ៦.១៥ មូលនិធិសម្រាប់អាងទន្លេកូឡំប៊ី នៅប្រទេសកាណាដា.....
តារាងប្រអប់អត្ថបទ៦.១៦ ប្រសិទ្ធភាព ការចូលរួម និងគណនេយ្យភាព.....
តារាងប្រអប់អត្ថបទ៧.១ មូលនិធិសម្រាប់ដោះស្រាយយ៉ាងទូលំទូលាយ នៅប្រទេសន័រវេ.....
តារាងប្រអប់អត្ថបទ៧.២ មូលនិធិទ្រទ្រង់ដំណាក់កាលបន្ទាប់ សម្រាប់គម្រោងអភិរក្សថាមពលវារីអគ្គិសនី និងទឹក នៅសាធារណរដ្ឋប្រជាមានិកចិន.....
តារាងប្រអប់អត្ថបទ៧.៣ សេចក្តីផ្តើមស្តីពីការលើកឡើងអំពីបញ្ហាសង្គម ដែលមិនទាន់បានដោះស្រាយ-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៧.៤ ទំនប់អគ្គិសនីប៉ាកមុន នៅប្រទេសថៃ.....
តារាងប្រអប់អត្ថបទ៧.៥ របៀបដោះស្រាយបញ្ហាសង្គម ដែលមិនទាន់បានដោះស្រាយ-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៨.១ គម្រោងអាក្វា នៅប្រទេសញូហ្សីឡែន.....
តារាងប្រអប់អត្ថបទ៨.២ ការកសាងសមត្ថភាព .....
តារាងប្រអប់អត្ថបទ៨.៣ ការចូលរួមរបស់ប្រជាសហគមន៍មូលដ្ឋាន.....
តារាងប្រអប់អត្ថបទ៨.៤ សាវតា និយមន័យ និងទស្សនៈគន្លឹះ-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៨.៥ យន្តការនៃការចូលរួម-ទិដ្ឋភាពគន្លឹះ.....
តារាងប្រអប់អត្ថបទ៨.៦ បទដ្ឋាននានាសម្រាប់ស្តាប័ន-ទិដ្ឋភាពគន្លឹះ .....
តារាងប្រអប់អត្ថបទ៨.៧ ទិដ្ឋភាព និងចំណាប់អារម្មណ៍ផ្សេងៗ-ទិដ្ឋភាពគន្លឹះ.....

ពាក្យបំពួញ និងអក្សរកាត់

ACRP	ផែនការធ្វើសម្បទាន ទូទាត់សំណង និងស្តារឡើងវិញ (ប្រទេសនេប៉ាល់)
ADB	ធនាគារអភិវឌ្ឍន៍អាស៊ី
BP	នីតិក្រមធនាគារ (ធនាគារពិភពលោក)
CCAI	គម្រោងផ្តួចផ្តើមគំនិតស្តីពីបម្រែបម្រួលអាកាសធាតុ និងការបន្សុំ
COPEL	ក្រុមហ៊ុនគ្រប់គ្រងថាមពល Paranaense (ប្រទេសប្រេស៊ីល)
CSR	មូលនិធិរួមចំណែកកសង្គម
DAC	គណៈកម្មការផ្តល់ជំនួយផ្នែកអភិវឌ្ឍន៍
DAD	សម្រេចចិត្ត ប្រកាស ការពារ
DDP	គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍន៍
ECSHD	គំនិតផ្តួចផ្តើមស្តីពីការគិតគូរលើបរិស្ថានសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនី ប្រកបដោយចីរភាព
EGAT	អាជ្ញាធរអគ្គិសនីប្រទេសថៃ
EHS	សុខមាលភាព និងសុវត្ថិភាពផ្នែកបរិស្ថាន
EAI	ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
EIAR	របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
EP	គោលការណ៍អេក្វាទ័រ
EPFI	វិទ្យាស្ថានគោលការណ៍ហិរញ្ញវត្ថុអេក្វាទ័រ
ERC	គណៈកម្មការទទួលបន្ទុកការតាំងទីលំនៅថ្មី Ekuvinjelweni (ប្រទេសស្វាស៊ីឡេន)
ESMF	បទដ្ឋាននៃការគ្រប់គ្រងបរិស្ថាន និងសង្គម
FAO	អង្គការស្បៀងអាហារ និងកសិកម្ម
FPEPB	មន្ទីរថាមពលអគ្គិសនីខេត្តហ្វូយជៀន (ប្រទេសចិន)
GIZ	អង្គការសហប្រតិបត្តិការអន្តរជាតិ (ប្រទេសអាឡឺម៉ង់)
GLRB	អាងទន្លេក្លូមម៉ា និងឡាហ្គិន (នរវេ)
IAP2	សមាគមអន្តរជាតិស្តីពីការចូលរួមជាសាធារណៈ
IEM	ការគ្រប់គ្រងបរិស្ថានចម្រុះ
IFC	ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
IHA	សមាគមថាមពលអគ្គិសនីអន្តរជាតិ
ISH	គម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលអគ្គិសនី ប្រកបដោយនិរន្តរភាព
IPDP	ផែនការអភិវឌ្ឍន៍ជនជាតិដើម
IUCN	សម្ព័ន្ធអន្តរជាតិដើម្បីកិច្ចអភិរក្សធម្មជាតិ

IWRD	ការអភិវឌ្ឍន៍ធនធានទឹកចម្រុះ
JBEC	ក្រុមហ៊ុនថាមពល ចេមស្សបេ (ប្រទេសកាណាដា)
JBNQA	កិច្ចព្រមព្រៀង ចេមស្សបេ និងកេបិកភាគខាងជើង
KOBWA	អាជ្ញាធរអាងទឹកភូម៉ាទី (អាហ្វ្រិកខាងត្បូង និងស្វាស៊ីឡែន)
LMB	អាងទន្លេមេគង្គក្រោម
LSSF	មូលនិធិគាំទ្រជំហានបន្ទាប់
MDG	គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍
MRC	គណៈកម្មការទន្លេមេគង្គ
MSP	វេទិកាពហុភាគីពាក់ព័ន្ធ
NAPA	កម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សុំ (កម្ពុជា ឡាវ)
NEMA	ច្បាប់ស្តីពីការគ្រប់គ្រងបរិស្ថានជាតិ ឆ្នាំ១៩៩៨ (អាហ្វ្រិកខាងត្បូង)
NEPA	ច្បាប់ស្តីពីគោលនយោបាយបរិស្ថានជាតិ (សហរដ្ឋអាមេរិក)
NET	ក្រុមអ្នកជំនាញការជាតិ (ថៃ កម្ពុជា ឡាវ និងវៀតណាម)
NGO	អង្គការមិនមែនរដ្ឋាភិបាល
NHPC	ក្រុមហ៊ុនថាមពលវារីអគ្គិសនីជាតិ (ឥណ្ឌា)
NTP	ផែនការគោលដៅជាតិ (វៀតណាម)
NSHD-M	បណ្តាញដើម្បីអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីប្រកបដោយចីរភាពនៃប្រទេសតាមដងទន្លេមេគង្គ
OECD	អង្គការដើម្បីសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច
OP	នីតិក្រមប្រតិបត្តិការ (ធនាគារពិភពលោក)
PALA	វិធីសាស្ត្រនៃការសិក្សារបស់យុវវ័យដោយមានការចូលរួម
PEI	គម្រោងគំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រ និងបរិស្ថាន (អង្គការសហប្រជាជាតិ)
RAP	ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី
RSAT	ឧបករណ៍វាយតម្លៃឆាប់រហ័សស្តីពីនិរន្តរភាពថាមពលអគ្គិសនីអាងទន្លេធំ
RSR	របាយការណ៍សរុបក្នុងតំបន់
SDG	គោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព
SE4ALL	ថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា
SEA	ការវាយតម្លៃជាយុទ្ធសាស្ត្រស្តីពីបរិស្ថាន និងសង្គម
SIA	ការវាយតម្លៃហេតុប៉ះពាល់សង្គម
UN	អង្គការសហប្រជាជាតិ
UNCED	សន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ
UNCHR	គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស
UNCHS	គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិលំនៅដ្ឋាន

UNDP	កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
UNEP	គម្រោងកម្មវិធីសហប្រជាជាតិ ស្តីពីបរិស្ថាន
UNFCCC	អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
USA	សហរដ្ឋអាមេរិក
WCD	គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី
WCED	គណៈកម្មការពិភពលោកទទួលបន្ទុកបរិស្ថាន និងការអភិវឌ្ឍន៍
WSSD	កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព

១. ចរនាសម្ព័ន្ធនៃសៀវភៅបណ្តុះបណ្តាល និងឯកសារដែលជាប្រភពសំខាន់

១.១- រចនាសម្ព័ន្ធ

សៀវភៅបណ្តុះបណ្តាលនេះចែកចេញជា៨ផ្នែក ៖

- ផ្នែកទី១ សាវតា និងបរិបទ
- ផ្នែកទី២ រចនាសម្ព័ន្ធនៃសៀវភៅបណ្តុះបណ្តាល
- ផ្នែកទី៣ វគ្គ១-សេចក្តីផ្តើមស្តីពីកិច្ចពិភាក្សាទៅលើទំនប់ខ្នាតធំ និងសំណង់អាគារវារីអគ្គិសនី
- ផ្នែកទី៤ វគ្គ២-ការវាយតម្លៃហេតុប៉ះពាល់សង្គម
- ផ្នែកទី៥ វគ្គ៣-ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត
- ផ្នែកទី៦ វគ្គ៤-គោលការណ៍ទូទាត់សំណង និងការបែងចែកផលប្រយោជន៍
- ផ្នែកទី៧ វគ្គ៥-បញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ
- ផ្នែកទី៨ វគ្គ៦-ការចូលរួមរបស់ភាគីពាក់ព័ន្ធ

នៅក្នុងវគ្គនីមួយៗ សម្ភារៈសិក្សាត្រូវបែងចែកជាវគ្គៗនៅពេលធ្វើការបណ្តុះបណ្តាលលើប្រធាន-បទខុសៗគ្នា ។ ទស្សនៈនានានៃវគ្គបណ្តុះបណ្តាល អាចបរិយាយយ៉ាងលម្អិតដោយការទាញយកបទពិសោធន៍ល្អៗ ពីករណីសិក្សាមួយចំនួននៅជុំវិញពិភពលោក ។ អ្នកអាន និង អ្នកប្រើប្រាស់សៀវភៅបណ្តុះ-បណ្តាលនេះ ចាំបាច់ត្រូវកត់ចំណាំឲ្យបានច្បាស់ថា វគ្គបណ្តុះបណ្តាលចំនួន ៥វគ្គ ដែលនិយាយអំពីដំណោះ-ស្រាយទាក់ទងនឹងទិដ្ឋភាព សង្គម មានការជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក ជាមួយនឹងសម្ភារៈជាច្រើន ដែលត្រូវប្រើប្រាស់រួមនៅក្នុងវគ្គបណ្តុះបណ្តាលលើសពីមួយ ។ ជាការពិត ប្រធានបទមួយ ដូចជាការចូលរួម (ជាសាធារណៈ) របស់ភាគីពាក់-ព័ន្ធ គឺមានជាប់ពាក់ព័ន្ធក្នុងវង្វង់ប្រធានបទ៤ផ្សេងទៀត ។ ដូច្នេះ ថ្វីបើហាក់មានការប្រើប្រាស់សម្ភារៈដដែលៗក៏ពិតមែន តែប្រការនេះជាការធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីធ្វើឲ្យវគ្គបណ្តុះបណ្តាលនីមួយៗមានតែវគ្គសិក្សា ចំនួនមួយ។

១.២ សម្ភារៈដែលជាប្រភពចាំបាច់

របាយការណ៍ខាងក្រោមនេះ គឺជាប្រភពព័ត៌មានសំខាន់សម្រាប់សម្ភារៈ ដែលបានបង្ហាញនៅក្នុងសៀវភៅបណ្តុះបណ្តាលនេះ ៖

Égré, D (2006). គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន-គម្រោងទន់ប់វារីអគ្គិសនី និង ការអភិវឌ្ឍ។ ឯកសារស្តីពីការអនុវត្តសមស្រប។ បញ្ហានៃការបែងចែងផលប្រយោជន៍។

Heinsohn, R-D (2007). គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP)- គម្រោងទន់ប់វារីអគ្គិសនី និង ការអភិវឌ្ឍ ។ ឯកសារស្តីពីការអនុវត្តសមស្រប។ ប្រជាពលរដ្ឋ ដែលទទួលរងហេតុប៉ះពាល់សង្គម ។ សមាគមអន្តរជាតិទទួលបន្ទុកការចូលរួមជាសាធារណៈ (២០០៧) ។ គម្រោងកម្មវិធីសហប្រជា-ជាតិស្តីពីបរិស្ថាន-គម្រោងទន់ប់វារីអគ្គិសនី និងការអភិវឌ្ឍ។ យន្តការស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ (Eds. V. Twyford and C. Bladwin)។

ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC 2002). សៀវភៅតូចស្តីពីការរៀបចំផែនការសកម្មភាព នៃការតាំងទីលំនៅថ្មី ។ IFC ៖ ក្រសួងអភិវឌ្ឍបរិស្ថាន និង សង្គម ។ ក្រុមការងារធនាគារពិភពលោក នាទីក្រុងវ៉ា-ស៊ីនតោន សហរដ្ឋអាមេរិក។

ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) គំរូស្តង់ដារអនុវត្តការងារស្តីពីនិរន្តរភាពផ្នែកបរិស្ថាន និងសង្គម (ខែកញ្ញា ឆ្នាំ២០១២) ៖ គំរូស្តង់ដារអនុវត្តការងារ៥ ៖ ការទទួលបានដីធ្លី និងការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)។

Roquet, V. (2006). គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP)-គម្រោងទន់ភ្លាវារីអគ្គិសនី និងការអភិវឌ្ឍ។ ឯកសារស្តីពីការអនុវត្តសមស្រប។ បញ្ហាទាក់ទងនឹងគោលនយោបាយស្តីពីការទូទាត់សំណង។

Schmidt-Soltau, K. (2006) គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP)- គម្រោងទន់ភ្លាវារីអគ្គិសនី និងការអភិវឌ្ឍ។ ឯកសារស្តីពីការអនុវត្តសមស្រប។ ដំណោះស្រាយលើបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ ។

Tapela, B.N., Matete, M.E. and Heinsohn R-D សៀវភៅបណ្តុះបណ្តាលស្តីពីទិដ្ឋភាពសម្រិតសម្រាំង ផ្នែកសេដ្ឋកិច្ច និងសង្គមនៃហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតធំ កម្មវិធីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតធំ ប្រកបដោយចីរភាព នៅភាគខាងកើត និងភាគខាងត្បូងទ្វីបអាហ្វ្រិក។ SADC, EAC, UNEP, InWest. (2009) ។

ធនាគារពិភពលោក (២០០៤)។ សៀវភៅប្រភពស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ។ ការរៀបចំផែនការ និងការអនុវត្តគម្រោងអភិវឌ្ឍន៍។ ធនាគារពិភពលោក នាទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអា-មេរិក។

គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007) ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ ការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរ ។ ឯកសារស្តីពីការអនុវត្តសមស្រប លើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន។ www.unep.org/dams។

២. សាខតា និងបរិបទ

២.១ កិច្ចប្រជុំកំពូលស្តីពីផែនដី និងគោលដៅអភិវឌ្ឍន៍ផែនដី

២.១.១ កិច្ចក្រជុំកំពូលស្តីពីផែនដីរីយ៉ូ (Rio Earth Summit)

ប្រទេសប្រេស៊ីលបានរៀបចំឲ្យមានសន្និសីទសហប្រជាជាតិស្តីអំពីបរិស្ថាន និង ការអភិវឌ្ឍ (UNCED) នាទីក្រុងរីយ៉ូដឺចាណៃរ៉ូ (Rio de Janeiro) នាឆ្នាំ១៩៩២។ កិច្ចពិភាក្សានៅក្នុងមហាសន្និបាតនោះ ផ្តោតទៅលើការស្វែងរកលទ្ធភាពនៃដំណោះស្រាយទៅលើបញ្ហា ដែលជាសារៈសំខាន់របស់ពិភពលោក ដូចជា ៖ ភាពក្រីក្រ សង្គ្រាម គម្លាតដ៏ធំធេងរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ចំនុចគន្លឹះដែលបានលើកឡើង គឺការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលសង្កត់ធ្ងន់ទៅលើការពឹងអាស្រ័យយ៉ាងធ្ងន់ធ្ងរ ចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដោយពឹងផ្អែកលើកិច្ចអភិរក្សធនធានធម្មជាតិ បូករួមទាំងវិធីសាស្ត្រ និង នីតិវិធីប្រកបដោយប្រសិទ្ធភាព ដើម្បីជៀសវាងការបំផ្លិចបំផ្លាញបរិស្ថាន។ កិច្ចប្រជុំកំពូលស្តីពីផែនដីរីយ៉ូកាលពីឆ្នាំ១៩៩២ បានបន្សល់ទុកនូវសេចក្តីថ្លែងការណ៍រីយ៉ូ ដែលក្នុងសេចក្តីថ្លែងការណ៍នោះបានកំណត់គោលការណ៍ចំនួន ២៧ ចំនុច សំដៅផ្សារភ្ជាប់រដ្ឋាភិបាលនៃប្រទេសនានា ដែលបានចូលរួមទៅនឹងតម្រូវការនៃការការពារបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវ ។ នៅក្នុងកិច្ចប្រជុំកំពូលស្តីពីផែនដីរីយ៉ូនោះ របៀបវារៈ២១ និងមូលដ្ឋានគ្រឹះសម្រាប់និរន្តរភាព និងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក៏ត្រូវបានបង្កើតឡើងចាប់តាំងពីពេលនោះមកផងដែរ ។

២.១.២ កិច្ចប្រជុំរីយ៉ូបូក១០ (Rio+10)

កិច្ចប្រជុំកំពូលចូហាន់ណេសប៊ឺក (Johannesburg) ត្រូវបានរៀបចំឡើងនាឆ្នាំ២០០២ ក្នុងគោលបំណងវាយតម្លៃការវិវត្តន៍រីកចម្រើនក្នុងក្របខ័ណ្ឌនៃការអនុវត្ត ដែលបានពីលទ្ធផលនៃកិច្ចប្រជុំកំពូលស្តីពីផែនដី ព្រមទាំងបានបង្ហាញពីបញ្ហាប្រឈមថ្មីៗ ដែលបានជួបប្រទះចាប់តាំងពីឆ្នាំ១៩៩២។ ទិដ្ឋភាពមួយដែលមិនបានលើកឡើងនាកិច្ចប្រជុំនេះ គឺការកើនឡើងនៃចំនួនប្រជាជន និង អលទ្ធភាពរបស់ផែនដីក្នុងការធានាកំណើនប្រជាជនដែលចេះតែបន្តកើនឡើងជាលំដាប់។

ប្រជាជននៃប្រទេសទន្លេមេគង្គក្រោម (កម្ពុជា ឡាវ ថៃ និងវៀតណាម) ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៧៧លាននាក់ នៅក្នុងឆ្នាំ២០១០ ហើយរំពឹងថានឹងកើនឡើងចំនួន២០៦លាននាក់ត្រឹមឆ្នាំ ២០៥០ (ប្រភព UN 2010, WDI 2013) ។ ប្រជាជនរស់នៅតាមអាងទន្លេមេគង្គក្រោម ត្រូវបានប៉ាន់ប្រមាណថាមានចំនួនប្រហែល ៦៥លាននាក់ នៅឆ្នាំ២០១០ ក្នុងនោះ៨០% រស់នៅតំបន់ទីជនបទដោយពឹងអាស្រ័យលើការប្រកបរបរកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ។ ប្រជាជននៅក្នុងប្រទេសតាមដងទន្លេមេគង្គក្រោម មានចំនួនកើនឡើង ១.១% នៅទសវត្សរ៍ចុងក្រោយនេះ ។ ត្រឹមឆ្នាំ២០៥០ ចំនួនប្រជាជនរស់នៅតាមអាងទន្លេមេគង្គក្រោម អាចនឹងកើនឡើងប្រមាណជា ៧៦លាននាក់ (ប្រភព WDI 2013)។



គំនូសសម្គាល់ ១១ ៖ ចំនួនប្រជាជនពីមុន និងវាំងទុកនៅប្រទេសអាងទន្លេមេគង្គក្រោមឆ្នាំ១៩៥០ ដល់ឆ្នាំ២១០០ (ការប្រែប្រួលជាមធ្យម) ប្រភព ៖ WDI 2013, UN 2010 ដោយយោងតាម Sawdon *et al.* (ឆ្នាំ២០១៣)

២.១.៣ កិច្ចប្រជុំរីយ៉ូប្លូក២០ (Rio+20)

នាឆ្នាំ២០១២ កិច្ចប្រជុំកំពូលស្តីពីផែនដី ត្រូវបានរៀបចំម្តងទៀតនាទីក្រុងរីយ៉ូដឺចាណៃរ៉ូ (Rio de Janeiro) ដែលនៅក្នុងកិច្ចប្រជុំនោះ ទស្សន:ស្តីពីនិរន្តរភាពត្រូវបានលើកឡើង និងយកមកពិភាក្សា។ សសរស្តម្ភចំនួន ៣ ត្រូវបានដាក់បញ្ចូលគ្នាជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមានដូចជា ៖ ការពង្រឹង ការធ្វើកំណែទម្រង់ និងការធ្វើសមាហរណកម្ម ។ បញ្ហាស្តីពីការផ្តត់ផ្តង់ថាមពល ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ដោយមានការចូលរួមពីប្រទេសជាសមាជិក ក្នុងគោលបំណងបង្កើតឲ្យមានគម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា ដែលបានផ្តួចផ្តើមដោយអគ្គលេខាធិការនៃអង្គការសហ-ប្រជាជាតិ។ គម្រោងផ្តួចផ្តើមគំនិតនេះ មានគោលបំណងជាច្រើន ដែលរួមមានការផ្តល់ឲ្យពិភពលោកទទួលបាននូវសេវាថាមពលទំនើបជាមូលដ្ឋាន និង នៅក្នុងកម្រិតធ្ងន់ថ្លៃបំផុតសម្រាប់គោលដៅប្រើប្រាស់ និងផលិតត្រឹមឆ្នាំ២០៣០ ក៏ដូចជាជម្រុញឲ្យមានការអភិវឌ្ឍន៍ និងការប្រើ-ប្រាស់ប្រភពថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យានានានៅក្នុងប្រទេសនីមួយៗ ។

នៅអំឡុងឆ្នាំ២០១២ ដែលជាឆ្នាំអន្តរជាតិស្តីពីថាមពលប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា (SE4ALL) អគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតគម្រោងផ្តួចផ្តើមគំនិត (SE4ALL) នេះឡើង និងបានរាយការណ៍ដូច្នេះថា ៖

- គោលដៅសហស្សវត្សរ៍អាចសម្រេចជោគជ័យទៅបាន អាស្រ័យលើការទទួលបាននូវសេវាថាមពលទំនើប។
- ការដែលមានសេវាថាមពលគ្រប់គ្រាន់ ដែលងាយស្រួលរកបាន និង អាចជឿជាក់បាន គឺជាកត្តាសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ ធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពរបស់មនុស្ស បង្កើនកម្រិតជីវភាព និងអាចធ្វើឲ្យការអភិវឌ្ឍប្រកបដោយចីរភាព អាចសម្រេច

ដល់គោលដៅនៅទីបំផុត។ សេវាថាមពលប្រកបដោយចីរភាពគ្រប់គ្រាន់ គឺជាមធ្យោបាយក្នុងការផ្តល់ដល់មនុស្សនូវសុខភាព ការអប់រំ ការដឹកជញ្ជូន ទូរគមនាគមន៍ ទឹកស្អាត និងអនាម័យ។

- ការសម្រេចគោលដៅថាមពលប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា ត្រូវជាប់ពាក់ព័ន្ធជាមួយការបង្កើតឲ្យមានប្រព័ន្ធនានា ដែលគាំទ្រដល់ការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវប្រភពថាមពលផ្សេងៗ ក្នុងលក្ខណៈសមភាព និងរួមគ្នា ស្របពេលជាមួយការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ហេដ្ឋារចនាសម្ព័ន្ធចម្រុះថ្នាក់ជាតិ និងតំបន់ ទាក់ទងនឹងការផ្គត់ផ្គង់ថាមពល ការបញ្ជូនថាមពល ប្រកបដោយប្រសិទ្ធភាព ប្រព័ន្ធចែកចាយ និងការរៀបចំកម្ម-វិធីតាមតម្រូវការ ដែលបញ្ជាក់អំពីប្រសិទ្ធភាពនៃថាមពល សុទ្ធសឹងជាការចាំបាច់សម្រាប់ប្រព័ន្ធថាមពល ប្រកបដោយចីរភាព។

២.១.៤ គោលដៅអភិវឌ្ឍន៍ផែនដី

មេដឹកដឹកនាំរបស់ប្រទេសនានាលើពិភពលោក បានមកជួបប្រជុំគ្នានៅទីស្នាក់ការអង្គការសហប្រជាជាតិ នាទីក្រុងញូយ៉កក្នុងឆ្នាំ២០០០ ក្នុងគោលបំណងអនុម័តសេចក្តីថ្លែងការណ៍សហស្សវត្សរ៍សហប្រជាជាតិ ។ ប្រទេសទាំងនេះបានប្តេជ្ញាចិត្តចំពោះភាពជាដៃគូពិភពលោកថ្មីមួយ ប្រយោជន៍ដើម្បីកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រដែលមាននៅលើជញ្ជើងពិភពលោក និង ដើម្បីបង្ហាញពីការកំណត់ពេលវេលាមួយ (កាលបរិច្ឆេទចុងក្រោយនៃឆ្នាំ២០១៥) ដើម្បីឆ្លើយតបចំពោះគោលដៅដែលបានកំណត់ទុកជាមុន ដែលគេហៅថា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចំនួន ៨ ត្រូវបានកំណត់ក្នុងបញ្ជីតារាង ដែលក្នុងនោះគោលដៅទី៧ សំដៅលើការធានានិរន្តរភាពបរិស្ថាន។ ក្នុងគោលដៅនេះគឺជាដាក់បញ្ចូលគោលការណ៍ នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាពទៅក្នុងគោលនយោបាយ និងនីតិវិធីរបស់ប្រទេសនានា ព្រមទាំងភាពអាចត្រឡប់វិញបាននៃការបាត់បង់ធនធានធម្មជាតិ។

គោលដៅសហស្សវត្សរ៍ចំនុច៧ ៖ ការអភិវឌ្ឍប្រកបដោយចីរភាព មានន័យថាជាការដាក់បញ្ចូលគ្នារវាងកត្តាសង្គម សេដ្ឋកិច្ច និងបរិស្ថាន ទៅក្នុងការរៀបចំផែនការ ការអនុវត្ត និងការសម្រេចចិត្ត ដើម្បីធានាឲ្យប្រាកដថា ការអភិវឌ្ឍនោះពិតជាបម្រើផលប្រយោជន៍ដល់មនុស្សនៅសម័យកាលបច្ចុប្បន្ន និងទៅអនាគត។

ការអភិវឌ្ឍប្រកបដោយចីរភាព មានគោលដៅធ្វើឲ្យមានសមភាពក្នុងរង្វង់ និងចន្លោះពីជំនាន់មួយទៅជំនាន់មួយ និង អនុវត្តតាមវិធីសាស្ត្រ ដែលបានគិតគូរពិចារណាក្នុងបែបបទយ៉ាងល្អិតល្អន់ចំពោះទិដ្ឋភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ តម្លៃនៃការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវឈរលើគោលការណ៍ស្មើភាពគ្នា យុត្តិធម៌ សន្តិភាព សុវត្ថិភាព និងសន្តិសុខ ដើម្បីសុឆន្ទៈ និងផលប្រយោជន៍រួមសម្រាប់ជីវិតគ្រប់ប្រភេទនៅលើភពផែនដីនេះ។

២.២- ថាមពលអគ្គិសនីនៅអាងទន្លេមេគង្គក្រោម

ទន្លេមេគង្គក្រោម គ្របដណ្តប់លើផ្ទៃក្រឡាប្រវែងប្រហែល៦០៦០០០គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ថាមពលអគ្គិសនី គឺជាវិស័យដ៏មានសារៈសំខាន់នៅអាងទន្លេមេគង្គ-ក្រោម ដែលប្រទេសមានសិទ្ធិប្រើប្រាស់ មានបំណងឆ្លើយតបចំពោះតម្រូវការសម្រាប់ថាមពល និងផ្តល់ជាជម្រើសសម្រាប់ហ្វូស៊ីលឥន្ធនៈ (សញ្ញាណដ៏មានសារៈសំខាន់ជាប់ទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព)។ ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម គឺជាប្រទេសសមាជិកនៃគណៈកម្មការទន្លេមេគង្គ ដែលមានគោលដៅប្រើប្រាស់សក្តានុពលនៃថាមពលអគ្គិសនី ដើម្បីជួយជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងសុខមាលភាពនៅក្នុងតំបន់ ។ គម្រោងវារីអគ្គិសនីជាច្រើនកំពុងដំណើរការ និងត្រូវបានស្នើឡើងនៅតាមខ្សែទឹកទន្លេមេគង្គក្រោម (គំនូសសម្គាល់១.១) ខណៈដែលមានការគ្រោងទុកជាមុនថានឹងមានការអភិវឌ្ឍន៍វារីអគ្គិសនីជាបន្ថែមទៀត នៅក្នុងចំណុះអាងទន្លេមេគង្គក្រោម នាពេលអនាគត។

កិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍ និង ការគ្រប់គ្រងវារីអគ្គិសនីនៅតាមព្រំប្រទល់ដែន ត្រូវបានកត់សម្គាល់ឃើញថា នឹងអាចជួយបង្កើនអត្ថប្រយោជន៍បានពីគម្រោង ទៅដល់ប្រទេសជាសមាជិកស្របពេលជាមួយគ្នានឹងកិច្ចសហប្រតិបត្តិការនេះ ក៏នឹងអាចកាត់បន្ថយលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមានដែលកើតមាននៅតាមព្រំប្រទល់ដែនផងដែរ ។ ជាការពិត ករណីសិក្សានានាបានបង្ហាញឲ្យឃើញពីវិធីសាស្ត្រផ្សេងៗ ដែលអាចប្រើប្រាស់បានក្នុងគោលដៅបន្ធូរបន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម ក៏ដូចជាការចែករំលែកនូវការចំណាយ និងចំណូលផងដែរ ។ ការវិភាគប្រៀបធៀបមួយទៅលើយន្តការ និងឧបករណ៍នានា ត្រូវបានយកមកអនុវត្តតាមករណីសិក្សាចំនួន៥ រួមមានករណីសិក្សាទៅលើទំនប់វារីអគ្គិសនីម៉ាណាន់តាលី (Manantali នៃប្រទេសសេណេហ្គាល់ ម៉ាលី និងម៉ូរីតានី) ទំនប់អ៊ីតៃពុយ (Itaipu Dam ប៉ារ៉ាហ្គាយ/ប្រេស៊ីល) គម្រោងអគ្គិសនីទន្លេ កូឡុំប៊ី (Combia River Project សហរដ្ឋអាមេរិក/កាណាដា) ទំនប់អគ្គិសនីការីបា (Kariba សាំប៊ីយ៉ា/សាំបាវ៉េ) និង ទំនប់អគ្គិសនីកូស៊ី (Kosi Dam ណេប៉ាល់/ឥណ្ឌា) ដែលករណីសិក្សាទាំងនេះបានផ្តល់នូវចំនុចផ្សេងៗ ដែលគណៈកម្មការទន្លេមេគង្គ ត្រូវយកមកធ្វើការពិចារណាទាក់ទិននឹងការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គក្រោម។

- ស្ថាប័នអាងទន្លេធំៗ អាចផ្តល់ជាបទដ្ឋានចាំបាច់សម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងថាមពលវារីអគ្គិសនីដោយមានការសម្របសម្រួល ។
- ការរៀបចំ និងបង្កើតឲ្យមានក្នាក់ងារជាក់លាក់មួយ សម្រាប់សម្រួលដល់កិច្ចសហប្រតិបត្តិការជាប្រចាំទាក់ទងនឹងការគ្រប់គ្រងដំណើរការទំនប់វារីអគ្គិសនី។
- យន្តការនានាទាក់ទងនឹងការបែកចែកការចំណាយ និងចំណូល ប្រកបដោយលក្ខណៈតម្លាភាព និងអាចទទួលយកបាន។
- វិធានការកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន ក៏ដូចជាតម្រូវការហិរញ្ញប្បទាន ត្រូវតែយកមកពិនិត្យពិចារណាតាមរយៈជំហាននៃការរៀបចំផែនការ។
- កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងមូលដ្ឋាន គឺជាការចាំបាច់ដើម្បីរៀបចំ និងអនុវត្តឲ្យមានប្រសិទ្ធភាព ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន។



គំនូសសម្គាល់១.២ គម្រោងវារីអគ្គិសនីដែលកំពុងដំណើការ និងស្ថិតនៅក្រោមគម្រោងផែនការ នៅអាងទន្លេមេគង្គក្រោម (ប្រភព គណៈកម្មការទន្លេមេគង្គ ២០០៨)

២.២.១ គម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលវារីអគ្គិសនី ប្រកបដោយចីរភាព

ការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងតំបន់មេគង្គ កំពុងទទួលបានមកវិញនូវលទ្ធភាពរីកចម្រើនលាយឡំជាមួយនឹងភាពឆាប់រហ័សនៃការអភិវឌ្ឍនានា ដែលផ្តោតទៅលើការផ្សារភ្ជាប់គ្នាជាមួយនឹងការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ របស់គណៈកម្មការទន្លេមេគង្គ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនៅក្នុងតំបន់ ប្រយោជន៍ ដើម្បីរៀបចំឲ្យមានផែនការជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១១-២០១៥។

តាមរយៈគម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលវារីអគ្គិសនីប្រកបដោយចីរភាពនេះ គេបានកត់សម្គាល់ឃើញថា បញ្ហាប្រឈមទាក់ទងនឹងការអភិវឌ្ឍវារីអគ្គិសនីនៅអាងទន្លេមេគង្គ ទាមទារឲ្យមានវិធីសាស្ត្រចម្រុះមួយ សម្រាប់និរន្តរភាពនៃវារីអគ្គិសនី ។

លទ្ធផលធំៗ៤នៃគម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលវារីអគ្គិសនីប្រកបដោយចីរភាព គឺជាការឆ្លើយតបចំគោលបំណងនៃផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១១-២០១៥ របស់គណៈកម្មការទន្លេមេគង្គ ៖

- លទ្ធផលទី១ ៖ ការរួមបញ្ចូលគ្នារវាងអត្ថប្រយោជន៍នៃការផ្សព្វផ្សាយចំណេះដឹង និងកិច្ចជជែកពិភាក្សារបស់ភាគីពាក់ព័ន្ធ។
- លទ្ធផលទី២ ៖ ការគ្រប់គ្រងការអប់រំ និងការកសាងសមត្ថភាព។
- លទ្ធផលទី៣៖ ការដាក់បញ្ចូលការពិចារណានានាអំពីវារីអគ្គិសនីប្រកបដោយចីរភាពទៅក្នុងការរៀបចំផែនការថ្នាក់តំបន់ និងប្រព័ន្ធនិយតកម្ម។
- លទ្ធផលទី៤ ៖ ការវាយតម្លៃពីនិរន្តរភាព និងការចាប់យកបទពិសោធន៍អនុវត្តល្អ។

គេអាចមើលឃើញថា គោលបំណងចម្បងមួយនៃគម្រោងផ្តួចផ្តើមគំនិតស្តីពីថាមពលវារីអគ្គិសនីប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០១១-២០១៥ គឺជួយដល់គណៈកម្មការទន្លេមេគង្គ ក្នុងការជ្រុំជ្រែងប្រទេសជាសមាជិក ដើម្បីធ្វើឲ្យប្រសើរឡើងលើការដាក់បញ្ចូលគ្នារវាងការសម្រេចចិត្តអំពីការគ្រប់គ្រង និងការអភិវឌ្ឍវារីអគ្គិសនី ជាមួយនឹងទស្សនវិស័យស្តីពីការគ្រប់គ្រងធនធានរួមផ្សំនៅអាងទន្លេធំ តាមរយៈមធ្យោបាយនៃយន្តការដែលបានទទួលស្គាល់របស់គណៈកម្មការទន្លេមេគង្គ និង ប្រព័ន្ធរៀបចំផែនការថ្នាក់ជាតិ ។ លទ្ធផលទាំងនេះមិនគ្រាន់តែស្របតាមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ តែមួយប៉ុណ្ណោះទេ វាក៏ស្របទៅនឹងគោលបំណងរបស់បណ្តាញអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី ប្រកបដោយចីរភាពនៃបណ្តាប្រទេសទន្លេមេគង្គផងដែរ ដែលមានគោលដៅគាំទ្រចំពោះលទ្ធផលនីមួយៗទាំង៤ ដែលបានបង្ហាញនៅខាងលើ។

២.៣. ការអភិវឌ្ឍន៍ធនធានទឹករួមផ្សំ ដោយពឹងផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់អាងទន្លេមេគង្គក្រោម

ការអភិវឌ្ឍន៍ធនធានទឹករួមផ្សំដោយពឹងផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង សម្រាប់អាងទន្លេមេគង្គក្រោម ផ្តល់នូវទិសដៅដំបូងសម្រាប់ការគ្រប់គ្រង និង អភិវឌ្ឍន៍អាងទន្លេមេគង្គ ដោយមានកិច្ចសហ-ប្រតិបត្តិការ និងប្រកបដោយចីរភាព ។ យុទ្ធសាស្ត្រនោះគឺ ៖

- ឧបករណ៍ស្នូលរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់ធ្វើឲ្យសម្រេចបាននូវគោលបំណងនៃកិច្ច-ព្រមព្រៀងឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការលើកិច្ចព្រមព្រៀង សម្រាប់កិច្ចអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយចីរភាព ត្រង់មានត្រា១ ៖ " ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យស្តីពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សទឹក និងធនធានពាក់ព័ន្ធដទៃទៀតនៃអាងទន្លេមេគង្គ " ។
- ការឆ្លើយតបជាបឋមរបស់គណៈកម្មការទន្លេមេគង្គ ត្រង់មាត្រា២ ដែលអំពាវនាវឲ្យមាន " ការរៀបចំយ៉ាងជាក់លាក់នូវផែនការអភិវឌ្ឍន៍អាងទន្លេ... ដើម្បីបញ្ចាក់ដាក់ចំណាត់ថ្នាក់ និងកំណត់អាទិភាពលើគម្រោង និងកម្មវិធីនានា..." ។

យុទ្ធសាស្ត្រនេះបានកំណត់អត្ថន័យលើ (ជំហានជាក់លាក់) នៃដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍អាងទន្លេដែលផ្សាភ្ជាប់ជាមួយផែនការថ្នាក់តំបន់ និង ផែនការថ្នាក់ជាតិនៃអាងទន្លេមេគង្គក្រោមដែលត្រូវបានរៀបចំឡើង តាមរយៈកិច្ចសហការរវាងប្រទេសជាប់ព្រំប្រទល់ដែន ។ យុទ្ធសាស្ត្រនេះត្រូវបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់៥ឆ្នាំម្តង ដោយគណៈកម្មការទន្លេមេគង្គ។

អាងទន្លេមេគង្គក្រោម និងទន្លេមេគង្គ កំពុងបន្តប្រែប្រួលជាបន្តបន្ទាប់។ កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅអាងទន្លេមេគង្គក្រោម ទាមទារឲ្យមានកិច្ចអភិវឌ្ឍន៍ធនធានទឹក សម្រាប់គោលដៅជាច្រើនរួមមាន ថាមពល កសិកម្ម ផលិតកម្មជលផល និងនាវាចរណ៍ ។ ក្រៅពីនេះ ក៏តម្រូវឲ្យមានការគ្រប់គ្រងទន្លេ និងអាយុកាលរបស់ទន្លេ និងប្រព័ន្ធអេកូឡូស៊ី ដែលផ្តល់ការចិញ្ចឹមជីវិត ដើម្បីធានាចីរភាពយូរអង្វែងក្នុងពេលវេលានៃការផ្លាស់ប្តូរដូចជា ប្រជាសាស្ត្រ សេដ្ឋកិច្ច និងបម្រែបម្រួលអាកាសធាតុ ។ ការអភិវឌ្ឍនៅអាងទន្លេមេគង្គឡង់កង់ភាគខាងលើ (Lancang-Upper Mekong Basin) ក្នុងប្រទេសចិន និងនៅអាងទន្លេមេគង្គក្រោម បានធ្វើឲ្យមានការផ្លាស់ប្តូររបបលំហូរទឹកទន្លេមេគង្គ នាពេលបច្ចុប្បន្ន។ ដើម្បីឆ្លើយតបចំពោះការកើនឡើងនៃតម្រូវការទំនិញ និង សេវាកម្មនានា វិស័យឯកជនបានស្វះស្វែងរកឱកាសវិនិយោគទៅលើអ្វីដែលទន្លេអាចផ្តល់ឲ្យ។ យុទ្ធសាស្ត្រនេះគឺមានលក្ខណៈជាសារវ័ន្ត និងជាការឆ្លើយតបចំពោះតថភាពជាក់ស្តែងនេះ ។

តាមរយៈកិច្ចសហការនៅថ្នាក់ជាតិ និង ថ្នាក់តំបន់ នៅមានឱកាសជាច្រើនទៀត សម្រាប់ការអភិវឌ្ឍនៅអាងទន្លេមេគង្គក្រោម ដែលអាចផ្តល់មកវិញនូវអត្ថប្រយោជន៍ជាច្រើន។ ឱកាសទាំងនេះក៏អាចប្រឈមនឹងហានិភ័យ និងការខាតបង់ដ៏ច្រើនផងដែរ ដែលតម្រូវឲ្យមានការគ្រប់គ្រង និងកាត់បន្ថយទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ក៏ដូចជានៅតាមទីកន្លែងពាក់ព័ន្ធដទៃទៀត តាមរយៈកិច្ចសហការនៅកម្រិតព្រំប្រទល់ដែនជាប់គ្នា ។ យុទ្ធសាស្ត្រនេះបានកំណត់ឲ្យឃើញច្បាស់នូវកាលានុវត្តភាព និងហានិភ័យនានា ដូចខាងក្រោម ៖

- សក្តានុពលយ៉ាងធំធេងសម្រាប់ការអភិវឌ្ឍ បន្ថែមទៅលើវារីអគ្គិសនីនៅក្នុងតំបន់ចំណុះទន្លេមេគង្គ ជាពិសេសនៅក្នុងប្រទេសឡាវ និង កម្ពុជា ដែលទាមទារឲ្យមានស្តង់ដារគិតគូរអំពីបញ្ហាសង្គម និងបរិស្ថាន សំដៅធានានិរន្តរភាពនៃការអភិវឌ្ឍនេះ ។
- សក្តានុពលចម្បងក្នុងការពង្រីក និង បង្កើនផលិតកម្មកសិកម្មរមធ្យំ ក៏ដូចជាប្រឆាំងចំពោះការរំលោភបំពានទៅលើដែនដីសណ្តារ ដែលទាមទារឲ្យមានកិច្ចសហការជាមួយប្រទេសចិន ដែលកំពុងប្រតិបត្តិការទំនប់វារីអគ្គិសនីមេគង្គឡង់កង់ភាគខាងលើ ដើម្បីធានាលំហូរទឹកនារដូវប្រាំង ដែលបានកើនឡើងចរាចរ និងពឹងអាស្រ័យ។
- ឱកាសដ៏មានសក្តានុពលសម្រាប់ការអភិវឌ្ឍវារីអគ្គិសនី ដែលជាមែកធាងដ៏សំខាន់ បានផ្តល់មកវិញនូវភាពមិនប្រាកដប្រជា និង ហានិភ័យជាច្រើន ដែលបានលើកយកមកធ្វើការដោះស្រាយយ៉ាងពេញទំហឹង ហើយដោយអនុឡោមតាមដំណើរការឯកភាពគ្នាផ្នែកព្រំប្រទល់ដែន ។ នៅពេលដែលអត្ថប្រយោជន៍មានសក្តានុពលខ្ពស់ ការចំណាយក៏មានសក្តានុពលខ្ពស់ រួមទាំងផលប៉ះពាល់នៅតាមព្រំប្រទល់ដែនផងដែរ ។
- តម្រូវការក្នុងការកំណត់ឲ្យឃើញច្បាស់ពីឪកាសជាអាទិភាពទាក់ទងនឹងទឹក (តួយ៉ាងដូចជា ៖ ជលផល នាវាចរណ៍ ការគ្រប់គ្រងទឹកជំនន់ ទេសចរណ៍ ការគ្រប់គ្រងបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី) ក៏ដូចជាឱកាសផ្សេងៗទៀតលើសពីវិស័យទឹក (តួយ៉ាងដូចជាជម្រើសនៃការទាញយកថាមពលដទៃទៀត)។

២.៣.១ យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ

យុទ្ធសាស្ត្រនេះបានកំណត់អត្ថន័យអំពីដំណើរការមួយ ដើម្បីផ្លាស់ប្តូរពីឱកាសឲ្យទៅជាការអនុវត្ត និង ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការកំណត់អត្ថន័យថា *អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអាងទន្លេ* ។

- ការផ្តល់ជាចាំបាច់នូវចំណេះដឹងដើម្បីដោះស្រាយពីភាពមិនប្រាកដប្រជា និង ដើម្បីកាត់បន្ថយហានិភ័យនៃឱកាសអភិវឌ្ឍ ដែលបានកំណត់ឃើញរួចហើយ រួមទាំងការយល់ដឹងអំពីដំណើរឆ្លងកាត់ទៅមក និងភាពបន្ទាំរបស់មច្ឆា ការរាំងខ្ទប់ និងការហូរច្រោះនៃកករលាប់ និងសារធាតុចិញ្ចឹម ការបាត់បង់ជីវចម្រុះ ផលប៉ះពាល់លើសង្គម និងការប្រកបរបរចិញ្ចឹមជីវិត។
- កាល្ហានុវត្តភាព និងហានិភ័យនៃការអភិវឌ្ឍបច្ចុប្បន្ន (រហូតដល់ឆ្នាំ២០១៥) រួមទាំងកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន ដើម្បីធានាកម្រិតលំហូរទឹកទាប ដែលបានកើនឡើង រួមទាំងកិច្ចព្រមព្រៀងស្តីពីកម្រិតខ្សែទឹកមានលំហូរទាបនៃអាងទន្លេមេគង្គក្រោម និង ការគ្រប់គ្រងហា-និភ័យនានា ដែលអាចកើតចេញពីគម្រោងដែលបានចាប់ដំណើរការរួច។
- ជម្រើសដែលបានកំណត់ឃើញច្បាស់រួចរាល់សម្រាប់បែងចែកអត្ថប្រយោជន៍ និងហានិភ័យនៃការអភិវឌ្ឍន៍។

- ការពង្រីក និងបង្កើនកសិកម្មប្រពលវប្បកម្ម ដើម្បីធានាសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។
- និរន្តរភាពនៃបរិស្ថាន និង សង្គមទាក់ទងនឹងការអភិវឌ្ឍវារីអគ្គិសនី ត្រូវបានលើកកម្ពស់យ៉ាងខ្លាំងក្លា។
- ជម្រើសនៃការបន្សុំដែលបានកំណត់ឃើញ និងការអនុវត្តដែលបានផ្លូចផ្តើមរួចហើយ។
- ការពិនិត្យពិច័យលើផែនការអាងទន្លេ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការថ្នាក់ជាតិ និងប្រព័ន្ធនិយ័តកម្ម។

២.៣.២ យុទ្ធសាស្ត្រគ្រប់គ្រងអាងទន្លេ

យុទ្ធសាស្ត្រនេះកំណត់អត្តន័យថា អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាងទន្លេ គឺជាអ្វីដែលដើរទន្ទឹមគ្នាជាចាំបាច់ជាមួយការអភិវឌ្ឍអាងទន្លេ សំដៅធានានិរន្តរភាព ដូចតទៅ ៖

- ត្រូវកំណត់អត្តន័យឲ្យបានហ្មត់ចត់ពីគោលបំណងពិតប្រាកដទាក់ទងនឹងបរិស្ថាន និងសង្គមនៃអាងទន្លេធំ និងសន្ទស្សន៍ជាមូលដ្ឋាននានា ។
- ត្រូវកំណត់អត្តន័យឲ្យច្បាស់លាស់ពីគោលបំណង និង យុទ្ធសាស្ត្រគ្រប់គ្រងអាងទន្លេ សម្រាប់ វិស័យពាក់ព័ន្ធនឹងទឹក រួមមានជលផល និងនាវាចរណ៍ ជាដើម។
- ត្រូវពង្រឹងនីតិវិធីគ្រប់គ្រងធនធានទឹកជាមូលដ្ឋានថ្នាក់ជាតិ រួមមាន ៖ ការតាមដានត្រួតពិនិត្យធនធានទឹក ការផ្តល់អាជ្ញាប័ណ្ណប្រើប្រាស់ទឹក និងការគ្រប់គ្រងទិន្នន័យ និងព័ត៌មាន។
- ត្រូវពង្រឹងធនធានទឹកកម្រិតអាងទន្លេ និងនីតិវិធីគ្រប់គ្រងនានាដែលពាក់ព័ន្ធ រួមមានការអនុវត្តនីតិវិធីនៃគណៈកម្មការទន្លេមេគង្គ លក្ខខ័ណ្ឌនៃការតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីអាងទន្លេ ការតាមដានត្រួតពិនិត្យលើរយៈកាលនៃគម្រោង និងជម្រុញការចូលរួមពីភាគីពាក់ព័ន្ធ។
- ត្រូវអនុវត្តនូវកម្មវិធីកសាងសមត្ថភាពលើការគ្រប់គ្រងធនធានទឹក ផ្សារភ្ជាប់ជាមួយគំនិតផ្តួចផ្តើមជារួមរបស់គណៈកម្មការទន្លេមេគង្គ និង ជាការបំពេញបន្ថែមទៅលើសកម្មភាពកសាងសមត្ថភាពថ្នាក់ជាតិ។

២.៣.៣ ការអនុវត្តលើយុទ្ធសាស្ត្រ

យុទ្ធសាស្ត្របានកំណត់អត្តន័យយ៉ាងច្បាស់លាស់ អំពីផែនទីបង្ហាញផ្លូវមួយយ៉ាងជាក់លាក់ដោយការ រៀបចំឡើងនូវចំណាត់ការជាអាទិភាព កាលបរិច្ឆេទ និងលទ្ធផល ។ សកម្មភាពជាជំហានដំបូងនៃផែនទីបង្ហាញផ្លូវនេះ គឺការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ និង ថ្នាក់ជាតិនៃអាងទន្លេមេគង្គក្រោមដោយការកំណត់អត្តន័យពីសកម្មភាព ការទទួលខុសត្រូវ ផលិតផល និងតម្លៃ ។ ការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ នឹងត្រូវដឹកនាំធ្វើដោយគណៈកម្មការទន្លេមេគង្គ និងត្រូវអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រ២០១១-២០១៥ របស់គណៈកម្មការនេះ។ ផែនការសកម្មភាពថ្នាក់ជាតិ នឹងត្រូវដាក់បញ្ចូលគ្នាទៅ

ក្នុងផែនការសេដ្ឋកិច្ច និងផែនការតាមវិស័យសម្រាប់រយៈពេលវែង និងខ្លី ហើយនឹងត្រូវអនុវត្តជាអាទិភាព ស្នូល។ កម្មវិធីតាមដានត្រួតពិនិត្យយ៉ាងទូលំទូលាយ ទៅលើសកម្មភាព និងលទ្ធផលជាយុទ្ធសាស្ត្រ នឹងត្រូវបង្កើតឡើងនៅក្នុងអំឡុង ៣ខែដំបូង នៃការអនុវត្ត។

៣.៣.៤ ស្ថានភាពនៃយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រ គឺជាឧបករណ៍មួយរបស់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលរួមមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ហើយនឹងត្រូវអនុវត្តដោយប្រទេសជាសមាជិកទាំងនេះ ក្រោមការជួយគាំទ្រ និងសម្របសម្រួលពីគណៈកម្មការទន្លេមេគង្គ ព្រមទាំងមានជំនួយផ្នែកហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍សំខាន់ៗ។ ដើម្បីធ្វើឲ្យសម្រេចបានជោគជ័យលើគោលដៅជាសេចក្តីប្រាថ្នាក្នុងការសហប្រតិបត្តិការ និងការអភិវឌ្ឍ ក៏ដូចជាការគ្រប់គ្រងប្រកបដោយចីរភាពនៃអាងទន្លេមេគង្គក្រោម គឺទាមទារឲ្យមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយលក្ខណៈតម្លាភាពពីភាគីពាក់ព័ន្ធទាំងអស់ក្នុងក្របខ័ណ្ឌទន្លេមេគង្គ ដើម្បីជាការចែករំលែកអត្ថប្រយោជន៍ ទៅដល់ប្រជាពលរដ្ឋដែលរស់នៅតាមអាងទន្លេមេគង្គក្រោម ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងអត់ឃ្លាន។

១.៥- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសអាងទន្លេមេគង្គក្រោម

អាងទន្លេមេគង្គក្រោមគ្របដណ្តប់លើផ្ទៃក្រឡាប្រហែល៦០៦០០០គីឡូម៉ែត្រការ៉េ ស្ថិតក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ផ្អែកតាមលទ្ធផលនៃការសិក្សាថ្មីៗនេះនៅថ្នាក់ជាតិ និងថ្នាក់តំបន់ បង្ហាញថា នៅមានកង្វល់ជាច្រើនអំពីប្រសិទ្ធភាពដ៏មានសក្តានុពល នៃបម្រែបម្រួលអាកាសធាតុ ទៅលើចរិតលក្ខណៈសង្គមសេដ្ឋកិច្ច និង ធនធានធម្មជាតិ នៃតំបន់អាងទន្លេមេគង្គក្រោម។ តម្រូវការមួយត្រូវបានរកឃើញ សម្រាប់ការស្វែងយល់ដោយការផ្តល់ព័ត៌មានបន្ថែមស្តីពីផលប៉ះពាល់ ដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ។

ជាការឆ្លើយតប គណៈកម្មការទន្លេមេគង្គ បានដាក់ចេញនូវគម្រោងផ្តួចផ្តើមគំនិតមួយស្តីពីបម្រែបម្រួលអាកាសធាតុ និងការបន្សាំ (CCAI) ។ គម្រោងនេះ គឺជាគំនិតផ្តួចផ្តើមចេញពីកិច្ចសហការនៅថ្នាក់តំបន់ ក្នុងការដោះស្រាយ និង ចែករំលែកអំពីបញ្ហាប្រឈមនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសអាងទន្លេមេគង្គក្រោម ។ របាយការណ៍សរុបក្នុងតំបន់ (RSR) ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃជំហានរួម របស់គម្រោងផ្តួចផ្តើមគំនិតស្តីពីបម្រែបម្រួលអាកាសធាតុនៅក្នុងតំបន់ និង ការបន្សាំ (CCAI) ដើម្បីផ្តល់ជាចំណេះដឹងមួយផ្នែកក្នុងពេលបច្ចុប្បន្ន និងសកម្មភាពនានាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងប្រទេសអាងទន្លេមេគង្គក្រោម។ គោលបំណងជាក់លាក់នៃរបាយការណ៍សរុបនេះ រួមមាន ៖

- ផ្តល់ព័ត៌មានដល់មហាជនអំពីស្ថានភាពចំណេះដឹងបច្ចុប្បន្ន លើបញ្ហាបម្រែបម្រួលអាកាសធាតុនៅក្នុងប្រទេសអាងទន្លេមេគង្គក្រោម និងនៅជុំវិញតំបន់។
- ផ្តល់ព័ត៌មានទាន់សភាពការណ៍ស្តីពីសកម្មភាព និង គោលការណ៍បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងថ្នាក់ជាតិ ក៏ដូចជាការឆ្លើយតបជាលក្ខណៈស្ថាប័ន ចំពោះការប្រែប្រួលអាកាសធាតុ។

- បង្ហាញលទ្ធផលនៃ "ការវិភាគលើភាពចន្លោះប្រហោង" តាមរយៈការកំណត់ឲ្យឃើញច្បាស់ពីកង្វះខាតព័ត៌មាន និងកំហុសឆ្គងនៅក្នុងសកម្មភាព និង គោលនយោបាយដែលបានរៀបជាផែនការរួច ក៏ដូចជាការឆ្លើយតបជាលក្ខណៈស្តាប់ន ។
- បង្ហាញបណ្តុំអនុសាសន៍នានា សម្រាប់ចំណាត់ការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ នៅអាងទន្លេមេគង្គក្រោម នាពេលអនាគត។

១.៥.១- ចំណេះដឹងសំខាន់ស្តីពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុក្នុងតំបន់

ការប្រែប្រួលអាកាសធាតុ ត្រូវបានរំពឹងថានឹងផ្តល់ជាលទ្ធផល ក្នុងការកែប្រែសណ្ឋាននៃធាតុអាកាសដែលមិនត្រឹមតែធ្វើឲ្យរឹងតែខ្លាំងឡើង ដូចជាសីតុណ្ហភាព ការធ្លាក់ភ្លៀង និងខ្យល់ នៅអាងទន្លេមេគង្គក្រោមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែប្រែភាពទៀងទាត់នៃចិរវេលា និង ការកើតឡើងជាញឹកញាប់នៃហេតុការណ៍ធំៗទៀតផង។ កង្វះខាតទឹកតាមរដូវ ភាពរាំងស្ងួត និងទឹកជំនន់ អាចកើតមានជាញឹកញាប់ជាងមុន និងអាចធ្ងន់ធ្ងរជាងមុន ហើយអាចនឹងបង្កប៉ះពាល់ដោយសារទឹកប្រៃទៀតផង (Salwater intrusion) ។ ការប្រែប្រួលទាំងនេះ ត្រូវបានគេយល់ថា អាចនឹងជះឥទ្ធិពលដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ផលិតកម្មកសិកម្ម និងស្បៀង និងរឹតតែធ្វើឲ្យមានបញ្ហាដល់កំណើននៃការផ្គត់ផ្គង់អាហារ និង កំណើនចំនួនប្រជាជន ។ ផលប៉ះពាល់នៃការប្រែប្រួលទាំងនេះហាក់ដូចជាមានលក្ខណៈធ្ងន់ធ្ងរ ទៅលើការអាស្រ័យផលដ៏ខ្លាំងក្លា របស់សហគមន៍អាងទន្លេមេគង្គក្រោម ទៅលើធនធានធម្មជាតិសម្រាប់ជារបរចិញ្ចឹមជីវិតរបស់ខ្លួន។

ការសិក្សាស្រាវជ្រាវមួយចំនួន បានព្យាយាមបង្ហាញយ៉ាងត្រឹមត្រូវពីស្ថានភាពអាកាសធាតុអាចកើតមានក្នុងពេលអនាគត ដែលអាចផ្តល់លទ្ធផលចេញពីការលើកកម្តៅផែនដីនៅក្នុងតំបន់។ ទោះយ៉ាងណា ការសិក្សាស្រាវជ្រាវទាំងនេះ ភាគច្រើនមិនអាចកំណត់បរិមាណពេញលេញជុំវិញការព្យាករណ៍ពីអាកាសធាតុ នាពេលអនាគតបានឡើយ។ ការសិក្សាស្រាវជ្រាវថ្មីមួយដែលបានធ្វើសម្រាប់ CSIRO (Eastham *et al*., 2008) បានព្យាយាមកែតម្រូវទៅលើការដាក់កំហិតការសិក្សាស្រាវជ្រាវនានាពីមុន ហើយដោយផ្អែកទៅលើ IPCC's Scenario A1B ដោយបានធ្វើការព្យាករសម្រាប់ថ្នាក់តំបន់ នៅត្រឹមឆ្នាំ២០៣០ ដូចខាងក្រោម ៖

- ការកើនឡើងនៃសីតុណ្ហភាពអាងទន្លេធំ ក្នុងកម្រិត ០.៧៩ ˚C ជាមួយនឹងការកើនឡើងខ្លាំងនៅតំបន់ផ្នែរងទឹកភ្លៀងដែលមានសីតុណ្ហភាពទាប នៅអាងទន្លេភាគខាងជើង។
- ការកើនឡើងនៃបរិមាណទឹកភ្លៀងប្រចាំឆ្នាំ ក្នុងកម្រិត ០.២ ម៉ែត្រ មានតម្លៃស្មើនឹង ១៥.៣% លើសលុបពីបរិមាណទឹកភ្លៀងដែលកើនឡើងនារដូវធ្លាក់សន្សើម។
- កំណើននៃបរិមាណទឹកភ្លៀងនារដូវប្រាំងនៅតាមតំបន់ផ្នែរងទឹកភ្លៀងភាគខាងជើង រួមទាំងតំបន់ភាគច្រើននៃអាងទន្លេមេគង្គក្រោម។
- កំណើននៃលំហូរពីលើគោគចូលទៅក្នុងទឹក សរុបប្រចាំឆ្នាំមានចំនួន ២១% ដែលនឹងអាចរក្សា ឬ ធ្វើឲ្យប្រសើរឡើងវិញនូវវត្តមានទឹកប្រចាំឆ្នាំ ដែលមានស្រាប់នៅក្នុងតំបន់ផ្នែរងទឹកភ្លៀង។ ទោះយ៉ាងណា នៅតាមទីកន្លែងមួយចំនួននារដូវប្រាំង តំបន់តូចៗដែលមានសំពាធ

ទឹកកំរិតខ្ពស់ស្ថិតនៅក្នុងកម្រិតធម្មតា ដូចជានៅភាគខ្លាសាននៃប្រទេសថៃ និង នៅបឹងទន្លេសាប (ប្រទេសកម្ពុជា) ។

- កំណើននៃទឹកជំនន់នៅគ្រប់ផ្នែកនៃអាងទន្លេ រួមជាមួយនឹងផលប៉ះពាល់ដ៏ធំបំផុតនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងនៅខ្សែទឹកខាងក្រោម ភាគខាងលើនៃដងទន្លេមេគង្គ។
- បំលាស់ប្តូរលើផលិតភាពនៃការនេសាទ ដែលតម្រូវឲ្យមានការស្វែងរកបន្ថែម ទោះបីជាមានការព្យាករណ៍ថាបរិមាណ និង កម្រិតស្តុកទឹកនៃបឹងទន្លេសាប ដែលជាប្រភពចម្បងនៃសកម្មភាពនេសាទ នឹងកើនឡើងក៏ដោយ។
- កំណើននៃផលិតកម្មកសិកម្មអាចនឹងមានចំនួន ៣.៦% ប៉ុន្តែជាមួយនឹងកំណើនជារួមនៃកង្វះខាតស្បៀងអាហារ ដោយសារកំណើនចំនួនប្រជាជន តម្រូវឲ្យផលិតកម្មស្បៀងត្រូវមានចំនួនដ៏ច្រើនលើសលុប។
- ចាំបាច់តម្រូវឲ្យមានការពិនិត្យពិច័យបន្ថែមលើការព្យាករទាំងនេះ សំដៅយកចិត្តទុកដាក់ដោះស្រាយទៅលើផលវិបាកនៃទឹកជំនន់ និងការបំផ្លាញផលដំណាំផ្សេងៗ។

១.៥.២- ចំណេះដឹងសំខាន់ស្តីពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុក្នុងប្រទេស

ព័ត៌មានសុក្រឹតស្តីពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុនៅកម្រិតជាតិ នៅមានកម្រិតនៅឡើយក្នុងប្រទេសនីមួយៗជាសមាជិកនៃអាងទន្លេមេគង្គក្រោម ។ ព័ត៌មានដែលមានជារឿយៗដកស្រង់ចេញពីគំរូថ្នាក់ពិភពលោក និង ថ្នាក់តំបន់ រួមជាមួយនឹងកម្រិតប្រែប្រួលនៃភាពជាប់ទាក់ទងគ្នានឹងថ្នាក់ជាតិ ។ ព័ត៌មានអំពីបរិមាណ នៅមានភាពខ្វះខាតនៅឡើយ ចំណែកទិន្នន័យភាគច្រើនទាក់ទងនឹងលំហូរខ្ពស់អាកាសធាតុ ត្រូវបានបង្ហាញតាមបែបបទបរទេសដែលគ្មានភាពជាក់ស្តែង។

នៅប្រទេសកម្ពុជា ត្រូវបានគេព្យាករថា នឹងមានកំណើនសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំចន្លោះពី ១.៥ ˚C ទៅ ៥.៣ ˚C នៅត្រឹមឆ្នាំ២១០០ ។ ការធ្លាក់ទឹកភ្លៀងប្រចាំឆ្នាំ ក៏ត្រូវបានគេព្យាករណ៍ថា នឹងកើនឡើងផងដែរ ជាមួយនឹងកំណើនដ៏ខ្លាំងបំផុតដែលជាធម្មតាមាននៅរដូវធ្លាក់សន្សើម។ ចំណែកនៅប្រទេសអាងទន្លេមេគង្គក្រោមដទៃទៀត ប្រសិនបើនិយាយអំពីភាពញឹកញាប់ ភាពធ្ងន់ធ្ងរ និងថិរវេលា នោះត្រូវបានគេព្យាករណ៍ថា នឹងមានការកើនឡើងនូវទឹកជំនន់ និង ភាពរាំងស្ងួត ។ ផលប៉ះពាល់ដ៏ធំនៃការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការប្រែប្រួលលើផលិតកម្មស្រូវ រួមជាមួយនឹងការកើនឡើងនៃដំណាំបន្លែនៅតំបន់មួយចំនួននារដូវធ្លាក់សន្សើម និងការថយចុះនៃផលិតកម្មដទៃ ទន្ទឹមជាមួយនឹងការពន្លឿនការសិកវេចរឹលនៃព្រៃឈើ ការបាត់បង់ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ នារដូវធ្លាក់សន្សើម និងរដូវប្រាំង ក៏ដូចជាមានទឹកលិចនៅតំបន់ឆ្នេរ ហើយអត្រាកើតជំងឺឆ្លងនឹងមានកម្រិតខ្ពស់។

នៅប្រទេសឡាវ សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ ត្រូវបានគេព្យាករណ៍ថា នឹងមានការកើនឡើងស្របពេលជាមួយនឹងការកើនឡើងនៃភាពធ្ងន់ធ្ងរ ថិរវេលា និង មានទឹកជំនន់ជាញឹកញាប់ ជាពិសេសអាចនឹងកើតមាននៅតំបន់វាលទំនាបដែលស្ថិតនៅគៀកដងទន្លេមេគង្គ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុត្រូវបានគេព្យាករណ៍ថា នឹងបណ្តាលឲ្យមានការខូចខាតលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ

បណ្តាលមកពីកំណើនព្រុះមានកម្រិតខ្លាំង និង មានភាពញឹកញាប់ ការខូចខាតដី និងការហូរច្រោះដី ដោយសារបរិមាណទឹកភ្លៀងកើនឡើង ហើយអត្រាកើតជំងឺឆ្លងមានកម្រិតខ្ពស់ ។

នៅប្រទេសថៃ សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ ត្រូវបានគេព្យាករណ៍ថាមានការកើនឡើង ស្របពេលជាមួយនឹងការកើនឡើងនៃចិរវេលារដូវក្តៅ ដែលជាហេតុធ្វើឲ្យសីតុណ្ហភាពនៅក្នុងថ្ងៃជាច្រើនកើនឡើងជាងពេលមុនរហូតដល់ ៣៣ ˚C ហើយស្របពេលគ្នានឹងការថយចុះចិរវេលានៃរដូវរងារ។ នៅរដូវរងារ កម្រិតធ្លាក់ទឹកភ្លៀងអាចមានចំនួនខ្ពស់ជាងការព្យាករណ៍ទៅទៀត ។ នៅតាមអាងទន្លេមួយចំនួនត្រូវបានគេរំពឹងថានឹងជួបប្រទះការខ្វះខាតទឹក ហើយកំណើននៃទឹកជំនន់ និង ភាពរាំងស្ងួតត្រូវបានគេព្យាករណ៍ថានឹងមានជាញឹកញាប់ ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការប្រែប្រួលលើផលិតកម្មស្រូវ រួមជាមួយនឹងការកើនឡើងនៃផលដំណាំនៅតំបន់មួយចំនួននារដូវធ្លាក់សន្សើម និងការថយចុះនៃផលិតកម្មដទៃទៀត អាចនឹងបង្កឲ្យខូចខាតដល់តំបន់ដីសំណើម ដោយសារភាពខ្សត់ទឹក និងការខូចខាតលើតំបន់ឆ្នេរ ដោយសារការប្រែប្រួលនៃការហូរច្រោះ និង សណ្ឋាននៃល្បប់ (Accretion patterns)។

នៅប្រទេសវៀតណាម គេបានព្យាករណ៍ថា សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំនឹងកើនឡើង ២.៥ ˚C នៅត្រឹមឆ្នាំ២០៧០ ស្របពេលជាមួយនឹងការកើនឡើងខ្លាំងនៃសីតុណ្ហភាពនៅតំបន់ខ្ពង់រាប។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំជាអតិបរមា និងអប្បបរិមា ក៏ត្រូវបានព្យាករណ៍ថា នឹងមានការកើនឡើងផងដែរ ។ គ្រោះមហន្តរាយនៃទឹកជំនន់ និងភាពរាំងស្ងួត ត្រូវបានព្យាករណ៍ថា នឹងមានការកើនឡើង ស្របពេលជាមួយនឹងការប្រែប្រួលនៃការធ្លាក់ទឹកភ្លៀងតាមរដូវកាល និងការកើនឡើងនៃបាតុភូត និងព្រុះសង្ឃរាធ្ងន់ធ្ងរ ។ កម្ពស់ទឹកសមុទ្រត្រូវបានព្យាករណ៍ថា នឹងអាចឡើងដល់១ម៉ែត្រ នៅត្រឹមឆ្នាំ២១០០ ។ ការឡើងនៃកម្រិតកម្ពស់ទឹកសមុទ្រដល់១ម៉ែត្រនេះ ត្រូវបានគេប៉ាន់ប្រមាណថា នឹងបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ១០% និង បណ្តាលឲ្យបាត់បង់ផលិតផលក្នុងស្រុកសរុប ស្មើនឹង១០% ដែរដោយសារកើតមានទឹកជំនន់លើផ្ទៃដីឆ្នេរ ចំនួន៤០០០០គីឡូម៉ែត្រក្រឡា។ ផលប៉ះពាល់ដោយសារជាតិអំបិល នៅដែនដីសណ្តារទន្លេមេគង្គ ត្រូវបានគេរំពឹងថា នឹងមានការកើនឡើង ដែលជាហេតុបណ្តាលឲ្យមានការប្រែប្រួលលើសណ្ឋាននៃការដាំដុះដំណាំ និងផលិតកម្ម ក៏ដូចជាការជះឥទ្ធិពលដល់ប្រព័ន្ធអេកូឡូស៊ីដែលរស់នៅក្នុងទឹក និងលើគោក ។ អត្រាកើតជំងឺឆ្លងក៏ត្រូវបានព្យាករណ៍ថា នឹងមានកម្រិតខ្ពស់ផងដែរ ។

១.៥.៣ ការឆ្លើយតបថ្នាក់ជាតិ ចំពោះការប្រែប្រួលអាកាសធាតុ

ការឆ្លើយតបថ្នាក់ជាតិ ចំពោះការប្រែប្រួលអាកាសធាតុ រួមមានការឆ្លើយតបជាគោលនយោបាយជាលក្ខណៈស្ថាប័ន និងតាមរយៈការបន្សាំ ។ ប្រទេសស្ថិតតាមអាងទន្លេមេគង្គក្រោមទាំងអស់ បានផ្តល់សច្ចាប័នរួចហើយលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UN-FCCC) និងពិធីសារក្យូតូ ។ ប្រទេសជាសមាជិកនីមួយៗ មានឯកសារគោលនយោបាយបឋមមួយច្បាប់រៀងៗខ្លួនដែលឯកសារនោះ មានរំលេចឲ្យឃើញពីយុទ្ធសាស្ត្រ និងការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ។ នៅប្រទេសកម្ពុជា និងប្រទេស ឡាវ គេបានបង្កើតកម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំ (NAPA)។ ប្រទេស

ថៃបានរៀបចំជាផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានឈ្មោះថា " យុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុរយៈពេល៥ឆ្នាំ ២០០៨-២០១២" ចំណែកប្រទេសវៀតណាម បានរៀបចំបង្កើត " ផែនការគោលដៅជាតិសម្រាប់ឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ" ។ ជាទូទៅបញ្ហាបម្រែបម្រួលអាកាសធាតុ មិនទាន់ត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងក្របខ័ណ្ឌគោលនយោបាយទូលំទូលាយរបស់រដ្ឋាភិបាលនៅឡើយទេ ។

ប្រទេសនីមួយៗជាសមាជិកអាងទន្លេមេគង្គក្រោម បានលើកស្ទើឡើងនូវចំនុចសំខាន់ថ្នាក់ជាតិមួយ គឺបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថាននៃប្រទេសកម្ពុជាដើរតួនាទីក្នុងកិច្ចការនេះ រួមជាមួយរដ្ឋបាលធនធានទឹក និងបរិស្ថាននៃប្រទេសឡាវ ព្រមទាំងក្រសួងធនធានធម្មជាតិ និងបរិស្ថាននៃប្រទេសថៃ និងប្រទេសវៀតណាមផងដែរ។ ប្រទេសជាសមាជិកទាំងអស់ បានបង្កើតជាស្ថានប័នថ្នាក់ខ្ពស់មួយ ដោយមានការទទួលខុសត្រូវលើការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ។ កម្ពុជាបានបង្កើតនូវគណៈកម្មការជាតិបម្រែបម្រួលអាកាសធាតុ ប្រទេសថៃបានបង្កើតនូវគោលនយោបាយជាតិ បម្រែបម្រួលអាកាសធាតុ ចំណែកប្រទេសវៀតណាមបានបង្កើតនូវគណៈកម្មការជាតិបម្រែបម្រួលអាកាសធាតុ។

ប្រទេសជាសមាជិកអាងទន្លេមេគង្គក្រោមទាំងអស់ មានប្រវត្តិក្នុងការអនុវត្តសកម្មភាពបន្សាំទៅនឹងការប្រែប្រួអាកាសធាតុ បើទោះបីជាសកម្មភាពភាគច្រើនបាននិងកំពុងផ្តោតទៅលើការឆ្លើយតបចំពោះការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ជាជាងទៅលើការប្រែប្រួលអាកាសធាតុក្តី ។ កម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំ (NAPA) របស់ប្រទេសកម្ពុជា និងប្រទេសឡាវ បង្កប់ទៅដោយព័ត៌មានស្តីពីគម្រោងបន្សាំដែលបានស្នើឡើង ដែលរួមបញ្ចូលចំនួន៣៩សកម្មភាព ដែលត្រូវបានដាក់បញ្ចូលជាផែនការសម្រាប់ប្រទេសកម្ពុជា ហើយចំនួន៤៥សកម្មភាព ត្រូវបានដាក់បញ្ចូលជាផែនការសម្រាប់ប្រទេសឡាវ។ " ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជាយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុរយៈពេល៥ឆ្នាំ (២០០៨-២០១២)"របស់ប្រទេសថៃ បានរៀបចំទិសដៅជាយុទ្ធសាស្ត្រ ដើម្បីបង្កើតផែនការសកម្មភាពលម្អិតសម្រាប់សកម្មភាពបន្សាំទៅថ្ងៃអនាគត ។ ចំណែកផែនការគោលដៅជាតិសម្រាប់ឆ្លើយតបចំពោះការប្រែ-ប្រួលអាកាសធាតុរបស់ប្រទេសវៀតណាម បានបង្កើតជាទិសដៅសម្រាប់ការរៀបចំឲ្យមានផែនការសកម្មភាពបន្សាំផ្អែកតាមវិស័យ និង ភូមិសាស្ត្រ ដែលមកដល់ពេលនេះវាជាផែនការសកម្មភាពមួយដែលបានអនុវត្តចប់រួចរាល់ហើយសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍជនបទ។

មានស្ថាប័នអង្គការអន្តរជាតិជាច្រើន កំពុងបម្រើការងាររបស់ខ្លួនលើបញ្ហាទាក់ទងនឹងការប្រែ-ប្រួលអាកាសធាតុ ដោយភាពជាដៃគូជាមួយរដ្ឋាភិបាល ។ សម្រាប់អាងទន្លេមេគង្គក្រោម មានគម្រោងជាង ៣០០កំពុង ត្រូវបានអនុវត្ត ឬ ស្ថិតនៅក្នុងផែនការអនុវត្ត ដោយគម្រោងទាំងនោះ មានដូចជា ៖

- គម្រោងផ្តួចផ្តើមគំនិតស្តីពីការប្រែប្រួលអាកាសធាតុ និងការបន្សាំ (CCAI) ដែលជាគម្រោងរបស់គណៈកម្មការទន្លេមេគង្គទើបដាក់ចេញឲ្យអនុវត្តនាពេលថ្មីៗនេះ ហើយដែលជាប់ទាក់ទិនជាមួយ សកម្មភាពបម្រែបម្រួលអាកាសធាតុពាក់ព័ន្ធដទៃទៀត ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តតាមវិស័យផ្សេងៗ ចាប់តាំងពីឆ្នាំ២០០០ ។

- កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) ដែលកំពុងបញ្ចាបសកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីអភិវឌ្ឍន៍ តាមរយៈគម្រោងផ្តួចផ្តើមគំនិតស្តីពីភាពក្រីក្រ និងបរិស្ថាន (PEI) ។
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុមួយចំនួន នៅក្នុងជំហាននៃការត្រៀមបម្រុង ដែលជាផ្នែកមួយនៃកម្មវិធីបរិស្ថាននៅមហាអនុតំបន់ទន្លេមេគង្គ ។
- ការសិក្សាស្រាវជ្រាវអំពីការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ នៅតាមទីក្រុងឆ្នេរធំជាងគេនៅអាស៊ី ដែលការសិក្សានេះកំពុងធ្វើឡើងក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ហើយការសិក្សានេះកំពុងពិនិត្យតាមដានអំពីបញ្ហានានាទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ក្នុងទីក្រុងបាងកក និងទីក្រុងហូជីមិញ ។

១.៥.៤ ការវិភាគអំពីភាពចន្លោះប្រហោង និងអនុសាសន៍នានា

ការវិភាគមួយអំពីភាពចន្លោះប្រហោង ដែលរៀបចំធ្វើដោយក្រុមអ្នកជំនាញការជាតិ (NETs) និងក្រុមអ្នកសិក្សាស្រាវជ្រាវទៅលើរបាយការណ៍សរុបក្នុងតំបន់ បានរកឃើញថា ពលរដ្ឋសាមញ្ញជាច្រើនអាចយល់ដឹងបានពីកំហុសឆ្គងលើការយល់ដឹង សកម្មភាព និងការឆ្លើយតបទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ សេចក្តីសង្ខេបនៃការវិភាគអំពីភាពចន្លោះប្រហោង ត្រូវបានយកមកបង្ហាញនៅផ្នែកខាងក្រោម ដែលសេចក្តីសង្ខេបនេះ ត្រូវចាត់ថ្នាក់ជាបញ្ហាជាតិសម្រាប់ប្រទេសជាសមាជិកអាងទន្លេទន្លេមេគង្គក្រោម និង ជាបញ្ហាមួយសម្រាប់តំបន់អាងទន្លេមេគង្គក្រោមទាំងមូលផងដែរ។

ការវិភាគអំពីភាពចន្លោះប្រហោង អាចឆ្លុះបញ្ចាំងពីក្តីកង្វល់ដ៏ចម្បង និងទិដ្ឋភាពគន្លឹះ ដូចដែលបានបង្ហាញដោយអ្នកជំនាញការជាតិ និងអ្នកជំនាញការក្នុងតំបន់។

អនុសាសន៍ជាច្រើនសម្រាប់អនុវត្តនាពេលអនាគត ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានចងក្រងឡើងដោយក្រុមអ្នកជំនាញការជាតិ និង ក្រុមអ្នកសិក្សាស្រាវជ្រាវ ទៅលើរបាយការណ៍សរុបក្នុងតំបន់ ។ អនុសាសន៍ទាំងនេះត្រូវបង្ហាញនៅខាងក្រោម ផ្អែកតាមអនុសាសន៍ដែលផ្តល់ដោយប្រទេសនីមួយៗជាសមាជិក អាងទន្លេមេគង្គក្រោម ដោយបូករួមទាំងអនុសាសន៍ទាំងឡាយដែលបានផ្តល់ដោយអ្នកជំនាញការក្នុងតំបន់ទៀតផង ។

អនុសាសន៍របស់ប្រទេសជាសមាជិក ៖

- ប្រទេសកម្ពុជា ៖
  - -ក១ ការគាំទ្រចំពោះការអនុវត្តសកម្មភាពជាអាទិភាព ទៅលើកម្មវិធីសកម្មភាពជាតិសម្រាប់ការបន្សាំ។
  - -ក២ ការរៀបចំ និង អនុវត្តយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។
  - -ក៣ ការបញ្ចាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីអភិវឌ្ឍនានា។

-ក៤ ស្តាប់ន្ទូបនីយកម្មនៃយន្តការសម្របសម្រួលអន្តរស្តាប់ន៍ស្តីពីការប្រែប្រួលអាកាសធាតុ។
-ក៥ ការដាក់បញ្ចូលកម្មវិធីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងគ្រោងថវិកា។
-ក៦ ការចងក្រងសេចក្តីព្រៀងច្បាប់/គោលនយោបាយ ស្តីពីការបន្សាំទៅនឹងការប្រែ-ប្រួលអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ។
-ក៧ ការពង្រឹងការសិក្សាស្រាវជ្រាវលើការប្រែប្រួលអាកាសធាតុ។

• ប្រទេសឡាវ ៖
-ឡ១ ការរៀបចំ និងការអនុវត្តកម្មវិធីកសាងសមត្ថភាព។
-ឡ២ ការបង្កើត និងផ្សព្វផ្សាយគំរូម៉ូដែល និងឧបករណ៍វាយតម្លៃនានា។
-ឡ៣ ការគាំទ្រចំពោះបទដ្ឋានគោលនយោបាយ និងបទដ្ឋានជានីតិវិធី និងជាលក្ខណៈស្តាប់ន ដែលមានលក្ខណៈល្អប្រសើរ។
-ឡ៤ ការសិក្សាស្រាវជ្រាវសាកល្បងលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅតាមបណ្តាខេត្តមួយចំនួន។
-ឡ៥ ការរៀបចំ និងការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងរាយការណ៍ថ្នាក់ជាតិ ។
-ឡ៦ ការអង្កេតតាមដានលើការប្រើប្រាស់សមស្របទៅលើធនធានព្រៃឈើ ក៏ដូចជាធនធានក្រោមទឹកសម្រាប់កាបូនឌីអុកស៊ីដ។
-ឡ៧ ការស្រាវជ្រាវដើម្បីពង្រឹងប្រព័ន្ធ និង សេវាសុខាភិបាល សម្រាប់ធ្វើទុកជាមុន និងបង្ហាញឲ្យប្រសើរឡើងពីបញ្ហាប្រឈមធំៗទាក់ទងនឹងសុខភាព ។
-ឡ៨ ការបង្កើតយុទ្ធសាស្ត្រមួយសម្រាប់ការប្រើប្រាស់ទឹកក្រោមគោលដៅរួម នៃសកម្មភាពអភិវឌ្ឍន៍ជាតិ។

• ប្រទេសថៃ ៖
-ថ១ ការរៀបចំ និងការវាយតម្លៃល្អប្រសើរ លើយុទ្ធសាស្ត្រក្នុងការបន្សាំ។
-ថ២ ការរៀបចំ និងការអនុវត្តកម្មវិធីកសាងសមត្ថភាព។
-ថ៣ ការរៀបចំ និងការអនុវត្តកម្មវិធីផ្សព្វផ្សាយការយល់ដឹង។
-ថ៤ ការបញ្ជ្រាបអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការនៃការរៀបចំគោលនយោបាយជាតិ។
-ថ៥ យន្តការបង្កើនមូលនិធិសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។
-ថ៦ ការអង្កេតតាមដានអំពីទំនាក់ទំនងរវាងភាពក្រីក្រ និងការប្រែប្រួលអាកាសធាតុ។
-ថ៧ ការរៀបចំ និងការផ្សព្វផ្សាយឧបករណ៍គំរូមានលក្ខណៈល្អប្រសើរ។
-ថ៨ ការបង្កើនការសិក្សាស្រាវជ្រាវលក្ខណៈបៃបវិទ្យាសាស្ត្រ។

- ប្រទេសវៀតណាម ៖
  - -វ១ ការកំណត់ប្រភពមូលនិធិសម្រាប់សកម្មភាពនៃផែនការគោលដៅជាតិ និងវិធានការបន្សុាំ។
  - -វ២ ការសិក្សាស្រាវជ្រាវបន្ថែមទៅលើផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
  - -វ៣ ការពង្រឹងបណ្តាញ និងយន្តការចែករំលែកព័ត៌មាន។
  - -វ៤ ការសម្របសម្រួលតាមស្តាប់ននៅថ្នាក់ជាតិ។
  - -វ៥ គោលការណ៍ណែនាំស្តីអំពីការរៀបចំផែនការបន្សុាំសម្រាប់ស្ថានប័នជាតិ។
  - -វ៦ ការទំនាក់ទំនងអំពីលទ្ធផលបែបវិទ្យាសាស្ត្រ តាមរយៈការបកប្រែនូវឯកសាររបកគំ-ហើញសំខាន់ៗ។

អនុសាសន៍របស់អ្នកជំនាញការក្នុងតំបន់ ៖

- ត១ ការរៀបចំរចនាសម្ព័ន្ធស្ថានប័នក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការប្រែប្រួល អាកាសធាតុ។
- ត២ ការព្យាករលើបម្រែបម្រួលអាកាសធាតុ។ និងការរួមបញ្ចូលការវាយតម្លៃលើផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុនៅអាងទន្លេធំ។
- ត៣ ការផ្តល់នូវនិរន្តរភាព នៃការរៀបចំផែនការគោលនយោបាយ ស្តីពីការប្រែប្រួលអាកាសធាតុ។
- ត៤ ការរៀបចំ និងការអនុវត្តយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដល់ភាគីពាក់ព័ន្ធ។
- ត៥ កិច្ចសហការជាមួយប្រទេសដែលនៅជាប់ព្រំប្រទល់ដែនគ្នា ដើម្បីដោះស្រាយបញ្ហាតាមព្រំប្រទល់ដែនពាក់ព័ន្ធនឹងសកម្មភាពបន្សុាំ។
- ត៦ ការរៀបចំបណ្តាញ និងយន្តការចែករំលែកព័ត៌មានក្នុងតំបន់។

១.៦- សេចក្តីសន្ទេប

នៅក្នុងខ្លឹមសារដែលបានលើកយកមកបង្ហាញពីមុន មានន័យថានឹងមានការអភិវឌ្ឍន៍បន្ថែមលើវិស័យធនធានទឹកទន្លេមេគង្គ និងនៅតាមតំបន់ស្ថិតនៅក្នុងចំណុះនៃទន្លេមេគង្គនេះ។ ជាចុងក្រោយបង្អស់ទាមទារឲ្យមានការយល់ដឹង និងខិតខំប្រឹងប្រែងដោះស្រាយបន្ថែមទៀត ទៅលើបញ្ហាប្រឈមជាច្រើន ដើម្បីធ្វើឲ្យសម្រេចបាននូវនិរន្តរភាពនៃសំណង់អាគារគ្រប់ប្រភេទ រួមទាំងសំណង់អាគារវារីអគ្គិសនីផង។

៣- សេចក្តីផ្តើមស្តីពីកិច្ចពិភាក្សាទៅលើទំនប់ខ្នាតធំ និងសំណង់អគារវារីអគ្គិសនី

៣.១ វគ្គ៣.១-សាវតា

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំអំពីកិច្ចពិភាក្សាទៅលើទំនប់វារីអគ្គិសនី ជាពិសេសថាមពលវារីអគ្គិសនី ដែលបានរៀបចំធ្វើដោយសហគមន៍អន្តរជាតិ។
ទិសដៅ	• ដើម្បីស្វែងយល់អំពីការបង្កើត និងទំហំនៃកិច្ចពិភាក្សានេះ..... • ដើម្បីយល់ដឹងអំពីស្ថាប័នជាច្រើន ដែលបានចូលរួមពាក់ព័ន្ធ នៅក្នុងកិច្ចពិភាក្សានេះ..... • ដើម្បីស្វែងយល់អំពីបញ្ហាស្នូលនៃកិច្ចពិភាក្សានេះ..... • ដើម្បីឲ្យតម្លៃទៅលើវិសាលភាពនៃបណ្តុំចំណេះដឹងដែលមាន.....
ការអានតាមលំដាប់លំដោយ	គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (២០០០)។ ទំនប់វារីអគ្គិសនី និង ការអភិវឌ្ឍ ៖ បទដ្ឋានថ្មីមួយសម្រាប់ការធ្វើការសម្រេចចិត្ត។ ក្រុមហ៊ុនបោះពុម្ពផ្សាយ រិភាគផែនដី ៖ ទីក្រុងឡុង (ចក្រភពអង់គ្លេស) ។ បុព្វកថារបស់ប្រធាន និងគណៈកម្មការនាយក។ ..... គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនីនិងការអភិវឌ្ឍ។ ការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរ។ឯកសារ ស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និង ជម្រើសដែលអាចជំនួសបាន ។ www.unep.org/dams

៣.១.១ ការគម្រាមកំហែងដល់បរិស្ថាន

ការរីកចម្រើនលូតលាស់ផ្នែកឧស្សាហកម្ម និង ការលូតលាស់ស្មារតីយល់ដឹងអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការអភិវឌ្ឍបច្ចេកវិទ្យាដោយគ្មានការរិតត្បិត បានចាប់ផ្តើមមានជាលើកដំបូងនៅសហរដ្ឋអាមេរិក ក្រោយសង្គ្រាមលោកលើកទី២ ។ សហរដ្ឋអាមេរិក បានប្រកាសឲ្យប្រើនូវច្បាប់ស្តីពីគោល-នយោបាយបរិស្ថានជាតិ (NEPA) នៅឆ្នាំ១៩៦៩ ។ ច្បាប់ជាតិនេះ គឺជាការតាក់តែងលើកដំបូងសំដៅនាំផ្លូវលើការវាយតម្លៃបរិស្ថាន និងតម្រូវឲ្យបោះពុម្ពផ្សាយលទ្ធផលលម្អិតនៅក្នុងសេចក្តីថ្លែងការណ៍អំពីបរិស្ថាន ។ ច្បាប់នេះបានញ៉ាំងឲ្យមានការស្រាវជ្រាវយ៉ាងទូលំទូលាយនៅក្នុងវិធីសាស្ត្រ ដែលត្រូវប្រតិបត្តិតាមច្បាប់ស្តីពីគោលនយោបាយបរិស្ថាន ជាតិ (NEPA) និង ការវាយតម្លៃអំពីបរិស្ថាន។

វិធីសាស្ត្ររបស់សហរដ្ឋអាមេរិក បានផ្តល់ជាមធ្យោបាយសម្រាប់គំនិតផ្តួចផ្តើមអន្តរជាតិ ដែលមានលក្ខណៈទូលំទូលាយ។ គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP) ត្រូវបានចាប់ផ្តើមបង្កើតឡើងនៅឯសន្និសីទសហប្រជាជាតិស្តីពីបរិស្ថានមនុស្ស កាលពីឆ្នាំ១៩៧២។ គណៈកម្មការពិភពលោកទទួល

បន្ទុកបរិស្ថាន និងការអភិវឌ្ឍន៍ (WCED) ដែលគេហៅជាទូទៅថា គណៈកម្មការ Brundtland បានបោះពុម្ព ផ្សាយរបាយការណ៍ របស់ខ្លួននាឆ្នាំ១៩៨៧ ដែលមានចំណងជើងថា " អនាគតរបស់យើងរួមគ្នា" ។ របាយ-ការណ៍នេះបានស្នើជា សាធារណៈឲ្យមានកិច្ចអភិវឌ្ឍដែលឆ្លើយតបចំពោះ សេចក្តីត្រូវការនៅក្នុងសម័យ កាលបច្ចុប្បន្ន ដោយគ្មានការសម្រុះសម្រួលអំពីលទ្ធភាពសម្រាប់សម័យកាលអនាគត ក្នុងការឆ្លើយតប ចំពោះសេចក្តីត្រូវការរបស់ខ្លួន និងជម្រុញឲ្យមានការប្រើប្រាស់ពាក្យថា " ការអភិវឌ្ឍប្រកបដោយចីរភាព " ។ នាដើមទសវត្សរ៍ទី៩០ ឧបករណ៍សំខាន់ទាំង៣នៃច្បាប់បរិស្ថានអន្តរជាតិត្រូវបានបង្កើតឡើង ក្នុងនោះរួមមាន អនុសញ្ញាក្របខ័ណ្ឌអន្តរជាតិស្តីពីការ ប្រែប្រួលអាកាសធាតុ អនុសញ្ញាអន្តរជាតិស្តីពីជីវចម្រុះ និងពិធីសារ ម៉ុងរ៉េអាល់ស្តីពីស្រទាប់អូហ្សូន។

ក្នុងឆ្នាំ១៩៩២ សន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ (UNCED) ត្រូវបានរៀបចំ ឡើងនៅទីក្រុងរីយ៉ូដឺជេណៃរ៉ូ (Rio de Janeiro) ។ នៅក្នុងសន្និសីទនេះ មានការពិភាក្សាអំពីបញ្ហាជាច្រើន ទាក់ទងនឹងបរិស្ថាន។ ជាលទ្ធផល គេទទួលបានមកវិញនូវ " របៀបវារៈ២១ ដែលជារបៀបវារៈស្តីពីបរិស្ថាន សម្រាប់សតវត្សរ៍ទី២១" ។ ជំពូកទី១៨នៃរបៀបវារៈនេះ និយាយអំពីដំណោះស្រាយលើធនធានទឹក ត្រង់ វាក្យខ័ណ្ឌ៤០នៃជំពូក១៨ ស្នើជាសាធារណៈឲ្យមានការចងក្រងឧបករណ៍ច្បាប់ជាតិ និងអន្តរជាតិ ដែលតម្រូវ ឲ្យមានការការពារគុណភាពធនធានទឹក រាប់ទាំងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ សេចក្តីថ្លែងការណ៍ នៃសន្និសីទឌីរីយ៉ូ (Conference's Rio Declaration) ត្រង់ចំនុចគោលការណ៍ ទី៧ បានកំណត់ថា ៖

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាឧបករណ៍ថ្នាក់ជាតិមួយ ដែលអាចយកទៅអនុវត្តបាន ចំពោះសកម្មភាពទាំងឡាយណាដែលបានស្នើឡើង ហើយដែលបង្កផលប៉ះពាល់មិនល្អដល់បរិស្ថាន និង ដោយផ្អែកទៅតាមសេចក្តីសម្រេចចិត្តរបស់អាជ្ញាធរជាតិមានសមត្ថកិច្ច។

នៅក្នុងរបាយការណ៍ (របាយការណ៍សហស្សវត្សរ៍) របស់អគ្គលេខានៃអង្គការសហប្រជាជាតិ ចេញកាលពីឆ្នាំ២០០០ បានកំណត់ថា ៖

វិបត្តិអេកូឡូស៊ីដែលយើងកំពុងជួបប្រឈម បណ្តាលមកពីមូលហេតុជាច្រើន ។ វិបត្តិទាំងនោះ រួមមានភាពក្រីក្រ ការធ្វេសប្រហែស និងភាពលោភលន់ និងលើសពីនេះទៀតគឺ ឋានជ័យនៃអភិបាលកិច្ច។ វិបត្តិទាំងនេះមិនអាចឈានដល់ដំណោះស្រាយដោយងាយស្រួល ឬគ្មានការប្រែប្រួលទេ។

បន្ថែមទៅលើគោលដៅសហស្សវត្សរ៍ (MDG) ដែលបានដាក់ស្នើឡើង របាយការណ៍នោះបាន អំពាវនាវជាសាធារណៈឲ្យមាន " ការបង្កើតក្រមសីលធម៌ស្តីពីភាពជាកម្មសិទ្ធិនៃសកលលោក" ។ របាយការណ៍ នេះបានបន្សល់ទុកនូវគោលនយោបាយដ៏មានប្រសិទ្ធភាពស្តីពីបរិស្ថាន ដែលពឹងផ្អែកលើព័ត៌មានលក្ខណៈ បែបវិទ្យាសាស្ត្រ និងបានស្នើឲ្យរដ្ឋាភិបាលបង្កើត និងពង្រឹងការអនុវត្តច្បាប់នានាស្តីពីបរិស្ថាន។

កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (WSSD) កាលពីឆ្នាំ២០០២ បាន គូសបញ្ជាក់សារជាថ្មីនូវកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ ត្រង់របៀបវារៈ២១។ កថាខ័ណ្ឌទី១៩ នៃផែនការ អនុវត្តនៃកិច្ចប្រជុំកំពូលចូហាន់ណេសប៊ឺក ដោយបានអំពាវនាវទៅកាន់ប្រទេសជាសមាជិក ទាំងអស់ ថា ៖

" ត្រូវជម្រុញអាជ្ញាធរពាក់ព័ន្ធនៅគ្រប់ថ្នាក់ឲ្យយកចិត្តទុកដាក់ ចំពោះការសម្រេចចិត្តដោយធ្វើការពិនិត្យពិចារណាចំពោះការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការរៀបចំធ្វើផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍមុខជំនួញ និង ដំណើរការនៃការផ្តល់ឲ្យជាសាធារណៈ។ ការសម្រេចចិត្តនេះ ត្រូវរួមបញ្ចូលទាំងចំណាត់ការនានានៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ដើម្បី៖

(ក).....

*(ខ) **ប្រើប្រាស់នីតិវិធីនានាក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** " ។*

នៅឯសន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព (RiO+20) កាលពីឆ្នាំ២០១២ សហគមន៍អន្តរជាតិ បានគូសបញ្ជាក់សារជាថ្មីម្តងទៀតអំពីគោលការណ៍ទាំងឡាយ ដែលបានចងក្រងឡើងក្នុងអំឡុងនៃសន្និសីទខាងលើ ។

ប្រមុខរដ្ឋនានាបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការ ៖

" ពង្រឹងកម្លាំងឆន្ទៈនយោបាយ និង ជម្រុញឲ្យកាន់តែខ្ពស់នូវកិច្ចខិតខំប្រឹងប្រែង របស់សហគមន៍អន្តរជាតិ ក្នុងការជម្រុញឲ្យរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយចីរភាពបានដំណើរការទៅមុខយ៉ាងឆាប់រហ័ស ព្រមទាំងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្រីក្រ និងសហគមន៍ដែលកំពុងស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ " ។

និង

" យើងទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ គឺជាវិបត្តិមួយសម្រាប់យើងទាំងអស់គ្នា និងជាវិបត្តិមួយដែលស្ថិតនៅជាយូរអង្វែង ដូច្នេះយើងសូមសម្តែងនូវការព្រួយបារម្ភចំពោះទំហំ និងមូលហេតុដ៏ធ្ងន់ធ្ងរនៃផលប៉ះពាល់ជាអវិជ្ជមាន ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ទៅលើប្រទេសទាំងអស់នៅក្នុងពិភពលោក និងដើម្បីឲ្យអន្តរាយដល់លទ្ធភាព ជាពិសេសនៃប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការធ្វើឲ្យសម្រេចបានជោគជ័យលើការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងជាការគម្រាមកំហែងដល់សមត្ថភាពក្នុងការអភិវឌ្ឍន៍ខ្លួន និង រស់រានដោយឯករាជ្យនៃប្រទេសជាតិនីមួយ "
ហើយ " យើងសូមគូសបញ្ជាក់ថា ការចូលរួមយ៉ាងទូលំទូលាយជាសាធារណៈ និងការទទួលបានព័ត៌មាន និងនីតិវិធីគតិយុត្តិ និងបែបបទរដ្ឋបាល ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការជម្រុញការអភិវឌ្ឍប្រកបដោយចីរភាព" ។

សេចក្តីថ្លែងការណ៍នេះ ក៏បានបង្ហាញផងដែរអំពី "សេដ្ឋកិច្ចបៃតង" និង ការកំណត់គោលការណ៍សម្រាប់កិច្ចពិភាក្សា។ បន្ថែមលើនេះ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងដើម្បីបង្កើតឲ្យមានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs)។ ប៉ុន្មានឆ្នាំកន្លងទៅ ទស្សនៈស្តីពីសេដ្ឋកិច្ចបៃតង បានផុសផុលឡើងនៅក្នុងការជជែកពិភាក្សាគន្លឹះនៅកម្រិតអន្តរជាតិ ជាពិសេសក្នុងអំឡុងកិច្ចប្រជុំ Rio+20។ តាមនិយមន័យ ទស្សនៈស្តីពីសេដ្ឋកិច្ចបៃតង បានផ្តល់ជាលទ្ធផលមកវិញនូវសុខមាលភាពល្អប្រសើរដល់មនុស្ស និង សមភាពសង្គម ក៏ដូចជាកាត់បន្ថយហានិភ័យបរិស្ថាន ការខូចខាតប្រព័ន្ធអេកូឡូស៊ី (ប្រភព UNEP ឆ្នាំ២០១២)។

តាមសំនួនសេចក្តីដ៏ងាយយល់ សេដ្ឋកិច្ចបៃតងអាចជាការគិតថាជាសេដ្ឋកិច្ច ដែលរួមបញ្ចូលសារធាតុកាបូនទាប ធនធានគ្រប់គ្រាន់ និងមានលក្ខណៈសង្គម ។ ជាក់ស្តែង សេដ្ឋកិច្ចបៃតង គឺជាការកើនឡើងនៃចំណូល និងការងារដែលផ្តល់ឲ្យតាមរយៈការវិនិយោគជាសាធារណៈ និងឯកជន ដែលអាចកាត់បន្ថយការបំភាយកាបូន និងការបំផុលបរិស្ថាន សំដៅជម្រុញឲ្យប្រសើរនូវថាមពល និងប្រសិទ្ធភាពធនធានព្រមទាំងបង្ការការបាត់បង់ជីវចម្រុះ និងសេវាកម្មបរិស្ថានផងដែរ ។ ផ្លូវសម្រាប់ការអភិវឌ្ឍនេះ គួរតែរក្សាឲ្យបានជម្រុញឲ្យបាន និងចាំបាច់គួរតែកសាងឡើងវិញនូវមូលធនធម្មជាតិ សម្រាប់ធ្វើជាធនធានសេដ្ឋកិច្ចដ៏មានសារៈសំខាន់ និងជាប្រភពនៃអត្ថប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រដែលការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ និងសន្តិសុខរបស់គាត់ពឹងផ្អែកយ៉ាងខ្លាំងទៅលើធម្មជាតិ។

និយមន័យនេះប្រហាក់ប្រហែលទៅនឹងនិយមន័យ ដែលបានកំណត់ដោយគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD ២០០០) និង ពិធីសារស្តីពីការវាយតម្លៃនិរន្តរភាពវារីអគ្គិសនី (HSAF) របស់សមាគមវារីអគ្គិសនីអន្តរជាតិ (IHA) ដែលបានផ្តល់អាទិភាពចំពោះបញ្ហានានាទាក់ទងនឹងសមភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។ នេះមានន័យថា ជាការផ្តោតលើការអភិវឌ្ឍសមត្ថភាព និងការងារថ្នាក់មូលដ្ឋាន ធ្វើឲ្យមានតុល្យភាពលំហូរនៃមូលធន និង ធនធានដែលបានពីតំបន់ទីជនបទ និងកិច្ចការពារបរិស្ថាន និងធនធានក្នុងតំបន់ដែលប្រជាជានពឹងអាស្រ័យលើ។

៣.១.២ ទស្សនៈនៃការធ្វើឲ្យមាននិរន្តរភាព

ទស្សនៈនៃការធ្វើឲ្យមាននិរន្តរភាព ត្រូវបានកំណត់ឡើងនាឆ្នាំ១៩៨៧ ដោយគណៈកម្មការពិភពលោក ទទួលបន្ទុកបរិស្ថាន និងការអភិវឌ្ឍន៍ (WCED)។ ទស្សនៈនេះ គឺជាកិច្ចអភិវឌ្ឍដែលឆ្លើយតបចំពោះ " សេចក្តីត្រូវការនៅក្នុងសម័យកាលបច្ចុប្បន្ន ដោយគ្មានការសម្រុះសម្រួលអំពីលទ្ធភាពសម្រាប់សម័យកាលអនាគតក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ខ្លួន" ។ សេចក្តីថ្លែងការណ៍ទីក្រុងរីយ៉ូស្តីពីបរិស្ថាន និង ការអភិវឌ្ឍន៍ បានបរិយាយយ៉ាងលម្អិតលើគោលការណ៍១៨ចំនុច ស្តីពីការធ្វើឲ្យមាននិរន្តរភាព ។ បច្ចុប្បន្នទស្សនៈនេះត្រូវបានទទួលស្គាល់ជាទូទៅថា បានផ្សាភ្ជាប់នូវការរួមបញ្ចូលគ្នារវាងសសរស្តម្ភទាំង៣នៃការអភិវឌ្ឍប្រកបដោយចីរភាព ៖ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយដែលត្រូវការសិទ្ធិជាមូលដ្ឋាន ដំណើរការប្រកបដោយសមភាព និង ដោយរួមសហការគ្នា ដែលអាចឈានដល់ការលើកកម្ពស់និរន្តរភាពនៅថ្នាក់ពិភពលោក តំបន់ជាតិ និងថ្នាក់មូលដ្ឋាន។

ឆ្នាំ២០១២ គឺជាឆ្នាំអន្តរជាតិស្តីពីថាមពលប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា ។អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានបង្កើតឲ្យមានគម្រោងផ្តួចផ្តើមគំនិតមួយ ឈ្មោះថា (SE4ALL) និងបានធ្វើសេចក្តីរាយការណ៍ ដូច្នេះថា ៖

" ៥. គោលដៅសហស្សវត្សរ៍អាចសម្រេចជោគជ័យទៅបាន អាស្រ័យលើការទទួលបាននូវសេវាថាមពលទំនើប ។

៦. ការដែលមានសេវាថាមពលគ្រប់គ្រាន់ ងាយស្រួលរកបាន និងអាចជឿជាក់បាន គឺជាកត្តាសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ ធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពរបស់មនុស្ស បង្កើន កម្រិតជីវភាព និងអាចធ្វើឲ្យការអភិវឌ្ឍប្រកបដោយចីរភាព អាចសម្រេចដល់គោលដៅនៅទីបំផុត។ សេវាថាមពល

ប្រកបដោយ ចីរភាពគ្រប់គ្រាន់ គឺជាមធ្យោបាយក្នុងការផ្តល់ដល់មនុស្សនូវសុខភាព ការអប់រំ ការដឹកជញ្ជូន ទូរគមនាគមន៍ ទឹកស្អាត និងអនាម័យ ។

៧. ការសម្រេចគោលដៅថាមពលប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា ត្រូវជាប់ពាក់ព័ន្ធ ជាមួយនឹងការបង្កើតឲ្យមានប្រព័ន្ធទាំងឡាយដែលគាំទ្រដល់ការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវប្រភពថាមពល នានាក្នុងលក្ខណៈសមភាព និងរួមគ្នា ស្របពេលជាមួយការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ហេដ្ឋារចនាសម្ព័ន្ធចម្រុះថ្នាក់ជាតិ និងថ្នាក់តំបន់ ទាក់ទងនឹងការផ្គត់ផ្គង់ថាមពល ការបញ្ជូនថាមពលដោយមានប្រសិទ្ធភាព ប្រព័ន្ធ ចែកចាយ និងការរៀបចំកម្មវិធីតម្រូវការ ដែលបញ្ជាក់អំពីប្រសិទ្ធភាពនៃថាមពល គឺជាការចាំបាច់សម្រាប់ប្រព័ន្ធ ថាមពលប្រកបដោយចីរភាព " ។

៣.១.៣ គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD)

អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលរដ្ឋាភិបាល អង្គការសង្គមស៊ីវិល មន្ត្រីកិច្ចការអភិវឌ្ឍន៍ ក្រុមហ៊ុនឧស្សាហកម្ម និង អ្នកគាំទ្រសកម្មភាពវិស័យឯកជន បានជជែកដេញដោលគ្នាអំពីការចំណាយ និងចំណូលដែលបានមកពីទំនប់វារីអគ្គិសនីធំៗ ។ នៅក្នុងពេលថ្មីៗនេះ គ្មានការសាងសង់ទំនប់វារីអគ្គិសនីណាមួយដែលកម្រនឹងជៀសផុតណាស់ពីភាពចម្រូងចម្រាសផ្នែកបរិស្ថាន សង្គម និងនយោបាយ ហើយនៅទសវត្សរ៍ទី៩០ ភាពចម្រូងចម្រាសទាំងនេះ ត្រូវបានមើលឃើញថាមានទំហំរឹតតែធំឡើង ។ ក្រុមអ្នកគាំទ្របានគូសបញ្ជាក់ថា ផលប្រយោជន៍នៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដែលទំនប់វារីអគ្គិសនីអាចទាញយកបានមានដូចជា ការផ្តល់នូវថាមពលអគ្គិសនី ធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹក។ក្រុមអ្នករិះគន់នានាបានលើកឡើងថា ការផ្តល់មូលនិធិដល់គម្រោង ទោះជាគម្រោងសាធារណៈក្តី និង/ឬឯកជនក្តី កំពុងអនុវត្តជាលក្ខណៈប្រព័ន្ធ ដោយចាត់ទុកថាផលប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីទំនប់វារីអគ្គិសនី មិនសូវជាសំខាន់ និងបានពន្លើសពីផលប្រយោជន៍នានា។ នៅពាក់កណ្តាលទសវត្សរ៍ទី៩០ បើតាមការប៉ាន់ស្មាន ទំនប់វារីអគ្គិសនីអាចមានចំនួន៨០០.០០០កន្លែងនៅទូទាំងពិភពលោក ដែលបានធ្វើឲ្យប្រជាពលរដ្ឋចំនួនពី៥០ទៅ៨០លាននាក់បាន បំលាស់ទីជម្រក និងរស់ក្នុងភាពតោកយ៉ាកដោយសារទំនប់ទាំងនោះ ព្រមទាំងបង្កឲ្យមានភាពចម្រូងចម្រាសជាច្រើននៅថ្នាក់អន្តរជាតិ លើការអនុញ្ញាតឲ្យមានគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតធំៗបន្ថែមទៀត។

នៅខែមេសា ឆ្នាំ១៩៩៧ អង្គការសម្ព័ន្ធអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) និងធនាគារពិភពលោក (WB) បានឧបត្ថម្ភឲ្យមានការរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់តូចមួយ នៅទីក្រុងគ្លេន (Gland) នៃប្រទេស ស្វីតសឺឡេន។ ក្រុមអ្នកតំណាងផលប្រយោជន៍ផ្សេងៗ បានមកជួបប្រជុំញ្ជាដើម្បីពិភាក្សាលើបញ្ហាចម្រូងចម្រាស ចម្បងៗទាក់ទងនឹងទំនប់វារីអគ្គិសនីធំៗ។ សិក្ខាកាមមានការភ្ញាក់ផ្អើលចំពោះភាពខុសស្រឡះនៃអត្ថប្រយោជន៍ ពីការអភិវឌ្ឍពីទំនប់វារីអគ្គិសនីធំៗ ដែលមិនបានរាំងដល់ភាពស្រុះស្រួលគ្នាមួយ ដែលជុសចេញជាតម្រូវការមធ្យោបាយថ្មីសម្រាប់ឈានឆ្ពោះទៅមុខ ហើយដែលត្រូវបានបង្កើតឡើងដោយភាគីពាក់ព័ន្ធចម្រុះនៃគណៈ-កម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD)។

នាខែកុម្ភៈ ឆ្នាំ១៩៩៨ គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ត្រូវបានបង្កើតឡើងនិងបានចាប់ផ្តើមការងាររបស់ខ្លួនក្រោមការដឹកនាំរបស់សាស្ត្រាចារ្យកាដឺអាសម៉ាល (Professor Kader

Asmal)។ គណៈកម្មការនេះ មានសមាជិកចំនួន១២រូប ដែលបានជ្រើសរើសតាមរយៈដំណើរការស្រាវជ្រាវជាសកល ក្នុងការឆ្លុះបញ្ចាំងភាពផ្សេងគ្នានៅតាមតំបន់ សមត្ថភាពជំនាញ និងការផ្លាស់ប្តូរទស្សនវិស័យរបស់ភាគីពាក់ព័ន្ធ។ គណៈកម្មការនេះ មានលក្ខណៈអព្យាក្រឹត ចំណែកសមាជិកទាំងអស់ត្រូវបំពេញតួនាទីដោយផ្អែកលើសមត្ថភាពជំនាញរៀងៗខ្លួន ហើយមិនមែនជាតំណាងស្ថាប័ន ឬប្រទេសណាមួយឡើយ។

គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី បានចាប់ផ្តើមជាដំបូងដោយការប្រមូលផ្តុំចំណេះដឹងជារួមមួយ ផ្អែកទៅតាមបទពិសោធន៍ជាសកលក្នុងផ្នែកទំនប់វារីអគ្គិសនីធំៗ ។ ដើម្បីផ្តល់នូវការវិភាគ និងការសំយោគជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយរបស់ខ្លួន គណៈកម្មការនេះបានរៀបចំ ឬទទួលស្គាល់នូវ ៖

- ករណីសិក្សាស៊ីជម្រៅទៅលើទំនប់វារីអគ្គសនីធំៗនៅក្នុងទ្វីបទាំង៥ ជាមួយនឹងប្រទេសជាដៃគូ២។
- ការអង្កេតសិក្សាស៊ីជម្រៅទៅលើទំនប់វារីអគ្គិសនីធំៗចំនួន១៥០ នៅក្នុងប្រទេសចំនួន៥៦។
- ការពិនិត្យលើឯកសារគោលចំនួន១៧ ដែលបានចងក្រងជាក្រុមទៅតាមទិដ្ឋភាព នៃកិច្ចជជែកពិភាក្សាចំនួន៥។
- ការពិគ្រោះយោបល់ថ្នាក់តំបន់ចំនួន៤។
- ខ្លឹមសារផ្តល់ដោយភាគីបុគ្គល ក្រុមភាគីផ្សេងៗ និងស្ថាប័នពាក់ព័ន្ធនានា។

តាមរយៈការវិភាគទៅលើមូលដ្ឋាននៃការយល់ដឹង បានបង្ហាញថា ទោះបីទំនប់វារីអគ្គិសនីមួយចំនួនទទួលបានជោគជ័យ ប៉ុន្តែទំនប់ធំៗជាច្រើនទទួលបរាជ័យទាំងគោលដៅសំណង់ និងសេដ្ឋកិច្ច ដែលបានបង្កជាការខូចខាតមិនអាចត្រឡប់វិញបានលើប្រព័ន្ធអេកូឡូស៊ីក្នុងទន្លេ ព្រមទាំងបង្កជាផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់ប្រជាសហគមន៍ទៀតផង។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០០ មានការបោះពុម្ពផ្សាយនូវរបាយការណ៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ដែលមានចំណងជើងថា " ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍន៍ ៖ បទដ្ឋានថ្មីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត " ។ របាយការណ៍នេះ ចែកចេញជាផ្នែកសំខាន់ៗជាច្រើន រួមមាន របាយការណ៍សង្ខេប របាយការណ៍គន្លឹះនិងមូលដ្ឋានចំណេះដឹង ដែលផ្នែកទាំងអស់នេះអាចរកឃើញនៅក្នុងគេហទំព័រ (http://www.dam.org) និងមានជាស៊ីឌីផងដែរ។ របាយការណ៍ទាំងអស់នេះសរុបមានជាង៥០០០ទំព័រ ប្រមូលផ្តុំទៅដោយចំណេះដឹងជាបទពិសោធន៍អំពីទំនប់វារីអគ្គិសនីជាច្រើន។

គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី បានស្នើមធ្យោបាយមួយសម្រាប់ជាការឈានឆ្ពោះទៅមុខ តាមរយៈ ៖

- វិធីសាស្ត្រដោយផ្អែកលើការទទួលស្គាល់សិទ្ធិ និងការវាយតម្លៃលើហានិភ័យនានា។
- គុណតម្លៃស្នូលចំនួន៥យ៉ាង ៖
  - សមភាព

- ប្រសិទ្ធភាព
- ការសម្រេចចិត្តដោយមានការចូលរួម
- និរន្តរភាព
- គណនេយ្យភាព

- អាទិភាពជាយុទ្ធសាស្ត្រទាំង៧ ៖
  - ការទទួលបាននូវការយល់ព្រមជាសាធារណៈ
  - ការវាយតម្លៃលើជម្រើសដែលមានលក្ខណៈទូលំទូលាយ
  - ការប្រកាសបញ្ជាក់ពីទំនប់វារីអគ្គិសនីដែលកំពុងមាន
  - ការធានានិរន្តភាពនៃទន្លេ និងការប្រកបរបរចិញ្ចឹមជីវិត
  - ការទទួលស្គាល់ភាពជាកម្មសិទ្ធិ និងការបែងចែកផលប្រយោជន៍
  - ការធានាចំពោះការព្រមព្រៀងអនុវត្តតាមច្បាប់
  - ការចែករំលែកទន្លេសម្រាប់សន្តិភាព ការអភិវឌ្ឍ និងសន្តិសុខ
- ចំនុចជាគោលការណ៍ទាំង២៦ សម្រាប់ការអនុវត្តអាទិភាពជាយុទ្ធសាស្ត្រ

បន្ទាប់ពីការបំពេញតួនាទីនៅក្នុងអាណត្តិការងាររបស់ខ្លួន គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនីត្រូវបានរំលាយ ដោយបន្សល់ទុកនូវពាក្យថា ៖ " យើងបានប្រាប់ឲ្យអ្នកទាំងអស់ដឹងរួចហើយ អំពីរឿងរ៉ាវរបស់យើង។ អ្វីដែលនឹងកើតឡើងនាពេលបន្ទាប់ គឺអាស្រ័យលើខ្លួនអ្នក " ។

៣.១.៤ គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) និងឯកសារអនុវត្ត

ដើម្បីកុំឲ្យបាត់បង់ឯកសារអនុវត្តដែលចងក្រងរួច ដោយគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី និង ក្នុងនាមជាអង្គភាពអព្យាក្រឹតទទួលបន្ទុកក្នុងការចែកផ្សាយរបាយការណ៍របស់គណៈកម្មការ ក៏ដូចជាការបន្តពិនិត្យសារជាថ្មីឡើងវិញលើអនុសាសន៍នានារបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន តាមរយៈកិច្ចជជែកពិភាក្សារួមគ្នារបស់ពហុភាគីពាក់ព័ន្ធ គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP) បានព្រមព្រៀងដាក់ចេញនូវគម្រោងផ្តួចផ្តើមគំនិតបន្តមួយ មានឈ្មោះថា គម្រោងទំនប់វារីអគ្គិសនី និង ការអភិវឌ្ឍន៍ (DDP) ។ គម្រោង (DDP) នេះ ចែកចេញជា៤ផ្នែកសំខាន់ៗ ដូចខាងក្រោម ៖

- ការជម្រុញលើកកម្ពស់កិច្ចជជែកពិភាក្សារបស់ភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក។
- ការពិនិត្យយ៉ាងលម្អិតទៅលើឧបករណ៍អនុវត្តដោយគ្មានបញ្ឆត្ត។
- ការចងក្រងបណ្តាញ និងការទំនាក់ទំនង។
- ការផ្សព្វផ្សាយព័ត៌មាន។

គោលបំណងរបស់គម្រោង (DDP) នៅជំហានទីពីរ និងជំហានចុងក្រោយសម្រាប់ឆ្នាំ ២០០៥-២០០៧ មានដូចជា ៖

- ដើម្បីគាំទ្រកិច្ចពិភាក្សារបស់ពហុភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ តំបន់ និងពិភពលោក ចំពោះការធ្វើសេចក្តីសម្រេចចិត្តស្តីពីទំនប់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន ដោយសំដៅឲ្យមានការចូលរួមពាក់ព័ន្ធពីភាគីពាក់ព័ន្ធទាំងអស់ តាយរយៈការគូសបញ្ជាក់ពីរដ្ឋាភិបាល។
- ដើម្បីផលិតឧបករណ៍អនុវត្តដោយគ្មានបញ្ហាត្តិ ដែលអាចជាជំនួយដល់អ្នកធ្វើការសម្រេចចិត្តដោយការទាញយកនូវលក្ខណៈសម្បត្តិ និង គោលការណ៍ពាក់ព័ន្ធដែលមានស្រាប់ សំដៅរៀបចំ ផែនការ និងការគ្រប់គ្រងទំនប់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន ។

លទ្ធផលនៃគោលបំណងទីពីរនេះ គឺការផលិត " ឯកសារស្តីពីការអនុវត្តលើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈល្អប្រសើរពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនី និងការបញ្ចៀសហានិភ័យនានា " ។ ឯកសារនេះ គឺជាឧបករណ៍ព័ត៌មានសម្រាប់ជាជំនួយដល់អ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកជំនាញការ និងភាគីពាក់ព័ន្ធដទៃទៀត ក្នុងការរៀបចំផែនការ និងគ្រប់គ្រងទំនប់វារីអគ្គិសនី និងការបញ្ចៀសហានិភ័យនានា ។ ឯកសារនេះ មាននិយាយអំពីប្រធានបទគន្លឹះស្តីពីបរិស្ថាន និងសង្គម (ប្រអប់អត្ថបទ ៣.១) ដែលបានកំណត់ជាអាទិភាពនៅក្នុងដំណើរការនៃគម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) ហើយផ្តល់ជាឧទាហរណ៍គំរូស្តីពីការអនុវត្តពាក់ព័ន្ធដែលត្រូវបានអនុវត្តកន្លងមក។

ប្រអប់អត្ថបទ៣.១ បញ្ហាគន្លឹះត្រូវដោះស្រាយតាមរយៈឯកសារ
• ការកំណត់ឲ្យបានច្បាស់លាស់លើជម្រើសនានា (ជំពូក២)។ • ការចូលរួមរបស់ភាគីពាក់ព័ន្ធ (យន្តការនានា) (ជំពូក៣)។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម និងការលើកឡើងអំពីបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ (ជំពូក៤)។ • គោលការណ៍នៃការទូទាត់សំណង និងយន្តការបែងចែកផលប្រយោជន៍ (ជំពូក៥)។ • ផែនការគ្រប់គ្រងបរិស្ថាន (ជំពូក៦)។ • ការយល់ព្រមអនុវត្តតាម (ជំពូក៧)។ • គោលការណ៍អន្តរជាតិកស្តីពីចំណែកទន្លេ (ជំពូក៨)។

៣.១.៥ ការគម្រាមកំហែងដល់ថាមពលវារីអគ្គិសនី

ដោយសារតែគម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) មិនទាន់ត្រូវបានចងក្រង ទើបសមាគមវារីអគ្គីសនីអន្តរជាតិ (IHA) បានប្រកាសដាក់ឲ្យប្រើប្រាស់នូវគម្រោងផ្តួចផ្តើមគំនិតរបស់ខ្លួន ។ ជំហររបស់សមាគមចំពោះរបាយការណ៍របស់គណៈកម្មការពិភពលោក ទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) គឺការទទួលយកគុណតម្លៃសំខាន់នានា ប៉ុន្តែមិនមែនអាទិភាពជាយុទ្ធសាស្ត្រ ឬគោលការណ៍ទាំងអស់ឡើយ ។ គោលការណ៍ស្តីពីនិរន្តរភាពនៃសមាគមវារីអគ្គីសនីអន្តរជាតិឆ្នាំ២០០៤ និងពិធីសារវាយតម្លៃស្តីពីនិរន្តរភាពឆ្នាំ២០០៦ ត្រូវបាន បោះពុម្ពផ្សាយរួចហើយ។ កិច្ចខិតខំប្រឹងប្រែងជាលើកដំបូងទាំងនេះ គឺការ

ផ្សព្វផ្សាយតាមរយៈអង្គការអន្តរជាតិមួយចំនួន អំពីទស្សនៈជាមូលដ្ឋាននៃឧស្សហកម្ម វារីអគ្គិសនី និងឯកសារនានាដែលមិនត្រូវបានទទួលនូវការជឿជាក់ខ្លាំងឡើយ។

ផ្អែកលើការជឿទុកចិត្តរបស់ខ្លួននៅឆ្នាំ ២០០៨ សមាគមនេះបានប្រកាសដាក់ឲ្យប្រើប្រាស់នូវគម្រោងផ្លូចផ្តើមគំនិតថ្មីមួយទៀតស្តីពីពិធីសារ ដូចគ្នានឹងគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី(WCD) និងគម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) ដែរ ដែលបានដំណើរការតាមរយៈវេទិកាអន្តរជាតិមួយរបស់ភាគីពាក់ព័ន្ធ ដែលជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ចល្អ។ វេទិកានេះត្រូវបានចូលរួមដោយអ្នកតំណាងនៃអង្គការនានាដែលបម្រើការងារលើពហុវិស័យ ហើយដែលមានទស្សនៈ និងគោលនយោបាយផ្សេងៗគ្នាលើបញ្ហានិរន្តរភាពនៃការអភិវឌ្ឍ និងប្រតិបត្តិការវិស័យថាមពលវារីអគ្គិសនី ។ សមាជិកទាំង១៤នៃវេទិកានេះ រួមមានតំណាងរដ្ឋាភិបាលនៃប្រទេសអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍ ធនាគារពាណិជ្ជកម្ម និងធនាគារអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលធ្វើការលើផ្នែកសង្គម និង បរិស្ថាន ព្រមទាំងតំណាងក្រុមហ៊ុនវារីអគ្គិសនីផងដែរ។ បន្ទាប់ពីបានអនុវត្តការងាររបស់ខ្លួន អស់រយៈពេល២ឆ្នាំកន្លះរួចមក ពិធីសារដែលបានពិនិត្យសារឡើងវិញរួច ត្រូវបានបោះពុម្ពផ្សាយនាឆ្នាំ២០១១ ។ គោលការណ៍ទាំងឡាយត្រូវបានដាក់បញ្ចូលទៅក្នុងពិធីសារ ដែលមាននៅក្នុង (ប្រអប់អត្ថបទ៣.២) ។

ពិធីសារនេះ ត្រូវបានដឹកនាំត្រួតពិនិត្យដោយក្រុមប្រឹក្សាវាយតម្លៃ ស្តីពីនិរន្តរភាពថាមពលវារីអគ្គិសនី ។ មានជំពូកមួយ បានកំណត់អំពីវិធាននានាទាក់ទងនឹងការបង្កើតក្រុមប្រឹក្សា និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានេះ ចំណែករយៈពេលកំណត់ និងលក្ខខ័ណ្ឌនៃការប្រើប្រាស់ពិធីសារនេះ ត្រូវបានអនុម័តនៅក្នុងខែមិថុនា ឆ្នាំ២០១១។

ឯកសារគន្លឹះទាំងនេះមាននៅក្នុងគេហទំព័រ www.hydrosustainability.org ។

ប្រអប់អត្ថបទ៣.២ គោលការណ៍ពិធីសារស្តីពីការវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី
ពិធីសារស្តីពីការវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី គឺបទដ្ឋានមួយនៃការវាយតម្លៃអំពីនិរន្តរភាពសម្រាប់ការអភិវឌ្ឍ និងប្រតិបត្តិការវារីអគ្គិសនី។ គោលការណ៍ទាំងឡាយដែលបានដាក់បញ្ចូលទៅក្នុងពិធីសារនេះ រួមមាន ៖ • ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាការអភិវឌ្ឍមួយដែលឆ្លើយតបនឹងតម្រូវការនៃសម័យកាលបច្ចុប្បន្ន ដោយគ្មានការសម្រុះសម្រួលអំពីលទ្ធភាព សម្រាប់សម័យកាលអនាគតក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ខ្លួន។ • ការអភិវឌ្ឍប្រកបដោយចីរភាព តំណាងឲ្យការកាត់បន្ថយភាពក្រីក្រ ការគោរពសិទ្ធិមនុស្ស ការផ្លាស់ប្តូរលំនាំនៃការផលិត និង ប្រើប្រាស់មិនមាននិរន្តរភាព ភាពអាចសម្រេចបាន ផ្នែកសេដ្ឋកិច្ចយូរអង្វែង មូលដ្ឋាននៃការការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថានប្រកបដោយការទទួលខុសត្រូវ។ • ការអភិវឌ្ឍប្រកបដោយចីរភាព តម្រូវឲ្យមានការគិតគូពីថាមពលបន្ថែម និងតុល្យភាពរវាងគុណតម្លៃសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ តុល្យភាពនេះ គួរតែធ្វើឲ្យសម្រេចបាន និងធានាឲ្យមានលក្ខណៈ

តម្លាភាព និងគណនេយ្យភាព ដោយទទួលបានអត្ថប្រយោជន៍ក្នុងការពង្រីកចំណេះដឹង ទស្សនវិស័យ ចម្រុះ និង គំនិតថ្មីៗ។

- ការទទួលខុសត្រូវលើសង្គម តម្លាភាព និងគណនេយ្យភាព គឺជាគោលការណ៍ស្នូលនៃនិរន្តរភាព។
- ការអភិវឌ្ឍ និងការគ្រប់គ្រងថាមពលវារីអគ្គិសនីប្រកបដោយចីរភាព អាចផ្តល់មកវិញនូវអត្ថប្រយោជន៍ដល់ប្រទេស តំបន់ និង មូលដ្ឋាន និង មានសក្តានុពលដើរតួនាទីក្នុងការជួយជម្រុញសហគមន៍ឲ្យសម្រេចដល់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ពិធីសារនេះ អាចជួយជម្រុញឲ្យមានការបង្កើតទម្រង់ស្តីពីនិរន្តរភាពសម្រាប់គម្រោងមួយ តាមរយៈការវាយតម្លៃលើការអនុវត្តការងារក្នុងក្របខ័ណ្ឌនៃប្រធានបទសំខាន់ៗស្តីពីនិរន្តរភាព ។ ដើម្បីឆ្លុះបញ្ចាំងពីជំហាន ខុសៗគ្នានៃការអភិវឌ្ឍថាមពលវារីអគ្គិសនី ពិធីសារបានបែងចែកចេញជា៤ផ្នែក ដែលត្រូវបានរៀបចំឡើង សម្រាប់ប្រើប្រាស់ធ្វើជាឯកសារគោលដែលមានតែមួយគត់ ។ តាមរយៈការវាយតម្លៃលើការរំពឹងទុកជាមូលដ្ឋាន និង មានកម្រិតខ្ពស់ ឧបករណ៍ជំហានដំបូងអាចយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃពីហានិភ័យនានា និងសម្រាប់កិច្ចពិភាក្សាមុននឹងឈានទៅដល់ការរៀបចំផែនការលម្អិត។ ឯកសារចំនួន៣ដែលនៅសេសសល់ រួមមានឯកសារស្តីពីការត្រោមរៀបចំ ឯកសារស្តីពីការអនុវត្ត ឯកសារស្តីពីការប្រតិបត្តិការ បានបង្ហាញពីគំនិតនៃការអនុវត្តគ្រប់ជ្រុងជ្រោយប្រកបដោយគុណភាព ក្រិតតាមខ្នាតនៃការលើកឡើងពីការអនុវត្តល្អប្រសើរជាមូលដ្ឋាន និងការអនុវត្តល្អបំផុត។ ការអនុវត្តប្រកបដោយគុណភាពលើប្រធានបទនីមួយៗស្តីពីនិរន្តរភាព អាចផ្តល់ឱកាសផងដែរក្នុងការជម្រុញឲ្យមានភាពកាន់តែប្រសើរឡើងជាលក្ខណៈរចនាសម្ព័ន្ធ និងជាបន្តទៅទៀត។

ការវាយតម្លៃនានា ត្រូវពឹងផ្អែកលើគោលបំណងជាក់លាក់ សំដៅគាំទ្រដល់ការឲ្យពន្ទុទៅលើប្រធានបទនីមួយៗ ដែលមានលក្ខណៈពិតប្រាកដ អាចអនុវត្តតាមបានច្បាស់លាស់ និងដោយមានការផ្ទៀង-ផ្ទាត់ត្រឹមត្រូវ។ ប្រព័ន្ធវាយតម្លៃ អាចផ្តល់មកវិញនូវការជឿជាក់ទៅលើអ្នកធ្វើការវាយតម្លៃដោយឯករាជ្យ ។ ពិធិសារអាចនឹងមានប្រសិទ្ធភាពបំផុតនៅពេលមានការការដាក់បញ្ចូលប្រព័ន្ធ និង ដំណើរការកិច្ចការងារបែបនេះ។ លទ្ធផលនៃការវាយតម្លៃ អាចយកមកប្រើប្រាស់បាន ដើម្បីផ្តល់ជាព័តមានដល់ការសម្រេចចិត្តនានា កំណត់ជាអាទិភាពការងារទៅអនាគត និង/ឬដើម្បីជាជំនួយ ក្នុងការពិភាក្សានៅខាងក្រៅ។

៣.១.៦ ជម្រើសដែលអាចជំនួសបានទាក់ទងនឹងទឹក WCD+10 :

នៅក្នុងឆ្នាំ២០១០ " ជម្រើសដែលអាចជំនួសបានទាក់ទងនឹងទឹក " គឺជាសៀវភៅទនានុប្បវត្តិហ្វឹកហ្វឺនមួយតាមប្រព័ន្ធកុំព្យូទ័រទៅវិញទៅមក ដែលមានលើកឡើងអំពីបញ្ហាជាច្រើនទាក់ទងនឹងទឹកដែលបានកើតមានឡើងនៅក្នុងសង្គមសហសម័យ ត្រូវបានបោះពុម្ពការចេញផ្សាយពិសេសមួយដែលមានរចនាបទជា WCD+10 ។ គោលបំណងនៃ WCD+10 គឺផ្តល់ឱកាសរយៈពេល១០ឆ្នាំ បន្ទាប់ពីគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) បានពិចារណាយ៉ាងយកចិត្តទុកដាក់អំពីការវិវត្តន៍ផ្លាស់ប្តូរនៃការគិតអំពីភាពស្មុគស្មាញ និងបញ្ហាផ្សេងៗដែលនៅតែកើតមានជុំវិញការសម្រេចចិត្តនានាទៅលើទំនប់វារី

អគ្គិសនី និងការអភិវឌ្ឍ។ នៅក្នុងការត្រួតពិនិត្យមួយសារជាថ្មី ដោយផ្អែកលើសំណៅឯកសារនានាដែលបានបានដាក់ស្នើ អ្នកបោះពុម្ពផ្សាយបានរកឃើញនូវសំណៅ ដូចខាងក្រោម ៖

- ទស្សនវិស័យមានលក្ខណៈខុសគ្នាអាស្រ័យលើផលប៉ះពាល់នៃរបាយការណ៍ និង ដំណើរការរបស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD)។
- តម្រូវការទឹក និងថាមពល បន្តកើនឡើង និងនាំទៅដល់ការអភិវឌ្ឍទំនប់វារីអគ្គិសនី។
- ការប្រែប្រួលអាកាសធាតុ នាំទៅដល់ការការពង្រីកថាមពលវារីអគ្គិសនីយ៉ាងធំសម្បើមនាពេលបច្ចុប្បន្ន។
- អ្នកជំនាញថ្មីៗខាងហិរញ្ញវត្ថុ បានចាប់ផ្តើមផ្លាស់ប្តូរទីតាំង និង បទដ្ឋានសម្រាប់ដំណើរការនានានៃការធ្វើសេចក្តីសម្រេចចិត្ត។
- ផលវិបាកជាអវិជ្ជមាននានានៃទំនប់វារីអគ្គិសនីទៅលើបរិស្ថាន និង ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍រងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនី នៅតែជាបញ្ហាដ៏រសើប។
- ការស្វែងរកឧបករណ៍ និងវិធីសាស្ត្រថ្មីទាក់ទងនឹងការសម្រេចចិត្ត នៅតែបន្តធ្វើចាប់ពីពិធីសារស្តីពីការវាយតម្លៃ រហូតដល់ការវិភាគផ្នែកសេដ្ឋកិច្ច ។
- តើការចូលរួម ការព្រមព្រៀង គណនេយ្យភាព និងការអនុវត្តការងារ ត្រូវធានាដោយរបៀបណា?
- វេទិកាសម្រាប់ពហុភាគីពាក់ព័ន្ធ (MSPs) នៅតែបន្តបង្ហាញពីការសន្យា ក្នុងការផ្តល់ព័ត៌មាន និងការរៀបចំឲ្យមានកិច្ចព្រមព្រៀង តាមរយៈការចចារដែលនឹងផ្តល់ជាលទ្ធផលក្នុងការបែងចែកឲ្យបានល្អប្រសើរជាងមុននូវធនធាន អត្ថប្រយោជន៍ និង ការចំណាយទាក់ទងនឹងទំនប់វារីអគ្គិសនី។

អ្នកបោះពុម្ពផ្សាយ បានធ្វើការសន្និដ្ឋានចុងក្រោយថា ឯកសារនានាក៏មានបង្ហាញអំពីតម្រូវការនៃការពិភាក្សាឡើងវិញពីសំណាក់ពហុភាគីពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់។ ការពិភាក្សានេះ នឹងមិនមែនជាការធ្វើសារថ្មីឡើងវិញ ដូចដែលគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) បានធ្វើនោះឡើយ ប៉ុន្តែនេះគ្រាន់តែជាការធ្វើឲ្យមានជាថ្មីម្តងទៀត និងរៀបចំឡើងវិញនូវដំណើរការ និងវេទិកានានាដើម្បីជាការស្វែងយល់ពីគ្នាទៅវិញទៅមក ជាការចែករំលែកព័ត៌មានទៅវិញទៅមក និងជាការកំណត់ឲ្យមានជាបទដ្ឋានច្បាស់លាស់ តែប៉ុណ្ណោះ។

៣.១.៧ អាងទន្លេមេគង្គ

អាងទន្លេមេគង្គត្រូវបានផ្លាស់ប្តូរទ្រង់ទ្រាយជា៣ផ្នែកសំខាន់ (១) ការផ្លាស់ប្តូរ និងបញ្ហាប្រឈមជុំវិញការអភិវឌ្ឍវារីអគ្គិសនី ដោយសារកំណើនសេដ្ឋកិច្ចឆាប់រហ័សនៅក្នុងអនុតំបន់ទន្លេមេគង្គ (GMS) និងការឡើងថ្លៃនៃប្រេងឥន្ធនៈ (២) ទន្លេផ្តល់ជាការប្រកបរបរចិញ្ចឹមជីវិតដល់មនុស្សរាប់លាននាក់ តាមរយៈព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម ជលផល និងការធ្លាក់ភ្លៀង និងធារាសាស្ត្រសម្រាប់កសិកម្ម និង

(៣) មិនមានប្រព័ន្ធអភិបាលកិច្ច និង គ្រប់គ្រងជារួម ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយចំពោះផលប៉ះពាល់ទៅលើខ្សែទឹកសំខាន់ៗ និង ការហូរចាក់ទៅក្នុងទន្លេ ដោយសារវាជាទន្លេឆ្លងកាត់ប្រទេសផ្សេងៗទៀត (ប្រភព Molle, Foran and Kakonen 2009)។

អាងទន្លេ ត្រូវបានចាត់ចែងរួមដោយអង្គការអន្តរដ្ឋាភិបាល ដែលហៅថា គណៈកម្មការទន្លេមេគង្គ (MRC) ដែលមានអាណត្តិរបស់ខ្លួនក្នុងការជម្រុញការអភិវឌ្ឍធនធានទឹកនៅ " ទន្លេមេគង្គក្រោម " ដែលជាផ្នែកមួយនៃអាងទន្លេមេគង្គដែលស្ថិតក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ តាមរយៈវេទិកាផ្លាស់ប្តូរព័ត៌មាន ប្រជាជនបានអំពាវនាវឲ្យគណៈកម្មការទន្លេមេគង្គធ្វើជាអ្នកថែរក្សាការពារផ្នែកសង្គម និងបរិស្ថាននៃអាងទន្លេនេះ ជាអ្នកផ្តល់ចំណេះដឹង ជាអ្នកប្រមូលផ្តុំគំនិត និងជាឈ្នួញកណ្តាល ជាអ្នកសម្របសម្រួលផ្នែកវិនិយោគ និង ជាអ្នករៀបចំនីតិវិធីសម្រាប់ភាគីពាក់ព័ន្ធ ដែលបង្ហាញពីការអនុវត្ត ដែលបានពិគ្រោះប្រកបដោយគុណភាពខ្ពស់ (ប្រភព Dore and Kate 2009)។ ការអនុវត្តការងាររបស់គណៈកម្មការទន្លេមេគង្គត្រូវស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សានីថ្នាក់ក្រសួងដែលត្រូវជួបប្រជុំគ្នាម្តងក្នុងមួយឆ្នាំ ចំណែកគណៈកម្មការចម្រុះ (JC) នៃមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ត្រូវជួបប្រជុំគ្នាជាផ្លូវការពីរដងក្នុងមួយឆ្នាំ ប៉ុន្តែអាចជួបគ្នាច្រើនដងបានក្រៅផ្លូវការ តាមការចាំបាច់ជាក់ស្តែង។ ក្រុមប្រឹក្សា និងគណៈកម្មការចម្រុះ ត្រូវស្ថិតក្រោមសេវាបម្រើរបស់លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ ដែលមាននាទីទទួលខុសត្រូវលើការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា រីឯគណៈកម្មការចម្រុះ ត្រូវទទួលខុសត្រូវលើការផ្តល់ប្រឹក្សា និងផ្តល់ជំនួយបច្ចេកទេស និងរដ្ឋបាល។ គណៈកម្មការទន្លេមេគង្គ មានស្នាក់ការរៀងៗខ្លួននៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា និងនៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ។

យោងមាត្រា១ នៃកិច្ចព្រមព្រៀងទន្លេមេគង្គ នាឆ្នាំ១៩៩៥ បង្ហាញថាប្រទេសជាសមាជិកទាំង៤ បានប្តេជ្ញាធ្វើកិច្ចសហការគ្នាក្នុងគ្រប់វិស័យទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព ការប្រើប្រាស់ ការគ្រប់គ្រងនិងការរក្សាទឹក និងធនធានទាក់ទងនឹងទឹកនៃអាងទន្លេមេគង្គ ដែលរួមមានធារាសាស្ត្រ វារីអគ្គិសនី នាវាចរណ៍ ការគ្រប់គ្រងទឹកជំនន់ និងជលផល ។ ចាប់តាំងពីឆ្នាំ១៩៩៥ គណៈកម្មការទន្លេមេគង្គធ្លាប់ជា និងនៅតែជាមជ្ឈមណ្ឌលអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយចីរភាព។ ទោះជាយ៉ាងណា ថ្មីៗនេះ គណៈកម្មការទន្លេមេគង្គ ត្រូវបានទទួលការរិះគន់ពីសង្គមស៊ីវិល ហើយបានផ្តោតការយកចិត្តទុកដាក់លើការងាររបស់ខ្លួនបានយ៉ាងល្អប្រសើរ។ ដើម្បីជាជំនួយដល់ប្រទេសជាសមាជិកនៃស្ថាប័នដែលមានឧបករណ៍ និងបទដ្ឋានការងាររួម ទើបនៅក្នុងឆ្នាំ២០០៦ ធនាគារអភិវឌ្ឍអាស៊ី (ADB) គណៈកម្មការទន្លេមេគង្គ (MRC) និងអង្គការមូលនិធិសត្វព្រៃពិភពលោក (WWF) បានបង្កើតក្រុមការងារមួយដើម្បីឈានទៅសម្រេចបាននូវគំនិតផ្តួចផ្តើមមួយស្តីពីការគិតគូរលើបរិស្ថានសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយចីរភាព (ECSHD) ។ គោលបំណងរបស់ក្រុមការងារនេះ គឺបង្កើតឧបករណ៍ដែលជាជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្ត សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយចីរភាព នៅអាងទន្លេមេគង្គ។ វិធីសាស្ត្រគឺមានលក្ខណៈស្រដៀងនឹងវិធីសាស្ត្ររបស់សមាគមវារី អគ្គីសនីអន្តរជាតិ (IHA) ដែលបានបរិយាយរួចហើយនៅខាងលើ ដែលជាវិធីសាស្ត្រត្រូវអនុវត្តស្របតាមជំហាននានានៅក្នុងរយៈកាលគម្រោង។

ក្នុងឆ្នាំ២០១០ គំនិតផ្តួចផ្តើមមួយស្តីពីការគិតគូរលើបរិស្ថាន សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយចីរភាព (ECSHD) និងដៃគូអនុវត្តនានា បានបោះពុម្ពផ្សាយនូវឧបករណ៍វាយតម្លៃឆាប់រហ័សស្តីពីនិរន្តរភាពថាមពលអគ្គិសនីអាងទន្លេធំ (RSAT)។ ឧបករណ៍នេះ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបចំគោលដៅនៃបញ្ហាសំខាន់ៗបំផុតដែលចាំបាច់ សម្រាប់វិធីសាស្ត្រអាងទន្លេធំ ក្នុងការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយចីរភាព។

គោលបំណងចម្បងនៃឧបករណ៍វាយតម្លៃ គឺដើម្បី ៖

- ផ្តល់ជាមូលដ្ឋានរួមសម្រាប់ដៃគូសំខាន់ៗក្នុងការពិភាក្សា និង ការសហការទាក់ទងនឹងការអភិវឌ្ឍ ថាមពលវារីអគ្គិសនីប្រកបដោយចីរភាព។
- ផ្តោតសំខាន់ និងកំណត់ជាអាទិភាពចំពោះតំបន់ដែលអាចផ្តល់ឱកាស និងបង្កជាហានិភ័យដល់និរន្តរភាពវារីអគ្គិសនី ជាពិសេសនៅអាងទន្លេ ឬ អនុអាងទន្លេ ដែលទាមទារឲ្យមានការសិក្សាលម្អិតបន្ថែម ។
- កំណត់ឲ្យច្បាស់ពីតម្រូវការនៃការកសាងសមត្ថភាពនៅអាងទន្លេ។

ចំនុចគោល គឺ ៖

- ការធ្វើឲ្យប្រសើរឡើងជាបន្តទៀត ។
- ការស្វែងយល់អំពីអាងទន្លេធំ និង ការការពារគុណតម្លៃសង្គម វប្បធម៌ សេដ្ឋកិច្ច សង្គម និងបរិស្ថាន។
- ការស្វែងយល់ និងការការពារតម្លៃនៃអាងទន្លេធំ។
- ការរួមបញ្ចូលគ្នារវាងការរៀបចំផែនការអាង និង និយ័តកម្មនៃការអភិវឌ្ឍវារីអគ្គិសនី និងបទដ្ឋានគ្រប់គ្រងនានា។
- កិច្ចសហប្រតិបត្តិការរវាងប្រទេសនានាក្នុងការបែងចែងអាងទន្លេមួយ។
- ការធ្វើឲ្យមានតុល្យភាពរវាងលក្ខណៈសម្បត្តិផ្នែកសង្គមនិងបរិស្ថាន និង លក្ខណៈសម្បត្តិផ្នែកសេដ្ឋកិច្ចនិងបច្ចេកទេស ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានា។
- ការធ្វើឲ្យមានលក្ខណៈស្របគ្នាទៅតាមវិធីសាស្ត្រ ក្នុងរង្វង់អាងទន្លេមួយ។
- ការចូលរួមដោយមានការផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការគ្រាំទ្រទូលំទូលាយពីសហគមន៍។
- ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហារួមសម្រាប់ទាំងអស់គ្នា។
- ប្រធានបទ និងលក្ខណៈសម្បត្តិ ត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃ។

គណៈកម្មការទន្លេមេគង្គ បានបង្កើតផងដែរនូវគម្រោងផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនី ប្រកបដោយចីរភាព (ISH) ដែលផ្តោតជាពិសេសលើការជម្រុញកិច្ចសហការក្នុងតំបន់សម្រាប់ការគ្រប់គ្រងប្រកបដោយចីរភាពទៅលើគម្រោងវារីអគ្គិសនី ដែលមានចំនួនកាន់តែច្រើន ក្នុងរង្វង់ទស្សនវិស័យមួយនៃអាងទន្លេធំ ។ តាមរយៈគម្រោង ផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនីប្រកបដោយចីរភាពនេះ គណៈកម្មការទន្លេមេគង្គផ្តល់ជា

ជំនួយដល់ប្រទេសជាសមាជិកនានា ទាក់ទងនឹងសេចក្តីសម្រេចចិត្តស្តីពីការគ្រប់គ្រង និង ការអភិវឌ្ឍវារីអគ្គិសនី ស្រមតាមទស្សនវិស័យនៃការគ្រប់គ្រងធនធានទឹកចម្រុះ នៅអាងទន្លេធំ។

ប្រអប់អត្ថបទ៣.៣ សារតា-ទិដ្ឋភាពគន្លឹះ
• ការជជែកពិភាក្សាស្តីពីទំនប់វារីអគ្គិសនី និងវារីអគ្គិសនីខ្នាតធំៗ ត្រូវបានរៀបចំធ្វើអស់រយៈពេលពីរ ទីបីទសវត្សរ៍ តាមរយៈគំនិតផ្តួចផ្តើមជាលក្ខណៈអន្តរជាតិ និងការធានាការពារសង្គម និងសិទ្ធិមនុស្ស រួមមាន ៖ - សន្និសីទសហប្រជាជាតិស្តីពីបរិស្ថានមនុស្ស ឆ្នាំ១៩៧២ - គណៈកម្មការ Brundtland ឆ្នាំ១៩៨៧ - សន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ ឆ្នាំ១៩៩២ - របាយការណ៍សហ្សវត្សរ៍ ឆ្នាំ២០០០ - កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០០២ - កិច្ចប្រជុំរីយ៉ូប្លក២០ (Rio+20) ឆ្នាំ២០១២ • ក្នុងឆ្នាំ២០០០ គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) បានស្នើវិធីសាស្ត្រមួយស្តីពីទំនប់វារីអគ្គិសនី ផ្អែកលើការទទួលស្គាល់សិទ្ធិ និងការវាយតម្លៃលើហានិភ័យនានា រួមមានគុណតម្លៃសំខាន់ទាំង៥ អាទិភាពជាយុទ្ធសាស្ត្រពីរទៅបី និងគោលការណ៍ចំនួន២៦។ • គម្រោងផ្តួចផ្តើមគំនិតបស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) ត្រូវបន្តអនុវត្តដោយអង្គការសហប្រជាជាតិ (តាមរយៈគម្រោងកម្មវិធីសហប្រជាជាតិ ស្តីពីបរិស្ថាន (UNEP-គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ_DDP) ដែលជាស្ថាប័នអព្យាក្រឹតសម្រាប់ផ្សព្វផ្សាយរបាយការណ៍របស់ WCD និង សម្របសម្រួលនូវការពិនិត្យសារជាថ្មីឡើងវិញនូវអនុសាសន៍នានានៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន តាមរយៈកិច្ចជជែកពិភាក្សារួមរបស់ពហុភាគីពាក់ព័ន្ធ។ • នៅឆ្នាំ២០១១ សមាគមវារីអគ្គសនីអន្តរជាតិ សម្រេចបាននូវការការព្រមព្រៀងគ្នាជាច្រើនលើពិធីសារស្តីពីការវាយតម្លៃលើនិរន្តរភាពថាមពលវារីអគ្គិសនី។

ប្រធានបទពិភាក្សា	គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD) និង គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (DDP) ត្រូវបានបញ្ចប់តាមអាណត្តិរបស់ខ្លួន។ តើមានអំណះអំណាងណាមួយក្នុងការបង្កើតឲ្យមានស្ថាប័នអចិន្ត្រៃយ៍មួយ ដើម្បីដឹកនាំផ្លូវទាក់ទងនឹងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ (ឧទាហរណ៍ដូចជាការបង្កើតឲ្យមានសមាគមវារីអគ្គិសនីអន្តរជាតិ) ដែរឬទេ? .... នៅក្នុងពិភពលោកបច្ចុប្បន្ន តើមានកន្លែងណាដែលថា " ប្រជាពលរដ្ឋមួយចំនួនទទួលរងការឈឺចាប់ ដោយសារការផ្តល់ផលប្រយោជន៍ឲ្យប្រជាជនភាគច្រើន" ។

	…… គោលការណ៍ទី១៥ នៃសេចក្តីថ្លែងការណ៍រីយ៉ូ ចែងថា ៖ *ដើម្បីការពារបរិស្ថាន គួរតែមានការអនុវត្តទូលំទូលាយនូវវិធីសាស្ត្រយ៉ាងប្រុងប្រយ័ត្ន ដោយសាមីរដ្ឋនានាស្របតាមសមត្ថភាពរបស់ខ្លួន ។ នៅទីណាដែលមានការគម្រាមកំហែងធ្ងន់ធ្ងរ ឬការខូចខាតមិនអាចត្រឡប់វិញបាន មិនត្រូវយកមកប្រើប្រាស់ វិធីសាស្ត្រដែលគ្មានភាពជាក់លាក់បែបវិទ្យាសាស្ត្រ ដើម្បីធ្វើជាហេតុផលសម្រាប់ការផ្អាកវិធានការដ៏មានប្រសិទ្ធភាព ក្នុងការបង្ការភាពរិចរិលនៃបរិស្ថានបានឡើយ។*តើគោលការណ៍នេះអាចអនុវត្តតាមបានដោយរបៀបណា ចំពោះទំនប់វារីអគ្គិសនី?
លំហាត់	ចូរកំណត់ពេលវេលាជាក់លាក់នៃព្រឹត្តិការណ៍សំខាន់ៗនៅក្នុងកិច្ចពិភាក្សា ស្តីពីវារីអគ្គិសនី និងការអភិវឌ្ឍ។ …… សូមរាយតារាងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗទាក់ទងនឹងទឹក នៅក្នុងប្រទេសរបស់អ្នក ដែលកើតមានភាពចម្រូងចម្រាស់ ឬ ស្ថិតក្រោមការអនុវត្តតាមលក្ខណៈបច្ចេកទេស សេដ្ឋកិច្ច បរិស្ថាន និងសង្គម។

៤. ការវាយតម្លៃហេតុប៉ះពាល់សង្គម

៤.១ សេចក្តីផ្តើម

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាម អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
ទិសដៅ	• ដើម្បីបង្ហាញពីគំនិតទស្សន: និងគុណតម្លៃនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ …… • ដើម្បីផ្តល់គន្លឹះសំខាន់ៗក្នុងវគ្គសិក្សា ក្នុងអំឡុងពេលដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននឹងត្រូវបរិយាយយ៉ាងល្អិតល្អន់។
ការអានតាមលំដាប់លំដោយ	Taylor, C.N., Bryan, C.H. and Goodrich (1995). ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ៖ ទ្រឹស្តី នីតិវិធី និងបច្ចេកទេស។ ការបោះពុម្ពផ្សាយលើកទី២។ The Caxton Press, Christchurch, New Zealand …… Adams, William (2000) ផលប៉ះពាល់សង្គមបណ្តាលមកពីទំនប់វារីអគ្គិ-សនីធំៗ ៖ សមភាព និងបញ្ហារួចពន្ធអាកវនានា។ របាយការណ៍ចុង

	ក្រោយត្រូវបានរៀបចំ សម្រាប់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ៖ ខេបថោន៨០១៨ (Cape Town) អាហ្វ្រិកខាងត្បូង។ ..... Burge, J. Rabel J (2004) គំនិតទស្សន នីតិវិធី វិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់សង្គម។ Social Ecology Press: Middleton, Wisconsin, USA. ..... គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007) ។ ទំនប់វារីអគ្គិសនី និង ការអភិវឌ្ឍ ៖ ឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និង ជម្រើសដែលអាចជំនួសបាន។ ផ្នែកទី៤ ៖ ដំណោះស្រាយលើទិដ្ឋភាពសង្គម។ (ផ្នែក ៤.១- ការវាយតម្លៃហេតុប៉ះពាល់សង្គម។ www.unep.org/dams

ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) គឺជាអនុវិស័យនៃវិទ្យាសាស្ត្រសង្គមមួយ សំដៅធ្វើឲ្យរីកចម្រើនចំណេះដឹងជាមូលដ្ឋាន ដើម្បីផ្តល់ជាមុននូវកម្រិតវាយតម្លៃជាលក្ខណៈប្រព័ន្ធ ទៅលើផលប៉ះពាល់ដល់គុណភាពជីវិតរបស់មនុស្ស និងសហគមន៍ ពីមួយថ្ងៃទៅមួយថ្ងៃ ដែលបរិស្ថានរស់នៅរបស់ពួកគេត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងដែលស្នើឡើង ឬ ការផ្លាស់ប្តូរដំណើរការនៃអង្គការនយោបាយពលរដ្ឋ។ ការវាយតម្លៃនេះ គឺជាដំណើរការនៃការស្រាវជ្រាវ រៀបចំផែនការ និងការគ្រប់គ្រងលើបម្រែបម្រួលសង្គម ឬ ផលវិបាក (វិជ្ជមាន និងអវិជ្ជមាន ដែលបានគិតទុកជាមុន និងមិនបានគិតទុកជាមុន) ដែលអាចកើតចេញពីគោលនយោបាយផែនការ កម្មវិធី និងគម្រោងនានា (ប្រភព Taylor, Bryan and Goodrich, 1995)។ វាគឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍នានា ដែលមាននៅក្នុងចង្កោមឧបករណ៍ស្តីពីការគ្រប់គ្រងបរិស្ថានចម្រុះ (ប្រអប់អត្ថបទ៤.១) ដែលផ្តោតលើភាគសំខាន់របស់មនុស្សក្នុងកិច្ចអន្តរាគមន៍នានាលើការអភិវឌ្ឍ ។ ទោះយ៉ាងណាក៏ដោយ ភាគសំខាន់របស់មនុស្សមិនអាចពិនិត្យ ឬ វាយតម្លៃបានដោយការញែកឲ្យដាច់ពីគ្នារវាងទិដ្ឋភាពជីវរូប និងសេដ្ឋកិច្ច រួមទាំងទិដ្ឋភាពសង្គមបានឡើយ ដោយមានប្រព័ន្ធអភិបាលកិច្ចអាចជឿ-ជាក់បានរួមចំណែកក្នុងការសម្រេចបាននិរន្តរភាព ពោលគឺសសរស្តម្ភទាំង៣ដែលបង្កបង្កើតជាបរិស្ថាន ត្រូវតែពិនិត្យ និងវាយតម្លៃក្នុងលក្ខណៈបញ្ចូលជាមួយគ្នា។ ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) ជាប់ទាក់ទងយ៉ាងជិតស្និតជាមួយធាតុសំខាន់ៗមួយចំនួនទៀត ដូចជា សម្បត្តិវប្បធម៌ សង្គមសេដ្ឋកិច្ច យេនឌ័រ នយោបាយ និងការប្រើប្រាស់ធនធាន។ ដោយឡែកនៅក្នុងពេលដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ប្រអប់អត្ថបទ៤.២) ការវាយតម្លៃហេតុប៉ះពាល់សង្គមអាចដំណើរការទៅបាន អាស្រ័យដោយមានការចូលរួមយ៉ាងសកម្មជាសាធារណៈ (ផ្នែកទី៨) ។ ដូច្នេះ ផ្អែកតាមរបៀបរបស់វា ការវាយតម្លៃហេតុប៉ះពាល់សង្គមត្រូវធ្វើឡើងដោយលក្ខណៈពេញលេញ និងទាមទារឲ្យមានបណ្តុំវិធីសាស្ត្រមួយ ដែលគ្របដណ្តប់នូវរបៀបជាច្រើនមានលក្ខណៈរួមផ្សំ។

ប្រអប់អត្ថបទ៤.១ ការគ្រប់គ្រងបរិស្ថានចម្រុះ
ការគ្រប់គ្រងបរិស្ថានចម្រុះ (IEM) អាចឲ្យនិយមន័យបានថា ជាបទដ្ឋានទស្សនវិជ្ជាដ៏ទូលំទូលាយមួយសម្រាប់វាយតម្លៃ និងគ្រប់គ្រងលើជំហាននីមួយៗនៃការប្រតិបត្តិទៅតាមកម្រិតណាមួយ (ដូចជា ៖ ផែនការ គោលនយោបាយ កម្មវិធី ឬ គម្រោង) ដែលមានឥទ្ធិពលលើ ឬ ទំនាក់ទំនងទៅវិញទៅមកជាមួយបរិស្ថាន (មានអត្ថន័យដូចជាបរិបទមនុស្សទាក់ទងនឹងរបៀបរស់នៅជាក់ស្តែងដោយការពិនិត្យទៅលើលក្ខណៈជីវូប ស្តាប័ន និង សង្គមសេដ្ឋកិច្ច) ដែលអាចអនុវត្តបានជាសកលនៅក្នុងសង្គមជាតិ (ប្រភព៖ ក្រសួងកិច្ចការបរិស្ថាន និងទេសចរណ៍-អាហ្វ្រិកខាងត្បូង ឆ្នាំ២០០៥)។

ប្រអប់អត្ថបទ៤.២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) គឺជាការសិក្សាលម្អិតមួយ សំដៅកំណត់ប្រភេទ និងកម្រិតនៃផលប៉ះពាល់បរិស្ថានដែលកើតមានដោយសារការសាង់សង់ដែលមានស្រាប់ ឬ គម្រោងដែលបានស្នើឡើង (ដោយពិនិត្យទៅលើបរិបទទូលំទូលាយ)។ គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួមមាន (១) ជួយកំណត់ឲ្យសេចក្តីសម្រេច ថាតើផលប៉ះពាល់នោះអាចទទួលយកបានឬទេ ឬ ថាតើត្រូវកាត់បន្ថយដើម្បីអាចឲ្យដំណើរការសំណង់បានបន្តទៅមុខទៀត ឬអាចបន្តដំណើរការគម្រោងដែលបានស្នើឡើង។ (២) ដើម្បីរៀបចំ និងអនុវត្តការវិធានការក្នុងការត្រួតពិនិត្យសមស្រប ការកាត់បន្ថយ និងគ្រប់គ្រង។ (៣) ដើម្បីលើកស្នើជម្រើសដែលអាចជំនួសបាន និង (៤) ដើម្បីរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIAR)។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានគុណភាពល្អគ្រប់គ្រាន់អាស្រ័យលើការកំណត់ឲ្យច្បាស់លាស់ ការវាយតម្លៃ និងការកាត់បន្ថយពីទំហំនៃផលប៉ះពាល់នានាទៅលើបរិស្ថាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាតម្រូវការស្តង់ដារមួយដោយមានការចូលរួមពាក់ព័ន្ធពីភ្នាក់ងារអន្តរជាតិ (ដូចជា ក្រុមធនាគារពិភពលោក ធនាគារអភិវឌ្ឍអាស៊ី ។ល។) ហើយការវាយតម្លៃនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់គម្រោងនានា ដែលតម្រូវឲ្យមានការផ្លាស់ប្តូរដ៏ធំមួយទៅលើការប្រើប្រាស់ដីធ្លី ឬ សម្រាប់គម្រោងទាំងឡាយណាដែលមានទីតាំងនៅក្នុងតំបន់រសើបពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន។ (www.businessdictionary.com)

ហេតុប៉ះពាល់សង្គម (ឬ ផលប៉ះពាល់ និងផលវិបាក) សំដៅដល់ការផ្លាស់ប្តូរចំពោះបុគ្គល និងសហគមន៍ ដោយសារសកម្មភាពដែលបានស្នើឡើង ដែលនាំឲ្យមានការផ្លាស់ប្តូររបៀបរបបប្រចាំថ្ងៃរបស់ប្រជាជនពីម្នាក់ទៅម្នាក់ ទាក់ទងនឹងការរស់នៅ ការប្រកបការងារ ការកំសាន្ត ការជួបប្រជុំដោះស្រាយតម្រូវការរបស់ខ្លួន និងការលៃលកដោះស្រាយជាទូទៅ ក្នុងនាមជាសមាជិកសង្គម។

គណៈកម្មការអន្តរអង្គការស្តីពីគោលការណ៍ និង សេចក្តីណែនាំសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានឲ្យនិយមន័យហេតុប៉ះពាល់សង្គម ដូច្នេះថា ៖

ជាផលវិបាកកើតមានចំពោះប្រជាពលរដ្ឋដោយសារសកម្មភាពសាធារណៈ ឬ ឯកជនណាមួយដែលបានធ្វើឲ្យមានការផ្លាស់ប្តូរពីម្នាក់ទៅម្នាក់ ដល់ការរស់នៅ ការប្រកបការងារ ការកំសាន្ត ការជួបប្រជុំដោះស្រាយតម្រូវការរបស់ខ្លួន និងការលៃលកដោះស្រាយជាទូទៅ ក្នុងនាមជាសមាជិកសង្គម។ ពាក្យនេះក៏បានរាប់បញ្ចូលផងដែរនូវផលប៉ះពាល់ដល់វប្បធម៌ទាក់ទងនឹងការផ្លាស់ប្តូរវិធានគុណតម្លៃ និងជំនឿ ដែលណែនាំ និងធ្វើសនិទានកម្មលើការទទួលស្គាល់របស់ខ្លួនទៅលើខ្លួនឯង និងសង្គម (ប្រភព Burge and Rebel 2004)។

ការវាយតម្លៃហេតុប៉ះពាល់សង្គម គឺផ្តោតលើការចងក្រងឯកសារ និង នីតិវិធីស្តីពីផលវិបាកពេញលេញទាក់ទងនឹងសង្គម វប្បធម៌ ប្រជាសាស្ត្រ និងសេដ្ឋកិច្ច នៃសកម្មភាពទាំងឡាយ និងជម្រើសដែលអាចជំនួសបានចំពោះភាគីពាក់ព័ន្ធធំៗទាំងអស់ បុគ្គល ក្រុម សហគមន៍ និងវិស័យនានាសម្រាប់សង្គមដែលមានចំណាប់អារម្មណ៍ជាមួយ ឬ ដែលទទួលរងផលប៉ះពាល់ពីចំណាត់ការដែលបានស្នើឡើង។ ដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់សង្គម អ្នកវាយតម្លៃត្រូវប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្រសង្គម បន្ថែមលើដំណើរការនៃការចូលរួមជាសាធារណៈ និង ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះ-ពាល់។

ការវាយតម្លៃហេតុប៉ះពាល់សង្គម បានផ្តល់ជាការណែនាំក្នុងការគ្រប់គ្រងផលវិបាកទាំងឡាយទាក់ទងនឹងការផ្លាស់ប្តូរសង្គមដែលកើតចេញពីចំណាតើការគោលនយោបាយ ឬ គម្រោងដែលបានស្នើឡើង ឬ កំពុងអនុវត្ត។ ការវាយតម្លៃ អាចជួយដល់អ្នកធ្វើសេចក្តីសម្រេចចិត្តឲ្យអាចសម្រេចចិត្តបានដោយត្រឹមត្រូវ ដោយការផ្តល់ព័ត៌មានស្តីពីផលវិបាកដែលអាចកើតមាន និងជាក់ស្តែង ទាក់ទងនឹងចំណាត់ការរបស់ខ្លួន ។ បន្ថែមពីលើនេះ នីតិវិធីវាយតម្លៃអាចជួយបញ្ជៀស ឬ កាត់បន្ថយផលប៉ះពាល់មិនល្អ និងផែនការ សម្រាប់កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដែលមិនអាចជៀសផុត ដែលជាកត្តាជួយបង្កើនសក្តានុពលដ៏សំខាន់សម្រាប់ជោគជ័យនៃគម្រោង ឬ គោលនយោបាយ ។ ការវាយតម្លៃហេតុប៉ះពាល់សង្គម អាចជួយដល់សាធារណជន ដែលរងផលប៉ះពាល់បានយល់ដឹងពីផលវិបាកនៃចំណាត់ការ និងអាចថ្លាថ្លែង និងបញ្ចេញគោលជំហររបស់ខ្លួនទាក់ទិននឹងចំណាត់ការទាំងនោះ។ ការវាយតម្លៃហេតុប៉ះពាល់សង្គមដែលអាចធ្វើបានដោយជោគជ័យ គឺសំដៅដល់ការវាយតម្លៃណាដែលអាចឆ្លើយតបចំពោះសំនួរដូចខាងក្រោម ៖

- តើនឹងមានអ្វីអាចកើតឡើងនៅពេលអនុវត្តចំណាត់ការដែលបានស្នើ ដោយឈរលើមូលហេតុអ្វី នៅពេលណា និងនៅកន្លែងណា?
- តើនរណានឹងត្រូវទទួលរងផលប៉ះពាល់?
- តើនរណាជាអ្នកទទួលបានផលប្រយោជន៍ ហើយនរណាជាអ្នកខាតបង់?
- តើមានអ្វីនឹងត្រូវផ្លាស់ប្តូរក្រោមជម្រើសដែលអាចជំនួសបានផ្សេងៗ?

- តើត្រូវបញ្ចៀស ឬ កាត់បន្ថយផលប៉ះពាល់មិនល្អ និង ត្រូវបង្កើតផលប្រយោជន៍ ដោយរបៀបណា?

ការអភិវឌ្ឍតម្រូវឲ្យមានជាចាំបាច់នូវភាពល្អប្រសើរខាងលក្ខខ័ណ្ឌសង្គម និង សុខមាលភាពរបស់ប្រជាពលរដ្ឋ ក៏ដូចជាឲ្យមានការកើនឡើងនូវទិន្នផលសរុបក្នុងស្រុក (GDP) ។ ដូចសមាសភាពមួយនៃការរៀបចំផែនការសម្រាប់ការអភិវឌ្ឍដែរ ការវាយតម្លៃហេតុប៉ះពាល់សង្គមផ្តល់ជាវិធីសាស្ត្រសម្រាប់ ផ្សារភ្ជាប់កត្តាសង្គម តាមរយៈការកំណត់ឲ្យបានច្បាស់នូវលក្ខណៈពិសេសទាំងនេះនៃបរិស្ថានសង្គម ដែលមានសក្តានុពលដ៏ធំធេងបំផុតសម្រាប់ជាធ្វើឥទ្ធិពល និងត្រូវរងឥទ្ធិពលពីគម្រោងដែលបានស្នើឡើង ការផ្លាស់ប្តូរគោលនយោបាយ ឬកម្មវិធីថ្មី (សូមមើលលើចំនុច Taylor, Bryan and Goodrich, 1995)។ នៅក្នុងន័យនេះ អត្ថប្រយោជន៍នៃការវាយតម្លៃហេតុប៉ះពាល់សង្គម បានបន្ថែមលើការគាំទ្រលើគម្រោង (ទោះជាវិស័យឯកជនក្តី ឬរដ្ឋាភិបាលក្តី) និងប្រជាសហគមន៍ដែលទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍ។

នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍភាគច្រើន ការវាយតម្លៃហេតុប៉ះពាល់សង្គមត្រូវធ្វើឡើង ដើម្បីឆ្លុះបញ្ចាំងពីទិដ្ឋភាព ដូចខាងក្រោម ៖

- ធ្វើឲ្យប្រាកដថា ដំណើរការត្រូវអនុវត្តប្រកបដោយដោយប្រសិទ្ធភាព ៖ ការមើលរំលងផលប៉ះពាល់សង្គម ចាប់ពីការធានាថា ការគាំទ្រមួយត្រូវចំណាយពេលវេលាច្រើនទៅអនាគតក្នុងការលាតត្រដាងបញ្ហានានាដែលមានលក្ខណៈផ្ទុយទៅនឹងការកំណត់។
- បង្កើតកម្មវិធីដែលអាចដំណើរការបាន ៖ ការវាយតម្លៃផលប៉ះពាល់សង្គម អាចធ្វើឲ្យបានល្អ និងធ្វើឲ្យប្រសើរចំពោះសេចក្តីស្នើនានា ផ្តល់ជាប្រយោជន៍ដែលជាតម្រូវការសម្រាប់អនុវត្ត និង រក្សានូវដំណោះស្រាយ ព្រមទាំងកំណត់ឲ្យបានប្រាកដពីហេដ្ឋារចនាសម្ព័ន្ធសហគមន៍ដែលជាតម្រូវការសម្រាប់ធ្វើឲ្យអត្រាកម្រិតទទួលបានមកវិញមានលក្ខណៈល្អប្រសើរ។
- បញ្ចៀសផលវិបាកដែលមិនបានគិតទុកជាមុន ៖ ផលប៉ះពាល់សង្គមមួយចំនួនមិនអាចកំណត់ឃើញឡើយ ប្រសិនបើគ្មានការវាយតម្លៃហេតុប៉ះពាល់សង្គម រហូតដល់ក្រោយការសម្រេចចិត្ត ត្រូវបានធ្វើរួចរាល់សិន បន្ទាប់មក ត្រូវចាប់ផ្តើមអនុវត្តគម្រោងតែម្តង។

អ្នកសម្រេចចិត្ត (និងសហគន៍ដែលទទួលរងផលប៉ះពាល់) ត្រូវយល់ពីលទ្ធផលនៃការសម្រេចចិត្តពាក់ព័ន្ធ និង ដ៏មានសារៈសំខាន់នានានៃចំណាត់ការដែលបានស្នើឡើង ដើម្បីរួមបញ្ចូលជម្រើសដែលអាចជំនួសបានដោយមិនត្រូវការចំណាត់ការ ។ ឧទាហរណ៍ ៖ ប្រសិនបើការសម្រេចចិត្តមួយត្រូវបានធ្វើឡើងដើម្បីដំណើរការអណ្តូងរ៉ែ គោលដៅរបស់សហគមន៍នឹងផ្លាស់ប្តូរពីវិស័យទេសចរណ៍ទៅជាការទទួលបាននូវអ្វីមួយផ្សេងវិញ ។ ទេសចរណ៍នឹងត្រូវជម្រុសមកវិញដោយវត្តមានកម្មករអណ្តូងរ៉ែវិញ។

ដើម្បីយល់ច្បាស់ពីផលប៉ះពាល់ប្រហាក់ប្រហែលនៃចំណាត់ការ និង ជម្រើសដែលស្នើឡើង សាធារណជន និងអ្នកសម្រេចចិត្ត ត្រូវដឹងថា ៖

- តើសហគមន៍ត្រូវជួបប្រជុំគ្នាដោយរបៀបណា? តើប្រជាពលរដ្ឋអាចទំនាក់ទំនងគ្នា និងឆ្លើយឆ្លងគ្នាដោយរបៀបណា? តើមានវត្តមានស្ថាប័នសង្គមពាក់ព័ន្ធទាំងអស់ដែរឬទេ? តើរដ្ឋាភិបាលមូលដ្ឋានដែលបានជួបប្រជុំទទួលយកនូវការផ្លាស់ប្តូរដែរឬទេ?
- ការហូរចូលយ៉ាងកំហុគនៃកសិករចំណូលថ្មី ភាគច្រើនអាចនឹងមិនបង្កផលប៉ះពាល់ច្រើនដល់សហគមន៍ដែលបានព្រមព្រៀងលើប្រភេទប្រជាជនផ្សេងៗ នាពេលកន្លងទៅនោះឡើយ ប៉ុន្តែវាអាចបង្កផលប៉ះពាល់ធំ ចំពោះសហគមន៍ដែលប្រជាជនកំពុងរស់នៅយូរឆ្នាំមកហើយ ។ តើអ្វីដែលជាការឆ្លើយតបកន្លងមករបស់សហគមន៍ ចំពោះការប្រែប្រួលផ្នែកសង្គម ?
- តើសហគមន៍អាចធ្វើការសម្រេចចិត្តដោយរបៀបណា ? តើអ្វីដែលមើលទៅឃើញថាមានសារៈ-សំខាន់ ៖ មានស្ថិរភាព ឬមានការរីកចម្រើន? តើនរណាជាអ្នកធ្វើការសម្រេចចិត្ត? តើមានវត្តមានហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រដល់ចំណាត់ការដែលបានស្នើឡើង និង មានជម្រើសដែលអាចជំនួសបាន ដែរឬទេ?

ប្រអប់អត្ថបទ៤.៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចជួយដល់អ្នកធ្វើការសម្រេចចិត្ត ភ្នាក់ងារ ឬអ្នកធ្វើសំណើគម្រោង តាមរយៈ ៖
• ការកំណត់ឲ្យបានច្បាស់ពីឪកាសដើម្បីជម្រុញផលប្រយោជន៍សង្គម និង បន្ធូរបន្ថយ ឬ កាត់បន្ថយផលវិបាកមិនល្អនានា។ • កំណត់ឲ្យបានច្បាស់ពីបញ្ហាសង្គម និង ភាពរាំងស្ទះដល់សង្គមដែលអាចប៉ះពាល់ដល់ការទទួលយល់ព្រមលើផែនការមួយពីសំណាក់សាធារណជនដែលមានចំណាប់អារម្មណ៍ ឬដែលទទួលរងផលប៉ះពាល់។ • ជួយដល់ការចងក្រងឯកសារស្តីពីផលប្រយោជន៍ និង ផលវិបាកនានានៃជម្រើសនីមួយៗ ដែលអាចជំនួសបាន។ • បង្កើតនីតិវិធីតាមដានត្រួតពិនិត្យ ដើម្បីធានាដល់ការទទួលយល់ព្រម និង ភាពអាចអនុវត្តបានដោយសារ បញ្ហាថ្មីៗកើតមានឡើងក្នុងអំឡុងពេលអនុវត្ត និងប្រតិបត្តិការគម្រោង។ • គ្រោះថ្នាក់ដ៏ធំបំផុត មិនមែនបណ្តាលមកពីចំណាត់ការនោះទេ ប៉ុន្តែបណ្តាលមកពីការដែលមិនបានពិចារណាទៅលើផលវិបាកនៃចំណាត់ការនោះ ។

ការវាយតម្លៃហេតុប៉ះពាល់សង្គម ត្រូវបានកំណត់និយមន័យយ៉ាងច្បាស់លាស់ ក្នុងប៊ុន្មានទសវត្សរ៍ចុងក្រោយនេះ។ វាគឺជារបៀបនៃការប្រមូលព័ត៌មានបន្ថែមដើម្បីជួយឲ្យមានការវិភាគ និងការប៉ាន់ស្មានពីផលប៉ះពាល់នានា សម្រាប់គោលបំណងនៃការកំណត់ឲ្យបានច្បាស់ពីសកម្មភាព ដើម្បីបង្កាផលប៉ះពាល់ជាអវិជ្ជមាន ឬ ដើម្បីបង្កើនផលប្រយោជន៍។ នៅក្នុងប្រទេសមួយចំនួន ពាក្យថា "បរិស្ថាន" ត្រូវបានបកស្រាយក្នុងបរិបទទូលំទូលាយ ដោយការរួមបញ្ចូលគ្នារវាងសសរស្តម្ភទាំងអស់នៃបរិស្ថាន (សង្គម ជីវរូប សេដ្ឋកិច្ច

នយោបាយ វប្បធម៌ អភិបាលកិច្ច។ល។) ។ នៅក្នុងប្រទេសមួយចំនួនទៀត ការបកស្រាយមានលក្ខណៈតូចចង្អៀតជាង ដោយមានភាពស្រដៀងគ្នាជាពិសេសទៅនឹងធាតុសំខាន់របស់ជីវរូបនៃបរិស្ថាន។ នៅក្នុងករណីបែបនេះ បរិស្ថានសង្គមត្រូវបានយល់ឃើញដាច់ដោយឡែក ។ ការបកស្រាយទាំងនេះមានជាប់ទាក់ទងគ្នា ដោយសារការកបស្រាយទាំងនោះនាំទៅ ដល់វិធីសាស្ត្រពីរខុសគ្នាទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់សង្គម។

នៅក្នុងករណីនៃការបកស្រាយទាំងនេះ ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) បានក្លាយទៅជាការសិក្សាមួយដែលមានលក្ខណៈធំទូលាយជាងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ស្របពេលដែលក្រោយមក ការវាយតម្លៃហេតុប៉ះពាល់សង្គមមានលក្ខណៈស្របគ្នាទៅនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរ (យោង១) ។ កម្រិត និងវិសាលភាពនៃ SIA ក្នុងករណីនីមួយៗ មិនអាចប្រៀបធៀបបានឡើយ ហើយអាចនាំទៅដល់ការគូសបញ្ជាក់ខុសៗគ្នាតាមស្ថានភាពនៃលទ្ធផលនីមួយៗ។

គួរកត់សម្គាល់ឲ្យបានច្បាស់ថា ផ្នែកជាច្រើនបំផុតនៃ SIA គឺជាការដោះស្រាយទៅលើផលប៉ះពាល់នៃគម្រោងជាក់លាក់សម្រាប់សហគមន៍ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោងដែលបានស្នើឡើង ។ SIA កម្រនឹងអនុវត្តណាស់ ទៅលើគម្រោងខ្នាតធំដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ឬ ជាគម្រោងថ្នាក់ជាតិ។ នៅក្នុងករណីបែបនេះ អ្នកធ្វើសំណើគម្រោង ជាធម្មតាត្រូវធ្វើការវាយតម្លៃសេដ្ឋកិច្ចដើម្បីស្វែងយល់ និងវាយតម្លៃយ៉ាងទូលំទូលាយលើផលប្រយោជន៍អាចមានបន្ថែមទៀតលើផ្នែកសេដ្ឋកិច្ច និងសង្គម បានពីគម្រោងដែលបានស្នើឡើង។ លទ្ធផលនៃការវាយតម្លៃទាំងនេះតម្រូវឲ្យអាន និងយល់រួមជាមួយនឹងការអាន និងយល់ពីលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់សង្គមទៅលើគម្រោងជាក់លាក់។

(យោង១) នៅក្នុងតួយ៉ាងជាច្រើន ការវាយតម្លៃហេតុប៉ះពាល់សង្គម បានវិវត្តជុំវិញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូច្នេះហើយទើបការបរិយាយ និងការវាយតម្លៃពីផលប៉ះពាល់សង្គម ត្រូវអនុវត្តយ៉ាងប្រុងប្រយ័ត្នតាមការបង្កើតឡើងនូវសន្ទុះ សម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទោះជាយ៉ាងណា នៅមានភាពខុសគ្នាខ្លាំងត្រង់ថា បរិស្ថានសង្គមមានការប្រែប្រួល ហើយការកាត់បន្ថយពេលខ្លះមានន័យថា ជាការប្រែត្រឡប់ផលប៉ះពាល់ជាអវិជ្ជមានទៅជាលទ្ធផលជាវិជ្ជមាន ជាមួយនឹងការកាត់បន្ថយដែលមានលក្ខណៈគ្រប់គ្រាន់។ តែយ៉ាងណាមិញ សមត្ថភាពក្នុងការអនុវត្តលើការកាត់បន្ថយនៅមានព្រំដែននៅឡើយ។

ប្រអប់អត្ថបទ៤.៤ សេចក្តីផ្តើម-ទិដ្ឋភាពគន្លឹះ
• ការវាយតម្លៃហេតុប៉ះពាល់សង្គម គឺជាការខិតខំប្រឹងប្រែងមានលក្ខណៈជាប្រព័ន្ធ ដើម្បីកំណត់ឲ្យបានច្បាស់ វិភាគ និងវាយតម្លៃផលប៉ះពាល់សង្គមនៃគម្រោងដែលបានស្នើឡើង ឬ ការផ្លាស់ប្តូរគោលនយោបាយទាក់ទងនឹងបុគ្គល ក្រុមមនុស្សក្នុងសង្គមក្នុងរង្វង់សហគមន៍ ឬ ក្នុងសហគមន៍ទាំងមូល នៅមុនដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត សំដៅធ្វើយ៉ាងណាឲ្យព័ត៌មានដែលបានរៀបចំឡើងតាមរយៈការវាយតម្លៃនោះអាចយកមកប្រើប្រាស់បានសម្រាប់ធ្វើការសម្រេចចិត្ត ។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម គឺជាមធ្យោបាយសម្រាប់បង្កើតជម្រើសដែលអាចជំនួសបានក្នុងពេលកំពុងអនុវត្តសកម្មភាព និង សម្រាប់កំណត់ឲ្យបានច្បាស់ពីផលប្រយោជន៍ពេញលេញ និងផលវិបាកនានាសម្រាប់ជម្រើសនីមួយៗ។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម អាចបង្កើនចំណេះដឹងទៅលើផ្នែកនៃការគាំទ្រគម្រោង និង សហគមន៍ដែលរងផលប៉ះពាល់ ។ ការវាយតម្លៃហេតុប៉ះពាល់សង្គមអាចលើកឡើងពីអ្វី ដែលបានដឹងនិងកម្រិតនៃការយល់ដឹងរបស់សហគមន៍ ហើយអាចកំណត់គោលជំហរល្អប្រសើរសម្រាប់អ្នកតាំងទីលំនៅ ឲ្យយល់កាន់តែទូលំទូលាយអំពីចំណាត់ការដែលបានស្នើឡើង។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម រាប់បញ្ចូលទៅក្នុងដំណើរការនៃការធ្វើឲ្យធូរស្រាល ឬ កាត់បន្ថយផលវិបាកនានាដែលអាចកើតមាន ប្រសិនណាសហគមន៍បានព្រមព្រៀងលើរួចហើយ ទៅលើចំណាត់ការដែលបានស្នើឡើង។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម គឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើន ដែលមាននៅក្នុងប្រអប់អត្ថបទស្តីពីការគ្រប់គ្រងបរិស្ថានចម្រុះ (IEM) ដែលត្រូវបានយកមកអនុវត្តដើម្បីធ្វើឲ្យសម្រេចបាន នូវនិរន្តរភាព។ • ការវាយតម្លៃហេតុប៉ះពាល់សង្គម ជាប់ទាក់ទងយ៉ាងជិតស្និតជាមួយរធាតុសំខាន់ៗមួយចំនួនទៀត ដូចជា ៖ សម្បត្តិវប្បធម៌ សង្គមសេដ្ឋកិច្ច យេនឌ័រ នយោបាយ និងការប្រើប្រាស់ធនធាន។

ប្រធានបទពិភាក្សា	តើអ្វីទៅជាដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់សង្គម? ..... ហេតុអ្វីត្រូវចាំបាច់គិតគូរពីបរិស្ថានសង្គមនៅពេលស្នើសុំ និង/ឬ ពេលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ? ..... តើអ្វីទៅដែលអ្នកធ្វើការសម្រេចចិត្តត្រូវដឹងក្នុងការវាយតម្លៃហេតុប៉ះពាល់សង្គម? ..... តើអ្វីដែលជាផលប្រយោជន៍នៃវិធីសាស្ត្ររួមផ្សំ ហើយវិធីសាស្ត្រនេះត្រូវធ្វើឲ្យសម្រេចបានដោយរបៀបណា?

លំហាត់	ចូរកំណត់ឲ្យឃើញពីគម្រោង ដែលអនុវត្តនៅក្នុងប្រទេសរបស់អ្នក ដែលបញ្ហាបរិស្ថានសង្គមមិនត្រូវបានគេគិតគូរក្នុងអំឡុងពេលរៀបចំផែនការ និងពេលអនុវត្ត និង សូមបរិយាយឲ្យបានលម្អិតពីផលវិបាកនានា។ ..... សូមប្រើរយៈមួយមានកំណត់ បរិយាយអំពីថាតើការគិតគូរពីបរិស្ថានសង្គមត្រូវបានទទួលស្គាល់បែបណា ហើយមានសារៈសំខាន់បែបណានៅក្នុង៣ទសវត្សរ៍កន្លងមកនេះ។

៤.២- បទដ្ឋានជានិយាម

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីបទដ្ឋានជានិយាម (យោង២) ដែលផ្អែកលើ និង/ឬ បានមកពីការវាយតម្លៃហេតុប៉ះពាល់សង្គម។
ទិសដៅ	• ដើម្បីបង្ហាញពីករណីឧទាហរណ៍ជាលក្ខណៈអន្តរជាតិ ស្តីពីបទដ្ឋានជានិយាម។ ..... • ដើម្បីបង្ហាញពីគោលរឿងនៃបទដ្ឋានជានិយាមនានា។
ការអានតាមលំដាប់លំដោយ	IFC (2006) គោលនយោបាយ និងស្តង់ដារគំរូនៃការអនុវត្តការងារស្តីពីនិរន្តរភាពផ្នែកសង្គម និងបរិស្ថាន www.ifc.org/enviro ..... IFC (2007) កំណត់សម្គាល់សេក្តីណែនាំ ៖ ស្តង់ដារគំរូនៃការអនុវត្តការងារស្តីពីនិរន្តរភាពផ្នែកសង្គម និងបរិស្ថាន www.ifc.org/enviro

(យោង២) បទដ្ឋានជានិយាម សំដៅដល់ “គំរូស្តង់ដារ បញ្ញត្តិជាផ្លូវការ” ដែលណែនាំបង្ហាញពីនីតិវិធី សកម្មភាព និងភាពស្រដៀងគ្នានេះ។ បទដ្ឋាននេះរួមមាន ច្បាប់ គោលនយោបាយ បទប្បញ្ញត្តិ។ល។

បទដ្ឋានជានិយាមសម្រាប់ដោះស្រាយជាពិសេស និង ជាក់លាក់ជាមួយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមានចំនួនកំណត់តិចតួចណាស់ ។ ទោះជាយ៉ាងណា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវគ្របដណ្តប់លើបទដ្ឋានជាលក្ខណៈអន្តរជាតិនានា (បញ្ជីតារាង ៤.១)។ ម៉្យាងទៀត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជារឿយៗអាស្រ័យលើគោលនយោបាយជាក់លាក់របស់ប្រទេសនីមួយៗ និង ច្បាប់របស់រដ្ឋាភិបាលថ្នាក់ជាតិតែប៉ុណ្ណោះ (គោលនយោបាយជាតិ ឬ គោលនយោបាយ និង ច្បាប់អនុវត្តក្រោមក្របខ័ណ្ឌនាយកដ្ឋានតាមមុខងារខុសៗគ្នា) និងរដ្ឋាភិបាលថ្នាក់រជាតិ/ខេត្ត/ស្រុក/តំបន់ (ដូចជា ៖ គោលនយោបាយដ៏មានសារៈសំខាន់បំផុត ឬ គោលនយោបាយសម្រាប់បុគ្គលអនុវត្តក្រោមក្របខ័ណ្ឌនៃនាយកដ្ឋានផ្សេងៗ) ។ ឧទាហរណ៍មានបង្ហាញនៅក្នុង (បញ្ជី តារាង៤.២)។

បន្ថែមពីលើនេះ ផ្អែកតាមកិច្ចប្រជុំកំពូលស្តីពីផែនដី និងគម្រោងផ្លូចផ្តើមគំនិតពិភពលោកស្តីពីសង្គម និង បរិស្ថាន ធាតុសំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់សង្គម ក៏ត្រូវដាក់បញ្ចូលគ្នាតាមរយៈក្រុមហ៊ុនអន្តរជាតិនានា (តួយ៉ាងក្រុមហ៊ុនឧស្សាហកម្ម ក្រុមហ៊ុនរ៉ែ ក្រុមហ៊ុនផលិតវារីអគ្គិសនី) សម្រាប់ការអនុវត្តនៅក្នុងគម្រោងផ្លូចផ្តើមគំនិតរបស់ខ្លួន។ ប្រហាក់ប្រហែលនេះដែរ អង្គការមិនមែនរដ្ឋាភិបាលនានា ភ្នាក់ងារផ្តល់ជំនួយ ស្ថាប័នជារបស់រដ្ឋ (ខុសៗគ្នា) ភ្នាក់ងារផ្តល់ជំនួយរបស់រដ្ឋាភិបាល (ខុសៗគ្នា) និង ស្ថាប័ន/សមាគមជំនាញ (ខុសៗគ្នា) ក៏អនុវត្តបទដ្ឋានជានិយាមសម្រាប់សកម្មភាពរបស់ខ្លួន រាប់ទាំងបទដ្ឋាននានាដែលគ្របដណ្តប់លើការវាយតម្លៃហេតុប៉ះពាល់សង្គម ឬ ធាតុសំខាន់ៗរបស់វាផង។

៤.២.១ សារគន្លឹះមួយចំនួននៃបទដ្ឋានជានិយាម

សារគន្លឹះមួយចំនួន (យោង៣) ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់សង្គម ក្នុងក្របខ័ណ្ឌបទដ្ឋានជានិយាម មានដូចតទៅ ៖

- សារៈសំខាន់នៃការគិតគូរលើសង្គម និងបរិស្ថានសង្គមសេដ្ឋកិច្ច (ដូចជា ប្រជាជន ផែនការប្រកបរបរចិញ្ចឹមជីវិត និងសកម្មភាពរកប្រាក់ចំណូលរបស់ប្រជាជន) នៅពេលបង្កើតគំនិតយល់ដឹង ពេលរៀបចំផែនការ ពេលអនុវត្ត ពេលប្រតិបត្តិការ ពេលថែទាំ និងពេលបញ្ចប់គម្រោង ។
- សារៈសំខាន់នៃការទទួលបានការយល់ដឹងលម្អិតអំពីបរិស្ថានសង្គម និងសង្គមសេដ្ឋកិច្ច ជាលើកដំបូង មុនរយៈកាលនៃគម្រោង។

(យោង៣) នេះមិនមែនជាសេចក្តីសង្ខេប ឬ អភិប្រាយនៃសារជាគន្លឹះនោះទេ តែជាការផ្ទុយទៅវិញសារជាគន្លឹះនេះ មានសារៈប្រយោជន៍ត្រូវបានដកស្រង់ចេញ សម្រាប់គោលដៅលាតត្រដាងពីរបៀបនៃការវាយតម្លៃហេតុប៉ះពាល់សង្គម មានចំណងទាក់ទងជាមួយបទដ្ឋានជានិយាម។

- លក្ខខ័ណ្ឌសង្គមជាមូលដ្ឋាន និងសង្គមសេដ្ឋកិច្ច គួរត្រូវបានពិនិត្យស្វង់មើល បង្កើត និង យល់ដឹង មុនពេលអន្តរាគមន៍គម្រោង ។ ការយល់ដឹងពីបរិស្ថានសង្គម និងសង្គមសេដ្ឋកិច្ច និងការផ្តល់ជាគំរូវិភាគវាស់វែងលើផលប៉ះពាល់នៃគម្រោង និង សកម្មភាពកាត់បន្ថយនានា ពិតជាមានសារៈសំខាន់ណាស់។
- ត្រូវកំណត់ឲ្យឃើញច្បាស់ពីជម្រើសដែលអាចជំនួសបាន និង គិតគូរក្នុងកម្រិតល្អិតល្អន់ដូចគ្នាចំពោះជម្រើសនីមួយៗ ទោះជាក្នុងវិធីណាក៏ដោយ គួរតែអនុវត្តឲ្យបាននូវការបញ្ចៀស និង ការកាត់បន្ថយផលប៉ះពាល់។
- ត្រូវកំណត់ និង វាយតម្លៃឲ្យបានច្បាស់លាស់ពីជម្រើសនីមួយៗទាក់ទងនឹងផលប៉ះពាល់ដោយប្រយោល ផលប៉ះពាល់នៃខ្សែទឹកខាងក្រោម និងផលប៉ះពាល់ ដែលរឹតតែមានច្រើនឡើងៗ ។
- ការពាក់ព័ន្ធ/ការចូលរួមរបស់សហគមន៍ទទួលរងផលប៉ះពាល់ដែលអាចកើតមាន ពិតជាមានសារៈសំខាន់ណាស់ក្នុងការ ៖
  - យល់ដឹង និងការកំណត់បរិមាណផលប៉ះពាល់ដែឡអាចកើតមានដោយសារគម្រោង
  - រៀបចំផែនការ និងការអនុវត្តវិធានការកាត់បន្ថយនានា ដូចជាការតាំងទីលំនៅថ្មី ជាដើម។
- ត្រូវពិចារណាឲ្យបានច្បាស់ថា ការតាំងទីលំនៅថ្មី (រាប់ទាំងការផ្លាស់ទីតាំងជាលក្ខណៈសេដ្ឋកិច្ច) អាចជាផលប៉ះពាល់អវិជ្ជមានដ៏ធំតែមួយគត់ទៅលើបរិស្ថានសង្គម អាស្រ័យហេតុនេះកម្មវិធីនៃការតាំងទីលំនៅថ្មី មិនគួរដោះស្រាយតែចំពោះអ្នកតាំងទីលំនៅថ្មីប៉ុណ្ណោះទេ ប៉ុន្តែដល់ប្រជាពលរដ្ឋទាំងអស់នៅជុំវិញទីតាំងសម្រាប់តាំងលំនៅថ្មី ព្រមទាំងដោះស្រាយផលប៉ះពាល់ដែលអាចកើតមានចំពោះប្រជាពលរដ្ឋទាំងនោះទៀតផង។ លើសពីនេះ កម្មវិធីស្តីពីការតាំងទីលំនៅថ្មីគួរតែធ្វើឡើងជាមួយនឹងគំរូអភិវឌ្ឍមួយ ដែលធានាឲ្យមាននិរន្តរភាពដល់ការប្រកបរបរចិញ្ចឹមជីវិត របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារការតាំងទីលំនៅថ្មី (អ្នកតាំងទីលំនៅ និង ទីតាំងសម្រាប់តាំងលំនៅ) (ផ្នែកទី៥)។
- បន្ទាប់ពីបញ្ចប់គម្រោងមួយ (ជាធម្មតាសំដៅដល់ការសាងសង់ចប់រួចរាល់) ស្ថានភាពសង្គម និង សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ អាចមានលក្ខណៈដដែលនៅទីបំផុត ប៉ុន្តែអាចនឹងបានប្រសើរជាងមុន បើប្រៀបធៀបទៅនឹងលក្ខខ័ណ្ឌជាមូលដ្ឋាន។
- ជាមួយនឹងការគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមាន ឧទាហរណ៍ ៖ ការតាំងទីលំនៅថ្មី ការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវផលប្រយោជន៍ សម្រាប់សហគមន៍ឲ្យបានទូលំទូលាយ ហើយគួរមានការយល់ដឹង ការរៀបចំផែនការ និងការអនុវត្តគម្រោងនៅក្នុងសហគមន៍នោះ ឲ្យដូចជាគម្រោងអភិវឌ្ឍនានាប្រកបដោយចីរភាព។

- គួរធ្វើការឲ្យតម្លៃចំពោះលទ្ធភាពរបស់ក្រុមអ្នករៀបចំសំណើអភិវឌ្ឍ ដើម្បីគៀងគរធនធានចាំបាច់នានា ក្នុងការគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមាន និងប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព ហើយបើទោះជាពាក់ព័ន្ធគ្នាយ៉ាងណាក៏ដោយ ត្រូវតែកំណត់ឲ្យបានច្បាស់ និងបង្ហាញឲ្យឃើញពីភាពរាំងស្ទះនានានៃការគ្រប់គ្រងនោះ។
- ត្រូវមានការពិនិត្យតាមដានចំពោះការកាត់បន្ថយ និងការគ្រប់គ្រង ក្នុងអំឡុងពេលកំពុងអនុវត្ត និងក្រោយពេលអនុវត្តគម្រោង ដើម្បីកំណត់ឲ្យឃើញថាតើគេអាចសម្រេចបាននូវលទ្ធផលគាប់ប្រសើរដែរឬទេ ហើយប្រសិនបើមិនអាចសម្រេចបាន ថាតើគេត្រូវអនុវត្តអន្តរាគមន៍ទប់ស្កាត់ដើម្បីធ្វើឲ្យសម្រេចលទ្ធផលទាំងនោះបានដែរឬទេ ។

សំខាន់ជាងនេះទៅទៀត ជាមួយបទដ្ឋានជានិយាមទាំងនេះ ក៏នៅមានការយល់ដឹងមួយក្នុងកម្រិត និង គុណភាពខុសៗគ្នា អាស្រ័យទៅលើការវាយតម្លៃហេតុប៉ះពាល់សង្គមដែលបានអនុវត្តចំពោះគម្រោងផ្លូចផ្តើមគំនិតខុសៗគ្នា (ធំ និងតូច ស្មុគស្មាញ និងសាមញ្ញ ជាតិ និងអន្តរជាតិ ទន្លេជាកម្មសិទ្ធិតែឯកឯង ឬ ជាកម្មសិទ្ធិរួម សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ និងសេដ្ឋកិច្ចអភិវឌ្ឍន៍។ល។ ជាការពិត ការកំណត់លក្ខណៈវិនិច្ឆ័យនៃប្រទេសនីមួយៗ ជារឿយៗបានលទ្ធផលមកវិញជាបទដ្ឋានជានិយាម ដែលត្រូវយកមកប្រើប្រាស់សម្រាប់សកម្មភាពអនុវត្តជាក់លាក់នៅតាមប្រទេសនីមួយៗនេះឯង។

ស្ថាប័នអង្គការ	បទដ្ឋានជានិយាម	ប្រភពយោង	កំណត់សម្គាល់
ធនាគារអភិវឌ្ឍអាហ្វ្រិក	• នីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម (ឆ្នាំ២០០១) • OS1 ៖ ប្រតិបត្តិការការការពារលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សេចក្តីព្រាង (ការវិវត្តន៍ការងារស្តីពីប្រព័ន្ធការពារចម្រុះ) ឆ្នាំ២០១២ • គោលនយោបាយស្តីពីការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្ត • OS2 ៖ ប្រតិបត្តិការការការពារ លើការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត ការទទួលបានសម្បទានដី ការបំលាស់ទីប្រជាពលរដ្ឋ និង ការទូទាត់សំណង សេចក្តីព្រាង (ការវិវត្តន៍ការងារស្តីពីប្រព័ន្ធការពារចម្រុះ) ឆ្នាំ២០១២ • កូនសៀវភៅស្តីពីការពិគ្រោះយោបល់ និង ការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងប្រតិបត្តិការនៃធនាគារអភិវឌ្ឍអាស៊ី (ឆ្នាំ២០០១) • គោលនយោបាយស្តីពីបរិស្ថាន • គោលការណ៍ណែនាំជាយុទ្ធសាស្ត្រស្តីពីការវាយតម្លៃហេតុប៉ះពាល់ • គោលការណ៍ណែនាំរួមស្តីពីការវាយតម្លៃហេតុប៉ះពាល់	• www.afdb.org	• ការវិវត្តន៍ការងារស្តីពីប្រព័ន្ធការពារចម្រុះ បង្ហាញនូវអនុសាសន៍នានា លើការចងក្រងប្រព័ន្ធការពារចម្រុះ ដែលកើតឡើងពីការកំណត់គោលនយោបាយពាក់ព័ន្ធគ្នាទៅវិញទៅមក និងឆ្លងតាមវិស័យ ក៏ដូចជានីតិវិធីវាយតម្លៃបរិស្ថាននិងសង្គម។

	បរិស្ថាន និងសង្គម (ឆ្នាំ២០០៣)		
ធនាគារអភិវឌ្ឍអាស៊ី	• គោលនយោបាយស្តីពីបរិស្ថាន (ឆ្នាំ២០០២) • គោលនយបាយស្តីពីប្រជាជនដើមភាគតិច (១៩៩៨) • ការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (ឆ្នាំ ១៩៩៥) • សេចក្តីថ្លែងការណ៍ស្តី ពីគោលនយោបាយនៃការការពារ (ឆ្នាំ២០០៩)	• www.adb.org	• សេចក្តីថ្លែងការណ៍ពីគោលនយោបាយ ការការពារ (២០០៩) នាំមកនូវការធ្វើបច្ចុប្បន្នភាពឡើងវិញលើគោលនយោបាយ ការពារចំនួន៣។
ធនាគារអឺរ៉ុបសម្រាប់ការស្តារ និងអភិវឌ្ឍន៍	• គោលនយោបាយស្តីពីការផ្តល់ព័ត៌មានជាសាធារណៈ (ឆ្នាំ២០១១) • គោលនយោបាយស្តីពីបរិស្ថាននិងសង្គម (ឆ្នាំ២០០៨)	• www.ebrd.com	• គោលនយោបាយស្តីពីការផ្តល់ព័ត៌មានជាសាធារណៈ ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញក្នុងឆ្នាំ២០១១ • គោលនយោបាយស្តីពីបរិស្ថាន និង សង្គម (ឆ្នាំ២០០៨) គឺជាការពិនិត្យ សើរើឡើងវិញលើគោលនយោបាយ ស្តីពីបរិស្ថាន (ឆ្នាំ ២០០៣)។ គោលនយោបាយ ស្តីពីបរិស្ថាន និងសង្គមនេះត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ការប្តេជ្ញាចិត្ត ចំពោះបញ្ហាសង្គម និង អភិបាលកិច្ចល្អ។
សភាពអឺរ៉ុប	• សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាសភាពអឺរ៉ុប លេខ 85/337/EEC-ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ១៩៨៥)	• www.ec.eropa.eu	

	• សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាសភាពអឺរ៉ុប លេខ 2001/42/EC-សេចក្តីបង្គាប់ស្តីពីការវាយតម្លៃជាយុទ្ធសាស្ត្រ លើបរិស្ថាន • គោលការណ៍ណែនាំរបស់សហភាពអឺរ៉ុប ស្តីពីការវាយតម្លៃហេតុប៉ះពាល់ដោយប្រយោល និង ដែលកើតមានរឹតតែធ្ងន់ធ្ងរ • អនុសញ្ញា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងបរិបទប្រទេសដែលមានព្រំប្រទល់ដែនជាប់គ្នា (ឆ្នាំ១៩៩១)		
គោលការណ៍អេក្វាទ័រ	• វិធីសាស្ត្រឧស្សាហកម្ម សម្រាប់វិទ្យាស្ថានហិរញ្ញវត្ថុក្នុងការកំណត់ឲ្យបានច្បាស់ ការវាយតម្លៃ និងគ្រប់គ្រងហានិភ័យលើផ្នែកបរិស្ថាន និងផ្នែកសង្គម ក្នុងការធ្វើហិរញ្ញប្បទានសម្រាប់គម្រោង (ខែមិថុនា ឆ្នាំ២០០៣) • ការវាស់វែងឧស្សាហកម្មហិរញ្ញវត្ថុសម្រាប់កំណត់ឲ្យច្បាស់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យលើផ្នែកបរិស្ថាន និង សង្គម ក្នុងការធ្វើហិរញ្ញប្បទានសម្រាប់គម្រោង (ខែមិថុនា ឆ្នាំ២០០៦)	• www.equator-principles.com • http://www.equator-principles.com/index.php/the-eps	• គោលការណ៍អេក្វាទ័រ ពឹងផ្អែកលើគំរូស្តង់ដាររបស់ ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC • ចាប់ពីថ្ងៃទី១ មករា ឆ្នាំ២០១២ គំរូស្តង់ដាររបស់ក្រុមហ៊ុនហិរញ្ញវត្ថុអន្តរជាតិ IFC ដែលបានសើរើរួច បានចូលជាធរមាន សម្រាប់សមាជិកសមាគមគោលការណ៍អេក្វាទ័រ
ធនាគារអភិវឌ្ឍអន្តរអាមេរិកកាំង	• ធនាគារអភិវឌ្ឍអន្តរអាមេរិកកាំង សម្រាប់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត គោលការណ៍ ប្រតិ-បត្តិការ ៧-១០	• www.iadb.rog	

	• ធនាគារអភិវឌ្ឍអន្តរអាមេរិកកាំង គោលនយោបាយស្តីពីការព្រមព្រៀងបរិស្ថាន និងការការពារ (២០០៦) • គោលការណ៍ណែនាំលើវិស័យឯកជនស្តីពីបរិស្ថាន និងសង្គម (២០០៤)		
សមាគមអន្តរជាតិទទួលបន្ទុកវាយតម្លៃហេតុប៉ះពាល់	• ការវាយតម្លៃហេតុប៉ះពាល់សង្គម ៖ គោលការណ៍អន្តរជាតិ (ខែឧសភា ២០០៣)	• Vanclay, F. (2003) • www.iaia.org	
អង្គការសហប្រជាជាតិ	• អនុសញ្ញាអេសពូ (Espoo Convention) ឆ្នាំ១៩៩៧ • សេចក្តីណែនាំស្តីពីបរិស្ថានដោយការយកចិត្តទុកដាក់លើគម្រោងថាមពលកកើតឡើងវិញ	• www.un.org	• អនុសញ្ញាអេសពូ ត្រូវបានធ្វើវិសោធនកម្មចំនួនពីរដងនាឆ្នាំ ២០០៤ ប៉ុន្តែគ្មានការកែប្រែណាមួយ ត្រូវបានរំពឹងថា អាចយកមកអនុវត្តនៅគ្រាណាមួយបានឡើយ។
ក្រុមធនាគារពិភពលោក (ធនាគារពិភពលោក ក្រុមហ៊ុនហិរញ្ញវត្ថុ និងភ្នាក់ងារធានារ៉ាប់រងការវិនិយោគពហុភាគី)	• គោលការណ៍ប្រតិបត្តិ (OP) ៤.០១-ការវាយតម្លៃបរិស្ថាន (ពិនិត្យជាថ្មីឆ្នាំ២០១១ សើរើឡើងវិញ ខែមេសា ឆ្នាំ២០១២) • គោលការណ៍ប្រតិបត្តិ ៤.១២-ការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត (សើរើឡើងវិញខែ ឆ្នាំ២០១១) • សេចក្តីបង្គាប់ប្រតិបត្តិការ ៤.២០-ប្រជាជនដើមភាគតិច • គោលការណ៍ប្រតិបត្តិ ៤.១១- ធនធានវប្បធម៌ជាលក្ខ-ណៈរូបវន្ត (ពិនិត្យជាថ្មីខែមីនា ឆ្នាំ២០០៧)	• www.worldbank.org • www.ifc.org • www.miga.org	• គោលការណ៍ប្រតិបត្តិ (OP) ៤.០១ ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ក្នុងខែធ្នូ ឆ្នាំ២០១១ ដើម្បីបញ្ចាក់ពីការប្រើប្រាស់ឧបករណ៍បទដ្ឋាននានា និង ដើម្បីដាក់បន្ថែមការវាយតម្លៃជាយុទ្ធសាស្ត្រស្តីអំពីបរិស្ថាននិងសង្គម ទៅក្នុងតារាងឧបករណ៍ដែលមានស្រាប់។ • គោលការណ៍ប្រតិបត្តិត្រូវបានសើរើឡើងវិញកាលពីមុន នៅឆ្នាំ២០០៧ ដើម្បី

	• គោលនយោបាយ ស្តីពីនិរន្តរភាពលើផ្នែកសង្គម និងបរិស្ថាន (២០០៦) • IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារអនុវត្តការងារស្តីពីនិរន្តរភាពលើផ្នែកបរិស្ថាន និង សង្គម (ចាប់ផ្តើមអនុវត្តខែមករា ឆ្នាំ២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ១- ការវាយតម្លៃ និង ការគ្រប់គ្រងហានិភ័យលើផ្នែកសង្គម និងបរិស្ថាន និងផលប៉ះពាល់នានា (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ២- លក្ខខ័ណ្ឌពលកម្ម និងការងារ (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៣- ប្រសិទ្ធភាពនៃធនធាន និង ការបង្ការការបំពុលបរិស្ថាន (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៤- សុខភាព សុវត្ថិភាព និងសន្តិសុខរបស់សហគមន៍ (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៥- ការទទួលបានសម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៦- ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិត ប្រកបដោយចីរភាព (២០១២)		ឆ្លុះបញ្ចាំងការធានាOP/BP 8.00 ការឆ្លើយតបយ៉ាងឆាប់រហ័ស ចំពោះវិបត្តិ និង ភាពអាសន្ន ហើយត្រូវបានសើរើម្តងទៀតនៅខែសីហា ឆ្នាំ២០០៤ ដើម្បីធានាឲ្យមានភាពស្របគ្នាទៅនឹងតម្រូវការនៃOP/BP 8.60 • OP 4.12 ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញនៅក្នុងខែកុម្ភៈ ឆ្នាំ២០១១ ដើម្បី បញ្ជាក់ពីការប្រើប្រាស់គណនេយ្យអេសក្រូ (Escrow Accounts) ក្នុងគោលបំណងជួយកាត់បន្ថយការពន្យាលើការអនុវត្តការតាំងទីលំនៅថ្មី ការគួសបញ្ជាក់ពីការផ្តល់មូលនិធិសម្រាប់យន្តការ ស្តីពីសារទុក្ខ។ OP 4.12 ក៏ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញក្នុងឆ្នាំ២០០៧ និង ឆ្នាំ ២០០៤ សម្រាប់ហេតុផលតែមួយដូចគ្នានឹង OP 4.01 ដែរ។ • OP 4.11 ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ដើម្បីឆ្លុះបញ្ចាំងពីការធានាដល់ OP/BP 8.00 ការឆ្លើយតបយ៉ាងឆាប់រហ័ស ចំពោះវិបត្តិ និងភាពអាសន្ន • គំរូស្តង់ដារអនុវត្តការងាររបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC ត្រូវបាន

	-IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៧- ប្រជាជនដើមភាគតិច (២០១២) -IFC ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារ ៨-បេតិកភណ្ឌវប្បធម៌ (២០១២) • គោលការណ៍ធនាគារ ១៧.៥០-ការប្រកាសបិទជាសាធារណៈ:		ធ្វើបច្ចុប្បន្នភាពឡើងវិញក្នុងឆ្នាំ២០១២

តារាង៤២ តារាងគំរូស្តីពីបទដ្ឋានជានិយាមនៃប្រទេសនីមួយៗ ដែលអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម

ប្រទេស	បទដ្ឋានជានិយាម	យោង
ប្រទេសអូស្ត្រាលី	• ច្បាប់ខាំមូនវីលស្តីពីការការពារ និងអភិរក្សបរិស្ថាន (១៩៩៩) • ច្បាប់ខ្វីនសឺឡេនស្តីពីការការពារបរិស្ថាន (១៩៩៤) • ច្បាប់ខ្វីនសឺឡេនស្តីពីបេតិកភ័ណ្ឌ (១៩៩២) • ច្បាប់ស្តីពីការរៀបចំផែនការចម្រុះ (១៩៩៧) • ទីក្រុងហុលរ៉ដ (២០០២) (របៀបវាយតម្លៃឲ្យបានពេញលេញនូវហេតុប៉ះពាល់សង្គម) • ទីក្រុងហុលរ៉ដ (២០០៤) (គោលនយោបាយវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់អនុវត្តកិច្ចអភិវឌ្ឍ)	• www.deh.gov.au/epbc/index.html • www.legislation.qld.gov.au • www.randwick.nsw.gov.au/attachments/SIAguidelines300062006.pdf
ប្រទេសប្រេស៊ីល	• ច្បាប់គោលនយោបាយស្តីពីបរិស្ថានជាតិនៃប្រទេសប្រេស៊ីល (ច្បាប់៦៩៣៨/៨១)	• សំអាងលើគម្រោងថាមពលវារីអគ្គិសនី Campos Novos-របាយការណ៍គ្រប់ គ្រងបរិស្ថាន និង សង្គម។ ធនាគារអភិវឌ្ឍអន្តរអាមេរិកកាំង (២០០៤)
ប្រទេសកាណាដា	• ច្បាប់ស្តីពីការវាយតម្លៃបរិស្ថាននៃប្រទេសកាណាដា (១៩៩២) • ច្បាប់ស្តីពីការវាយតម្លៃបរិស្ថាននៃប្រទេសប្រឺធីសកូឡុំប៊ី (១៩៩៥)	• http://laws.justice.gc.ca
ប្រទេសចិន	• ច្បាប់ស្តីពីការការពារបរិស្ថាននៃសាធារណៈរដ្ឋប្រជាមានិកចិន (១៩៨៩)	• http://www.china.org.cn • http://www.zhb.gov.cn
ប្រទេសអ៊ីរ៉ង់	• មាត្រាទី៥០ នៃរដ្ឋធម្មនុញ្ញសាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ • ច្បាប់ស្តីពីការទទួលបានសម្បទានដី (១៩៨០) • ច្បាប់ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ សង្គម (១៩៨៩) • ច្បាប់ស្តីពីការការពារ និងអភិវឌ្ឍន៍បរិស្ថាន (១៩៩១)	• www.parstimes.com/law/iran • ច្បាប់សំអាងលើគម្រោងគ្រប់គ្រងដីធ្លីចម្រុះ និង ទឹកនៅAlborz-ការវាយតម្លៃបន្ថែមស្តីពីបរិស្ថាន និង សង្គម ៖ របាយការណ៍ សង្ខេប។ ក្រុមហ៊ុនវិស្វកម្មផ្តល់ឱវាទមាហាប់កុដស្ស (Mohab Ghodss

		Consulting Engineers (២០០៥)
ប្រទេសណេប៉ាល់	• ច្បាប់ស្តីពីការការពារបរិស្ថាន (១៩៩៦) • ច្បាប់ស្តីពីធនធានទឹក (១៩៩២) • គោលនយោបាយបរិស្ថាននៃប្រទេសណេប៉ាល់ និងផែនការសកម្មភាព (១៩៩៣) • វិធាននៃការការពារបរិស្ថាន (១៩៩៧) (ត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩) • គោលការណ៍ណែនាំជាតិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៣) • មគ្គុទ្ទេសក៍ស្តីពីការវាយតម្លៃបរិស្ថានក្នុងប្រទេសណេប៉ាល់ (២០០២) • ការទទួលបានសម្បទាន ការទូទាត់សំណង និងផែនការស្តារឡើងវិញ (ប្រទេសណេប៉ាល់ ១៩៩៩)	• សំអាងលើការសិក្សាស្រាវជ្រាវលំដាប់ខ្ពស់លើគម្រោងស្តុកវារីអគ្គិសនីនៅសេតិផ្នែកខាងលើ (ដាម៉ូលី)។ NEA (2004)
ប្រទេសនីហ្គ្រី	• ច្បាប់ស្តីពីបរិស្ថាននៃប្រទេសនីហ្គ្រី	• http://www.ibimet.cnr.it/Case/den/Documents/Code_environment.pdf
ប្រទេសប៉ូឡូញ	• ច្បាប់ស្តីពីការការពារបរិស្ថាននៃប្រទេសប៉ូឡូញ (២០០១) • ច្បាប់ស្តីពីការអភិរក្ស និងការការពារជាប្រវត្តិសាស្ត្រនៃប្រទេសប៉ូឡូញ (២០០៣)	• ច្បាប់សំអាងលើការវាយតម្លៃបរិស្ថាននៃគម្រោងការពារទឹកជំនន់នៅអាងទន្លេអូដ្រា Regional Water Board Gliwice រដ្ឋាភិបាលនៃប្រទេសប៉ូឡូញ (២០០៥)
ប្រទេសសេរ៉ាឡេអូន	• គោលនយោបាយជាតិស្តីពីបរិស្ថាន (១៩៩០) • ច្បាប់ស្តីពីការការពារបរិស្ថាន (២០០០)	• គោលនយោបាយ និង ច្បាប់ សំអាងលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងវារីអគ្គិសនី ប៊ុមបុយណា ៖ ពង្រាងរបាយការណ៍ចុងក្រោយ ។ Nippon Koei UK (2005)
ប្រទេសអាហ្វ្រិកខាងត្បូង	• ច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋអាហ្វ្រិកខាងត្បូង (ច្បាប់១០៨ នៃឆ្នាំ១៩៩៦) ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋអាហ្វ្រិកខាងត្បូង (ច្បាប់៣៥ នៃឆ្នាំ១៩៩៧)	• www.info.gov.za/documents/constitution/index.htm • www.info.gov.za/gazette/acts/1998/a107-98.pdf • www.acts.co.za/enviro

	• ច្បាប់ជាតិស្តីពីការគ្រប់គ្រងបរិស្ថាន (ច្បាប់១០៧ នៃឆ្នាំ១៩៩៨) • ច្បាប់ស្តីពីការអភិរក្សបរិស្ថាន (ច្បាប់៧៣ នៃឆ្នាំ១៩៨៩) • ច្បាប់ជាតិស្តីពីទឹក (ច្បាប់៣៦ នៃឆ្នាំ១៩៩៨) • ច្បាប់ជាតិស្តីពីធនធានបេតិកភ័ណ្ឌ (ច្បាប់២៥ នៃឆ្នាំ១៩៩៩)	• www.info.gov.za/gazette/acts/1998/a36-98.pdf • www.dac.gov.za/acts/a25-99.pdf
ប្រទេសស្វ៊ីសឺឡែន	• ច្បាប់ស្តីពីអាជ្ញាធរបរិស្ថាននៃប្រទេសស្វ៊ីសឺឡែន (១៩៩២)	• www.ecs.co.sz/leg_sd_files/env_leg_sd_seaact.htm
ប្រទេសវៀតណាម	• ច្បាប់ស្តីពីការការពារបរិស្ថាន (១៩៩៣) • ក្រិតស្តីពីការផ្តល់សេចក្តីណែនាំសម្រាប់អនុវត្តច្បាប់ស្តីពីការការពារបរិស្ថាន (១៩៩៤) • សេចក្តីណែនាំស្តីពីការតាំងទីលំនៅថ្មី និងការស្តារឡើងវិញនៃប្រទេសវៀតណាម	សំអាងលើ ៖ • Bladh, U. & Nilsson, E-L. (2005). តើត្រូវរៀបចំផែនការសម្រាប់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដោយរបៀបណា ? ករណីគម្រោងថាមពល វារីអគ្គិសនីស៊ុនឡា ក្នុងប្រទេសវៀតណាម។ • កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (២០០០) ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជំហានបឋម នៃគម្រោងទន្លេហ្គាំ។ • http://www.undp.org.vn/projects/parc/docs/bn6-eia.pdf
ប្រទេសថៃ	• មិនមានច្បាប់ណាមួយកំណត់ដោយផ្ទាល់ឡើយ ប៉ុន្តែមានជាប់ទាក់ទងជាមួយការវាយតម្លៃហេតុប៉ះពាល់សង្គម និងការចូលរួមជាសាធារណៈ • ច្បាប់រដ្ឋធម្មនុញ្ញ ពុទ្ធសករាជ២៥៥០ (ឆ្នាំ២០០៧ មានការផ្តល់សិទ្ធិ និង សេរីភាពដល់ពលរដ្ឋក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន ដូចដែលមានរាប់បញ្ចូលនៅក្នុងទស្សនវិស័យចំនួន៣ • សិទ្ធិទទួលបានការជួបប្រជុំ និងទទួលព័ត៌មាន	• ក្រសួងសុខាភិបាលសាធារណៈ • ក្រសួងធនធានធម្មជាតិ និងបរិស្ថាន • ក្រសួងមហាផ្ទៃ • ការិយាល័យនិយតកម្មនាយករដ្ឋមន្ត្រី • ក្រសួងយុត្តិធម៌ except NEQA in MONRE

	• សិទ្ធិក្នុងការចូលរួមដោយប្រជាពលរដ្ឋ • សិទ្ធិទទួលបានប្រព័ន្ធយុត្តិធម៌ • ច្បាប់ជាតិស្ដីពីសុខភាព ឆ្នាំ២០០៧ ដែលបានកំណត់ពីសារសំខាន់នៃសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការរស់នៅក្នុងបរិស្ថានល្អ។ • ច្បាប់ជាតិស្ដីពីគុណភាពបរិស្ថាន ពុទ្ធសករាជ២៥៣៥ (១៩៩២) បានផ្ដល់នូវសិទ្ធិទទួលបានព័ត៌មានអំពីបរិស្ថាន (ផ្នែកទី៦) ប៉ុន្តែមិនមានបញ្ញត្តិជាក់លាក់ណាដែលជួយសម្រួលដល់ការទទួលបានព័ត៌មាននេះពីសាធារណជនឡើយ។ • ច្បាប់ជាតិស្ដីពីគុណភាពបរិស្ថាន ពុទ្ធសករាជ ២៥៣៥ (១៩៩២) បានប្រកាសពីគម្រោងនានា (ប្រភេទ និង ទំហំ) ដែលត្រូវតែអនុវត្តការសិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ការវាយតម្លៃហេតុប៉ះពាល់សង្គម រួមទាំងការចូលរួមជាសាធារណៈ ត្រូវរៀបចំឡើងស្របតាមនីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ • ច្បាប់ស្ដីពីនីតិវិធីរដ្ឋបាល ពុទ្ធសករាជ ២៥៣៩ (១៩៩៦) ដែលបានកំណត់ពី វិធានទូទៅ និងមានតម្លាភាព និង ដំណើរការនៃនីតិវិធីលើការធ្វើសេចក្ដីសម្រេចចិត្តសម្រាប់ភ្នាក់ងាររដ្ឋាភិបាល តាមរយៈការកំណត់ឲ្យឃើញ ពីជំហាននានាទាក់ទងនឹងសេចក្ដីសម្រេចចិត្តទាំងនេះ និងកំណត់ឲ្យឃើញពីអ្នកដែលអាចចូលរួម ។ • សវនាការជាសាធារណៈ ពុទ្ធសករាជ ២៥៤៨ (២០០៥) បានផ្ដល់ឱកាសដល់សាធារណជនអាចចូលរួមក្នុងដំណើរការ ក្នុងការសម្រេចចិត្តទាក់ទងនឹងគម្រោងរបស់រដ្ឋ។ • ច្បាប់ស្ដីពីការទទួលបានប្រព័ន្ធយុត្តិធម៌ ជាឧទាហរណ៍ ច្បាប់ដែលបានកំណត់ទោសបញ្ញត្តិចំពោះការរំលោភបំពានលើបរិស្ថាន។ • ច្បាប់នីតិក្រមស៊ីវិល ច្បាប់ស្ដីពីការបង្កើតតុលាការរដ្ឋបាល និង នីតិវិធីតុលាការរដ្ឋបាល ពុទ្ធសករាជ២៥៤២ (១៩៩៩)	សំអាងលើ ៖ • របាយការណ៍សំយោគ ស្ដីពីអភិបាលកិច្ចបរិស្ថានល្អ ៖ សន្ធស្សន៍នៃការ ចូលរួមជាសាធារណៈ សម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាពនៃប្រទេសថៃ ការវាយតម្លៃលើកទី៣ ធ្វើឡើងដោយបណ្ដាញគម្រោងផ្លូចផ្ដើមគំនិតលើការវាយតម្លៃ របស់អង្គការមិនមែនរដ្ឋាភិបាលចំនួន៤ • វិទ្យាស្ថានបរិស្ថាននៃប្រទេសថៃ • វិទ្យាស្ថានស្ដេចព្រះចាធិប៉ុក • មូលនិធិអភិវឌ្ឍប្រកបដោយចីរភាព • យុទ្ធសាស្ត្រគោលនយោបាយគម្រោងស្ដីពីមូលដ្ឋានធនធានតំបន់ត្រូពិក ស្ថិតក្រោមការគ្រប់គ្រងដោយគណៈកម្មការជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៃប្រទេសថៃ។ • ការគាំទ្ររបស់កិច្ចការបរទេសនៃចក្រភពអង់គ្លេស និង ការិយាល័យខាំមូនវែលនិងមូលនិធិហ្វត។

	• ច្បាប់ជាតិស្តីពីគុណភាពបរិស្ថាន ពុទ្ធសករាជ២៥៣៥ (១៩៩២) • ក្រមព្រហ្មទណ្ឌ	
ប្រទេសកម្ពុជា	• ច្បាប់ជាតិស្តីពីការការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) បានលើកឡើងអំពី “ មូលនិធិទាយជ្ជទានបរិស្ថាន (EEF) ” សម្រាប់គម្រោងឧស្សាហកម្ម កសិកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ អាចជាការរួមចំណែកក្នុងការការពារបរិស្ថាន និងអភិវឌ្ឍសង្គម ដោយផ្អែកលើកិច្ចព្រមព្រៀងសម្បទានគម្រោង។ • អនុក្រឹតស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩) បន្ថែមលើច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រកាសលេខ៩៦១) ចុះថ្ងៃទី៦ មេសា ឆ្នាំ២០០០ ៖ មិនអនុញ្ញាតឲ្យមានការដកចេញនូវការបង់ថ្លៃពីថវិកាជាតិ សម្រាប់រចនាសម្ព័ន្ធ និងទ្រពសម្បត្តិដទៃទៀតរបស់រដ្ឋ ដែលស្ថិតនៅក្នុង the ROW (សិទ្ធិធ្វើដំណើរស្របច្បាប់) • អនុក្រឹតលេខ ១៩ ANK/BK (ចុះថ្ងៃទី១៩ មីនា ឆ្នាំ២០០៣) ស្តីពីដំណោះស្រាយលើសម្បទានដីសង្គមកិច្ច • ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ • សេចក្តីសម្រេចលេខ១៣ និងប្រកាសលេខ០៩៨ ស្តីពីការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត ក្នុងប្រទេសកម្ពុជា។ សេចក្តីសម្រេចលេខ ១៣ ចុះថ្ងៃទី១៨ មីនា ឆ្នាំ១៩៩៧ សំដៅដោះស្រាយលើការតាំងទីលំនៅថ្មី និង ការផ្តល់ហិរញ្ញប្បទាន ប៉ុន្តែការដោះស្រាយនេះ ត្រូវបានអនុវត្តកាន់តែសកម្ម ចាប់តាំងពីការបង្កើតគណៈកម្មការទទួលបន្ទុកដោះស្រាយការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (IRC) នៅឆ្នាំ១៩៩៩។	• ក្រសួងបរិស្ថាន • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រទេសឡាវ	• ច្បាប់ស្តីពីទឹក និងធនធានទឹក (១៩៩៦) • ច្បាប់ស្តីពីការការពារបរិស្ថាន (១៩៩៩) • ច្បាប់ស្តីពីដីធ្លី (២០០៣) • ក្រិតលេខ១៩២/PM ស្តីពីការទូទាត់សំណង និង ការតាំងទីលំនៅថ្មី នៃគម្រោងអភិវឌ្ឍន៍ (២០០៥) • គោលការណ៍បច្ចេកទេសស្តីពីការទូទាត់សំណង និងការតាំងទីលំនៅថ្មីនៃគម្រោងអភិវឌ្ឍន៍ (២០០៥) • ក្រិតលេខ១២២/PM ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (២០១០) • គោលនយោបាយជាតិស្តីពីបរិស្ថាន និង និរន្តរភាពនៃវិស័យថាមពលវារីអគ្គិសនី សង្គម នៃសាធារណរដ្ឋប្រជាធិបតេយ្យឡាវ (២០១១)	• រដ្ឋសភានៃប្រទេសឡាវ • ការិយាល័យនាយករដ្ឋមន្ត្រីឡាវ • ក្រសួងថាមពល និងរ៉ែ

ប្រអប់អត្ថបទ៤.៤ បទដ្ឋានជានិយាម-ទិដ្ឋភាពគន្លឹះ
• បទដ្ឋានជានិយាមសម្រាប់ដោះស្រាយជាពិសេស និង ជាក់លាក់ជាមួយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមានចំនួនកំណត់តិចតួចណាស់។ • ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានគ្របដណ្តប់លើបទដ្ឋានអន្តរជាតិនានាជាច្រើន រួមមាន ៖ (ភ្នាក់ងារផ្តល់ជំនួយ សមាគម អង្គការមិនមែនរដ្ឋាភិបាល ។ល។) ជារឿយៗការវាយតម្លៃត្រូវបានណែនាំបង្ហាញតាមរយៈគោលនយោបាយនិងច្បាប់ជាក់លាក់របស់ប្រទេស រដ្ឋាភិបាល ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់រដ្ឋ ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន។ • សារគន្លឹះដែលមាននៅក្នុងបទដ្ឋានជានិយាម បង្ហាញយ៉ាងច្បាស់អំពីការចូលរួមរបស់ប្រជាពលរដ្ឋរង-ផលប៉ះពាល់ ការយល់ដឹងអំពីបរិស្ថានសង្គម ដែលអាចបង្កជាផលប៉ះពាល់ដោយសារគម្រោង ការព្យាករណ៍ផលប៉ះពាល់ ការបញ្ចៀសផលប៉ះពាល់ តាមរយៈការគិតគូពិចារណាអំពីជម្រើស ដែលអាចជំនួសបាន និង ការបង្កើតផែនការទូលំទូលាយ ដើម្បីដោះស្រាយចំពោះផលប៉ះពាល់ជាអវិជ្ជមាន និងប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព។ • វិធីសាស្ត្រអភិវឌ្ឍ ត្រូវបានគាំទ្រនៅទីបំផុតពីសំណាក់ប្រជាពលរដ្ឋរងគ្រោះ ដែលមានភាពល្អប្រសើរជាងមុនពេលអន្តរាគមន៍។ • ការបន្តត្រួតពិនិត្យ និង វាយតម្លៃ គឺមានភាពចាំបាច់ណាស់កដើម្បីធានាថា លទ្ធផលគាប់ប្រសើរត្រូវបានសម្រេចជោគជ័យ ហើយប្រសិនបើពុំដូច្នេះទេ ចាំបាច់ត្រូវមានវិធានការបង្ការជាមុន។

ប្រធានបទពិភាក្សា	តើបទដ្ឋានជានិយាយអ្វីខ្លះដែលមាននៅក្នុងប្រទេសរបស់អ្នក ហើយដែលបទដ្ឋានទាំងនេះស្របទៅនឹងសារជាគន្លឹះដែលមាននៅក្នុងបទដ្ឋានជានិយាមអន្តរជាតិដែរឬទេ? ..... តើត្រូវធ្វើរបៀបណា ដើម្បីធ្វើឲ្យប្រសើរនូវការធានាឲ្យកាន់តែទូលំទូលាយ ចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ហើយត្រូវកាត់បន្ថយជាបណ្តើរៗនូវផលប៉ះពាល់ទាំងនោះដោយរបៀបណា ហើយគួរតែស្តារ និងធ្វើឲ្យប្រសើរឡើងវិញដោយរបៀបណា ចំពោះរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរងគ្រោះទាំងនោះ?
លំហាត់	តើគេអាចធ្វើឲ្យសេដ្ឋកិច្ចងើបឡើងវិញ និងអាចអនុវត្តជាក់ស្តែងបាន ដើម្បីជម្រុញឲ្យប្រសើរឡើងចំពោះរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋបានដែរឬទេ ?

៤.៣- ការវាយតម្លៃហេតុប៉ះពាល់សង្គម និងរយៈកាលនៃការអនុវត្តគម្រោង

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីការអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម ក្នុងរយៈកាលនៃការអនុវត្តគម្រោង។
ទិសដៅ	•ដើម្បីរំលេចឲ្យឃើញពីការអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម នៅក្នុងជំហាននីមួយៗនៃរយៈកាលអនុវត្តគម្រោង។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ៖ ឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន។ ផ្នែកទី៤ ៖ ដំណោះស្រាយលើទិដ្ឋភាពសង្គម។ (ផ្នែក៤.១-ការវាតម្លៃហេតុប៉ះពាល់សង្គម។ www.unep.org/dams ..... ACER (ទ្វីបអាហ្វ្រិក) អ្នកផ្តល់ប្រឹក្សាស្តីពីការគ្រប់គ្រងបរិស្ថាន (២០០៧) គម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ៖ ឯកសារស្តីពីការអនុវត្តពាក់-ព័ន្ធ ៖ ការវាយតម្លៃហេតុប៉ះពាល់សង្គមទាក់ទងនឹងប្រជាពលរដ្ឋរងគ្រោះ ។ របាយការណ៍ចុងក្រោយរៀបចំឡើងសម្រាប់គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាននិងគម្រោងទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ។

៤.៣.១ សេចក្តីផ្តើមនៃការវាយតម្លៃហេតុប៉ះពាល់សង្គមក្នុងរយៈកាលនៃការអនុវត្តគម្រោង

ការកសាងគម្រោងត្រូវធ្វើឡើងទៅតាមជំហានៗដែលរួមមានការរៀបចំផែនការ ការអនុវត្ត និងការស្ថាបនា ប្រតិបត្តិការ និងការថែទាំ ការបោះបង់ ឬ ការបញ្ឈប់ដំណើរការ ។ ផលប៉ះពាល់សង្គមមានលក្ខណៈខុសគ្នាទៅតាមជំហាននីមួយៗ ។ ករណីសិក្សាពីប្រទេសថៃបង្ហាញថា ផលប៉ះពាល់សង្គមមិនមែនកើតឡើងគ្រប់តែជំហាននៃគម្រោងនោះទេ។

៤.៣.១.១ ការរៀបចំផែនការ/ការបង្កើតគោលនយោបាយ

ការរៀបចំផែនការ សំដៅដល់សកម្មភាពទាំងឡាយណា ដែលអនុវត្តចេញពីពេលវេលានៃគម្រោងមួយ ហើយបានបង្ហាញឲ្យឃើញពីចំនុចនៃការបង្កើត និងការអនុវត្ត។ ការរៀបចំនេះរួមមាន ៖ ការកសាងគម្រោង ការត្រួតពិនិត្យឡើងវិញ ការផ្តល់មតិជាសាធារណៈ ការផ្តល់អាជ្ញាប័ណ្ណ ការវាយតម្លៃពីជម្រើសនានាដែលអាចជំនួសបាន និងការសម្រេចចិត្តទៅពេលខាងមុខ ។ ផលប៉ះពាល់សង្គមចាប់ផ្តើមកើតមានពីថ្ងៃដែលចំណាត់ការត្រូវបានស្នើឡើង និង អាចធ្វើការវាស់វែងបានពីចំនុចនេះ។ អ្នកវាយតម្លៃសង្គម ត្រូវទទួលស្គាល់ពីសារៈសំខាន់នៃការកសាងសង្គមតាមតថភាពជាក់ស្តែង នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលចាប់ផ្តើមពីដំបូងបំផុតមុនជំហានទាំងបួននៃការរៀបចំផែនការ និងការបង្កើតគោលនយោ-បាយ។ ជារឿយៗគេអាចសន្មត់បានថា មិនមានផលប៉ះពាល់ណាមួយកើតឡើងនោះទេ រហូតដល់ជំហាន ទី ២ (ការបង្កើត និងការអនុវត្ត) ដែលជំហាននៃការចាប់ផ្តើមសកម្មភាពគម្រោងមួយ ជាឧទាហរណ៍តាមរយៈ ប្រតិបត្តិការមានការផ្លាស់ប្តូរមិនល្អ ឬ ការចាប់ផ្តើមសកម្មភាពសាងសង់ ។ ទោះជាយ៉ាងណាក៏ដោយគេអាចវាសវែងបាននូវផលប៉ះពាល់ពិតប្រាកដ ដែលជារឿយៗអាចចាប់ផ្តើមកើតមានភ្លាមនូវផលប៉ះពាល់

លើបរិស្ថានមនុស្ស នៅពេលណាមានការផ្លាស់ប្តូរលំដ្ឋខ័ណ្ឌសង្គម ឬ សេដ្ឋកិច្ច។ ចាប់ពីពេលជូនដំណឹងជាលើកដំបូងបំផុត អំពីការផ្លាស់ប្តូរគោលនយោបាយមិនទាន់សម្រេច ឬ ពាក្យចចាមអារាមអំពីគម្រោង រួមទាំងទាំងក្តីសង្ឃឹម ទាំងការជំទាស់ប្រឆាំងអាចចាប់ផ្តើមកើតមានជាហូរហែរ ចំណែកអ្នកស្ទង់មើលអាចថែរក្សាបានដោយសុវត្ថិភាពនូវទ្រព្យសម្បត្តិនានាមានតម្លៃ ចំណែកអ្នកនយោបាយអាចដឹកនាំ ដើម្បីបានតួនាទីមុខតំណែង រីឯក្រុមមនុស្សដែលចាប់អារម្មណ៍លើគម្រោង ក៏អាចប្រមូលផ្តុំ ឬ ប្តូរទិសកម្លាំងថាមពលរបស់ខ្លួន។ ការផ្លាស់ប្តូរទាំងនេះអាចកើតមាន តាមរយៈគ្រាន់តែផ្តល់ព័ត៌មានថ្មីទៅដល់សហគមន៍ ឬ ក្នុងតំបន់តែប៉ុណ្ណោះ។

៤.៣.១.២ ការបង្កើត/ការអនុវត្ត

ជំហាននៃការបង្កើត/ការអនុវត្ត ចាប់ផ្តើមនៅពេលមានការសម្រេចចិត្ត មានការអនុញ្ញាត ឬ មានច្បាប់ ឬ មានបទបញ្ជាក្នុងការអនុវត្ត។ សម្រាប់គម្រោងសាងសង់ជាធម្មតា មានជាប់ទាក់ទងនឹងការរានដី ការស្តាបនាផ្លូវថ្នល់ និងការបង្កើតសេវាសាធារណៈផ្សេងៗ។ល។ ប្រសិនបើចាំបាច់ ការផ្លាស់ទីលំនៅ និងការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ គួរធ្វើឡើងនៅក្នុងជំហាននេះ ។ ការបង្កើតកម្លាំងពលកម្មក្នុងផ្នែកសំណង់ទេសន្តរប្រវេសន៍អាចនឹងកើតមាន អាស្រ័យលើទំហំនៃគម្រោងនោះ ។ ប្រសិនបើមានទេសន្តរ-ប្រវេសន៍កើតមានច្រើន អ្នកតាំងទីលំនៅថ្មីអាចមានកង្វល់ទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ក៏ដូចជាការបង្កើតនូវភាពស្មុគស្មាញផ្នែកសង្គម ដោយសារការផ្លាស់ប្តូរលំនាំនៃអន្តរកម្មសង្គម ។ សហគមន៍អាចមានការលំបាកក្នុងការឆ្លើយតបចំពោះកំណើននៃតម្រូវការផ្នែកសាលារៀន សំណង់អាគារសុខាភិបាល ផ្ទះសម្បែង និង សេវាសង្គមនានា ។ ភាពស្មុគស្មាញលើសពីនេះទៅទៀតអាចកើតឡើងដោយសារ ការអាក់អន់ស្រពន់ចិត្តរវាងអ្នកចំណូលថ្មី និងអ្នកតាំងទីលំនៅយូរយារណាស់ហើយ ដោយសារការកើនភ្លាមៗនៃតម្លៃក្នុងការសាងសង់លំនៅដ្ឋាន និង សេវាកម្មសង្គមនានា ហើយអាចកើតឡើងដោយសារភាពមិនច្បាស់លាស់ជាច្រើននាពេលអនាគត។ នៅពេលចាប់អនុវត្តគោលនយោបាយថ្មី សេដ្ឋកិច្ចក្នុងតំបន់ និងការចាត់ចែងរៀបចំក៏អាចមានការផ្លាស់ប្តូរ ចំណែកឥរិយាបទចាស់ត្រូវជំនួសដោយវិធីថ្មីៗ ទាក់ទងនឹងបរិស្ថាន និងធនធាននានា។

៤.៣.១.៣ ការប្រតិបត្តិ/ការថែទាំ

ជំហាននៃការប្រតិបត្តិ/ការថែទាំ អាចចាប់ផ្តើមបន្ទាប់ពីការសាង់សង់ចប់រួចរាល់ ឬ នៅពេលគោលនយោបាយត្រូវបានអនុវត្តយ៉ាងពេញលេញ។ នៅក្នុងករណីជាច្រើន ជំហាននេះតម្រូវឲ្យមានការប្រើប្រាស់កម្មករតិចជាងជំហាននៃការសាងសង់/ការអនុវត្ត ។ ប្រសិនបើប្រតិបត្តិការត្រូវបន្តនៅក្នុងកម្រិតថេរប្រហាក់ប្រហែលនេះ សម្រាប់ការពន្យារយៈពេលមួយនោះជារឿយៗផលប៉ះពាល់ក្នុងជំហាននេះនឹងផ្តល់ជាផលប្រយោជន៍យ៉ាងធំបំផុតដល់ប្រតិបត្តិការនៅក្នុងជំហានណាមួយទៀត ។ ការស្វែងរកការអភិវឌ្ឍឧស្សាហកម្មរបស់សហគមន៍ ជារឿយៗនឹងផ្តោតសំខាន់នៅក្នុងជំហាននេះ ដោយយោងទៅលើផល-ប្រយោជន៍សេដ្ឋកិច្ចមានលក្ខណៈយូរអង្វែង ដែលអាចកើតមានក្រោយការអភិវឌ្ឍន៍ណាមួយ ។ នៅក្នុងអំឡុងជំហាននេះដែរ សហគមន៍អាចអនុវត្តតាមល័ក្ខខ័ណ្ឌថ្មីផ្នែកសង្គម និង សេដ្ឋកិច្ច អាចមានការសម្រុះសម្រួល ហើយការព្យាករលើផលប៉ះពាល់ជាវិជ្ជមាន ដូចជាចំនួនប្រជាពលរដ្ឋអាចនៅថេរដដែល ហេដ្ឋារចនាសម្ព័ន្ធនៅមានគុណភាព និងអាចមានឱកាសការងារយ៉ាងពិតប្រាកដ។

៤.៣.១.៤ ការបោះបង់/ការបញ្ចប់

ការបោះបង់/ការបញ្ចប់ អនុវត្តនៅពេលការស្នើសុំត្រូវបានធ្វើឡើងថាគម្រោង ឬ គោលនយោបាយ និង សកម្មភាពពាក់ព័ន្ធនឹងត្រូវបញ្ចប់នៅពេលណាមួយនាពេលអនាគត ។ ដូចដែលបានកំណត់នៅក្នុងជំហាននៃការរៀបចំផែនការ ផលប៉ះពាល់សង្គម ដែលបណ្តាលមកពីការបញ្ចប់សកម្មភាព ចាប់ផ្តើមនៅពេលមានការប្រកាសពីបំណងនៃការបញ្ចប់សកម្មភាព ហើយសហគមន៍ ឬ តំបន់ត្រូវតែសម្របខ្លួនជាថ្មីម្តងទៀតទៅតាមនោះដែរ ប៉ុន្តែម្តងនេះគឺជាការបាត់បង់គម្រោង ឬ ជាការកែតម្រូវទៅតាមការផ្លាស់ប្តូរនៃគោលនយោបាយ។ ពេលខ្លះ ប្រការនេះមានន័យថា ជាការបាត់បង់មូលដ្ឋានសេដ្ឋកិច្ច ដោយសារតែការរកស៊ីជួញដូរត្រូវបិទទ្វារ។ នៅពេលខ្លះទៀតអាចមិនមានការបង្កភាពរអាស់រអួលដល់សហគមន៍មូលដ្ឋានច្រើនពេកទេ ឬ យ៉ាងហោចណាស់គ្រាន់តែធ្វើឲ្យមានការផ្លាស់ប្តូរខ្លះ ប្រសិនបើប្រភេទអ្នកអ្នកធ្វើការងារត្រូវបានជំនួសដោយប្រភេទអ្នកធ្វើការងារផ្សេងមួយទៀត ដូចជាករណីមួយចំនួន តួយ៉ាងនៅតំបន់រោងចក្រ ហេនហ្វដ (Handford Facility) នាទីក្រុងវ៉ាស៊ីនតោន ដែលជាទីតាំងរោងចក្រ ផលិតជាតិនុយក្លេអ៊ែរនានាត្រូវបានបញ្ឈប់ដំណើរការ ប៉ុន្តែការមានការងារធ្វើមានចំនួនកើនឡើងសម្រាប់អ្នកជំនាញខាងផ្នែកសំអាតបរិស្ថាន ដែលត្រូវបានជ្រើសរើសឲ្យបម្រើការងារ ក្នុងការជួយដោះស្រាយទៅលើការចម្លងជំងឺនានា នៅ ទីតាំងរោងចក្រ។ ក្នុងករណីផ្សេងៗទៀត ប្រការនេះអាចបង្កជាភាពរអាក់រអួលរិតតែខ្លាំងឡើយ ប្រសិនបើសហគមន៍មិនត្រឹមតែខាតបង់មូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនក្នុងពេលបច្ចុប្បន្ន ប៉ុន្តែថែមទាំងបាត់បង់សមត្ថភាពដើម្បីត្រឡប់ទៅរកមូលដ្ឋានសេដ្ឋកិច្ចពីមុន ។ ទីក្រុងមរហ្គេន រដ្ឋលូ៊ីស្យាណា (Mor-gan City, Louisiana) ដែលធ្លាប់បានប្រកាសដោយខ្លួនឯងថា " ដើមទុនវិនិយោគកំពឹសពិភពលោក" នាទសវត្សរ៍ទី៥០ គឺជាឧទាហរណ៍គំរូដ៏ល្អមួយសម្រាប់សហគមន៍ដែលបាត់បង់សមត្ថភាព ក្នុងការវិលត្រឡប់ទៅរកមូលដ្ឋានសេដ្ឋកិច្ចពីមុនរបស់ខ្លួន។ ក្នុងអំឡុងទសវត្សរ៍ទី៦០ និង៧០ការមានការងារធ្វើនៅក្នុងសហគមន៍នេះ បានផ្លាស់ទៅជាការអភិវឌ្ឍផ្នែករុករកប្រេងនៅបាទសមុទ្រទៅវិញ។ នៅពេលតម្លៃប្រេងធ្លាក់ចុះខ្លាំងនាទសវត្សរ៍ទី៨០ សហគមន៍នេះយល់ឃើញថាមិនអាចត្រឡប់ទៅចាប់ការងារឧស្សាហកម្មកំពឹសបានទៀតទេ ពីព្រោះរោងចក្រផលិតអាហារធ្វើពីកំពឹសបានឈប់ដំណើរការអស់ទៅហើយ រីឯទូកនេសាទកំពឹសមិនត្រូវបានអនុញ្ញាតឲ្យឆ្លងកាត់ ឬ ចាកចេញពីតំបន់សមុទ្រនោះឡើយ។

ដោយមានការស៊ើបអង្កេតមួយលើផ្នែកបរិស្ថាន វិធីសាស្ត្រវិលជុំមួយគួរតែយកមកអនុវត្តសម្រាប់ការវាយតម្លៃហេតុប៉ះពាល់សង្គម ហើយក្នុងន័យនេះការចាប់ផ្តើមឲ្យបានជាមុននូវការវាយតម្លៃពិតជាមានសារៈសំខាន់ខ្លាំងណាស់ មិនខុសពីការចាប់ផ្តើមអនុវត្តជាក់ស្តែងជាមួយនឹងរយៈពេលវិលជុំនៃគម្រោងមួយ ហើយគួរតែបន្តអនុវត្តឲ្យបានពេញលេញ ដោយត្រូវទទួលស្គាល់ថា វិធីសាស្ត្រនិងសកម្មភាពទាំងនេះ នឹងមានលក្ខណៈខុសគ្នាទៅតាមជំហានផ្សេងៗគ្នាក្នុងអំឡុងរយៈពេលវិលជុំនៃគម្រោង។ ចំណាប់អារម្មណ៍ជាទូទៅ សូមមើលនៅក្នុងបញ្ជីតារាង៤.៣។

ប្រអប់អត្ថបទ៤.៥ ការវាយតម្លៃហេតុប៉ះពាល់សង្គម និងរយៈកាលអនុវត្តគម្រោង-ទិដ្ឋភាពគន្លឹះ
• ការវាយតម្លៃហេតុប៉ះពាល់សង្គម គួរតែអនុវត្តនៅគ្រប់ជំហាននៃរយៈកាលអនុវត្តគម្រោង ដោយការអនុវត្តតាមវិធីសាស្ត្រ និងសកម្មភាពផ្សេងៗគ្នា ព្រមទាំងការប្រែប្រួលកម្រិតជាក់លាក់ និងការជឿជាក់។ • មានការលើកជាអនុសាសន៍ថា គួរតែមានការចាប់ផ្តើមឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានចំពោះការវាយតម្លៃហេតុប៉ះពាល់សង្គម ក្នុងអំឡុងរយៈពេលអនុវត្តគម្រោង ។

ប្រធានបទពិភាក្សា	តើអ្នកអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម គួរតែធ្វើការវាយតម្លៃបរិស្ថានសង្គមនៅជំហាននីមួយៗនៃរយៈកាលអនុវត្តគម្រោង ក្នុងកម្រិតជាក់លាក់យ៉ាងណា? ..... ចូរកំណត់និយមន័យ "បញ្ហាស្ថិតក្នុងកំរិតធ្ងន់ធ្ងរ Red flag issue" "ការខូចខាតដែលអាច បណ្តាលឲ្យបាត់បង់ជីវិត fatal flaw " នៅក្នុងបរិបទនៃបរិស្ថានសង្គមទៅលើប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។
លំហាត់	ចូរបង្កើតតារាងម៉ាទ្រិចងាយស្រួលមួយសម្រាប់វាយតម្លៃហានិភ័យ ដែលអាចអនុវត្តនៅក្នុងជំហាននីមួយៗនៃរយៈកាលអនុវត្តគម្រោង សំដៅធ្វើការវាយតម្លៃហានិភ័យសង្គម ទៅតាមការប្រែប្រួលកម្រិតនៃការជឿជាក់។

តារាង៤.៣ ចំណាប់អារម្មណ៍ជាទូទៅស្តីពីការវាយតម្លៃហេតុប៉ះពាល់សង្គម និងរយៈកាលអនុវត្តគម្រោង

ជំហាននៅក្នុងរយៈកាលគម្រោង	លក្ខណៈពិសេសនៃការវាយតម្លៃហេតុប៉ះពាល់សង្គម	លទ្ធផល
គោលនយោបាយ ការរៀបចំផែនការ យុទ្ធសាស្ត្រ ការរៀបចំផែនការអាងទន្លេ	នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់សង្គមត្រូវបានអនុវត្តនៅក្នុងជំហានទាំងនេះក្នុងរយៈកាលគម្រោង គឺចាំបាច់ដូចគ្នាទៅនឹងការចាប់ផ្តើមអនុវត្តនៅក្នុងកម្រិតគម្រោងជាក់លាក់ដែរ ។ ទោះយ៉ាងណា នឹងមានការពឹងអាស្រ័យលើលំដាប់ព័ត៌មានកម្រិតខ្ពស់ ដែលប្រឈមនឹងសេចក្តីត្រូវការ នៃការសម្រេចចិត្តកម្រិតខ្ពស់។	លទ្ធផលគន្លឹះនៅកម្រិតខ្ពស់រួមមាន៖ ការកំណត់ឲ្យបានច្បាស់លាស់ ពីជម្រើសដែលអាចជំនួសបានការកំណត់ឲ្យបានច្បាស់លាស់ ពីបញ្ហាជាគន្លឹះនៃសង្គម និងការវាយតម្លៃក្នុងលំដាប់ដំបូងទៅលើផលប៉ះពាល់នានា និងលទ្ធភាពនៃការអាចគ្រប់គ្រងបានលើបញ្ហាទាំងអស់ដែលមាន។
ការរៀបចំផែនការគម្រោង		
ការបង្កើតឲ្យមានគំនិតយល់ឃើញ	ចំនុចដែលជាការយល់ឃើញផ្អែកលើបទពិសោធន៍កន្លងមក និង យោបល់ប្រកបដោយវិជ្ជាជីវៈរបស់អ្នកវាយតម្លៃហេតុប៉ះ-ពាល់សង្គម។	ការកំណត់ឲ្យបានច្បាស់លាស់ពីបញ្ហាជាគន្លឹះដែលអាចកើតមាន បញ្ហាស្ថិតក្នុងកំរិតធ្ងន់ធ្ងរ "Red flag issue" ការខូចខាត ដែលអាចបណ្តាលឲ្យបាត់បង់ជីវិត fatal flaw ឡាយឡំជាមួយនឹងជម្រើសនៃគំនិតយល់ឃើញខុសៗគ្នា។
ជំហានដំបូងនៃការសិក្សាស្រាវជ្រាវ	ការសិក្សា និងវិភាគនៅជំហានបឋម	ការអះអាងបញ្ជាក់ពីបញ្ហាជាគន្លឹះ និងបញ្ហាស្ថិតក្នុងកម្រិតធ្ងន់ធ្ងរ " Red flag issue" នៅក្នុងកម្រិតនៃការធានាឲ្យមានលក្ខណៈល្អប្រសើរ។
ការសិក្សាស្រាវជ្រាវ	ការងារលើតុ និង ការសិក្សានៅមូលដ្ឋាន ការបកស្រាយ ការវិភាគ ការរួមបញ្ចូលគ្នាការព្យាករផលប៉ះពាល់ និង ចំណាត់នៃការគ្រប់គ្រង។	របាយការណ៍វាយតម្លៃសង្គមទូលំ-ទូលាយ គ្របដណ្តប់លើគ្រប់ទិដ្ឋភាពសង្គម ពាក់ព័ន្ធនឹងជម្រើសនៃការអភិវឌ្ឍដោយឡែក។

ការធ្វើឲ្យលេចចេញជារូបរាង	លក្ខណៈល្អិតល្អន់ វិធីបញ្ចៀស ធ្វើឡើងជាច្រើនដង ការកាត់បន្ថយ និង/ឬ ការគ្រប់គ្រងផលប៉ះពាល់សង្គម។ វិធីសាស្ត្រលម្អិត និង រូមផ្សំដែលផ្តល់ជាលទ្ធផលក្នុងការបង្កើតផែនការគ្រប់គ្រង (ដើម្បីគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមាន ឧ. ផែនការសកម្មភាពនៃការតាំងទី លំនៅថ្មី និងផលប្រយោជន៍នានា ឧ. ផែនការអភិវឌ្ឍសង្គម)	មានលក្ខណៈមិត្តភាពស្និតស្នាល/ ជាការរៀបចំ ដែលអាចទទួលយកបានហើយផែនការគ្រប់គ្រងនានា ត្រូវអនុវត្តក្នុងអំឡុងពេលសាងសង់តែម្តង។
ការអនុវត្តន៍		
ការសាងសង់ ការបញ្ចប់ដំណើរការ	ការប្រគល់ ការអនុវត្តន៍ផែនការនៅទីវាល	ការស្តារឡើងវិញ នូវផែនការចិញ្ចឹមជីវិត (ក្របខ័ណ្ឌគំរូអភិវឌ្ឍ) របស់ប្រជាជនរងផលប៉ះពាល់ជាអវិជ្ជមានពីការអភិវឌ្ឍ។ ការធ្វើឲ្យសម្រេចបានផលប្រយោជន៍។ តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ព្រមទាំងធ្វើឲ្យមានការផ្លាស់ប្តូរ ដូចមានចង្អុលបង្ហាញតាមលទ្ធផលផ្សេងៗ។
ប្រតិបត្តិការ	ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ	បន្តស្តារឡើងវិញនូវផែនការចិញ្ចឹមជីវិតជាមួយការកាត់បន្ថយ/វិធានការគ្រប់-គ្រងបន្ថែម ឬ ថ្មី ដូចមានចង្អុលបង្ហាញតាមរយៈការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលផ្សេងៗ
ការបញ្ចប់សកម្មភាព		
ការប្រកាសបិទ	នីតិវិធីវាយតម្លៃហេតុប៉ះពាល់សង្គមទាំងមូល គួរតែចាប់ផ្តើមសារជាថ្មី ដើម្បីឆ្លើយតបតាមតម្រូវការ នៃការបញ្ចប់សកម្មភាព ការបិទ និង ការគ្រប់គ្រងផលប៉ះពាល់ដែលនៅសេសសល់។	របាយការណ៍វាយតម្លៃសង្គមទូលំទូ-លាយ គ្របដណ្តប់លើគ្រប់ទិដ្ឋភាពសង្គម ពាក់ព័ន្ធនឹងការបញ្ចប់ និងការប្រកាសបិទ។
ភាពសេសសល់	ការប្រគល់ ការអនុវត្តផែនការនៅទីវាល	ការស្តារឡើងវិញនូវផែនការចិញ្ចឹមជីវិត (ក្របខ័ណ្ឌគំរូអភិវឌ្ឍ) របស់ប្រជាជនរងផលប៉ះពាល់ជាអវិជ្ជមានពីការបញ្ចប់សកម្មភាព ការប្រកាសបិទ និង ការគ្រប់គ្រងផលប៉ះពាល់ ដែលនៅសេសសល់ ។ ការធ្វើឲ្យសម្រេចបានផលប្រយោជន៍។ តាមដាន ត្រួត

		ពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើឲ្យមានការផ្លាស់ប្តូរដូចមានចង្អុលបង្ហាញតាមលទ្ធផលផ្សេងៗ។

៤.៤-នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់សង្គម និងធាតុផ្សំសំខាន់ៗ

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីនីតិវិធីអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម។
ទិសដៅ	• ដើម្បីរំលេចឲ្យឃើញពីនីតិវិធីអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម និងធាតុផ្សំសំខាន់ៗរបស់វា ក្នុងលក្ខណៈជាជំហានៗ។ ..... • ដើម្បីផ្តល់ជាឧទាហរណ៍នៃឧបករណ៍មួយចំនួនប្រើប្រាស់ ក្នុងអំឡុងពេលនៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម។
ការអានតាមលំដាប់លំដោយ	Taylor, C.N., Bryan, C.H. and Goodrich (1995). ការវាយតម្លៃហេតុ-ប៉ះពាល់បរិស្ថាន ៖ ទ្រឹស្តី នីតិវិធី និងបច្ចេកទេស។ ការបោះពុម្ពផ្សាយលើកទី២។ The Caxton Press, Christchurch, New Zealand ..... Vanclay, F. (2003). ការវាយតម្លៃហេតុប៉ះពាល់សង្គម គោលការណ៍អន្តរជាតិ ។ សមាគមអន្តរជាតិសម្រាប់ការបោះពុម្ពពិសេសស្តីពីការវាយតម្លៃផលប៉ះពាល់ក្រុមទី២ ..... Burge, J. Rabel J. 2004. ទស្សនយល់ឃើញ នីតិវិធី និងវិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់សង្គម។ សារព័ត៌មានអេកូឡូស៊ីសង្គម ៖ មីដលតុន វីស្កុនសីន សហរដ្ឋអាមេរិក។ ..... IFC. (2002). កូនសៀវភៅសម្រាប់រៀបចំផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។ IFC ៖ នាយកដ្ឋានអភិវឌ្ឍបរិស្ថាន និង សង្គម ។ ក្រុមធនាគារពិភពលោក ក្រុងវរស៊ីនតោន សហរដ្ឋអាមេរិក www.iap2.org/associations/4748/files/fpundations-bro.pdf

៤.៤.១ សេចក្តីផ្តើម

គោលដៅនៃនីតិវិធីវាយតម្លៃហេតុប៉ះពាល់សង្គម គឺចូលរួមចំណែកក្នុងការបង្កើតគោលនយោបាយ ផែនការ កម្មវិធី និង គម្រោង (PPPP's) ឲ្យកាន់តែមានដំណើរការល្អ និង កាន់តែមាននិរន្តរភាពតាមរយៈការធានាឲ្យប្រាកដថា ជម្រើសដែលបានសម្រិតសម្រាំងរួចមានភាពសមស្របទៅនឹងបុគ្គលម្នាក់ៗ និងសហគមន៍ដែលជាអ្នកទទួលផល និងជាអ្នករងផលប៉ះពាល់ ។ ការវាយតម្លៃនេះ គឺជាការជួយធានាប្រសិទ្ធភាពតាមរយៈការបង្កើនការគាំទ្រ និងសម្រុះសម្រួលស្តាប័នឲ្យស្របតាមវប្បធម៌ក្នុងមូលដ្ឋាន និងធ្វើឲ្យគោលនយោបាយ ផែនការ កម្មវិធី និងគម្រោង (PPPP's) កាន់តែមានលក្ខណៈរួមផ្សំតាមរយៈការធ្វើឲ្យមានការចូលរួមមិនត្រឹមតែភាគីពាក់ព័ន្ធដែលបានជ្រើសរើសប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការចូលរួមឲ្យទូលំទូលាយជាងនេះ ព្រមទាំងមានការចូលរួមពីសហគមន៍ផ្សេងៗជាច្រើនបន្ថែមទៀត (ប្រភព Burge and Rabel 2004) ។

នៅប្រទេសទន្លេមេគង្គមួយចំនួន ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) ជារឿយៗត្រូវបានរួមបញ្ចូលជាមួយនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(EIA) ។ ករណីនៅប្រទេសឡាវបង្ហាញថា គ្រប់គម្រោងវារីអគ្គិសនីខ្នាតធំទាំងអស់ ត្រូវធ្វើរបាយការណ៍ពេញលេញស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការគ្រប់គ្រងបរិស្ថាន និងផែនការតាមដានត្រួតពិនិត្យ (EMMP) ការគ្រប់គ្រងសង្គម និងផែនការតាមដានត្រួតពិនិត្យ (SMMP) អនុឡោមទៅតាមច្បាប់ការពារបរិស្ថានឆ្នាំ១៩៩៩ និងក្រឹតលេខ១១២ ឆ្នាំ២០១០ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ នេះមានន័យថា ម្ចាស់គម្រោងនីមួយៗត្រូវតែ ៖

- ប្រតិបត្តិតាមទំហំនៃការសិក្សា និងល័ក្ខខ័ណ្ឌការងារដែលបានព្រមព្រៀងដោយរដ្ឋបាលធនធានទឹក និងបរិស្ថាន។
- ប្រមូលព័ត៌មានពីស្ថានភាពទូទៅនៃគម្រោងវិនិយោគ ដូចជាទិដ្ឋភាពរូបសាស្ត្រ ជីវសាស្ត្រ និងសង្គមសេដ្ឋកិច្ច ទៅតាមផ្នែក និងតាមរដ្ឋបាលមូលដ្ឋាន ឬ តាមរយៈការរៀបចំការសិក្សានៅថ្នាក់មូលដ្ឋាន និង ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងវិនិយោគ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត នៅថ្នាក់ភូមិ ស្រុក និងខេត្ត ក្រុង។
- អនុវត្តការសិក្សា និង កំណត់ឲ្យបានច្បាស់ពីផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលទៅលើអ្នករស់នៅជុំវិញទីតាំងគម្រោង ដោយការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះផលប៉ះពាល់ដល់សុខភាព ការខូចខាតទ្រព្យសម្បត្តិ និងលំនៅដ្ឋាន ផលប៉ះពាល់ដល់ជីវភាពរស់នៅការប្រើប្រាស់ធនធានធម្មជាតិ និងផលប៉ះពាល់ដទៃទៀតលើបរិស្ថាន និងសង្គម ដូចជាប៉ះពាល់លើដី ទឹក អាកាសធាតុ ព្រៃឈើ និងជីវចម្រុះ រួមទាំងបេតិកភ័ណ្ឌស្ថាបត្យកម្ម និងវប្បធម៌ និងបុរាណ-ភណ្ឌ/បុរាណកាល ហើយត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ ស្តីការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន។
- ត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយនានានៅថ្នាក់ភូមិ ដោយសហការជាមួយអាជ្ញាធររដ្ឋបាលមូលដ្ឋាន និងនាយកដ្ឋាន ឬ មន្ទីរពាក់ព័ន្ធ ដើម្បីពន្យល់ពីស្ថានភាពរួមនៃគម្រោងវិនិយោគ ក៏ដូចជាផលប្រយោជន៍ ផលប៉ះពាល់នានាទៅលើបរិស្ថាន និងសង្គម ដែលអាចកើតមានឡើងដោយសារគម្រោងវិនិយោគនោះ ពន្យល់ពីវិធានការបង្ការ និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងសង្គម ព្រមទាំងធ្វើការសង្ខេបឡើងវិញ ពីមតិយោបល់ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍។

- រៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ការគ្រប់គ្រងបរិស្ថាន និង ផែនការតាមដានត្រួតពិនិត្យ (EMMP) និងការគ្រប់គ្រងសង្គម និងផែនការតាមដានត្រួតពិនិត្យ (SMMP) ដែលរួមបញ្ចូលទាំងការវាយតម្លៃផលប៉ះពាល់លើសុខភាព និងវិធានការគ្រប់គ្រងលើវិស័យសុខាភិបាល និងដាក់បង្ហាញជូនប្រជាពលរដ្ឋរងផលប៉ះពាល់ មុននឹងដាក់ស្នើសុំការយល់ព្រមពីរដ្ឋាភិបាល។

របៀបនិងវិធីសាស្ត្រសម្រាប់ការវាយតម្លៃហេតុប៉ះពាល់សង្គម ប្រែប្រួលអាស្រ័យលើគោលបំណង និង ការអនុវត្តនៃការវាយតម្លៃនោះ ។ ទោះជាយ៉ាងណា ដំណើរការជាទូទៅមានជាប់ពាក់ព័ន្ធចំនុច ដូចខាងក្រោម ៖

- ការកំណត់ចរិកលក្ខណៈនៃបរិស្ថានសង្គម និងការកំណត់និយមន័យនៃព្រំប្រទល់ដែន។
- ការយល់ដឹងអំពីអន្តរាគមន៍ (គោលនយោបាយ ផែនការ កម្មវិធី ឬ គម្រោង) ដើម្បីជួយឲ្យមានការព្យាករណ៍ទៅលើផលប៉ះពាល់ពលនានា។
- ការប៉ាន់ស្មានភាពធ្ងន់ធ្ងរនៃការជះឥទ្ធិពលនានា និង ការបង្កើតវិធានការគ្រប់គ្រង ដើម្បីបង្ការទិដ្ឋភាពជាអវិជ្ជមាន ឬក៏ដើម្បីបង្កើនផលប្រយោជន៍បន្ថែម។
- ការគ្រប់គ្រងយ៉ាងសកម្មទៅលើការប្រែប្រួលសង្គម (ជាមួយនឹងការត្រួតពិនិត្យសារជាថ្មី និងការពិនិត្យលើមតិផ្តល់ត្រឡប់មកវិញ ដើម្បីជួយឲ្យមានការផ្លាស់ប្តូរ ប្រសិនបើតម្រូវការលើចំនុចទាំងនេះ ត្រូវបានចង្អុលបង្ហាញ)។
- ធ្វើការតាមដានត្រួតពិនិត្យជាបន្ត (ក្រោយសាងសង់ ពេលគឺក្នុងអំឡុងពេលប្រតិបត្តិការ) ដើម្បីកំណត់ឲ្យបានច្បាស់ថា តើលទ្ធផលទទួលបានសម្រេចតាមការចង់បាន ឬ អត់ទេ។
- ការវាយតម្លៃ (ត្រង់ចំនុចដែលបានព្រមព្រៀងក្នុងរយៈកាលអនុវត្តគម្រោង) ដើម្បីផ្តល់ព័ត៌មានអំពីជម្រើសដែលអាចជំនួសបាន។

ធាតុផ្សំសំខាន់ៗ ដែលកំណត់ចរិកលក្ខណៈនៃការវាយតម្លៃហេតុប៉ះពាល់សង្គម ហើយដែលនាំទៅដល់ការអនុវត្តការវាយតម្លៃនេះ (ប្រែប្រួលទៅតាមកម្រិត) មានដូចខាងក្រោម ៖

- ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ
- ការកំណត់ឲ្យបានច្បាស់ និងការគិតគូរដល់ជម្រើសដែលអាចជំនួសបាន
- ការកំណត់លក្ខខ័ណ្ឌជាមូលដ្ឋាន
- ការកំណត់ពីវិសាលភាព
- ការព្យាករពីផលប៉ះពាល់នានា
  - ការព្យាករ និងវាយតម្លៃលើការឆ្លើយតបចំពោះផលប៉ះពាល់
  - ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព
  - ការវាយតម្លៃផលប៉ះពាល់ដោយប្រយោល និងផលប៉ះពាល់ដែលចេះតែបន្តកើតមាន
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

៤.៤.២- ការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ

ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ មានគោលដៅផ្តល់ជានីតិវិធីមួយ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយលក្ខណៈល្អប្រសើរ ធ្វើឡើងដោយភាគីដែលមានចំណាប់អារម្មណ៍ និង ភាគីរងផលប៉ះពាល់ អ្នកជំនាញបច្ចេកទេស អាជ្ញាធរ និងអ្នកគាំទ្រការអភិវឌ្ឍ ដែលនេះគឺជាការសម្រេចចិត្តប្រសើរជាងការធ្វើការងារតែឯកឯងរបស់ភាគីទាំងនេះ ។ សមាគមអន្តរជាតិស្តីពីការចូលរួមជាសាធារណៈ (IAP2) បានកំណត់និយមន័យ ការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ ដូច្នេះថា *គឺជានីតិវិធីណាមួយដែលពាក់ព័ន្ធជាមួយសារធារណជនក្នុងការចូលរួមដោះស្រាយបញ្ហា ឬ ការធ្វើសេចក្តីសម្រេចចិត្តដោយការប្រើប្រាស់គំនិតចំណេះដឹងរបស់សាធារណជននោះ មកធ្វើសេចក្តីសម្រេចចិត្តប្រកបដោយលក្ខណៈល្អប្រសើរ (www.iap2.org/associations/4748/files/fpundations-bro.pdf)* ។

ទាក់ទងនឹងការអនុវត្តពាក់ព័ន្ធ សមាគមអន្តរជាតិស្តីពីការចូលរួមជាសាធារណៈ (IAP2) បានបង្កើតឲ្យមានការកំណត់គុណតម្លៃស្នូលដែលទាក់ទងរវាងខ័ណ្ឌសីមាជាតិ វប្បធម៌ និងសាសនា ដែលមានគោលដៅដើម្បី *ជួយធ្វើសេចក្តីសម្រេចចិត្តយ៉ាងល្អប្រសើរដែលឆ្លុះបញ្ចាំងពីផលប្រយោជន៍ និង ក្តីកង្វល់របស់ប្រជាពលរដ្ឋ និងអង្គភាពនានា ដែលអាចរងផលប៉ះពាល់* (www.iap2.org/associations/4748/files/fpundations-bro.pdf) មានដូចខាងក្រោម ៖

- សាធារណជនគួរមានមតិយោបល់ ក្នុងការសម្រេចចិត្តអំពីសកម្មភាព ដែលប៉ះពាល់ដល់អាយុជីវិតរបស់ខ្លួន។
- ការចូលរួមរបស់សាធារណជន រាប់បញ្ចូលទាំងការឲ្យប្រជាពលរដ្ឋដឹងថា ការរួមចំណែករបស់ពួកគាត់នឹងជះឥទ្ធិពលលើការសម្រេចចិត្តនោះ។
- ដំណើរការនៃការចូលរួមរបស់សាធារណជន អាចឲ្យអ្នកចូលរួមបានដឹងអំពីផលប្រយោជន៍ និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគាត់។
- ដំណើរការនៃការចូលរួមរបស់សាធារណជន គឺជាការស្វែងរកយ៉ាងផុសផុល និងជាការសម្របសម្រួលរាល់អ្វីៗ ដែលពាក់ព័ន្ធទៅនឹងផលប៉ះពាល់ទាំងឡាយដែលអាចកើតមាន។
- ដំណើរការនៃការចូលរួមរបស់សាធារណជន គឺការឲ្យអ្នកចូលរួមបានចូលរួមជាប់ពាក់ព័ន្ធ ក្នុងការកំណត់អត្តន័យនៃរបៀបដែលពួកគាត់អាចចូលរួម។
- ដំណើរការនៃការចូលរួមរបស់សាធារណជន ផ្តល់ឲ្យអ្នកចូលរួមនូវព័ត៌មានដែលពួកគាត់ត្រូវការក្នុងការចូលរួមនៅក្នុងរដំណើរការមួយដ៏មានអត្ថន័យ។
- ដំណើរការនៃការចូលរួមរបស់សាធារណជន អាចឲ្យអ្នកចូលរួមបានដឹងថា ដំណើរការនៃការចូលរួមរបស់ពួកគាត់ មានឥទ្ធិពលចំពោះការសម្រេចចិត្ត (www.iap2.org/associations/4748/files/fpundations-bro.pdf) ។

បន្ថែមពីលើគុណតម្លៃស្នូលរបស់សមាគមអន្តរជាតិ ស្តីពីការចូលរួមជាសាធារណៈ (IAP2) នៅមានគោលការណ៍ផ្សេងទៀតនៃការអនុវត្តពាក់ព័ន្ធ ដែលអាចប្រើប្រាស់បានចំពោះការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ ដោយធ្វើយ៉ាងណាឲ្យអ្នកចូលរួមទាំងអស់បានដឹងឮស្មើៗគ្នា ហើយគំនិតយោបល់របស់ពួកគាត់ត្រូវបានយកទៅគិតគូរពិចារណា និង ធ្វើយ៉ាងណាឲ្យដំណើរការនោះអាចឆ្លើយតប ចំពោះតម្រូវការរបស់អ្នកចូលរួម ហើយដំណើរការនោះទៀតសោតមិនត្រូវបានរំលោភបំពាន ឬ ពន្យារពេលឡើយ ។

តាមរយៈបទពិសោធន៍ពីគម្រោងនានាកន្លងមកនៅអាស្រ្តិកខាងត្បូង (ទាក់ទងនឹងវិស័យខុសៗគ្នា ពោលគឺមិនត្រឹមតែគម្រោងអភិវឌ្ឍធនធានទឹក ឬ ថាមពលវារីអគ្គិសនីប៉ុណ្ណោះទេ) គេបានអនុវត្តដូចខាងក្រោម ៖

- ការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ ត្រូវធ្វើឡើងក្នុងលក្ខណៈតម្លាភាព ស្មោះត្រង់ និងការរួមបញ្ចូលវត្តមានរបស់មនុស្សទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងដំណើរការនេះ ។ ដើម្បីភាពងាយស្រួល ភាគីទាំងអស់ត្រូវយល់ព្រមលើតួនាទី សិទ្ធិ និង ការទទួលខុសត្រូវជាមុនសិន នៅក្នុងដំណើរការនៃការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈណាមួយ។
- គួរតែរាប់បញ្ចូលផងដែរនូវការពិគ្រោះយោបល់នានា (ពោល គួរតែធ្វើឡើងជាមួយគ្រប់វិស័យសង្គមទាំងអស់ ហើយផ្តល់ឱកាសល្មមគ្រប់គ្រាន់ដល់ភាគីផ្សេងៗទៀត អាចចូលរួមបានយ៉ាងទូលំទូលាយ ដោយហេតុថាការពិគ្រោះយោបល់ ដែលធ្វើឡើងជាមួយបុគ្គលនីមួយៗ ដាច់ដោយឡែកនៅក្នុងទីតាំងគម្រោង អាចមិនមែនជាការអនុវត្តដែលធ្វើទៅរួចទេ។
- គួរតែប្រកាសតាមមធ្យោបាយផ្សេងៗ ទៅតាមពេលវេលាសមស្រមមួយ សម្រាប់ផ្តល់ឱកាសក្នុងការផ្តល់មតិយោបល់ (ឧ. តាមរយៈសំបុត្រផ្ញើទៅកាន់ភាគីពាក់ព័ន្ធនីមួយៗដាច់ដោយឡែក ការផ្សព្វផ្សាយពាណិជ្ជកម្ម ឯកសារដាក់តាមទីសាធារណៈ ការប្រកាសតាមវិទ្យុ ការចុះទស្សនកិច្ចផ្ទាល់ជាមួយជនងាយរងគ្រោះ ឬ ក្រុមងាយរងគ្រោះនានា)។
- គួរតែផ្សព្វផ្សាយព័ត៌មានចេញទៅដោយងាយទទួលបាន និងមានលក្ខណៈគ្រប់គ្រាន់ដើម្បីអាចឲ្យការរួមចំណែកមានអត្ថប្រយោជន៍ (ហើយព័ត៌មានគួរតែធ្វើឡើងជាភាសាដែលភាគីពាក់ព័ន្ធអាចយល់បាន និងគួរសរសេរ ឬ បង្ហាញតាមបែបងាយស្រួលមិនមានលក្ខណៈបច្ចេកទេស)។
- គួរតែផ្តល់ឱកាសសមល្មមសម្រាប់ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ ស្របទៅតាមលទ្ធភាព និងកម្រិតនៃចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធផ្សេងៗគ្នា (ឯកសារមានលក្ខណៈបច្ចេកទេសខ្លាំង សម្រាប់អ្នកបច្ចេកទេស ឯកសារមានលក្ខណៈសាមញ្ញសម្រាប់អ្នកយល់ដឹងកម្រិតធម្មតា)។
- គួរតែបង្ហាញព័ត៌មានតាមមធ្យោបាយផ្សេងៗ ដើម្បីសម្រួលដល់ការធ្វើឲ្យជ្រួតជ្រាប (ឧ. តាមរយៈការពិភាក្សាលើឯកសារ ការធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំ និងសិក្ខាសាលា ការដាក់តាំងបង្ហាញ ការផ្សព្វផ្សាយតាមសារព័ត៌មាន និង ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ) ។
- គួរតែផ្តល់មធ្យោបាយជាក់ស្តែងឲ្យបានសមល្មមដល់ភាគីពាក់ព័ន្ធនានា ក្នុងការផ្តល់ជាគំនិតយោបល់ (ឧ. ការដាក់ស្នើជាលាយលក្ខណ៍អក្សរ ក្រដាសឯកសារបញ្ចេញយោបល់ អ៊ីម៉ែល ទូរសារ កិច្ចប្រជុំរយៈពេលខ្លី សិក្ខាសាលា ការប្រជុំជាសាធារណៈ ការទំនាក់ទំនងផ្ទាល់ជាមួយសមាជិកក្រុមសិក្សាស្រាវជ្រាវ)។
- គួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងដោយឡែកសម្រាប់ក្រុមងាយរងគ្រោះ (ឧ. មនុស្សចាស់ ជនពិការ ជនមានជំងឺសតិបញ្ញាយុវជនអ្នកដែលមានគំនិតយោបល់ទៅគេមិនសូវយកចិត្តទុកដាក់។ល។)
- គួរតែផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការបញ្ចេញគំនិតយោបល់។ ទោះយ៉ាងណាមិនគួរខ្ជះខ្ជាយពេលវេលាលើជម្រើសណា ដែលបានបង្ហាញថាមិនអាចសម្រេចទៅរួច។
- គួរបន្តឲ្យមានការពាក់ព័ន្ធ / ការចូលរួមក្នុងក្របខ័ណ្ឌដំណើរការនៃការសង្កេតមួយ ដូចជា ៖ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់សង្គម ការសិក្សាស្រាវជ្រាវ ឬ សកម្មភាពប្រហាក់ប្រហែលដទៃទៀត ។ ក្នុងន័យនេះ ភាគីពាក់ព័ន្ធគួរតែទទួលបាននូវមតិត្រឡប់វិញ និងការទទួលស្គាល់លើអ្វីដែលកំពុងកើតមាន និងផ្តល់ឱកាសយល់ដឹងអំពីពីរបៀបដែលការរួមចំណែករបស់ពួកគេត្រូវបានយកទៅគិតពិចារណា។

- គួរផ្តល់ឱកាសឲ្យបានគ្រប់គ្រាន់ ដល់ភាគីពាក់ព័ន្ធក្នុងការផ្លាស់ប្តូរព័ត៌មាន និង គំនិតទស្សន: (ឧ. នៅក្នុងសិក្ខាសាលា និងកិច្ចប្រជុំជាសាធារណៈជាដើម)។

ដើម្បីធ្វើឲ្យសម្រេចបាននូវការលើកឡើងដូចខាងលើ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់ជាមុន តាមដែលអាចធ្វើទៅបាននូវភាគីពាក់ព័ន្ធ (អ្នកដែលរងផលប៉ះពាល់ដោយផ្ទាល់ និងអ្នកដែលមានចំណាប់អារម្មណ៍ធំទូលាយទូលាយលើសំណើអភិវឌ្ឍន៍) ក្នុងរយៈពេលអនុវត្តគម្រោង ធ្វើឲ្យមានការទទួលស្គាល់ថា ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធឲ្យបានច្បាស់លាស់ ត្រូវតែជាដំណើរការមួយដែលមានជាបន្តសម្រាប់អំឡុងពេលនៃការអនុវត្តគម្រោង (ឧ ដោយសារតែរូបសណ្ឋាននៃគម្រោងមានការផ្លាស់ប្តូរ នោះភាគីពាក់ព័ន្ធថ្មីអាចលេចចេញជារូបរាងឡើង) ។ (ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធឲ្យបានច្បាស់ជាមុនរយៈពេលអនុវត្តគម្រោង អាចជួយផងដែរដល់ការបញ្ជាក់ពីភាពស្របច្បាប់ និងសិទ្ធិមានកម្មសិទ្ធិនៅពេលក្រោយរយៈពេលអនុវត្តគម្រោង នៅពេលដែលវិធានការកាត់បន្ថយ តូយ៉ាង ពេលត្រូវអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត)។

បន្ទាប់ពីការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធឲ្យបានច្បាស់លាស់រួច ចាំបាច់ត្រូវបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងមួយដើម្បីបញ្ចុះបញ្ចូលក្រុមភាគីពាក់ព័ន្ធខុសៗគ្នា តូរយ៉ាងទៅតាមវិស័យ ដើម្បីធ្វើឲ្យងាយ-ស្រួលដល់ការផ្លាស់ប្តូរគ្នានូវព័ត៌មានសំខាន់។ ការកត់ចំណាំពីយុទ្ធសាស្ត្រទំនាក់ទំនងដែលមានលក្ខណៈស្របតាមតម្រូវការ ត្រង់ថាមានភាពស្របគ្នានៃសារជាគន្លឹះដែលមាននៅក្នុងយុទ្ធសាស្ត្រទាំងនេះ គឺពិតជាមានសារៈសំខាន់បំផុត។

តាមរយៈការចូលរួមយ៉ាងសកម្មជាមួយសាធារណជន តាមមធ្យោបាយដ៏មានអត្ថន័យ ទាំងបញ្ហាបរិស្ថាន (ជីវសាស្ត្រ) និងសង្គម (វប្បធម៌ នយោបាយ សង្គមសេដ្ឋកិច្ច ជាដើម) ទាក់ទងនឹងសំណើអភិវឌ្ឍនឹងត្រូវកំណត់ឲ្យបានឃើញច្បាស់ជាក់ជាមិនខាន។

គួរកត់សម្គាល់ថា នៅពេលមានទំនាក់ទំនងរវាងការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ និង ការវាយតម្លៃហេតុប៉ះពាល់សង្គម ហើយដែលផ្តល់ជាការគាំទ្រទៅវិញទៅមក នោះដំណើរការនីមួយៗមានគោលបំណងខុសៗគ្នាដោយឡែក និងការកំណត់ជាក្រោយនូវលទ្ធផល ដោយមិនគិតថាតើការវាយតម្លៃហេតុប៉ះពាល់សង្គមត្រូវតែអនុវត្តនូវការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈរបស់វា ឬ ថាតើវាត្រូវរាប់បញ្ចូលទៅក្នុងដំណើរការកាន់តែធំទូលាយនៃការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ ។ ជាពិសេស គោលដៅដំបូងគឺថាមធ្យោបាយពីរផ្លូវ នៃការទំនាក់ទំនងត្រូវរក្សាឲ្យមានជានិច្ចជុំវិញរយៈកាលនៃការអនុវត្តគម្រោង។ ដូច្នេះ ទោះបីជួនពេលខ្លះការវាយតម្លៃហេតុប៉ះពាល់សង្គម និងការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈត្រូវបានគេយល់ឃើញថា ជាពាក្យដែលមានន័យដូចគ្នាក៏ដោយ ក៏ការពិតវាមិនមែនមានន័យដូចគ្នានោះទេ។

ប្រអប់អត្ថបទ៤.៦ គម្រោងការពារទឹកជំនន់នៅអាងទន្លេអូដ្រា នៅប្រទេសប៉ូឡូញ

គម្រោងការពារទឹកជំនន់នៅអាងទន្លេអូដ្រា នៅប្រទេសប៉ូឡូញ គឺជាឧទាហរណ៍ដ៏មានសារៈប្រយោជន៍មួយនៃការអនុវត្តទាក់ទងនឹងការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ។ គម្រោងដែលបានស្នើឡើង ត្រូវបានប្រឆាំងដោយសហគមន៍ជាច្រើនដែលរងផលប៉ះពាល់ ។ ដើម្បីបង្ហាញពីកង្វល់របស់សហគមន៍ អ្នកគាំទ្រការអភិវឌ្ឍ ក្រុមប្រឹក្សាទឹកក្នុងតំបន់នៃប្រទេសប៉ូឡូញ បានរៀបចំកិច្ចពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងស៊ីជម្រៅអស់ជាច្រើនឆ្នាំ។ ទោះបីជាលទ្ធផលមិនត្រូវបានយល់ស្របដោយភាគីទាំងអស់ក្តី (ហើយមិនមែនជាគោលបំណង ឬ លទ្ធផលរំពឹងទុកនៃការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈទេ) ក៏កិច្ចពិគ្រោះយោបល់ដែលរៀបចំធ្វើនោះមានជាប់ពាក់ព័ន្ធនឹងរបៀប ដែលការចូលរួមជាសាធារណៈត្រូវបានធ្វើឡើង និង របៀបដែលការចូលរួមជាសាធារណៈអាចរួមចំណែកដល់ការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយលក្ខណៈល្អប្រសើរ។

ប្រអប់អត្ថបទ៤.៧ ដំណើរការនៃការចូលរួមជាសាធារណៈនៅប្រទេសឡាវ

រដ្ឋបាលធនធានទឹក និងបរិស្ថាន រដ្ឋបាលមូលដ្ឋាន ភ្នាក់ងារទទួលបន្ទុកគម្រោងអភិវឌ្ឍ និង ម្ចាស់គម្រោង ត្រូវមានការទទួលខុសត្រូវរួម ក្នុងការធានាឲ្យមានការចូលរួមពីប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោងវិនិយោគ ព្រមទាំងពីភាគីពាក់ព័ន្ធដទៃទៀត ស្របតាមដំណើរការនៃការត្រួតពិនិត្យផ្ទៃក បរិស្ថាន ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចខាងក្រោម ៖

- ក្នុងពេលប្រមូលព័ត៌មាន ដើម្បីរៀបចំរបាយការណ៍មួយ ស្តីពីការត្រួតពិនិត្យរួមផ្ទៃកបរិស្ថាន ឬ របាយ ការណ៍ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រដ្ឋបាលមូលដ្ឋាន និងម្ចាស់គម្រោង ត្រូវរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយនៅថ្នាក់ភូមិ ដើម្បីជូនព័ត៌មានដល់អ្នកភូមិ ក្នុងទម្រង់ផ្សេងៗនៃផែនការ អភិវឌ្ឍរបស់គម្រោង និងផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមាន ក៏ដូចជាប្រមូលចងក្រងជម្រើសនានារបស់ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោងវិនិយោគ។
- ក្នុងពេលរៀបចំ និងពិនិត្យឡើងវិញនូវរបាយការណ៍ស្តីពីការត្រួតពិនិត្យរួមផ្ទៃកបរិស្ថាន រួមទាំងវិធានការនានាដើម្បីបង្ការ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម ឬ របាយការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការគ្រប់គ្រងបរិស្ថាន និងផែនការត្រួតពិនិត្យ (EMMP) និងការគ្រប់គ្រងសង្គម និងផែនការត្រួតពិនិត្យ (SMMP) រដ្ឋបាលធនធានទឹក និងបរិស្ថាន រដ្ឋបាលមូលដ្ឋាន ភ្នាក់ងារទទួលបន្ទុកគម្រោងអភិវឌ្ឍ និងម្ចាស់គម្រោង ត្រូវរៀបចំកិច្ចប្រជុំ ពិគ្រោះយោបល់នៅថ្នាក់ភូមិ ថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីធ្វើជាវេទិកា និងផ្តល់ឱកាសឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង និង ភាគីពាក់ព័ន្ធទាំងអស់ បានចូលរួមចែករំលែកគំនិតយោបល់ និងផ្តល់មតិលើរបាយការណ៍ និងផែនការ ចាប់ពីពង្រាងដំបូង ដល់ពង្រាងចុងក្រោយ។
- ក្នុងពេលធ្វើការអង្កេត ការសាងសង់ និងប្រតិបត្តិការគម្រោង ម្ចាស់គម្រោងត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោងវិនិយោគ និង ភាគីពាក់ព័ន្ធដទៃទៀតអំពីសកម្មភាពគម្រោងដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ដូចជាការឈូសឆាយផ្ទៃដី ការកំទេចថ្ម ការបង្ហូរទឹកចេញពីក្នុងអាង។ល។ ក្នុងពេលជាមួយគ្នានេះដែរ ម្ចាស់គម្រោងត្រូវ

អនុញ្ញាតដល់ ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង និងភាគីពាក់ព័ន្ធដទៃទៀត ឲ្យទទួលបានព័ត៌មានទូទៅអំពីគម្រោង។

នៅថ្នាក់តំបន់ ប្រទេសជាសមាជិកទាំង៤បានអនុវត្តតាមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ កិច្ចពិគ្រោះយោបល់ និង កិច្ចព្រមព្រៀងជាមុន (PNPCA) ដែលតម្រូវឲ្យមាន ការជូនព័ត៌មានពេញលេញពីគម្រោងណាមួយទាំងនៅតាមខ្សែទឹកធំ ឬ តាមចំណុះព្រំប្រទល់ដែននៃអាងទន្លេមេគង្គ។

ប្រអប់អត្ថបទ៤.៨ នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ កិច្ចពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងជាមុន (PNPCA)

ចាប់តាំងពីឆ្នាំ២០០៣ ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ បានព្រមព្រៀងលើនីតិវិធីសម្រាប់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ កិច្ចពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងជាមុន (PNPCA) ក្នុងគោលបំណងដើម្បី ៖

- ផ្តល់ជាជំហានសម្រាប់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដើម្បីគាំទ្រដល់ការបង្កើតវិធាននានាសម្រាប់ការប្រើប្រាស់ទឹក និងការបែងចែកចន្លោះអាង។
- ជម្រុញការយល់ដឹង និងកិច្ចសហប្រតិបត្តិការឲ្យកាន់តែប្រសើរ ក្នុងចំណោមប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គក្នុងលក្ខណៈស្ថាបនា និង ទទួលបានផលប្រយោជន៍ទៅវិញទៅមក ដើម្បីធានាឲ្យមានការអភិវឌ្ឍ ការគ្រប់គ្រង និងការអភិរក្សប្រកបដោយចីរភាពទៅលើទឹក និងធនធានពាក់ព័ន្ធដទៃទៀតនៃអាងទន្លេមេគង្គ។
- គោលការណ៍នៃនីតិវិធីនេះ ផ្អែកលើសមភាព អធិបតេយ្យភាព បូរណភាពទឹកដី ការប្រើប្រាស់ប្រកបដោយសមធម៌ និងសមហេតុផល ការគោរពចំពោះសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ សច្ចភាព និងតម្លាភាព។

ប្រទេសជាសមាជិកទាំង៤ បានព្រមព្រៀងថានឹងជូនព័ត៌មានជាលាយលក្ខណ៍អក្សរ ចំពោះការប្រើ-ប្រាស់ដែលបានស្នើឡើងដូចជា ៖ ការប្រើប្រាស់អាងផ្នែកខាងក្នុង ការបែងចែកចន្លោះអាងនៅតាមចំណុះទន្លេ រួមមានទន្លេសាប និងការប្រើប្រាស់អាងផ្នែកខាងក្នុងក្នុងអំឡុងរដូវសន្សើមនៅខ្សែទឹកធំ ។ ទម្រង់នៃការជូនដំណឹង និង ខ្លឹមសារត្រូវរួមបញ្ចូលយន្តការស្តានប័ន ឯកសារសង្ខេបពីការវាយតម្លៃផលប៉ះពាល់ របាយការណ៍ផ្សេងៗ របាយការណ៍លទ្ធផលនៃការសិក្សាស្រាវជ្រាវ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន IEE មុននឹងចាប់ផ្តើមការពិគ្រោះយោបល់។

ដំណើរការនេះ ធ្វើឡើងដើម្បីបញ្ជាក់ជាថ្មីនូវវិធីសាស្ត្រដែលអាចយកជាលំនាំសម្រាប់បង្កើតជាវិធាននៃការប្រើប្រាស់ទឹក ហើយសភាពនៃនីតិវិធីនានា ដែលជាផ្នែកទាំងស្រុងនៃវិធានស្តីពីការប្រើប្រាស់ទឹក និង ការបែងចែកចន្លោះអាង ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងធ្វើការងារទាំងអស់គ្នា ដើម្បីបង្ហាញពីការការពារបរិស្ថាន និងតុល្យភាពអេកូឡូស៊ីនៅក្នុងអាងទន្លេមេគង្គ រួមមានការបង្ការផលប៉ះពាល់គ្រោះថ្នាក់ និងការចាត់វិធានការក្នុងស្ថានភាពអាសន្ន ដូចដែលមានកំណត់នៅក្នុងវិធាន/នីតិវិធីផ្សេងៗទៀត។

ការពាក់ព័ន្ធ / ការចូលរួមជាសាធារណៈ: មានបរិយាយលម្អិតបន្ថែមនៅក្នុង (ផ្នែកទី៨)។

៤.៤.៣ ការកំណត់ឲ្យឃើញច្បាស់លាស់ និងការគិតគូរលើជម្រើសផ្សេងៗដែលអាចជំនួសបាន

ដោយការទទួលថា ការវាយតម្លៃហេតុប៉ះបាល់សង្គម គួរចាប់ផ្តើមធ្វើឲ្យបានជាមុនតាមដែលអាចធ្វើទៅបាន ក្នុងអំឡុងរយៈពេលអនុវត្តគម្រោង ទើបការវាយតម្លៃហេតុប៉ះពាល់សង្គម គួរត្រូវបានប្រើប្រាស់ដើម្បីធ្វើជាជំនួយដល់ការកំណត់ឲ្យបានច្បាស់លាស់ និងការគិតគូរលើជម្រើសផ្សេងៗដែលអាចជំនួសបាន។

- បន្ថែមទៅលើជម្រើស ដែលបានកំណត់ឃើញនៅពេលមានការយល់ដឹង ក្នុងគំនិតអំពីគម្រោង (ជាធម្មតាត្រូវបានកំណត់ឃើញដោយអ្នកគាំទ្រការអភិវឌ្ឍ) ក៏គួរពិចារណាលើជម្រើសផ្សេងៗទៀតតាមជាក់ស្តែង និងដែលអាចធ្វើបាន ដែលលេចចេញពីលទ្ធភាពដែលអាចជោគជ័យ (រួមមានការអង្កេត និងការផ្តល់ព័ត៌មានសំខាន់) ជាមួយនឹងទិដ្ឋភាពសង្គមដែលរួមចំណែកក្នុងលក្ខណៈជាមូលដ្ឋានស្មើភាពគ្នា (ជាមួយនឹងរបៀបផ្សេងៗទៀត) សម្រាប់ធ្វើសេចក្តីសម្រេចចិត្ត។
- ត្រូវតែរាប់បញ្ចូលជម្រើសដែលអាចជំនួសបាន " គ្មានការផ្លាស់ប្តូរ" ឬ "គ្មានការអភិវឌ្ឍ" ទៅក្នុងជម្រើសតាមជាក់ស្តែង និងដែលអាចទៅធ្វើបាន។ ប្រហាក់ប្រហែលគ្នានេះដែរ ជម្រើសទាំងឡាយមិនតម្រូវឲ្យមានការផ្លាស់ប្តូរឡើយ តួយ៉ាងដូចជាតម្រូវការក្នុងផ្តល់ការធានាចំពោះមាឌទឹកបន្ថែមមិនតម្រូវឲ្យធ្វើឡើងតែតាមមធ្យោបាយនៃការបង្ហាំងទុកជាថ្មីនៅត្រង់ទីកន្លែង ដែលជម្រើសអាចទាក់ទងនឹងទីតាំង និងទំហំទំនប់វារីអគ្គិសនីខុសគ្នា។ ក្នុងករណីបែបនេះ គួរពិចារណាលើជម្រើសដែលមិនទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជាការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ការរក្សាទឹកទុក ការគ្រប់គ្រងតម្រូវការទឹក។
- ជាពិសេស ត្រូវតែត្រួតពិនិត្យមើលទៅតាមកម្រិតលម្អិតដូចគ្នា ចំពោះជម្រើសទាំងអស់ ដើម្បីធានាឲ្យមានការប្រៀបធៀបប្រកបដោយអត្ថប្រយោជន៍។
- ត្រូវត្រួតពិនិត្យមើលអំពីបរិបទនៃជម្រើសនីមួយៗ នៅកម្រិតអន្តរជាតិ ជាតិ តំបន់ និងមូលដ្ឋានស្របតាមទំហំដែលអាចអនុវត្តបាន ភាពស្មុគស្មាញ និងផលប៉ះពាល់ដែលអាចកើតមានដោយសារគម្រោង។
- គួរយកចិត្តទុកដាក់ជាសំខាន់លើជម្រើសទាំងឡាយដែលអាចកាត់បន្ថយ និង បញ្ចៀសផលប៉ះពាល់នានា។ ការយកចិត្តទុកដាក់លើចំនុចនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅពេលគិតគូរដល់ទិដ្ឋភាពហិរញ្ញវត្ថុពាក់ព័ន្ធនឹងជម្រើសនីមួយៗ ។ នៅពេលដែលផលប៉ះពាល់សង្គមត្រូវបានមើលឃើញថាអាចគ្រប់គ្រងបាន គេត្រូវរៀបចំខ្ជង់ចំណាយពិតប្រាកដសម្រាប់ផែនការគ្រប់គ្រងសង្គម ហើយកំណត់សរុបលើពេលវេលា ដើម្បីធានាឲ្យមានការប្រៀបធៀបប្រកបដោយអត្ថន័យជាមួយនឹងការចំណាយទុនបន្ថែមតាមដែលអាចធ្វើទៅបាន ដោយផ្សារភ្ជាប់ជាមួយជម្រើសនានាដទៃទៀត។
- ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការពិនិត្យលើជម្រើសទាំងឡាយ ក៏ដូចជាផលប៉ះពាល់/អត្ថប្រយោជន៍នៃជម្រើសនោះ ទាក់ទងនឹងគម្រោងដទៃ (កំពុងដំណើរការ និងស្ថិតក្នុងផែនការអនុវត្តនាពេលអនាគត) ក្នុងគោលបំណងដើម្បីកំណត់ឲ្យឃើញច្បាស់ និងដោះស្រាយចំពោះផលប៉ះពាល់នានាដែលចេះតែបន្ថែមកើតមាន។ តួយ៉ាងដូចជា ៖
    - ការបញ្ចេញខ្យល់អាកាសពីរោងចក្រមួយដែលបានស្នើឡើង អាចចាត់ទុកថាអាចទទួលយកបាន ប្រសិនបើការបញ្ចេញខ្យល់អាកាសនោះនៅដាច់តែឯង ប៉ុន្តែនៅពេលមានការ

បន្ថែមនូវការបញ្ចេញខ្យល់អាកាសបែបនេះនៅជុំវិញរោងចក្រទាំងនោះ អាចបង្កជាការបំពុលបរិយាកាសក្នុងកម្រិតដែលមិនអាចទទួលយកបាន។

- ផលប៉ះពាល់នៃការតាំងទីលំនៅថ្មី ដែលកើតចេញពីការអភិវឌ្ឍ អាចត្រូវបានមើលឃើញថាអាចទទួលយកបាន និងអាចគ្រប់គ្រងបាន សម្រាប់ស្ថានីយ៍អគ្គិសនីតែមួយ ប៉ុន្តែនៅពេលគិតពិចារណាទៅដល់បរិបទផលប៉ះពាល់នៃការតាំងទីលំនៅថ្មី ដែលកើតចេញពីស្ថានីយ៍អគ្គិសនី ច្រើនកន្លែង អាចក្លាយទៅជាមិនអាចទទួលយកបាន និងមិនអាចគ្រប់គ្រងបាន បើនិយាយអំពីការចំណាយផ្នែកសង្គមកិច្ច ដែលទាមទារដោយភាគីរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។
- ប្រហែលគ្នានេះដែរ ការពិចារណាលើគោលនយោបាយ ឬ ផែនការតែមួយ អាចមានប្រយោជន៍តែឯកឯង ប៉ុន្តែបើគ្មានការពិចារណាលើគោលនយោបាយ ឬ ផែនការដទៃទៀតនោះទេ អាចជាការគ្មានប្រយោជន៍ទៅវិញ។ នៅក្នុងលក្ខណៈនេះ ជម្រើសដែលអាចផ្តល់ជាលទ្ធផលមួយអាចលេចចេញជារូបរាងឡើងដាច់ដោយឡែកតែឯង ប៉ុន្តែនៅពេលពិចារណាទៅដល់ផលប៉ះពាល់ដែលចេះតែបន្ថែមកើតមាន ជម្រើសនោះមិនអាចផ្តល់ជាលទ្ធផលល្អបានឡើយ។

មានគំរូឧទាហរណ៍ជាច្រើនដែលទិដ្ឋភាពសង្គម បានជះឥទ្ធិពលជាអវិជ្ជមានទៅលើការគិតគូរពិចារណាចំពោះជម្រើសដែលអាចជំនួសបាន គួបផ្សំជាមួយនឹងផលប៉ះពាល់សង្គម ដែលងាយឲ្យឃើញច្បាស់ត្រូវបានបញ្ចៀសផុតនៅមុនរយៈពេលអនុវត្តគម្រោង ។ វាកើតឡើងនៅពេលសម្រិតសម្រាំងយកមុនពេលសកម្មភាពរៀបចំផែនការគម្រោង ដែលមានគោលបំណងរបស់វា ការកំណត់ឲ្យឃើញច្បាស់ពីការខូចខាតបរិស្ថាន (សង្គម) ដែលអាចបណ្តាលឲ្យបាត់បង់ជីវិត fatal flaw និងបញ្ហាស្ថិតក្នុងកំរិតធ្ងន់ធ្ងរ red flag ហើយដែល fatal flaw ត្រូវបានឲ្យអត្ថន័យថា ជាផលវិបាកអវិជ្ជមានដ៏ធំដែលមានរយៈពេលយូរទៅលើបរិស្ថានសង្គមដែលរងផលប៉ះពាល់ និង ជាការពិបាកបំផុតក្នុងការកាត់បន្ថយ ឬ មិនមែនជាការប្រាថ្នាចង់បានក្នុងការលើកកម្ពស់ ចំណែក red flag ត្រូវបានឲ្យអត្ថន័យថាជាផលប៉ះពាល់ដ៏ធ្ងន់ធ្ងរ ដែលអាចបង្កផលវិបាកអវិជ្ជមានរយៈពេលល្មម និងយូរទៅលើបរិស្ថានសង្គម ឬ ជីវរូបដែលរងផលប៉ះពាល់ ដែលអាចកាត់បន្ថយបានលុះត្រាតែមានឆន្ទៈ មានការខិតខំប្រឹងប្រែង និងការចំណាយខ្ពស់ (ចំណាយសរុប ពោលគឺមិនមែនគ្រាន់តែជាការគិតគូរពិចារណាផ្នែកហិរញ្ញវត្ថុ និង សេដ្ឋកិច្ចប៉ុណ្ណោះទេ)។ ក្នុងន័យនេះ ជម្រើសមួយដើម្បីដោះស្រាយចំពោះ fatal flaw មិនគួរយកមកគិតគូរពិចារណាបន្ថែមទៀតឡើយ។

ប្រអប់អត្ថបទ៤.៩ ប្រព័ន្ធត្រួតពិនិត្យទូលំទូលាយលើការតាំងទីលំនៅថ្មី នៅក្នុងប្រទេសចិន
ប្រព័ន្ធត្រួតពិនិត្យទូលំទូលាយលើការតាំងទីលំនៅថ្មីនៅប្រទេសចិន ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ សម្រាប់គម្រោងទំនប់វារីអគ្គិសនីThree George Dam។ ប៉ុន្តែគម្រោងទំនប់វារីអគ្គិសនី Xiaoliangdi Dam គឺជាគម្រោងទីមួយ ដែលបានអនុវត្តប្រព័ន្ធត្រួតពិនិត្យទូលំទូលាយលើការតាំងទីលំនៅថ្មី ចាប់តាំងពីឆ្នាំ១៩៩៦។ ក្រោយមកប្រព័ន្ធនេះ ត្រូវបានអនុវត្តចំពោះគម្រោងដទៃទៀត ដូចជាគម្រោងទំនប់វារីអគ្គិសនី Wanjiazhai និង Shanxi ជាដើម។ ក្នុងឆ្នាំ១៩៩៨ អតីតក្រសួងថាមពល និងឧស្សាហកម្ម បានចេញ*សារាចរណែនាំស្តីពីការត្រួតពិនិត្យទូលំទូលាយលើការតាំងទីលំនៅថ្មីសម្រាប់គម្រោងវារីអគ្គិសនី។*

អង្គភាពមួយមានសមត្ថភាពឯករាជ្យទទួលបន្ទុកត្រួតពិនិត្យលើការតាំងទីលំនៅថ្មី នឹងត្រូវចុះកិច្ចសន្យាការងារដើម្បីត្រួតពិនិត្យលើការតាំងទីលំនៅថ្មី ។ បុគ្គលិករបស់អង្គភាពនេះ នឹងស្នាក់នៅជាប្រចាំក្នុងតំបន់ដើម្បីត្រួតពិនិត្យមើលពីការវិវត្តនៃការតាំងទីលំនៅថ្មី អនុឡោមតាមកាលវេលាតាំងទីលំនៅថ្មីជារួម និងប្រចាំឆ្នាំ។ តាមរយៈការប្រមូលបាននូវព័ត៌មានផ្សេងៗ បុគ្គលិកអង្គភាព នឹងត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យ និងគ្រប់គ្រងការវិនិយោគលើការតាំងទីលំនៅថ្មី គុណភាពនៃការតាំងទីលំនៅថ្មី និងការគ្រប់គ្រងកិច្ចសន្យា ។ របាយការណ៍ត្រួតពិនិត្យ នឹងត្រូវដាក់ជូនតាមពេលវេលាច្បាស់លាស់ ដល់រដ្ឋាភិបាល ការិយាល័យទទួលបន្ទុកការតាំងទីលំនៅថ្មី ម្ចាស់គម្រោង និងភាគីពាក់ព័ន្ធដទៃទៀត តាមការចាំបាច់។ ប្រសិនបើក្នុងករណីចាំបាច់បន្ទាន់ បុគ្គលិកក៏អាចធ្វើរបាយការណ៍ពិសេស និង បញ្ជូនភ្លាមទៅកាន់ភាគីពាក់ព័ន្ធទាំងអស់នៅពេលណាមួយក៏បាន។ អង្គភាពនឹងត្រូវដើរតួនាទីផងដែរ ក្នុងការជួយដល់រដ្ឋាភិបាលក្នុងការកំណត់ឲ្យបានយល់ច្បាស់ និងដោះស្រាយបញ្ហាទាក់ទងនឹងការតាំងទីលំនៅថ្មី។

ប្រអប់អត្ថបទ៥.១០ គម្រោងអភិវឌ្ឍន៍ធនធានទឹកទន្លេអូលីហ្វង់ នៅអាហ្វ្រិកខាងត្បូង

ជំហាននៃការសម្រិតសម្រាំងគម្រោងអភិវឌ្ឍន៍ធនធានទឹកទន្លេអូលីហ្វង់ (ជំហានទី២) នៅអាហ្វ្រិកខាងត្បូង គឺជាឧទាហរណ៍គំរូដ៏មានសារប្រយោជន៍ទាក់ទងនឹងការអនុវត្ត ក្នុងការកំណត់ឲ្យឃើញច្បាស់ និង វាយតម្លៃលើជម្រើសដែលអាចជំនួសបាន ។ សម្រាប់ការអភិវឌ្ឍដែលបានស្នើឡើងនេះ ជម្រើសដែលអាចជំនួសបានរាប់បញ្ចូលទាំងជម្រើសទាក់ទង និង មិនទាក់ទងនឹងទំនប់វារីអគ្គិសនី ។ សម្រាប់ជម្រើសដែលទាក់ទងនឹងទំនប់វារីអគ្គិសនី ផលប៉ះពាល់ដែលអាចកើតមាន ត្រូវបានត្រួតពិនិត្យយ៉ាងលម្អិត ហើយរួមចំណែកក្នុងការសម្រិតសម្រាំងជម្រើសទំនប់វារីអគ្គិសនីដែលគេនិយមជាង (ដែលអាចបញ្ជៀសផលប៉ះពាល់សង្គមធ្ងន់ធ្ងរបាន) ។ ចំណែកជម្រើសដែលមិនទាក់ទងនឹងទំនប់វារីអគ្គិសនី ទិដ្ឋភាពនានាដូចជាការថែរក្សាទឹកទុក ការគ្រប់គ្រងតម្រូវការទឹក ជម្រើសទឹកក្រោមដី និងការធ្វើអាជីវកម្មតំបន់មានទឹក ត្រូវបានពិនិត្យពិច័យយ៉ាងខ្ជាប់ខ្ជួនផងដែរ។ ផ្អែកតាមទស្សនវិស័យសង្គម ការធ្វើអាជីវកម្មទឹក ត្រូវបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ ដោយហេតុថាផលប៉ះពាល់ជាអវិជ្ជមានទៅលើធារទឹកខ្នាតតូច ក៏ដូចជាផលប៉ះពាល់សង្គមជាអវិជ្ជមាន ទៅលើរបរកសិកម្ម ជាប់ទាក់ទងគ្នាជាមួយនឹងធារទឹកខ្នាតធំជាង និងមានលក្ខណៈជាអាជីវកម្ម ។ ក្នុងករណីទាំងពីរនេះ ផលប៉ះពាល់សង្គម ដែលអាចកើតមានពាក់ព័ន្ធគ្នាជាមួយនឹងការបាត់បង់ការងារ ការបាត់បង់ប្រាក់ចំណូល ការថយចុះនូវសន្តិសុខស្បៀង និងលទ្ធភាពនៃការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។ ការត្រួតពិនិត្យលើជម្រើសទាក់ទង និង មិនទាក់ទងនឹងទំនប់វារីអគ្គិសនី រួមចំណែកដល់គម្រោងដែលបានស្នើឡើង ដែលមិនត្រឹមតែផ្តោតលើទំនប់វារីអគ្គិសនីស្តុកទឹកធំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញឲ្យឃើញពីជម្រើសដែលមិនទាក់ទងនឹងទំនប់វារីអគ្គិសនីទៀតផង ដែលជាការរួមចំណែកឲ្យបានល្អប្រសើរជាងមុនដល់ស្ថិរភាពធនធានទឹក និង ដល់តំបន់ដែលមានការគ្រប់គ្រងទឹកស្រាប់ ដែលតម្រូវការទឹកមានលើសពីចំនួនទឹកដែលមាន ហើយដែលត្រូវបានចាត់ទុកថាជាតម្រូវការសម្រាប់វិស័យក្រកូតប្រជែង (រាប់បញ្ចូលទាំងតម្រូវការឲ្យមាននៃអេកូឡូស៊ីទឹក ដែលត្រូវតែឆ្លើយតបចំពោះបរិស្ថានធម្មជាតិ)។

៤.៤.៤- ការរៀបចំឲ្យមានជាទម្រង់លក្ខខ័ណ្ឌជាមូលដ្ឋាន

ការរៀបចំឲ្យមានជាទម្រង់ ដែលជាប់ពាក់ព័ន្ធនឹងការធ្វើអង្កេតជាមូលដ្ឋាន សំដៅចងក្រងជាឯកសារទាក់ទងនឹងបរិស្ថានមនុស្ស ជុំវិញតំបន់ដែលមានឥទ្ធិពលលើគម្រោងស្នើសុំអភិវឌ្ឍ។ វាជាការប្រឆាំងទៅនឹងមូលដ្ឋាននៃលក្ខខ័ណ្ឌ និងនិន្នាការសង្គមដែលមានស្រាប់ ដែលតម្រូវឲ្យមានការយល់ដឹង វាយតម្លៃ និង វាស់វែងលើផលប៉ះពាល់នៃការផ្លាស់ប្តូរ ។

ការរៀបចំឲ្យមានជាទម្រង់ ដែលជាធម្មតាត្រូវធ្វើឡើងប្រដេញជាមួយនឹងការកំណត់ពីវិសាលភាព ដែលគួរតែផ្តល់នូវចំនុចខាងក្រោម ៖

- ការបរិយាយអំពីបរិស្ថានសង្គម (បរិបទនយោបាយ រចនាសម្ព័ន្ធស្ថាប័ន ការរៀបចំចាត់ចែង និងសមត្ថភាព ប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច ការប្រើប្រាស់ដីធ្លី លក្ខខ័ណ្ឌបច្ចុប្បន្ន ស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋ និងនិន្នាការសង្គម)។ គួរតែបង្កើតជាផែនទី និងការពិពណ៌នារៀបរាប់ស្តីពីស្ថាប័នរដ្ឋ ដូចជា ៖ តំបន់អាជ្ញាធរមូលដ្ឋាន និង តំបន់ប្រើប្រាស់ដីរបស់អាជ្ញាធរខ័ណ្ឌសីមាកុលសម្ព័ន្ធ និងតំបន់ប្រហាក់ប្រហែលនេះ។
- សេដ្ឋកិច្ចមូលដ្ឋាន និង តំបន់ និងការវិភាគពីទំនាក់ទំនងដ៏មានសក្តានុពលផ្នែកសេដ្ឋកិច្ចរវាងការអភិវឌ្ឍដែលបានស្នើឡើង និងស្ថានភាពជាក់ស្តែងបច្ចុប្បន្ន។
- ការបរិយាយ និង ការវិភាគអំពីគុណតម្លៃសង្គម និងវប្បធម៌ដែលមានស្រាប់ និងទំនាក់ទំនងនៃការអភិវឌ្ឍដែលបានស្នើឡើង (និងការផ្លាស់ប្តូរ)។
- បទដ្ឋាន និងផែនការសម្រាប់វាយតម្លៃហេតុប៉ះពាល់សង្គម រួមទាំងកត្តាសង្គម ដែលត្រូវប្រើប្រាស់ធ្វើជាសន្ទស្សន៍សម្រាប់វាស់វែង (ប្រភព Taylor *et al*., 1995)។

ផលប៉ះពាល់សង្គម ទៅលើសមាសភាពខុសៗគ្នានៃទំនប់វារីអគ្គិសនី ៖ (យកលំនាំតាម Adams, 2000)

ដំណើរការអភិវឌ្ឍ	សន្ទស្សន៍ផលប៉ះពាល់សង្គម
ផលប៉ះពាល់ក្នុងអំឡុងពេលរៀបចំផែនការ និងពេលសាងសង់	• ភាគីរងផលប៉ះពាល់ជាវិជ្ជមានពីជំហាននេះ រួមមាន ៖ ក្រុមហ៊ុនមៅការសាងសង់ អ្នកជំនាញការម្ចាស់ធនាគារ និយោជិត បម្រើការឲ្យគម្រោង និង អ្នកជំនួញនានាដែលចែកចាយផលិតផល និង សេវាផ្សេងៗ។ • ផលប៉ះពាល់ជាអវិជ្ជមាន ជាប់ទាក់ទងនឹងការភ័យខ្លាច និង ភាពមិនប្រាកដប្រជានៅតាមទីតាំងគម្រោង។ • ផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរបំផុត គឺកើតឡើងដោយសារភាពតប់ប្រមល់នៃការតាំងទីលំនៅថ្មី ឬ ការចំណាយផ្នែកសង្គមសេដ្ឋកិច្ច និងវប្បធម៌ទៅលើប្រជាពលរដ្ឋផ្លាស់ទីកន្លែងរស់នៅ ដែលមិនតាំងទីលំនៅថ្មី។ • ស្ត្រីដែលគេចាត់ទុកថាមិនសូវជាសំខាន់ក្នុងរង្វង់សហគមន៍ត្រូវបានបង្ខំកាន់តែធ្ងន់ធ្ងរឲ្យទូលរែង

	នូវបទពិសោធន៍លំបាក ដោយសារការផ្លាស់ទីលំនៅ។ • សហគមន៍ ដែលត្រូវបានជ្រើសរើសសម្រាប់ប្រជាពលរដ្ឋតាំងទីលំនៅថ្មី អាចប្រឈមនឹងបទពិសោធន៍នៃការផ្លាស់ប្តូរជាអវិជ្ជមានផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌។
ផលប៉ះពាល់នៅទីតាំងទំនប់វារីអគ្គិសនី	• ទំនប់ទាមទារកម្មករមិនជំនាញមានចំនួនច្រើន ហើយកម្មករជំនាញមានចំនួនតិចតួច ។ • កម្លាំងសាងសង់ទំនប់ បង្កើតឲ្យមានតម្រូវការច្រើនផ្នែកផលិតផល និងសេវាកម្ម។ • ភាពអត់ការងារធ្វើ អាចជាបញ្ហាធ្ងន់ធ្ងរនៅក្រោយពេលទំនប់ត្រូវបានសាងសង់រួច។
ផលប៉ះពាល់នៅតំបន់ទីជម្រាល	• ការប្រើប្រាស់ដីធ្លីនៅតំបន់ទីជម្រាល នៅផ្នែកខាងលើទំនប់អាចនឹងបង្កជាការហូរច្រោះដី និងមិនអាចរក្សាបរិមាណទឹកគ្រប់គ្រាន់។
ការសាងសង់ខ្សែបណ្តាញអគ្គិសនី ប្រព័ន្ធប្រឡាយទឹក និងផ្លូវថ្នល់	• ការសាងសង់ខ្សែបណ្តាញអគ្គិសនី ប្រព័ន្ធប្រឡាយទឹក និងផ្លូវថ្នល់ អាចផ្តល់ផលល្អជាវិជ្ជមានសម្រាប់ឱកាសការងារ។ • ចំណូលថ្មីអាចបង្កជាផលប៉ះពាល់អវិជ្ជមាន និងអាចបណ្តាលឲ្យមានការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការរីករាលដាលនៃជំងឺ និង បញ្ហាប្រឈមនានា ដល់ឥរិយាបទវប្បធម៌មូលដ្ឋាន និងការប្រព្រឹត្ត។
ផលប៉ះពាល់នៃការគ្រប់គ្រងអាងស្តុកទឹក	• បង្កជាផលប៉ះពាល់ដោយផ្ទាល់ ជាវិជ្ជមាន តាមរយៈការបង្កើតឲ្យមានការនេសាទជាចំហរ។ • បង្កជាផលប៉ះពាល់ជាវិជ្ជមាន នៅខ្សែទឹកខាងក្រោម ប្រសិនបើទំនប់នោះអាចគ្រប់គ្រងទឹកជំនន់ និងអាចការពារហេដ្ឋារចនាសម្ព័ន្ធ និង ទ្រពសម្បត្តិ និងជម្រុញឲ្យមានការអភិវឌ្ឍលើតំបន់ទឹកជំនន់នៅទីរាប។ • ទំនប់អាចបណ្តាលឲ្យមានការប្រែប្រួលភាពទៀងទាត់នៃធម្មជាតិរបស់លំហូរទន្លេ ហើយអាចបង្កជាផលអវិជ្ជមានទៅលើសេដ្ឋកិច្ចកសិកម្ម និងការនេសាទ។

ផលប៉ះពាល់នៃការផ្គត់ផ្គង់ទឹក	• ការប្រើប្រាស់ទឹកមានចំនួនច្រើន ដែលបានពីទំនប់ គឺសម្រាប់ស្រោចស្រប និង សម្រាប់ឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។

ការរៀបចំឲ្យមានជាទម្រង់ គួរតែត្រូវបានយកចិត្តទុកដាក់ជាពិសេសដល់ក្រុមងាយរងគ្រោះ តួយ៉ាងដូចជា ៖ យុវជន មនុស្សចាស់ ស្ត្រី ជនទន់ខ្សោយ និងជនពិការ ។ នៅពេលក្រុមងាយរងគ្រោះមានភាពខុសៗគ្នាពីគម្រោងមួយទៅគម្រោងមួយ ការកំណត់ឲ្យឃើញច្បាស់ និង ការរៀបចំឲ្យមានជាទម្រង់ក្នុងគម្រោងនីមួយៗសម្រាប់ពួកគេ ពិតជាមានសារៈសំខាន់ណាស់។ ប្រការនេះអាចជួយឲ្យក្រុមងាយរងគ្រោះទាំងនេះពេញចិត្តនឹងការកំណត់ពីវិសាលភាពតាមការចង់បាន បង្កើតនូវដំណោះស្រាយនានាតាមការចង់បាន និងកំណត់ជាឯកសារក្នុងផែនការកាត់បន្ថយផលប៉ះពាល់។

ដើម្បីបានជាមូលដ្ឋាននៃការលើកឡើងពីមុននេះ គួរតែមានការចងក្រងជាឯកសារស្តីពីប្រភពទិន្នន័យ និងការប៉ាន់ស្មាន ដែលនៅក្រោមការវិភាគ និងព្យាករ។ អាចមានទាំងការពិភាក្សាអំពីការពឹងអាស្រ័យលើទិន្នន័យ ក៏ដូចជាភាពមិនស្របគ្នា ឬគម្លាតដែលអាចប៉ះពាល់ដល់ការវិភាគនានា (ប្រភព Taylor *et al*., 1995)។

បើផ្អែកតាម (ប្រភព Taylor *et al*., 1995) ប្រភពទិន្នន័យដ៏សំខាន់ (បន្ទាប់ (មានស្រាប់) ឬ (ដំបូង (ថ្មី)) សម្រាប់ការរៀបចំឲ្យមានជាទម្រង់ រួមមាន ៖

- **ទិន្នន័យស្ថិតិ ៖** រួមមានរបាយការណ៍ជំរឿន និងទិន្នន័យធ្វើតាមស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។
- **ទិន្នន័យសង្គមជាលាយលក្ខណ៍អក្សរ ៖** រួមមានលិខិតទៅកាន់ការីនិពន្ធ អត្ថបទសារព័ត៌មានភស្តុតាងជាលាយលក្ខណ៍អក្សរ ឯកសារប្រវត្តិសាស្ត្រ សារណាបញ្ចប់ថ្នាក់ របាយការណ៍ប្រចាំឆ្នាំ ការសិក្សាស្រាវជ្រាវជាក់លាក់នៅទីតាំងគម្រោង។
- **ទិន្នន័យត្រួតពិនិត្យ និងការទំនាក់ទំនងឆ្លើយឆ្លង ៖** អាចបានមកពីការជជែក និងការទំនាក់-ទំនងទៅវិញទៅមកជាមួយប្រជាពលរដ្ឋនៅតាមតំបន់ ក្នុងបរិយាកាសការងារ ការលេងកំសាន្ត និងព្រឹត្តិការណ៍សង្គមផ្សេងៗទៀត។
- **ទិន្នន័យស្នង់មតិ ៖** ជាប់ពាក់ព័ន្ធនឹងការអនុវត្តកិច្ចសំភាសន៍ដែលមានលក្ខណៈជាទម្រង់ និងកម្រងសំនួរ (អនុវត្តចំពោះតែគំរូជាតំណាង ជាជាងការជំរឿន ឬ សារពើភ័ណ្ឌពេញលេញ)។ មុននឹងអនុវត្តសកម្មភាពទាំងនេះ សំខាន់ត្រូវអនុវត្តការស្នង់មតិជាបឋមសិន ដើម្បីធ្វើឲ្យការជ្រើសរើសសំនួរបានត្រឹមត្រូវ និងសំនួរដែលរំលេចពីភាពប្រែប្រួលនៃសង្គម។
- **ទិន្នន័យនៃការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ ៖** ដូចមានបរិយាយលម្អិតនៅក្នុង (ផ្នែក ៥.៤.២) និង (ផ្នែក៨) ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈត្រូវបានធ្វើឡើងដើម្បីកំណត់ឲ្យឃើញច្បាស់ពីបញ្ហាគន្លឹះក្នុងវិស័យសាធារណៈ។ តម្រូវការនេះត្រូវតែស្របតាមការវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់ការវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់ដែលបានព្យាករណ៍រួច។
- **ភ្នាក់ងារ ឬ បុគ្គលិកគម្រោង ៖** អ្នកតំណាងគម្រោង គឺជាប្រភពទិន្នន័យសម្រាប់សហគមន៍ដែលពួកគេរស់នៅ និងធ្វើការជាមួយ។

- **ផែនទី ៖** ផែនទីហានលេខានានា រូបថតបានពីអាកាស និងរូបភាពបានពី Google Earth ជារឿយៗបានផ្តល់ជាការបង្ហាញផ្លូវមួយ ទៅដល់មនុស្សជាច្រើនប្រភេទ ដែលអាចនឹងទទួលរងផលប៉ះពាល់ និងលំនាំនៃការប្រើប្រាស់ដីធ្លី។

ការស្នង់មតិជាមូលដ្ឋាន (យោង៤) គឺត្រូវការពេលវេលា ហេតុដូច្នេះហើយទើបការស្នង់មតិក្លាយជាការងារមានតម្លៃយ៉ាងថ្លៃ។ បន្ថែមពីលើនេះ តម្រូវឲ្យមានការរៀបចំផែនការដោយយកចិត្តទុកដាក់ ដោយសារប្រជាជន និងសហគមន៍ដែលត្រូវបានសម្ភាសន៍ និងស្នង់មតិមិនគួរត្រូវបានរំខានទៀត លើសពីការចាំបាច់ក្នុងការប្រមូលព័ត៌មានសំខាន់ៗ។ នេះជាចំនុចពិសេសមួយ សម្រាប់គម្រោងធំៗ ឬ តំបន់ដែលមានការអភិវឌ្ឍច្រើន ហើយដែលប្រជាពលរដ្ឋអាចនឿយណាយក្នុងការផ្តល់មតិចូលរួម (អាចនិយាយបានថា ជាការនឿយហត់របស់ភាគីពាក់ព័ន្ធ) ប៉ុន្តែយ៉ាងណាការតាំងចិត្ត គឺនៅតែចង់ជួយដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលយូរ។ ជាមួយគ្នានេះដែរ ការរៀបចំផែនការដោយប្រុងប្រយ័ត្ន អនុញ្ញាតឲ្យមានការបង្ហាញពីផលប៉ះ-ពាល់ ដែលបានកំណត់ឃើញជាដំបូង បូករួមទាំងទស្សនៈនៃការបញ្ចៀសផលប៉ះពាល់ ឬ ការកំណត់វិធានការកាត់បន្ថយឲ្យបានជាមុន ដោយមានការចូលរួមពាក់ព័ន្ធយ៉ាងជុំសជុលពីប្រជាពលរដ្ឋ ដែលអាចរងផលប៉ះពាល់។

(យោង៤) នៅពេលធ្វើការស្នង់មតិ (បរិមាណ តួយ៉ាង តាមរយៈវិធីសាស្ត្រវាយតម្លៃរហ័សតាមជនបទ ឬបរិមាណ តួយ៉ាង តាម រយៈបច្ចេកទេសវាយតម្លៃការចូលរួមតាមជនបទ) ពិតជាមានសារៈសំខាន់ណាស់ដែលថា អ្នកបានចុះឈ្មោះ គឺជាអ្នកដែលទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ ពួកគេគោរពប្រពៃណីរបស់អ្នកស្រុក ពួកគេនិយាយភាសាអ្នកស្រុក ហើយពួកគេអាចឆ្លុះបញ្ចាំងពីអ្នកចូលរួមដែលពួកគេបានប្រមូលព័ត៌មាន តួយ៉ាងអ្នកចុះឈ្មោះជាស្ត្រីនឹងមានការចូលរួមជាមួយក្រុមស្ត្រីមូលដ្ឋាន បានល្អជាងអ្នចុះឈ្មោះជាបុរស។ ការយកចិត្តទុកដាក់យ៉ាងលម្អិត និងការគោរពចំពោះសហគមន៍ ជាធម្មតាបានផ្តល់មកវិញនូវលទ្ធផលជាប្រយោជន៍ ហើយបើពុំដូច្នេះទេ នឹងមិនបានលទ្ធផលល្អឡើយ។

នៅទីបញ្ចប់ គួរកត់សម្គាល់ថា ទិន្នន័យគោលបង្កើតបានជាមូលដ្ឋានដែលបានពីការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមាន បានពីសកម្មភាពកាត់បន្ថយ/គ្រប់គ្រងដែលបានបង្កើតឡើង និងជាពិសេសបានមកពីការផ្លាស់ប្តូរនៃការប្រែប្រួល/សន្ទស្សន៍ សម្រាប់គោលដៅតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ប្រអប់អត្ថបទ៤.១១ គម្រោងវារីអគ្គិសនីប៊ុមបុណា (Bumbuna) នៅសៀរ៉ាឡេអូន
គម្រោងវារីអគ្គិសនីប៊ុមបុណា នៅសៀរ៉ាឡេអូន គឺជាឧទាហរណ៍គំរូមួយនៃការរៀបចំឲ្យមានជាទម្រង់លក្ខខ័ណ្ឌជាមូលដ្ឋាន។ គម្រោងនេះដំបូងឡើយត្រូវបានស្នើឡើងនាទសវត្សរ៍ទី៧០ ហើយការសាងសង់បានចាប់ផ្តើមចន្លោះឆ្នាំ១៩៨២ និង ឆ្នាំ ១៩៩៧។ ប្រទេសនេះបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលអស់ រយៈពេលជាយូរ។ ទោះបីយ៉ាងនេះក៏ដោយ ទិន្នន័យទូលំទូលាយជាមូលដ្ឋាន ត្រូវបានប្រមូលផ្តុំក្នុងរយៈពេលនៃការពន្យារមួយដ៏យូរ រហូតដល់ការសាងសង់ទំនប់បានចាប់ផ្តើម ក្រោយពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានធ្វើរួច ។ វិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ រួមមានកម្រងសំនួរអង្កេតជាមួយមេគ្រួសារ ក្រុមពិភាក្សាជាមួយយុវជន ស្ត្រី បុរស មនុស្សចាស់ និងប្រធានភូមិ ឃុំ និងកិច្ចប្រជុំពិគ្រោះយោបល់នានាជាមួយសហគមន៍។ ព័ត៌មានជាមូលដ្ឋានដែលប្រមូលបានមានភាពទូលំទូលាយជាមួយនឹងអត្ថបទ ទិន្នន័យ និង ការរំលេចលម្អដោយរូបភាព ដែលនិយាយពីលក្ខខ័ណ្ឌសង្គមសេដ្ឋកិច្ចជារួម ប្រជាសាស្ត្រ ការតាំងទីលំនៅ និងហេដ្ឋារចនាសម្ព័ន្ធ ក្រុមជនជាតិភាគតិច រចនាសម្ព័ន្ធគ្រួសារ

ទំហំភូមិ ការផ្គត់ផ្គង់ទឹក កាកសំណល់រឹង សុខាភិបាលសាធារណៈ ឥរិយាបទក្នុងការតាំងទីលំនៅថ្មី វប្បធម៌ ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា ការចូលរួមក្នុងសង្គម និង ទំនៀមទម្លាប់ សាសនា ទីតាំងសក្ការៈបូជា អាថិកំបាំងសង្គម ទេសចរណ៍ និងការច្នៃប្រឌិត។ ការស្ទង់មតិតាមគ្រួសារ ត្រូវបានធ្វើឡើងនៅក្នុង៥៤ ភូមិដែលរស់នៅតាមតំបន់អាងស្តុងទឹក ហើយទិន្នន័យត្រូវបានប្រមូលពីគ្រួសារសរុបចំនួន៨៧២ ។ ជាពិសេសទិន្នន័យជាមូលដ្ឋាន គឺជាការផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការ និងធ្វើសេចក្តីសម្រេចចិត្ត សម្រាប់ការគ្រប់គ្រងលើការប្រែប្រួលសង្គម ដែលកើតឡើងដោយសារទំនប់វារីអគ្គិសនី ហើយនៅពេលអនាគតទិន្នន័យនេះអាចជាវង្វាស់សម្រាប់វាស់វែងការអនុវត្តការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើសវនកម្ម ។

៤.៤.៥ ការកំណត់ពីវិសាលភាព

ការកំណត់ពីវិសាលភាព គឺជានីតិវិធីកំណត់ឲ្យបានឃើញច្បាស់ពីបញ្ហានានា ដែលអាចធ្វើបានក្រោមទម្រង់ ដូចជា ៖

- **ការកំណត់ពីវិសាលភាពបច្ចេកទេស** (យោង៥) ជាមួយអ្នកគាំទ្រការអភិវឌ្ឍ និងអ្នកជំនាញការបច្ចេកទេស។
- **ការកំណត់ពីវិសាលភាពអាជ្ញាធរ** ជាមួយអាជ្ញាធរផ្សេងៗ ដែលអាចមានចំណាប់អារម្មណ៍លើគម្រោងដែលបានស្នើឡើង (ប្រហែលជាអាជ្ញាធរមានសមត្ថកិច្ច ឬទទួលបានសិទ្ធិអនុញ្ញាត)។
- **ការកំណត់ពីវិសាលភាពអ្នកជំនាញ** ជាមួយអ្នកមានជំនាញ ដែលមានលក្ខណៈជាក្បួនខ្នាតពិតប្រាកដ ។
- **ការកំណត់ពីវិសាលភាពសារធារណៈ:** នៅក្នុងវិស័យសាធារណៈជាមួយសមាជិកសាធារណៈដែលមានចំណាប់អារម្មណ៍ និងដែលរងផលប៉ះពាល់ពីគម្រោងដែលបានស្នើឡើង។

ការកំណត់ពីវិសាលភាព គឺជានីតិវិធីវិភាគមួយ ដែលអាចធានាថាការវាយតម្លៃត្រូវបានអនុវត្តនៅកម្រិតសមស្របយ៉ាងលម្អិត ត្រូវគ្នានឹងទំហំ និងសារៈសំខាន់នៃគម្រោងដែលបានស្នើឡើង។ ប្រសិនបើធ្វើទៅបានល្អ ការកំណត់ពីវិសាលភាព នឹងអាចធានាឲ្យមានការផ្តោតសំខាន់មួយ ទៅលើបញ្ហាពាក់ព័ន្ធនានា និងព័ត៌មាន។ ការកំណត់ពីវិសាលភាព គឺជាការធានាថា បញ្ហាធំៗនឹងមិនត្រូវបានភ្លេចគិតគូរឡើយ ហើយនឹងផ្តោតលើការប្រមូលទិន្នន័យ និងការផ្លាស់ប្តូរព័ត៌មានរវាងភាគីពាក់ព័ន្ធ (ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ) ។ ក្នុងន័យនេះ ការកំណត់ពីវិសាលភាព គឺជាចាំបាច់បំផុត ពីព្រោះវាផ្តោតសំខាន់លើការសិក្សាអំពីបញ្ហាគន្លឹះនានា។ អាស្រ័យហេតុនេះ ជាការចាំបាច់បំផុត ដែលថាលំហាត់ស្តីពីការកំណត់ពីវិសាលភាពនៅមិនទាន់អាចបត់បែនបានទូលំទូលាយនៅឡើយទេ។

ប្រការសំខាន់ នៅត្រង់ថាការកំណត់ពីវិសាលភាពមិនផ្តោតសំខាន់លើទិដ្ឋភាពជាអវិជ្ជមាន នៃការអភិវឌ្ឍដែលបានស្នើឡើងនោះទេ។ នៅមានឱកាសជាច្រើនទៀត ដែលអាចឆក់បានពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាទំនប់វារីអគ្គិសនី និងសំណង់ថាមពល ដែលត្រូវកំណត់ឲ្យឃើញច្បាស់ បង្ហាញឲ្យបានល្អិតល្អន់ និងក្តាប់ឲ្យបានណែន។ ឱកាសទាំងនេះ រួមមានការមានការងារធ្វើ (រយៈពេលខ្លីក្នុងពេលសាងសង់ និងរយៈពេលវែងក្នុងពេលដំណើរការក្រុមហ៊ុន) ជម្រុញសេដ្ឋកិច្ចមូលដ្ឋាន និងតំបន់ តាមរយៈកំណើននៃការចំណាយ ប្រាក់បៀវត្សរ៍ និង ប្រាក់ឈ្នួលនៅទីតាំងគម្រោង ហេដ្ឋារចនាសម្ព័ន្ធ និង សេវា

កម្មមានលក្ខណៈល្អប្រសើរ (ផ្លូវថ្នល់ ការចែកចាយអគ្គិសនី មណ្ឌលសុខភាព ជាដើម) ព្រមទាំងឱកាសសេដ្ឋកិច្ចយូរអង្វែងដែលកើតចេញពីហេដ្ឋារចនាសម្ព័ន្ធនោះផង (តួយ៉ាង ការប្រើប្រាស់អាងស្តុកទឹក ។
(យោង៥) ក្នុងអត្ថន័យនេះ (បច្ចេកទេស) សំដៅដល់ការងារវិស្វកម្មទាក់ទងនឹងក្បួនខ្នាតដែល (អ្នកឯកទេស) សំដៅជាទូទៅដល់ក្បួនខ្នាតវិទ្យាសាស្ត្រ (វិទ្យាសាស្ត្រធម្មជាតិ និងសង្គម បុរាណវិទ្យា បេតិកភណ្ឌវប្បធម៌ ជាដើម)។ ទោះយ៉ាងណា ក្នុងករណីខ្លះចាំបាច់ត្រូវមានការជាប់ព័ន្ធគ្នាជាមួយអាជីពវិស្វកម្ម (តួយ៉ាង បច្ចេកទេស) ក្នុងតួនាទីដូចជាអ្នកឯកទេសដែរ។

សម្រាប់ការនេសាទ សកម្មភាពទេសចរណ៍ផ្សាភ្ជាប់ជាមួយអាងស្តុកទឹក និង តំបន់ជុំវិញអាង ព្រមទាំងសកម្មភាពទេសចរណ៍ផ្សាភ្ជាប់ជាមួយសំណង់អគារអគ្គិសនី)។ ឱកាសទាំងអស់នេះ គួរតែស្វែងរកឲ្យបានខ្ជាប់ខ្ជួន និងធ្វើការព្យាករណ៍ជាមុននូវផលប្រយោជន៍ដែលអាចទទួលបាន។ ការងារនេះអាចធ្វើបានតាមរយៈការរៀបចំផែនការជាសេណារីយ៉ូ ដែលគួរត្រូវបានផ្តល់ជាព័ត៌មានសម្រាប់ការរៀបចំផែនការអភិវឌ្ឍសង្គមនាពេលអនាគត។

ការកំណត់ពីវិសាលភាព ក៏មានជាប់ទាក់ទិននឹងការពណ៌នាអំពី**ចំនុចចុងក្រោយ**ផងដែរ (លោកិយ៌ និងរូបរាងកាយ) នៃការសិក្សា ការវាយតម្លៃអំពីការប្រែប្រួលដែលត្រូវធ្វើការវាស់វែង ឬ ត្រូវបរិយាយ និងការវាយតម្លៃអំពីផលប៉ះពាល់ដែលអាចកើតមាន (ផលអវិជ្ជមាន និងផលប្រយោជន៍) ដែលអាចប៉ះពាល់ទៅលើ ឬ ប៉ះពាល់ដោយសារគម្រោងដែលបានស្នើឡើង។ ក្នុងន័យនេះ អ្វីដែលបានពីការរៀបចំឲ្យមានជាទម្រង់ ត្រូវចាំបាច់អនុវត្តការកំណត់បញ្ហាទៅតាមការចង់បាន ដើម្បីដោះស្រាយលើបញ្ហាទាំងឡាយទាក់ទងនឹងក្រុមងាយរងគ្រោះ។ សកម្មភាពនេះ ត្រូវបានចាត់ទុកថាជាធាតុផ្សំដ៏រសើបមួយនៃបរិស្ថានដែលទទួលបាន ដោយតម្រូវឲ្យមានការវិភាគជាក់លាក់លើផលប៉ះពាល់ ដែលអាចកើតមាន ដើម្បីជម្រុញឲ្យមានការបង្កើតចេញជាវិធានការកាត់បន្ថយទៅតាមតម្រូវការដែលចង់បាន។

ការកំណត់ពីវិសាលភាព គួរបង្ហាញឲ្យបានច្បាស់ពីកត្តារួមផ្សំនានានៃបរិស្ថានដែលទទួលបាន ដូចជាគោលនយោបាយសំខាន់ៗ ផែនការ កម្មវិធី និង គម្រោង/ប្រតិបត្តិការនានា ដែលអាចជះឥទ្ធិពលលើ បរិស្ថានសង្គម និងសង្គមសេដ្ឋកិច្ច ក្នុងរង្វង់ចំនុចចុងក្រោយដែលបានជ្រើសរើស ព្រមទាំងព័ត៌មាន និងទិន្នន័យសមស្របដែលមានស្រាប់ ឬ ដែលអាចទទួលបាន ហើយដែលអាចប្រើប្រាស់បានសម្រាប់ធ្វើការវិភាគ និងដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះផលប៉ះពាល់ដែលអាចកើតមាន។

ក្នុងពេលកំណត់បញ្ហា ជាទូទៅត្រូវមានកត្តារួមផ្សំ ដូចខាងក្រោម ៖

- ការកំណត់ឲ្យបានច្បាស់ពីចរិកលក្ខណៈបរិស្ថានសង្គម នៃតំបន់ដែលអាចរងផលប៉ះពាល់ដោយការអភិវឌ្ឍដែលបានស្នើឡើង។
- ការកំណត់ឲ្យបានឃើញច្បាស់ពីការចូលរួមរបស់ភាគីពាក់ព័ន្ធ ដើម្បីឲ្យភាគីទាំងអស់អាចមានឱកាសបញ្ចេញយោបល់អំពីសកម្មភាពដែលស្នើឡើង (ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ)។
- ការកំណត់ឲ្យឃើញច្បាស់ពីបញ្ហាគន្លឹះដែលអាចលេចចេញជាលទ្ធផលពីការអភិវឌ្ឍ ឬ បង្កផលប៉ះពាល់លើការអភិវឌ្ឍដែលបានស្នើឡើង។

វិធីសាស្ត្រមួយចំនួនអាចអនុវត្តបានសម្រាប់ការកំណត់ពីវិសាលភាព ដោយការប្រើប្រាស់ព័ត៌មាននិងទិន្នន័យបឋម និងបន្ទាប់ រួមមានការពិភាក្សា សិក្ខាសាលា និងកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋ និងអង្គភាពរងផលប៉ះពាល់ (ទាក់ទងសំខាន់ជាមួយការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ) ការប្រមូលផ្តុំ និងពិនិត្យឡើងវិញទៅលើឯកសារជាលាយលក្ខណ៍អក្សរ ផែនការ ផែនទី និងសម្ភារពាក់ព័ន្ធ កម្រងសំនួរ និងការស្ទង់មតិ ជាដើម។ គម្លាតនៃការផ្តល់ព័តមានអាចនឹងចង្អៀត ដោយសារការប្រើប្រាស់ព័ត៌មានដែល

ប្រមូលបានជាផ្នែកមួយនៃការរៀបចំឲ្យមានជាទម្រង់។ បន្ថែមពីលើនេះ ការវាយតម្លៃហេតុប៉ះពាល់សង្គម ត្រូវតែធ្វើការវាយតម្លៃលើរាល់ផលប៉ះពាល់ទាំងឡាយ (ផ្ទាល់និងប្រយោល) ទៅលើមនុស្ស និងមធ្យោបាយ គ្រប់យ៉ាងដែលប្រជាពលរដ្ឋ និង សហគមន៍ធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក (ដោយផ្ទាល់ និង ដោយប្រយោល) ជុំវិញបញ្ហាសង្គមវប្បធម៌ សេដ្ឋកិច្ច និងជីវរូប (ប្រភព Vanclay, 2003) ។ ដូច្នេះ យោងតាម Taylor *et al*., (1995) ការកំណត់ពីវិសាលភាព គ្របដណ្តប់លើចំនុចច្រើន ប៉ុន្តែមិនទាន់បានរួមបញ្ចូលជាមួយកត្តារួមផ្សំសង្គមឡើយ ដូចជា ៖

- របៀបរបរស់នៅ (តួយ៉ាង ឥរិយាបថ និងការទំនាក់ទំនង)។
- ទិដ្ឋភាពវប្បធម៌ (តួយ៉ាងដូចជា ប្រពៃណី ទំនៀមទម្លាប់ គុណតម្លៃ និងជំនឿសាសនា) និងអត្ថន័យនៃទីកន្លែង (ពាក់ព័ន្ធនឹងទិដ្ឋភាពជាក់ស្តែង និងអរូបីយ៍)។
- ទិដ្ឋភាពខាងបុរាណវិទ្យា។
- សហគមន៍ ស្ថាប័ន និងផលប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ហេដ្ឋារចនាសម្ព័ន្ធ, សេវាកម្ម និងបណ្តាញ សមត្ថភាព ។ល។)
- ភាពឆើតឆាយ និង/ឬ គុណភាពនៃជីវិត (ដូចជាស្ថានភាពសន្តិសុខ)។
- ការគិតគូរអំពីសុខភាព(យោង៦) (ដូចជាសុខភាពផ្លូវចិត្ត និងរាងកាយ ផលប៉ះពាល់នៃការបំពុលបរិស្ថាន រោគអេដស៍/ជំងឺអេដស៍។ល។)
- សោភ័ណភាព ដែលអាចមើលឃើញ និង/ឬផលប៉ះពាល់ដទៃទៀតដល់វិញ្ញាណ
(តួយ៉ាង សម្លេង ពន្លឺ ធូលី ការបន្ទច់បង្អាក់។ល។)
- ប្រជាសាស្ត្រ (ដូចជាយៃនឌ័រ អាយុ និងទំនោរផ្លូវភេទ) ។
- ផលប៉ះពាល់នានានៃការអភិវឌ្ឍន៍។
- ផលប៉ះពាល់សេដ្ឋកិច្ច និងសារពើពន្ធ។
- ផលប៉ះពាល់យេនឌ័រ។
- ផលប៉ះពាល់លើសិទ្ធិជនជាតិដើមភាគតិច។
- ការលំហែកែកំសាន្ត និងផលប៉ះពាល់ខាងវិស័យទេសចរណ៍។

(យោង៦) ការគិតគូរអំពីសុខភាព អាចចង្អុលបង្ហាញពីតម្រូវការដើម្បីអនុវត្តការវាយតម្លៃផលប៉ះពាល់សុខភាពដែលឆ្លើយតបចំពោះគោលនយោបាយ ផែនការ និងគម្រោងស្តីពីផលប៉ះពាល់ផ្នែកសុខាភិបាល ក្នុងវិស័យស្រដ្ឋកិច្ចច្រុះដោយប្រើបច្ចេកទេសបរិមាណ គុណភាព និងការចូលរួមផងដែរ ។ ជាធម្មតាមានចំនួន៥ជំហាន ដើម្បីដំណើរការជាមួយការវាយតម្លៃផលប៉ះពាល់សុខភាពគឺ ៖ (ទី១) ការបញ្ជាំងការ - ដើម្បីកំណត់ឲ្យបានឃើញច្បាស់ ប្រសិនបើដូចការវាយតម្លៃមួយដែលត្រូវបានទាមទារ (ទី២) ការកំណត់ពីវិសាលភាព - កំណត់នូវអ្វីដែលត្រូវបានទាមទារ និងរបៀបក្នុងការកំណត់វា (ទី៣) ការវាយតម្លៃ - ដោយការកំណត់ឲ្យឃើញច្បាស់ ពីគ្រោះថ្នាក់ដល់សុខភាព និងពិចារណាលើភស្តុតាងនៃផលប៉ះពាល់ (ទី៤) ការរាយការណ៍ - ចងក្រងអនុសាសន៍ ដើម្បីកាត់បន្ថយគ្រោះថ្នាក់និង/ឬដើម្បីឱ្យប្រសើរឡើងនូវការពិនិត្យតាមដានសុខភាព (ទី៥) ការតាមដានត្រួតពិនិត្យ - ការវាយតម្លៃ និងការតាមដានត្រួតពិនិត្យ។ ការវាយតម្លៃផលប៉ះពាល់សុខភាព កំពុងមានសារៈសំខាន់កាន់តែខ្លាំងនៅក្នុងសហគមន៍ដែលងាយរងគ្រោះកាន់តែច្រើនឡើងនៅទូទាំងពិភពលោក និង ជួយដល់អ្នកធ្វើការសម្រេចចិត្តឱ្យមានជម្រើសអំពីជម្រើស ដែលអាចជំនួសបាន និងការធ្វើឱ្យប្រសើរឡើងដើម្បីបង្ការជំងឺ/ការរងរបួស និង ដើម្បីលើកកម្ពស់សុខភាពឲ្យបានកាន់តែសកម្ម។

- ផលប៉ះពាល់ផ្នែកនយោបាយ (ដូចជា សិទ្ធិមនុស្ស អភិបាលកិច្ច លទ្ធិប្រជាធិបតេយ្យ។ល។)
- ភាពក្រីក្រ (តួយ៉ាង ការលើកកម្ពស់សង្គម និងឱកាសការងារ)។
- ផលប៉ះពាល់ផ្នែកសរីរសាស្ត្រ។
- ការប្រើប្រាស់ធនធាន (តួយ៉ាងសិទ្ធិក្នុងការទទួលបាន និងភាពជាម្ចាស់កម្មសិទ្ធិលើធនធាន)។
- ផលប៉ះពាល់លើមូលនិធិសង្គម និងមនុស្ស។
- ក្រុមងាយរងគ្រោះ (ដូចជាមនុស្សចាស់ និង ជនខ្សត់ខ្សោយ កុមារ និងយុវជន ជនជាតិភាគតិច (ឧទាហរណ៍ ជនជាតិដើម) ក្រុមជនជាតិដើមភាគតិច ស្ត្រីជាដើម)។
- ការរំពឹងទុក (ការច្នៃប្រពិត និងការគ្រប់គ្រង)។
- ផលប៉ះពាល់លើសង្គម និងផលប៉ះពាល់ដោយប្រយោលផ្សេងទៀត។
- ទិដ្ឋភាពដែលចេះតែបន្តែមកើតមាន (ដូចដែលបានពិភាក្សាពីមុន) (ប្រភព Vanclay, 2003) ។

វាជាការសំខាន់ក្នុងការសំគាល់ថា វិសាលភាព និងប្រពលភាព នៃការកំណត់ពីវិសាលភាព ត្រូវតែស្របជាមួយនឹងប្រភេទ ទំហំ វិសាលភាព ការឈានដល់។ល។ នៃគម្រោងដែលបានស្នើឡើង ហេតុដូច្នេះ វាច្បាស់ណាស់ថា មិនមែនគម្រោងទាំងអស់ នឹងតម្រូវឱ្យមានជាក្បួតខ្ជាតទាំងមូលគ្រប់ជ្រុងជ្រោយនោះឡើយ។

ការកំណត់ពីវិសាលភាព និង ការពាក់ព័ន្ធការចូលរួម / ជាសាធារណៈ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត។ គិតជាអប្បរមា ការកំណត់ពីវិសាលភាព ត្រូវជាប់ពាក់ព័ន្ធជាមួយការទំនាក់ទំនង និងការ ពិគ្រោះយោបល់ជាមួយអ្នកតំណាងផ្សេងៗ ដូចខាងក្រោមនេះ ៖

- រដ្ឋាភិបាល (តាមលក្ខណៈប្រពៃណី ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ជាតិ) (យោង៧)។
- អ្នកគាំទ្រការអភិវឌ្ឍន៍ (និងអ្នកតំណាងវិស័យផ្សេងៗ)។
- សាធារណៈ:ជនដែលរងផលប៉ះពាល់។
- អ្នកគាំទ្រផ្នែកបរិស្ថាន និងក្រុមមានចំណាប់អារម្មណ៍នានា។
- អ្នកជំនាញការឯករាជ្យ។
- អង្គការសង្គមស៊ីវិល។

លើសពីនេះទៀត វាជាការសំខាន់ក្នុងការទទួលស្គាល់ថា ការកំណត់ពីវិសាលភាព និងការរៀបចំឲ្យមានជាទម្រង់ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត រួមជាមួយនឹងការកំណត់ឲ្យឃើញច្បាស់ពីបញ្ហាផ្សេងៗ ដែលត្រូវបានធ្វើបរិការណ៍នៅក្នុងលក្ខខ័ណ្ឌជាមូលដ្ឋាន។ ដោយផ្អែកលើសមភាព អ្នកអនុវត្តការវាយតម្លៃសង្គម ត្រូវតែមានការយល់ដឹងជាមូលដ្ឋានលើសំណើអភិវឌ្ឍន៍ (និងជម្រើសដែលអាចជំនួសបាន) សំដៅកំណត់ឲ្យឃើញច្បាស់លាស់ និងយល់ដឹងឲ្យបានត្រឹមត្រូវអំពីបញ្ហាទាំងឡាយ។

(យោង៧) ការថែទាំគួរតែត្រូវបានអនុវត្តដើម្បីជៀសវាងនូវស្ថានភាព ដែលពួកវីរៈជនថាមពលក្លាយជាអ្នកគ្រប់គ្រងផ្តាច់មុខ។ ការកត់សំគាល់ថា "សហគមន៍ច្រើន" រួមមានក្រុមមនុស្សដែលមានផលប្រយោជន៍ស្រដៀងគ្នា គឺជាការសំខាន់។ សញ្ញាណបញ្ជាក់ថាមានទស្សនៈរបស់ "សហគមន៍តែមួយ" ជាធម្មតាអាចនាំឲ្យកើតមាននូវការភាន់ច្រឡំ។

ប្រអប់អត្ថបទ៤.១២ ទំនប់វារីអគ្គិសនីជ្រោយកូពីស (Driekoppies) នៅអាហ្វ្រិកខាងត្បូង
ទំនប់វារីអគ្គិសនី Driekoppies នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ដើរតួនាទីជាគំរូឧទាហរណ៍ដ៏មានអត្ថ-ប្រយោជន៍មួយ សម្រាប់ការកំណត់ពីវិសាលភាព ។ គម្រោងនេះ បានចាប់ផ្តើមក្នុងពាក់កណ្តាលទសវត្សទី ៩០ ដោយមានការកំណត់ពីវិសាលភាពដ៏ទូលំទូលាយ ដែលបានកំពុងអនុវត្តចំពោះសហគមន៍ដែលរងផលប៉ះពាល់ពីទំនប់វារីអគ្គិសនីដែលបានស្នើឡើង។ ការកំណត់ពីវិសាលភាព ត្រូវបានអនុវត្តរួមជាមួយបទដ្ឋានគោលនយោបាយដែលបានកំណត់យ៉ាងច្បាស់លាស់ ហើយត្រូវបានកំណត់ឲ្យឃើញយ៉ាងច្បាស់ពីបញ្ហាផ្សេងៗ រួមមានការបាត់បង់ធនធានដែលហុចផលច្រើន ផលប៉ះពាល់លើសកម្មភាពសេដ្ឋកិច្ច ផលប៉ះពាល់លើការតាំងទីលំនៅ និង ការជ្រកកោន ការតម្រូវឲ្យមានជាចាំបាច់នូវការតាំងទីលំនៅថ្មី ផលប៉ះពាល់លើមូលដ្ឋានសហគមន៍ និងសេវាកម្ម (ជាពិសេសដែលទាក់ទងនឹងសេវាកម្មដែលមានលក្ខណៈល្អប្រសើរ) ការរៀបចំសហគមន៍ និងទំនាក់ទំនងស្ថាប័ន ទីតាំងប្រវត្តិសាស្ត្រ និង ទីតាំងបុរាណ សម្ពាធចំនួនប្រជាពលរដ្ឋ និងការផ្លាស់ទីលំនៅដោយរបាំត់របាយក្នុងសង្គម ។ វាអាចជាការរំលេចឲ្យឃើញថាការកំណត់ពីវិសាលភាព ដែលមានលក្ខណៈទូលំទូលាយ និងជម្រុញឲ្យមានការវាយតម្លៃទៅលើសារៈសំខាន់នៃផលប៉ះពាល់ដែលអាចកើតមាន ។ ផលប៉ះពាល់នីមួយៗ ត្រូវបានចាត់ថ្នាក់តាមប្រភេទវិជ្ជមាន ឬអវិជ្ជមាន ហើយត្រូវបានដាក់តាមលំដាប់នៃទំហំ សារៈសំខាន់ ភាពប្រហាក់ប្រហែល និងរយៈពេល។ ផលប៉ះពាល់សំខាន់ៗ ត្រូវបានកំណត់ឃើញច្បាស់ ថាមានដូចជា ៖ ការបាត់បង់នូវធនធានហុចផលជាច្រើន (ជាអវិជ្ជមាន) ការផ្លាស់ទីលំនៅដោយរបាំត់របាយក្នុងសង្គម (ជាអវិជ្ជមាន) ការផ្គត់ផ្គង់ទឹកក្នុងមូលដ្ឋានមានលក្ខណៈល្អប្រសើរ (ជាវិជ្ជមាន) និងសក្តានុពលនៃការអភិវឌ្ឍនៅក្នុងអនុតំបន់ (ជាវិជ្ជមាន)។ ជាការគួរកត់សម្គាល់ចំពោះលទ្ធផលនៃការកំណត់ពីវិសាលភាព ដូចដែលបានធ្វើបរិការណ៍ រួមជាមួយនឹងទម្រង់នៃល័ក្ខខ័ណ្ឌជាមូលដ្ឋាន សកម្មភាពគម្រោងនាពេលអនាគត ត្រូវបានផ្តល់ជាព័ត៌មានទាក់ទងនឹងការគ្រប់គ្រង ការផ្លាស់ប្តូរសង្គមការបង្កើត និង ការអនុវត្តផែនការសកម្មភាពស្តីពីការតាំងលំនៅថ្មីក្នុង ក្របខ័ណ្ឌគំរូអភិវឌ្ឍន៍។

៤.៤.៦- ការព្យាករណ៍លើផលប៉ះពាល់នានា

ការកំណត់ពីវិសាលភាព ការកំណត់ឲ្យមានជាទម្រង់ និងការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ ផ្តល់ជាមូលដ្ឋានគ្រឹះ (ល័ក្ខខ័ណ្ឌជាមូលដ្ឋាន) ដែលបានពីការព្យាករណ៍លើផលប៉ះពាល់សង្គម ដែលអាចកើតមានដោយសារគម្រោងដែលបានស្នើឡើង សម្រាប់លទ្ធភាពគ្រប់យ៉ាង និង/ឬ ជម្រើសនៃគម្រោងដែលមានលក្ខណៈច្បាស់លាស់ រួមទាំងជម្រើស" គ្មានការផ្លាស់ប្តូរ " ឬ "គ្មានការការអភិវឌ្ឍ" ដោយការយកចិត្តទុកដាក់ជាពិសេស ទៅលើផលប៉ះពាល់ដែលអាចកើតមានចំពោះក្រុមងាយគ្រោះ។ បទពិសោធន៍ បានបង្ហាញថា ការព្យាករណ៍ និងការប៉ាន់ស្មានលើប៉ះពាល់ទាំងឡាយ ត្រូវបានអនុវត្តយ៉ាងល្អបំផុតនៅក្នុងប្រព័ន្ធម៉ាទ្រីសមួយ ដោយការវាយតម្លៃពី**មាត្រដ្ឋាន ប្រពលភាព ចីរវេលា** និង **ភាពប្រហែលកើតមានឡើង** នៃផលប៉ះពាល់ ជាអវិជ្ជមាន ក៏ដូចជាផលប្រយោជន៍ផ្សេងៗ។ សម្រាប់ជម្រើសនៃគម្រោងនីមួយៗ និងសម្រាប់ផលប៉ះពាល់ដែលអាចកើតមាន/ផលប្រយោជន៍នីមួយៗ ការវិភាគពីហានិភ័យ ក៏ត្រូវបានចាប់ អនុវត្តដោយប្រើការសន្មត់ដែលមានលក្ខណៈជាស្តង់ដារ (បញ្ជីតារាង៤.៤) ដែលនាំទៅដល់ការវាយតម្លៃពី**សារៈសំខាន់**នៃផលប៉ះពាល់ ដែលអាចកើតមាន/ផលប្រយោជន៍សម្រាប់ជម្រើសមួយនៃគម្រោងជាក់លាក់។

នៅពេលវាយតម្លៃផលប៉ះពាល់សង្គមដែលអាចកើតមាន គួរត្រូវបានផ្តល់ប្រឹក្សាឲ្យមានការរៀបចំយុទ្ធសាស្ត្រមួយក្នុងការកាត់បន្ថយ ដែលរួមបញ្ចូលទាំងទិដ្ឋភាពនានា ដូចជាអ្វីដែលអាចធ្វើបាន ត្រូវធ្វើបានដោយរបៀបណា អ្វីដែលជាឧបសគ្គ និងអ្វីដែលជាការតម្រូវឲ្យមានដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងត្រូវប្រើពេលវេលាយូរប៉ុណ្ណា។

វាជាការសំខាន់ណាស់ដែលការវាយតម្លៃមួយលើហានិភ័យ មិនត្រូវបានអនុវត្តនៅក្នុងលក្ខណៈដាច់ដោយឡែកនោះទេ សម្រាប់ជម្រើសនៃគម្រោងនីមួយៗ ។ ផ្ទុយទៅវិញ ការវាយតម្លៃត្រូវផ្តោតការយកចិត្តទុកដាក់ពិចារណាទៅលើលក្ខខ័ណ្ឌជាមូលដ្ឋានទាំងអស់ រួមទាំងលក្ខខ័ណ្ឌដែលមិនទាក់ទង ប៉ុន្តែមានសក្តានុពល ដែលគាំទ្រ ឬ ចំណុះឲ្យសំណើអភិវឌ្ឍន៍ សំដៅ ផ្តល់ព័ត៌មានលម្អិតអំពីផលប៉ះពាល់ /អត្ថ-ប្រយោជន៍នានាដែលចេះតែបន្ថែមកើតមាន។

(បញ្ជីតារាង៤.៤) គំរូនៃការសន្មត់ដែលប្រើប្រាស់នៅក្នុងការវាយតម្លៃផលប៉ះពាល់ ដែលអាចកើតមាន/អត្ថប្រយោជន៍នានា។

ការពិពណ៌នា	និយមន័យ
លក្ខណៈនៃផលប៉ះពាល់	
វិជ្ជមាន	ប្រភេទនៃឥទ្ធិពលនៃសកម្មភាពមួយដែលអាចកើតមានចំពោះបរិស្ថានសង្គម
អវិជ្ជមាន	
ទំហំនៃផលប៉ះពាល់	
ក្នុងមូលដ្ឋាន	មានកម្រិតទៅតាមតំបន់គម្រោង និងដែលនៅជុំវិញដោយផ្ទាល់
ក្នុងតំបន់	មានកម្រិតទៅតាមថ្នាក់តំបន់
ក្នុងកម្រិតជាតិ	មានកម្រិតទៅតាមថ្នាក់ប្រទេស
ក្នុងកម្រិតអន្តរជាតិ	មានកម្រិតឆ្លងអន្តរជាតិ
ចីរវេលានៃផលប៉ះពាល់	
រយៈពេលខ្លី	ពី0 ដល់៥ ឆ្នាំ
រយៈពេលធម្យម	ពី៥ ដល់១៥ឆ្នាំ
រយៈពេលវែង	លុះត្រាតែបញ្ចប់សកម្មភាព
ជាអចិន្ត្រៃយ៍	មានជារហូត
ប្រពលភាព (អាំតង់ស៊ីតេ)	
ទាប	ប៉ះពាល់តិចតួច
មធ្យម	ប៉ះពាល់ខ្លាំង
ខ្ពស់	ប៉ះពាល់ធ្ងន់ធ្ងរបំផុត

ភាពមិនអាចជំនួសបាននៃធនធានបង្កឡើងដោយផលប៉ះពាល់	
ទាប	មិនមានធនធានមិនអាចជំនួសបានណាមួយដែលនឹងបង្កឡើងដោយសារផលប៉ះពាល់ (ធនធានដែលរងផលប៉ះពាល់ គឺងាយស្រួលក្នុងការជំនួស/ស្តារឡើងវិញបាន)
មធ្យម	ធនធានដែលនឹងត្រូវរងផលប៉ះពាល់អាចជំនួសបាន ដោយការប្រឹងប្រែង
ខ្ពស់	គម្រោងនឹងបំផ្លាញធនធាន ដែលមានតែមួយគត់ ដែលមិនអាចជំនួសបាន
ភាពអាចត្រឡប់វិញបាននៃផលប៉ះពាល់	
ទាប	ភាពអាចត្រឡប់វិញបានក្នុងកម្រិតទាប ទៅជាមិនអាចត្រឡប់វិញបាន
មធ្យម	ភាពអាចត្រឡប់វិញបានក្នុងកម្រិតធម្យម នៃផលប៉ះពាល់
ខ្ពស់	ភាពអាចត្រឡប់វិញបានក្នុងកម្រិតខ្ពស់ នៃផលប៉ះពាល់
ផលវិបាក	
ទាប	រួមផ្សំដោយចំនុចមានដូចខាងក្រោម ៖ • អាំងតង់ស៊ីតេ ថិរវេលា វិសាលភាព និង ផលប៉ះពាល់ទៅលើធនធានដែល មិនអាចជំនួសបាន ត្រូវចាត់ថ្នាក់ក្នុងកម្រិតទាប • អាំងតង់ស៊ីតេ មានកម្រិតទាប និង មាន ចាប់ពីពីរឡើងទៅនៃលក្ខណៈវិនិច្ឆ័យដទៃទៀត ចាត់ថ្នាក់ថាស្ថិតក្នុងកម្រិតមធ្យម • អាំងតង់ស៊ីតេ ស្ថិតក្នុងកម្រិតមធ្យម ហើយលក្ខណៈវិនិច្ឆ័យទាំង៣ ត្រូវចាត់ ថ្នាក់ក្នុងកម្រិតទាប
មធ្យម	អាំងតង់ស៊ីតេធម្យម ហើយយ៉ាងហោចចំនួន២ នៃលក្ខណៈវិនិច្ឆ័យដទៃ ត្រូវចាត់ថ្នាក់ ក្នុងកម្រិតមធ្យម
ខ្ពស់	• អាំងតង់ស៊ីតេ និង ផលប៉ះពាល់នៃធនធានមិនអាចជំនួសបាន ត្រូវចាត់

	ថ្នាក់ក្នុងកម្រិតខ្ពស់ ជាមួយការរួមបញ្ចូលគ្នានៃវិសាលភាព និងចរវេលា • អាំងតង់ស៊ីតេត្រូវចាត់ថ្នាក់ក្នុងកម្រិតខ្ពស់ ជាមួយលក្ខណៈវិនិច្ឆ័យទាំងអស់ដែលត្រូវចាត់ថ្នាក់ ក្នុងកម្រិតមធ្យម និងខ្ពស់
ភាពដែលអាចកើតមាន	
ច្បាស់	ច្បាស់ជាកើតមាន
ប្រហែលខ្លាំង	ប្រហែលអាចកើតមាន
ប្រហែល	ដូចជាប្រហែលកើតមាន
ប្រហែលជាមិន	ប្រហែលជាមិនអាចកើតមាន
សារៈសំខាន់	
ទាប	មិនមានឥទ្ធិពលចំពោះគម្រោង
មធ្យម	អាចមានឥទ្ធិពលចំពោះគម្រោង
ខ្ពស់	អាចបង្កជាឧបសគ្គគ្រប់គ្រាន់ចំពោះគម្រោង

យកលំនាំពីនាយកដ្ឋានកិច្ចការបរិស្ថាននៃអាជ្រ្វិកខាងត្បូង (ប្រភព អាជ្រ្វិកខាងត្បូង ឆ្នាំ២០១០)

នៅពេលអនុវត្តដំណើរការវាយតម្លៃមួយ គួរតែទទួលស្គាល់ថា ការព្យាករដ៏ត្រឹមត្រូវ គឺមានការលំបាកដើម្បីធ្វើឱ្យចប់ស្រេចបាច់ ដូច្នេះគួរតែមានការប្រើប្រាស់បច្ចេកទេសផ្សេងៗសម្រាប់ធ្វើការព្យាករណ៍ (ដែលមានបច្ចេកទេសមួយចំនួន ត្រូវពឹងផ្អែកលើលក្ខណៈសេដ្ឋកិច្ច) (Taylor *et al.*, 1995) ៖

- ការបន្តនិន្នាការផ្សេងៗ។
  និន្នាការនេះជាប់ពាក់ព័ន្ធនឹងការព្យាករលើនិន្នាការបច្ចុប្បន្ន ចូលទៅក្នុងថ្ងៃអនាគត។
- វិធីសាស្ត្រមេគុណចំនួនប្រជាជន។
  ការប្រើប្រាស់បច្ចេកទេសនេះ ទំហំនៃចំនួនប្រជាជនបច្ចុប្បន្ន ត្រូវបានគុណដោយមេគុណ ដើម្បីរាប់ចំនួននៃការប្រែប្រួលរនៅក្នុងអថេរផ្សេងទៀត។
- គំរូកុំព្យូទ័រ។
  គំរូនេះ ជាប់ពាក់ព័ន្ធនឹងការបង្កើតជារូបមន្តគណិតវិទ្យាស្តីពីការសន្មត់ និងដំណើរការនៃការវាស់បរិមាណនៃអថេរមួយទៀត។
- អ្នកជំនាញខាងផ្តល់ប្រឹក្សា។
  ជាប់ពាក់ព័ន្ធនឹងការទាញយកបទពិសោធន៍របស់អ្នកដទៃ ដែលការពិគ្រោះយោបល់ទាំងនេះបានធ្វើឱ្យមានការប្រើប្រាស់ និង អនុវត្តលើចំណេះដឹងរបស់មនុស្សដទៃផ្សេងទៀត ។ ក្នុងន័យនេះ វាជាការសំខាន់ក្នុងការកត់សម្គាល់ថា “អ្នកជំនាញ” មិនសំដៅទាំងស្រុងទៅលើអ្នកមានជំនាញវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែក៏រាប់បញ្ចូលទាំងសមាជិកសហគមន៍មូលដ្ឋានតាមបែបប្រពៃណីជាអ្នកប្រកបដោយចំណេះដឹងមូលដ្ឋានដ៏មានតម្លៃមួយ ដែលមិនអាចប៉ាន់ស្មានបាន។
- ការប្រៀបធៀបរវាងសហគមន៍ផ្សេងៗ។

បច្ចេកទេសនេះ ពាក់ព័ន្ធនឹងការធ្វើការប្រៀបធៀបរវាងសហគមន៍ និងសហគមន៍ (ឧ.ការធ្វើការប្រៀបធៀបសហគមន៍មួយដែលរងផលប៉ះពាល់ដោយសារគម្រោងដែលបានស្នើឡើង ជាមួយសហគមន៍មួយផ្សេងទៀតដែលធ្លាប់ទទួលរងផលប៉ះពាល់ស្រដៀងគ្នានេះដែរ។)

- គំរូមូលដ្ឋានសេដ្ឋកិច្ច។
  គំរូទាំងនេះអាចត្រូវបានប្រើនៅពេលដែលតំបន់មូលដ្ឋាន ទាញស្រូបយកកម្លាំងសេដ្ឋកិច្ចពីសកម្មភាពជាក់លាក់មួយ (ឧ .ភាពមានការងារធ្វើ)។
- គំរូបញ្ចូល-បញ្ចេញទិន្នផល។
  គំរូនេះពាក់ព័ន្ធនឹងការគណនា និង ការយល់ដឹងអំពីទំនាក់ទំនងរវាងអ្វីដែលត្រូវតែបញ្ចូល ទៅក្នុងការផលិត ជាពិសេសទំនិញ ឬ សេវាកម្ម (ការបញ្ចូល) ក៏ដូចជាកម្រិតនៃការផលិត ដែលចេញជាលទ្ធផល (ការបញ្ចេញ)។
- ការវិភាគលើចំណាយ-ចំណូល។
  គំរូបែបសេដ្ឋកិច្ច ពាក់ព័ន្ធនឹងការតំឡើងទំងន់នៃការចំណាយ និងផលប្រយោជន៍ (រួមបញ្ចូលទាំងការចំណាយ និងផលប្រយោជន៍ “លាក់កំបាំង” ដើម្បីយល់ពីផលប៉ះពាល់ដល់សេដ្ឋកិច្ចដែលមិនគ្រាន់តែជាផលប៉ះពាល់អាចគិតជាតួលេខដែលបានវាស់វែងដោយតម្លៃទីផ្សារប៉ុណ្ណោះទេ។
- ការគណនាតួលេខផ្នែកខាងក្រៅ។
  ការគណនានេះជាប់ពាក់ព័ន្ធនឹងការគណនាតម្លៃ ប្រយោលនៃផលប៉ះពាល់ ដែលផលប៉ះពាល់នោះ មិនអាចត្រូវបានផ្តល់ព័ត៌មានល្អិតល្អន់សម្រាប់ ប្រតិបត្តិការសេដ្ឋកិច្ចនៃគម្រោងជាក់លាក់មួយ តួយ៉ាង ៖
  - ចំណាយលើការថែទាំសុខភាព ដែលអាចជាការដាក់បន្ទុកលើការបំភាយឧស្ម័នខ្យល់ចូលក្នុងបរិយាកាសរបស់រោងចក្រសហគ្រាសមួយ។
  - ចំណាយលើការដឹកជញ្ជូន បានបង្កឡើងដោយសារចំនួនប្រជាជននៅក្នុងតំបន់ ដោយមូលហេតុនៃការកើនឡើងលើរយៈចម្ងាយធ្វើដំណើរ កើតចេញពីការឃុំគ្រងមួយដែលតម្រូវសម្រាប់មូលដ្ឋានវារីអគ្គិសនីមួយ ។ ប្រការនេះ ត្រូវបានគេស្គាល់ផងដែរថា ជាការឲ្យតម្លៃដោយចៃដន្យ និង ជារង្វាស់មួយនៃឆន្ទៈរបស់អ្នកអភិវឌ្ឍន៍ក្នុងការចំណាយសម្រាប់ផ្នែកខាងក្រៅ ដែលបានផ្សារភ្ជាប់ជាមួយគម្រោងដែលបានស្នើឡើង ឬ ជម្រើស ដែលអាចជំនួសបានរបស់គម្រោង។
- គំរូសេដ្ឋមាត្រ។
  គំរូទាំងនេះ រួមមានប្រព័ន្ធសមីការគណិតវិទ្យា ដែលបានរចនាឡើងដើម្បីចាប់យករចនាសម្ព័ន្ធទម្រង់លក្ខណៈសុគស្មាញ និងទំនងទំនងទៅវិញទៅមកនៃសេដ្ឋកិច្ចមួយ ជាពិសេស។
- ម៉ាទ្រីសគណនេយ្យសង្គម។
  វាគឺជាគំរូសេដ្ឋកិច្ចដែលមានលក្ខណៈសុគស្មាញ ត្រូវបានរចនាឡើងដើម្បីកំណត់បរិមាណផលប្រយោជន៍សង្គម និង ការចំណាយផ្សេងៗ (តាមបែបតម្រង់ទិស ច្រើនជាងការវិភាគលើចំណាយ-ចំណូល តាមបែបប្រពៃណី)។
- សេណារីយ៉ូ។

សេណារីយ៉ូ ជាប់ពាក់ព័ន្ធនឹង " ចេញពីការគិតទៅជាមិនអាចគិតបាន" ដើម្បីបង្កើតឲ្យមានគំរូជាទ្រឹស្តី នៃលទ្ធផលអាចទទួលបាន។

សម្រាប់គម្រោងជាច្រើន ជម្រើសដែលអាចជំនួសបានរបស់គម្រោង និងផលប៉ះពាល់ដែលអាចកើតមាន វាមិនចាំបាច់ក្នុងការប្រើបច្ចេកទេសដែលមានការលំបាក និងស្មុគស្មាញនោះទេ ។ ផ្ទុយទៅវិញ ការស្នើដោយ Taylor, *et al*., (1995) ផ្តោតសំខាន់លើ **បទពិសោធន៍ត្រឹមត្រូវតាមហេតុផល** និង**សុភវិនិច្ឆ័យ**។ នេះ គឺជាការធ្វើឲ្យវាទៅជាសំខាន់ចំពោះការវាយតម្លៃផលប៉ះពាល់សង្គម/ផលប្រយោជន៍ ដែលត្រូវតែចងចាំជានិច្ចចំពោះដំណោះស្រាយនៃការវាយតម្លៃហេតុប៉ះពាល់សង្គមជាមួយមនុស្ស និង ធម្មជាតិរបស់មនុស្ស។ ភាគច្រើននៃទិដ្ឋភាពទាំងនេះ មិនចេះតែអាចកំណត់បរិមាណបានគ្រប់ពេលទាំងអស់ទេ។ ផ្ទុយទៅវិញ ទិដ្ឋភាពទាំងនេះច្រើនតែទាក់ទងនឹងគុណភាពនៅក្នុងផ្នែកធម្មជាតិច្រើនជាង ហេតុដូច្នេះបច្ចេកទេសពឹងផ្អែកលើវិទ្យាសាស្ត្រ និង ឬ/សេដ្ឋកិច្ច មិនមែនតែងតែមានលក្ខណៈសមស្របតែទាំងអស់នោះទេ។

ដូចបានបង្ហាញពីមុនរួចហើយ ការព្យាករពីផលប៉ះពាល់ពឹងផ្អែកយ៉ាងសំខាន់ទៅលើមូលដ្ឋានទិន្នន័យដែលប្រមូលបានពីមុន។ លើសពីនេះទៀត មូលដ្ឋានទិន្នន័យដូចគ្នា ក៏ដូចជាលទ្ធផលនៃការវាយតម្លៃ ត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណអថេរ ដែលអាចត្រូវបានវាស់វែងសម្រាប់គោលបំណង នៃការត្រួតពិនិត្យ និងការវាយតម្លៃ។

លទ្ធផលនៃព្យាករណ៍ និងការប៉ាន់ស្មានអំពីផលប៉ះពាល់ គួរតែត្រូវបានបង្ហាញជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវ និងជារបាយការណ៍ដែលមានរំលេចដោយរូបភាពលម្អផង (ឬបើពុំដូច្នេះទេ ដូចដែលបានចង្អុលបង្ហាញតាមរយៈបទដ្ឋានជានិយាម ដែលអាចអនុវត្តបានចំពោះការអភិវឌ្ឍដាច់ដោយឡែក ឬ ចំពោះការវាយតម្លៃហេតុប៉ះពាល់សង្គម។

ប្រអប់អត្ថបទ៤.១៣ គម្រោងទំនប់វារីអគ្គិសនីកាន់ដាដជី (Kandadji Dam) នៅប្រទេសនីហ្សេរីយ៉ា

គម្រោងទំនប់វារីអគ្គិសនីកាន់ដាដជី (Kandadji Dam) នៅប្រទេសនីហ្សេរីយ៉ា គឺជាគំរូឧទាហរណ៍ដ៏មានសារៈប្រយោជន៍មួយនៃការព្យាករណ៍ និងប៉ាន់ស្មានពីផលប៉ះពាល់សង្គម ដែលហាក់ដូចជាត្រូវបាន ហ៊ឹមព័ទ្ធយ៉ាងទូលំទូលាយ គ្របដណ្តប់ទាំងផលប៉ះពាល់អវិជ្ជមាន ទាំងផលប្រយោជន៍ រួមទាំងការតាំងទីលំនៅថ្មី (៣៥០០០ នាក់ មកពី១៥ ភូមិ) ការបាត់បង់ (ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវជាតិ boreholes គ្លីនិក សាលារៀន ព្រះវិហារ ទីសត្វឃាត ទីផ្សារ និងវោងម៉ាស៊ីនកិនស្រូវការបាត់បង់ដី (កសិកម្ម) ប្រមាណជា ៧០០០ហិកតា (ការផ្គត់ផ្គង់ទឹកស្អាតដោយមានការធានាសម្រាប់ប្រើប្រាស់ក្នុង ទីក្រុងនិងទីជនបទ ប្រព័ន្ធធារាសាស្ត្រ សត្វចិញ្ចឹម និងវារីវប្បកម្ម) ការកាត់បន្ថយក្នុងការពឹងអាស្រ័យលើការនាំចូលថាមពលសន្តិសុខស្បៀង និងឱកាសសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ផលប៉ះពាល់លើសុខភាពសាធារណៈ និងផលប៉ះពាល់ដោយប្រយោល (កាត់បន្ថយការធ្វើចំណាកស្រុកជនបទ ឱកាសសម្រាប់ឧស្សាហកម្មនៅខ្សែទឹកខាងលើ និងខាងក្រោម ឱកាសការងារ ក្នុងអំឡុងពេលសាងសង់ទំនប់វារី និងការរួមចំណែកឆ្ពោះទៅរកការកាត់បន្ថយភាពរហោឋាន)។ ចំពោះគម្រោងទំនប់ Kandadji ផលប៉ះពាល់ដែលអាចកើតមានត្រូវបានព្យាករណ៍នៅដើមដំហានដំបូងនៃការរៀបចំផែនការគម្រោង ដើម្បីធ្វើយ៉ាងណាឲ្យបញ្ហានិងផលប៉ះពាល់ដែលអាចកើតមានត្រូវបានកំណត់ចូលនៅក្នុងដំហាន ធ្វើផែនការជាបន្តបន្ទាប់។ ជាការសមហេតុផលដែរក្នុងការកត់សំគាល់ថា ការព្យាករណ៍ពីផលប៉ះពាល់ដែលអាចកើតមានមិនត្រឹមតែផ្តោតទៅលើទិដ្ឋភាពអវិជ្ជមានតែប៉ុណ្ណោះទេ ប៉ុន្តែក៏រួមបញ្ចូលទាំងការប៉ាន់ប្រមាណពីអត្ថ

ប្រយោជន៍ផ្សេងៗ ដោយហេតុនេះ គេត្រូវជូនដំណឹងពីការកសាងផែនការ ដើម្បីធ្វើឲ្យមានការយល់កាន់តែច្បាស់ទាន់ពេលវេលា អំពីផល-ប្រយោជន៍ផ្សេងៗ។

៤.៤.៦.១ ការព្យាករ និងការវាយតម្លៃលើការឆ្លើយតបចំពោះផលប៉ះពាល់នានា

មានវិធីសាស្ត្រជាច្រើនដែលអាចយកមកប្រើប្រាស់សម្រាប់ធ្វើជាគោលបំណងនៃការព្យាករ និងវាយតម្លៃផលប៉ះពាល់ រួមមាន ៖ ការប្រៀបធៀបស្រដៀងគ្នា មតិយោលបល់របស់អ្នកជំនាញ ការពិនិត្យឡើងវិញចំពោះឯកសារព័ត៌មាន និងទំនាក់ទំនងនៃការបង្កផលប៉ះពាល់។ ក្នុងពេលជ្រើសរើសវិធីសាស្ត្រគួរគិតគូរដល់លក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ៖

- ភាពសមស្របនៃការអភិវឌ្ឍន៍ដែលបានស្នើឡើង។
- ភាពអាចទទួលយកបាន ចំពោះភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ និង ភាគីដែលរងផលប៉ះពាល់ ។
- មានលក្ខណៈវិជ្ជាជីវៈដែលអាចទទួលយកបាន។
- ការធ្វើឲ្យធូរស្រាលដល់ការអនុវត្តមិនដាច់ស្រេច និងការកំណត់ព្រំដែននៃការគ្រប់គ្រង។
- ភាពអាចអនុវត្តបានលើបញ្ហាគន្លឹះមួយចំនួន។
- ការផ្តល់នូវលទ្ធផល ដែលបានធ្វើឲ្យមានការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ ទៅលើការវាយតម្លៃផលប៉ះពាល់។

សារៈសំខាន់នៃផលប៉ះពាល់ជាក់លាក់មួយ គឺជាមុខងារនៃការយល់ដឹងពីទំហំ អាំងតង់ស៊ីតេ ចិរវេលារបស់ខ្លួន និងភាពប្រហាក់ប្រហែលនៃការកើតឡើង។

មានឧទាហរណ៍ជាច្រើននៃផលប៉ះពាល់ ដែលអាចកើតឡើងចេញពីគម្រោងដែលបានស្នើឡើង។ ភាគច្រើននៃផលប៉ះពាល់ទាំងនេះ ជាធម្មតាអាចគ្រប់គ្រងបាន តាមរយៈដំណោះស្រាយបច្ចេកទេសមួយត្រួយ៉ាងដូចជា ការរៀបចំផ្លូវថ្មល់ជាថ្មីឡើងវិញ ការលុបបំបាត់ធូលី នៅតំបន់សាងសង់ ការកម្រិតសម្លេងរំខាន ជាដើម។

ទោះយ៉ាងណា នៅមានផលប៉ះពាល់សំខាន់តែមួយគត់ ដែលពិបាកក្នុងការគ្រប់គ្រង ហើយដែលគ្មានដំណោះស្រាយជាបច្ចេកទេសណាអាចធ្វើបាន នោះគឺការតាំងទីលំនៅថ្មី (រួមទាំងទិដ្ឋភាពនានា ដូចជាការបំលាស់ទីសេដ្ឋកិច្ច ការបាត់បង់អ្វីដែលធ្លាប់តែទទួលបាន (តំបន់ដែលផ្តល់អត្ថប្រយោជន៍ តំបន់ជាទីគោរពសក្ការៈ ឬ ទីតាំងបូជាសាសនា ធនធានធម្មជាតិ។ល។) នៅទីកន្លែងណាដែលមិនអាចបញ្ចៀសផលប៉ះពាល់បានត្រូវយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន ក្នុងការបង្កើតផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ជាមួយនឹងការចូលរួមយ៉ាងជុំសជុលពីសំណាក់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ (ជាមួយនឹងសកម្មភាពនៃការតាំងលំនៅថ្មីទាំងអស់នេះ ត្រូវស្របគ្នាបំផុតជាមួយសកម្មភាពនៃគម្រោងអភិវឌ្ឍន៍ដំបូង)។

ការតាំងទីលំនៅថ្មី មានបរិយាយយ៉ាងលម្អិតនៅក្នុងផ្នែកទី៥។

ប្រអប់អត្ថបទ៤.១៤ គម្រោងទឹកធុកិឡា (Thukela Water) នៅអាហ្វ្រិកខាងត្បូង
គម្រោងទឹក Thukela Water (ការសិក្សាស្រាវជ្រាវ) នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ដើរតួនាទីជាឧទាហរណ៍ដ៏មានអត្ថប្រយោជន៍មួយនៃការព្យាករ និងការវាយតម្លៃលើការឆ្លើយតបចំពោះផលប៉ះពាល់ទាំងឡាយ។ សម្រាប់គម្រោងដែលបានស្នើនេះ ការវាយតម្លៃហេតុផលប៉ះពាល់សង្គម បានកំណត់ឲ្យឃើញច្បាស់ និង បានពិភាក្សាពីបញ្ហាសង្គម និង ផលប៉ះពាល់ដែលអាចកើតមាននៅក្នុងពីរកម្រិត ។ កម្រិតដំបូង ជាការពិនិត្យលើបញ្ហាជាបរិបទមួយចំនួនដែលពាក់ព័ន្ធទៅនឹងគម្រោងដែលបានស្នើ ដែលជាបញ្ហាបានលេចចេញក្នុងអំឡុងពេលនៃការស៊ើបអង្កេត ។ បញ្ហាដែលធំបំផុតនោះ គឺផលប៉ះពាល់ដែលអាចកើតមានដោយសារការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ និន្នាការចំនួនប្រជាជននៅក្នុងតំបន់ដែលសឹករិចរិល ផលប៉ះពាល់នៃកករល្បាប់ កំណែទំរង់ ការប្រគល់ដីធ្លីសងវិញ ផលប៉ះពាល់ លើបរិស្ថានផ្នែកខាងក្រោម និងផលប៉ះពាល់លើបរិស្ថានដែលទទួល។ បន្ទាប់ពីនោះ ការសិក្សាបានផ្តោតសំខាន់លើ ផលប៉ះពាល់ដែលអាចកើតមានលើអ្នកធ្វើសំណើគម្រោងអភិវឌ្ឍន៍ធំនីមួយៗ មានដូចជា គម្រោងទំនប់Jana ទំនប់Mielietuin ទំនប់ និងផ្លូវសម្រាប់ការដឹកជញ្ជូន (ប្រឡាយនិងខ្សែបំពង់ដែក)។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងយ៉ាងលម្អិត ជាមួយនឹងលទ្ធផលដែលទាក់ទងជាមួយនឹងការបង្កើតផែនការគ្រប់គ្រង សង្គមរួបមន្តនាពេលអនាគត (ដើម្បីដោះស្រាយជាមួយបញ្ហាធំៗនៃផលប៉ះពាល់អវិជ្ជមានលើសង្គម និងការប្រើប្រាស់អត្ថប្រយោជន៍ឲ្យអស់ពីលទ្ធភាព ផ្អែកតាមទំហំក្នុងស្រុក និងក្នុងតំបន់)។

ប្រអប់អត្ថបទ៤.១៥ គម្រោងទំនប់វារីអគ្គិសនីណាំធឿន២ (Nam Theun 2) សាធារណរដ្ឋប្រជាធិបតេយ្យឡាវ
គម្រោងវារីអគ្គិសនី Nam Theun ២ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ភាគកណ្តាលនៃប្រទេសឡាវ គឺជាឧទាហរណ៍ដ៏មានអត្ថប្រយោជន៍មួយនៃការព្យាករ និង ការវាយតម្លៃលើការឆ្លើយតបចំពោះផលប៉ះ-ពាល់នានា។ សម្រាប់គម្រោងដែលបានស្នើនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (រួមទាំទិដ្ឋភាពសង្គម) ដែលបានកំណត់ និងបានពិភាក្សាពីបញ្ហាសង្គម និងផលប៉ះពាល់ដែលអាចកើតមាននៅក្នុង៣កម្រិត។ កម្រិតដំបូង គឺជាការពិនិត្យលើបញ្ហាក្នុងតំបន់ដែលទាក់ទងនឹងគម្រោងស្នើឡើង ។ បញ្ហាដែលធំបំផុតនោះ គឺផលប៉ះពាល់ដែលអាចកើតមានទៅលើជីវចម្រុះ ផលប៉ះពាល់លើបរិស្ថានផ្នែកខាងក្រោម និងប្រភពស្បៀងអាហារ និងចំណូល។ បន្ទាប់ពីនោះ ការសិក្សានេះបានផ្តោតទៅលើទីតាំងគម្រោង។ តំបន់គម្រោងនេះ ត្រូវបានបែងចែកទៅជា១៥តំបន់នៃសកម្មភាព និង/ឬ ផលប៉ះពាល់ តួយ៉ាងដូចជាតំបន់ការពារ តំបន់តាំងទីលំនៅថ្មី ផ្លូវថ្នល់ ជាដើម។ កម្រិតទី៣ គឺផលប៉ះពាល់ដែលអាចកើតមានចំពោះអ្នកធ្វើសំណើគម្រោងអភិវឌ្ឍន៍ធំនីមួយៗ មានដូចជា ហេដ្ឋារចនាសម្ព័ន្ធ ៖ ទំនប់រងបន្ទុក ស្ថានីយ៍ថាមពលរចនាសម្ព័ន្ធត្រួតពិនិត្យខ្សែទឹកខាងក្រោម និងការដឹកជញ្ជូន ខ្សែបញ្ជូនចរន្តអគ្គិសនី។ល។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងយ៉ាងលម្អិត ជាមួយនឹងលទ្ធផលដែលទាក់ទងជាមួយនឹងការបង្កើតផែនការគ្រប់គ្រងសង្គម រួបមន្តនាពេលអនាគត (ដើម្បីដោះស្រាយលើបញ្ហាប្រឈមធំៗ ផលប៉ះពាល់អវិជ្ជមានលើសង្គម និងការប្រើប្រាស់អត្ថប្រយោជន៍ឲ្យអស់ពីលទ្ធភាព ផ្អែកតាមទំហំក្នុងស្រុក និងក្នុងតំបន់)។

៤.៤.៦.២ ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងការប្រើប្រាស់អត្ថប្រយោជន៍ឲ្យអស់ពីលទ្ធភាព

ការកាត់បន្ថយ គឺជាការបញ្ឈៀស ឬ កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមានដោយសារគម្រោងណាមួយ នៅក្នុងលក្ខណៈមួយដែលមាននិរន្តរភាព ។ និយាយយ៉ាងខ្លី ការកាត់បន្ថយមានជាប់

ពាក់ព័ន្ធនឹងការអនុវត្តលើលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់សង្គម ដែលអាចសម្រេចជោគជ័យទៅបានតាមរយៈការបង្កើត និង ការអនុវត្តផែនការគ្រប់គ្រងសង្គម ដែលជាពិសេសគឺការដោះស្រាយផងដែរនូវការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព។

ជាពិសេស មានផែនការគ្រប់គ្រងសង្គមចំនួន២ប្រភេទ ដែលផែនការទាំងនោះសំដៅដោះស្រាយផលប៉ះពាល់ជាអវិជ្ជមាន និងជាការដោះស្រាយប្រកបដោយផលប្រយោជន៍ ។ ទោះយ៉ាងណា នៅក្នុងករណីនីមួយៗ អ្វីដែលគួរពិចារណា គឺការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ។ ក្នុងន័យនេះ ផែនការគ្រប់គ្រងសង្គម គួរត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃគំរូអភិវឌ្ឍន៍ និងគួរធ្វើឲ្យមានលើសពីការបំលាស់ទី " យ៉ាងហោចណាស់ក៏អាចធ្វើឲ្យប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ទទួលបានជីវភាពធូរធារដូចពីមុនការអន្តរាគមន៍នៃគម្រោងដែរ " ។ សកម្មភាពនេះតម្រូវឱ្យមានជាដំបូងនូវការស្តារជីវភាពឡើងវិញ និង យុទ្ធសាស្ត្រក្នុងការចិញ្ចឹមជីវិត និងបន្ទាប់មក តម្រូវឲ្យមាននូវការធ្វើឲ្យប្រសើរឡើងដល់សង្គម និងសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាពដល់ប្រជាពលរដ្ឋ និងសង្គមជាតិដែលពួកគេកំពុងរស់នៅ។

វាក៏ជាការសំខាន់ដែរក្នុងការកត់សម្គាល់លើផែនការគ្រប់គ្រងសង្គម ថាតើការដោះស្រាយលើការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ឬ ការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព តម្រូវឲ្យមានការ ផ្តល់ជូនជាពិសេសសម្រាប់ដោះស្រាយលើតម្រូវការ និងសេចក្តីប្រាថ្នារបស់ប្រជាជនងាយរងគ្រោះ។ ការផ្តល់ជូននេះ អាចត្រូវបានចងក្រងជាឯកសារ នៅក្នុងក្របខ័ណ្ឌផែនការរួម ឬ អាចបង្កើតជាផែនការដាច់ដោយឡែកមួយ តួយ៉ាងដូចជាផែនការសកម្មភាពស្តីពីយេនឌ័រ ដើម្បីដោះស្រាយលើទិដ្ឋភាពជាក់លាក់ស្តីពីយែនឌ័រ។

នៅក្នុងលក្ខខ័ណ្ឌនៃផលប៉ះពាល់សង្គមជាអវិជ្ជមាន ដែលភាគច្រើនគឺមានដំណោះស្រាយបច្ចេកទេសមួយ សម្រាប់បញ្ជៀសផលប៉ះពាល់ទាំងស្រុង ឬ យ៉ាងហោចណាស់ក៏អាចកាត់បន្ថយផលប៉ះពាល់នោះបានជាអប្បបរមា។ នៅក្នុងករណីជាច្រើនបំផុត ប្រសិនបើកម្រិតនៃការបញ្ជៀស ឬ កាត់បន្ថយដែលអាចទទួលយកបាន មិនអាចធ្វើទៅរួច ការតាំងទីលំនៅថ្មី គឺជាវិធានការដែលត្រូវតែអនុវត្តដើម្បីកាត់បន្ថយ / គ្រង់គ្រង។ នៅក្នុងករណីនេះ ការតាំងទីលំនៅថ្មី ត្រូវបានអនុវត្តក្រោមក្របខ័ណ្ឌនៃការផ្តល់ជូន តាមរយៈផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី។ គោលដៅជាមូលដ្ឋាននៃផែនការសកម្មភាពស្តីពីការតាំងលំនៅថ្មី *គឺត្រូវធ្វើយ៉ាងណាឲ្យអ្នកដែលបានរុះរើទីលំនៅ ដោយសារគម្រោងអាចពង្រឹងជីវភាពរស់នៅរបស់ខ្លួនបានល្អប្រសើរ* (IFC, 2002) ពោលគឺគួរធ្វើឲ្យមានលើសពីការបំលាស់ទី " យ៉ាងហោចណាស់ក៏អាចធ្វើឲ្យប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ទទួលបានជីវភាពធូរធារដូចពីមុនការអន្តរាគមន៍នៃគម្រោងដែរ" ។

ផែនការសកម្មភាពស្តីពីការតាំងលំនៅថ្មី គួរតែគ្របដណ្តប់ជាអប្បបរមានូវចំនុច ដូចខាងក្រោម ៖

- ការកំណត់ឲ្យបានច្បាស់លាស់ពីផលប៉ះពាល់នៃគម្រោងមួយ និងចំនួនប្រជាពលរដ្ឋរងផលប៉ះពាល់។
- ក្របខ័ណ្ឌច្បាប់ស្តីពីការទទួលបានដីធ្លី និងការទូទាត់សំណង។
- ក្របខ័ណ្ឌនៃការទូទាត់សំណង (ជាមួយនឹងលក្ខណៈវិនិច្ឆ័យសមតា និង ម៉ាទ្រីស ដែលបង្ហាញពីការផ្តល់សិទ្ធិទទួលបាន។
- ការពិពណ៌នាពីការផ្តល់ជំនួយដល់ការតាំងលំនៅថ្មី និង ការស្តារឡើងវិញនូវសកម្មភាពប្រកបរបរចិញ្ចឹមជីវិត។

- ការចំណាយថវិកាលម្អិត។
- កាលវិភាគនៃការអនុវត្ត។
- ការពិពណ៌នាអំពីការទទួលខុសត្រូវរបស់ស្ថាប័ន។
- បទដ្ឋានសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ ការចូលរួម និង ការកសាងផែនការអភិវឌ្ឍន៍។
- ការពិពណ៌នាអំពីបទប្បញ្ញត្តិសម្រាប់ការដោះស្រាយលើបណ្តឹងសារទុក្ខ។
- បទដ្ឋានសម្រាប់ត្រួតពិនិត្យ វាយតម្លៃ និងធ្វើរបាយការណ៍ (ប្រភព IFC, 2002)។

ត្រូវយកចិត្តដាក់យ៉ាងខ្លាំង ក្នុងការបង្កើតផែនការសកម្មភាពនៃការតាំងលំនៅថ្មីនេះ ។ បន្ទាប់ពីការកំណត់ឲ្យឃើញច្បាស់ជាមុននូវចំនួនប្រជាជនដែលរងផលប៉ះពាល់ ចាំបាច់ត្រូវធានាឲ្យប្រាកដថា សិទ្ធិសមតា និងសិទ្ធិទទួលបានកម្មសិទ្ធិ ត្រូវបានយល់ព្រមជាមុន តាមដែលអាចធ្វើទៅបានលើដំណើរការនៃការរៀបចំផែនការតាំងទីលំនៅថ្មី។ សកម្មភាពនេះ តម្រូវឱ្យមានការចចារជាមួយប្រជាពលរដ្ឋរងផលប៉ះ-ពាល់ ដោយពន្យល់យ៉ាងងាយអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធទាំងអស់។ នៅក្នុងលក្ខខ័ណ្ឌនៃការទទួលខុសត្រូវ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ត្រូវជួយដល់អ្នកធ្វើសំណើគម្រោងអភិវឌ្ឍន៍ ក្នុងការប្រឆាំងនឹងការតវ៉ាមិនត្រឹមត្រូវ ឬ ភាពស្លាំងស្លាត់ណាមួយ ទោះជាការតវ៉ានោះធ្វើឡើង ដោយប្រជាពលរដ្ឋរងផលប៉ះពាល់ក្តី ឬ ដោយអ្នកចំណូលថ្មី ដែលចូលមកតាំងទីលំនៅក្នុងតំបន់ដែលរងផលប៉ះ-ពាល់ដោយសារគម្រោង ដោយសង្ឃឹមថានឹងអាចទទួលបានការទូទាត់សំណងក្តី។

អ្វីដែលសំខាន់គឺផែនការតាំងលំនៅថ្មី និងការអនុវត្តផែនការនោះ គួរតែទទួលបានជាអាទិភាពដូចគ្នាថា ជាការអន្តរាគមន៍ការអភិវឌ្ឍជំហានដំបូង (ការរៀបចំផែនការ ធនធាននានា។ល។) ហើយគួរតែអនុវត្ត ស្របពេលជាមួយនឹងគម្រោងជំហានបឋមដែរ។

នៅក្នុងករណីជាច្រើន តំបន់ដែលរងឥទ្ធិពលពីគម្រោងមួយ គឺមានទំហំធំជាងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយផ្ទាល់ តួយ៉ាងពីការតាំងទីលំនៅថ្មី។ ក្នុងករណីទាំងអស់នេះ ផែនការអភិវឌ្ឍសង្គម គួរត្រូវបានបង្កើតឡើង សម្រាប់ប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវអត្ថប្រយោជន៍នៃគម្រោងនេះ។ជាពិសេសផែនការទាំងនេះត្រូវតែដើរទន្ទឹមគ្នាជាមួយយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវអត្ថប្រយោជន៍នានា (ដែលបានពីជាំហានបឋម ក៏ដូចជាការអភិវឌ្ឍន៍នៅផ្នែកខាងក្រោម) ក្នុងលក្ខណៈប្រកបដោយចីរភាព ក៏ដូចជាធ្វើយ៉ាងណាឲ្យគម្រោងនីមួយៗទទួលបានការគាំទ្រជាចាំបាច់ពីរដ្ឋាភិបាលនាពេលអនាគត (ពីការផ្តត់ផ្តង់បុគ្គិលសម្រាប់សាលារៀន ទៅជាការផ្តល់ជាមណ្ឌលសុខភាព)។ ក្នុងន័យនេះ អ្នកធ្វើសំណើអភិវឌ្ឍន៍ចាំបាច់ត្រូវយល់ច្បាស់អំពីពីឥទ្ធិពលលើបរិស្ថានសង្គម នៃគម្រោងដែលបានស្នើ និងផ្ទុយមកវិញ អំពីឥទ្ធិពលនៃបរិស្ថានសង្គមទៅលើគម្រោងដែលបានស្នើ។

ការវិនិយោគផ្នែកសង្គម គឺជាភាពចាំបាច់ និងជាអ្វីដែលអាចជួយធ្វើឲ្យជីវិតធូរស្រាលឡើង។ ដល់ចុងបញ្ចប់កម្មវិធីមូលនិធីសង្គម (យោង៩) ត្រូវកសាងឲ្យមានការទំនាក់ទំនងសម្រាប់អាស្រ័យផលប្រយោជន៍ទៅវិញទៅមក ជាជាងសម្រាប់គុណតម្លៃនៃការផ្សព្វផ្សាយ ។ ដូចគ្នានឹងផែនការអភិវឌ្ឍន៍សង្គមដែរ កម្មវិធីមូលនិធិសង្គម ត្រូវតែស្របគ្នាជាមួយយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការប្រើប្រាស់អត្ថប្រយោជន៍ឲ្យអស់ពីលទ្ធភាព។

ដូច្នេះ មានការស្នើឡើងថា ផែនការអភិវឌ្ឍសង្គម គួរត្រូវបានបង្កើតឡើងក្នុងវិសាលភាពដូចគ្នា និង ក្នុងកម្រិតល្អិតល្អន់ រួមជាមួយនឹងកម្មវិធីចំណាយ និង អនុវត្តដូចគ្នាទៅនឹងផែនការ ដែលបានបង្កើត

ឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ។ នៅទៅចុងបញ្ចប់ ដរាបណាមានការខិតខំប្រឹងប្រែង និង ការចូលរួមរបស់អ្នកធ្វើសំណើអភិវឌ្ឍន៍កាន់តែទូលំទូលាយ នោះមានន័យថាការអន្តរាគមន៍ផ្នែកសង្គម នឹងប្រាកដជាទទួលបានជោគជ័យ និងប្រកបដោយចីរភាពជាក់ជាមិនខាន។

(យោង៩) មូលនិធិទទួលខុសត្រូវសង្គម (CSR) មាននិយមន័យជាច្រើនខុសៗគ្នា ប៉ុន្តែវាជាកាតព្វកិច្ចដែលត្រូវការជាចាំបាច់សម្រាប់ស្តាប័នជំនួញ ដែលហួសពីការតម្រូវដោយច្បាប់ ដើម្បីបន្តគោលដៅរយៈពេលវែង ដែលមានផលល្អសម្រាប់សង្គម។ វាគឺជាវិធីមួយដែលអាចជម្រុញឲ្យក្រុមហ៊ុនមួយ និងភាគីពាក់ព័ន្ធទាំងអស់អាចគ្រប់គ្រងដោយខ្លួនឯងនូវផលប៉ះពាល់ជាវិជ្ជមានជារួមទៅលើសង្គម ។ ជាពិសេសជាងនេះទៅទៀត (CSR)ពាក់ព័ន្ធនឹងជំនួញដែលកំណត់យ៉ាងច្បាស់លាស់លើក្រុមភាគីពាក់ព័ន្ធ និងរួមបញ្ចូលតម្រូវការ និងគុណតម្លៃរបស់ពួកគេ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចជាយុទ្ធសាស្ត្ររបស់ភាគីទាំងនោះរួមជាមួយនឹងដំណើរការជាយុទ្ធសាស្ត្រ ព្រមទាំងការធ្វើសេចក្តីសម្រេចចិត្តប្រចាំថ្ងៃ។ CSRជាប់ពាក់ព័ន្ធនឹង: (១) ការធ្វើជំនួញក្នុងលក្ខណៈក្រមសីលធម៌ និងដើម្បីផលប្រយោជន៍ទូលំទូលាយនៃសហគមន៍ (២) ការឆ្លើយតបជាវិជ្ជមានចំពោះអាទិភាពនិងការរំពឹងទុកផ្នែកសង្គមដែលលេចឡើង (៣) ឆន្ទៈមួយដើម្បីធ្វើសកម្មភាពនាំមុខនៃការប្រឈមផ្នែកបទប្បញ្ញត្តិ (៤) ការធ្វើឲ្យមានតុល្យភាពនូវការបែងចែកផលប្រយោជន៍រវាងម្ចាស់ផលប្រយោជន៍រួម និងសហគមន៍ទូលំទូលាយ (៥) ធ្វើជាពលរដ្ឋល្អនៅក្នុងសហគមន៍។ **ជាការសំខាន់ដោយមិនត្រូវបំភ្លេច ឬមានការយល់ច្រឡំថា មូលនិធិទទួលខុសត្រូវសង្គម (ដែលជាធម្មតា ជាការស្ម័គ្រចិត្ត) ជាមួយការទូទាត់សំណង និងការចែករំលែកផលប្រយោជន៍ (ដែលជាធម្មតាគឺជាកាតព្វកិច្ច (ផ្នែកទី៦)។ ក្នុងន័យនេះ (CSR) ដំណើរការលើសពីការទូទាត់សំណង និងការចែករំលែកផលប្រយោជន៍ដើម្បីបន្ថែមគុណតម្លៃដែលអាចនឹងលេចចេញពីឱកាសទទួលបានពីគម្រោង និងការបន្ថែមអត្ថប្រយោជន៍សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ និង/ឬអ្នកទទួលផលពីគម្រោង។**

ជាមួយនឹងផែនការកាត់បន្ថយ ផែនការអភិវឌ្ឍន៍សង្គម ត្រូវបានបង្កើតឲ្យបានមុនពេលអន្តគមន៍ការអភិវឌ្ឍន៍ ហើយក្នុងចំណោមទាំងនោះ គួរតែមានព័ត៌មាន ដូចខាងក្រោម ៖

- គោលបំណង និង តម្រូវការសេចក្តីថ្លែង (រួមទាំងទិដ្ឋភាពនានា ដូចជាការជម្រុញការអនុវត្តការគ្រប់គ្រងបរិស្ថានសង្គមដែលមានមូលដ្ឋានត្រឹមត្រូវ សម្រាប់រយៈកាលនៃគម្រោងដែលបានស្នើ) ការផ្តល់គោលការណ៍អនុវត្ត ដើម្បីជួយសម្រួល និង គ្រប់គ្រងការផ្លាស់ប្តូរផ្នែកសង្គម (ការដោះស្រាយលើទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាន ដែលកើតចេញពីការអភិវឌ្ឍស្នើឡើង) និងការធ្វើឲ្យសម្រេចគោលដៅ និងគោលបំណង។
- ទស្សនវិជ្ជា និងគោលការណ៍ជាមូលដ្ឋាន ។
- រៀបចំរចនាសម្ពន្ធ និងការទទួលខុសត្រូវ រួមទាំងធម្មោបាយនៃការប្រាស្រ័យទាក់ទង និងនីតិវិធីនៃបណ្តឹងតវ៉ា (សារទុក្ខ)។
- និតិវិធីនៃគណនេយ្យភាព ការទទួលខុសត្រូវ និងការធ្វើរបាយការណ៍។
- កម្មវិធីអភិវឌ្ឍន៍ និងការអនុវត្តគម្រោង (ដោយមានកម្មវិធីអនុវត្ត និងថវិកាចំណាយ)។
- ការគ្រប់គ្រងចំណាត់ការ (ក្នុងមួយកម្មវិធី និងក្នុងមួយគម្រោង)។
- ការកំណត់ឲ្យឃើញច្បាស់ពីសូចនាករលើការអនុវត្តការងារ តបនឹងគោលបំណងដែលអាចធ្វើការវាស់វែងបាន។
- ការកំណត់ឲ្យឃើញច្បាស់ពីនីតិវិធីនៃការត្រួតពិនិត្យ និងការវាយតម្លៃ ដើម្បីវាស់ស្ទង់ការអនុវត្តបរិស្ថានសង្គម និងដើម្បីអនុវត្តចំណាត់ការបង្ការ ប្រសិនបើចាំបាច់។

៥.៥.៦.៣ ការវាយតំលៃផលប៉ះពាល់ដោយប្រយោល និងផលប៉ះពាល់ដែលចេះបន្តកើតមាន

ការវាយតម្លៃផលប៉ះពាល់ដោយប្រយោល និង ផលប៉ះពាល់ដែលចេះតែបន្តែមកើតមាន ត្រូវធ្វើឡើងដោយអនុវត្តតាមគំរូបង្កពាល់ផលប៉ះពាល់ ដែលបង្កើតជាមធ្យោបាយដែល “ធនធាននៃគុណតម្លៃ” (នៅក្នុងករណីនេះ ជាទូទៅសំដៅទៅលើសង្គម និង សង្គមសេដ្ឋកិច្ច) ដែលត្រូវរងផលប៉ះពាល់ដោយប្រភពផលប៉ះពាល់ចម្រុះ ។ ការវាយតម្លៃនេះ ប្រើវិធីសាស្ត្រលក្ខណៈជាប្រព័ន្ធ នៅពេលកំណត់ដោយច្បាស់លាស់នូវផលប៉ះពាល់ដែលចេះតែបន្តែមកើតមាន និងទំនាក់ទំនងនៃផលប៉ះពាល់។ និន្នាការដែលជាលទ្ធផល ត្រូវបានវាយតម្លៃទៅលើគោលបំណង និងសូចនាករដែលបានកំណត់ (ការត្រួតពិនិត្យ)។ ជាធម្មតា ការវាយតម្លៃលើផលប៉ះពាល់បែបនេះ ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃបទដ្ឋានទូលំទូលាយជាយុទ្ធសាស្ត្រ (នៅក្នុងកម្រិតជាតិ ខេត្ត ស្រុក ឬ កម្រិតមូលដ្ឋាន)។ វិធានការនៃការកាត់បន្ថយត្រូវបានស្នើឡើង សម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលចេះតែបន្តែមកើតមាន ដែលត្រូវបានកំណត់ឲ្យឃើញច្បាស់ ហើយនឹងអនុសាសន៍ដែលបានធ្វើឡើងដើម្បីលើកកម្ពស់គុណតម្លៃនៃធនធាន។ ដើម្បីធ្វើឲ្យស្របតាមគោលការណ៍នៃការគ្រប់គ្រងបរិស្ថានចម្រុះ សំខាន់គឺម្រូវឲ្យមានការចូលរួមពាក់ព័ន្ធសមស្របណាមួយរបស់ដៃគូដែលមានចំណាប់អារម្មណ៍ និងភាគីពាក់ព័ន្ធនានា។

ដំណើរការនៃការវាយតម្លៃប៉ះពាល់ដល់ដែលចេះតែបន្តកើតមាន គឺជាដំណើរការសារឡើងវិញមួយ និង ជាគោលការណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្នជាមុន គួរតែអនុវត្តឲ្យសមស្របតាមការទទួលស្គាល់ចំពោះកម្រិតចំណេះដឹងចុងក្រោយបង្អស់ប្បន្នអំពីផលវិបាកនៃការសម្រេចចិត្ត ឬ ចំណាត់ការ។

ជាពិសេស ធាតុដូចគ្នាដែលមានលំនាំដូចការវាយតម្លៃហេតុប៉ះពាល់សង្គម ដែលកំណត់លក្ខណៈនៃការវាយតម្លៃលើផលប៉ះពាល់ប្រយោល និងដែលចេះតែបន្តកើតមាន មានដូចជា ការពាក់ព័ន្ធ/ការចូល

រួមជាសាធារណៈ ការផ្តល់ព័ត៌មាន ការកំណត់ពីវិសាលភាព ការព្យាករផលប៉ះពាល់រំពឹងទុក និងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើជម្រើសដែលអាចជំនួសបាន ស្ថិតក្រោមការពិចារណាត្រឹមត្រូវ។

ប្រអប់អត្ថបទ៤.១៦ គម្រោងទំនប់វារីអគ្គិសនី Tuyen Quang និងគម្រោងបង្ការទឹកជំនន់នៅប្រទេសវៀតណាម
គម្រោងទំនប់វារីអគ្គិសនី Tuyen Quang និងគម្រោងបង្ការទឹកជំនន់ នៅប្រទេសវៀតណាម ដើរតួនាទីជា ឧទាហរណ៍ដ៏មានអត្ថប្រយោជន៍មួយនៃការវាយតម្លៃផលប៉ះពាល់ដោយប្រយោល និង ចេះតែបន្ថែមកើតមាន។ សំនុំឯកសារគម្រោង បានស្នើថាការសាងសង់ទំនប់រួចរាល់ និងការជន់លិចអាងស្តុកទឹក នឹងអាចបំលាស់ប្តូរយ៉ាងខ្លាំងទៅលើភាពទៀងទាត់នៃទឹក និងដី ដែលប្រើប្រាស់នៅក្នុងស្រុក Na Hang។ ទំនប់វារីអគ្គិសនីនេះ ត្រូវបានប៉ាន់ស្មានថានឹងមានទឹកពេញក្នុងរយៈពេលមួយឆ្នាំ ។ បន្ទាប់មកអាងស្តុកទឹកនឹងមានស្ថិរភាពរហូតដល់ពីរទៅបីឆ្នាំ ដូចការប្រែប្រួលនៃល័ក្ខខ័ណ្ឌ និង ផលដំណាំដែលជន់លិចត្រូវខូចខាត។ ក្នុងរយៈពេលពី៥ទៅ១០ឆ្នាំ ប្រហែលជាមានផលប៉ះពាល់ដល់លក្ខខ័ណ្ឌសមស្រប សម្រាប់ការអភិវឌ្ឍសកម្មភាពទាក់ទងនឹងទេសចរណ៍ពឹងផ្អែកលើទឹក និង ជលផល (ថ្វីបើមិនមានផែនការណាមួយត្រូវបានបង្កើតឡើងសម្រាប់ការអភិវឌ្ឍន៍នេះក្តី) ។ យ៉ាងណាក៏ដោយ ទាំងការអភិវឌ្ឍវិស័យទេសចរណ៍ និងវិស័យជលផលត្រូវបានរំពឹងទុកជាមុនថា អាចជាផលប៉ះពាល់ជាវិជ្ជមានយូរអង្វែងទៅលើសង្គមសេដ្ឋកិច្ច ដែលកើតចេញពីទំនប់វារីអគ្គិសនី ។ សំខាន់ដូចគ្នានេះដែរ ការព្យាករណ៍ត្រូវបានកំណត់ថានឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានណាមួយដែលអាចកើតមានលើធម្មជាតិប្រយោល ដែលកើតឡើងដោយសារគម្រោងដែលបានស្នើ។

៤.៤.៧ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីឲ្យស្របតាមច្បាប់ **ការពិនិត្យតាមដាន**អាចប្រើបានសម្រាប់កំណត់ឲ្យបានច្បាស់លាស់ពីភាពខុសគ្នាដោយអន្លើរវាងផលប៉ះពាល់ដែលបានរំពឹងទុក និងផលប៉ះពាល់ដែលកើតមានជាក់ស្តែងពីគម្រោង (Taylor *et al*., 1995) ដោយហេតុនេះ ការរៀបចំកែសម្រួលអាចជាការចាំបាច់ សម្រាប់ការគ្រប់គ្រងការប្រែប្រួល ឬការផ្លាប់ប្តូរដែលកំពុងត្រូវបានបានអនុវត្តដោយឯកឯង ដើម្បីជួយការកាត់បន្ថយផលប៉ះពាល់ដែលមិនបានគិតទុកជាមុន និងដែលមិនចង់បាន ឬអាចជាការបង្កើនផលប្រយោជន៍នានា។ ដូច្នេះ ការពិនិត្យតាមដាន គឺជាការផ្តល់ព័ត៌មានមួយដល់គម្រោង ។

កម្មវិធីពិនិត្យតាមដាន ត្រូវបានផ្តួចផ្តើមដ៏ល្អបំផុតនៅក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់សង្គមកាន់តែឆាប់កាន់តែល្អ ហើយត្រូវបន្តធ្វើពេញមួយរយៈពេលនៃការប្រែប្រួល ដើម្បីវាយតម្លៃប្រសិទ្ធិភាពនៃវិធានការបន្ធូរបន្ថយ និងដើម្បីផ្តល់យោបល់ត្រឡប់វិញពីនិន្នាការ ផលប៉ះពាល់ និងបញ្ហានាពេលបច្ចុប្បន្ន សំដៅកែប្រែផែនការគ្រប់គ្រងសង្គមម្តី តាមការចាំបាច់ (Taylor *et al*. , 1995) ។ នេះគឺជាសារៈសំខាន់ យ៉ាងពិសេស នៅពេលដែលពិនិត្យតាមដានលទ្ធផលនៃការផ្តល់ជូនធ្វើឡើង ដើម្បីរៀបចំសម្រាប់សេចក្តីត្រូវការរបស់ក្រុមងាយរងគ្រោះ។

Taylor *et al*., (1995) កត់ចំណាំជាញឹកញាប់ថា ការពិពណ៌នា និងការគ្រប់គ្រងនៃការប្រែប្រួលផ្នែកសង្គម និងការវាយតម្លៃលើសារៈសំខាន់របស់វា គឺជាបញ្ហាផ្នែកវិធីសាស្ត្រនៅក្នុងការត្រួតពិនិត្យ និងជាការលំបាកណាស់ ដើម្បីធ្វើឲ្យមានភាពខុសគ្នា ក្នុងចំណោមប្រភពជាច្រើន នៃការប្រែប្រួលជាក់លាក់ផ្នែកសង្គម ។ ដូច្នេះ ការត្រួតពិនិត្យតម្រូវការឲ្យមានការបង្កើតលក្ខណៈវិនិច្ឆ័យមួយចំនួន ដើម្បីផ្តោតលើកិច្ច

ខិតខំប្រឹងប្រែងនៅជុំវិញរូបមន្តគន្លឹះ និងដើម្បីផ្តោតលើបញ្ហាគន្លឹះនានា ។ លក្ខណៈវិនិច្ឆ័យលើរូបមន្តគន្លឹះ និងបញ្ហាគន្លឹះទាំងនេះ គួរតែចេញពីប្រភពទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលនៃការកំណត់ឲ្យមានជាទម្រង់ និងការកំណត់ពីវិសាលភាព។

ដូច្នេះ ប្រព័ន្ធត្រួតពិនិត្យ (ការប្រមូលទិន្នន័យ ការរក្សាទុក និងការវិភាគ) ត្រូវតែស្របនឹងអ្វីដែលបានបង្កើតឡើងរួចទៅហើយក្នុងអំឡុងនៃការកំណត់ឲ្យមានជាទម្រង់ និងការកំណត់ពីវិសាលភាព ហើយត្រូវតែរចនាឡើងផងដែរ នៅក្នុងមធ្យោបាយបែបនេះ ដើម្បីជួយសម្រួលដល់ការធ្វើរបាយការណ៍ធម្មតា និងឆាប់រហ័ស ដើម្បីឲ្យការផ្លាស់ប្តូរអាចមានប្រសិទ្ធភាពឆាប់រហ័ស មុនពេលមានការបង្កការខូចខាតធ្ងន់ធ្ងរ ឬ មិនអាចជំនួយបាន ឬ ដើម្បីបង្កើនប្រសិទ្ធភាពអត្ថប្រយោជន៍។

ជាថ្មីម្តងទៀត វាជាការចាំបាច់សម្រាប់ភ្ជាប់កម្មវិធីការត្រួតពិនិត្យជាមួយនឹងការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ ក្នុងគោលបំណងធ្វើឲ្យប្រាកដថា បញ្ហាគន្លឹះនានាត្រូវបានត្រួតពិនិត្តតាមដាន និងដោះ-ស្រាយ។

ការតាមដាននេះគឺជាសមាសភាគដ៏សំខាន់មួយនៃ**ការវាយតម្លៃ**របស់គម្រោង។ ទោះជាយ៉ាងណានៅក្នុងបរិបទនេះ ការវាយតម្លៃ គឺជាការសរុបសេចក្តី ត្រង់ចំណុចឆ្ពោះទៅរកទីបញ្ចប់/សេចក្តីសន្និដ្ឋាននៃដំណើរការគម្រោង ជាមួយនឹងទស្សនៈក្នុងការជូនដំណឹងព័ត៌មានដល់គម្រោងផ្សេងៗទៀត (ជាជាងការវាយតម្លៃលើគម្រោងដែលកំពុងចាប់ដំណើរការ)។ ក្នុងន័យនេះ ការវាយតម្លៃត្រូវបានគេមើលឃើញថាជាផ្នែកមួយចុងក្រោយនៃដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គម តែយ៉ាងណាក៏ដោយក៏វាមិនត្រូវបានអនុវត្តតែនៅក្នុងការសន្និដ្ឋានចុងក្រោយនៃគម្រោងនោះឡើយ ។ លើសពីនេះទៀត វាត្រូវបានគេមើលឃើញថាមានលក្ខណៈដាច់ដោយឡែកពីការត្រួតពិនិត្យ និង ការគ្រប់គ្រងផលប៉ះពាល់សង្គម បើទោះបីជាវាមានលក្ខណៈគួរឲ្យកោតសរសើរក៏ដោយ (Taylor *et al*., 1995)។

ប្រភព Carsey and Kumar (1987) បានកំណត់ការវាយតម្លៃថាជា *ការវាយតម្លៃទៅតាមរយៈពេលនៃការពាក់ព័ន្ធការអនុវត្តការងារ ប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោង ក្នុងបរិបទនៃគោលបំណងរបស់ខ្លួនដែលបានបញ្ជាក់។* ដើម្បីសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវធ្វើមានការប្រើប្រាស់ទិន្នន័យត្រួតពិនិត្យ ប៉ុន្តែក៏អាចតម្រូវឱ្យមានការប្រមូលទិន្នន័យបន្ថែម និង អាចពាក់ព័ន្ធជាមួយការប្រៀបធៀបជាមួយនឹងគម្រោងផ្សេងទៀត ដែលមានលក្ខណៈ ស្រដៀងគ្នានេះដែរ (Taylor *et al*., 1995)។ ក្នុងករណីនេះ Casley និង Kumar (1987) ជឿថា ការវាយតម្លៃគួរធ្វើឡើងឲ្យបាន៣ដងក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ៖

- លើកទីមួយ នៅក្នុងពាក់កណ្តាលនៃការអនុវត្តគម្រោង ប៉ុន្តែស្របពេលដែលចាប់ផ្តើមកើតមានផលប៉ះពាល់សង្គម។
- លើកទីពីរ នៅចុងបញ្ចប់នៃការអនុវត្តគម្រោង។
- លើកចុងក្រោយ នៅពេលក្នុងពេលវេលាសមស្របមួយនៃការសន្និដ្ឋានចុងក្រោយនៃគម្រោងក្នុងគោលបំណងដើម្បីកំណត់ឲ្យបានច្បាស់ពីផលប៉ះពាល់រយៈពេលវែង។

លើសពីនេះទៀត ដើម្បីត្រួតពិនិត្យការប្រែប្រួលផ្នែកសង្គម ដែលជាលទ្ធផលនៃគម្រោង (ទាំងដោយផ្ទាល់ និងដោយប្រយោល) វាអាចបញ្ជាក់ឲ្យឃើញពីអត្ថប្រយោជន៍ដើម្បីអនុវត្ត**ការធ្វើសវនកម្ម**ផ្នែកខាងក្រៅ និងឯករាជ្យ លើដំណើរការ និងលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់សង្គម។ ក្រៅពីផ្តល់នូវ

ទស្សនវិស័យខាងក្រៅទាំងស្រុង ការធ្វើសវនកម្មមួយ ក៏អាចបង្ហាញយ៉ាងច្បាស់ផងដែរ អំពីតួនាទីរបស់ តួអង្គពាក់ព័ន្ធទាំងអស់ ត្រង់ថាសកម្មភាពរបស់គម្រោងមានលក្ខណៈតម្លាភាព និងបើកចំហទាំងស្រុងឱ្យមានការពិនិត្យពិច័យច្បាស់លាស់។

សម្រាប់ផ្នែកជាច្រើនបំផុត ការត្រួតពិនិត្យ និងការវាយតម្លៃ មានលក្ខណៈលំអៀងទៅរកការផ្តោតលើការគ្រប់គ្រងការប្រែប្រួលផ្នែកសង្គម និង ផែនការគ្រប់គ្រងសង្គមរៀងខ្លួន ដើម្បីកាត់បន្ថយ និង/ឬ លើកកម្ពស់ការផ្លាស់ប្តូរទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ គួរតែត្រូវគិតគូរផងដែរថា ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់សង្គម គួរតែត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ សំដៅផ្តល់ជាព័ត៌មានសម្រាប់ការងារនាពេលអនាគត ក៏ដូចជាដើម្បីធ្វើឲ្យទស្សនៈ និងវិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់សង្គម សម្រាប់គម្រោងថ្មីបានជឿនលឿនទៅមុខ (Taylor *et al*., 1995) ។

ប្រអប់អត្ថបទ៤.១៧ គម្រោង Brilliant Expansion នៅប្រទេសកាណាដា

គម្រោង Brilliant Expansion នៅប្រទេសកាណាដា ដើរតួនាទីជាឧទាហរណ៍ដ៏មានអត្ថប្រយោជន៍មួយនៃការត្រួតពិនិត្យ។ ដើម្បីតាមដាន និងរាយការណ៍លើផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច ក៏ដូចជាផលប្រយោជន៍ដែលផ្សារភ្ជាប់ជាមួយការពង្រីកសមត្ថភាពផលិតនៃទំនប់វារីអគ្គិសនី Brilliant Expansion នេះ និងដើម្បីកំណត់ឲ្យបានច្បាស់លើគម្លាតនៃលទ្ធផលរំពឹងទុកជាមុន ទើបក្រុមហ៊ុនសាជីវកម្មថាមពលកូឡុំប៊ី (Columbia Power Corporation) បានជួលក្រុមហ៊ុនដែលបានចុះកិច្ចសន្យាមួយដែលឯករាជ្យជាភាគីទីបី ឲ្យដើរតួនាទីជាអ្នកត្រួតពិនិត្យសង្គមសេដ្ឋកិច្ចសម្រាប់គម្រោងនេះ។ អ្នកត្រួតពិនិត្យសង្គមសេដ្ឋកិច្ច មានភារកិច្ចត្រួតពិនិត្យ និង រាយការណ៍ដោយមិនលំអៀងទៅលើផលប៉ះពាល់ និងផលប្រយោជន៍ដែលបានកើតឡើងពីលទ្ធផលនៃការពង្រីកគម្រោង ។ តាមរយៈការសង្កេតយ៉ាងហ្មត់ចត់លើរូបមន្តជាច្រើននៃសង្គម សេដ្ឋកិច្ច អ្នកត្រួតពិនិត្យសង្គមសេដ្ឋកិច្ច អាចវាស់វែងផលប៉ះពាល់ទៅលើសហគមន៍មូលដ្ឋាន និងទៅលើតំបន់ បណ្តាលមកពីការពង្រីកគម្រោង (ពោលគឺក្នុងរយៈចំងាយ ១០០គីឡូម៉ែត្រ រងប្រតិបត្តិការដោយសារតំបន់គម្រោង) ។ អ្នកត្រួតពិនិត្យសង្គមសេដ្ឋកិច្ច បានប្រើប្រាស់សូចនាករផ្សេងៗ ដើម្បីថ្លឹងថ្លែងលើផល-ប្រយោជន៍ និងផលប៉ះពាល់នៃគម្រោង។ ទិដ្ឋភាពដែលត្រូវបានពិនិត្យឃើញនៅក្នុងលក្ខខ័ណ្ឌនៃការងារ និងការចំណាយមានរួមបញ្ចូលទាំងចំនួននៃការជួលនៅក្នុងស្រុក ពាណិជ្ជកម្ម កម្មករជាស្ត្រី កម្មករជាតិតាមជាតិនីមួយៗ និងតាមក្រុមនីមួយៗ និងកម្មករ ជាជនពិការ ចំនួនកូនជាង អាត្រាការងារបានពីគម្រោង រហូតដល់កម្លាំងពលកម្មក្នុងតំបន់ ការចំណាយផ្ទាល់ខ្លួន និងការចំណាយធ្វើឡើងដោយសហគមន៍ និងចំនួននៃក្រុមហ៊ុនក្នុងស្រុក ដែលបានទទួលផលប្រយោជន៍ពីគម្រោង។

ប្រអប់អត្ថបទ៤.១៨ ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់សង្គម-ទិដ្ឋភាពគន្លឹះ

ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់សង្គម គឺជាដំណើរការមួយ។ធាតុសំខាន់ៗដែលបានកំណត់ចរិកលក្ខណៈនៃការវាយតម្លៃហេតុប៉ះពាល់សង្គម និងដែលនាំទៅដល់ការអនុវត្តភារកិច្ច (ក្នុងការផ្លាស់ប្តូរនៃកម្រិតអាំងតង់ស៊ីតេ ដែលជាញឹកញាប់តម្រូវតាមទំហំ និង/ឬភាពស្មុគស្មាញនៃគម្រោង និងបរិស្ថានសង្គមដែលទទួលបាន) គឺមានដូចខាងក្រោម ៖

- ការពាក់ព័ន្ធ/ការចូលរួមជាសាធារណៈ ។
- កំណត់ឲ្យបានច្បាស់លាស់ និងការពិចារណាលើជម្រើសដែលអាចជំនួសបាន។

- ការកំណត់ឲ្យមានជាទម្រង់លក្ខខ័ណ្ឌជាមូលដ្ឋាន។
- ការកំណត់ឲ្យមានជាទម្រង់។
- ការព្យាករពីផលប៉ះពាល់ដែលបានប៉ាន់ស្មានទុក។

-ការព្យាករនិងការវាយតម្លៃលើការឆ្លើយតបចំពោះផលប៉ះពាល់នានា។

-ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព។

-ការវាយតម្លៃផលប៉ះពាល់ដោយប្រយោល និងផលប៉ះពាល់ដែលចេះតែបន្តមកើតមាន។

- ការតាមដាន ការត្រួពិនិត្យ និងការវាយតម្លៃ។

មានឧទាហរណ៍ជាច្រើនបានមកពីទំនប់វារីអគ្គិសនីធំៗ និងគម្រោងវារីអគ្គិសនីនៅជុំវិញពិភពលោក ដែលបង្ហាញពន្យល់ថា ត្រូវតែតម្រូវឲ្យមានតាមដែលអាចធ្វើទៅបាន នៅក្នុងកំឡុងពេលនៃការវាយតម្លៃហេតុប៉ពាល់សង្គម និងតាមប្រភេទលទ្ធផលដែលអាចទទួលបាន។

ប្រធានបទពិភាក្សា	ពិភាក្សាអំពីហេតុអ្វីបានជាចាំបាច់ត្រូវពិចារណាអំពីជម្រើស ដែលអាចជំនួសបាន និងផលប្រយោជន៍ ដែលបន្ថែមលើការបញ្ចៀស និង កាត់បន្ថយផលប៉ះពាល់ និងការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព។ ..... ក្រៅពីជម្រើសដែលអាចជំនួសបាននៅក្នុងមូលដ្ឋាន ចូរពិភាក្សាលើប្រភេទជម្រើសដទៃទៀត ដែលអាចត្រូវបានចាត់ទុកថាជាជម្រើសក្នុងការបញ្ចៀស និង/ឬកាត់បន្ថយផលប៉ះពាល់លើបរិស្ថានសង្គម។ ..... ការកំណត់ពីវិសាលភាព ត្រូវបានប្រើប្រាស់ ដើម្បីកំណត់ព្រំដែនរូបសាស្ត្រនៃគម្រោងមួយ។ ចូរពិភាក្សាអំពីវិធីដែលអាចអនុវត្តបានក្នុងរង្វង់បរិបទការអភិវឌ្ឍដែលគម្រោងមួយនឹងត្រូវទទួលខុសត្រូវ ចំពោះការកាត់បន្ថយផលប៉ះពាល់សង្គម ឧទាហរណ៍តាមរយៈការអនុវត្តផែនការសកម្មភាពស្តីពីការតាំងលំនៅថ្មី និងការប្រើប្រាស់ផលប្រយោជន៍ឲ្យអស់ពីលទ្ធភាព ឧទាហរណ៍ការអនុវត្តន៍ផែនការអភិវឌ្ឍន៍សង្គម។
លំហាត់	ចូរបង្កើតឧទាហរណ៍មួយពីប្រទេសរបស់អ្នក ធ្វើការវាយតម្លៃយុតញ្ញធសាស្ត្រ និង វិធីសាស្ត្រ ដែលបានអនុវត្តក្នុងអំឡុងពេលនៃការវាយតម្លៃហេតុប៉ះពាល់សង្គម និងចូរផ្តល់មតិស្តីពីទិដ្ឋភាពល្អៗ និងដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់។ ..... តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ចូរផ្តល់នូវការវាយតម្លៃមួយលើឧបករណ៍ដែលបានបង្ហាញថាមានប្រយោជន៍ ក្នុងកំឡុងពេលនៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់សង្គម។ .....

	ចូរបញ្ជាក់ឲ្យបានក្បោះក្បាយពីបច្ចេកទេសជាច្រើន នៃការវាយតម្លៃដោយមានការចូលរួម ដែលអាចប្រើប្រាស់ក្នុងអំឡុងពេលនៃការវាយតម្លៃហេតុប៉ះពាល់សង្គម។ ..... ចូរបង្កើតការត្រួតពិនិត្យតាមប្រភេទសាមញ្ញមួយ និងធ្វើការពន្យល់ពីបទដ្ឋាននៃការវាយតម្លៃ ដែលរូបមន្តនៃការវាយតម្លៃនោះ ត្រូវធ្វើការវាសើវែង និងជារូបមន្តដែលនឹងត្រូវបង្ហាញ។

៥. ការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត

៥.១- សេចក្តីផ្តើម និងបទដ្ឋានជានិយាយ

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្តនិងការគ្រប់គ្រងបទដ្ឋានជានិយាម។
ទិសដៅ	ដើម្បីឲ្យសិក្ខាកាមយល់ពីអ្វី ដែលបង្កើតឲ្យមានការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្ត និងទិដ្ឋភាពគន្លឹះនៃបទដ្ឋានជានិយាម។
ការអានតាមលំដាប់លំដោយ	ធនាគារអភិវឌ្ឍន៍អាស៊ី (១៩៩៨)។ សេចក្តីសង្ខេបនៃកូនសៀវភៅស្តីពីការតាំងទីលំនៅថ្មី ។ គោលការណ៍ណែនាំស្តីពីការអនុវត្តល្អ ។ ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ..... ក្រុមហ៊ុនហិរញ្ញវត្ថុអន្តរជាតិ IFC (2002). កូនសៀវភៅស្តីការការរៀបចំផែនការសកម្មភាណស្តីពីការតាំងទីលំនៅថ្មី។ IFC ៖ នាយកដ្ឋានអភិវឌ្ឍបរិស្ថាន និងសង្គម។ ក្រុមធានាគារពិភពលោក ទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក។ ..... IFC គំរូស្តង់ដារអនុវត្តនិរន្តរភាពបរិស្ថាន និងសង្គម (ខែមករា ឆ្នាំ២០១២)៖ គំរូស្តង់ដារទី៥ ៖ ការធ្វើសម្បទានបានដី និងការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org) ..... IFC-គោលនយោបាយ និងគំរូបទដ្ឋានស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន (២០០៦) ៖ គំរូស្តង់ដារទី៥ ៖ ការធ្វើសម្បទានបានដី និងការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org) .....

	IFC- កំណត់ចំណាំការណែនាំ ៖ គំរូបទដ្ឋានស្តីពីនិរន្តរភាពសង្គម និង បរិស្ថាន (២០០៧) ៖ កំណត់ចំណាំការណែនាំទី៥ ៖ ការធ្វើសម្បទានដី និងការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)

ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ និង ផ្តល់ជំនួយ រិតតែប្រឹងប្រែងក្នុងការផ្តល់ហិរញ្ញវត្ថុសម្រាប់គម្រោង ដែលមានមូលដ្ឋានត្រឹមត្រូវ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ។ ផលប៉ះពាល់ដែលអាចកើតមានដ៏ធំបំផុតតែមួយគត់ និងសំខាន់បំផុតដែលកើតចេញពីគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាទំនប់វារីអគ្គិសនី និងសំណង់អគារវារីអគ្គិសនី គឺការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។

ការតាំងទីលំនៅជាថ្មី ដែលមិនមែនជាការស្ម័គ្រចិត្ត នៅពេលដែលប្រជាពលរដ្ឋរងផលប៉ះពាល់មានសិទ្ធិបដិសេធចំពោះការធ្វើសម្បទានដី ដែលជាលទ្ធផលនៃការផ្លាស់ទីលំនៅថ្មី។ ជាទូទៅការផ្លាស់ទីលំនៅថ្មី ត្រូវធ្វើឡើងតាមរយៈការចចាររវាងអ្នកស្នើគម្រោង រដ្ឋាភិបាល និងប្រជាពលរដ្ឋរងផលប៉ះពាល់ (និងមិនហ៊ុមព័ទ្ធការរុះរើលំនៅដ្ឋានដោយការបង្ខិតបង្ខំ)។

ការទទួលបានដីធ្លីតាមរយៈគម្រោង ដែលជាប់ពាក់ព័ន្ធនឹងការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្តជារូបវន្ត (ការបាត់បង់ជម្រក ទ្រព្យសម្បត្តិផ្ទះកំណើត និងការតាំងលំនៅដ្ឋានថ្មី) និង/ឬ ផ្នែកសេដ្ឋកិច្ច (ការបាត់បង់សម្បត្តិសេដ្ឋកិច្ច ឬ ការទទួលបានសម្បត្តិសេដ្ឋកិច្ច ដែលនាំទៅដល់ការបាត់បង់ប្រភពចំណូល ឬមធ្យោបាយនៃការប្រកបរបរចិញ្ចឹមជីវិត) ការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋ បង្ហាញឲ្យឃើញពីបញ្ហាប្រឈមដែលមានសារៈសំខាន់ ដែលប្រសិនបើគ្មានការរៀបចំផែនការ និង ការគ្រប់គ្រងត្រឹមត្រូវទេនោះ អាចបង្កឲ្យមានការលំបាករយៈពេលយូរសម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងការបំផ្លេចបំផ្លាញបរិស្ថាននៅក្នុងទីតាំងដែលពួកគេតាំងលំនៅដ្ឋាន ។ ជាការពិត ប្រវត្តិនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាទំនប់វារីអគ្គិសនី និងសំណង់អគារវារីអគ្គិសនី បង្ហាញឲ្យឃើញពីការបន្សល់ទុកភាពអវិជ្ជមានជាច្រើន នៅទីកន្លែងដែលប្រជាពលរដ្ឋ ដែលបានផ្លាស់ទីដោយសារគម្រោង បន្តប្រឈមនឹងការលំបាកក្នុងការស្តារជីវភាពរស់នៅរបស់ខ្លួន។ បញ្ហានេះត្រូវបានទទួលស្គាល់ និងនាំទៅរកលទ្ធផល និង បន្តតាមដានដោយ គណៈកម្មការទំនប់វារីអគ្គិសនីពិភពលោក ដែលមានបង្ហាញនៅក្នុង(ផ្នែកទី៣)នៃសៀវភៅបណ្តុះបណ្តាលនេះ។

ទោះជាយ៉ាងណាក៏ដោយ តាមរយៈការរៀបចំផែនការសម្រាប់ការតាំងទីលំនៅថ្មីប្រកបដោយលក្ខណៈសមស្រប អ្នកធ្វើសំណើគម្រោងលើកកម្ពស់ផលប៉ះពាល់នៃការអភិវឌ្ឍន៍ ដោយការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាឡបរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង។ ការវិនិយោគផ្នែកសេដ្ឋកិច្ច និងសង្គមនៅក្នុងមូលដ្ឋាន ដើរតួនាទីប្រៀបដូចជាអ្នកធ្វើសំណើគម្រោង ដែលមានសុឆន្ទៈក្នុងការធ្វើឲ្យល្អប្រសើរយ៉ាងទូលំទូលាយដល់សហគមន៍ដែលជាទីតាំងគម្រោង និង ធ្វើឲ្យល្អប្រសើរដល់កិត្តិសព្ទរបស់ក្រុមហ៊ុននៅក្នុងប្រទេស និងលើឆាកអន្តរជាតិ។

អ្នកធ្វើសំណើគម្រោងគួរបញ្ជៀសឲ្យបាននូវការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្តតាមដែលអាចធ្វើទៅបាន ឬ ដើម្បីកាត់បន្ថយវាតាមរយៈស្វែងរកការរៀបចំគម្រោង និង ទីតាំងគម្រោងដែលអាចជាជម្រើសសម្រាប់ជំនួសបាន ។ នៅទីកន្លែងណាដែលការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្ម័គ្រចិត្តមិនអាចជៀសបាន អ្នកធ្វើសំណើគម្រោងគួរអនុញ្ញាតឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់បានចូលរួមពាក់ព័ន្ធក្នុងការរៀបចំផែនការអនុវត្ត និងតាមដានដំណើរការនៃការតាំងទីលំនៅថ្មី ។ ក្នុងន័យនេះ ការពិចារណាបច្ចុប្បន្នដែលមានលក្ខណៈអន្តរជាតិ គឺការគិតថាការតាំងទីលំនៅថ្មី គួរតែត្រូវបានកំណត់ក្នុងផែនការ និងអនុវត្តក្រោមរូបភាពជាគម្រោងផ្តួចផ្តើមគំនិតលើការអភិវឌ្ឍន៍ដើម្បីធានាឲ្យប្រាកដថា ការចិញ្ចឹមជីវិត និង

កំរិតជីវភាពរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ទទួលបានភាពល្អប្រសើរមុនពេល នៃការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋទាំងនោះ ។ សកម្មភាពនេះមានលក្ខណៈខុសពីការពិចារណាពីមុនដែលមានគោលដៅស្តារជីវភាព ទៅជាកម្រិតដូចគ្នាមុនការអន្តរាគមន៍នៃគម្រោង។

បញ្ហាខាងលើ ត្រូវបានទទួលស្គាល់ជាសកលនៅក្នុងទសវត្សរ៍ទី៨០ បន្ទាប់ពីមានការតវ៉ារបស់មហាជន និងការធ្វើបាតុកម្មទាមទារ (ក្នុងចំណោមសហគមន៍ដែលរងផលប៉ះពាល់ និង អង្គការសង្គមស៊ីវិល) ទាក់ទងនឹងផលប៉ះពាល់ជាអវិជ្ជមាននៃគម្រោងអភិវឌ្ឍទៅលើប្រជាពលរដ្ឋ ដែលរស់នៅតាំងពីដើមនាយក្នុងទីតាំងគម្រោង ដូចជាគ្រួសារកសិករត្រូវបានកាត់បន្ថយឲ្យទៅជាគ្រួសារក្រីក្រ ដោយសារគ្មានដីធ្លី ។ បច្ចុប្បន្នស្ថាប័នផ្តល់ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ បានតម្រូវថាប្រជាពលរដ្ឋ និងសហគមន៍ដែលរងផលប៉ះពាល់ គួរតែត្រូវបានដោះស្រាយឲ្យសមស្របជាងនេះ ហើយបើអាចគួររាប់បញ្ចូលប្រជាពលរដ្ឋ និងសហគមន៍នៃទីតាំងគម្រោងថា ក៏ជាអ្នកទទួលផលរបស់គម្រោងផងដែរ។

ទស្សនទានស្តីពីការថែរក្សាការពារផ្នែកសង្គម បានបង្កើតជាពាក្យថា " ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត " ដែលគ្របដណ្តប់ទាំង (១) ការទូរទាត់សំណង (តាមតម្លៃទីផ្សារ ឬ តាមការចេញថ្លៃជំនួស) សម្រាប់ការសងជំនួសចំពោះទ្រព្យសម្បត្តិទាំងអស់ដែលបាត់បង់ (ដី ផ្ទះ កម្មសិទ្ធិហុចផល) និង (២) ការស្តារ និងកសាងការប្រកបរបរចិញ្ចឹមជីវិតដែលត្រូវបាត់បង់ មូលនិធិវប្បធម៌ និង សង្គម ។ វាក្យស័ព្ទ " ការតាំងទីលំនៅថ្មី " ត្រូវបានប្រើប្រាស់ក្នុងបរិបទនេះមានន័យថា គឺជាអ្វីនាំឲ្យមានការភាន់ច្រឡំ ពីព្រោះការតាំងទីលំនៅថ្មី អាច ឬ មិនអាចតម្រូវឲ្យមានការរើទីកន្លែងជារូបវន្តចំពោះផ្ទះសម្បែង ឬ សហគមន៍ទៅកាន់តំបន់ថ្មីសម្រាប់ការតាំងទីលំនៅថ្មីនោះទេ។

នៅមានបទដ្ឋានជានិយាមជាតិ និង អន្តរជាតិជាច្រើន ដែលមានឥទ្ធិពលលើការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដែលបទដ្ឋានជាច្រើនពឹងផ្អែកលើគោលនយោបាយ និង នីតិវិធីដែលបង្កើតឡើងដោយក្រុមធនាគារពិភពលោក ដែលមានជាឧទាហរណ៍ ដូចតទៅ ៖

- ធនាគារអភិវឌ្ឍន៍អាស៊ី - គោលនយោបាយស្តីពីការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត (www.afdb.org)
- ធនាគារអភិវឌ្ឍន៍អាស៊ី - ការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (www.adb.rog)
- ធនាគារអភិវឌ្ឍន៍អន្តរអាមេរិកកាំង - គោលនយោបាយប្រតិបត្តិការលើការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ទី៧-១០ (www.iadb.org)
- ប្រទេសអ៊ីរ៉ង់ -ច្បាប់ស្តីពីធ្វើសម្បទានដី (www.parstimes.com/law/iran)
- IFC គំរូស្តង់ដារអនុវត្តនិរន្តរភាពបរិស្ថាន និងសង្គម (ខែមករា ឆ្នាំ២០១២) ៖ គំរូស្តង់ដារទី៥ ៖ ការទទួលបានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)
- IFC-គោលនយោបាយ និង គំរូបទដ្ឋានស្តីពីនិរន្តរភាពសង្គម និង បរិស្ថាន (៣០ មេសា ២០០៦) ៖ គំរូស្តង់ដារទី៥ ៖ ការធ្វើសម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)
- IFC-កំណត់ចំណាំការណែនាំ ៖ គំរូបទដ្ឋានស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន (៣១ កក្កដា ឆ្នាំ ២០០៧) ៖ កំណត់ចំណាំការណែនាំទី៥ ៖ ការធ្វើសម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)
- ប្រទេសណេប៉ាល់-ការធ្វើសម្បទានដី ការទូទាត់សំណង និងផែនការស្តារឡើងវិញ (១៩៩៩)

- ច្បាប់ស្តីពីអាជ្ញាធរបរិស្ថាននៃប្រទេសស្វាសីឡែន (១៩៩២) www.ecs.co.sz/leg_sd_files/env_leg_sd_seaact.htm
- ប្រទេសវៀតណាម- សេចក្តីណែនាំស្តីពីការតាំងទីលំនៅថ្មី និង ការស្តារឡើងវិញនៃប្រទេសវៀតណាម (Loc cit-Bladh, U. & Nilsson, E-L. (2005). តើត្រូវរៀបចំផែនការសម្រាប់ការតាំងទីលំនៅថ្មី ដោយរបៀបណា ? ករណីគម្រោងថាមពលវារីអគ្គិសនីស៊ុនឡា ក្នុងប្រទេសវៀតណាម។
- ក្រុមធនាគារពិភពលោក (យោង១០) -គោលការណ៍ប្រតិបត្តិ និងនីតិវិធីធនាគារ ពីចំនុច៤ដល់ ១២-ការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត (www.worldbank.org) (www.ifc.org) និង (www.miga.org)។

(១០) ធនាគារពិភពលោក ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងភ្នាក់ងារធានាការវិនិយោគពហុភាគី។

សារគន្លឹះមួយចំនួននៃបទដ្ឋានជានិយាមទាំងនេះ រួមមានដូចខាងក្រោម ៖

- ដើម្បីបញ្ជៀស ឬ យ៉ាងហោចកាត់បន្តយការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្តនៅទីកន្លែងណាតាមដែលអាចធ្វើទៅបាន តាមរយៈការស្វែងរកគំរូប្លង់គម្រោង ឬ ទីតាំងដែលជាជម្រើសអាចជំនួសបាន។ សំខាន់ត្រូវកត់ចំណាំថា សកម្មភាពនេះត្រូវតែអនុវត្តបានចំពោះអ្នកធ្វើសំណើគម្រោងទាំងអស់ ឧទាហរណ៍សម្រាប់សំណង់អគារវារីអគ្គិសនី ដែលនឹងមានតម្រូវការក្នុងការផ្ទេរហេដ្ឋារចនាសម្ព័ន្ធ (អនុស្ថានីយ៍ និង ខ្សែបណ្តាញអគ្គិសនី) ដែលត្រូវតែយកចិត្តទុកដាក់ជាផ្នែកមួយនៃផលប៉ះពាល់គម្រោងជារួម និង វិធានការកាត់បន្តយ រួមទាំងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។
- ដើម្បីកាត់បន្តយផលប៉ះពាល់មិនល្អទៅលើសង្គម និង សេដ្ឋកិច្ច ដែលកើតចេញពីការធ្វើសម្បទានដី ឬ ការដាក់កំហិតលើការប្រើប្រាស់ដីធ្លីរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ តាមរយៈ ៖
  - ការផ្តល់ជូននូវការទូទាត់សំណងដោយយុត្តិធម៌ និងសមស្រប (ផ្នែកទី៦) សម្រាប់ការបាត់បង់ទ្រពសម្បត្តិទៅតាមតម្លៃនៃការចំណាយក្នុងការជ្លាស់ទីកន្លែង។
  - ដើម្បីធានាឲ្យប្រាកដថា សកម្មភាពនៃការតាំងទីលំនៅថ្មីត្រូវបានអនុវត្តដោយបិតប្រកាសព័ត៌មានសមស្រប ការពិគ្រោះយោបល់ និងផ្តល់ព័ត៌មានឲ្យមានការចូលរួមពីប្រជាពលរដ្ឋរងផលប៉ះពាល់។
  - អង្កេតតាមដាន និងអនុវត្តសំណងលើកទឹកចិត្ត ឬ ទម្រង់នៃផលប្រយោជន៍ដទៃទៀត រួមមានឱកាសនៃការចែករំលែកផលប្រយោជន៍ ប្រសិនជាមានលើគម្រោងជាលំលាក់ណាមួយ (ផ្នែកទី៦)។
- ដើម្បីស្តារឡើងវិញ និងធ្វើឲ្យប្រសើរឡើងនូវការប្រកបរបចិញ្ចឹមជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលជ្លាស់ទី។
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវលក្ខខ័ណ្ឌជីវភាពក្នុងចំណោមប្រជាពលរដ្ឋដែលជ្លាស់ទី តាមរយៈ ការផ្តល់ជូនផ្ទះសម្បែងសមរម្យ រួមនឹងសុវត្ថិភាពនៃការកាន់កាប់ជាកម្មសិទ្ធិ (យោង១១) នៅទីកន្លែងតាំងទីលំនៅថ្មី។

(១១) នៅប្រទេសជាច្រើន ដីត្រូវបានគ្រប់គ្រងកម្មសិទ្ធិដោយរដ្ឋ ដែលប្រជាពលរដ្ឋអាចកាន់កាប់ និងមានសិទ្ធិប្រើប្រាស់ ។ ក្នុង បរិបទនេះ សុវត្ថិភាពនសការកាន់កាប់ត្រូវបានកំណត់ដើម្បីការពារអ្នកដែលធ្វើបំលាស់ទី ពីការជ្លាស់ទីដោយបង្ខំនាពេកអនាគត (ពោលគឺ មិនបានសម្រេចចំពោះសុវត្ថិភាពនៃការកាន់កាប់ តាមរយៈការផ្តល់កម្មសិទ្ធិដីនៅទីកន្លែងដែលគ្មានកម្មសិទ្ធិ)។

ប្រអប់អត្ថបទ: ៥.១ គោលនយោបាយដោយសង្ខេបរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត
គោលបំណងរួមនៃគោលនយោបាយរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត មានដូចខាងក្រោម ៖ (ក). ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ត្រូវតែជៀសវាងប្រសិនបើអាចធ្វើទៅបាន ឬគួរតែកាត់បន្ថយ ដោយការស្វែងរកគំរូប្លង់គម្រោងដែលជាជម្រើសអាចជំនួសបាន។ (ខ). ទីកន្លែងណាដែលការតាំងទីលំនៅថ្មីមិនអាចជៀសផុត សកម្មភាពនៃការតាំងទីលំនៅត្រូវប្រែក្លាយ ឬត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍ តាមរយៈការផ្តល់ធនធានវិនិយោគគ្រប់គ្រាន់ ដើម្បីជម្រុញឲ្យប្រជាពលរដ្ឋដែលផ្លាស់ទីដោយសារគម្រោង អាចចែករំលែកផលប្រយោជន៍ទាក់ទងនឹងគម្រោង ។ អ្នកដែលបានផ្លាស់ទី គួរត្រូវបានពិគ្រោះយោបល់យ៉ាងមានអត្ថន័យ ហើយគួរផ្តល់ឱកាសឲ្យបានចូលរួមក្នុងការរៀបចំផែនការ និង អនុវត្តកម្មវិធីតាំងទីលំនៅថ្មី។ (គ). អ្នកផ្លាស់ទីលំនៅ គួរត្រូវបានជួយជ្រុំជ្រែងក្នុងកិច្ចខិតខំរបស់ខ្លួន ក្នុងការពង្រឹងការចិញ្ចឹមជីវិត ជីវភាពរស់នៅ ឬ យ៉ាងហោចត្រូវស្តារឲ្យបានកម្រិតខ្ពស់ឡើងវិញនូវល័ក្ខខ័ណ្ឌយល់ព្រមជាក់ស្តែងចំពោះកម្រិតមុនការបំលាស់ទីឬកម្រិតមុនចាប់ផ្តើមអនុវត្តគម្រោង។ គោលនយោបាយនេះ គ្របដណ្តប់លើប៉ះពាល់ដោយផ្ទាល់លើសេដ្ឋកិច្ច និងសង្គម ដែលជាលទ្ធផលបានពីគម្រោងក្រោមជំនួយនៃធនាគារ និងបង្កឡើងដោយ ៖ • ការទទួលយកដីធ្លីមិនមែនជាការស្ម័គ្រចិត្ត អាចហុចផលជា ៖ ◦ ការផ្លាស់ទីលំនៅ ឬ ការបាត់បង់ជម្រក ការបាត់បង់ទ្រព្យសម្បត្តិ ឬ ការទទួលបាទ្រព្យសម្បត្តិ ឬ ◦ ការបាត់បង់ប្រភពចំណូល ឬ មធ្យោបាយនៃការប្រកបរបរទទួលទាន ចង់មិនចង់ប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវតែសម្រេចចិត្តរុះរើលំនៅដ្ឋានទៅកាន់ទីកន្លែងផ្សេង។ • ការដាក់កំហិតនៃការទទួលបានដែលមិនមែនជាការស្ម័គ្រចិត្ត ចំពោះសួនឧស្សានសាធារណៈដែលកំណត់ដោយច្បាប់ និងតំបន់ការពារ ដែលជាលទ្ធផលបានពីផលប៉ះពាល់មិនល្អលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលបានផ្លាស់ទី។

ប្រអប់អត្ថបទ: ៥.២ សេចក្តីផ្តើម និងបទដ្ឋានជានិយាម-ទិដ្ឋភាពគន្លឹះ
• ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត លេចចេញតាមរយៈការទទួលបានដីសម្រាប់គម្រោងមួយ (រួមមានអ្នកធ្វើសំណើគម្រោងទាំងអស់) នៅទីកន្លែងដែលប្រជាពលរដ្ឋរងផលប៉ះពាល់មិនអាចជំទាស់នឹងការត្រូវតែផ្លាស់ទីពីដីដែលពួកគេកាន់កាប់ ឬ ប្រើប្រាស់។ • ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត គ្របដណ្តប់លើការផ្លាស់ទីជារូបវន្ត និងសេដ្ឋកិច្ច។ • នៅមានបទដ្ឋានជានិយាមជាតិ និងអន្តរជាតិជាច្រើនដែលមានឥទ្ធិពលលើការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដែលបទដ្ឋានជាច្រើនពឹងផ្អែកលើគោលនយោបាយ និងនីតិវិធីដែលបង្កើតឡើងដោយក្រុមធនាគារពិភពលោក។

- ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត គួរត្រូវតែជៀសវាងបាន ហើយទីកន្លែងណាដែលការតាំងទីលំនៅថ្មីមិនអាចជៀសផុត ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ត្រូវតែរៀបចំជាផែនការ និងអនុវត្តឲ្យបានសមស្រប ដោយមានការពេគ្រោះយោបល់យ៉ាងជិស្និតជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់។
- ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ត្រូវតែអនុវត្តក្នុងក្របខ័ណ្ឌនៃគំរូអភិវឌ្ឍន៍សំដៅស្តារ និង ធ្វើឲ្យប្រសើរឡើងនូវកំរិតជីវភាពរបស់ពលរដ្ឋរងផលប៉ះពាល់ និង សហគមន៍ដែលជាទីកន្លែងពួកគាត់តាំតទីលំនៅថ្មី។

ប្រធានបទពិភាក្សា	តើបទដ្ឋានជានិយាយអ្វីខ្លះដែលគ្របដណ្តប់លើការតាំងទីលំនៅមិនមែនជាការស្ម័គ្រចិត្ត ដែលមាននៅក្នុងប្រទេសរបស់អ្នក ហើយបទដ្ឋានទាំងនេះអាចប្រៀបធៀបជាមួយបទ-ប្បញ្ញត្តិនៃបទដ្ឋាន ដែលមានជាលក្ខណៈអន្តរជាតិ ដោយរបៀបណា? .... តើត្រូវធ្វើឲ្យកាន់តែប្រសើរនូវបទដ្ឋានជានិយាម ដើម្បីដាក់បញ្ញត្តសម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារការតាំងទីលំនៅថ្មី មិនមែនជាការស្ម័គ្រចិត្ត ដោយធានាឲ្យបានកាន់តែទូលំទូលាយថា ជីវភាពរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងនោះត្រូវបានស្តារ និងធ្វើឲ្យកាន់តែប្រសើរឡើងដោយរបៀបណា?
លំហាត់	ទោះបីជាបទដ្ឋានជានិយាមនានាត្រូវបានអនុវត្តជាច្រើនឆ្នាំកមហើយក្តី ក៏នៅមានឧទាហរណ៍គំរូជាច្រើនទៀត ទាក់ទងនឹងកំហុសឆ្គងលើការអនុវត្តគម្រោង ។ ចូរពិពណ៌នាឲ្យបានក្បោះក្បាយអំពីមូលហេតុដែលនាំឲ្យមានករណីបែបនេះ។ .... តើគេអាចអនុវត្តយន្តការអ្វីខ្លះដើម្បីធានាឲ្យប្រាកដថារដ្ឋាភិបាល និងអ្នកធ្វើសំណើគម្រោងអាចក្តាប់ជាប់តាមរយៈការផ្តល់បទប្បញ្ញត្តិលើបទដ្ឋានជានិយាម មិនគ្រាន់តែដើម្បីទទួលហិរញ្ញវត្ថុសម្រាប់គម្រោងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាឲ្យមាននិរន្តរភាពនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ផងដែរ។

៥.២. តម្រូវការចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីតម្រូវការចាំបាច់ផ្នែកហិរញ្ញវត្ថុ នៅពេលតម្រូវឲ្យមានការតាំងទីលំនៅថ្មីដែលមិនមែនជាការស្ម័គ្រចិត្ត សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ។
ទិសដៅ	ដើម្បីឲ្យសិក្ខាកាមយល់ពីអ្វី ដែលជាតម្រូវការចាំបាច់របស់ហិរញ្ញិក ចំពោះការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។
ការអានតាមលំដាប់លំដោយ	IFC គំរូស្តង់ដារអនុវត្តនិរន្តរភាពសង្គម និង បរិស្ថាន (ខែមករា ឆ្នាំ ២០១២) ៖ គំរូស្តង់ដារទី៥ ៖ ការធ្វើសម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (www.ifc.org)។

ការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត អនុវត្តចំពោះការផ្លាស់ទីជារូបវន្ត និងសេដ្ឋកិច្ច ដែលជាលទ្ធផលបានពីការដោះស្រាយដីធ្លី កើតចេញពីការធ្វើសម្បទានដី តាមរយៈនីតិវិធីអស្សាមិករណ៍ ឬដោយជៀសមិនរួច ក៏ដូចជាការទទួលបានដីតាមរយៈការតាំងទីលំនៅដោយមានការចចារជាមួយម្ចាស់កម្មសិទ្ធិ ឬអ្នកដែលមានសិទ្ធិកាន់កាប់ដីធ្លី រួមមានសិទ្ធិដែលមានជាប្រពៃណី ឬ ទំនៀបទម្លាប់ ដែលទទួលទទួលស្គាល់ ឬ ដែលអាចទទួលស្គាល់ដោយច្បាប់របស់ប្រទេស ប្រសិនបើនីតិវិធីអស្សាមិករណ៍ ឬ ដោយជៀសមិនរួច ត្រូវធ្វើឡើងហើយនាំទៅដល់លទ្ធផលបរាជ័យលើការចចារ ។ ត្រូវបង្កើតបទប្បញ្ញតសម្រាប់អ្នកផ្លាស់ទីលំនៅដោយគ្មានសិទ្ធិស្របច្បាប់ ដែលអាចទទួលស្គាល់បាន ឬ ការតវ៉ាលើដីធ្លីដែលពួកគាត់កំពុងរស់នៅ។

៥.២.១ តម្រូវការចាំបាច់ទូទៅ

៥.២.១.១ ការរចនាគម្រោង

ការសន្មត់ជាទូទៅដែលអាចទទួលយកបាន គឺការរចនាគម្រោងដោយមានជម្រើស ដែលអាចជំនួសបាន សម្រាប់បញ្ជៀស ឬ យ៉ាងហោចកាត់បន្ថយការផ្លាស់ទីជារូបវន្ត និងសេដ្ឋកិច្ច ខណៈធ្វើឲ្យមានតុល្យភាពនៃការចំណាយ និងផលប្រយោជន៍ លើផ្នែកបរិស្ថាន សង្គម និងហិរញ្ញវត្ថុ ។

ប្រអប់អត្ថបទ ៥៣ ករណីសិក្សា ៖ ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី សម្រាប់គម្រោងវារីអគ្គិសនីណាំញុម២ (Nam Ngum 2 Hydroelectric Power Project) ក្នុងប្រទេសឡាវ

គម្រោង វារីអគ្គិសនីណាំញុន២ (NN2HPP) ត្រូវបានបង្កើតឡើងដើម្បីផលិតថាមពលអគ្គិសនីជាប្រចាំឲ្យបានចំនួន២២១៨ គីឡូវ៉ាត់ម៉ោង សម្រាប់លក់ទៅឲ្យប្រទេសថៃ ក្នុងរយៈពេល៣០ឆ្នាំ (២០០៧ ដល់ ២០៣៧) ក្រោមកិច្ចព្រមព្រៀងសម្បទាន (CA) រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យឡាវ (GoI) និង ក្រុមហ៊ុនថាមពលណាំញុម២ (NN2PC) ។ ទំនប់វារីអគ្គិសនីនេះមានទីតាំងស្ថិតនៅប្រហែល៩០គីឡូម៉ែត្រភាគខាងជើងរដ្ឋធានីវៀងចាន់ ឬ ប្រហែល៣៥គីឡូម៉ែត្រ ភាគឥសាន្ត និង ភាគខាងលើនៃទំនប់ណាំញុម១ ។ ទំនប់នេះជាទំនប់ប្រភេទ concrete face-rock fill dam (CFRD) មានកម្ពស់១៨១ម៉ែត្រ និងមានសមត្ថភាពស្តុកទឹកក្នុងអាងប្រហែល ៦៧៧៥ លានម៉ែត្រគូប (MCM) ហើយគ្របដណ្តប់ដោយផ្ទៃតំបន់លិចទឹកប្រហែល១២២គីឡូម៉ែត្រក្រឡា ស្ថិតក្នុងកំរិតផ្តត់ផ្គង់ពេញ (FSL) ជុតពីកម្ពស់ទឹកសមុទ្រចំនួន៣៧៥ម៉ែត្រ ។

គម្រោងនេះ តម្រូវឲ្យមានការផ្លាស់ទីកន្លែង / ការតាំងទីលំនៅថ្មី ដល់១១០៧ ខ្នងផ្ទះនៃ១៦ភូមិដែលរងផលផលប៉ះពាល់ពីគម្រោង។ តំបន់តាំងទីលំនៅMuang Fuang (ទីតាំងថ្មី) ត្រូវបានបង្កើតឡើងសម្រាប់ស្នាក់អាស្រ័យដល់គ្រួសារ១០៥៣ ដែលជាពលរដ្ឋរងពលប៉ះពាល់ដោយសារគម្រោង (PAPs)។ ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) ត្រូវបានបង្កើតឡើង ដើម្បីបន្ធូរបន្ថយផលប៉ះពាល់សង្គមពីការផ្លាស់ទីលំនៅ/ការតាំងទីលំនៅថ្មីសម្រាប់ពលរដ្ឋរងពលប៉ះពាល់ដោយសារគម្រោង (PAPs) ដែលមកពីភូមិហានចាស់នានា ទៅកាន់ទីកន្លែងរស់នៅថ្មី។

ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) ត្រូវបានបង្កើតឡើងតាំងពីដើមឆ្នាំ២០០៥ ។ របាយការណ៍ចំនួន៤ ត្រូវបានធ្វើឡើង និងដាក់ស្នើទៅកាន់អាជ្ញាធរ សម្រាប់ត្រួតពិនត្យ និងយល់ព្រម ដែលមានឈ្មោះ ដូចខាងក្រោម ៖

- ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០០៥ ។

- RAP របាយការណ៍បន្ថែមស្តីពីការពិគ្រោះយោលបល់ជាសាធារណៈ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។
- ផែនការអភិវឌ្ឍជនជាតិភាគតិច (EMDP) ថ្ងៃទី១៥ មីនា ឆ្នាំ២០០៦
- ផែនការអភិវឌ្ឍសង្គម (SDP) ថ្ងៃទី១៥ មីនា ឆ្នាំ២០០៦។

ការអនុវត្តផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី បានចាប់ផ្តើមតាំងពីខែវិច្ឆិកា ឆ្នាំ២០០៥ តាមរយៈការចាត់តាំងឲ្យមានគណៈកម្មការនានា កិច្ចពិគ្រោះយោបល់ជាសាធារណៈ ការរចនា និងកសាងសង្គមថ្មី ការទូទាត់សំណងលើទ្រព្យសម្បត្តិរងផលប៉ះពាល់ និង ការឆ្លើយតបចំពោះសារទុក្ខផ្សេងៗ។ ការបំលាស់ទីជារូបវន្តនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ទៅកាន់សហគមន៍ថ្មី ត្រូវបានរៀបចំឡើងក្នុងអំឡុងខែកញ្ញា ដល់ខែកុម្ភៈ ឆ្នាំ២០១០ ផ្អែកតាមផែនការអភិវឌ្ឍសង្គម។

កម្មវិធីទូទាត់សំណង និង ការបំលាស់ទីជារូបវន្តនៃគ្រួសារដែលជាពលរដ្ឋរងពលប៉ះពាល់ដោយសារគម្រោង ទៅកាន់ទីតាំងសហគមន៍ថ្មី ត្រូវបានធ្វើសម្រេចរួចរាល់តាមផែនការដែលបានកំណត់នាចុងខែកុម្ភៈ ឆ្នាំ២០១០ មុនពេលបិតបង្ហាំងអាងស្តុកទឹក។ កម្មវិធីអភិវឌ្ឍសង្គម និងអភិវឌ្ឍជនជាតិភាគតិច បានចាប់អនុវត្ត និងបន្តអនុវត្តរហូតដល់ចុងឆ្នាំ២០២០ រួមនឹងការបន្តអនុវត្តលើសកម្មភាពចំនួន៧ រហូតដល់ចុងកិច្ចកិច្ចព្រមព្រៀងសម្បទានក្នុងឆ្នាំ២០៣៧។

ទោះយ៉ាងណា លទ្ធផលនៃកម្មវិធី/សកម្មភាព ដែលបានអនុវត្តចំពោះតំបន់តាំងទីលំនៅថ្មី ទាមទារឲ្យមានការវាយតម្លៃសម្រាប់ត្រួតពិនិត្យឡើងវិញ និងដោះស្រាយក្នុងករណីដែលជួបប្រទះបញ្ហាបរិស្ថាន។ ការចូលរួមជាសាធារណៈ ទាមទារឲ្យមានការត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាពដែលបានអនុវត្ត។

ប្រភព ៖ Amnat Prommasutra ការរៀបចំផែនការ និងការអនុវត្តផែនការសកម្មភាពស្តីការតាំង ទីលំនៅថ្មី សម្រាប់គម្រោងវារីអគ្គិសនីណាំញ្ម២ (Nam Ngum 2 Hydroelectric Power Project) ក្នុងប្រទេសឡាវ។ ក្រុមហ៊ុនក្រុមពិគ្រោះយោបល់ស្តីវិស្វកម្ម និងគ្រប់គ្រង នៃទីក្រុងបាងកក ប្រទេសថៃ។ E-mail: amnatp@team.co.th www.teamgroup.co.th/index/en/download/category/2.html.....

៥.២.១.២ ការទូទាត់សំណង និងផលប្រយោជន៍សម្រាប់អ្នកដែលត្រូវផ្លាស់ទី

នៅពេលដែលការផ្លាស់ទីជម្រកមិនអាចជៀសវាងបាន អ្នកធ្វើសំណើគម្រោងត្រូវតម្រូវឲ្យមានការផ្តល់ឲ្យអ្នកដែលត្រូវផ្លាស់ទីជម្រក និងសហគមន៍នូវការទូទាត់សំណងសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិក្នុងតម្លៃនៃការដោះដូរពេញលេញ ។ បន្ថែមពីលើនេះ អ្នកធ្វើសំណើគម្រោង តម្រូវឲ្យជួយជ្រុំជ្រែងដល់ពលរដ្ឋរងផលប៉ះពាល់ដើម្បីអាចស្តារ និងធ្វើឲ្យប្រសើរឡើងនូវកំរិតជីវភាព ឬ ការចិញ្ចឹមជីវិតរបស់ពលរដ្ឋទាំងនោះ។ ប្រសិនបើគម្រោងនោះ មិនមែនជារបស់រដ្ឋ អ្នកធ្វើសំណើគម្រោងត្រូវបង្កើតទំនាក់ទំនងយ៉ាងជិតស្និតជាមួយរដ្ឋាភិបាល ដើម្បីទទួលបានការយល់ព្រមលើដំណើរការ និងបទដ្ឋានស្តង់ដារក្នុងការអនុវត្តការទូទាត់សំណង និងផលប្រយោជន៍ចំពោះពលករដ្ឋរងផលប៉ះពាល់។

បទដ្ឋានស្តង់ដារសម្រាប់ការទូទាត់សំណង ត្រូវតែមានលក្ខណៈតម្លាភាព និង ស្របជាមួយគម្រោង ។ ទីកន្លែងណាដែលការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋត្រូវផ្លាស់ទី ជាការប្រកបរបរដោយពឹងផ្អែកលើដីជាមូលដ្ឋាន ឬ ទីកន្លែងដែលដីជាកម្មសិទ្ធិប្រើប្រាស់រួម នោះអ្នកធ្វើសំណើរគម្រោងតម្រូវឲ្យមានការផ្តល់ឱកាសដល់ពលរដ្ឋ និងសហគមន៍ដែលត្រូវផ្លាស់ទីជម្រក ឲ្យទទួលបានផលប្រយោជន៍សមស្របពីការអភិវឌ្ឍរបស់គម្រោងផងដែរ។

ការទូទាត់សំណង មានបរិយាយនៅក្នុងផ្នែកទី៦ នៃសៀវភៅបណ្តុះបណ្តាលនេះ។

៥.២.១.៣ ការចូលរួម និងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ

អ្នកធ្វើសំណើគម្រោង ត្រូវទទួលខុសត្រូវចំពោះការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ ជុំវិញដំណើរការនៃការតាំងទីលំនៅថ្មី។ ផែនការពិគ្រោះយោបល់គួរតែធ្វើទៅតាមកាល:ទេស:របស់សហគមន៍មូលដ្ឋាន និងគួរឲ្យមានការចូលរួមបីប្រជាពលរដ្ឋរងផលប៉ះពាល់គ្រប់ៗគ្នា រួមទាំងសហគមន៍ដែលជាអ្នកទទួលភ្ញៀវសហគមន៍ថ្មី។ ផែនការពិគ្រោះយោបល់គួរត្រូវបានរៀបចំឡើងក្នុងលក្ខណ:ដែលភាគីពាក់ព័ន្ធអាចចូលរួមយ៉ាងសកម្មជុសជុល ក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការតាំទីលំនៅថ្មីដែលនឹងអាចបង្កផលប៉ះពាល់ដល់ពលរដ្ឋទាំងនោះ។ ការចូលរួម ការពាក់ព័ន្ធ និងការពិគ្រោះយលបល់របស់ភាគីពាក់ព័ន្ធគួរតែបន្តធ្វើអំឡុងពេលអនុវត្ត ត្រួតពិនិត្យតាមដាន និង វាយតម្លៃ លើការទូទាត់សំណង និង ការតាំងទីលំនៅថ្មី ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធ មានបរិយាយនៅក្នុងផ្នែកទី៨ នៃសៀវភៅបណ្តុះបណ្តាលនេះ។

៥.២.១.៤ យន្តការស្តីពីសារទុក្ខ

យន្តការស្តីពីសារទុក្ខ គឺជាដំណើរការទាំងឡាយណាដែលតម្រូវឲ្យមានដើម្បីធ្វើឲ្យមានប្រសិទ្ធភាពចំពោះការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដែលជាដំណើរការដ៏កម្រជៀសផុតពីជម្លោះ និង ការកើតទុក្ខមិនសុខចិត្តនានា (សារទុក្ខ)។ ដូច្នេះ ជាផ្នែកមួយនៃដំណើរការតាំងទីលំនៅថ្មី វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលយន្តការសារទុក្ខត្រូវបានបង្កើតឡើង និងព្រមព្រៀងគ្នារវាងភាគីទាំងអស់មុនចាប់ផ្តើមដំណើរការ។ យន្តការសារទុក្ខ គួរត្រូវបានរៀបចំឡើងដើម្បីទទួល និង ដោះស្រាយក្តីកង្វល់សំខាន់ៗជុំវិញដំណើរការនៃការតាំទីលំនៅថ្មី ការទូទាត់សំណង និងការតាំងទីលំនៅថ្មី ដូចដែលបានលើកឡើងដោយអ្នកដែលត្រូវបំលាស់ទី ឬ សមាជិកនៃសហគមន៍ជាភ្ញៀវ ។ យន្តការនេះ គួរជម្រុញឲ្យមានដំណោះស្រាយលើជម្លោះផ្សេងៗក្នុងលក្ខណ:តម្លាភាព និងមិនលំអៀង។

៥.២.១.៥ ការកំណត់ផែនការ និងការអនុវត្តការតាំងទីលំនៅថ្មី

ខាងក្រោមនេះ គឺជាតម្រូវការចាំបាច់សម្រាប់ការកំណត់ផែនការនៃការតាំងទីលំនៅថ្មី និង ត្រូវបានចងក្រងជាឯកសារទុកនៅក្នុងផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) ៖

- ជំរឿន/ការអង្កេតលើប្រជាសាស្ត្រពាក់ព័ន្ធ ទិន្នន័យជាមូលដ្ឋានស្តីពីសង្គមសេដ្ឋកិច្ច និងការប្រើប្រាស់ដីធ្លី ៖
  - ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលនឹងត្រូវធ្វើបំលាស់ទីដោយគម្រោង។
  - ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលមានសិទ្ធិទទួលបានការទូទាត់សំណង និង ជំនួយផ្សេងៗ។
  - ដើម្បីទប់ស្កាត់ពីការហូរចូលនៃប្រជាពលរដ្ឋ ដែលមិនអាចមានសិទ្ធិនឹងទទួលផលប្រយោជន៍ ។ ជាពិសេស ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល អ្នកធ្វើសំណើគម្រោងត្រូវបង្កើតប្រព័ន្ធកាលបរិច្ឆេទមានរយ:ពេលខ្លីសម្រាប់ការមានសិទ្ធិនឹងទទួលផលប្រយោជន៍ ។ ព័ត៌មានទាក់ទងនឹងប្រព័ន្ធកាលបរិច្ឆេទមានរយ:ពេលខ្លីនេះត្រូវតែចងក្រងទុកជាឯកសារ និងចែកផ្សាយនៅជុំវិញទីតាំងគម្រោង។
- បង្កើតឲ្យមានបទដ្ឋាននៃការទូទាត់សំណង លក្ខណ:វិនិច្ឆ័យនៃការមានសិទ្ធិនឹងទទួលបាន និងភាពមានកម្មសិទ្ធិនៃអ្នករងផលប៉ះពាល់តាមប្រទេសនីមួយៗ (រួមទាំងសហគមន៍ដែល

ជាម្ចាស់) តាមរយៈការយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ។

- បង្កើតឲ្យមានការទទួលខុសត្រូវជាលក្ខណៈស្ថាប័ន។
- កំណត់ឲ្យបានច្បាស់ពីតម្រូវការនៃជំនួយដល់ការតាំងទីលំនៅថ្មី និងវិធានការដែលទាមទារឲ្យមានសម្រាប់ស្តារ និងធ្វើឲ្យប្រសើរឡើងវិញដល់ការប្រកបរបរចិញ្ចឹមជីវិត។
- វិធីសាស្ត្រត្រួតពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំងព្រឹត្តិការណ៍ដែលកើតមានជាញឹក-ញាប់។
- ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី គួរបញ្ចូលឲ្យមានគ្រោងថវិការលម្អិត និងកម្មវិធីមួយដែលស្របគ្នាជាមួយនឹងកម្មវិធីសម្រាប់គម្រោងផ្តួចផ្តើមគំនិតវិនិយោគសំខាន់ជាងគេ (យោង១២)។

ក្នុងករណី បំលាស់ទីជាលក្ខណៈសេដ្ឋកិច្ច (ប៉ុន្តែមិនជាលក្ខណៈរូបវន្ត) អ្នកធ្វើសំណើគម្រោងត្រូវបង្កើតឲ្យមាននីតិវិធីផ្តល់ឲ្យអ្នកដែលត្រូវផ្លាស់ទី និងសហគមន៍នូវការទូទាត់សំណង និងជំនួយផ្សេងៗទៀតក្នុងការទូទាត់សងទ្រព្យសម្បត្តិសេដ្ឋកិច្ច ឬ ការទទួលបានទ្រពសម្បត្តិសេដ្ឋកិច្ច ដែលបានបាត់បង់។ នីតិវិធីនេះត្រូវបង្កើតឲ្យមានភាពមានកម្មសិទ្ធិចំពោះអ្នករងផលប៉ះពាល់ ឬ សហគមន៍រងផលប៉ះពាល់ ក៏ដូចជាធានាឲ្យប្រាកដថា ការផ្តល់ជូនទាំងនេះមានលក្ខណៈតម្លាភាព សមស្រប និងស្មើភាពគ្នា។

(យោង១២) ផ្អែកតាមការកំណត់ពេលវេលានៃការតាំងទីលំនៅថ្មី ជាធម្មតា ហិរញ្ញិកតម្រូវថាការទទួលបានដីធ្លី ការទូទាត់សំណងលើទ្រពសម្បត្តិដែលរងផលប៉ះពាល់ និងការតាំងទីលំនៅថ្មីដែលផ្សារភ្ជាប់ជាមួយគម្រោង (ឬអ្នកធ្វើសំណើគម្រោង) ត្រូវតែបញ្ចប់ឲ្យបានរួចរាល់មុនការចាប់ផ្តើមនៃផលប៉ះពាល់គម្រោង។ ទោះយ៉ាងណា ត្រូវគត់សម្គាល់ថា អ្នកធ្វើសំណើគម្រោងអាចមានអនុ-គម្រោងផ្សេងៗទៀត ឬ អ្នកធ្វើសំណើគម្រោងពហុភាគី ដែលមិនអាចកំណត់ឲ្យបានឃើញច្បាស់ មុនពេលការព្រមព្រៀងលើគម្រោង ឬដែលត្រូវបានអនុវត្តជាបន្តមកទៀតលើរយៈពេលពន្យារមួយ។ ស្ថិតក្រោមកាលៈទេសៈនេះ ត្រូវបង្កើតបទបញ្ញត្តមួយសម្រាប់ការរៀបចំឲ្យមានបទដ្ឋានជាគោលនយោបាយស្តីបីការតាំងទីលំនៅថ្មី ដើម្បីបង្កើតជាគោលការណ៍ នីតិវិធី និងការរៀបចំចាត់ចែងដែលនឹងត្រូវស្ថិតនីជាប់ជាមួយអ្នកធ្វើសំណើគម្រោង ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។ អ្នកធ្វើសំណើគម្រោង ត្រូវតែរៀបចំឲ្យមានផែនការសកម្មភាព ស្តីពីការតាំងទីលំនៅថ្មីមួយ ដែលស្របជាមួយនឹងបទដ្ឋានជាគោលនយោបាយសម្រាប់អនុ-គម្រោងបន្ទាប់ក្រោយមកទៀត ឬអ្នកធ្វើសំណើគម្រោងត្រូវកំណត់ឲ្យមានការបំលាស់ទីជាលក្ខណៈរូបវន្ត និង/ឬជាលក្ខណៈសេដ្ឋកិច្ច។

ប្រអប់អត្ថបទ ៥.៤ ករណីសិក្សានៅប្រទេសឡាវ (យោង១៣) ទៅលើទំហំ និងផលប៉ះពាល់ដែលត្រូវការឲ្យមានផែនការនៃការតាំងទីលំនៅថ្មី

សម្រាប់ប្រទេសឡាវ ការទូទាត់សំណង និងការតាំងទីលំនៅថ្មីដោយសារគម្រោងអភិវឌ្ឍន៍នានា ត្រូវបែងចែកទៅតាមទំហំ និងផលប៉ះពាល់ ដែលតម្រូវឲ្យមានជាចាំបាច់នៅក្នុងផែនការនៃការតាំងទីលំនៅថ្មី ដូចខាងក្រោម ៖

<u>ចំណាត់ថ្នាក់សង្គម 'S1' ៖</u> ជាប្រភេទអនុគម្រោងទាំងឡាយណា រួមនឹងផលប៉ះពាល់ធំៗលើប្រជាពលរដ្ឋ ដែលត្រូវបានកំណត់អត្តន័យ ដូចខាងក្រោម ៖

ក. មនុស្សចំនួន២០០នាក់ (៥០ទៅ៥០គ្រួសារ) ឬដែលត្រូវរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារ ៖ ធំជាង២០% នៃការបាត់បង់ទ្រពសម្បត្តិហូបផល ឬ នៅទីកន្លែងដែលការបាត់បង់មានចំនួនតិចជា ២០% ប៉ុន្តែទ្រពសម្បត្តិដែលនៅសេសសល់មិនអាចផ្តល់ត្រឡប់វិញជាលក្ខណៈសេដ្ឋកិច្ច ៖

- ការបំលាស់ទីដោយសារបាត់បង់ដីធ្លី និង/ឬ រចនាសម្ព័ន្ធ
- ការបាត់បង់ទាំងស្រុងនូវប្រាក់ចំណូល និងការងារ

ខ.មនុស្សចំនួន២០០ឬលើសពីនេះ(៥០ទៅ៥០គ្រួសារ)សំដៅដល់ក្រុមងាយរងគ្រោះដោយសារ គម្រោង ៖

- ជនជាតិភាគតិច
- អ្នករស់នៅតាមតំបន់ចង្អាត់មាត់ញក និងអ្នកដែលមានជីវភាពទន់ខ្សោយ
- ជនជាតិដើម
- ក្រុមពលរដ្ឋក្រីក្រ
- ស្ត្រីជាមេគ្រួសារ

គម្រោងដែលបានចាត់ថ្នាក់ថាជា 'S1' នឹងតម្រូវឲ្យមានជាផែនការពេញលេចស្តីពីការតាំងទីលំនៅថ្មី ឬករណីខ្លះអាចត្រូវការផែនការអភិវឌ្ឍជនជាតិភាគតិច (EMDP) តែមួយក៏បាន។ នៅក្នុងប្រភេទគម្រោង 'S1' ផលប៉ះពាល់ត្រូវបានយកចិត្តទុកថាមានលក្ខណៈសំខាន់បំផុត។

<u>ចំណាត់ថ្នាក់សង្គម 'S2' ៖</u> ជាប្រភេទអនុគម្រោងទាំងឡាយណា ដែលផលប៉ះពាល់របស់វាមានលក្ខណៈតិចតួចបន្ទាប់បន្សំ ៖ ផលប៉ះពាល់មានតិចតួច ទោះបីប្រជាជនរងផលប៉ះពាល់អាចមានចំនួនច្រើនជាង២០០នាក់ក្តី ដែលជាអ្នកត្រូវបាត់បង់ទ្រពសម្បត្តិហូបផល ឬ ក្រុមងាយរងគ្រោះ (ជនជាតិភាគតិច ក្រុមពលរដ្ឋក្រីក្រ អ្នករស់នៅតាមតំបន់ចង្អាត់មាត់ញក និង អ្នកដែលមានជីវភាពទន់ខ្សោយ ស្ត្រីជាមេគ្រួសារ)។

គម្រោងចំណាត់ថ្នាក់សង្គម 'S2' តម្រូវឲ្យមានតែផែនការធម្មតាមួយស្តីពីតាំងទីលំនៅថ្មី ឬ របាយការណ៍ស្តីពីការទទួលបានដី និង ការទូទាត់សំណងតែប៉ុណ្ណោះ ។ ផលប៉ះពាល់ក្នុងប្រភេទចំណាត់ថ្នាក់សង្គម 'S2' ត្រូវបានចាត់ទុកថាមានលក្ខណៈបន្ទាប់បន្សំ ឬមិនសូវជាសំខាន់ឡើយ។

<u>ចំណាត់ថ្នាក់សង្គម 'S3' ៖</u> ជាប្រភេទអនុគម្រោងទាំងឡាយណាដែលមិនបង្កផលជាការទទួលបានទ្រពសម្បត្តិ ការផ្លាស់ទីជម្រក ការបាត់បង់ប្រាក់ចំណូល និង ការងារ ការរិតត្បិតសិទ្ធិទទួលបានធនធានសហគមន៍ និងការរិតត្បិតការទទួលបានការគាំទ្រផ្នែកទំនៀមទម្លាប់វប្បធម៌របស់ក្រុមជនងាយរងគ្រោះ និង/ឬ ក្រុមជនជាតិភាគតិច ។ មិនមានការសិក្សាបន្ថែមទៅលើបញ្ហានៃការតាំងទីលំនៅថ្មី ដែលចាំបាច់សម្រាប់គម្រោងប្រភេទចំណាត់ថ្នាក់សង្គម 'S3'នេះឡើយ។

(ឃោង ១៣) ប្រភព: ខុទ្ទកាល័យនាយករដ្ឋមន្ត្រីឡាវ ភ្នាក់ងារបច្ចេកវិទ្យាវិទ្យាសាស្ត្រ និងបរិស្ថាន (STEA) ខែវិច្ឆិកា ឆ្នាំ២០០៥

ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) មានបរិយាយបន្ថែមនៅក្នុងផ្នែកទី៥.៣។

៥.២.១.៦ ការប្រកាសបិទជាសាធារណៈ

ដើម្បីធ្វើឲ្យស្របទៅនឹងគោលនយោបាយរបស់ហិរញ្ញិក ដែលមានលក្ខណៈជាអន្តរជាតិ ផែនការសកម្មភាពទាំអស់ស្តីពីការតាំងទីលំនៅថ្មី តម្រូវឲ្យមានការប្រកាសបិទជាសធារណៈ ។ ការប្រកាសបិទនេះ អាចធ្វើឡើងតាមរយៈការដាក់តាំងបង្ហាញរបាយការណ៍ (RAP) និង ឯកសារជំនួយស្មារតីនៅតាម ទីសាធារណៈ ក៏ដូចជានៅលើទំព័រវេបសាយ ។ វាជាការសំខាន់ដោយត្រូវកត់ចំណាំថា នៅពេលបិទប្រកាសឯកសារជាសាធារណៈ សាធារជនអាចទទួលបានព័ត៌មានថា មានឯកសារសម្រាប់សាធារណជនក្នុងការពិនិត្យ (តាមរយៈការទំនាក់ទំនងដោយផ្ទាល់មាត់ លិខិតស្នាម ការផ្សព្វផ្សាយពាណិជ្ជកម្ម និងស្លាកសញ្ញាពាណិជ្ជកម្មនៅលើទំព័រវេបសាយនានា)។

៥.២.២ ការផ្លាស់ទីជម្រកជាលក្ខណៈរូបវន្ត

ប្រសិនបើប្រជាជនរស់នៅក្នុងទីតាំងគម្រោងមួយ ត្រូវផ្លាស់ទីទៅកាន់ទីកន្លែងមួយទៀត អ្នកធ្វើសំណើ គម្រោងត្រូវ ៖

- ផ្តល់ជម្រើសដល់អ្នកដែលផ្លាស់ទីជម្រក ក្នុងចំណោមជម្រើសដែលអាចធ្វើបាន ទាក់ទងនឹងការតាំងទីលំនៅថ្មី រួមទាំងសំណងជាលំនៅដ្ឋានសមរម្យ និង ការទូទាត់សំណងជាសាច់ប្រាក់ សមរម្យ។
- ផ្តល់ជំនួយដល់ការតាំងទីលំនៅថ្មី សមស្របតាមតម្រូវការរបស់ក្រុមអ្នកផ្លាស់ទីជម្រក ដោយការយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និង ប្រជា-ពលរដ្ឋងាយរងគ្រោះ។

ការទូទាត់សំណងដោយជម្រើសនៃការផ្តល់ទីជម្រក និង/ឬ ជាសាច់ប្រាក់ ត្រូវរៀបចំឲ្យមានជាមុនមុនការចាប់ផ្តើមការតាំងទីលំនៅថ្មី ។ បន្ថែមពីលើនេះ ទីកន្លែងតាំងទីលំនៅដែលសាងសង់ឡើងសម្រាប់បុគ្គលផ្លាស់ទីជម្រកត្រូវតែជាទីតាំងដែលមានហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និង កត្តាជីវភាពល្អប្រសើរ។ ត្រូវផ្តល់ដល់អ្នកតាំងទីលំនៅថ្មី នូវជម្រើសសម្រាប់ផ្តល់លំនៅជ្រកកោនជាមួយនឹងការធានាដល់សិទ្ធិកាន់កាប់ ដើម្បីឲ្យអ្នកផ្លាស់ទីជម្រកទាំងនោះអាចតាំងទីលំនៅថ្មីដោយស្របច្បាប់ ដោយគ្មានការប្រឈមនឹងហានិភ័យដោយសារការរុះរើដោយបង្ខំណាមួយ នាពេលអនាគត។

ត្រូវផ្តល់ឲ្យអ្នកតាំងទីលំនៅថ្មី នូវជំនួយលើការរើទៅកន្លែងផ្សេងមានលក្ខណៈគ្រប់គ្រាន់សម្រាប់ពួកគេ ដើម្បីស្តារឡើងវិញនូវកំរិតជីវភាពនៅទីតាំងសមរម្យដែលអាចជម្រុសបាន ។

នៅទីកន្លែងណាដែលអ្នកផ្លាស់ទីជម្រកបានគ្របគ្រងជាកម្មសិទ្ធិ ឬ កាន់កាប់រចនាសម្ព័ន្ធនានា អ្នកធ្វើសំណើគម្រោងត្រូវតែផ្តល់សំណងដល់ពួកគេ ចំពោះការបាត់បង់ទ្រពសម្បត្តិផ្សេងៗក្រៅពីការផ្តល់សំណងដីធ្លី ដូចជាទីកន្លែងស្នាក់អាស្រ័យ និង ការធ្វើបសិដ្ឋកម្មដី ក្នុងតម្លៃដោះដូរពេញលេញ ផ្តល់ឲ្យប្រជាពលរដ្ឋទាំងនោះ អាចកាន់កាប់ទីតាំងគម្រោងមុនការបិទកាលបរិច្ឆេទ សម្រាប់ការផ្តល់សិទ្ធិទទួល

បាន ។ ការទូទាត់សំណងក្នុងទម្រង់មិនមែនជាប្រាក់ នឹងត្រូវផ្តល់ជូនជំនួសការទូទាត់សំណងជាសាច់ប្រាក់ សម្រាប់ទីកន្លែងណាដែលអាចធ្វើបាន (ផ្នែកទី៦)។

នៅពេលដែលការទទួលបានដីធ្លី មិនចាំបាច់តម្រូវឲ្យមានការផ្លាស់ទីជម្រករបស់ប្រជាពលរដ្ឋដែលកំពុងកាន់កាប់ ឬ ប្រើប្រាស់ វាអាចជាការកើតផលមួយ កម្រិតលើជីវភាពរបស់ប្រជាជនដែលពឹងអាស្រ័យលើធនធានស្ថិតនៅក្នុងទីតាំងដែលមាននៅលើដីនោះ ។ តួយ៉ាង គ្រួសារកសិករមួយអាចបាត់បង់ដីមួយចំណែករបស់ខ្លួនបានទៅគម្រោង ដោយមិនចាំបាច់ចាកចេញពីផ្ទះសម្បែងរបស់ខ្លួនឡើយ។ ប៉ុន្តែការបាត់បង់សូម្បីតែមួយចំណែកនៃដីក៏ដោយ ក៏អាចធ្វើឲ្យផលិតកម្មរួមនៃរបរកសិកម្មនោះថយចុះផងដែរ។ ការគម្រាមកំហែងនេះរាលដាលតែធំឡើង ក្នុងចំណោមចំនួនប្រជាពលរដ្ឋ ដែលមានរបរធ្វើស្រែចំការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលផ្នែដីកសិកម្មជាធម្មតាមានទំហំតូច និងជារឿយៗស្ថិតនៅរប៉ាត់រប៉ាយ។ ស្ថិតក្នុងលក្ខណៈដែលអាចជំនួសបាន ការទទួលបានដីអាចរិតត្បិតដល់សហគមន៍ ក្នុងការទទួលបានជាធម្មតានូវធនធានដែលបានកាន់កាប់ ដូចជា rangeland និងតំណភូមិ ធនធានអនុផលព្រៃឈើ (ដូចជា រុក្ខ-ជាតិសម្រាប់ធ្វើជាឱសថ ឬសម្រាប់ធ្វើសំណង់ និងសម្ភារៈសិប្បកម្មនានា) កូនឈើព្រៃសម្រាប់ធ្វើជាអុស និងអុសសម្រាប់ធ្វើឥន្ធនៈ ឬ ឧបករណ៍នេសាទ។

ដូចគ្នានេះដែរ ការទទួលបានធនធានទឹកតាមរយៈគម្រោង អាចមិនតម្រូវឲ្យមានជាចាំបាច់នូវការទទួលបានសម្បទានដី ឬ ការរុះរើលំនៅដ្ឋានជារូបវន្តទេ ប៉ុន្តែអាចបង្កជាផលប៉ះពាល់ជាអវិជ្ជមានលើការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងទីតាំងគម្រោង។ តួយ៉ាងការពង្វាង ឬ ការរាំងខ្ទប់លំហូរទឹក ទន្លេសម្រាប់ផលិតថាមពលអគ្គិសនី អាចបង្កជាផលប៉ះពាល់ទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់កសិកររស់នៅផ្នែកខាងក្រោម ដែលពឹងផ្អែកលើលំហូរទឹកជាអប្បបរិមា សម្រាប់ស្រោចស្រពផលដំណាំ ។ រោងច្រកថាមពលនៅឆ្នេរសមុទ្រ ដែលប្រើប្រាស់ទឹកសមុទ្រសម្រាប់គោលដៅធ្វើឲ្យត្រជាក់ស្រួលអាចបង្កផលប៉ះពាល់ដល់ជម្រកមច្ឆា ហេតុនេះវាក៏បង្កឲ្យមានផលប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជាអ្នកនេសាទនៅតំបន់ឆ្នេរសមុទ្រផងដែរ។

អ្នកធ្វើសំណើគម្រោងពមិនតម្រូវឲ្យសង ឬ ជួយជ្រុំជ្រែងដល់ប្រជាពលរដ្ឋណា ដែលទន្ទ្រានចូលតំបន់គម្រោងបន្ទាប់ពីការបិតការបរិច្ឆេទទូទាត់សំណងឡើយ។

៥.២.២.២ ការផ្លាស់ទីជម្រកជាលក្ខណៈសេដ្ឋកិច្ច

ប្រសិនបើការសម្បទានដី សម្រាប់គម្រោងបង្កឲ្យមានការបាត់បង់ចំណូល ឬ ការចិញ្ចឹមជីវិតដោយមិនគិតថាតើប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវធ្វើបំលាស់ទីជាលក្ខណៈរូបវន្ត ឬ អត់ ត្រូវតែទាមទារឲ្យមានចំនុច ដូចខាងក្រោម ៖

- ផ្តល់សំណងសមរម្យជាសេដ្ឋកិច្ចដល់អ្នកផ្លាស់ទីជម្រក ចំពោះការបាត់បង់ទ្រពសម្បត្តិ ឬ ការទទួលបានទ្រពសម្បត្តិទៅតាមតម្លៃចំណាយទូទាត់សងពេញលេញ។
- ក្នុងករណីទីតាំងធ្វើសម្បទានដី បង្កផលប៉ះពាល់ដល់រចនាសម្ព័ន្ធនៃជំនួញ ត្រូវសងទៅម្ចាស់ក្រុមហ៊ុនជំនួញ ចំពោះតម្លៃនៃការកសាងសកម្មភាពជំនួញឡើងវិញ នៅទីកន្លែងណាផ្សេងមួយទៀត ចំពោះការបាត់បង់ប្រាក់ចំណូលដើម ក្នុងអំឡុងពេលអន្តរកាល និងចំពោះការចំណាយលើការផ្ទេរ និង ការរៀចបំតំឡើងរោចក្រជាថ្មី តំឡើងគ្រឿងម៉ាស៊ីន ឬ ឧបករណ៍ដទៃទៀត។

- ត្រូវផ្តល់កម្មសិទ្ធិជាការដោះដូរ (តួយ៉ាង ទីតាំងកសិកម្ម ឬជំនួញ) ដែលមានគុណតម្លៃស្មើ ឬ ប្រសើរជាង ឬ ការទូទាត់សំណងជាសាច់ប្រាក់ក្នុងតម្លៃដោះដូរពេញលេញ ក្នុងលក្ខណៈសមរម្យ ចំពោះអ្នកដែលមានសិទ្ធិនឹងទទួលបានដោយស្របច្បាប់ ឬ ការទាមទារដីធ្លីដែលទទួលស្គាល់ ឬ ដែលស្ថិតក្រោមការគ្រប់គ្រងនៃច្បាប់ជាតិ។
- ត្រូវផ្តល់សំណងជាសេដ្ឋកិច្ចដល់អ្នកដែលផ្លាស់ទីជម្រក ដែលគ្មានការទាមទារទទួលស្គាល់ស្របច្បាប់ចំពោះដីធ្លី សម្រាប់ការបាត់បង់ទ្រព្យសម្បត្តិ (ដូចជា ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងការធ្វើឲ្យប្រសើរឡើងចំពោះដី តាមតម្លៃដោះដូរពេញលេញ។
- ត្រូវផ្តល់ជំនួយបន្ថែម (តួយ៉ាង មូលដ្ឋានឥណទាន ការបណ្តុះបណ្តាល ឬការផ្តល់ឱកាសការងារ) ព្រមទាំងឱកាសស្តារ និងធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរកប្រាក់ចំណូល កម្រិតផលិតកម្ម និងកម្រិតជីវភាព ទៅដល់អ្នកដែលផ្លាស់ទីជម្រកជាសេដ្ឋកិច្ច ដែលការប្រកបរបរចិញ្ចឹមជីវិត និងកម្រិតរកប្រាក់ចំណូលរបស់ពួកគេ ត្រូវរងផលប៉ះពាល់មិនល្អ។
- ត្រូវផ្តល់ការគាំទ្របណ្តោះអាសន្នតាមការចាំបាច់ ចំពោះអ្នកផ្លាស់ទីជម្រកជាសេដ្ឋកិច្ច ដែលពឹងផ្អែកលើពេលវេលាប៉ាន់ស្មានសមហេតុផល ដែលតម្រូវឲ្យមានការស្តារសមត្ថភាពរកប្រាក់ចំណូល កម្រិតផលិតកម្ម និងកម្រិតជីវភាពរស់នៅរបស់ពួកគេ។

អ្នកធ្វើសំណើគម្រោង មិនតម្រូវផ្តល់សំណង ឬ ជួយដល់អ្នកតាំងទីលំនៅឪកាសនិយម ដែលទន្ទ្រានលើទីតាំងគម្រោង បន្ទាប់ពីបិទកាលបរិច្ឆេទទូទាត់សំណងឡើយ។

ការទូទាត់សំណង មានបរិយាយលម្អិតនៅក្នុងផ្នែកទី៦ នៃសៀវភៅបណ្តុះបណ្តាលនេះ។

ប្រអប់អត្ថបទ ៥៣ ជំរឿនឆាប់រហ័ស-ដំណោះស្រាយចំពោះអ្នកតាំតទីលំនៅឪកាសនិយម

គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ បានអូសទាញប្រជាពលរដ្ឋជាច្រើនឲ្យមករស់នៅក្នុងតំបន់គម្រោងជាពិសេសដោយក្តីសង្ឃឹមថាអាចទទួលបានការងារធ្វើ។ ទោះយ៉ាងណា បញ្ហាជារួមដែលបានជួបប្រទះគឺថាប្រជាជនទាំងនោះក៏បានផ្លាស់ទីមកកាន់តំបន់គម្រោង ដោយសង្ឃឹមថានឹងអាចទទួលបានសំណងនិងអត្ថប្រយោជន៍នៃការតាំងទីលំនៅថ្មី។ អ្នកទាំងនោះ គឺជាអ្នកតាំងទីលំនៅបែបឱកាសនិយម។ ចំនុចនេះគឺជាហេតុផលដ៏ចម្បងមួយ សម្រាប់ការបង្កើតឲ្យមានប្រព័ន្ធកាលបរិច្ឆេទទូទាត់សំណងដែលមានលក្ខណៈជាការជូនព័ត៌មានត្រឹមត្រូវដល់សាធារណជន បន្ទាប់ពីសិទ្ធិអាចនឹងទទួលបានសំណង និងអត្ថប្រយោជន៍នៃការតាំងទីលំនីថ្មី ត្រូវបានបិតបញ្ចប់រួមក ។ តាមរយៈបទពិសោធន៍ពីគម្រោងនានា ដែលបរិមាណសំណងលើការខូចខាតជាច្រើន ត្រូវបានធ្វើឡើងបង្ហាញថាការជំរឿនឆាប់រហ័សមួយ គឺជាមធ្យោបាយល្អ និង មានអត្ថប្រយោជន៍ ដើម្បីបង្កើតជាប្រជាសាស្ត្រមូលដ្ឋាន សម្រាប់ទីតាំងដែលរងផលប៉ះពាល់ពីគម្រោង។ ជំរឿនឆាប់រហ័ស ត្រូវបានរៀបចំធ្វើដើម្បីប្រមូលទិន្នន័យជាអប្បបរមាលើចំនួនគ្រួសារ ដែលនឹងមានសិទ្ធិត្រូវទទួលសំណងនាពេលអនាគត។ ការមានសិទ្ធិនឹងទទួលបានសំណងរបស់អ្នកដែលចុះឈ្មោះតាមលេខរៀងរួច ត្រូវបានបញ្ជាក់តាមទម្លាប់ និង តាមរចនាសម្ព័ន្ធដឹកនាំមូលដ្ឋាន ហើយបុគ្គលម្នាក់ៗដែលបានចុះឈ្មោះក្នុងបញ្ជីរួច ត្រូវបានចេញប័ណ្ណសម្គាល់ក្នុងក្របខ័ណ្ឌគម្រោងបញ្ជាក់អត្តសញ្ញាណជាក់លាក់ និងដោយមានបិតរូបថត។ ការថតចម្លងអត្តសញ្ញាណប័ណ្ណ និងរូបថត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមការងារគម្រោង និងត្រូវបំពេញ បញ្ចូលទៅក្នុងទិន្នន័យជំរឿន (ធ្វើឲ្យស្របគ្នានឹងទីលំនៅ ឈ្មោះមេគ្រួសារ ចំនួនមនុស្សស្នាក់នៅ រចនាសម្ព័ន្ធទីលំនៅ និងការប្រើប្រាស់ដីធ្លី)។ ការជំរឿនឆាប់រហ័សត្រូវធ្វើឲ្យបានមុនកាលបរិច្ឆេទនៃការប្រកាសបិទការទូទាត់សំណង។

ប្រអប់អត្ថបទ ៥.៤ តម្រូវការចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី-ទិដ្ឋភាពគន្លឹះ
• តម្រូវការចាំបាច់ជាទូទៅ ដែលត្រូវអនុវត្តមានដូចខាងក្រោមនេះ ៖ ° ការរចនាគម្រោងដើម្បីបញ្ចៀស ឬ កាត់បន្ថយការតាំងទីលំនៅថ្មី។ ° ការទូទាត់សំណង និង ផលប្រយោជន៍ សម្រាប់អ្នកដែលត្រូវផ្លាស់ទីជម្រក។ ° ការចូលរួម និងការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ។ ° យន្តការស្តីពីសារទុក្ខ។ ° ការកំណត់ផែនការ និងការអនុវត្តការតាំងទីលំនៅថ្មី ។ ° ការប្រកាសបិទជាសាធារណៈ។ • នៅមានបទបញ្ញត្តជាក់លាក់មួយចំនួនទៀត ដែលអាចយកមកអនុវត្តបានជារូបវន្ត (រួមមាន ៖ ការបាត់បង់សិទ្ធិទទួលបានធនធានធម្មជាតិ) និងការផ្លាស់ទីជម្រកជាលក្ខណៈសេដ្ឋកិច្ច។ • ជាពិសេស ប្រជាពលរដ្ឋដែលចូលមករស់នៅក្នុងតំបន់គម្រោង ដែលរងផលប៉ះពាល់ក្រោយការប្រកាសបិទ ការទូទាត់សំណងយ៉ាងត្រឹមត្រូវជាសាធារណៈសម្រាប់បង្កើតសិទ្ធិនឹងទទួលបានសំណង (ដែលគេហៅថា ជនតាំងទីលំនៅបែបឱកាសនិយម) នឹងមិនត្រូវបានទទួលសំណង ឬទទួលផលប្រយោជន៍ពីការតាំងទីលំនៅថ្មីនេះឡើយ។

ប្រធានបទពិភាក្សា	មានការសរសេរជាច្រើនអំពីការបញ្ចៀសការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តតាមដែលអាចធ្វើទៅបាន ។ ចូរពិភាក្សាថាតើគេពិតជាអាច ឬ មិនអាចបញ្ចៀសការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តនេះបានដែរឬទេ? ..... តាមរយៈប្រើប្រាស់ឧទាហរណ៍គំរូដែលមាននៅក្នុងប្រទេសរបស់អ្នក ចូរកំណត់ឲ្យបានឃើញច្បាស់ពីឧទាហរណ៍នៃទីកន្លែង ដែលប្រព័ន្ធប្រកាសបិទកាលបរិច្ឆេទទូទាត់សំណងរបស់គម្រោងត្រូវបានរៀបចំឲ្យមាន និង សូមពណ៌នាពីលទ្ធផលនោះ ។ ប្រហែលគ្នានេះដែរ ចូរកំណត់ឲ្យបានឃើញច្បាស់ពីគំរូឧទាហរណ៍នៃទីកន្លែង ដែលប្រព័ន្ធបិទប្រកាសកាលបរិច្ឆេទទូទាត់សំណង មិនត្រូវបានរៀបចំឲ្យមាន និងសូមពណ៌នាពីលទ្ធផលនោះ។
លំហាត់	តាមរយៈបទពិសោធរបស់អ្នក តើអ្វីខ្លះដែលជាបញ្ហាប្រឈមដ៏ធំបំផុតដែលរដ្ឋាភិបាលមួយ ឬអ្នកធ្វើសំណើគម្រោងមួយបានជួបប្រទះ ក្នុងពេលនៃការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ជាប់ទាក់ទងនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ? ..... ចូរបង្កើតកម្រងសំនួរសាមញ្ញ និងតាមប្រភេទដែលអាចផ្តល់ឲ្យក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ដើម្បីចង្អុលបញ្ជាក់ពីអ្នកកាន់កាប់ទ្រពសម្បត្តិស្របច្បាប់ និងអ្នកប្រើប្រាស់ដីស្របច្បាប់ ដែលពួកគាត់នឹងត្រូវផ្លាស់ទីពីកន្លែងដីនោះ។

៥.៣ ផែនការសកម្មភាពស្តីពីតាំងទីលំនៅថ្មី

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីតម្រូវការចាំបាច់សម្រាប់ផែនការសកម្មភាពស្តីការតាំងទីលំនៅថ្មី។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់អំពីអ្វីដែលជាតម្រូវការចាំបាច់នៅក្នុងផែនការសកម្មភាពស្តីការតាំងទីលំនៅថ្មី និងពីរបៀបនៃការប្រមូលផ្តុំផែនការ។
ការអានតាមលំដាប់លំដោយ	IFC. (2002). កូនសៀវភៅសម្រាប់រៀបចំផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។ IFC ៖ នាយកដ្ឋានអភិវឌ្ឍបរិស្ថាន និងសង្គម។ ក្រុមធនាគារពិភពលោក ក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក

ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) គឺជាឯកសារដែលអ្នកគាំទ្រគម្រោង ឬ ភាគីផ្សេងទៀតដែលទទួលខុសត្រូវលើការងារតាំងទីលំនៅថ្មី (ដូចជាស្ថាប័នរដ្ឋាភិបាល) ជាអ្នកតាក់តែងឡើងដោយបង្ហាញនិតិវិធីជាក់លាក់ ដើម្បីឲ្យអនុវត្តតាម និងបង្ហាញពីចំណាត់ការដែលត្រូវអនុវត្ត ក្នុងការតាំងទីលំនៅថ្មី និង ការទូទាត់សំណងយ៉ាងសមស្របដល់ប្រជាពលរដ្ឋនិងសហគមន៍ ដែលរងផលប៉ះពាល់ពីការផ្លាស់ទីលំនៅ។ ផែនការសកម្មភាពស្តីពីតាំងទីលំនៅថ្មី ត្រូវបង្ហាញឲ្យបានច្បាស់អំពីអ្នកទាំងឡាយដែលរងផលប៉ះពាល់ពីគម្រោង និង បង្ហាញពីហេតុផលដែលនាំឲ្យមានការតាំងទីលំនៅថ្មី បន្ទាប់ពីបានពិចារណាលើជម្រើសដែលអាចកាត់បន្ថយជាអប្បបរមា ឬ ជៀសវាងឲ្យបានចំពោះការតាំងទីលំនៅថ្មី។ RAP ត្រូវកំណត់នូវលក្ខណៈវិនិច្ឆ័យឲ្យបានសមស្រប សម្រាប់អ្នកដែលរងផលប៉ះពាល់ពីគម្រោង កំណត់អត្រានៃការទូទាត់សំណងលើទ្រព្យសម្បត្តិដែលបានបាត់បង់ បង្ហាញពីកម្រិតនៃជំនួយសម្រាប់ការតាំងទីលំនៅថ្មី និងការ ក សាងជីវភាពជាថ្មីម្តងទៀត។ RAP ត្រូវគាំទ្រគម្រោងចំពោះការទាមទារដែលមិនបានរំពឹងទុកជាមុន ឬការប្រឆាំងតវ៉ាហូសពីការពិតពីសំណាក់អ្នកដែលមិនមានសិទ្ធិស្របច្បាប់ ក្នុងការទទួលផលប្រយោជន៍ពីការតាំងទីលំនៅថ្មី។ ក្នុងស្ថានភាពបែបនេះ ការចចារលើការទាមទារទាំងឡាយអាចនាំឲ្យមានការពន្យារពេលការអនុវត្តគម្រោង ហើយអាចនាំឲ្យមានការចំណាយប្រាក់ច្រើនលើសពីការរំពឹងទុក។

៥.៣.១ ប្រភេទនៃការតាំងទីលំនៅថ្មី

ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត អាចកើតឡើងចំពោះគម្រោងផ្សេងៗ ដែលមានលក្ខណៈទ្រង់ទ្រាយធំឡើយ ហើយកម្រិតនៃការបំលាស់ទីដែលជាប់ទាក់ទងជាមួយនឹងការតាំងទីលំនៅថ្មីបែបនេះអាចមានលក្ខណៈខុសគ្នាពីគម្រោងមួយទៅគម្រោងមួយ។ ប្រភេទជាទូទៅនៃការតាំងទីលំនៅថ្មី និងបញ្ហានានាដែលជាប់ទាក់ទងជាមួយនឹងការតាំងទីលំថ្មី មានដូចជា ៖

- **ការតាំងទីលំនៅថ្មីនៅតំបន់ជនបទ**

ជាទូទៅ ការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទដោយសារគម្រោង មានសិទ្ធិកាន់កាប់ដីកសិកម្ម តំបន់វាលស្មៅ និងតំបន់ដែលធ្លាប់ជាកន្លែងសម្រាប់សត្វស៊ីស្មៅជាអាហារ ឬ ដោយសារការរាំងមិនឲ្យប្រជាពលរដ្ឋចូលទៅប្រើប្រាស់ធនធានធម្មជាតិ (ឧទាហរណ៍ អនុផលព្រៃឈើ សត្វព្រៃ និងត្រីជាដើម) ដែលធនធានទាំងនោះជាប្រភពចិញ្ចឹមជីវិតរបស់ពួកគេ។ បញ្ហាប្រឈមធំៗដែលជាក់ទាក់ទងជាមួយនឹងការតាំងទីលំនៅថ្មីនៅតំបន់ជនបទ មានដូចជា ៖ ការទាមទារឲ្យមានការស្តារឡើងវិញនូវប្រាក់ចំណូលដោយអាស្រ័យលើដី និងធនធាន ការបោះបង់ចោលផ្នែកខ្លះៗនៃសកម្មភាពសង្គម និង វប្បធម៌

របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី ។ សម្រាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ជាម្ចាស់ទីតាំងទីលំនៅថ្មីវិញ សកម្មភាពវប្បធម៌ និងសង្គមរបស់គេ ក៏ត្រូវរងផលប៉ះពាល់ដែរ។

- **ការតាំងទីលំនៅថ្មីនៅតំបន់ទីប្រជុំជន**

ការតាំងទីលំនៅថ្មីនៅតំបន់ទីប្រជុំជន បណ្តាលឲ្យមានការបំលាស់ទីជាលក្ខណៈរូបវន្ត និងសេដ្ឋកិច្ច ដែលបង្កផលប៉ះពាល់មកលើការសាងសង់ផ្ទះសម្បែង ការងារនិងសកម្មភាពសហគ្រាសរបស់គេ។ បញ្ហាប្រឈមធំៗដែលទាក់ទងជាមួយនឹងការតាំងទីលំនៅថ្មីនៅតំបន់ទីប្រជុំជន ជាប់ទាក់ទងនឹងការស្តារឡើងវិញនូវជីវភាពរស់នៅដែលពឹងទៅលើប្រាក់ខែ និងសកម្មភាពសហគ្រាស ដែលមានទំនាក់ទំនងជាមួយនឹងទីតាំងថ្មី (ចម្ងាយពីកន្លែងធ្វើការ អតិថិជន និងផ្សារ)។ ទីតាំងសម្រាប់ការតាំងទីលំនៅថ្មីត្រូវតែជ្រើសរើសឲ្យបាននៅជិតកន្លែងធ្វើការសម្រាប់ប្រជាជនដែលប៉ះពាល់ពីគម្រោងតាំងទីលំនៅថ្មីនោះ ដើម្បីឲ្យគេអាចបង្កើតប្រាក់ចំណូល និងស្វែងរកការងារនិងរក្សាទំនាក់ទំនងជាមួយនឹងសហគមន៍ និងអ្នកជិតខាងរបស់គេ ។ នៅក្នុងករណីខ្លះ ការបំលាស់ទីរបស់អ្នករស់នៅទីប្រជុំជននិងផលវិបាកនាំឲ្យទន់ខ្សោយដល់សុវត្ថិភាពសង្គមដែលជាចរិកលក្ខណៈនៃតំបន់ជនបទ ដែលទាមទារឲ្យអ្នកធ្វើផែនការការតាំងទីលំនៅថ្មីត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះសេចក្តីត្រូវការរបស់ក្រុមជនងាយរងគ្រោះ។

- **ការតាំងទីលំនៅថ្មីជាលក្ខណៈជួរបណ្តោយ**

ការតាំងទីលំនៅថ្មីជាលក្ខណៈជួរបណ្តោយ អនុវត្តចំពោះគម្រោងដែលមានលំនាំជាជួរៗតៗគ្នានៃការធ្វើសម្បទានដី (ផ្លូវជាតិ ផ្លូវរថភ្លើង ប្រឡាយទឹក និងខ្សែបញ្ជូនចរន្តអគ្គិសនីជាដើម) ។ នៅតំបន់ជនបទដែលមានប្រជាជនតិចតួច ការអនុវត្តគម្រោងតាំងទីលំនៅថ្មីតាមលំនាំនេះ តួយ៉ាងដូចជាខ្សែបញ្ជូនចរន្តអគ្គិសនី អាចមានផលប៉ះពាល់តិចតួចដល់ម្ចាស់ដី។ សំណងលើការខូចខាតទ្រព្យសម្បត្តិ ដូចជាផលដំណាំដែលរងការបំផ្លាញដោយគម្រោងនេះ មានលក្ខណៈជាការទូទាត់តិចតួចតែមានចំនួនច្រើន ។ បើគម្រោងនេះត្រូវបានរៀបចំផែនការបានល្អនោះ ការតាំងទីលំនៅតាមលំនាំនេះ អាចកាត់បន្ថយជាអបប្បរមា ឬ បញ្ចៀសការបំផ្លាញលើរចនាសម្ពន្ធ័ជាអចិន្ត្រៃយ៍បាន។ តែផ្ទុយទៅវិញ នៅតំបន់ប្រជុំជនដែលមានមនុស្សច្រើនវិញនោះ គម្រោងមួយចំនួនដូចជាការកែលម្អផ្លូវអាចតម្រូវឲ្យមានការបំផ្លាញរចនាសម្ពន្ធ័នៅតាមបណ្តោយផ្លូវដែលជាផ្លូវគម្រោងឆ្លងកាត់ ហើយជាហេតុនាំឲ្យមានការប៉ះពាល់ដល់មនុស្សជាច្រើន។ ការតាំងទីលំនៅជាលក្ខណៈជួរបណ្តោយ មានលក្ខណៈផ្ទុយពីការតាំងទីលំនៅ ដែលមានឈ្មោះថា ការតាំងទីលំនៅលើទីកន្លែងជាក់លាក់ ដោយសារតែបញ្ហាដែលបានកើតឡើង នៅពេលមានចំណាត់ការលើការតាំងទីលំនៅថ្មី ត្រូវធ្វើការសម្របសម្រួល ជុំវិញយុត្តាធិការរដ្ឋបាលចម្រុះ និង/ឬ ទីតាំងដែលមានវប្បធម៌និងភាសាផ្សេងគ្នា។

- **ការតាំងទីលំនៅលើទីតាំងជាក់លាក់**

ការតាំងទីលំនៅលើទីតាំងជាក់លាក់ ជាប់ទាក់ទងជាមួយនឹងគម្រោង នៃការតាំងទីលំនៅដែលដាច់តែឯងមិនមានលក្ខណៈជាជួរៗ ដូចជានៅតាមរោងចក្រ កំពង់ផែ ផ្លូវថ្នល់ឆ្លងកាត់ទៅមក សណ្ឋាគារ និងទីកន្លែងដាំដុះផលជំនួញជាដើម ដែលនៅទីនោះការធ្វើសម្បទានដីហ៊ុមព័ទ្ធទៅដោយទីតាំងចម្រុះ ។ ទោះបីជាយ៉ាងណា ការតាំងទីលំនៅនៅលើទីតាំងជាក់លាក់ ដែលនៅជាប់ទីតាំងឧស្សាហកម្មរុករករ៉ែ និងឧស្សាហកម្មបូមយកប្រេង និងឧស្មន៍ អាចតម្រូវឲ្យមានការធ្វើសម្បទានដី ជាបន្តបន្ទាប់សម្រាប់រយៈពេលយូរ ។ ជាលទ្ធផល ការបំលាស់ទីរបស់សហគមន៍អាចកើតឡើងជាជំហានៗរយៈពេលជាយូរឆ្នាំអាចរហូត

ដល់ទៅទសវត្សរ៍ក៏មាន។ សហគមន៍ដែលរងការគម្រាមកំហែងពីការបំលាស់ទីនាពេលអនាគតជារឿយៗ តែងចង់បន្តរស់នៅលើទីដដែល រហូតទាល់តែការតាំងទីលំនៅទៅកាន់ទីកន្លែងថ្មីជាការចាំបាច់ដោយខានមិនបាន ។ បញ្ហាប្រឈមធំៗ ដូចជាការតាំងទីលំនៅដែលកើនតាមកម្រិត គឺការរក្សារនូវវិធីសាស្ត្រដែលស្របតាមការទូទាត់សំណង និងការស្តារឡើងវិញនូវប្រភពប្រាក់ចំណូល ក្នុងមួយរយៈពេលអនុវត្តគម្រោងទាំងមូល។ ប្រហាក់ប្រហែលគ្នានេះដែរ ការរៀបចំអាងស្តុកទឹកសម្រាប់គម្រោងវារីអគ្គសនី និងគម្រោងស្រោចស្រព អាចបណ្តាលឲ្យមានការបំលាស់ទីជាលក្ខណៈរូបវន្ត និង សេដ្ឋកិច្ចជាច្រើនសម្រាប់ប្រជា-សហគមន៍ជនបទ។

តាមរយៈការរៀបរាប់ខាងលើ បង្ហាញយ៉ាងច្បាស់ថាវិសាលភាព និង កម្រិតនៃការរៀបចំផែនការល្អិតល្អន់នៃការតាំងទីលំនៅថ្មី អាចមានការប្រែប្រួលពីស្ថានភាពមួយទៅស្ថានភាពមួយ អាស្រ័យទៅលើភាពស្មុគស្មាញនៃគម្រោង និងទំហំនៃផលប៉ះពាល់នៃការគម្រោងនោះ។ តាមការតម្រូវឲ្យមានជាអតិបរមានៃការតាំងទីលំនៅថ្មី ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ត្រូវធានាថាជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ពីគម្រោង ត្រូវបានស្តារឡើងវិញនៅក្នុងកម្រិតមួយ ប្រហាក់ប្រហែលទៅនឹងជីវភាពរបស់ប្រជាជនមុនពេលការអនុវត្តគម្រោង ។ តែទោះបីជាយ៉ាងណាក៏ដោយការស្តារឡើងវិញយ៉ាងងាយលើជីវភាពរស់នៅ អាចមិនគ្រប់គ្រាន់ ដើម្បីការពារដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងឡើយ ជាពិសេសផលប៉ះពាល់ដ៏ធំលើការប្រកួតប្រជែង ដើម្បីធនធាន និង ការងារ អតិផរណា និង ការធ្លាក់ចុះនៃ បណ្តាញគាំទ្រផ្នែកសង្គមកិច្ច ជាដើម។ ដូច្នេះ សកម្មភាពតាំងទីលំនៅថ្មីត្រូវផ្តល់ផលរីកចម្រើន ដែលអាចវាស់វែងបានលើលក្ខខ័ណ្ឌសេដ្ឋកិច្ច និង សុខមាលភាពសង្គមរបស់ប្រជាពលរដ្ឋ និងសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង។

៥.៣.២ ធាតុសំខាន់ៗ នៃផែនការការតាំងទីលំនៅថ្មី

- ការកំណត់ឲ្យបានច្បាស់ពីផលប៉ះពាល់នៃគម្រោង និងប្រជាជនរងផលប៉ះពាល់
- បទដ្ឋានគតិយុត្តិសម្រាប់ការធ្វើសម្បទានដី និងការទូទាត់សំណង
- បទដ្ឋាននៃការទូទាត់សំណង
- ការពិពណ៌នាអំពីការផ្តល់ជំនួយសម្រាប់ការតាំងទីលំនៅថ្មី និងការកសាងជីវភាពថ្មីឡើងវិញ
- ថវិកាចំណាយលម្អិត
- គម្រោងពេលវេលានៃការអនុវត្តសកម្មភាព
- ការពិពណ៌នាអំពីការទទួលខុសត្រូវរបស់ស្ថាប័ន
- បទដ្ឋានសម្រាប់ការចូលរួមរបស់ភាគីពាក់ពន្ធ័ ការពិគ្រោះយោបល់ និង ការរៀបចំផែនការអភិវឌ្ឍន៍
- យន្តការស្តីពីបណ្តឹងសារទុក្ខ
- បទដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើរបាយការណ៍

៥. ៣. ២. ១ ការកំណត់ឲ្យបានច្បាស់ពីផលប៉ះពាល់នៃគម្រោង និងប្រជាពលរដ្ឋរងផលប៉ះពាល់

ការងារដំបូងក្នុងការរៀបចំផែនការតាំងទីលំនៅថ្មី គឺត្រូវកំណត់ឲ្យបានច្បាស់ពីផលប៉ះពាល់មិនល្អរបស់គម្រោង និង ប្រជាពលរដ្ឋដែលនឹងត្រូវរងផលប៉ះពាល់ទាំងនោះ។ ប្រការនេះ ជាធម្មតាតម្រូវឲ្យមានការចូលរួមពីអ្នកជំនាញការដែលធ្លាប់មានបទពិសោធន៍ និង ធ្លាប់ទទួលការបណ្តុះបណ្តាលត្រឹមត្រូវទាក់ទងនឹងកិច្ចការនេះ ។ ការរៀបចំផែនការតាំងទីលំនៅថ្មី ជាប់ទាក់ទងលើសពីការស្វង់មតិអំពីកិច្ចការ

សុរិយោដីធម្មតា ឬ ការធ្វើសារពើភ័ណ្ឌលើទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ។ គោលដៅជាមូលដ្ឋាននៃផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី គឺធ្វើយ៉ាងណាអាចលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋដែលបានបំលាស់ទីលំនៅដោយសារគម្រោង ដែលគោលដៅនេះ តម្រូវឲ្យមានការត្រួតពិនិត្យលើលក្ខខ័ណ្ឌសង្គម បរិស្ថាន និងសេដ្ឋកិច្ច លើសពីការត្រួតពិនិត្យទៅលើសារពើភ័ណ្ឌទ្រព្យសម្បត្តិជាធម្មតា។

ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ត្រូវកំណត់ឱឲ្យបានច្បាស់ពីប្រជាពលរដ្ឋទាំងអស់ដែលទទួលរងផលប៉ះពាល់ពីគម្រោង និង ផលប៉ះពាល់មិនល្អទាំងឡាយទៅលើជីវភាពរស់នៅ ពាក់ព័ន្ធនឹងការធ្វើសម្បទានដីរបស់គម្រោង។ ផលប៉ះពាល់ទាំងនោះ រួមមាន ៖ ការកាត់ផ្តាច់បណ្តាញគាំទ្រសហគមន៍ និងសង្គមកិច្ច ការបាត់បង់ផ្ទះសម្បែង កសិដ្ឋាន និងរចនាសម្ព័ន្ធផ្សេងៗទៀត (ដូចជាអណ្តូងទឹក boreholes ការដ្ឋានធារាសាស្ត្រ របង) ដីកសិកម្ម ដើមឈើ ផលដំណាំ ការបាត់បង់ឱកាសប្រើប្រាស់ធនធានសហគមន៍ដូចជាប្រភពទឹក វាលស្មៅ អុសដុត និងរុក្ខជាតិផ្តល់ជាឱសថ ល្បែងប្រជល់សត្វ ឬ ប្រជល់ត្រី ការបាត់បង់មុខជំនួញ លែងទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬ សេវាកម្មផ្សេងៗ ដែលសុទ្ធសឹងតែជាការខាតបង់ប្រាក់ចំណូលយ៉ាងក្រាស់ក្រែលដោយសារការបាត់បង់ទាំងនេះ។

ចាំបាច់ត្រូវធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន អ្នកតំណាងសហគមន៍ និងប្រធានសហគមន៍ និងអ្នកតំណាងដទៃទៀត របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី ដើម្បីស្វែងយល់ពីប្រភេទផ្សេងៗ និងកម្រិតផលប៉ះពាល់របស់គម្រោង។ អ្នកគាំទ្រគម្រោងត្រូវពិភាក្សាលើផែនការនៃការធ្វើជំរឿន និងកម្មវិធីចុះបញ្ជីជាមួយអ្នកដឹកនាំមូលដ្ឋាន និងអ្នកតំណាងអង្គការដែលមាននៅសហគមន៍មូលដ្ឋាន។ អ្នកធ្វើជំរឿន និងធ្វើសារពើភ័ណ្ឌលើទ្រព្យសម្បត្តិ អាចជាបុគ្គលិកគម្រោង ដំបូងគេដែលអាចនឹងត្រូវជួបជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ ។ អ្នកធ្វើកិច្ចការនេះត្រូវពន្យល់ឲ្យបានលម្អិតអំពីគោលបំណង និងកាលវិភាគនៃគម្រោង ព្រមទាំងផែនការទាំងឡាយដែលត្រូវអនុវត្តទាក់ទងនឹងការបំលាស់ទីជាលក្ខណៈរូបវន្ត ការទូទាត់សំណងលើទ្រព្យសម្បត្តិដែលបាត់បង់ និងការស្តារជីវភាពរបស់ប្រជាពលរដ្ឋឡើងវិញ។

ត្រូវប្រុងប្រយត្ន័ផងដែរក្នុងការដាក់បញ្ចូលនូវសហគមន៍ និង តំបន់ដែលត្រូវជ្រើសរើសសម្រាប់ការតាំងទីលំនៅថ្មី។ ប្រជាពលរដ្ឋដែលរស់នៅទីនោះ គឺជាប្រជាពលរដ្ឋម្ចាស់មូលដ្ឋាន (Host population) ឬ ម្ចាស់សហគមន៍ (Host community) ដែលអាចរងផលប៉ះពាល់មិនល្អពីការតាំងទីលំនៅថ្មី ហើយពួកគេទាំងនោះក៏ត្រូវតែចាត់ទុកជាក្រុមមនុស្សដែលរងផលប៉ះពាល់ពីគម្រោងផងដែរ ។ ដូច្នេះហើយ ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវតែដោះស្រាយ និងកាត់បន្ថយផលប៉ះពាល់មិនល្អ ដែលបណ្តាលមកពីការតាំងទីលំនៅថ្មីនៅក្នុងសហគមន៍របស់គេ មានដូចជា ៖ ការដាក់សម្ពាធទៅលើដី ទឹក សារពើធម្មជាតិ (ព្រៃឈើ តំបន់ព្រៃ វាលស្មៅ និងតំបន់ដីសើម ជាដើម) ការដាំដុះ និងតំបន់ព្រៃ ឬ សម្បត្តិធនធានជារួមផ្សេងៗទៀត ហេដ្ឋារចនាសម្ពន្ធ័សាធារណៈ និងសេវាកម្មផ្សេងៗទៀត ។ ត្រូវជូនដំណឹង និងពិភាក្សាជាមួយប្រជាពលរដ្ឋជាម្ចាស់មូលដ្ឋាន ដែលជាផ្នែកមួយនៃដំណើរការនៃការរៀបចំផែនការតាំងទីលំនៅថ្មី។ ការចូលរួមពាក់ព័ន្ធក្នុងការពិគ្រោះយោបល់ ត្រូវធ្វើឡើងជាមួយតំណាងទាំងពីរ គឺតំណាងសហគមន៍ម្ចាស់ មូលដ្ឋាន និងតំណាងសហគមន៍ដែលត្រូវផ្លាស់ទីលំនៅ អាចជួយឲ្យពួកគេមានទំនាក់ទំនងជាមួយគ្នាបានខ្លះៗ និងជួយដោះស្រាយជម្លោះដែលអាចនឹងកើតឡើងចៀសមិនផុតក្នុងកំឡុងពេល និងក្រោយពេលតាំងទីលំនៅថ្មី ។ ការផ្តល់ការទូទាត់ណាមួយដល់សហគមន៍មូលដ្ឋានសម្រាប់ផ្លែដី និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលត្រូវផ្តល់ ដល់អ្នកតាំងទីលំនៅថ្មីទាំងនោះ ត្រូវតែមានការព្រមព្រៀង និងជាការទូទាត់សំណងភ្លាមៗ។

មានជំហានមួយចំនួន ដែលជាជំហានមិនចាំបាច់សម្រាប់យកទៅអនុវត្តន៍តាមលំដាប់លំដោយ បន្ទាប់ពីការកំណត់បានច្បាស់លាស់ពីប្រជាពលរដ្ឋរងផលប៉ះពាល់ និង ផលប៉ះពាល់ទាំងនោះ ។ គួរកត់សម្គាល់ផងដែរថា ព័ត៌មានដែលបានពីការវាយតម្លៃហេតុប៉ះពាល់សង្គម អាចផ្តល់ជាព័ត៌មានអំពីទិន្នន័យដែលប្រមូលបាន តាមរយៈការអនុវត្តជំហានទាំងនេះ។

- ការកំណត់ផែនទីដែលបង្ហាញអំពីលក្ខណៈពិសេស ដូចជាការតាំងទីលំនៅរបស់ប្រជា-ពលរដ្ឋ ហេដ្ឋារចនាសម្ពន្ធ័ សណ្ឋានដី តំបន់សារពើធម្មជាតិ, ធនធានទឹក និងលំនាំនៃការប្រើប្រាស់ដី ។ ត្រូវកំណត់ផែនទីឲ្យបានលម្អិតលើតំបន់ដែល *ប្រជាជនត្រូវផ្លាស់ទីចេញ* និងតំបន់ដែល *ប្រជាជនត្រូវផ្លាស់ទីទៅកាន់។* ជាការល្អ ត្រូវកំណត់ផែនទីខ្នាតធំដែលមានលក្ខណៈលម្អិត (ហើយបើសិនជាអាចទៅរួច ត្រូវមានរូបភាពបានពីលើអាកាសផងដែរ) ហើយនៅលើផែនទីនោះ ត្រូវដៅកំណត់បង្ហាញពីគ្រួសារដែលរងផលប៉ះពាល់នីមួយៗ (ដែលបានកំណត់ពីលេខចុះបញ្ជីបានពីការជំរឿនចំនួនប្រជាជន)។ ក្រៅពីនេះ ត្រូវមានឯកសារអំពីរបាយការណ៍អង្កេតដែលកំណត់ អំពីប្រភេទដីខុសៗគ្នា អាស្រ័យទៅលើការប្រាស់ប្រាស់ដីនិងសក្តានុពលរបស់ដីនោះ (ឧទាហរណ៍មានដូចជា ការវាយតម្លៃលើនិរន្តរភាពនៃដំណាំដាំដុះ សារពើធម្មជាតិ និងការវាយតម្លៃលើសមត្ថភាពអនុវត្តការចិញ្ចឹមបសុសត្វ) ។ តាមរយៈផែនទីអង្កេតទាំងនេះ អ្នករៀបផែនការតាំងទីលំនៅថ្មីអាចរៀបចំជាផែនទីដែលបង្ហាញអំពីទីតាំងផ្សេងៗ និងសារៈប្រយោជន៍នៃការប្រើប្រាស់ប្រភេទដីខុសៗគ្នា។ ផែនទីបន្ថែមទៀតត្រូវរៀបចំដើម្បីកំណត់អំពី ៖ ប្រភេទនៃការប្រើ-ប្រាស់ដី ទីតាំងនៃធនធានធម្មជាតិសាធារណៈ សម្បត្តិវប្បធម៌ (ឧទាហរណ៍ ៖ កន្លែងគោរពបូជា និងបូជនីយដ្ឋានសំខាន់ជាដើម) បណ្តាញផ្លូវថ្នល់ និងគមនាគមន៍ និងទីតាំងកន្លែងធ្វើការ និងសេវាកម្មផ្សេងៗទៀត។ ក្រៅពីផ្តល់ប្រយោជន៍ដល់ការធ្វើផែនការ ការកំណត់ផែនទីនៃទីតាំងគម្រោង គ្រួសាររងផលប៉ះពាល់ ធនធានធម្មជាតិ អចលវត្ថុ និងហេដ្ឋារចនាសម្ពន្ធ័ អាចផ្តល់ឲ្យអ្នកធ្វើសំណើរគម្រោងនូវឯកសារយោង និង មូលដ្ឋានដើម្បីជួយគម្រោងកុំឲ្យប្រជាជន ដែលបានចូលមកតាំងលំនៅក្រោយពេលបញ្ចប់គម្រោងអាចទាមទារថ្លៃសំណងផ្សេងៗបាន។
- ស្ថិតិដែលបានចុះឈ្មោះប្រជាពលរដ្ឋរងផលប៉ះពាល់រួច និង ការចុះបញ្ជីពួកគេទៅតាមទីតាំងដែលគេរស់នៅ។ ស្ថិតិប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង គឺជាជំហានទីមួយក្នុងការត្រៀមរៀបចំផែនការសកម្មភាពតាំងទីលំនៅថ្មី ។ ការធ្វើជំរឿនដើរតួនាទីសំខាន់និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ចំនួនប្រាំចំនុច ដូចខាងក្រោមនេះ ៖
  - ការចុះឈ្មោះ និងការប្រមូលព័ត៌មានជាមូលដ្ឋានអំពីប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។
  - ការចុះបញ្ជីប្រជាពលរដ្ឋរងផលប៉ះពាល់ទៅតាមភូមិ ឬទីតាំងដែលគេរស់នៅ។
  - ការបង្កើតបញ្ជីឈ្មោះជាផ្លូវការស្តីអំពីអ្នកទទួលផលស្របច្បាប់ មុននឹងការចាប់ផ្តើមគម្រោង ដើម្បីចៀសវាងកុំឲ្យអ្នកដែលចូលទៅរស់នៅទីតាំងគម្រោង អាចទាមទារចង់បានផលប្រយោជន៍ដែរ។
  - បង្កើតជាបទដ្ឋានដើម្បីឈានដល់ការស្រាវជ្រាវសង្គមសេដ្ឋកិច្ច ដែលជាការស្រាវជ្រាវចាំបាច់ ដើម្បីកំណត់អត្រាទូទាត់សំណងដោយយុត្តិធម៌ ដោយការបង្កើតតាមដាន

ត្រួតពិនិត្យ និង វាយតម្លៃ អំពីការស្តារប្រាក់ចំណូលប្រកបដោយនិរន្តរភាព និង អន្តរាគមន៍នៃការអភិវឌ្ឍ។

- ផ្តល់មូលដ្ឋានក្នុងការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ។

ការចុះឈ្មោះ និងការចុះបញ្ជី

ការធ្វើជំរឿន និងការចុះឈ្មោះអាចផ្តល់ជាព័ត៌មានអំពីទំហំ និងភាពស្មុកស្មាញលើរៀបចំផែនការតាំងទីលំនៅថ្មីដែលជាការតម្រូវឲ្យមាន (ឧទាហរណ៍ ទំហំ ការបែងចែក និងភាពចម្រុះគ្នានៃសង្គមសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋ)។ ការធ្វើជំរឿន ត្រូវធ្វើចំពោះប្រជាពលរដ្ឋទាំងអស់ទាំងអស់ដែលរងផលប៉ះពាល់មិនល្អពីគម្រោង ដោយមិនគិតពីស្ថានភាពស្របច្បាប់របស់ពួកគេ (ជាម្ចាស់ដី អ្នកជួលផ្ទះ និង ជនមកតាំងទី-លំនៅមិនស្របច្បាប់) ឬ សូម្បីតែអ្នកទើបមករស់នៅតំបន់នោះនៅពេលធ្វើជំរឿនក៏ដោយ។ ការធ្វើបែបនេះមានន័យថាការដែលប្រជាជនមិនមានកម្មសិទ្ធិដីធ្លី មិនមែនមានន័យថាពួកគេមិនមានសិទ្ធិទទួលបានជំនួយការតាំងទីលំនៅថ្មីឡើយ។ ម្ចាស់ដីឯកជន និងអ្នកមានសិទ្ធិទទួលបានដី និងអ្នកកំពុងតែរស់នៅលើដីសាធារណៈ ឬ រស់នៅលើដីរបស់អ្នកដទៃ សម្រាប់ធ្វើជាជម្រក ប្រកបរបរជំនួញ ឬ ធ្វើការងារផ្សេងទៀត ដើម្បីចិញ្ចឹមជីវិត (អ្នកមើលថែទាំមនុស្សក្នុងគ្រួសារ និង អ្នកមកតាំងទីលំនៅមិនស្របច្បាប់) គួរតែដាក់បញ្ចូលក្នុងស្ថិតិជំរឿនផងដែរ។ ក្នុងខណៈដែលមនុស្សគ្មានដីធ្លី ឬ មនុស្សមកតាំងទីលំនៅខុសច្បាប់អាចនឹងមិនមានសិទ្ធិទទួលសំណងចំពោះថ្លៃដីទេ តែគេអាចមានសិទ្ធិទទួលជំនួយគាំទ្រការតាំងទីលំនៅថ្មី និងការទូទាត់សំណងថ្លៃទ្រព្យសម្បត្តិផ្សេងៗទៀតរបស់គេ (ដូចជាការខូចខាតជម្រក និងផលដំណាំដែលគេបានដាំដុះ ស្រែចំការ ឬ ឈើសម្រាប់ធ្វជាអុស) ដែលតាមគារអនុវត្តជាក់ស្តែង វាជាការសមស្របបើសិនជាគេអាចទទួលផលប្រយោជន៍ផ្សេងៗទៀតពីការអភិវឌ្ឍន៍ អាចរួមទាំងការទទួលបានកម្មសិទ្ធិលើដីផងដែរ។

ត្រូវយកចិត្តទុកដាក់ជាពិសេសលើក្រុមមនុស្សងាយរងគ្រោះដែលរស់នៅក្នុងតំបន់នោះ។ ក្រុមងាយរងគ្រោះទាំងនោះមានដូចជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ឬ កុមារតូចៗ ជនពិការ ជនក្រីក្រ មនុស្សចាស់ជរា និង ក្រុមមនុស្សដែលទទួលរងគ្រោះពីការរើសអើងផ្នែកសង្គមនិងសេដ្ឋកិច្ច រួមទាំង ជនជាតិដើមភាគតិច និងជនជាតិភាគតិច។ ក្រុមជនងាយរងគ្រោះអាចទាមទារឲ្យមានជំនួយពិសេស ឬជំនួយបន្ថែមទាក់ទងនឹងការតាំងទីលំនៅថ្មី ដោយសារតែពួកគេមានសមត្ថភាពតិចតួច ដើម្បីដោះស្រាយបញ្ហានៃការបំលាស់ទីជាលក្ខណៈរូបវន្ត និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការតាំងទីលំនៅថ្មី បើធៀបជាមួយអ្នកដទៃដែលទទួលរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី។ ត្រូវយកចិត្តទុកដាក់ផងដែរទៅលើក្រុមមនុស្សដែលបានមកតាំងទីលំនៅលើកន្លែងដែលតម្រូវសម្រាប់ការតាំងទីលំនៅថ្មី ក្នុងពេលដែលការចុះឈ្មោះរបស់គម្រោងកំពុងតែដំណើរការ ។ ជនភៀសខ្លួន ឬជនភៀសសឹកដោយសារសង្គ្រាមស៊ីវិលមិនអាច ឬ មិនចង់ ត្រលប់ទៅកន្លែងស្រុកភូមិរបស់គេដើម្បីទាមទារដីរបស់គេវិញឡើយ បន្ទាប់ពីសង្គ្រាមបានចប់ទៅ ។ ឧទាហរណ៍នៅប្រទេសមូហ្សាំប៊ិក ក្រុមហ៊ុនអចលទ្រពមួយបានផ្តល់ជំនួយដល់ការតាំងលំនៅជាថ្មី ដល់កសិករដែលបានរត់ភៀសខ្លួនពីតំបន់គម្រោងនៅសម័យសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ ទោះបីជាពួកគេមិនបានរស់នៅក្នុងតំបន់នោះនៅពេលធ្វើជំរឿនក៏ដោយ ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រជាកសិករទាំងនោះត្រូវបានគេរាប់បញ្ចូលក្នុងចំណោមអ្នកទទួលរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី និង ទទួលបានសំណងនៅពេលគេត្រលប់មកវិញ ។ នៅក្នុងស្ថានភាពបែបនេះវាជាចាំបាច់ណាស់ដែលត្រូវបង្កើតឲ្យមានប្រព័ន្ធត្រួត-ពិនិត្យ និង បញ្ជាក់ការពិតលើការទាមទារដីរបស់ពួកគេទាំងនោះ ដែលជាទូទៅគេតែងតែពឹងទៅលើអ្នកដឹកនាំសហគមន៍ ឬ អ្នកតំណាងសហគមន៍ ដើម្បីបញ្ជាក់នូវសិទ្ធិទទួលបានដោយស្របច្បាប់។

ការដាក់កម្រិតចំពោះអ្នកទទួលផល

ការបញ្ចប់ការធ្វើជំរឿន មានន័យថាជាពេលវេលានៃការបញ្ចប់កាលបរិច្ឆេទបញ្ចប់ការផ្តល់ជំនួយស្របច្បាប់សម្រាប់ការតាំងទីលំនៅថ្មី ។ អ្វីដែលសំខាន់នោះគឺត្រូវធ្វើឲ្យសាធារណៈជនបានដឹងអំពីកាល-បរិច្ឆេទបញ្ចប់ការផ្តល់ជំនួយនេះ ។ បន្ថែមពីនេះទៀត គេត្រូវផ្តល់ដល់អ្នកដែលត្រូវតាំងទីលំនៅថ្មីនូវឯកសារដែលបញ្ជាក់អំពីការចុះឈ្មោះរបស់គេ (អត្តសញ្ញាណប័ណ្ណប្រជាជន និងឯកសារចម្លងបានពីការធ្វើជំរឿនដែលបានយល់ព្រមដោយមេគ្រួសារជាដើម)។ ការធ្វើបែបនេះជួយទប់ស្កាត់កុំឲ្យមានការហូរចូលនៃប្រជាជនថ្មី ដែលគ្មានសិទ្ធិទទួលបានសំណង មកតាំងទីលំនៅថ្មីក្នុងតំបន់គម្រោង បន្ទាប់ពីកាលបរិច្ឆេទបិទបញ្ចប់។ តែទោះបីជាយ៉ាងណាក៏ដោយ បើសិនជានៅមានចន្លោះពេលរវាងការបិទបញ្ចប់ជំរឿន និង ការអនុវត្តសកម្មភាពតាំងទីលំនៅថ្មី គួរតែបន្តធ្វើសម្រាប់ការផ្លាស់តីរបស់ប្រជាពលរដ្ឋ និងកំណើនរបស់ប្រជាពលរដ្ឋក៏ដូចជាការរីករាលដាលនៃចំនួនគ្រួសារ។

ការសិក្សាអំពីសង្គម-សេដ្ឋកិច្ច

ការធ្វើជំរឿនអាចធ្វើឡើងជាមួយនឹងការប្រមូលព័ត៌មានប្រជាសាស្ត្របន្ថែមទៀតដូចជា (អាយុ ភេទ ទំហំគ្រួសារ កំណើតថ្មី និងអ្នកស្លាប់) និងព័ត៌មានទាក់ទងនឹងសង្គម និងសេដ្ឋកិច្ច ដូចជា (ជាតិពន្ធុ សុខភាព ការអប់រំ មុខរបរ និងប្រភពប្រាក់ចំណូល) ក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់។ ព័ត៌មានទាំងនេះ ផ្តល់ការយល់ដឹងជាទូទៅ អំពីសហគមន៍រងផលប៉ះពាល់ពីគម្រោង រាប់បញ្ចូលទាំងប្រជាពលរដ្ឋជាម្ចាស់មូលដ្ឋានផង ទំហំនៃការទូទាត់សំណង និង ជំនួយក្នុងការតាំងទីលំនៅថ្មី ដែលជាជំនួយចាំបាច់ដើម្បីកាត់បន្ថយផលប៉ះពាល់មិនល្អពីគម្រោង។ ទិន្នន័យទាំងនេះអាចផ្តល់ជាមូលដ្ឋានដើម្បីឲ្យគេអាចប្រើដើម្បីសិក្សាបន្ថែមទៅលើសង្គមសេដ្ឋកិច្ច (ឧទាហរណ៍ ៖ ការសិក្សាអំពីដី និងការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិ ការវិភាគលើចរន្តប្រាក់ចំណូល ការវាយតម្លៃលើតួនាទីយេនឌ័រ និង ក្រុមងាយរងគ្រោះ ជាដើម) ដើម្បីជួយឲ្យការទូទាត់សំណងនិងយុទ្ធសាស្ត្រក្នុងការស្តារជីវភាពប្រព្រឹត្តិទៅបានល្អប្រសើរ។

ទិន្នន័យជាមូលដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ

ការធ្វើជំរឿន នឹងផ្តល់ផងដែរនូវទិន្នន័យជាបរិមាណដែលអាចជួយឲ្យមានការបែងចែកធនធាននិងសេវាកម្មផ្សេងៗ ដើម្បីត្រួតពិនិត្យលើសេវាកម្ម និងធនធានទៅដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងធ្វើកែតម្រូវចំពោះបញ្ហាក្នុងការបែងចែកធនធាន និងសេវាកម្ម ជុំវិញការអនុវត្តន៍ការតាំងទីលំនៅថ្មី។ បន្ថែមពីនេះ ព័ត៌មានដែលប្រមូលបានពីការធ្វើជំរឿន អាចផ្តល់ទិន្នន័យជាមូលដ្ឋានសំខាន់ៗនៅតាមគ្រួសារ និងសហគមន៍ ដែលទិន្នន័យនោះ អាចបង្កើតជាសូចនាករសម្រាប់ការអនុវត្តការតាំងទីលំនៅថ្មី និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការស្តារប្រាក់ចំណូលឡើងវិញ ក៏ដូចជាគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ផ្សាភ្ជាប់នឹងកម្មវិធីតាំងទីលំនៅថ្មី។

- ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិដែលបាត់បង់នៅតាមគ្រួសារ សហគ្រាស និងសហគមន៍

  អ្នកធ្វើសំណើគម្រោង ត្រូវធ្វើការស្រាវជ្រាវឲ្យលម្អិតលើការបាត់បង់ទាំងឡាយកើតឡើងចំពោះគ្រួសារ សហគ្រាស ឬ សហគមន៍រងផលប៉ះពាល់ពីគម្រោង។ ការអង្កេតស្រាវជ្រាវនោះគួរផ្តល់ព័ត៌មានលម្អិតអំពីការផ្តល់សម្បទានដី និង ការខូចខាតទ្រព្យសម្បត្តិជារូបវន្ត ក៏ដូចជាប្រាក់ចំណូល ទោះបីជាការខូចខាតបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ ដោយសារតែការផ្លាស់ទីលំនៅថ្មីនៃសមាជិកគ្រួសារពីការងារ និងប្រភពរកប្រាក់ចំណូល (ឧទាហរណ៍ អ្នកធ្វើឆ្នាំងដីត្រូវ

ចេញឆ្ងាយពីប្រភពដីឥដ្ឋ អ្នកនេសាទត្រូវចេញឆ្ងាយពីស្នឹងទន្លេ ដែលគេផ្លាប់នេសាទ និងអ្នកលក់ដូរតូចតាចត្រូវចេញឆ្ងាយពីអតិថិជន)។ គេត្រូវកត់ត្រាដោយឡែកៗពីគ្នានូវទ្រព្យសម្បត្តិរួមរបស់សហគមន៍ ដូចជាប្រភពទឹក វាលស្មៅសម្រាប់គោក្របី ប្រពន្ធ័ស្រោចស្រព និងរចនាសម្ពន្ធ័សហគមន៍ ។ ចំបាច់ត្រូវឲ្យមានការចូលរួមពីភាគីពាក់ពន្ធ័ ដើម្បីបង្កើតឲ្យមានការព្រមព្រៀងមួយសមរម្យទៅលើវិធី និងរបៀបក្នុងការកំណត់គុណតម្លៃទ្រព្យសម្បត្តិដែលខូចខាត និងប្រាក់ចំណូលដែលបាត់បង់ក្នុងពេលការតាំងទីលំនៅថ្មី។ នៅក្នុងយុត្តាធិការមួយចំនួន ចាំបាច់ត្រូវឲ្យអាជ្ញាធរមូលដ្ឋានបញ្ជាក់ឲ្យបានពិតប្រាកដអំពីទ្រព្យសម្បត្តិដែលខូចខាត ។ ទោះជាយ៉ាងណាក៏ដោយការធ្វើសារពើរភ័ណ្ឌលើទ្រពសម្បត្តិដែលបានចងក្រង ត្រូវចុះហត្ថលេខាដោយមេគ្រួសារ ដើម្បីកាត់បន្ថយលទ្ធភាពនៃការទាមទារបន្ទាប់ក្រោយមកទៀត ឬ ជម្លោះនានាទាក់ទងនឹងការទាមទារណាមួយ។ ខាងក្រោមនេះគឺជាការចាត់ថ្នាក់ប្រភេទសារពើភ័ណ្ឌសំខាន់ៗ ៖

ការប្រើប្រាស់ដី និងសមត្ថភាពរបស់ដី

ត្រូវធ្វើការសិក្សាស្រាវជ្រាវដីទាំងអស់ដែលទទួលបាន ឬ ដីប៉ះពាល់ដោយគម្រោង ទោះបីជាស្ថិតលើមូលដ្ឋានអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ត្រូវតែធ្វើការអង្កេតស្រាវជ្រាវ ចាត់ថ្នាក់តាមប្រភេទ និង កត់ត្រាទុក។ អាជ្ញាធរមូលដ្ឋាន ត្រូវចាត់ថ្នាក់ និងវាយតម្លៃតាមបែបផែនលើគុណតម្លៃនៃដី ដែលប្រើប្រាស់ (ឧទាហរណ៍ កសិកម្មធារាសាស្ត្រ ដីសម្រាប់ធ្វើស្រែប្រាំង វាលស្មៅ ព្រៃឈើ ដីសម្រាប់សាងសង់ផ្ទះ និងសម្រាប់ធ្វើជំនួញ)។ តែទោះបីជាយ៉ាងណាក៏ដោយ គេមិនត្រូវមើលរំលងភាពខុសប្លែកគ្នារវាងការប្រើប្រាស់ដីបច្ចុប្បន្ន និង តម្រូវការនៃការប្រើដីនាពេលអនាគត របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ជាពិសេសនៅត្រង់ដីដែលប្រជាពលរដ្ឋអាចដាំដំណាំឆ្លាស់គ្នាបាន ។ ប្រការនេះ ជាធម្មតាទាមទារឲ្យមានផែនទីលម្អិតទៅលើប្រភេទដី និងការវាយតម្លៃលើប្រើប្រាស់ដី និងសមត្ថភាពរបស់ដី។

ត្រូវមានការសិក្សាជាបន្តទៀត ដើម្បីគាំទ្រដល់ការប៉ាន់ប្រមាណទីលើប្រាក់ចំណូលប្រចាំឆ្នាំដែលទទួលបានពីការប្រើដី និងប្រភេទដី ដូចជាដីដែលមានប្រពន្ធ័ស្រោចស្រព ដីស្រែប្រាំង ដីមានស្រះចិញ្ចឹមត្រី និងដីមានកូនឈើព្រៃ ជាដើម។ ជាទូទៅ ការធ្វើបញ្ជីសារពើភណ្ឌលើទ្រពសម្បត្តិហុចផល ត្រូវធ្វើទៅតាមប្រភេទនិងការប្រើប្រាស់ដីនោះ ប្រាក់ចំណូលសរុបក្នុងមួយឆ្នាំក្នុងមួយហិចតា ការបាត់បង់ប្រាក់ចំណូលគ្រួសារ តម្លៃសងជំនួសតាមតម្លៃប្រៀបធៀបនៅលើទីផ្សារ និងរបៀបរបបនៃការកាន់កាប់ដី។

ផ្ទះសម្បែង និងរចនាសម្ពន្ធ័ផ្សេងទៀតនៅក្នុងផ្ទះ

រាប់បញ្ចូលទាំងតួផ្ទះ ចង្ក្រានបាយដាច់ដោយឡែក បង្គន់ ជង្រុក ក្រោលសត្វ ទ្រុងសត្វពាហនៈ និងរោងជាងសម្រាប់ជាជម្រកឧស្សាហកម្ម ហើយត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទសម្ភារសាងសង់ (ឈើ ឬស្សី ត្រែងបបុស ឬ បាយអរ បេតុងអាបេ និងដី)។ ត្រូវរួមបញ្ចូលគ្រប់រចនាសម្ព័ន្ធទាំងអស់ទៅក្នុងសារពើភ័ណ្ឌ ដោយមិនគិតថា តើរចនាសម្ព័ន្ធទាំងនោះ មានប្រជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍ ឬ គ្រាន់តែកាន់កាប់ជា បណ្តោះអាសន្ន។

ទ្រព្យសម្បត្តិរូបវន្តដទៃទៀត

រាប់បញ្ចូលទាំងអចលនទ្រព្យ មានដូចជាដំណាំដែលកំពុងលូតលាស់ ដើមឈើហូបផ្លែ រុក្ខជាតិជាចំណីសត្វ អុសដុត កូនឈើធ្វើជាឱសថ ចំការ របង អណ្តូងទឹក ប្រពន្ធ័ស្រោចស្រព និងផ្នូរខ្មោច ឬ ទីបញ្ចុះសព ជាដើម។

សហគ្រាសឯកជន

មានដូចជាហាងទំនិញ រោងជាង តូបលក់ដូរ រោងចក្រ និងទីតាំងលក់ដូរផ្សេងៗទៀត។ គេត្រូវចាត់ថ្នាក់សហគ្រាសទាំងអស់នេះទៅតាមភាពជាម្ចាស់កម្មសិទ្ធិ (មុខជំនួញឯកជន សហគ្រាសសាធារណៈ សារជីវកម្មរួមគ្នា ជាដើម) ។ គេត្រូវចុះឈ្មោះអ្នកដែលបាត់បង់សហគ្រាសរបស់ខ្លួន នយោជិតដែលបានបាត់បង់ការងារ និង អ្នកលក់ដូរដែលបាត់បង់អតិថិជន ដោយត្រូវធ្វើការប៉ាន់ប្រមាណផងដែរអំពីតម្លៃនៃការបាត់បង់ក្នុងអំឡុងពេលនៃការធ្វើការតាំងទីលំនៅថ្មី។

នៅកម្រិតសហគមន៍ ការអង្កេតសិក្សាលើទ្រព្យសម្បត្តិនានា អាចជួយឲ្យមានការធ្វើបញ្ជីសារពើ-ភ័ណ្ឌ និងការវាយតម្លៃលើការបាត់បង់ធនធានសាធារណៈ មានដូចជា ៖

ធនធានទ្រព្យសម្បត្តិរូម ៖ មានដូចជា ព្រៃឈើ និងដីព្រៃ (ប្រភពនៃឈើសំណង់ និងសម្ភារៈសិប្បកម្ម ជីវម៉ាស់ សម្រាប់ផលិតជាថាមពលប្រើប្រាស់ក្នុងផ្ទះ) និងវាលស្មៅ ជាដើម។

រចនាសម្ពន្ធ័សាធារណៈ ៖ មានដូចជា សាលារៀន មន្ទីរពេទ្យ សាលប្រជុំ ទីសក្ការៈបូជា អណ្តូងទឹក/ស្រះសហគមន៍ ស្រះទឹកសម្រាប់សត្វពាហនៈផឹក និងងូត ទឹកន្លែងរួមសម្រាប់ងូតទឹក និងបោកគក់ ចំណតរថយន្តក្រុង និងបូជនីយដ្ឋាន ជាដើម។

ទ្រព្យសម្បត្តិវប្បធម៌ ៖ មានដូចជា ស្ថានទីបុរាណវត្ថុ ទីបញ្ចុះសព បូជនីយដ្ឋាន ទីធ្វើសក្ការៈបូជា និងទីកន្លែងដែលមានលក្ខណៈពិសេសសម្រាប់សាសនា និងប្រវត្តិសាស្ត្រ។

ហេដ្ឋារចនាសម្ពន្ធ៍ ៖ គេត្រូវរាប់បញ្ចូលផងដែរនូវហេដ្ឋារចនាសម្ពន្ធ៍ទាំងអស់ ដែលនឹងត្រូវបំផ្លាញ ឬ រងផលប៉ះពាល់ដោយសារគម្រោង មានដូចជា ផ្លូវថ្នល់ ស្ពាន ប្រពន្ធ័ស្រោចស្រព និងប្រពន្ធ័បង្ហូរទឹក លូបង្ហូរទឹកសំអុយ ខ្សែបណ្តាញអគ្គិសនី និងខ្សែបណ្តាញទូរគមនាគមន៍។

ការធ្វើបញ្ជីសារពើភ័ណ្ឌលើទ្រព្យសម្បត្តិទាំងនោះ ត្រូវយោង និងពាក់ព័ន្ធគ្នាជាមួយទ្រព្យសម្បត្តិដែលមាននៅក្នុងបញ្ជីជំរឿនផងដែរ។ វាជាការល្អដែលត្រូវថតរូប កត់ត្រាទុកជាឯកសារ និងចុះបញ្ជីទ្រព្យសម្បត្តិទាំងអស់តាមគ្រួសារនីមួយៗ សហគ្រាស ឬអង្គការសហគមន៍។

- ការធ្វើអង្កេតសិក្សា និង ការសិក្សាស្រាវជ្រាវអំពីសង្គមសេដ្ឋកិច្ច អាចអនុវត្តបានចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង (រួមមានអ្នកមកស្វែងរកការងារតាមរដូវ ជនចំណាកស្រុក និងប្រជាពលរដ្ឋជាម្ចាស់មូលដ្ឋាន) ។

ក្នុងកំឡុងពេលនៃការធ្វើបញ្ជីសារពើភ័ណ្ឌ និងជំរឿនលើទ្រព្យសម្បត្តិតាមគ្រួសារ គេត្រូវប្រមូលចំនួនទិន្នន័យសង្គមសេដ្ឋកិច្ចនៃគ្រួសារនីមួយៗឲ្យបានត្រឹមត្រូវ ។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារដែលមានប្រាក់ចំណូលទាប ជាពិសេសអ្នករស់នៅតំបន់ជនបទ (ជាធម្មតា អ្នកទាំងនោះតែងតែរងផលប៉ះពាល់ពីគម្រោង) ដែលជាទូទៅតែងតែមានប្រភពចិញ្ចឹមជីវិតផ្សេងៗ និង ច្រើនយ៉ាងដែលមានទាំងរបរកសិកម្ម ការងារទទួលប្រាក់ខែ និងជំនួញខ្នាតតូច ។ ហេតុដូច្នេះហើយ ចាំបាច់ត្រូវស្រាវជ្រាវពីប្រភពចំណូលទាំងអស់នេះជាមុនសិន ទើបអាចគណនាប្រាក់ចំណូលសរុបដែលត្រូវបាត់បង់ដោយសារការបំលាស់ទីលំនៅថ្មី ។ ដោយហេតុនេះ ការសិក្សាអំពីសង្គមសេដ្ឋកិច្ចត្រូវតែប្រមូលព័ត៌មានបរិមាណបន្ថែមទៀត លើផ្នែកសំខាន់ពីរ ៖

- ប្រភពប្រាក់ចំណូលរបស់គ្រួសារ និង យុទ្ធសាស្ត្រក្នុងការចិញ្ចឹមជីវិតដែលគេមិនបានកំណត់នៅពេលធ្វើជំរឿន និងការធ្វើបញ្ជីសារពើភ័ណ្ឌលើទ្រព្យសម្បត្តិនៃគ្រួសារនីមួយៗ។
- រចនាសម្ពន្ធ ការប្រមូលផ្តុំ និងការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងសហគមន៍ទាំងមូលដែលរងផលប៉ះពាល់ពីគម្រោង។

ការវិភាគលើទិន្នន័យទាំងនេះ នឹងជួយកំណត់បានច្បាស់ពីគ្រួសារទាំងឡាយ ដែលទទួលរងផល-ប៉ះពាល់ខ្លាំងជាងគេ បណ្តាលមកពីការបំលាស់ទីជាលក្ខណៈរូបវន្ត និងសេដ្ឋកិច្ច។

ការសិក្សាអំពីសង្គមសេដ្ឋកិច្ច ត្រូវតែមានទំនាក់ទំនងយ៉ាងជិតជិតជាមួយនឹងការធ្វើជំរឿន និងការធ្វើសារពើភ័ណ្ឌលើទ្រព្យសម្បត្តិ ដើម្បីផ្តល់ជាព័ត៌មានលម្អិតអំពីប្រភពចំណូលក្នុងគ្រួសារ ដោយរាប់បញ្ចូលទាំងទ្រព្យសម្បត្តិរួមផងដែរ ។ ជំរឿន និងការធ្វើសារពើភ័ណ្ឌលើទ្រព្យសម្បត្តិត្រូវកំណត់ឲ្យបានច្បាស់ជាមុន អំពីឯកតាសង្គមជាមូលដ្ឋាននៃការផលិតផល ឬ ការរៀបចំសេដ្ឋកិច្ច។ ជាធម្មតា គ្រួសារនីមួយៗ គឺជាប្រភពនៃសេដ្ឋកិច្ច និងជាអ្នកផលិតសម្រាប់សហគមន៍ (គ្រួសារនីមួយៗ អាចមានសមាជិកក្នុងគ្រួសារ និងសាច់ថ្លៃ ឬ អ្នកផ្សេងទៀតដែលមិនមែនជាសាច់ញាតិ)។ បើប្រភពប្រាក់ចំណូលពឹងផ្អែងទាំងស្រុងទៅលើការងារកសិកម្ម និង សកម្មភាពដែលមានផ្សាភ្ជាប់នឹងកសិកម្ម គេអាចបញ្ចប់យ៉ាងទូលំទូលាយលើការសិក្សាសង្គមសេដ្ឋកិច្ច តាមរយៈការបូកបញ្ចូលគ្នារវាងទិន្នន័យនៃជំរឿន និងការទិន្នន័យទ្រព្យសម្បត្តិ ។ បន្ទាប់មកចាំបាច់ ត្រូវកំណត់បរិមាណនៃប្រាក់ចំណូលពីប្រភពចំណូលផ្សេងៗ និងតម្លៃដី និងទ្រព្យសម្បត្តិទាំងនោះ។ ព័ត៌មាននេះផ្តល់ការយល់ដឹងអំពីប្រភពចំណូលគ្រួសារ និងថាតើគេអាចបង្កើតឲ្យមានប្រភពចំណូលទាំងនោះវិញដោយរបៀបណា បន្ទាប់ពីការបញ្ចប់ការតាំងទីលំនៅថ្មី ។ ព័ត៌មាននេះ ក៏ផ្តល់ជាមូលដ្ឋានដើម្បីវាយតម្លៃលើជោគជ័យនៃការស្តារជីវភាពឡើងវិញ និង គំនិតផ្តួចផ្តើមកម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ បន្ថែមពីនេះទៀត ចាំបាច់ត្រូវរាយលម្អិតពីផលិតផល និងទិន្នន័យប្រាក់ចំណូល ទៅតាមប្រភេទយេនឌ័រ សំដៅបែងចែកដាច់បីគ្នារវាងតួនាទីរបស់បុរស និងស្ត្រី ក្នុងការកែលម្អជីវភាពគ្រួសារ និងសំដៅរៀបចំយុទ្ធសាស្ត្រសមស្រប ដើម្បីស្តារប្រាក់ចំណូលឡើងវិញ ។

ខណៈដែលប្រជាពលរដ្ឋមានសកម្មភាពផ្សេងទៀត ដែលរួមចំណែកដល់ការបង្កើនសេដ្ឋកិច្ចគ្រួសាររបស់គេ (ដូចជា ប្រាក់ចំណូលពីការធ្វើការតាមរដូវកាល ប្រាក់បញ្ជើជាប្រចាំ ឬ ប្រាក់ចំណូលបានមកពីការចិញ្ចឹមសត្វពាហនៈនៅទីតាំងចំងាយពីសហគមន៍) ការអង្កេតសិក្សាអំពីសង្គមសេដ្ឋកិច្ច ត្រូវកំណត់ឲ្យបានច្បាស់ពីប្រាក់ចំណូលដើមបានមកពីប្រភពប្រាក់ចំណូលទាំងនោះ ។ នៅតាមប្រទេសជាច្រើនលើពិភពលោកនេះ ប្រជាជននៅជនបទសុទ្ធសឹងតែជាកសិករ ។ ទោះបីជាយ៉ាងណាក៏ដោយការវិភាគបន្ថែមទៀតបានបង្ហាញឲ្យឃើញថា ប្រភពប្រាក់ចំណូលបានមកពីការងារកសិកម្មមិនគ្រប់គ្រាន់ សម្រាប់គ្រួសារទេ ហើយវាគ្រាន់តែជាផ្នែកតូចមួយនៃប្រាក់ចំណូលគ្រួសារតែប៉ុណ្ណោះ។ តាមពិតទៅប្រាក់ចំណូលគ្រួសាររបស់គេអាចរកបានពីប្រភពផ្សេងទៀត ដូចជាប្រាក់ដែលបានពីការលក់កម្លាំងពលកម្ម និង សកម្មភាពសេដ្ឋកិច្ចក្រៅប្រពន្ធ័។

ការប្រមូលទិន្នន័យបរិមាណនៅក្នុងស្ថានភាពតាំងទីលំនៅថ្មីអាចនឹងមានបញ្ហា ។ កត្តាជាច្រើនដូចជាមិនមានសំណាកធ្វើវិភាគគ្រប់គ្រាន់ បុគ្គលិកចុះសហគមន៍មិនមានបទពិសោធន៍ មិនមានចំណេះដឹង និងកិច្ចសហការរវាងប្រជាពលរដ្ឋ ការធ្វើដំណើរ និងការប្រាស័យទាក់ទង និង ការខ្វះខាតការត្រួតពិនិត្យបុគ្គលិកចុះសហគមន៍ អាចនាំឲ្យមានការលំអៀងចំពោះសំណាកធ្វើវិភាគ ក៏ដូចជាការប្រមូលទិន្នន័យ។

ដូច្នេះ ចាំបាច់ត្រូវធ្វើឲ្យមានតុល្យភាពរវាងវិធីស្រាវជ្រាវប្រមូលទិន្នន័យបែបបរិមាណ និង គុណភាពដើម្បីសិក្សាស្វែង យល់ឲ្យបានលម្អិតអំពីចរន្តប្រាក់ចំណូលរបស់សប្រជាពលរដ្ឋតាមដែលអាចធ្វើទៅបាន។

- ការវិភាគលើការអង្កេតសិក្សា និងការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតមាត្រដ្ឋានក្នុងការទូទាត់សំណង បង្កើតឲ្យមានការស្តារប្រាក់ចំណូលឡើងវិញ និងគំនិតផ្តួចផ្តើមការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដើម្បីកំណត់ឲ្យបានច្បាស់ពីសូចនាករជាមូលដ្ឋាន សម្រាប់ការតាមដានត្រួតពិនិត្យ។

ការវិភាគទិន្នន័យដែលប្រមូលបានពីការធ្វើជំរឿន ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រពសម្បត្តិ និងការសិក្សាអំពីសង្គមសេដ្ឋកិច្ច ផ្តល់ប្រយោជន៍៣យ៉ាង ដូចជា ៖

- ផ្តល់ព័តិមានដែលចាំបាច់ ដើម្បីបង្កើតតារាងម៉ាទ្រិចបង្ហាញអំពីអ្នកដែលមានសិទ្ធិទទួលសំណងនៅកម្រិតគ្រួសារ និងសហគមន៍។
- លាតត្រដាងព័តិមានចាំបាច់ជាមូលដ្ឋានស្តីពីសង្គម និងសេដ្ឋកិច្ច ដើម្បីបង្កើតឲ្យមានការស្តារជីវភាពឡើងវិញ និងការអន្តរាគមន៍នៃការអភិវឌ្ឍន៍។
- ផ្តល់សូចនាករដែលអាចវាយតម្លៃជាបរិមាណបាន អំពីប្រជាសាស្ត្រ សេដ្ឋកិច្ច ការសិក្សាអប់រំ មុខរបរជួញដូរ និងសុខភាព ដើម្បីធ្វើការតាមដានត្រួតពិនិត្យ និងវាយ-តម្លៃនាពេលអនាគត លើការអនុវត្តការតាំងទីលំនៅថ្មី។

ទិន្នន័យតាមគ្រួសារ អាចត្រូវបានប្រមូលចងក្រង ដើម្បីធ្វើការប្រៀបធៀបការត្រលប់ទៅធ្វើការវិញ ឬ ការវិនិយោគលើជម្រើសនៃចរន្តប្រាក់ចំណូលផ្សេងៗទៀត (ឧទាហរណ៍ ការងារស្រែចំការការចិញ្ចឹមសត្វ ឬ ការធ្វើពាណិជ្ជកម្ម ជាដើម) ។ យើងត្រូវការព័តិមានទាំងនេះ ដើម្បីបង្កើតឲ្យមានវិធានការស្តារជីវភាពឡើងវិញ សម្រាប់គ្រួសារ និងសហគមន៍ដែលរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី។ ប្រហាក់ប្រហែលគ្នានេះដែរ គេត្រូវការយល់ដឹងបន្ថែមលើការវាយតម្លៃលើទ្រពសម្បត្តិដែលខូចខាត ដោយសារផលប៉ះពាល់របស់គម្រោង ក្នុងបរិបទសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ជារួម។ ទិន្នន័យតាមគ្រួសារអាចនឹងត្រូវបែងចែកដាច់ពីគ្នា ដើម្បីកំណត់ឲ្យបានច្បាស់ពីកម្រិតសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌសហគមន៍ (ក្រុមគ្រួសារក្រីក្រ និងងាយរងគ្រោះបំផុត គ្រួសារដែលពឹងលើប្រាក់បញ្ញើជាប្រចាំ ជាដើម) និងកំណត់ឲ្យបានច្បាស់ពីជំនួយសមស្រប ក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។

ការសិក្សាអំពីសង្គមសេដ្ឋកិច្ច អាចលាតត្រដាងពីព័តិមានសំខាន់អំពី ថាតើសហគមន៍ដែលរងផលប៉ះពាល់ត្រូវបានរៀបចំ និងដំណើរការយ៉ាងដូចម្តេច។ ការសិក្សាទាំងនេះ អាចផ្តល់ឲ្យយើងយល់ដឹងអំពីភាពជាអ្នកដឹកនាំ និង ដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសហគមន៍រងផលប៉ះពាល់ ដែលសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំនោះអាចដំណើរការដោយឯករាជ្យ ជាមួយនឹងរចនាសម្ពន្ធ័នយោបាយ និង រដ្ឋបាលដែលមានជាទូទៅ ។ ការសិក្សានេះក៏អាចជួយកំណត់ឲ្យបានច្បាស់ផងដែរនូវបណ្តាញគាំទ្រសង្គមដែលមានសារៈប្រយោជន៍ដល់ការរស់រានរបស់សហគមន៍ និង ជាពិសេសសមាជិកសហគមន៍ងាយរងគ្រោះជាច្រើនដទៃទៀត។

- ការចូលរួមពីភាគីពាក់ពន្ធ័ ជាពិសេសការចូលរួមនៅក្នុងដំណាក់កាលកាត់បន្ថយផលប៉ះពាល់ និងឱកាសក្នុងការអភិវឌ្ឍន៍ ក្នុងដំណាក់កាលនៃការរៀបចំផែនការតាំងទីលំនៅថ្មី ទាមទារឲ្យមានការចូលរួម និងពិគ្រោះយោបល់យ៉ាងសកម្មពីភាគីពាក់ពន្ធ័។ គណៈកម្មការដែលជាអ្នក

តំណាងសហគមន៍អាចដើរតួនាទីជាមនុស្សសំខាន់ សម្រាប់ការពិគ្រោះយោបល់លើប្រភេទជំនួយដែលត្រូវបានស្នើ ក៏ដូចជាការចូលរួមបន្ទាប់ក្រោយមកទៀតពីសហគមន៍ ក្នុងការអនុវត្តការតាំងទីលំនៅថ្មី។គេត្រូវពិភាក្សាជាមួយម្ចាស់សហគមន៍មូលដ្ឋានដែលទទួលផលប៉ះពាល់ពីការសម្រេចចិត្តលើការតាំងទីលំនៅថ្មីនោះផងដែរ។

ផលប៉ះពាល់ពីគម្រោងអាចពន្យារលើសពីចំនួនដាច់ពីគ្នានៃគ្រួសារនីមួយៗ រហូតទៅដល់សហគមន៍ទាំងមូល។ ស្ថានភាពបែបនេ នាំឲ្យមានផលប៉ះពាល់ដល់ទំនាក់ទំនងសេដ្ឋកិច្ចនិងសង្គមរបស់សហគមន៍ទាំងមូលហើយគេមិនអាចទូទាត់សំណងលើផលប៉ះពាល់ទាំងនោះ ដោយគ្រាន់តែបង្កើតប្រភពប្រាក់ចំណូលថ្មីប៉ុណ្ណោះទេ ឧទាហរណ៍ការផ្តល់ផលចំណេញដល់ការរួមសហការរបស់កសិករត្រូវធ្លាក់ចុះ បន្ទាប់ពីការផ្លាស់ប្តូរពីសមាជិកគ្រួសារមួយចំនួនត្រូវបំលាស់ទីជារូបវន្តដោយសារគម្រោង។ ការចូលរួមពីភាគីពាក់ព័ន្ធពិតជាមានសារៈសំខាន់ណាស់ ក្នុងការដោះស្រាយផលប៉ះពាល់ដែលចេះតែបន្តែមកើតមាន។

ជាទូទៅ ការអន្តរាគមន៍លើអភិវឌ្ឍន៍ ជាប់ទាក់ទងនឹងផលិតកម្ម ឬ ការធ្វើប្រពលភាពផលិតផលនៃចរន្តប្រាក់ចំណូលដែលមានស្រាប់ តាមរយៈការពង្រីកកសិកម្មដែលមានប្រពន្ធ័ស្រោចស្រពរួចជាស្រេចការសាងសង់ឃ្លាំងស្តុក ការគាំទ្រផ្នែកឥណទានខ្នាតតូចនិងការបង្កើតយុទ្ធសាស្ត្រទីផ្សារនិងកិច្ចសហការរួម ឬ ការផ្សព្វផ្សាយពីផលិតផល និងសហគ្រាសថ្មី។ ត្រូវគិតគូរផងដែរចំពោះភាពមានការងារធ្វើ តាមរយៈគម្រោង ទាំងក្នុងដំណាក់កាលចាប់ផ្តើម រហូតដល់ដំណាក់កាលប្រតិបត្តិការយូរអង្វែង ដែលជាផ្នែកមួយនៃកញ្ចប់ការអភិវឌ្ឍន៍ទាំងមូល ។

បន្ថែមលើការស្តារ និងធ្វើឲ្យប្រសើរឡើងនូវជីវភាព ការតាំងទីលំនៅថ្មីអាចផ្តល់ឱកាសដល់សហគមន៍ដែលរងផលប៉ះពាល់ឲ្យធ្វើឲ្យប្រសើរដល់ការសង់លំនៅដ្ឋានរបស់ខ្លួន ហេដ្ឋារចនាសម្ពន្ធ័ និង សេវាសាធារណៈ ក៏ដូចជាអាចជួយឲ្យពួកគេអាចចូលរួមពាក់ព័ន្ធ ក្នុងការរៀបចំផែនការប្រើប្រាស់ដី ដែលអាចរួមចំណែកក្នុងការសម្រេចបានគោលបំណងនៃការអភិវឌ្ឍន៍របស់គ្រួសារនីមួយៗ និងសហគមន៍ទាំងមូលក្នុងរយៈពេលយូរអង្វែង។

ដរាបណាមានការកំណត់បានច្បាស់លាស់ពីឱកាសនៃការអភិវឌ្ឍន៍ នោះចាំបាច់ត្រូវបង្កើតឲ្យមានកិច្ចអន្តរាគមន៍សមស្រប ដោយមានកិច្ចសហការស្មិតរមួតរវាងអ្នកទទួលផល អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។ កិច្ចអន្តរាគមន៍លើការអភិវឌ្ឍន៍ដែលបានស្នើឡើង នឹងទាមទារឲ្យមានការចងក្រងជាឯកសារ ប្រហាក់ប្រហែលនឹងផែនការតាំងទីលំនៅថ្មី ពោលគឺគ្រោងពេលវេលានៃការអនុវត្ត ការទទួលខុសត្រូវច្បាស់លាស់ និង មានប្រសិទ្ធភាពរបស់ស្ថាប័ន កម្មវិធីសម្រាប់ការចូលរួម និងពិគ្រោះយោបល់របស់ភាគីពាក់ពន្ធ័ យន្តការដោះស្រាយទំនាស់ និងការដោះស្រាយបញ្ហាផ្សេងៗ គ្រោងថវិកាលម្អិត គ្រោងពេលវេលាសម្រាប់ការតាមដានត្រួតពិនិត្យ និង វាយតម្លៃ ក៏ដូចជាយន្តការសម្រាប់អនុវត្តចំណាត់ការកែតម្រូវ ដែលបានកណត់ឃើញក្នុងពេលវាយតម្លៃ។

៥.៣.២.២ បទដ្ឋានគតិយុត្តិ

បទដ្ឋានគតិយុត្តិនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) បរិយាយអំពីច្បាប់ ក្រិតក្រមគោលនយោបាយ និងបទបញ្ជាផ្សេងៗ ពាក់ព័ន្ធនឹងសកម្មភាពនៃការតាំងទីលំនៅថ្មី ដែលទាក់ទងនឹងគម្រោង។ប្រទេសជាច្រើនមានការបង្កើតច្បាប់ និងគោលនយោបាយគ្របដណ្តប់លើអស្សាមិករណ៍ដី និងការទូទាត់សំណងចំពោះទ្រពសម្បត្តិរងផលប៉ះពាល់ ។ ទោះយ៉ាងណា គោលនយោបាយស្តីពីការតាំងទីលំនៅថ្មី ជារឿយៗត្រូវតែកំណត់អត្ថន័យឲ្យបានច្បាស់លាស់ បើមិនដូច្នេះទេ នឹងកើតមានភាពខ្វះចន្លោះ

ជាមិនខាន។ ដូច្នេះ ការប្រើប្រាស់បទដ្ឋានជានិយាមលក្ខណៈអន្តរជាតិ ដែលបានបង្កើតបានឡើយយ៉ាងល្អ គឺមានលក្ខណៈសមស្រប ក្នុងក្របខ័ណ្ឌនៃបទដ្ឋានគតិយុត្តរបស់ប្រទេសនីមួយៗ ៖

- ទំហំនៃអំណាចការត្រួតត្រាយ៉ាងធំធេង និងលក្ខណៈនៃការទូទាត់សំណង គឺរួមទាំងនីតិវិធីសម្រាប់វាយតម្លៃលើគុណតម្លៃការទូទាត់សំណង និង គម្រោងពេលវេលាសម្រាប់ធ្វើការទូទាត់សំណង។
- នីតិវិធីផ្លូវច្បាប់ និងរដ្ឋបាលដែលអាចយកមកអនុវត្តបាន រួមទាំងនីតិវិធីបណ្តឹងសាទុក្ខ និងពេលវេលាជាប្រក្រតីសម្រាប់នីតិវិធីនេះ។
- ការផ្តល់កម្មសិទ្ធិដីធ្លី នីតិវិធីក្នុងការចុះបញ្ជីដីធ្លី។
- ច្បាប់ និងបទបញ្ជាផ្សេងៗ ទាក់ទងនឹងភ្នាក់ងារទទួលខុសត្រូវលើការអនុវត្តការតាំងទីលំនៅថ្មី និងបទបញ្ជាទាក់ទងនឹងការទូទាត់សំណងជាដី សាមគ្គីភាព ការប្រើប្រាស់ដី បរិស្ថាន ការប្រើប្រាស់ទឹក និងសុខមាលភាពសង្គម។

ត្រូវយកចិត្តទុកដាក់ចំពោះការគោរពទំនៀមទម្លាប់ និង ប្រពៃណីមូលដ្ឋាន ដែលមាននៅតាមសហគមន៍រងផលប៉ះពាល់។

បទដ្ឋានគតិយុត្តផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ធាតុសំខាន់៣ នៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP) ៖

- ការកំណត់អត្រានៃការទូទាត់សំណង។
- ការកំណត់ពីសិទ្ធិស្របច្បាប់សម្រាប់ការទូទាត់សំណង និងជំនួយនៃការតាំងទីលំនៅថ្មី រួមទាំងគម្រោងផ្តួចផ្តើមគំនិត សំដៅធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពសង្គម និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់។
- ការបង្កើតយន្តការដើម្បីដោះស្រាយសាទុក្ខផ្សេងៗ ក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ទាក់ទងនឹងការទូទាត់សំណង និងសិទ្ធិទទួលបានដោយស្របច្បាប់។

៥.៣.២.៣ បទដ្ឋាននៃការទូទាត់សំណង

បទដ្ឋាននៃការទូទាត់សំណងបញ្ជាក់ពីទម្រង់ទាំងអស់នៃភាពជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិ និងសិទ្ធិប្រើប្រាស់ ក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង និង យុទ្ធសាស្ត្រសម្រាប់ការទូទាត់សំណងដល់ប្រជាពលរដ្ឋទាំងនោះ ចំពោះការបាត់បង់មួយចំណែក ឬ ទាំងស្រុងនៃទ្រព្យសម្បត្តិទាំងនោះ។ បទដ្ឋាននៃការទូទាត់សំណង គួររួមបញ្ចូលការបរិយាយលើចំនុច ដូចខាងក្រោម ៖

- គោលការណ៍ផ្តល់សំណងណាមួយដែលបានបង្កើតឡើងដោយរដ្ឋាភិបាលម្ចាស់ផ្ទះ។
- បើគ្មានគោលការណ៍ណាមួយត្រូវបានបង្កើតទេ អ្នកធ្វើសំណើគម្រោងនឹងប្រើវិធីសាស្ត្រដើម្បីវាយតម្លៃពីការបាត់បង់នានា។
- ប្រភេទដែលបានស្នើ និងកម្រិតនៃការទូទាត់សំណងដែលត្រូវសង។
- លក្ខណៈស្របច្បាប់សម្រាប់ការទូទាត់សំណង និងការផ្តល់ជំនួយ។
- របៀប និងពេលវេលាដែលនឹងត្រូវទូទាត់សំណង។

ការទូទាត់សំណង មានបរិយាយនៅក្នុង (ផ្នែកទី៦) នៃសៀវភៅបណ្តុះបណ្តាលនេះ។

ប្រអប់អត្ថបទ ៥៥ ការទូទាត់សំណងលើដី ដោយដី

គួរតែផ្តល់ជម្រើសនៃការតាំងទីលំនៅថ្មីដោយពឹងផ្អែកលើដី ទៅដល់ប្រជាពលរដ្ឋដែលផ្លាស់ទីជម្រក ដែលការចិញ្ចឹមជីវិតរបស់ពលរដ្ឋទាំងនោះពឹងផ្អែកលើការប្រើប្រាស់ដី (ឧបមាដូចជាកសិករ និង អ្នកចិញ្ចឹមសត្វ)។ ជម្រើសទាំងនេះ អាចរួមបញ្ចូលការតាំងទីលំនៅថ្មីនៅលើ ឬ ទទួលបានដីទទួលបាន ឬ ទិញបានសម្រាប់ការតាំងទីលំនៅ។ ប្រភេទនៃការទូទាត់សំណងដី ជាដី ត្រូវយកចិត្តទុកដាក់លើចំនុចដូចខាងក្រោម ៖

- ការដោះដូរជាដី គួរតែមានលក្ខណៈស្មើ ឬ មានសក្តានុពលដែលឲ្យផលច្រើន ល្អប្រសើរជាងដីដែលពួកគាត់នឹងត្រូវផ្លាស់ទីទៅកាន់។
- ការដោះដូរជាដី គួរតែស្ថិតនៅក្នុងទីតាំងសមស្របប្រហាក់ប្រហែលនឹងដី ដែលប្រជាពលរដ្ឋនឹងផ្លាស់ទីទៅកាន់។
- ការដោះដូរជាដី គួរតែផ្តល់ឲ្យដោយឥតគិតប្រាក់ម្រៃលើចំណាយនៃការដោះស្រាយ ដូចជាការចុះបញ្ជីដោយឥតគិតកម្រៃ ការផ្ទេរពន្ធអាករ ឬ ពន្ធគយ។
- ការដោះដូរជាដី គួរតែរៀបចំឡើង (ដោយលក្ខណៈច្បាស់លាស់ មានស្ថានភាពស្មើ នឹងងាយស្រួលទទួលបាន) សម្រាប់ស្ថានភាពដែលមានផលច្រើនប្រហាក់ប្រហែលនឹងស្ថានភាព នៃដីដែលប្រជាពលរដ្ឋបានផ្លាស់ទីចេញ (យល់ឃ្លគួរតែបង់ថ្លៃជូនពលរដ្ឋរងផលប៉ះដោយសារគម្រោង ឲ្យធ្វើកិច្ចការនេះ)។

នៅក្នុងស្ថានភាពមានដីស្រាប់ ដែលអាចភ្ជួរដាំដំណាំបានសម្រាប់ទូទាត់សំណង គឺមានលក្ខណៈខុសគ្នាជាមូលដ្ឋានពីដីដែលប្រជាពលរដ្ឋបានផ្លាស់ទីចេញ គម្រោងគួរតែផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជំនួយសមស្របនានាដល់កសិករ ដើម្បីឲ្យទទួលបានដីដែលមានសក្តានុពលដែលឲ្យផលបានពេញ-លេញ។

នៅក្នុងស្ថានភាពគ្មានដីមានស្រាប់ដែលអាចភ្ជួរដាំដំណាំបាន គម្រោងគួរតែផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ (ដូចជា ៖ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ថវិកាផ្គត់ផ្គង់ ឬ ឥណទានសម្រាប់ចាប់ផ្តើមសហគ្រាស) ដើម្បីកែសម្រួលដល់មុខរបរក្រៅពីកសិកម្ម ដែលជាផ្នែកមួយនៃជំនួយសម្រាប់ការតាំងទីលំនៅរបស់ពលរដ្ឋទាំងនោះ ។ គោលការណ៍ដូចគ្នា ត្រូវអនុវត្តចំពោះប្រជាពលរដ្ឋដែលមានរបរចិញ្ចឹមជីវិតជាអ្នកចិញ្ចឹមសត្វ ប៉ុន្តែសម្រាប់អ្នកដែលគ្មានដីវាលសមរម្យ ឬ ដីដែលមានស្មៅសម្រាប់សត្វស៊ីជាអាហារ។

ទោះបីជាមានការលើកទឹកចិត្តចំពោះការដោះដូរដី ដែលជារឿយៗល្អជាងការមិនដោះដូរ ក៏តម្រូវឲ្យមានការអន្តរាគមន៍ និងគាំទ្ររយៈពេលវែងដោយអ្នកធ្វើសំណើគម្រោងចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ ចំពោះដីដែលមិនមានស្រាប់ ឬដីដែលមានគុណភាពទាបជាងដីដែលបាត់បង់។

៥.៣.២.៤ ការផ្តល់ជំនួយលើការតាំងទីលំនៅថ្មី និងការស្តារជីវភាពរស់នៅឡើងវិញ

គួររៀបចំផែនការ និង អនុវត្តការតាំងទីលំនៅថ្មី ឲ្យស្របតាមគម្រោងផ្តួចផ្តើមគំនិតអភិវឌ្ឍន៍ដែលផ្តល់ឱកាសដល់អ្នកផ្លាស់ទីជម្រកបានចូលរួមក្នុងការរៀបចំផែនការ និងអនុវត្តសកម្មភាពនៃការតាំងទីលំនៅថ្មី ក៏ដូចជាដើម្បីស្តារ និងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពលរដ្ឋទាំងនោះ ។ ចំនុចនេះទាមទារឲ្យមានចំណាត់ការ ដូចខាងក្រោម ៖

- ផ្តល់ព័តមានដល់ប្រជាពលរដ្ឋរងផលប៉ះពាល់អំពីជម្រើស និងសិទ្ធិរបស់ពួកគេទាក់ទងនឹងការតាំទីលំនៅថ្មី។
- ផ្តល់ជម្រើសបច្ចេកទេស និង សេដ្ឋកិច្ច ដែលអាចធ្វើបានសម្រាប់ការតាំងទីលំនៅថ្មី ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយពលរដ្ឋរងផលប៉ះពាល់ និងការវាយតម្លៃពីជម្រើសនៃការតាំងទីលំនៅថ្មី ដែលអាចជំនួសបាន។
- នៅទីកន្លែងណាដែលតម្រូវឲ្យមាន ឬ មិនតម្រូវឲ្យមានការតាំងទីលំនៅថ្មីជាលក្ខណៈរូបវន្ត ត្រូវផ្តល់ឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់នូវការទូទាត់សំណងយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពតាមតម្លៃនៃការដោះដូរពេញលេញ ចំពោះការបាត់បង់ទ្រពសម្បត្តិដោយសារសកម្មភាពរបស់គម្រោង។
- ទីកន្លែងណាដែលចាំបាច់តម្រូវឲ្យមានការតាំងទីលំនៅថ្មីជាលក្ខណៈរូបវន្ត ត្រូវផ្តល់ជំនួយរួមជាមួយការចំណាយលើការតាំងទីលំនៅ (ប្រាក់ឈ្នួលក្នុងការរុះរើ ការដឹកជញ្ជូន ជំនួយពិសេស និងការគាំពារសុខភាពសម្រាប់ក្រុមងាយរងគ្រោះ) ។
- ទីកន្លែងណាដែលចាំបាច់តម្រូវឲ្យមានការតាំងទីលំនៅថ្មីជាលក្ខណៈរូបវន្ត ត្រូវផ្តល់ទីជម្រកបណ្តោះអាសន្ន ទីតាំងសាងសង់ទីជម្រកជាអចិន្ត្រៃយ៍ និងធនធានផ្សេងៗ (ជាសាច់ប្រាក់ ឬ មិនមែនជាសាច់ប្រាក់) សម្រាប់សាងសង់លំនៅដ្ឋាន ទីតាំងកសិកម្ម ដែលរាប់បញ្ចូលទាំងទីតាំងដែលមានសក្តានុពលដែលអាចផ្តល់ផលច្រើន ផ្តល់អត្ថប្រយោជន៍ ព្រមទាំងកត្តាផ្សេងៗទៀត យ៉ាងហោចណាស់មានស្ថានភាពស្មើនឹងអត្ថប្រយោជន៍នៃទីតាំងចាស់។
- ត្រូវផ្តល់ឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់នូវជំនួយហិរញ្ញវត្ថុបណ្តោះអាសន្ន (ដូចជា ការងារយៈពេលខ្លី ការគាំទ្រជីវភាព ឬការរក្សាឲ្យមានប្រាក់បៀវត្សរ៍)។
- ត្រូវផ្តល់ឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់នូវជំនួយអភិវឌ្ឍន៍បន្ថែម លើការទូទាត់សំណងសម្រាប់ ការបាត់បង់ទ្រពសម្បត្តិផ្សេងៗ។

ប្រអប់អត្ថបទ ៥.៦ ៖ ករណីសិក្សាលើទំនប់វារីអគ្គិសនីពីរ ៖ Shuikou និង Yantan ស្តីពីការតាំងទីលំនៅយ៉ាងល្អ និងការស្តារប្រាក់ចំណូលឡើងវិញ ក្នុងប្រទេសចិន

ប្រទេសចិនត្រូវបានចាត់ទុកថា ជាប្រទេសនាំមុខគេនៅក្នុងតំបន់ ក្នុងការអនុវត្តកម្មវិធីតាំងទីលំនៅថ្មី។ ទំនប់វារីអគ្គិសនីស៊ុយគូ (Shuikou) នៅប្រទេសចិន មានប្រជាពលរដ្ឋចំនួន៦៧០០០នាក់ ត្រូវបានផ្លាស់ទីចេញពីតំបន់ជ្រលងភ្នំ និង ១៧០០០នាក់ទៀត ពីក្រុងណានភីង (Nanping) ផ្លាស់ទីចេញពីផ្នែកខាងលើចុងអាងស្តុកទឹក ដើម្បីធ្វើជាផ្លូវសម្រាប់ជាទំនប់ការពារទឹក ដែលបញ្ចៀសកុំឲ្យមានការបំលាស់ទីប្រជាពលរដ្ឋចំនួនជាង២០០០០០នាក់ បន្ថែមទៀត។ ការផ្លាស់ទីជម្រកទាំងអស់ត្រូវបានធ្វើចប់រួចរាល់ត្រឹមឆ្នាំ១៩៩២ ។ ទោះបីនៅក្នុងផែនការដើមនៃការតាំងទីលំនៅថ្មី បានអំពាវនាវឲ្យមានការប្រើប្រាស់កសិកម្មជាលក្ខណៈប្រពៃណីដើម្បីធ្វើនីតិសម្បទាឡើងវិញ ចំពោះអ្នកដែលផ្លាស់ទីជម្រកទាំងនោះចំនួន៧៥% តាមជាក់ស្តែងមានប្រជាពលរដ្ឋ៧៥% ត្រូវបានធ្វើនីតិសម្បទាឡើងវិញតាមមធ្យោបាយផ្សេងៗ។ មន្ត្រីរដ្ឋាភិបាលមូលដ្ឋានបានបង្កើតដោយគឃ្លើននូវអាងស្តុកទឹកសម្រាប់ជលផល ជម្រកអយស្ទ័រ ដំណាំ ហូបផ្លែ និងផលឈើ ទីប្រជុំជនតូចៗ និងសហគ្រាសនៅតាមភូមិ និងការជ្រើសរើសវិនិយោគិនបរទេស ដើម្បីបង្កើតរោងចក្រ ដើម្បីផ្តល់ការងារធ្វើដល់អ្នកតាំងទីលំនៅ ។

ប្រាក់ចំណូលរបស់អ្នកផ្លាស់ទីជម្រក ត្រូវបានវិលមកកំរិតដូចដើមវិញត្រឹមឆ្នាំ១៩៩៤ និងកើនឡើង ៥៥%នៅត្រឹមឆ្នាំ១៩៩៦ ស្ទើរតែទ្វេរមួយជាពីរនៃកំណើនប្រាក់ចំណូលរបស់អ្នកផ្លាស់តីជម្រក។ ការអនុវត្តការតាំងទីលំនៅតាមបែបជាការផ្តល់ឱកាស អភិវឌ្ឍន៍ បាននាំទៅសម្រេចបានលទ្ធផលជោគជ័យស្ទើរតែទាំងស្រុង ចំពោះការតាំងទីលំនៅថ្មីក្នុងចំណោមករណីសិក្សាលើគម្រោងនានា។

ទំនប់វារីអគ្គិសនីយ៉ាន់តាន់ (Yantan) នៃប្រទេសចិន មានប្រជាពលរដ្ឋចំនួន៤៣០០០នាក់ត្រូវបានផ្លាស់ទី ហើយបង្កផលប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់របស់ប្រជាពលរដ្ឋចំនួន១៩០០០នាក់ផ្សេងទៀត។ ទំនប់យ៉ាន់តាន់ ស្ថិតនៅក្នុងតំបន់ជនបទ និងជាតំបន់ដាច់ស្រយាលមួយ ដែលមិនបានទទួលអត្ថប្រយោជន៍ពីការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចតំបន់ឡើយ ។ យ៉ាងណាក៏ដោយ ប្រាក់ចំណូល របស់អ្នកតាំងទីលំនៅថ្មីមានការកើនឡើង និងត្រូវបន្តែមលើសពីអត្រាប្រាក់ចំណូលដែលពួកគេទទួលបានរហូតឈានដល់កំរិតដែលបានកំណត់។ បន្តែមពីលើនេះ រដ្ឋាភិបាលបានរៀបចំឲ្យមានការផ្ទេរប្រជាពលរដ្ឋពី ៣-៥ពាន់គ្រួសារ ឲ្យទៅរស់នៅតំបន់ភោគទ្រពចំការអំពៅចំនួនពីរតំបន់ និង ទៅតំបន់ កសិដ្ឋានរបស់រដ្ឋមួយទៀតស្ថិតនៅផ្នែកមួយនៃខេត្ត ។ ចំណូលជាមធ្យមក្នុងចំណោមអ្នកតាំងទីលំនៅទាំងនោះ បានកើនឡើងឆាប់រហ័សបំផុត។

ប្រភព ៖ ការិយាល័យប្រតិបត្តិការ និងវាយតម្លៃនៃធនាគារពិភពលោក (ឆ្នាំ២០០០) ។ ការតាំងទី-លំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ៖ បទពិសោធនៃទំនប់វារីអគ្គិសនីខ្នាតធំ ។

មិនត្រូវអនុវត្តការសម្បទានដី និង ទ្រពសម្បត្តិផ្សេងៗទៀត លុះត្រាតែការទូទាត់សំណងត្រូវបានធ្វើឡើង ។ ចំណែកនៅទីកន្លែងណាដែលទីតាំងនៃការតាំងទីលំនៅថ្មីអាចអនុវត្តបាន ត្រូវផ្តល់ប្រាក់ឈ្នួលដល់អ្នកផ្លាស់ទីទាំងនោះសម្រាប់ចំណាយលើការរុះរើ ។ នៅក្នុងស្ថានភាពខ្លះ កិច្ចការមួយចំនួនទាក់ទងនឹងការតាំងទីលំនៅថ្មី ត្រូវតែឆ្លងកាត់ការទទួលខុសរបស់ក្រុមហ៊ុនចុះកិច្ចសន្យា (ដូចជាការត្រៀមរៀបចំទីកន្លែងសម្រាប់ការតាំងទីលំនៅថ្មី ការផ្តល់សេវាកម្មសង្គមជាបណ្តោះអាសន្ន និងការដឹកជញ្ជូន) នោះអ្នកធ្វើសំណើរគម្រោងគួរតែធ្វើឲ្យប្រាកដថា ការចាត់ចែងត្រូវតែមានលក្ខណៈសមស្រប ដូចជាការខុសច្បាប់ដាក់ជាទោសបញ្ញត្តចំពោះការមិនអនុវត្តតាម ត្រូវសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងកិច្ចសន្យា និងពង្រឹងការអនុវត្ត ។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងស្ថានភាពខ្លះនៅពេលដែលរដ្ឋាភិបាលជាម្ចាស់ផ្ទះធ្វើជាអ្នកកាន់កាប់ការទទួលខុសត្រូវសម្រាប់ការតាំងទីលំនៅថ្មី តាមរយៈការគាំទ្រផ្នែកហិរញ្ញវត្ថុបានពីអ្នកធ្វើសំណើគម្រោង នោះអ្នកធ្វើសំណើគម្រោងគួរធ្វើការចចារលើកិច្ចព្រមព្រៀងអនុវត្តផ្នែកតាមការបំពេញការងារជាមួយភ្នាក់ងាររដ្ឋាភិបាលដែលមានសមត្ថកិច្ច តាមរយៈការតភ្ជាប់ការបើកប្រាក់ចំណាយជាទម្រង់ទូទាត់បណ្តើរៗ ទៅនឹងការសម្រេចបាននូវផែនការសកម្មភាពគោលដៅដែលបានព្រមព្រៀងរួចហើយ។

ការតាំងទីលំនៅថ្មីជាប់ពាក់ព័ន្ធនឹងការផ្លាស់ទីជាលក្ខណៈរូបវន្តនៃប្រជាជន ត្រូវមានសមាសភាគដូចខាងក្រោម ៖

- ការជ្រើសទីតាំង និងការត្រៀមរៀបចំ។
- ការគ្រប់គ្រងការហូរចូលយ៉ាងគំហុក។
- គម្រោងពេលវេលា និងជំនួយដល់ការតាំងទីលំនៅថ្មី។
- ការដោះដូរនៃសេវាកម្ម និងសកម្មភាពជំនួញនានា។
- ការស្តារជីវភាពឲ្យបានល្អប្រសើរឡើងវិញ។
- ការដោះស្រាយដោយទទួលយកទ្រពសម្បត្តិវិញ្ញធម៌។

- ជំនួយជាពិសេសសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ។

ការជ្រើសរើសទីតាំងសម្រាប់តាំងទីលំនៅថ្មី និងការត្រៀមរៀបចំ

គេត្រូវជ្រើសរើសទីតាំងសម្រាប់ការតាំងទីលំនៅថ្មី ត្រូវធ្វើឡើងតាមការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋទាំងអស់ដែលត្រូវធ្វើបំលាស់ទី និងប្រជាពលរដ្ឋជាម្ចាស់សហគមន៍។ យើងត្រូវវាយតម្លៃលើធនធាននិងផែនការសម្រាប់ការប្រើប្រាស់ដី ។ ការជ្រើសរើសទីតាំងសម្រាប់ការតាំងលំនៅថ្មី និងជម្រើសក្នុងការសាងសង់ទិជម្រក និង ហេដ្ឋារចនាសម្ពន្ធ ត្រូវតែឆ្លុះបញ្ចាំងអំពីការពេញចិត្តរបស់ប្រជាពលរដ្ឋ និងជាឱកាសដ៏ល្អបំផុតសម្រាប់ការស្តារជីវភាពថ្មីឲ្យបានទាន់ពេលវេលា ។ ត្រូវពិចារណាឲ្យបានល្អិតល្អន់ចំពោះចំនុចជាក្តីកង្វល់សំខាន់ពីរគឺទីតាំងសម្រាប់តាំងទីលំនៅថ្មី និងការការពារដល់សហគមន៍។ ការជ្រើសរើសទីតាំងថ្មីសម្រាប់តាំងទីលំនៅដែលអាចផ្តល់ឲ្យប្រជាពលរដ្ឋនូវធនធានហុចផល (ដីដែលអាចដាំដំណាំបាន និងវាលស្មៅសម្រាប់សត្វពាហនៈ ទឹក ដីដែលមានព្រៃឈើ) ឱកាសការងារ និង មុខរបរដែលជាគន្លឹះសម្រាប់ការស្តារជីវភាពឡើងវិញ។

ជម្រើសនៃការតាំងទីលំនៅថ្មី គួរតែជៀសវាងឲ្យបាននូវការកាត់ផ្តាច់ទំនាក់ទំនងរបស់ប្រជាសហគមន៍ ពីព្រោះការរក្សាទំនាក់ទំនងសង្គម និងទំនាក់ទំនងជាមួយសមាជិកសហគមន៍ ដែលរងផលប៉ះពាល់ដូចគ្នា គឺជាកត្តាគន្លឹះរួមក្នុងការអនុវត្តតាមសហគមន៍ថ្មី និង កាលៈទេសៈថ្មីដោយជោគជ័យ ។ ទោះបីជាយ៉ាងណាក៏ដោយ ថ្វីបើការការពារដល់សហគមន៍ គឺជាក្តីកង្វល់ចម្បង សមាជិកខ្លះនៃសហគមន៍អាចមានជម្រើសលើការតាំងទីលំនៅ រួមទាំងជម្រើសក្នុងការមិនស្ថិតនៅជាផ្នែកនៃសហគមន៍រងផលប៉ះពាល់ ដូច្នេះហើយតម្រូវឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃសហគមន៍រងផលប៉ះពាល់។ ផែនការសកម្មភាពស្តីពីតាំងទីលំនៅថ្មី ត្រូវពិពណ៌នាអំពីដំណើរការនៃការជ្រើសរើសទីតាំង ផ្តល់ការបរិយាយអំពីទីតាំងថ្មីដែលបានជ្រើសរើស (រួមទាំងទីតាំងដែលអាចជំនួសបាន) បរិយាយពីការវាយតម្លៃទីតាំងបឋម (រួមទាំងលទ្ធផលនៃការវាយតម្លៃបរិស្ថាន និង សង្គមនៃប្រជាពលរដ្ឋជាម្ចាស់សហគមន៍) និងបង្ហាញជម្រើសគំរូផ្ទះ តម្រូវការដើម្បីរៀបចំដី បរិយាយពីជម្រើសនៃការសាងសង់លំនៅដ្ឋាន តម្រូវការចាំបាច់នៃការត្រៀមរៀបចំដី តម្រូវការចាំបាច់នៃសេវាហេដ្ឋារចនាសម្ព័ន្ធ (ការទទួលបានផ្លូវថ្នល់/ផ្លូវធ្វើដំណើរឆ្លងកាត់ទៅមក ការផ្តល់ប្រព័ន្ធទុយោទឹក អគ្គិសនី ភ្លើងបំភ្លឺ ប្រពន្ធ័បង្ហូរទឹកសំអុយ និងប្រពន្ធ័គ្រប់គ្រងកាកសំណល់) ។

ការគ្រប់គ្រងលំហូរចូលរបស់ប្រជាជន

បញ្ហាលំហូរចូលនៃអ្នកចំណូលថ្មី និងការតាំងទីលំនៅថ្មីតែងតែមានទំនាក់ទំនងគ្នាយ៉ាងជិតជិត ហើយបង្កផលប៉ះពាល់ស្រដៀងគ្នាទៅលើម្ចាស់សហគមន៍ ។ ទីកន្លែងសម្រាប់តាំងទីលំនៅថ្មីជារឿយៗមានទីតាំងនៅជិតតំបន់គម្រោង ហេតុនេះហើយទើបវាជាកន្លែងដែលទាក់ទាញមនុស្សចំណូលថ្មីៗថែមទៀត ដើម្បីស្វែងរកការងារធ្វើ ។ នៅក្នុងប្រទេសភាគច្រើន ការផ្តល់ជម្រកស្នាក់នៅ និងការគាំទ្រដល់សមាជិកគ្រួសារ គឺជាកាតព្វកិច្ចសង្គមដ៏សំខាន់មួយ។គម្រោងខ្នាតធំនានា (ជាពិសេសគម្រោងរុករករ៉ែ និងគម្រោងថាមពលវារីអគ្គិសនីនៅតំបន់ជនបទ) តែងតែទាក់ទាញមនុស្សចំណូលថ្មីជាច្រើនឲ្យមកស្វែងរកការងារធ្វើ និងឱកាសផ្សេងៗទៀតទាក់ទងជាមួយនឹងការសាងសង់ និងការអនុវត្តគម្រោងទាំងនោះ។ តួយ៉ាង គម្រោងរុករករ៉ែមួយនៅម៉ាលី លំហូរចូលនៃប្រជាជនមកស្វែងរកការងារធ្វើ ជាពិសេសការតាំងទីលំនៅដោយមិនអាចគ្រប់គ្រងបាន នៃមនុស្សចំណូលថ្មីជាង ៣៥០០នាក់ ដែលបង្កឲ្យមានផលប៉ះពាល់ជា

អវិជ្ជមានធ្ងន់ធ្ងរដល់ម្ចាស់សហគមន៍មូលដ្ឋាន ដែលនៅក្នុង និងនៅជុំវិញទីតាំងគម្រោង ក៏ដូចជាប៉ះពាល់ធ្ងន់ធ្ងរដល់គម្រោងនោះផ្ទាល់ផងដែរ ។ ការពង្រីកការរុករករ៉ែបន្ទាប់ក្រោយមកទៀត បណ្តាលឲ្យមានការតាំងទីលំនៅថ្មីកាន់តែច្រើននៃក្រុមមនុស្សចំណូលថ្មី នៅក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីពួកគេបានមកដល់ ទីកន្លែងនោះ ។ ដើម្បីបញ្ចៀសស្ថានភាពបែបនេះ ចាំបាច់ត្រូវដោះស្រាយបញ្ហាដោយភាពច្នៃប្រឌិតនិងរៀបចំផែនការគ្រប់គ្រងលំហូរជនចំណូលថ្មីចូលមកស្វែងរកការងារធ្វើ ដើម្បីបង្កើតឲ្យមានការឆ្លើយតបមួយដោយមានកិច្ចសម្របសម្រួលចំពោះផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច ដែលបណ្តាលពីលំហូរចូលនៃមនុស្សចំណូលថ្មីទាំងនោះ។

ការផ្តល់សេវានិងការបង្កើតសហគ្រាស

ផែនការសកម្មភាពការតាំងទីលំនៅថ្មី ត្រូវផ្តល់ដោយលម្អិតថា ត្រូវសងជំនួសដោយរបៀបណាចំពោះសេវាសង្គមកិច្ច ដូចជាមណ្ឌលសុខភាព សាលារៀន និងហាងលក់ទំនិញ អ្នកផ្តល់សេវា និងសេវាកម្មសហគមន៍។ គេត្រូវដោះស្រាយអំពីចំណុចទាំងនេះដោយកិច្ចសហការជិតស្និតមួយរដ្ឋាភិបាល ដើម្បីធានាដល់ការបន្តឲ្យមានសេវាសង្គមកិច្ចដល់ប្រជាពលរដ្ឋជាបន្តទៀតនៅក្នុងតំបន់តាំងទីលំនៅថ្មី ។ ម្យ៉ាងទៀត រដ្ឋាភិបាលត្រូវបង្ហាញការប្តេជ្ញាចិត្តក្នុងការផ្តល់ការសហការ ប្រតិបត្តិការ និងថែទាំសេវាទាំងនោះ។

ការស្តារជីវភាពឡើងវិញ

នៅក្នុងករណីដែលការតាំងទីលំនៅថ្មី មានផលប៉ះពាល់ដល់សមត្ថភាពរកប្រាក់ចំណូលរបស់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅ ការផ្តល់សំណងតែមួយមុខមិនអាចធានាបាននូវការស្តារឡើងវិញ ឬការកែលម្អជីវភាពបានឡើយ ។ គំរូឧទាហរណ៍ខាងក្រោមដែលបង្ហាញវិធានការ ដើម្បីធ្វើឲ្យប្រសើរឡើងនិងដើម្បីនិរន្តរភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ៖

- **ជីវភាពដែលពឹងផ្អែកលើដី**

ទីតាំងសម្រាប់ការតាំងទីលំនៅថ្មី តម្រូវឲ្យមានដីសម្រាប់ធ្វើស្រែចំការ មានព្រៃឈើ ប្រភពទឹក ឬ ការត្រៀមសម្រាប់ដីកសិកម្ម (ការរានដី ការពង្រាបដីឲ្យស្មើ ការលើកផ្លូវឆ្លងកាត់ និងការធ្វើឲ្យមានស្ថិរភាពដី) ការធ្វើរបងការពារកុំឲ្យសត្វពាហនៈស៊ី ឬ ដីសម្រាប់ដាំដុះ មូលដ្ឋានកសិកម្ម (គ្រាប់ពូជ កូនឈើ ជី ការស្រោចស្រព) សេវាពេទ្យសត្វ ឥណទានខ្នាតតូច មានដូចជាធនាគារស្រូវ ធនាគារគោក្របី ប្រាក់កម្ចី និងទីផ្សារ ជាដើម។

- **ជីវភាពដែលពឹងផ្អែកលើប្រាក់ខែ**

អ្នកធ្វើការបានប្រាក់ខែនៅក្នុងសហគមន៍ អាចទទួលផលប្រយោជន៍ពីវគ្គបណ្តុះបណ្តាលជំនាញនិងការផ្តល់ការងារដោយក្រុមហ៊ុន ដែលចុះកិច្ចសន្យាផ្តល់ការងារដល់កម្មករ ដែលមានជំនាញ ការធានាដល់អ្នកមិនមានការងារធ្វើ និងការផ្តល់ឥណទានខ្នាតតូចសម្រាប់ចាប់ផ្តើមមុខជំនួញខ្នាតតូចផ្សេងៗ។

- **ជីវភាពដែលពឹងផ្អែកលើសហគ្រាស**

សហគ្រិនដែលបានធ្វើការរួច និងសហគ្រិនដែលទើបចាប់ផ្តើមអាជីពរបស់ខ្លួន និង អ្នកសិល្បៈ អាចទទួលផលប្រយោជន៍ពីការផ្តល់ឥណទាន ឬ វគ្គបណ្តុះបណ្តាល (ការរៀបចំផែនការមុខជំនួញ ផ្សព្វផ្សាយទីផ្សារ ការធ្វើបញ្ជីសារពើភ័ណ្ឌ និងការត្រួតពិនិត្យគុណភាព) ដើម្បីពង្រីក

មុខជំនួញរបស់គេ និងបង្កើតការងារនៅតាមសហគមន៍។ អ្នកធ្វើសំណើគម្រោង អាចជួយជម្រុញ ដល់សហគ្រាសក្នុងសហគមន៍ តាមរយៈការផ្តត់ផ្តង់ទំនិញ និងសេវាកម្មដល់គម្រោងរបស់ខ្លួន ពីអ្នកផ្តត់ផ្តង់ទំនិញក្នុងមូលដ្ឋាន។

ការយកចិត្តទុកដាក់ចំពោះទ្រព្យសម្បត្តិវប្បធម៌

ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវចងក្រងទុកជាឯកសារនូវរាល់កិច្ចប្រឹងប្រែងទាំងអស់ ដែលចាំបាច់ដើម្បីការពារ រុះរើ និងស្តារឡើងវិញនូវសម្បត្តិវប្បធម៌របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ។ ការរុះរើសម្បត្តិវប្បធម៌ត្រូវធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយប្រជាសហគមន៍ និងកិច្ចសហការជាមួយស្ថាបន័រដ្ឋាភិបាលដែលមានសមត្ថកិច្ច ។ ការបំលាស់ទីសម្បត្តិវប្បធម៌ និង រចនាសម្ពន្ធ័ផ្សាភ្ជាប់ជាមួយទី-សក្ការៈបូជាបែបសាសនាអាចធ្វើបាន លុះណាតែមានការពិគ្រោះយោបល់ជាមួយអ្នកធ្វើពិធីកម្មសាសនា (ដូចជាព្រះសង្ឃ និងអាចារ្យ) ហើយត្រូវរាប់បញ្ចូលក្នុងការទូទាត់សំណងសម្រាប់ពិធីបុណ្យសាសនាផងដែរ ។ ត្រូវផ្តល់សំណងដល់គ្រួសារប្រជាពលរដ្ឋចំពោះការខូចខាតសម្ភារៈ និង ការខូចខាតផ្នែកបុណ្យសាសនា ការគាស់ផ្ទរ និងការបំលាស់ទីផ្ទរសព ទៅកាន់ទីតាំងថ្មី។

ជំនួយពិសេសសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ

នៅក្នុងប្រទេសភាគច្រើននៃពិភពលោក ស្ត្រីតែងតែស្ថិតក្នុងស្ថានភាពក្រីក្រច្រើនជាងគេ ។ ការរើសអើងយេនឌ័របានកំហិតព្រំដែនដល់ស្ត្រីក្នុងការទទួលបានធនធានឱកាសផ្សេងៗ និងសេវាសាធារណៈដែលចាំបាច់សម្រាប់ការកសាងជីវភាពខ្លួនឯងនិងក្រុមគ្រួសារ។ ជាលទ្ធល ស្ត្រីតែងតែជាជនទីមួយដែលត្រូវរងគ្រោះនៅពេលមានផែនការតាំងទីលំនៅថ្មី ឬ ពេលផែនការនោះត្រូវបានគេអនុវត្តន៍មិនបានល្អប្រពៃ។ បើប្រៀបធៀបជាមួយនឹងបុរស ជាទូទៅស្ត្រីតែងតែពឹងអាស្រ័យទៅលើបណ្តាញគាំទ្រក្រៅផ្លូវការ ដូចជា ៖ ជំនួយពីមិត្តសំឡាញ់ អ្នកជិតខាង ឬ សាច់ញាតិសម្រាប់ការងារមើលថែទាំកូនៗរបស់គេ។ ស្ត្រីដែលមានកូនតូចៗមិនអាចដើរទៅណាឆ្ងាយដើម្បីទៅរកការងារបានឡើយ ។ ដោយហេតុផលទាំងនេះហើយ ចាំបាច់ណាស់ដែលត្រូវរក្សាទំនាក់ទំនងសង្គមរបស់សហគមន៍ដែលរងប៉ះពាល់ពីគម្រោង (ទោះបីតាមរយៈការរៀបចំបង្កើតទីតាំងថ្មីក្តី តាមរយៈវិធានការពារកុំឲ្យសហគមន៍បែកបាក់គ្នាក្តី ឬ តាមរយៈការផ្តល់សេវាកម្មសង្គមកិច្ចជាពិសេសដល់ទីកន្លែងតាំងទីលំនៅថ្មីក្តី)។

ការគិតដល់បញ្ហាយេនឌ័រ គឺជាកត្តាសំខាន់ដែលអាចរួមចំណែកជួយឲ្យការតាំងទីលំនៅថ្មីបានជោគជ័យ។ ត្រូវពិចារណាចំពោះគំនិតផ្តួចផ្តើមខ្លះៗដែលមានលក្ខណៈបន្ទាន់ និងជាក់ស្តែង ដើម្បីជួយឲ្យស្ត្រីអាចសម្របសម្រួលខ្លួនបាននៅទីតាំងលំនៅថ្មី មានដូចជា ៖

- ការធានាចំពោះការចេញកម្មសិទ្ធិដីធ្លី និងសិទ្ធិក្នុងការទទួលបានសំណងដល់ម្ចាស់កម្មសិទ្ធិទាំងឈ្មោះប្តី និងឈ្មោះប្រពន្ធ។
- ការកាត់បន្ថយបន្ទុកការងារស្ត្រីតាមរយៈការផ្តល់អណ្តូងទឹក អណ្តូងស្នប់ ត្បាល់កិន អុសដុត និងចង្ក្រានហ្គាស រទេះគោ និងនង្គ័ល។
- ការពង្រឹងសេវាសុខភាព តាមរយៈការផ្តល់ការបណ្តុះបណ្តាលឆ្មបតាមភូមិ មណ្ឌលថែទាំសុខភាពបឋម ការផ្តល់ប្រឹក្សាអំពីការពន្យាកំណើត/ផែនការគ្រួយសារ ការផ្តល់វគ្គបណ្តុះបណ្តាលអំពីទឹកស្អាត និងអនាម័យ ។
- ការធ្វើឲ្យប្រសើរឡើងនូវសេវាសុខភាពគ្រួសារ តាមរយៈការចាក់វ៉ាក់សាំងបង្ការ ការគាំពារសុខភាពកុមារ សាលាបឋមសិក្សា សម្ភារៈសម្រាប់បង្កបង្កើតជល និងការសាងសង់លំនៅដ្ឋាន។

- ការបង្កើនប្រាក់ចំណូលគ្រួសារតាមរយៈការបង្កើតក្រុមឥណទាន ការផ្តល់វគ្គបណ្តុះបណ្តាលជំនាញ និងការស្វែងរកទីផ្សារលក់ផលិតផល។

ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពសង្គម និងផ្លូវច្បាប់របស់ស្ត្រី នៅតែមិនទាន់អាចកែប្រែឲ្យបានប្រសើរនៅឡើយ។ បើសិនជាគ្មានយុទ្ធសាស្ត្រយូរអង្វែង ដើម្បីផ្លាស់ប្តូរស្ថានភាពស្ត្រីនិងការប្រកាន់ពីរសអើងចំពោះស្ត្រីទេនោះ ពួកគេមិនអាចមានសមត្ថភាពពេញលេញ ក្នុងការកែប្រែជីវភាពរបស់គេបានឡើយ។ គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រដែលអាចជួយកែលម្អស្ថានភាពជីវភាពស្ត្រី ក្នុងស្ថានភាពថ្មីរបស់គេតាមរយៈដូចជា ៖

- ការផ្តល់ឱកាសសិក្សាសម្រាប់ស្ត្រី (តាមរយៈការផ្តល់ការអប់រំអក្ខរកម្ម និង ការរៀនលេខ និងការផ្តល់ឱកាសឲ្យកុមារីទទួលបានការអប់រំ ។
- ការផ្តល់ឱកាសឲ្យស្ត្រីទទួលបានធនធានហិរញ្ញវត្ថុនានា ។
- ការផ្តល់ឱកាសឲ្យស្ត្រីបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត (គាំទ្រដល់ក្រុមស្ត្រីពាក់-ព័ន្ធ)។
- ការផ្តល់ឲ្យស្ត្រីមានឱកាសស្មើភាពគ្នាជាមួយបុរសក្នុងការទទួលបានការងារធ្វើ។

ក្រុមងាយរងគ្រោះ មានដូចជាក្រុមគ្រួសារដែលមានស្ត្រីជាមេគ្រួសារ គ្រួសារដែលមានសមាជិកមានផ្ទុកវីរុសអេដស៍/ជំងឺអេដស៍ដែលមានកុមារជាមេគ្រួសារ គ្រួសារដែលមានសមាជិកគ្រួសារជាមនុស្សចាស់ ឬ ជនពិការគ្រួសារដែលមានសមាជិកគ្រួសារជាជនទីទ័លក្រ ឬ គ្រួសារដែលមានសមាជិកគ្រួសារគេមិនរាប់រក (ដោយសារហេតុផលអគតិប្រពៃណី ឬ វប្បធម៌) និងគ្រួសារដែលមានសេដ្ឋកិច្ចទន់ខ្សោយ។

ជំនួយពិសេសដែលត្រូវផ្តល់ឲ្យក្រុមងាយរងគ្រោះ មានដូចជា៖

- ផ្តល់ការប្រឹក្សាយោបល់ដាច់ដោយឡែកៗពីគ្នា និងដោយរក្សាការសម្ងាត់។
- ផ្តល់អាទិភាពឲ្យគេជ្រើសរើសទីតាំងសម្រាប់តាំងទីលំនៅថ្មី។
- ត្រូវផ្តល់ឱកាសឲ្យគេតាំងទីលំនៅនៅជិតសាច់ញាតិ បងប្អូន និងអ្នកជិតខាងរបស់គេ។
- បើចាំបាច់ ត្រូវផ្តល់អ្នកមៅការសម្រាប់សាងសង់ផ្ទះរបស់គេ។
- ជួយរុះរើ និងដឹកជញ្ជូនសម្ភារ ដែលអាចប្រើប្រាស់ពីផ្ទះថ្មីរបស់គេ។
- ផ្តល់ឱកាសអាទិភាពឲ្យគេទទួលបានជំនួយអភិវឌ្ឍន៍ និងសង្គ្រោះបន្ទាន់។
- តាមដានត្រួតពិនិត្យលើស្ថានភាពសុខភាព ដើម្បីធានាឲ្យមានសមាហរណកម្មដោយជោគជ័យនៅក្នុងសហគមន៍ដែលតាំងទីលំនៅថ្មី។

ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវចងក្រងទុកជាឯកសារនូវវិធានការស្តារឡើងវិញដែលអ្នកគាំទ្រគម្រោងត្រូវដាក់ចូលជាធរមាន សម្រាប់ក្រុមងាយរងគ្រោះទាំងអស់ ក្នុងអំឡុងពេលបំលាស់ទីជារូបវន្ត និងការស្តារឡើងវិញចំពោះសហគមន៍រងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី។

៥.៣.២.៥ គ្រោងថវិការចំណាយ និងគ្រោងពេលវេលាអនុវត្ត

ការចំណាយជាក់ស្តែងសម្រាប់ការរៀបចំផែនការ និងការអនុវត្តការតាំងទីលំនៅថ្មី ជាធម្មតាត្រូវធ្វើឡើងក្រោមលក្ខណៈប៉ាន់ស្មាន ។ ចាំបាច់ត្រូវប៉ាន់ស្មានការចំណាយសរុបឲ្យបានត្រឹមត្រូវ ហើយដាក់បញ្ចូលនៅក្នុងផែនការលម្អិត។ បើសិនជាគេមិនអាចប៉ាន់ប្រមាណឲ្យបានត្រឹមត្រូវលើការផ្តល់សម្បទានដី

ការទូទាត់សំណងសម្រាប់ទ្រព្យសម្បត្តិដែលខូចខាត និង ការបំលាស់ទីជារូបវន្តទេនោះ អ្នករៀបផែនការគម្រោងមិនអាចកំណត់នូវតម្លៃពិតប្រាកដលើជម្រើសដែលអាចជំនួសបានក្នុងការរៀបចំគម្រោងដូចជា ៖ ជម្រើសនៃផ្លូវសម្រាប់ដាក់ខ្សែបញ្ជូនចរន្តអគ្គិសនី ឬ ទីតាំងដែលអាចជំនួសសម្រាប់គម្រោងដែលស្ថិតក្នុងទីតាំងបរិស្ថាន។ អ្នកធ្វើសំណើគម្រោង ត្រូវរាយលម្អិតពីការចំណាយសម្រាប់ការតាំងទីលំនៅថ្មី ទៅតាមប្រភេទនៃផលប៉ះពាល់ សិទ្ធិទទួលបាន និងការចំណាយដទៃទៀតលើការតាំងទីលំនៅថ្មី រាប់បញ្ចូលទាំងវគ្គបណ្តុះបណ្តាល ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យគម្រោង។

ការគ្រោងថវិកាចំណាយសម្រាប់ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវរួមបញ្ចូលនូវដំណោះសារនៃការសន្និដ្ឋានទាំងអស់ ដែលបានធ្វើឡើងជាការគណនាអត្រាទូទាត់សំណង និងការប៉ាន់ស្មានលើការចំណាយផ្សេងៗទៀត ហើយការគណនានេះ ត្រូវរាប់បញ្ចូលទាំងសំណងលើទ្រព្យសម្បត្តិ ដែលខូចខាតជារូបវន្ត និងការចំណាយជាយថាហេតុ ។

នៅក្នុងស្ថានភាពដែលរអាជ្ញាធរជាម្ចាស់មូលដ្ឋាន ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់សំណង និងជំនួយឧបត្ថម្ភផ្សេងៗទៀតទាក់ទងការតាំងទីលំនៅថ្មី អ្នកធ្វើសំណើគម្រោង ត្រូវសហការជាមួយភ្នាក់ងាររដ្ឋាភិបាលមានសមត្ថកិច្ច ដើម្បីធានាឲ្យប្រាកដថាការទូទាត់សំណងធ្វើឡើងទាន់ពេលវេលា។ ប្រសិនបើអ្នកធ្វើសំណើគម្រោងជាអ្នកផ្តល់ហិរញ្ញប្បទានដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការតាំងទីលំនៅថ្មី ស្ថាប័ននោះត្រូវផ្តល់ហិរញ្ញវត្ថុជាជំហានៗ អាស្រ័យទៅលើទំហំការងារដែលបានសម្រេចតាមដំណាក់កាលសំខាន់។ តែបើក្នុងស្ថានភាពដែលអ្នកធ្វើសំណើគម្រោងជាអ្នកទទួលខុសត្រូវផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពតាំងទីលំនៅថ្មី ស្ថានប័ននោះត្រូវពិពណ៌នាអំពីការរៀបចំដើម្បីទូទាត់សំណងតាមពេលវេលាសមស្រប។

ការគ្រោងថវិកាចំណាយសម្រាប់ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវមានទំនាក់ទំនងជាមួយនឹងគ្រោងពេលវេលាសម្រាប់ការអនុវត្តលម្អិត ចំពោះសកម្មភាពគន្លឹះនៃការតាំងទីលំនៅថ្មី និងការធ្វើនីតិ-សម្បទា ។ ការគ្រោងពេលវេលានេះ ត្រូវរៀបចំឲ្យស្របគ្នាជាមួយគ្នានឹងកាលវិភាគនៃការងារផ្នែកសាងសង់របស់គម្រោង។ ការកំណត់ពេលវេលាសម្រាប់សកម្មភាពនៅមូលដ្ឋាន ដូចជាការពិគ្រោះយោបល់ ការធ្វើជំរឿន និងការអនុវត្តការអង្កេតសិក្សា គឺជាចាំបាច់ណាស់ ៖ ការចាប់ផ្តើមសកម្មភាពនៅតាមមូលដ្ឋានលឿនពេកមុនពេលគម្រោងចាប់ផ្តើម អាចនាំឲ្យប្រជាពលរដ្ឋមានការលេចចេញនូវការរំពឹងសម្រាប់ពលរដ្ឋមូលដ្ឋាន និងអាចជាការទាក់ទាញមនុស្សចំណូលថ្មីឲ្យមកកាន់ទីតាំងនោះ ។ តែបើចាប់ផ្តើមសកម្មភាពនៅមូលដ្ឋានយឺតពេក បន្ទាប់ពីគម្រោងបានចាប់ផ្តើម ក៏អាចជាការរំខានដល់ដល់ការអនុវត្តគម្រោងផងដែរ។ ការផ្សាភ្ជាប់គម្រោងតាំងទីលំនៅថ្មីជាមួយនឹងកាលវិភាគនៃការសាងសង់ អាចធ្វើធានាឲ្យអ្នកគ្រប់គ្រងគម្រោង អាចកំណត់បានពីសកម្មភាពគន្លឹះនានានៃការតាំងទីលំនៅថ្មី ឲ្យស្របគ្នាជាមួយនឹងសកម្មភាពគន្លឹះនៃការសាងសង់របស់គម្រោងដែរ។ ការផ្សាភ្ជាប់កាលវិភាគតាមរបៀបនេះបង្កើតជាភាពចាំបាច់មួយសម្រាប់សម្របសម្រួលដល់ការតាំងទីលំនៅថ្មី ជាមួយសកម្មភាពដទៃទៀតរបស់គម្រោង។

៥.៣.២.៦ ការទទួលខុសត្រូវរបស់ស្ថាបន័ពាក់ពន្ធ័ផ្សេងៗ

ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវកំណត់ឲ្យបានច្បាស់ និង ផ្តល់នូវចំនុចលម្អិតអំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងឡាយដែលពាក់ពន្ធ័ (ស្ថាប័នសាធារណៈ: ឯកជន ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល) ដែលទទួលខុសត្រូវចំពោះសកម្មភាពតាំងទីលំនៅថ្មី ព្រមទាំងសមត្ថភាពរបស់ស្ថាប័នទាំងនោះក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន។

អាស្រ័យលើទំហំនៃការតាំងទីលំនៅថ្មី ផ្សារភ្ជាប់នឹងគម្រោង វាជាប្រការសមស្របសម្រាប់អ្នកធ្វើសំណើគម្រោងក្នុងការបង្កើតឲ្យមានក្រុមផ្តល់ប្រឹក្សាយោបល់លើការតាំងទីលំនៅថ្មី (គណៈកម្មការអចិន្ត្រៃយ៍ ឬ ក្រុមការងារពិសេស) ដើម្បីជួយសម្របសម្រួលដល់ការអនុវត្តផែនការសកម្មភាពតាំងទីលំនៅថ្មី។ ក្រុមផ្តល់ប្រឹក្សាយោបល់ ត្រូវមានតំណាងពីស្ថាបន័គាំទ្រគម្រោង ស្ថាប័នរដ្ឋាភិបាល និងរដ្ឋបាលពាក់ព័ន្ធ អង្គការមានមូលដ្ឋាននៅសហគមន៍ អង្គការក្រៅរដ្ឋាភិបាលគាំទ្រការងារតាំងទីលំនៅថ្មី តំណាងសហគមន៍ ដែលត្រូវផ្លាស់ប្តូរទីលំនៅ និងតំណាងសហគមន៍ជាម្ចាស់មូលដ្ឋាន ។ ក្រុមនេះត្រូវជួបប្រជុំជាទៀងទាត់ក្នុងអំឡុងពេលអនុវត្តដំណាក់កាលផ្សេងៗនៃផែនការតាំងទីលំនៅថ្មី ដើម្បីធានាឲ្យការផ្លាស់ប្តូរព័ត៌មានជាទៀងទាត់ក្នុងចំណោមភាគីទាំងអស់ ដើម្បីជួយសម្របសម្រួលដល់ការអនុវត្តសកម្មភាពតាំងទីលំនៅថ្មីទាំងអស់ ។ សមាជិកភាពនៃក្រុមប្រឹក្សាយោបល់ត្រូវរួមបញ្ចូលទាំងអ្នកតំណាងរដ្ឋាភិបាល ដែលចាំបាច់ឲ្យមានទាំងអាជ្ញាធរពាក់ព័ន្ធ និងអាជ្ញាធររដ្ឋបាល ។ តួនាទីអាជ្ញាធរលំដាប់ថ្នាក់ទាំងពីរនេះ គឺដើម្បីធានាដល់ការអនុវត្តការតាំងទីលំនៅថ្មីឲ្យបានទាន់ពេលវេលា និងដើម្បីដោះស្រាយចំពោះបណ្តឹងសារទុក្ខនានា។

ស្ថិតក្នុងស្ថានភាព ដែលស្ថាប័នគាំទ្រគម្រោងជាអ្នកទទួលខុសត្រូវ ចំពោះប្រជាពលរដ្ឋរងផល-ប៉ះពាល់ពីការតាំងទីលំនៅថ្មី ជាធម្មតាស្ថាប័ននេះត្រូវបង្កើតអង្គភាពទទួលបន្ទុកកិច្ចការតាំងទីលំនៅថ្មី ក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធគ្រប់គ្រងរួមរបស់គម្រោង ដើម្បីជួយសម្របសម្រួល គ្រប់គ្រង និងតាមដានត្រួត-ពិនិត្យលើការអនុវត្តសកម្មភាពតាំងទីលំនៅថ្មីជាក់ស្តែងប្រចាំថ្ងៃ។

នៅដំណាក់កាលដំបូងនៃដំណើរការតាំងទីលំនៅថ្មី ស្ថាបន័គាំទ្រគម្រោងត្រូវលើកទឹកចិត្តប្រជា-ពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅថ្មីឲ្យបង្កើតជាគណៈកម្មការតាំងទីលំនៅថ្មី។ សមាសភាពគណៈកម្មការនេះត្រូវមានអ្នកដឹកនាំផ្លូវការ ក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី ព្រមទាំងតំណាងក្រុមដែលមានចំណាប់អារម្មណ៍ផ្សេងៗទៀតនៅក្នុងសហគមន៍ ដែលក្រុមនោះមិនមានតួនាទីជាអ្នកដឹកនាំផ្លូវការ (ក្រុមសិល្បករ ក្រុមអ្នកមានលំនៅដ្ឋានតែគ្មានដី និងក្រុមស្ត្រី)។ គណៈកម្មការតាំងទីលំនៅថ្មី អាចដើរតួនាទីសំខាន់ក្នុងការចចារអំពីការទូទាត់សំណងតាំងទីលំនៅថ្មី ជាមួយនឹងអ្នកគ្រប់គ្រងគម្រោងតាមរយៈការរៀបចំយុទ្ធសាស្ត្រដើម្បីស្តារ និងអភិវឌ្ឍជីវភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋឡើងវិញ ក៏ដូចជាការតាមដានការអនុវត្តជារួមលើផែនការសកម្មភាពតាំងទីលំនៅថ្មី។

នៅបណ្តាប្រទេសទន្លេមេគង្គ ការប្រគល់ភារកិច្ចទទួលខុសត្រូវ ក្នុងការរៀបចំផែនការតាំងទីលំនៅថ្មី មានលក្ខណៈប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយទៀត ។ តួយ៉ាងនៅប្រទេសចិន បើយោងទៅលើបទប្បញ្ញត្តិស្តីពីការទូទាត់សំណងសម្រាប់ការផ្តល់សម្បទានដី និងការតាំងទីលំនៅថ្មី និងការរក្សាទឹកខ្ពាតធំ និងមធ្យម និងគម្រោងវារីអគ្គសនី (ឆ្នាំ២០០៦) ម្ចាស់គម្រោងទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាព នៃការតាំងទីលំនៅថ្មី។ ប្រសិនបើគ្មានម្ចាស់គម្រោងទេ ស្ថាប័នដែលមានសមត្ថកិច្ចអាចធ្វើការរួមគ្នាជាមួយ រដ្ឋាភិបាលប្រជាជននៅកម្រិតជាតិ ឬ ក្នុងកម្រិតមូលដ្ឋានរបស់អ្នកតាំងទីលំនៅថ្មី និងម្ចាស់ទីតាំង ដែលត្រូវទទួលអ្នកតាំងទីលំនៅថ្មី ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពតាំងទីលំនៅថ្មីនេះ ។ ផែនការសកម្មភាពតាំងទីលំនៅថ្មីនឹងត្រូវដាក់ស្នើ និង ទទួលការព្រមព្រៀងពីរដ្ឋាភិបាលប្រជាជន តំបន់ស្វ័យត សាលាក្រុង ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកណ្តាល ឬ ស្ថាប័នរដ្ឋបាលទទួលបន្ទុកកិច្ចការតាំងទីលំនៅថ្មី ក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សារដ្ឋ អាស្រ័យលើព្រំដែនអំណាចនៃការត្រួតពិនិត្យ និងយល់ព្រម។

នៅប្រទេសកម្ពុជា ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវបានរៀបចំឡើងដោយអ្នកធ្វើសំណើគម្រោង និងទទួលបានការយល់ព្រមពីគណៈកម្មការអន្តរក្រសួង នៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៥.៣.២.៧ យន្តការស្តីពីបណ្តឹងសារទុក្ខ

ការផ្លាស់ប្តូរទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ទោះបីជាមានទំហំប៉ុណ្ណាក៏ដោយមិនអាចជៀសផុតពីការលេចឡើងនូវបណ្តឹងសារទុក្ខ ក្នុងចំណោមប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មី រាប់ចាប់តាំងពីបញ្ហាអត្រាទូទាត់សំណង និងលក្ខណៈវិនិច្ឆ័យ ក្នុងការទទួលបានការតាំងទីលំនៅស្របច្បាប់ និងគុណភាពនៃសេវាកម្មនៅតំបន់តាំងទីលំនៅថ្មី ។ ការដោះស្រាយបណ្តឹងសារទុក្ខទាំងនោះឲ្យបានទាន់ពេលវេលា គឺជាប្រការសំខាន់ ដើម្បីឲ្យគេអាចអនុវត្តការតាំងទីលំនៅថ្មីប្រកបដោយការពេញចិត្ត និងបានបញ្ចប់ដំណើរការគម្រោងតាមការគ្រោងទុក ។

អ្នកធ្វើសំណើគម្រោង ត្រូវធានាឲ្យប្រាកដថា នីតិវិធីដែលបានអនុវត្តអាចបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មីក្នុងការប្តឹង ឬ ទាមទារអ្វីមួយ (រួមទាំងការទាមទារដែលកើតចេញពីច្បាប់ និង ការប្រើប្រាស់ដែលជាប្រពៃណី) ដោយគ្មានការចំណាយរួមជាមួយនឹងការធានាឲ្យមានដំណោះស្រាយទាន់ពេលវេលា និងប្រកបដោយការពេញចិត្តចំពោះការទាមទារនោះ (ប្រអប់អត្ថបទ៥.៦) ។ បន្ថែមពីនេះ គម្រោងត្រូវផ្តល់ភាពងាយស្រួលនៅដល់ស្ត្រី និងសមាជិកក្រុមងាយរងគ្រោះ ដើម្បីឲ្យពួកគេមានឱកាសស្មើភាពគ្នាចំពោះនីតិវិធី ក្នុងធ្វើការទាមទារឲ្យមានដំណោះស្រាយលើបណ្តឹងសារទុក្ខ។ ប្រការនេះ ត្រូវរាប់បញ្ចូលទាំងភាពមានការងារធ្វើរបស់ស្ត្រី ឬ សមាជិកក្រុមងាយរងគ្រោះ ដើម្បីជួយសម្រួលដល់ដំណើរការដោះស្រាយបណ្តឹងសារទុក្ខ ឬ ធានាថាក្រុមដែលតំណាងផលប្រយោជន៍ស្ត្រី និងក្រុមងាយរងគ្រោះទាំងនោះ អាចចូលរួមនៅក្នុងដំណើរការនោះបាន។

បណ្តឹងសារទុក្ខអាចត្រូវបានដោះស្រាយបានយ៉ាងល្អបំផុត តាមរយៈអ្នកគ្រប់គ្រងគម្រោងរដ្ឋបាលមូលដ្ឋាន ឬ បណ្តាញសម្របសម្រួលបញ្ហា ដែលអាចទទួលយកបានសម្រាប់ភាគីទាំងអស់។ បណ្តាញសម្របសម្រួលបញ្ហាទាំងនេះ អាចជាប់ពាក់ពន្ធ័ពីស្តាប័នដែលដោះស្រាយទំនាស់តាមបែបប្រពៃណី និងលក្ខណៈវប្បធម៌ ។ អ្នកគ្រប់គ្រងគម្រោង ត្រូវខិតខំគ្រប់បែបយ៉ាងដើម្បីដោះស្រាយបណ្តឹងសារទុក្ខនៅកម្រិតសហគមន៍។ ការប្រើប្រាស់ប្រពន្ធ័ច្បាប់លើកលែង គួរតែត្រូវបានជៀសវាង វាលែងតែការប្រើប្រាស់ច្បាប់នោះជាជម្រើសចុងក្រោយ ។

ផែនការសកម្មភាពតាំងទីលំនៅថ្មី ត្រូវពិពណ៌នាពីបទដ្ឋាននៃការដោះស្រាយបណ្តឹងសារទុក្ខដែលនឹងត្រូវយកមកអនុវត្ត ដោយរួមមានដូចខាងក្រោម ៖

- ការរៀបចំជាលក្ខណៈស្តាប័ន។
- នីតិវិធីក្នុងការកត់ត្រា និងដំណើរការបណ្តឹងសារទុក្ខ។
- យន្តការសម្រាប់ការវិនិច្ឆ័យលើបណ្តឹងសារទុក្ខ និងការដោះស្រាយវិវាទនៅថ្នាក់ឧទ្ធរណ៍។
- គ្រោងពេលវេលា ដោយមានកាលកំណត់ជាក់លាក់ សម្រាប់ជំហានទាំងអស់នៃដំណើរការដោះស្រាយបណ្តឹងសារទុក្ខ។

បណ្តឹងសារទុក្ខក៏អាចដោះស្រាយបាន តាមរយៈអាជ្ញាកណ្តាល ដែលនេះជាយន្តការមួយក្នុងការដោះស្រាយទំនាស់នៅក្រៅពីប្រព័ន្ធតុលាការរបស់ភាគីទំនាស់យោងបញ្ហារបស់គេទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ឲ្យធ្វើការសម្រេចចិត្តចំពោះអ្វីដែលពួកគេបានព្រមព្រៀងគ្នា ។ អាជ្ញាកណ្តាល ដែលជាទូទៅ

សំដៅដល់អ្នកច្បាប់ជាន់ខ្ពស់ដែលមានវិជ្ជាជីវៈ (ជាអ្នកដែលប្រកាន់តាមក្បួតខ្នាតវិជ្ជាជីវៈច្បាស់លាស់ ក្នុងការស្វែងយល់អំពីសភាពលក្ខណៈ និងអង្គហេតុនៃទំនាស់) ជាអ្នកឰកែពិចារណាលើការទាស់ទែងនេះជាលក្ខណៈឯកជន និងធ្វើសេចក្តីសម្រេចចិត្តជាចុងក្រោយសម្រាប់ភាគីទំនាស់ទាំងអស់ដែលពាក់ព័ន្ធ។

៥.៣.២.៨ ការតាមដាន និងការវាយតម្លៃ

ការអនុវត្តល្អ តម្រូវឱ្យអ្នកធ្វើសំណើគម្រោងធ្វើការតាមដានត្រួតពិនិត្យ និង រាយការណ៍លើប្រសិទ្ធិភាពនៃការអនុវត្តការតាំងលំនៅថ្មី រួមបញ្ចូលទាំងការរីកចំរើននៃសកម្មភាពនៃការតាំងលំនៅថ្មី និងការស្តារនីតិសម្បទា ការទទួលបានប្រាក់សំណង ប្រសិទ្ធិភាពនៃការពិគ្រោះយោបល់ជាសាធារណៈ និងសកម្មភាពនៃការចូលរួម និង និរន្តរភាពនៃការស្តារឡើងវិញនូវចំណូល និង ការខិតខំប្រឹងប្រែងនៃការអភិវឌ្ឍក្នុងចំណោមសហគមន៍រងផលប៉ះពាល់ ។ គោលបំណងនៃការតាមដានត្រួតពិនិត្យ គឺដើម្បីផ្តល់យោបល់ត្រឡប់វិញ លើការអនុវត្តការតាំងលំនៅថ្មី និងដើម្បីកំណត់ឲ្យឃើញពីបញ្ហា និងជោគជ័យឲ្យបានកាន់តែឆាប់កាន់តែល្អ ដើម្បីអនុញ្ញាតឲ្យមានការលៃតម្រូវទាន់ពេលវេលាលើការរៀបចំអនុវត្ត ។ ប្រការនេះតម្រូវឱ្យសកម្មភាព តាមដានត្រួតពិនិត្យ និងការវាយតម្លៃ គួរតែត្រូវបានទទួលការឧបត្ថម្ភថវិកាគ្រប់-គ្រាន់ ត្រូវអនុវត្តដោយអ្នកឯកទេសមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង ដាក់បញ្ចូលទៅក្នុងដំណើរការនៃការគ្រប់គ្រងគម្រោងទាំងមូល ។

ត្រូវតែផ្តល់នូវផែនការតាមដានត្រួតពិនិត្យមួយ ដែលកំណត់ឲ្យឃើញច្បាស់ពីការទទួលខុសត្រូវរបស់ស្ថាប័ន វិធីសាស្ត្រ និងគម្រោងពេលវេលា សម្រាប់ការតាមដាន និងការរាយការណ៍។ ធាតុសំខាន់ៗទាំងបីនៃផែនការត្រួតពិនិត្យមួយ គួរតែមានការពិនិត្យតាមដានការអនុវត្ត ការត្រួតពិនិត្យផលប៉ះពាល់ និងសវនកម្មបញ្ចប់មួយ (ដោយកត់ចំណាំថាវិសាលភាពនៃផែនការត្រួតពិនិត្យ គួរតែស្របតាមមាត្រដ្ឋាន និងភាពស្មុគស្មាញនៃ RAP) ។

ប្រអប់អត្ថបទ ៥.៦ គំរូឧទាហរណ៍មួយនៃយន្តការស្តីពីបណ្តឹងសារទុក្ខ - គម្រោងឧស្ម័នធម្មជាតិសាសុល (Sasol) នៅប្រទេសមូសាំប៊ិក

ដើម្បីធ្វើជាមធ្យោបាយក្នុងការដោះស្រាយលើពាក្យបណ្តឹង និងបញ្ហាដែលកើតមានឡើងពីដំណើរការតាំងលំនៅថ្មី គម្រោងសាសុលបានបង្កើតយន្តការស្តីពីបណ្តឹងសារទុក្ខមួយ តាមរយៈការដែលប្រជា-ជនរងផលប៉ះពាល់ អាចដាក់ពាក្យបណ្តឹងមួយ ឬ សារទុក្ខ ក្នុងលក្ខណៈធម្មតា និងសមរម្យមួយដោយការសង្ឃឹមលើការដោះស្រាយឆាប់រហ័ស និងពេញចិត្តនៃជម្លោះនេះ ។ បែបបទនេះ ត្រូវបានអនុញ្ញាតសម្រាប់ការវាយតម្លៃសារជាថ្មីលើការសម្រេចចិត្ត នៅពេលប្រជាពលរដ្ឋរងផលប៉ះពាល់សម្តែងការព្រួយបារម្ភទាក់ទងនឹងលទ្ធផលនៃដំណើរការតាំងលំនៅថ្មី ដូចជាការព្រួយបារម្ភ ដែលបានលេចចេញឡើងហើយជាជំនួយដល់ការអនុវត្តចំណាត់ការត្រឹមត្រូវទាន់ពេលវេលា ។ នីតិវិធីនេះ ក៏បានជួយសម្រួលឲ្យមាន តម្លាភាពផងដែរ ។

គម្រោងសាសុល ចាប់ផ្តើមទទួលបានពត៌មានដែលចាំបាច់ ដើម្បីកំណត់ថាតើគ្រួសារ ដែលរង-ផលប៉ះពាល់ បានលើកឡើងបណ្តឹងតវ៉ាណាខ្លះ ។ នីតិវិធីដូចខាងក្រោមនេះ ត្រូវបានអនុវត្តស្របតាមនីតិវិធីរបស់គម្រោងសាសុល និងរបស់រដ្ឋាភិបាលមូសាំប៊ិកដែលជាអ្នកតំណាងក្នុងការដោះស្រាយជម្លោះ ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់នេះ ៖

- គម្រោងសាសុល និងតំណាងរដ្ឋាភិបាលនៅមូលដ្ឋាន បានស៊ើបអង្កេតពីជម្លោះនេះ ហើយបើចាំបាច់ ត្រូវពិភាក្សាពីជម្លោះនេះជាមួយអ្នកគ្រប់គ្រងមូលដ្ឋាន មុនពេលពួកគេធ្វើការវាយតម្លៃឡើងវិញចំពោះការសម្រេចចិត្តនេះ។
- ប្រសិនបើជម្លោះនោះ មិនអាចដោះស្រាយនៅកម្រិតមូលដ្ឋាននោះទេ ជម្លោះនោះនឹងត្រូវបញ្ជូនបន្តទៅឲ្យក្រុមការងាររួម ដើម្បីធ្វើការការដោះស្រាយ (ដែលរួមមានសមាសភាពអ្នកគាំទ្រគម្រោង និង តំណាងរដ្ឋាភិបាល) ដែលក្រុមការងារត្រូវបានបង្កើតឡើងជាពិសេស ដើម្បីត្រួតពិនិត្យមើលលើដំណើរការតាំងទីលំនៅថ្មី ។ ប្រសិនបើក្រុមការងាររួចមិនអាចដោះស្រាយជម្លោះនោះបានទៀត ជម្លោះនោះនឹងត្រូវញ្ជូនបន្តទៅកាន់គណៈកម្មការទំនាក់-ទំនងគម្រោងដើម្បីធ្វើសេចក្តីសម្រេចចិត្ត) ដែលជាស្ថាប័នត្រួតពិនិត្យខ្ពស់បំផុតរបស់គម្រោង ដែលរួមមានសមាសភាពអ្នកគាំទ្រគម្រោង និងតំណាងរដ្ឋាភិបាល) ។
- ប្រសិនបើអ្នកប្តឹងតវ៉ា មិនព្រមទទួលយកតាមការសម្រេចចិត្តរបស់គណៈកម្មការទំនាក់ទំនង គម្រោងនោះទេ អ្នកប្តឹងរូបនោះ អាចប្តឹងឧទ្ធរណ៍លើការសម្រេចចិត្តនោះ នៅក្នុងលក្ខណៈធម្មតា ដែលអនុវត្តបានស្របតាមប្រព័ន្ធច្បាប់របស់ប្រទេសមូសាំប៊ិក។ ប្រការនេះជាប់ពាក់ព័ន្ធជាដំបូងនឹងបណ្តឹងឧទ្ធរណ៍ទៅកាន់រដ្ឋបាលស្រុក ហើយបន្តបន្ទាប់ទៅអភិបាលខេត្ត និងជាចុងក្រោយ បណ្តឹងនេះនឹងត្រូវបញ្ជូនទៅកាន់តុលាការប្រទេសមូសាំប៊ិក។

កំណត់ត្រាមួយដែលបានសរសេរអំពីវិវាទទាំងអស់ / បណ្តឹងសារទុក្ខ ដែលបានលើកឡើងក្នុងអំឡុងពេលសាងសង់ ត្រូវបានរក្សាទុកដោយក្រុមហ៊ុនសាសុល ។ កំណត់ត្រាទាំងនេះ ត្រូវបានត្រួតពិនិត្យជាទៀងទាត់ ដោយទីភ្នាក់ងារឯករាជ្យមួយ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យជាបន្ត និងដំណើរការនៃការវាយតម្លៃ។

យន្តការស្តីពីបណ្តឹងសារទុក្ខ ទោះបីវាជាយន្តការសាមញ្ញធម្មតាក្តី វាអាចដំណើរការបានយ៉ាងល្អនៅពេលដែលមានការដាក់ប្តឹងសារទុក្ខនានា (ក្នុងឧទាហរណ៍នេះ សារទុក្ខត្រូវបានដាក់ប្តឹងដោយភាគីរងផលប៉ះពាល់ ដែលមានវិសាលគមមួយក្នុងរយៈពេលបីឆ្នាំ ការទូទាត់សំណងតិចតួច និងការតាំងទី-លំនៅថ្មី)។

ប្រអប់អត្ថបទ ៥៨ ការតាំងទីលំនៅថ្មីដែលមានការផ្លាស់ប្តូរ-ការអនុវត្តល្អនៅក្នុងខេត្តយ៉ុនណាន ប្រទេសចិន

ខេត្តយ៉ុនណាន បានបង្កើតឲ្យមានវិធីសាស្ត្រនៃការតាំងទំលំនៅថ្មីមួយ ដោយឡែកសម្រាប់គម្រោង វារីអគ្គិសនីនៅភាគកណ្តាលនៃអាងទន្លេជៀនស៊ា (Jiansha River) នៅក្នុងឆ្នាំ២០០៧ ។ អ្វីដែលហៅថាគោលនយោបាយ ‘16118’ មានន័យថាជាការទូទាត់សំណងរយៈពេលយូរ តាមរយៈវិធី៦យ៉ាងនៃការតាំងទីលំនៅថ្មីសម្រាប់ប្រើនៅពេលមានគ្រោះអាសន្នចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់ (រួមមានការតាំង ទីលំនៅថ្មីនៅទីក្រុង ការតាំងទីលំនៅថ្មីដោយបូករួមទាំងនៅទីក្រុង និងជនបទ ការតាំងទីលំនៅដោយទទួលបានជាដី ការតាំងទីលំនៅដោយទទួលបានជាសាច់ប្រាក់ ការតាំងទីលំនៅដោយរប៉ាត់រប៉ាយ និងការតាំងទីលំនៅដោយទទួលបានការងារធ្វើ) តាមរយៈមូលនិធិអភិវឌ្ឍតំបន់វារីអគ្គិសនី ជំនួយទ្រទ្រង់ក្រោយពេលគម្រោង ព្រមទាំងវិធានការទាំងផយ៉ាងក្នុងការជួយដល់ការតាំងទី

លំនៅថ្មី (រួមទាំងការបំពេញ ការងារដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌរូបវន្តប្រកបដោយលក្ខណៈសុក្រិត្យ ដើម្បីបង្កើតជាក្រុងទេសចរណ៍តូចមួយ និងការចិញ្ចឹមសត្វដែលរស់ក្នុងទឹកដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដើម្បីបង្កើតកសិកម្មពិសេស និងទេសចរណ៍ទាក់ទងនឹងអេកូឡូស៊ី ដើម្បីប្រើប្រាស់សម្បត្តិរួមឲ្យកាន់តែល្អប្រសើរ ដើម្បីបង្កើតការងារថែមទៀត ដើម្បីផ្តល់សេវាសងកញ្ចប់បន្ថែម ដូចជាសាលារៀន ការធានារ៉ាប់រងសុខភាព ដើម្បីជួយប្រ-ជាជនក្រីក្រឲ្យទទួលបានលំនៅដ្ឋានថ្មី និង ការពារបរិស្ថាននៅក្នុងតំបន់វារីអគ្គិសនី រួមទាំងការជួយអ្នកដែលបានតាំងលំនៅហើយឲ្យចេះបង្កើតអាងជីវឧស្ម័ន ឬ បន្ទះស្រូបពន្លឺព្រះអាទិត្យសឡា ជាដើម)។

(ឯកសារដើមភាសាអង់គ្លេស មិនច្បាស់លាស់ថាតពីទំព័រណាមក)

- ការតាមដានលើការអនុវត្តនេះ គឺជាដំណើរការក្នុងការជម្រុញឲ្យអង្គភាពទទួលខុសត្រូវលើការតាំងទីលំនៅ អាចចាត់វិធានការឲ្យបានចម្រើនជាលក្ខណៈរូបវន្ត ស្របតាមសកម្មភាពគោល ដែលបានបង្កើតឡើងនៅក្នុងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ដែលការីក-ចម្រើនត្រូវរាយការណ៍ឲ្យស្របនឹងគម្រោងពេលវេលានៃចំណាត់ការដែលតម្រូវឲ្យមាន។
  ឧទាហរណ៍នានានៃសកម្មភាពគោលក្នុងការអនុវត្ត រួមមានដូចខាងក្រោម ៖
  - ការរៀបចំកិច្ចប្រជុំជាសាធារណៈ។
  - ការបញ្ចប់ឲ្យបានរួចរាល់នូវការជំរឿន ការធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិ ការវាយតម្លៃ និងការសិក្សាលើសង្គមសេដ្ឋកិច្ច។
  - ដំណើរការនៃការដោះស្រាយលើសារទុក្ខនៅនឹងកន្លែង និងដំណើរការនៃប្រព្រឹត្តទៅ។
  - ការទូទាត់សងចំពោះសំណងនានា។
  - ការកំណត់ទីតាំងដីសម្រាប់សាងសង់លំនៅដ្ឋាន។
  - ការបញ្ចប់ការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ។
  - ការផ្តួចផ្តើមលើការស្តារឲ្យប្រសើរឡើងវិញនូវការរកប្រាក់ចំណូល និងសកម្មភាពអភិវឌ្ឍនានា។
  - ការដាក់ស្នើរបាយការណ៍តាមដាន និងវាយតម្លៃ។

ត្រូវរៀបចំរបាយការណ៍តាមដានលើការអនុវត្តឲ្យបានទៀតទាត់ជាប្រចាំ (ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ) ចាប់ផ្តើមពីការចាប់អនុវត្តសកម្មភាពទាក់ទងនឹងការតាំងទីលំនៅថ្មី។

- ការត្រួតពិនិត្យតាមដានផលប៉ះពាល់។

  ការត្រួតពិនិត្យតាមដានផលប៉ះពាល់ អាចវាស់វែងពីប្រសិទ្ធភាពនៃផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី និងការអនុវត្តផែនការនេះ ក្នុងឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋរង-ផលប៉ះពាល់ ។ គោលបំណងនៃការត្រួតពិនិត្យតាមដានផលប៉ះពាល់ គឺដើម្បីផ្តល់ឲ្យភ្នាក់ងារទទួលខុសត្រូវលើការតាំងទីលំនៅថ្មីអាចអនុវត្តដោយមានការវាយតម្លៃលើប្រសិទ្ធភាពនៃការតាំងទីលំនៅថ្មី សំដៅផ្សៀងផ្ទាត់ឲ្យបានត្រឹមត្រូវលើការពិនិត្យតាមដានការអនុវត្តការងារផ្ទៃក្នុង ក៏ដូចជាកំណត់ឲ្យបានឃើញច្បាស់ ពីការកែតម្រូវលើការអនុវត្តផែនការសកម្មភាពនៃការតាំងទីលំនៅថ្មីតាមការចាំបាច់ ។ ត្រូវតែរួមបញ្ចូលប្រជាពលរដ្ឋរងផលប៉ះពាល់ឲ្យបានចូលរួមក្នុងគ្រប់ជំហាននៃ

ការត្រួតពិនិត្យ តាមដាន រួមទាំងការកំណត់អត្តសញ្ញាណ និង ការវាស់វែងលើសន្ទស្សន៍នានាជាមូលដ្ឋាន។

ត្រូវតាមដានពីប្រសិទ្ធភាពនៃការតាំងទីលំនៅថ្មី ឲ្យស្របតាមលក្ខណៈជាមូលដ្ឋាននៃចំនួនប្រជាពលរដ្ឋ មុនពេលចាប់ផ្តើមការតាំងទីលំនៅថ្មី ។ មូលដ្ឋាននេះត្រូវបានបង្កើតឡើងតាមរយៈការជំរឿន ការធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិ ការវាយតម្លៃលើការប្រើប្រាស់ដីធ្លី និងការសិក្សាពីសង្គមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ និងតំបន់រងផលប៉ះពាល់ដោយគម្រោង។ អង្គភាពទទួលខុសត្រូវលើការអនុវត្តការតាំងទីលំនៅថ្មី ត្រូវបង្កើតឲ្យមានសន្ទស្សន៍ដែលអាចផ្ទៀងផ្ទាត់បានដោយមិនលំអៀង សម្រាប់វាស់វែងផលប៉ះពាល់នៃការតាំងទីលំនៅថ្មីជាលក្ខណៈរូបវន្តទៅលើសុខភាព និង សុខមាលភាពរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់រួមទាំងការស្តារជីវភាព និងការផ្តួចផ្តើមលើការអភិវឌ្ឍន៍។

ការត្រួតពិនិត្យតាមដាននេះ គួរបន្តអនុវត្តឲ្យបានច្រើនឆ្នាំទៅមុខទៀត ឲ្យលើសពីពេលបញ្ចប់ការតាំងទីលំនៅ ដើម្បីធានាឲ្យប្រាកដថាការខិតខំស្តារប្រាក់ចំណូល និងការផ្តួចផ្តើមការអភិវឌ្ឍន៍អាចសម្រេចបានជោគជ័យ ព្រមទាំងធានាថាប្រជាពលរដ្ឋរងផលប៉ះពាល់អាចកសាងជីវភាពរបស់ផងខ្លួន នៅទីតាំងថ្មីនោះបានដោយខ្លួនឯង។

ការតាមដានត្រួតពិនិត្យយ៉ាងទៀងទាត់ អាចផ្តល់ឲ្យអ្នកធ្វើគម្រោងបានដឹងជាមុនអំពីបញ្ហា ដែលកំពុងកើតមានក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ (ដូចជា ៖ ការធ្លាក់ចុះនៃទិន្នផលដំណាំ ការកើតមានកាន់តែច្រើននូវជំងឺដង្កាត់នានា និងការធ្លាក់ចុះនៃប្រាក់ចំណូលប្រចាំគ្រួសារ) ដែលគួរតែត្រូវមានចម ណាត់ការឆ្លើយតបឲ្យបានឆាប់រហ័សពីសំណាក់អ្នកធ្វើសំណើគម្រោង។

បន្ថែមពីលើសន្ទស្សន៍បរិមាណ ការត្រួតពិនិត្យតាមដានលើផលប៉ះពាល់គួរត្រូវបានបំពេញបន្ថែមនូវការប្រើប្រាស់សន្ទស្សន៍បរិមាណ ដើម្បីវាយតម្លៃពីការពេញចិត្តរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ជាមួយនឹងគំនិតផ្តួចផ្តើមគំនិតស្តីពីការតាំងទីលំនៅថ្មី ក៏ដូចជាភាពសមល្មមនៃគំនិតផ្តួចផ្តើមទាំងនោះ ។ វិធីសាស្ត្រតាមដានត្រួតពិនិត្យបរិមានដែលមានប្រសិទ្ធភាពបំផុត គឺការពិគ្រោះយោបល់ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ តាមរយៈការជួបប្រជុំយ៉ាងទៀងទាត់ និង/ឬ ការពិភាក្សាជាក្រុម ។ នៅមានលំហាត់បែបចូលរួមជាច្រើនទៀត ដែលមានសារៈប្រយោជន៍សំខាន់ក្នុងការឈ្លេចយកបរិមាណនៃព័ត៌មាន។

- ការបញ្ចប់ការធ្វើសវកម្ម។

គោលបំណងគន្លឹះនៃការបញ្ចប់ការធ្វើសវនកម្ម គឺដើម្បីកំណត់ឲ្យបានច្បាស់ថាតើការខិតខំស្តារកំរិតជីវិតរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវបានទទួលលទ្ធផលសមស្រមបែបណា និងត្រូវបានអនុវត្តដោយសមស្របហើយឬនៅ ។ ការធ្វើសវនកម្ម គួរមានការផ្ទៀងផ្ទាត់ថា ពិតជាបានផ្តល់អត្ថប្រយោជន៍ជារូបវន្ត ដែលមានកំណត់នៅក្នុងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ហើយសេវាកម្មទាំងអស់ពិតជាបានផ្តល់ឲ្យពិតមែន ។ បន្ថែមពីលើនេះ ការធ្វើសវនកម្មគួរមានការវាយតម្លៃថាតើ ចំណាត់ការក្នុងការកាត់បន្ថយ ដែលមានបរិយាយនៅក្នុងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ពិតជាត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពតាមការចង់បានដែរឬទេ ។ ត្រូវវាស់វែងពីស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ រួមទាំងប្រជាពលរដ្ឋជាម្ចាស់ផ្ទះឲ្យស្របតាមលក្ខខ័ណ្ឌជាមូលដ្ឋាននៃចំនួនប្រជាពលរដ្ឋ មុននឹងចាប់ផ្តើមការបំលាស់ទីជម្រក។

ការបញ្ចប់ការធ្វើសវកម្ម គួរចាប់អនុវត្តបន្ទាប់ពីការសម្រេចរួចរាល់នូវលទ្ធផលនៃផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី រួមទាំងគំនិតផ្តួចផ្តើមការអភិវឌ្ឍន៍។

ប្រអប់អត្ថបទ ៥.៧ ធាតុសំខាន់ៗនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ក្នុងប្រទេសចិន

បទដ្ឋានគតិយុត្តគន្លឹះ ក្នុងប្រទេសចិន រួមបញ្ចូលទាំងច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី (ឆ្នាំ២០០៤)

បទបញ្ញត្តរដ្ឋបាលជាតិ ក្នុងប្រទេសចិន ៖ បទបញ្ញត្តស្តីពីការទូទាត់សំណងសម្បទានដី និងការតាំងទីលំនៅថ្មី ដោយសារការសាងសង់ អាងរក្សាទឹកក្នុងកម្រិតធំ និងមធ្យម វារីអគ្គិសនី និងការសាងសង់ទំនប់វារីអគ្គិសនីដែលបានដាក់ចេញឲ្យអនុវត្តក្នុងឆ្នាំ១៩៩១ និងត្រូវបានត្រួតពិនិត្យឡើងវិញក្នុងឆ្នាំ ២០០៦។

ការបរិយាយលម្អិតផ្នែកបច្ចេកទេសថ្នាក់ជាតិ ៖ ការបរិយាយលម្អិតស្តីពីការរៀបចំផែនការ និង ការព្រាងប្លង់គម្រោងសម្រាន់ប់ការតាំងទីលំនៅថ្មីនៃគម្រោងថាមពលវារីអគ្គិសនី ដែលបានដាក់ចេញឲ្យអនុវត្តដោយប្រទេសចិន រួមជាមួយនឹងការបរិយាយលម្អិតចំនួន៧ចំនុចផ្សេងទៀត ដើម្បី (១) កំណត់ឲ្យបានឃើញច្បាស់ពីវិសាលភាពនៃផ្ទៃដីកាកសំណល់ (២) ការអង្កេតលើការបាត់បង់ជារូបវន្ត (៣) ការកំណត់ផែនការ និងការគ្រោងប្លង់សម្រាប់ការតាំងទីលំនៅតាមទីជនបទ (៥) កំណត់ផែនការ និងការគ្រោងប្លង់សម្រាប់ប្រការពិសេស (៥) កំណត់ផែនការ និងការគ្រោងប្លង់សម្រាប់ការសាងសង់ក្រុង (៦) គ្រោងប្លង់ សម្រាប់ការសំអាតអាងស្តុកទឹក (៧) ការត្រៀមរៀបចំថវិកាសម្រាប់ទូទាត់សំណងនៃការតាំងទីលំនៅថ្មី។

បទបញ្ជា និង វិធានការថ្នាក់មូលដ្ឋាន ៖ ថ្នាក់ខេត្ត/ក្រុង/ជាតិ ដែលបានដាក់ចេញឲ្យបានប្រើប្រាស់ដោយអាជ្ញាធរខេត្ត និងមូលដ្ឋាន។

គោលនយោបាយពិសេសនៃការតាំងទីលំនៅថ្មីដោយសារគម្រោង និងវិធានការនៃការអនុវត្ត ៖ មានដូចជាបទបញ្ជាស្តីការតាំងទីលំនៅថ្មីសម្រាប់សាងសង់គម្រោងវារីអគ្គិសនី Three Gorges នៅទន្លេយង់សេ ដែលបានដាក់ចេញឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៣ និងត្រូវបានពិនិត្យជាថ្មីនៅក្នុងឆ្នាំ២០០១។

គម្រោងក្នុងស្រុក និងគម្រោងដែលទទួលបានមូលនិធិពីបរទេស សុទ្ធតែត្រូវការផែនការនៃការតាំងទីលំនៅថ្មី។ ប៉ុន្តែទោះយ៉ាងណា ខ្លឹមសារនិងការបញ្ជាក់ន័យនៃផែនការតាំងទីលំនៅថ្មីទាំងនេះមិនដូចគ្នាទេ។

គម្រោងបរទេសដែលទទួលបានមូលនិធិពី ដូចជាធនាគារពិភពលោក ឬ ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវតែអនុវត្តតាមបែបផែននៃធនាគារពិភពលោក ឬ ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការរៀបចំផែនការតាំងទី-លំនៅថ្មី។ នៅក្នុងផែនការតាំងទីលំនៅថ្មី តម្រូវឲ្យមានផ្នែកសំខាន់ ដូចជា (១) ការវិភាគពីផលប៉ះពាល់ (២) ស្ថានភាពប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ច នៃប្រជាពលរដ្ឋរងផលប៉ះពាល់ (៣) បទដ្ឋានគតិយុត្ត និងគំរូស្តង់ដារនៃការទូទាត់សំណង (៤) ផែនការស្តារជីវភាព និងប្រាប់ចំណូល (៥) ការចូលរួម និងសារទុក្ខ (៦) ការរៀបចំស្តាប័ន (៧) ការប៉ាន់ស្មានថវិកាចំណាយ និងគម្រោងពេលវេលានៃការតាំងទីលំនៅថ្មី (៨) ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ។

ក្នុងប្រទេសចិន គម្រោងវារីអគ្គិសនីក្នុងស្រុក អនុវត្តតាមបែបផែននៃការតម្រូវឲ្យមានចំពោះ*បទប្បញ្ញត្តិស្តីពីការទូទាត់សំណងសម្បទានដី និង ការតាំងទីលំនៅថ្មី ដោយសារការសាងសង់ អាងរក្សាទឹក*

ក្នុងកំរិតធំ និងមធ្យម វារីអគ្គិសនី និងការសាងសង់ទំនប់វារីអគ្គិសនី (ឆ្នាំ២០០៦) (ក្រោយពីបានធ្វើឲ្យបទប្បញ្ញត្តិនៃការតាំងទីលំនៅថ្មី នៅសល់ខ្លី ក្នុងឆ្នាំ២០០៦) ព្រមទាំងការបរិយាយលម្អិតផ្នែកបច្ចេកទេសចំនួន៨ចំនុចផ្សេងទៀត (ឆ្នាំ២០០៧)។ ផែនការតាំងទីលំនៅថ្មីគួរតែតម្រូវមានការរៀបចំលើចំនុច ដូចជា (១) ការអង្កេតសង្គមសេដ្ឋកិច្ច (២) ការអង្កេតលើសន្ធស្សន៍រូបវន្ត និងលទ្ធផល (៣) ការតាំទីលំនៅថ្មីរបស់អ្នកតាំងទីលំនៅតំបន់ជនបទ ដែលរាប់បញ្ចូលទាំងការគណនាចំនួនអ្នកតាំងទីលំនៅ និងសមត្ថភាពលើការអនុវត្ត គ្រោងការណ៍តាំងទីលំនៅ ការកំណត់ផែនការតាំងទីលំនៅថ្មីប្រកបដោយលទ្ធផលល្អប្រសើរ ការរៀបចំផែនការផ្លាស់ទីជម្រក ជាដើម។ល។ (៤) ការផ្លាស់ទីជម្រកទៅកាត់ទីប្រជុំជនឬក្រុង (៥) ការផ្លាស់ទីជម្រកទៅកាន់តំបន់ឧស្សាហកម្ម និងសកម្មភាពជំនួញរុករករ៉ែ (៦) ការផ្លាស់ទីជម្រក ឬការសាងសង់ជាថ្មីនូវសំណង់អគារសំខាន់ៗ (៧) ការសាងសង់រោងចក្រសម្រាប់ការពារ (៨) ការធ្វើអាជីវកម្មលើទឹកដែលបានពីអាងស្តុក (៩) វិធានការសម្រាប់បន្តគាំទ្រដល់អ្នកតាំងទីលំនៅថ្មីសម្រាប់ការសាងសង់អាងស្តុកទឹក (១០) ការប៉ាន់ស្មានថវិកាចំណាយសម្រាប់ការទូទាត់សំណងសម្បទានដី និងការតាំងទីលំនៅថ្មី និងសំណងផ្សេងៗទៀត។

ទាំងផែនការតាំងទីលំនៅថ្មីរបស់គម្រោងក្នុងស្រុក (RPD) និងផែនការតាំងទីលំនៅថ្មីរបស់គម្រោងដែលទទួលបានមូលនិធិពីបរទេស (RPF) នឹងត្រូវប្រមូលព័ត៌មានស្តីពីសង្គមសេដ្ឋកិច្ចមូលដ្ឋានត្រូវកំណត់ អត្តសញ្ញាណសហគមន៍រងផលប៉ះពាល់ដោយសារគម្រោង ព្រមទាំងត្រូវវិភាគលើផលប៉ះពាល់នៃគម្រោង ទៅលើគ្រួសារ/បុគ្គល (Ahs/APs) ។ ដូច្នេះ តាមរយៈការរៀបចំផែនការតាំងទីលំនៅថ្មីគម្រោងវារីអគ្គិសនីចិន អាចឆ្លើយតបចំពោះតម្រូវការអនុវត្តជាមូលដ្ឋាន (HSAP) ចំនុច I-9 Assessment 3a and I-10 Assessment 3a ។ ទោះយ៉ាងណា និយាយជារួម ផែនការតាំងទីលំនៅថ្មីរបស់គម្រោងក្នុងស្រុក (RPD) មិនសូវបានគិតគូរពីយេនឌ័រ និងក្រុមងាយរងគ្រោះ ដូចគម្រោងដែលទទួលបានមូលនិធិពីបរទេស (RPF) ឡើយ។ ទន្ទឹមនឹងនេះដែរ ផែនការតាំងទីលំនៅថ្មីរបស់គម្រោងក្នុងស្រុក (RPD) បញ្ជាក់អត្ថន័យលើស្ថិតិនៃទិន្នន័យសន្ធស្សន៍ជារូបវន្ត ចំណែកឯគម្រោងដែលទទួលបានមូលនិធិពីបរទេស (RPF) ផ្តោតសំខាន់លើការវិភាគពីផលប៉ះពាល់លើគ្រួសារ/បុគ្គល (Ahs/APs)។

ប្រអប់អត្ថបទ ៥.៨ ធាតុសំខាន់ៗនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី នៅក្នុងប្រទេសឡាវ

ប្រទេសឡាវ បទដ្ឋានគតិយុត្តិរួមមាន បទប្បញ្ញត្តិច្បាប់ស្តីពីទឹក និងធនធានទឹក (១៩៩៦) ច្បាប់ស្តីពីការការពារបរិស្ថាន (១៩៩៩) ច្បាប់ស្តីពីដីធ្លី (២០០៣) ក្រឹតលេខ១៩២/PM ស្តីពីការទូទាត់សំណង និងការតាំងទីលំនៅថ្មី នៃគម្រោងអភិវឌ្ឍ (២០០៥) គោលការណ៍បច្ចេកទេសស្តីពីការទូទាត់សំណង និងការតាំងទីលំនៅថ្មីនៃគម្រោងអភិវឌ្ឍ (២០០៥) ក្រឹត្យលេខ១១២/PM ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (២០១០) គោលនយោបាយជាតិស្តីពីបរិស្ថាន និង និរន្តរភាពនៃវិស័យថាមពលវារីអគ្គិសនីសង្គម នៃសាធារណរដ្ឋប្រជាធិបតេយ្យឡាវ (២០១១)។

វប្បធម៌ និងទំនៀមទម្លាប់នានា

ក្នុងអំឡុងពេលនៃការរៀបចំផែនការ ការសាងសង់ និងប្រតិបត្តិការ ម្ចាស់គម្រោងគួរពិចារណាលើសម្បត្តិវប្បធម៌ និងសាសនា ទំនៀមទម្លាប់ និងជំនឿផ្សេងៗ។ ម្ចាស់គម្រោង គួរកំណត់ឲ្យបានច្បាស់ពីវិធានការកាត់បន្ថយ និង ផលប្រយោជន៍សង្គមវប្បធម៌ ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរបស់សហគមន៍ជនជាតិដើម និងគួរតែស្ថិតក្នុងលក្ខណៈចុះសម្រុងគ្នាជាមួយសេចក្តីស្រឡាញ់ ចូលចិត្តខាងវប្បធម៌ និងគួរត្រូវបានសម្រេចចិត្ត ដោយមានការពិភាក្សាជាមួយសហគមន៍រងផលប៉ះពាល់។

ការចូលរួមជាសាធារណៈ និងការពិគ្រោះយោបល់

ម្ចាស់គម្រោងត្រូវអនុវត្តកម្មវិធីនៃការតាំងទីលំនៅថ្មី ក្នុងលក្ខណៈមានការចូលរួម តាមរយៈការធានា ឲ្យប្រាកដថាអ្នករងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន និង ភាគីពាក់ព័ន្ធដទៃទៀត ត្រូវបានផ្តល់ព័ត៌មានគ្រប់-គ្រាន់ និងពិគ្រោះយោបល់ ហើយកង្វល់របស់ពួកគេត្រូវបានយកទៅពិចារណាដោះស្រាយនៅគ្រប់ជំហាន នៃរយៈពេលអនុវត្តគម្រោង ជាពិសេសក្នុងអំឡុងពេលរៀបចំផែនការ និង អនុវត្តជំហាននានានៃដំណើរការនៃការផ្តល់សម្បទានដី ការវាយតម្លៃ និងការតាំងទីលំនៅថ្មី។

យន្តការដោះស្រាយចំពោះសារទុក្ខ

ម្ចាស់គម្រោងគួរបង្កើតយន្តការដ៏មានប្រសិទ្ធភាពមួយសម្រាប់ទទួលព័ត៌មាន និង ដោះស្រាយចំពោះសារទុក្ខក្នុងអំឡុងពេលរៀបចំផែនការ និងការអនុវត្តការតាំងទីលំនៅថ្មីនៃគម្រោង ជាមួយអាជ្ញាធរពាក់ព័ន្ធ។

ការចំណាយលើការតាំងទីនៅថ្មី និងថវិកា

ម្ចាស់គម្រោងគួររៀបចំផែនការតាំងទីលំនៅថ្មីរួមជាមួយការប៉ាន់ស្មានលើចំណាយលម្អិតសម្រាប់ការទូទាត់សំណង និងសិទ្ធនឹងទទួលបានការតាំងទីលំនៅថ្មី និងការផ្លាស់ទីជម្រករបស់ប្រជាពរដ្ឋរងផលប៉ះពាល់។

ការធ្វើរបាយការណ៍ និងការចងក្រងទុកជាឯកសារ

ម្ចាស់គម្រោង គួរផ្តល់រាបាយការណ៍ និងឯកសារ ទៅដល់អាជ្ញាមានសមត្ថកិច្ចដើម្បីធ្វើការពិចារណា។ របាយការណ៍ និងឯកសារទាំងនោះគួរមានការបរិយាយអំពីគម្រោង ដែលរួមមានលើចំនុចដូចតទៅ ៖

(ក) ឈ្មោះម្ចាស់គម្រោង
(ខ) ប្រភេទគម្រោង
(គ) វិសាលភាព និងទីតាំងគម្រោង
(ឃ) គោលបំណងគម្រោង
(ង) ចំនួន និងប្រភពពលកម្មដែលនឹងត្រូវប្រើក្នុងអំឡុងពេលសាងសង់ និងប្រតិបត្តិការ
(ច) ការប៉ាន់ស្មានពីចំនួនប្រជាជនដែលនឹងត្រូវរងផលប៉ះពាល់ដោយសារគម្រោង និងប្រភេទ នៃផលប៉ះពាល់
(ឆ) ការប៉ាន់ស្មានលើការចំណាយផ្នែកសង្គមកិច្ច និងផលប្រយោជន៍នៃគម្រោង
(ជ) វិធានការកាត់បន្ថយផលប៉ះពាល់

បន្ទាប់ពីធ្វើការត្រួតពិនិត្យ លើរបាយការណ៍គម្រោង និងឯកសារ វាហាក់បង្ហាញថា គម្រោងនឹងបង្កផលប៉ះពាល់មិនល្អផ្នែកសង្គម ម្ចាស់គម្រោង ត្រូវអនុវត្តការសិក្សាជាចាំបាច់ និងការអង្កេតតាមដាននៅមូលដ្ឋាន រួបបញ្ចូលទាំងជំរឿន សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលខូចខាត និងការអង្កេតសិក្សាផ្នែកសង្គមសេដ្ឋកិច្ចជាមូលដ្ឋាន និងត្រូវរៀបចំរបាយការណ៍ និងឯកសារស្តីពីផលប៉ះពាល់សង្គម ដូចខាងក្រោម និងត្រូវដាក់ជូនទៅកាន់អាជ្ញាធរ ដើម្បីស្នើការការយល់ព្រម ៖

(ក) ការវាយតម្លៃសង្គមជំហានដំបូង (ISA) / ការវាយតម្លៃពីការផ្តល់សម្បទានដី និងទ្រព្យកម្ម
(ខ) ការវាយតម្លៃហេតុប៉ះពាល់សង្គម
(គ) របាយការណ៍សម្បទានដី និងការទូទាត់សំណង
(ឃ) ផែនការស្តីពីការតាំងទីលំនៅថ្មី
(ង) ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP)

ប្រអប់អត្ថបទ ៥៩ ផែនការសកម្មភាព-ទិដ្ឋភាពគន្លឹះ

- មានប្រភេទនៃការតាំងទីលំនៅថ្មីផ្សេងៗគ្នា រួមជាមួយបញ្ហាតែមួយ ៖
  - ការតាំទីលំនៅថ្មីនៅជនបទ
  - ការតាំងទីលំនៅថ្មីនៅទីក្រុង
  - ការតាំងទីលំនៅថ្មីជាខ្សែបណ្តោយ
  - ការតាំងទីលំនៅថ្មីនៅតំបន់ជាក់លាក់
- ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី មានធាតុសំខាន់ៗដូចខាងក្រោម ៖
  - ការកំណត់ឲ្យឃើញច្បាស់ពីផលប៉ះពាល់ដោយសារគម្រោង និង ប្រជាពលរដ្ឋរង-ផលប៉ះពាល់
  - បទដ្ឋានគតិយុទ្ធ សម្រាប់ការផ្តល់សម្បទានដី និងការទូទាត់សំណង
  - បទដ្ឋាននៃការទូទាត់សំណង
  - ការបរិយាយអំពីជំនួយនៃការតាំងទីលំនៅថ្មី និងការស្តាររបរចិញ្ចឹមជីវិត
  - គ្រោងថវិកាចំណាយលម្អិត
  - គម្រោងពេលវេលានៃការអនុវត្ត
  - ការបរិយាយលើការទទួលខុសត្រូវរបស់អង្គភាព
  - បទដ្ឋានសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការពិគ្រោះយោបល់ និងការរៀបចំផែនការអភិវឌ្ឍន៍
  - យន្តការដោះស្រាយលើសារទុក្ខ
  - បទដ្ឋានសម្រាប់ត្រួតពិនិត្យ វាយតម្លៃ និងធ្វើសេចក្តីរាយការណ៍
- ការតាំងទីលំនៅថ្មីគឺជាបញ្ហាមួយរសើប និងស្មុកស្មាញ ហើយទាមទារឲ្យមានធនធានគ្រប់-គ្រាន់ និងបុគ្គលិកមានចរិកលះបង់។
- ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី និងក្រុមជនងាយរងគ្រោះ។

ប្រធានបទពិភាក្សា	ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី អាចក្លាយជាឯកសារដ៏ធំដែលរួមមានព័ត៌មានយ៉ាងច្រើនឥតគណនា ។ ចូរពិភាក្សាលើអ្វីដែលជាកំរិតលម្អិតសមស្របសម្រាប់ប្រភេទខុសៗគ្នានៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ..... តើត្រូវចំណាយពេលប៉ុណ្ណាទើបសមល្មើការតាំងទីលំនៅថ្មី ហើយត្រូវពិនិត្យសារឡើងវិញជារឿយៗលើផែនការទាំងនេះដោយរបៀបណា? ..... ចូរកំណត់គំរូឧទាហរណ៍នៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ដែលមានអនុវត្តនៅក្នុងប្រទេសរបស់អ្នក ចូរពន្យល់ថា ហេតុអ្វីបានជាផែនការទាំងនោះត្រូវបានចាត់ទុកថាជាគំរូឧទាហរណ៍នៃការអនុត្តល្អ ចូរបរិយាយឲ្យបានលម្អិតពីលទ្ធផលនៃការអនុវត្តផែនការទាំងនោះ។ ..... មានការសរសេរជាច្រើនអំពីការផ្លាស់ទីជម្រកដែលពឹងផ្អែកលើដី ។ ចូរពិភាក្សាអំពីការផ្លាស់ទីជម្រកដែលមិនពឹងផ្អែកលើដី ឧទាហរណ៍ នៅតាមមាត់សមុទ្រ និងនៅតាមទ្បូនេសាទតាមទន្លេ និង ចូរបរិយាយថាតើគេអាច និងគួរតែដោះស្រាយចំពោះការផ្លាស់ទីជម្រកនេះដោយរបៀបណា។
លំហាត់	ចូរផ្តល់ឧទាហរណ៍មួយលើមូលដ្ឋានទិន្នន័យដែលអាចប្រើប្រាស់បានសម្រាប់ចាប់យក រក្សាទុក និង ប្រើប្រាស់ទិន្នន័យមូលដ្ឋាន ដែលប្រមូលបានសម្រាប់គោលបំណងរៀបរៀងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។ ..... សម្រាប់ការផ្លាស់ទីជម្រកជាលក្ខណៈរូបវន្ត និងសេដ្ឋកិច្ចនៃប្រជាជនចំនួន២០០គ្រួសារ ចូរផ្តល់វេទិកាចំណាយ និងកម្មវិធីជាក់លាក់លើផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។ ..... ជាមួយឧទាហរណ៍ដែលបានលើកឡើងនៅខាងលើនេះ ចូរអធិប្បាយលម្អិតពីវិធានការជាក់លាក់ ដែលតម្រូវឲ្យអនុវត្ត ដើម្បីជួយដល់ក្រុមងាយរងគ្រោះនៅក្នុងគ្រួសារដែលមានមនុស្សចាស់ចំនួន៣នាក់ និង កុមារចំនួន៥នាក់ និង គ្រួសារដែលមានមនុស្សពិការកាយសម្បទាចំនួន១០។ ..... តាមរយៈការប្រើប្រាស់ល័ក្ខខ័ណ្ឌ ដែលមានជាទូទៅនៅក្នុងប្រទេសរបស់អ្នក ចូររៀបរៀងបទដ្ឋានស្តានប័នតាមប្រភេទ រួមបញ្ចូលការទទួលខុសត្រូវរបស់បុគ្គល តាមរយៈការរៀបចំជាផែនការ និងអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។

៥.៤- ការអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីទិដ្ឋភាពមួយចំនួនទាក់ទងនឹងការអនុវត្តការតាំងទីលំនៅថ្មី ដែលមិនមែនជាការស្មុគ្រចិត្ត។
ទិសដៅ	ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងពីតម្រូវការចាំបាច់ និង ភាពស្មុគស្មាញមួយចំនួន នៃការអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត។
ការអានតាមលំដាប់លំដោយ	ធនាគារពិភពលោក (២០០៤)។ ប្រភពសៀវភៅស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត ។ ការរៀបចំផែនការ និង ការអនុវត្តគម្រោងអភិវឌ្ឍន៍។ ធនាគារពិភពលោក ទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក។

ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី គឺជាគោលការណ៍ណែនាំមួយសម្រាប់ការអនុវត្ត ។ បទ-ពិសោធន៍បានបង្ហាញថា លទ្ធផលនៃការតាំងទីលំនៅថ្មី អាស្រ័យលើគុណភាពនៃការអនុវត្ត ។ ទោះជាមានផែនការល្អបំផុតហើយក្តី ដែលបានរៀបចំឡើងជាមួយការយកចិត្តទុកដាក់យ៉ាងល្អិតល្អន់ធំធេង ក៏ផែនការទាំងនោះមិនអាចធ្វើឲ្យប្រសើរដោយឯកឯងចំពោះជីវភាពរបស់អ្នកតាំងទីលំនៅថ្មីនោះដែរ ។ ការអនុវត្តការតាំងទីលំនៅថ្មី គឺជាការប្រឈមមួយ ហេតុដូច្នេះហើយ កម្មវិធីនៃការតាំងទីលំនៅថ្មីត្រូវតែអនុវត្តដោយយកចិត្តទុកដាក់បំផុត។

៥.៤.១ ការរៀបចំ

ការរៀបចំដើម្បីអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត អាចចាប់ផ្តើមក្នុងអំឡុងពេលជំហានចុងក្រោយនៃការរៀបចំគម្រោង ។ ជំហានសំខាន់ជាដំបូង គឺការធានាឲ្យប្រាកដថា ភ្នាក់ងារអនុវត្ត បានត្រៀមខ្លួនរួចរាល់សម្រាប់ ៖

- ពន្យល់ពីលក្ខណៈពិសេសនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ទៅដល់អ្នកគ្រប់គ្រងគម្រោង បុគ្គលិកគម្រោងសំខាន់ៗ និង បុគ្គលិកទាំងអស់បម្រើការការងារនៅក្នុងភ្នាក់ងារអនុវត្តការតាំងទីលំនៅថ្មី។ ចំណាត់ការសំខាន់ៗមានដូចខាងក្រោម ៖
  - ជាញឹកញាប់បំផុត ក្រុមការងារពាក់ព័ន្ធនឹងការរៀបចំផែនការគម្រោង មិនជាប់ពាក់ព័ន្ធការងារក្នុងអំឡុងពេលសាងសង់ ពោលគឺបុគ្គលិកថ្មីរបស់គម្រោង ដែលជាអ្នកមានវត្តមាននៅតំបន់គម្រោង ដោយមានការយល់ដឹងជាមូលដ្ឋានមានកម្រិតអំពីអ្វីដែលបានកើតឡើង ក្នុងអំឡុងពេលរៀបចំផែនការ។
  - ជាធម្មតាទៅហើយដែលប្រជាពលរដ្ឋដែលចូលរួមពាក់ព័ន្ធ ក្នុងការរៀបចំផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី មិនមែនជាប្រជាពលរដ្ឋដែលត្រូវទទួលខុសត្រូវ ចំពោះការអនុវត្តផែនការទាំងនោះទេ។
  - អាចនឹងមានពេលវេលានៅពេលក្រោយជាច្រើនទៀត ចន្លោះពេលនៃការបញ្ចប់ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី និងការអនុវត្តជាក់ស្តែងលើផែនការនេះ។

អាស្រ័យហេតុនេះ វាជាការចាំបាច់ណាស់សម្រាប់បុគ្គលិកទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការដាក់ឲ្យអនុវត្តជាសាធារណៈលើផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី អាចប្រាប់ពីប្រវត្តិ ខ្លឹមសារ ធាតុសំខាន់ និងកម្មវិធីសំខាន់ៗ ។ ត្រូវលើកទឹកចិត្តឲ្យបុគ្គលិកអាចជជែកពិភាក្សាពីភាពស្មុកស្មាញនានា និង អាចកំណត់ឲ្យឃើញច្បាស់ពីបញ្ហាដែលអាចកើតមាន តាមរយៈការគាំទ្រឲ្យមានការបណ្តុះបណ្តាល ប្រសិនបើតម្រូវឲ្យមាន។

- រៀបចំធនធានបុគ្គលិកទៅតាមតម្រូវការចំបាច់ នៃគម្រោងពេលវេលាអនុវត្តផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី។ តម្រូវការចាំបាច់ចំពោះបុគ្គលិក ទាក់ទងនឹងចំនួន និងជំនាញ នឹងប្រែប្រួលទៅតាមជំហានផ្សេងៗគ្នា នៃការដាក់ឲ្យអនុវត្តជាសាធារណៈ លើផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ។ ដើម្បីធានាឲ្យប្រាកដថា កម្រិតបុគ្គលិកផ្សាភ្ជាប់នឹងតម្រូវការជំនាញ និងចំនួនបុគ្គលិក ត្រូវមានការប្រុងប្រយ័ត្នជាមុនក្នុងការរៀបចំផែនការ ក៏ដូចជាពេលវេលានៃការជ្រើសរើសបុគ្គលិក និងការបណ្តុះបណ្តាលបុគ្គលិក (ក្នុងក្របខ័ណ្ឌតម្រូវការចាំបាច់នៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី) ។
- ដើម្បីចងភ្ជាប់ចំនុចខាងលើ មុនការចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន អង្គភាពអនុវត្តការតាំងទីលំនៅថ្មី ត្រូវតែមានបំពាក់សម្ភារគ្រប់គ្រាន់ (ឆ្លៀងដូចជា រថយន្ត កុំព្យូទ័រ បន្ទប់ការិយាល័យ គ្រឿងសង្ហារឹម ឧបករណ៍ទំនាក់ទំនង ជាដើម)។
- ត្រូវធានាឲ្យប្រាកដថា ភ្នាក់ងាររដ្ឋាភិបាលទាំងអស់ដែលដើរតួនាទីក្នុងដំណើរការនៃការតាំងទីលំនៅថ្មី គឺជាភ្នាក់ងារសំខាន់ សំដៅធ្វើឲ្យការសម្របសម្រួលរវាងភាគីទាំងអស់បានដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ ការសម្របសម្រួលមានសារៈសំខាន់ខ្លាំងណាស់ និង គួរធ្វើឲ្យសកម្មឡើងមុននៃការចាប់ផ្តើមការតាំងទីលំនៅថ្មី។ នៅក្នុងលក្ខណៈនេះ ត្រូវកំណត់គ្រោងការឲ្យមានការចាប់ផ្តើមមួយប្រកបដោយលក្ខណៈរលូន ចំពោះកម្មវិធីនៃការតាំងទីលំនៅថ្មីជាមួយនឹងបញ្ហាដែលមានចំនួនតិចតួចបំផុត។
- បន្តការពិគ្រោះយោបល់ជាមួយអ្នកត្រូវផ្លាស់ទីជម្រក និង សហគមន៍ជាម្ចាស់ផ្ទះ ។ ភាគច្រើននៃគម្រោង តែងតែមានគម្លាតរវាងការរៀបចំផែនការតាំងទីលំនៅថ្មី និងការអនុវត្តជាក់ស្តែង។ ក្នុងអំឡុងពេលនេះ តម្រូវការ និងអាទិភាព របស់អ្នករងផលប៉ះពាល់អាចនឹងផ្លាស់ប្តូរ ដោយការទាមទារឲ្យមានការកែតម្រូវលើកម្មវិធីតាំងទីលំនៅថ្មី ។ លើសពីនេះទៅទៀត វាជាការចាំបាច់ក្នុងការរក្សាទំនាក់ទំនងគ្រប់ពេលវេលា សំដៅសម្រាលការភ័យខ្លាច ការព្រួយបារម្ភ និងការរំពឹងរបស់អ្នករងផលប៉ះពាល់។
- កែប្រែសាជាថ្មីលើការអង្កេត ឆ្លៀងដូចជា ជំរឿន ការអង្កេតសិក្សាសង្គម សេដ្ឋកិច្ច និងការប្រើប្រាស់ដីធ្លី ។ គម្រោងធំៗជាច្រើន ដូចជា ៖ គម្រោងទំនប់វារីអគ្គិសនី និងសំណង់អាគារថាមពលវារីអគ្គិសនីមានដំណើរការរយៈពេលយូរ ជាមួយនឹងរយៈកន្លងដ៏យូរអង្វែងរវាងការរៀបចំផែនការ និង ការអនុវត្តការតាំងទីលំនៅថ្មី ។ នៅក្នុងករណីបែបនេះ កាលៈទេសៈអាចនឹងមានការផ្លាស់ប្តូរ ដោយទាមទារឲ្យមានការកែប្រែសារជាថ្មីឡើងវិញនូវទិន្នន័យសង្គម (ប្រជាសាស្ត្រសង្គមសេដ្ឋកិច្ច និង ការប្រើប្រាស់ដីធ្លី) ក៏ដូចជាស្ថានភាពសង្គមសេដ្ឋកិច្ចនៃប្រជាពលរដ្ឋរង-ផលប៉ះពាល់ (ប្រជាពលរដ្ឋខ្លះអាចស្លាប់ អាចមានសមាជិកគ្រួសារថ្មីទើបតែកើត អ្នកខ្លះកើនអាយុ និងឈានចូលក្នុងចំណាត់ថ្នាក់ជា " ជនងាយរងគ្រោះ" ជាដើម។ ការកែប្រែព័ត៌មានជាថ្មី

បែបនេះ គឺជាមានតម្លៃបំផុតសម្រាប់ការផ្តល់ធនធានលើផែនការសកម្មភាព ស្តីពីការតាំងទីលំនៅថ្មី និង ការដំណើរការទៅដោយរលូន ក៏ដូចជាការសម្តែងជាសាធារណៈប្រកបដោយជោគជ័យ។

៥.៤.២ ការអនុវត្ត

៥.៤.២.១ ការផ្តល់ប្រាក់ទូទាត់សំណង

ការផ្តល់ប្រាក់ទូទាត់សំណង គឺជាសកម្មភាពដ៏មានសារៈសំខាន់នៃកម្មវិធីតាំងទីលំនៅថ្មី ស្ទើរតែទាំងអស់ ។ វិធានការ ដូចខាងក្រោមអាចជួយឲ្យដំណើរការទូទាត់សំណងប្រព្រឹត្តិទៅដោយរលូន ៖

- ការផ្តល់ប្រាក់ទូទាត់សំណងចូលទៅក្នុងគណនីធនាគារ និង ដោយមិនផ្តាល់ទៅឲ្យអ្នកដែលរងផលប៉ះពាល់។ ការទូទាត់នេះ ជួយកាត់បន្ថយគ្រោះថ្នាក់នៃការស្វកប៉ាន់ និងអំពើពុករលួយនៅក្នុងដំណើរការនៃការទូទាត់សំណងនេះ។ សំណងដោយការដាក់ប្រាក់ក្នុងគណនីធនាគារ គឺអាចជួយកាត់បន្ថយការចំណាយដែលមិនចាំបាច់ ។ ប្រការនេះ គឺដោយសារការជាប់ពាក់ព័ន្ធនឹងធនាគារ ក្នុងដំណើរការទូទាត់សំណង ដែលចង់ផ្តល់ព័ត៌មានដល់បុគ្គលដែលរងផលប៉ះពាល់ឲ្យបានដឹងពីជម្រើសនៃការសន្សំ និង ការផ្តល់ឥណទាន ដែលអាចជួយឱ្យពួកគេអាចស្តារជីវភាពឡើងវិញ ។ ជម្រើសដ៏ល្អបំផុតនោះ គឺត្រូវប្រើគណនីធនាគាររួមគ្នា ដែលតម្រូវឱ្យមានការអនុញ្ញាតពីភាគីអ្នករងផលប៉ះពាល់ និងភ្នាក់ងារតាំងទីលំនៅថ្មី។ សំខាន់ជាងនេះទៅទៀត គឺវាត្រូវបានទទួលស្គាល់ថានៅក្នុងករណីជាច្រើនទៀត បុគ្គលដែលរងផលប៉ះពាល់ដោយសារការតាំងទីលំនៅថ្មី ដែលរស់នៅតាមតំបន់ជនបទដាច់ស្រយាល មិនមានទទួលបាននូវប្រព័ន្ធធនាគារជាផ្លូវការឡើយ។ នៅក្នុងករណីបែបនេះ សំណង ជាសាច់ប្រាក់ ត្រូវបានតម្រូវឱ្យបង់ទៅបុគ្គលនោះ។ នេះអាចថាជាការបូកសរុបទាំងអស់ ឬ ក្នុងទម្រង់ជាដុំសាច់ប្រាក់ ដែលត្រូវបង់ឲ្យក្នុងអំឡុងពេលមួយ ។ ដោយសារការផ្តល់ប្រាក់ទូទាត់សំណងជាសាច់ប្រាក់ ភាគច្រើនត្រូវបានធ្វើនៅក្នុងតំបន់ជនបទដាច់ស្រយាល ដែលជាញឹកញាប់ពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ច្រើនគួរសម ដែលជាហេតុធ្វើឲ្យមានព្រួយបារម្ភចំពោះសុវត្ថិភាពរបស់ការិយាល័យទទួលបង់ប្រាក់សំណង និង សម្រាប់មនុស្សដែលទទួលរងផលប៉ះពាល់ ដែលជាអ្នកទទួលបានសំណងជាសាច់ប្រាក់សុទ្ធ នោះផងដែរ។
- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គួរចូលរួមនៅក្នុងដំណើរការនៃការទូទាត់ប្រាក់សំណងនេះ។ នៅក្នុងករណីជាច្រើន នៅមានការមន្ទិលសង្ស័យទាក់ទងនឹងការទូទាត់សំណងនេះ ។ ការចូលរួមនេះ អាចជួយជម្រុញឲ្យមានតម្លាភាព ចំណែកឯអង្គការមិនមែនរដ្ឋាភិបាល ជាធម្មតាក៏អាចជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ ក្នុងការសម្រេចចិត្តលើការប្រើប្រាស់ឲ្យបានល្អបំផុតចំពោះប្រាក់ទូទាត់សំណង ដូចជា៖ ដើម្បីទទួលបានធនធានដែលហុចផលកាន់តែច្រើនជាដើម។
- ការជូនដំណឹងដល់ជាសមាជិកក្នុងគ្រួសារទាំងអស់អំពីប្រាក់ទូទាត់សំណង គឺជាការសំខាន់។ ជាញឹកញាប់បំផុត មេគ្រួសារគឺជាអ្នកត្រូវទទួលប្រាក់សំណង បើទោះបីជាអ្នកទទួលផលនៃការផ្តល់សំណងនេះ គួយ៉ាងដូចជាសមាជិកក្នុងគ្រួសារទាំងមូល ដែលអាចមានចំនួនច្រើនជាងនេះក្តី។ ការជូនដំណឹងឲ្យសមាជិកគ្រួសារបានដឹងគ្រប់ៗគ្នា មិនត្រឹមអាចធានាដល់ការបែងចែកដោយត្រឹមត្រូវ និងសមធម៌នៃសំណងនោះតែប៉ុណ្ណោះទេ វាក៏អាចនាំទៅដល់ការប្រើប្រាស់លុយ

ដែលបានមកឲ្យកាន់តែប្រសើរឡើង (សង្ឃឹមថាប្រាក់ទាំងនោះ នឹងមិនយកទៅប្រើក្នុងផ្លូវខុស ជាក់ស្តែងដូចជា ការសេពសុរា ការទិញថ្នាំជក់ ឬ ការទិញសម្ភារៈទំនើបដែលមិនជាការចាំបាច់ជាដើម)។

- ត្រូវចេះរក្សទុក និងកំណត់ត្រាប្រាក់សំណងនេះ ដោយការផ្ចិតផ្ចង់ និងមានភាពសុក្រិតត្រឹមត្រូវ។ ជាអកុសល សាច់ប្រាក់ និង ការទូទាត់សំណង នាំឱ្យមានជម្លោះជាញឹកញាប់ ទៅលើអ្វីខ្លះដែលត្រូវបានសង ទៅលើចំនួនប្រាក់សំណង និងពេលវេលានៃការសង។ល។ អង្គភាពទទួលបន្ទុកកិច្ចការតាំងទីលំនៅថ្មីចាំបាច់បំផុត ត្រូវរក្សាឲ្យបាននូវកំណត់ត្រាជាឯកសារ និងទិន្នន័យដែលបានដាក់បញ្ចូលរួចរាល់ ដូចជា ៖ កំណត់ត្រាធនាគារ វិក័យប័ត្រទូទាត់សំណងជាសាច់ប្រាក់ រូបថត ជាដើម និងសំណៅផ្សេងៗទៀត ទាក់ទងនឹងការបង់ប្រាក់សំណងនេះ ។ ការកត់ត្រាឯកសារទាំងនេះ ពិតជាមានតម្លៃខ្លាំងណាស់នៅពេលកើតមានជម្លោះណាមួយ ដែលត្រូវតែដោះស្រាយ ដើម្បីជាផលប្រយោជន៍របស់អ្នករងផលប៉ះពាល់ និងដើម្បីផលប្រយោជន៍គម្រោង ក៏ដូចជាសុខមាលភាពជារួមនៃទំនាក់ទំនងរវាងប្រជាសហគមន៍ និងគម្រោងផ្ទាល់ផងដែរ។

៥.៤.២.២ ការតាំងលំនៅថ្មីជាលក្ខណៈរូបវន្ត

ការតាំងលំនៅថ្មីជាលក្ខណៈរូបវន្ត គឺជាការផ្លាស់ប្តូរមនុស្សមកពីទីកន្លែងរស់នៅបច្ចុប្បន្ន ទៅកាន់ទីកន្លែងរស់នៅថ្មីមួយទៀត ដែលអាចក្លាយជាទិដ្ឋភាពមួយប៉ះទង្គិចផ្លូវអារម្មណ៍ដ៏ធំបំផុត ដែលទាក់ទងទៅនឹងការតាំងទីលំនៅថ្មី។

- វាជាការចាំបាច់ណាស់ក្នុងការបញ្ជាក់អះអាងប្រាប់អ្នកដែលរងផលប៉ះពាល់ថា ពួកគេបានត្រៀមខ្លួនជាស្រេចបាច់ហើយ ដើម្បីទទួលយកតំបន់តាំងទីលំនៅថ្មីពិតប្រាកដ (ដែលត្រូវបានជ្រើសរើសក្នុងអំឡុងដំណាក់កាលធ្វើផែនការតាំងលំនៅថ្មី នៅក្នុងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងនោះ ។ នេះជាប់ពាក់ព័ន្ធនឹងការធ្វើឱ្យប្រាកដថា រាល់បុគ្គលក្នុងគ្រួសារ/អង្គភាព គឺមានឆន្ទៈក្នុងការទទួលកាន់កាប់តំបន់តាំងលំនៅថ្មីពិតប្រាកដរបស់ខ្លួន។ ប្រសិនបើគ្រួសារណាមួយដែលរងផលប៉ះពាល់ បានរកឃើញថាលក្ខណៈពិសេសនៃតំបន់តាំងទីលំនៅថ្មីពិតប្រាកដនោះ មិនគួរជាទីគាប់ចិត្ត ជួបការលំបាក ឬ មិនសមរម្យចំពោះវិស័យវប្បធម៌ ត្រូវរៀបចំការកែលម្អតំបន់នោះឡើងវិញ ឬ ត្រូវផ្តល់ជម្រើសទីតាំងថ្មីមួយទៀតដែលអាចជំនួសបាន។
- តំបន់តាំងទីលំនៅថ្មី ត្រូវតែរៀបចំឲ្យបានរួចរាល់ និងបញ្ចប់ជាស្រេច មុនពេលកាលបរិច្ឆេទនៃការផ្លាស់ទីពិតប្រាកដ ។ មានការលើកស្នើឡើងថា 'តំបន់តាំងទីលំនៅថ្មីបណ្តោះអាសន្ន' ត្រូវតែជៀសវាងនូវការចំណាយគ្រប់បែបយ៉ាងទាំងអស់។ ដើម្បីសម្រេចបាននូវគោលបំណងនេះ តម្រូវឱ្យមានការសម្របសម្រួលយ៉ាងជិតស្និទ្ធបំផុត រវាងអង្គភាពទទួលបន្ទុកកិច្ចការតាំងទីលំនៅថ្មី និង សមាជិកក្រុមការងាររបស់គម្រោង ដែលទទួលខុសត្រូវចំពោះការផ្តល់សម្បទានដី ។ ប្រការនេះ តម្រូវឲ្យមានត្រឡប់វិញនូវភាពស្របគ្នាយ៉ាងគៀកកិតជាមួយនឹងអ្នកគ្រប់គ្រងគម្រោងដែលទទួលខុសត្រូវចំពោះកម្មវិធីសាងសង់របស់គម្រោងទាំងមូល។ ប្រសិនបើអាចធ្វើទៅបានទីតាំងលំនៅថ្មី គួរតែត្រូវរៀបចំឲ្យបានចប់រួចរាល់ មុនពេលការរុះរើជារូបវន្ត ដោយសារការធ្វើបែបនេះអាចឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ រ៉ាប់រងសកម្មភាពរុះរើពីលំនៅដ្ឋានបច្ចុប្បន្ន និងលំនៅដ្ឋានថ្មី ជាពិសេសការបង្កបង្កើតធនធានហូចផលនានានៅតំបន់តាំងទីលំនៅថ្មី ដែល

នឹងផ្តល់ភាពធូរស្រាលដ៏មានសារៈផលប្រយោជន៍ ក្នុងអំឡុងពេលនៃការតាំងលំនៅថ្មីជាលក្ខណៈរូបវន្ត។

- អង្គភាពទទួលបន្ទុកកិច្ចកាតាំងទីលំនៅថ្មី គួរតែផ្តល់ជាជំនួយដល់គ្រួសាររងផលប៉ះពាល់ ក្នុងការផ្លាស់ប្តូរទីតាំងលំនៅ ។ ការផ្តល់ជំនួយនេះ ជាប់ពាក់ព័ន្ធនឹងទិដ្ឋភាព ដូចជាជំនួយក្នុងការដឹកជញ្ជូន (គ្រឿងសង្ហារឹមដែលមាននៅក្នុងលំនៅដ្ឋាន និងផលប៉ះពាល់នានា សត្វចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របី ។ល។ និង អនុញ្ញាតឲ្យអ្នកដែលរងផលប៉ះពាល់ អាចយកទៅជាមួយនូវទ្រព្យសម្បត្តិ ដែលលែងប្រើប្រាស់របស់ពួកគាត់ទៅកាន់លំនៅដ្ឋានថ្មីផង។

គួរធ្វើការប៉ាន់ស្មានលើកម្រិតនៃការធ្វើផែនការ និងចំនួននៃកិច្ចខិតខំប្រឹងប្រែង ដែលទាមទារឲ្យមានដើម្បីកសាងលំនៅដ្ឋានជារូបវន្ត ។ វាគឺជាការរ៉ាប់រងដ៏ប្រឈមមួយ និង អាស្រ័យលើចំនួនប្រជាជនដែលរងផលប៉ះពាល់ដែលបានចូលរួមពាក់ព័ន្ធអាចវិសាលគមជាច្រើនខែ។ ក្នុងន័យនេះ គួរតែយកចិត្តទុកដាក់ដោយមិនត្រូវរៀបចំតាំងទីលំនៅឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ ក្នុងអំឡុងពេលមិនអំណោយផលនោះទេ តួយ៉ាងដូចជា ល័ក្ខខ័ណ្ឌអាកាសធាតុមិនល្អ ឬ រដូវការនៃការប្រារព្ធពិធីផ្សេង ។ល។ បន្ថែមពីលើនេះទៀតត្រូវផ្តល់ជាជំនួយពិសេសដល់ក្រុមដែលងាយរងគ្រោះក្នុងការបំលាស់ទីជារូបវន្ត។

៥.៤.២.៣ ការធ្វើឲ្យស្របគ្នារវាងការតាំងទីលំនៅថ្មី និងកម្មវិធីសាងសង់របស់គម្រោងទាំងមូល

បទពិសោធន៍ បានបង្ហាញថានៅក្នុងគម្រោងជាច្រើន ការអនុវត្តការតាំងលំនៅថ្មីភាគច្រើនធ្វើឡើងក្រោយពេលកំណត់ បន្ទាប់ពីតម្រូវការផ្តល់សម្បទានរបស់គម្រោង។ ភាគច្រើនបំផុត ដើម្បីកុំឲ្យការសាងសង់របស់គម្រោងត្រូវពន្យារពេល (ជាមួយនឹងការកើនឡើងនៃការចំណាយរួមផ្សំ ដែលកើតចេញពីការពិន័យ ឬ ការខូចខាតពេលវេលា) អ្នករងផលប៉ះពាល់ត្រូវតាំងទីលំនៅថ្មីនៅទីតាំងបណ្តោះអាសន្នសិន ទម្រាំដល់ពេលវេលាបញ្ចប់ការតាំងទីលំនៅ សម្រាប់ការតាំងទីលំនៅជាអចិន្ត្រៃយ៍ ។ ប្រការនេះ គឺជាស្ថានភាពមិនល្អមួយដែលគួរតែជៀសវាងឲ្យបាន តាមរយៈការតម្រូវឱ្យអនុវត្តឲ្យបានទាន់ពេលវេលា និងអភិវឌ្ឍឲ្យបានទាន់ពេលចំពោះការផ្តល់សម្បទានដី សម្រាប់តាំងលំនៅថ្មី ។ ការធ្វើបែបនេះ តម្រូវឱ្យមានសកម្មភាព ដូចខាងក្រោម ៖

- ធ្វើជំរឿនលម្អិត និង ការស្ទង់មតិសង្គមសេដ្ឋកិច្ចនៃគ្រួសារដែលរងផលប៉ះពាល់។
- ការផ្តល់ប្រាក់ទូទាត់សំណងសម្រាប់ទ្រព្យសម្បត្តិរងផលប៉ះពាល់។
- ការកំណត់អត្តសញ្ញាណតំបន់សម្រាប់តាំងទីលំនៅថ្មី និង តំបន់សម្រាប់កសិកម្ម (ប្រសិនបើគម្រោងតម្រូវឲ្យមាន) ដែលអាចទទួលយកបាន សម្រាប់ប្រជាជនដែលត្រូវ ផ្លាស់ទីលំនៅ។
- ការអភិវឌ្ឍន៍តំបន់តាំងទីលំនៅថ្មី រួមបញ្ចូលទាំងការផ្តល់ជូននូវការកែលម្អស៊ីវិល និង ផល-ប្រយោជន៍តាមតម្រូវការផ្នែកកសិកម្មជាមូលដ្ឋាន។
- ការផ្តល់ជូនទីតាំងលំនៅថ្មី សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់អ្នកដែលរងផលប៉ះពាល់។
- ផ្តល់ការងារ ប្រសិនបើការផ្តល់ជម្រើសការងារ គឺជាផ្នែកមួយនៃកញ្ចប់ការតាំងលំនៅថ្មីនោះដែរ។
- ការផ្តល់ជូនការបណ្តុះបណ្តាល គ្រាប់ពូជ ទុន ឥណទាន និងការផ្តល់សិទ្ធិទទួលបានដទៃទៀត ប្រសិនបើកញ្ចប់នៃការតាំងទីលំនៅថ្មី មានរួមបញ្ចូលជំនួយសម្រាប់ការជួលដោយខ្លួនឯង។
- ការទូទាត់សំណងជាសាច់ប្រាក់ សម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ ប្រសិនបើអ្នករងផលប៉ះពាល់បានជ្រើសយកជម្រើសទូទាត់សំណងជាសាច់ប្រាក់។

៥.៤.២.៤ ការកសាងឡើងវិញ និងការរុះរើទីកន្លែង ដោយការសងជំនួសជាលំនៅដ្ឋានថ្មី

នៅកន្លែងដែលមានការសាងសង់លំនៅដ្ឋានថ្មី នៅក្រោមកម្មវិធីនៃការតាំងលំនៅថ្មី គំរូប្លង់ផ្ទះ និងម៉ូដផ្ទះ ក៏ដូចជាទីតាំងនៃហេដ្ឋារចនាសម្ព័ន្ធសហគមន៍ គួរតែត្រូវបានកំណត់ ដោយមានការចូលរួម និងការព្រមព្រៀងពីម្ចាស់តាំងទីលំនៅថ្មី។ ប្រជាពលរដ្ឋ និង/ឬ សហគមន៍រងផលប៉ះពាល់អាចជួ ធ្វើការរចនា បំពេញតាមតម្រូវការជាក់ស្តែងរបស់ពួកគេ ដូចជា ៖ ទីកន្លែងសម្រាប់បសុសត្វ សួនច្បារ និង សម្រាប់សកម្មភាពផ្សេងទៀត ដែលអាចនឹងមិនច្បាស់ចំពោះអង្គភាពទទួលបន្ទុកកិច្ចការតាំងលំនៅថ្មី ។ នៅមានជម្រើសក្នុងការសាងសង់លំនៅដ្ឋានជាច្រើនទៀត ដែលគួរតែជាផ្ទះដែលមានស្តង់ដារល្អ ។ បើអាចធ្វើទៅបាន គួរតែអនុញ្ញាតឱ្យអ្នករងផលប៉ះពាល់មានជម្រើស ក្នុងការសង់លំនៅដ្ឋាន ដើម្បីអាចបន្ថែមធនធានផ្ទាល់ខ្លួនរបស់ពួកគេ ដូច្នេះពួកគេអាចទទួលបានផ្ទះដែលមានទំហំធំ ឬ ប្រសើរជាងនេះ ទាំងពេលភ្លាមៗ ឬ ពេលទៅមុខទៀត ។ នៅក្នុងករណីមួយចំនួនជម្រើសនៃការសាងសង់លំនៅដ្ឋាន គួរតែរួមបញ្ចូលជម្រើសមួយជាសាច់ប្រាក់ ដែលអនុញ្ញាតឱ្យអ្នករងផលប៉ះពាល់អាចសាងសង់ផ្ទះផ្ទាល់ខ្លួនរបស់ពួកគេ ឬ ផ្លាស់ទីទៅកន្លែងផ្សេង ។ អ្វីដែលសំខាន់គឺ ជម្រើសនៃការសង់លំនៅដ្ឋាន មិនគួរធ្វើឲ្យលើសពីលទ្ធភាពហិរញ្ញវត្ថុជាធម្យមរបស់បុគ្គលដែលរងផលប៉ះពាល់ ដើម្បីកុំឲ្យនាំទៅដល់ការជំពាក់បំណុលតាមរយៈការយកវត្ថុផ្សេងៗទៅដាក់បញ្ចាំ ការជួល វត្ថុមានប្រយោជន៍ និងការចំណាយផ្សេងៗទៀត ។

នៅក្នុងកម្មវិធីនៃការតាំងលំនៅថ្មីជាច្រើននៅតាមជនបទ សំណួរសំខាន់គឺនៅត្រង់ ថាតើអ្នកតាំងលំនៅថ្មី ចង់រស់នៅក្នុងសហគមន៍ផលិតនុយក្លេអ៊ែរ ឬ យ៉ាងណា ឬ មួយនៅលើដីស្រែចំការរបស់ខ្លួន តាមបណ្តោយផ្លូវ ឬ អាស្រ័យទៅតាមជម្រើសដែលអាចជំនួសបាន ឬការប្របាច់បញ្ចូលជម្រើសផ្សេងៗ។ ភូមិអាករដែលមានការផលិតនុយក្លេអ៊ែរ មានអត្ថប្រយោជន៍គៀកជិតហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងគ្រួសារដទៃទៀតក៏ពិតមែន ប៉ុន្តែភូមិទាំងនោះក៏អាចបង្កើនរយៈចំងាយឆ្ងាយពីដីកសិកម្មសម្រាប់សមាជិកសហគមន៍មួយចំនួន ។ ការរស់នៅតាមបណ្តោយផ្លូវដែលអាចងាយស្រួលដឹកជញ្ជូនទៅមកជាង និងអាចផ្តល់នូវជម្រើ នៃការចិញ្ចឹមជីវិតបន្ថែមទៀត ។ គួរអនុញ្ញាតឱ្យសហគមន៍តាំងទីលំនៅថ្មី អាចជ្រើសរើសជម្រើសយ៉ាងល្អបំផុតតាមតម្រូវការ និងចំណង់ចំណូលចិត្តផ្នែកសង្គមវប្បធម៌របស់ពួកគេ។ ការជាប់ពាក់ព័ន្ធនឹងជម្រើសផ្សេងៗ គួរត្រូវបានពិភាក្សាយ៉ាងហ្មត់ចត់ជាមួយនឹងគ្រួសារ ដែលទទួលរងផលប៉ះពាល់។

- នៅក្នុងក្របខ័ណ្ឌនៃការបែងចែកលំនៅដ្ឋាន លំនៅដ្ឋានថ្មី គួរតែត្រូវបានបម្រុងទុក ផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យដែលបានកំណត់យ៉ាងច្បាស់ថា អ្នកតាំងលំនៅថ្មីត្រូវតែយល់ និងដែលពួកគេបានព្រមព្រៀងគ្នារួចហើយ ។ អង្គភាពទទួលបន្ទុកកិចការតាំងទីលំនៅថ្មី គួរជៀសវាងឲ្យបាននូវការបែងចែកលំនៅដ្ឋានដោយបំពាន ព្រោះអ្នកតាំងលំនៅថ្មីអាចនឹងយល់ឃើញថាជាការបែងចែកគ្មានលក្ខណៈតម្លាភាព និងធ្វើឡើងដោយអយុត្តិធម៌។
- ប្រសិនបើអ្នកតាំងលំនៅថ្មី មានបំណងចង់សាងសង់លំនៅដ្ឋានរបស់ពួកគេ ដោយខ្លួនគេជំនួសវិញ ចាំបាច់ត្រូវតែផ្តល់ជាជំនួយ ។ ជាពិសេស ការរៀបចំគួរតែត្រូវបានធ្វើឡើង ដើម្បីធានាឲ្យប្រាកដថា អ្នកតាំងលំនៅដ្ឋានមានពេលវេលាគ្រប់គ្រាន់ ដើម្បីរុះរើលំនៅដ្ឋានចាស់ ផ្នែរសម្ភារៈដែលប្រើការលែងបាន ឬ ទទួលបានថ្មី និងដើម្បីកសាងលំនៅដ្ឋានថ្មីនៅលើតំបន់មានស្រាប់ និងដែលបានរៀបចំគ្រប់គ្រាន់ជាស្រេច។ អង្គភាពទទួលបន្ទុកកិច្ចការតាំងលំនៅថ្មីគួរតែត្រូវបានត្រួតពិនិត្យមើលពីល្បឿន និងដំណើរការនៃការសាងសង់ដើម្បីអាចដោះស្រាយបានទាន់ពេលវេលាចំពោះបញ្ហាដែលកើតមានហួសពីការគ្រប់គ្រង។ ជាធម្មតា ការរៀបចំជា

ពិសេស ចាំបាច់ត្រូវផ្តល់ឲ្យដល់ជនងាយរងគ្រោះ (មនុស្សចាស់ មេគ្រួសារជាស្ត្រី ឬ មនុស្សពិការកាយសម្បទា) រួមជាមួយនឹងធនធាន និងកម្លាំងពលកម្មបន្ថែម សម្រាប់ការការបំលាស់ទី និងការកសាងឡើងវិញ។

- ប្រសិនបើមិនអាចជៀសវាងបានទាំងស្រុងទេ វាអាចចាំបាច់ត្រូវរៀបចំផ្តល់ការស្នាក់អាស្រ័យបណ្តោះអាសន្ន។ បន្ថែមទៅនឹងការផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ការរៀបចំអន្តរកាលនេះ អាចតម្រូវឲ្យអង្គភាពទទួលបន្ទុកកិច្ចការតាំងទីលំនៅថ្មី ជួយផ្តល់ជំនួយលើផ្នែកធ្វើដំណើរទៅ ឬ មកពីកន្លែងធ្វើការ ការចំណាយផ្សេងៗ ការដឹកជញ្ជូនជាដើម។

៥.៤.២.៥ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម

តំបន់តាំងទីលំនៅថ្មី អាចត្រូវបានរៀបចំបង្កើតឡើង និងនៅទំនេរទាំងស្រុង ឬអាចមានសហគមន៍ជាម្ចាស់ជាអ្នករស់នៅ ។ នៅក្នុងព្រឹត្តិការណ៍ណាមួយ វានឹងជាការចាំបាច់ដើម្បីយកចិត្តទុកដាក់ ចំពោះហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលនឹងត្រូវទាមទារដោយអ្នកតាំងទីលំនៅ និងសហគមន៍ជាម្ចាស់។

- ប្រសិនបើអ្នកតាំងលំនៅថ្មីត្រូវបានផ្លាស់ប្តូរទៅកាន់សហគមន៍ដែលមានស្រាប់ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មរបស់ម្ចាស់សហគមន៍ ឧទាហរណ៍ដូចជា សាលារៀន មណ្ឌលសុខភាព ការផ្គត់ផ្គង់ ទឹកស្អាតនិងលូទឹកសំអុយ និងផ្លូវថ្នល់ គួរតែត្រូវបានពង្រីក ឬ ធ្វើឱ្យបានប្រសើរឡើង។ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសហគមន៍នៅក្នុងទីតាំងថ្មីនេះ គួរតែមានកម្រិតដូចគ្នា ប្រសិនបើមិនបានល្អប្រសើរជាងកន្លែងរស់នៅពីមុនរបស់អ្នកដែលរងផលប៉ះពាល់នោះទេ។ ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវា ដែលមានលក្ខណៈល្អប្រសើរអាចជួយដល់ម្ចាស់សហគមន៍ ដើម្បីដោះស្រាយជាមួយនឹងការកើនឡើងនៃតម្រូវការ ក៏ដូចជាផ្តល់ឲ្យពួកគេនូវចំណាប់អារម្មណ៍ជាវិជ្ជមាននៃដំណើរការតាំងលំនៅថ្មីនោះ ។ ស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មនៅក្នុងតំបន់តាំងទីលំនៅថ្មី មានលក្ខណៈស្តង់ដារខ្ពស់ បើប្រៀបធៀបទៅនឹងសហគមន៍ជាម្ចាស់ គួរតែជៀសវាងដោយសារស្ថានភាពបែបនេះជៀសមិនផុតពីការឈានទៅរកការប៉ះទង្គិចគ្នា និងមានអារម្មណ៍មិនល្អ ដោយសារដំណើរការតាំងលំនៅថ្មី។ លក្ខណៈស្តង់ដារដូចគ្នា គួរអនុវត្តសម្រាប់អ្នកតាំងលំនៅថ្មី និងសហគមន៍ជាម្ចាស់។
- ប្រសិនបើមានការទាមទារឱ្យមានហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មថ្មី មិនត្រូវរិតត្បិតចំពោះការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មរបស់ប្រជាពលរដ្ឋដែលតាំងទីលំនៅឡើយ ដូចជាសំណង់អាគារសាលារៀន ដែលជាចំណង់ចំណូលចិត្ត ដែលត្រូវផ្តល់ឲ្យសហគមន៍តាំងទីលំនៅជាដើម។ ប្រសិនបើមាន ហេដ្ឋារចនាសម្ព័ន្ធថ្មីដែលបានបង្កើតសម្រាប់អ្នកតាំងលំនៅថ្មីនោះគឺជាហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពល្អប្រសើរជាងសំណង់អគារដែលមានស្រាប់សម្រាប់សហគមន៍រស់នៅជិតខាងគ្នា នោះការអនុវត្តល្អ គឺត្រូវវិនិយោគក្នុងការធ្វើឲ្យប្រសើរឡើងនូវសំណង់អាគាររបស់សហគមន៍ជាម្ចាស់ផ្ទះ។ ជាការពិតណាស់ បើគ្មានវិធានការបែបនេះទេ អាចបណ្តាលឲ្យសហគមន៍ជាម្ចាស់ផ្ទះ មានអារម្មណ៍មិនសប្បាយចិត្តឡើយ។
- វាគឺជាការចាំបាច់ក្នុងការពិភាក្សាជាមួយប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ (អ្នកតាំងលំនៅថ្មី និងសហគមន៍ជាម្ចាស់) អំពីការរៀបចំថែទាំចំពោះហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។ នៅក្នុងករណីជាច្រើន ប្រជាជនពលរដ្ឋរងផលប៉ះពាល់ និង អាជ្ញាធរមូលដ្ឋានមិនបានឲ្យតម្លៃពេញលេញចំពោះការជំពាក់វាក់វិនផ្នែកហិរញ្ញវត្ថុ និងការរៀបចំចាត់ចែង ក្នុងការប្រតិបត្តិការ

និងថែទាំហេដ្ឋារចនាសម្ព័ន្ធ បន្ទាប់ពីដំណាក់កាលការតាំងលំនៅថ្មីរបស់គម្រោង ឬដោយសារភាគីទាំងពីរនេះ មិនមានលទ្ធភាពក្នុងការចំណាយលើកិច្ចការនេះ ។ ក្នុងន័យនេះ វាជាការសំខាន់ដែលថា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម ត្រូវតែមានលក្ខណៈស្របគ្នាបំផុតជាមួយផែនការរបស់រដ្ឋាភិបាល (ធ្លាប់បានកើតឡើងរួចហើយ ត្រង់ថាសាលារៀនត្រូវបានសាងសង់រួច ប៉ុន្តែរដ្ឋាភិបាលមិនមានលទ្ធភាព ក្នុងការធានានិន្នភាពចំពោះគ្រូបង្រៀនប្រហាក់ប្រហែលគ្នានឹងមណ្ឌលសុខភាព ដែលគ្មានបុគ្គលិកអស់រយៈពេលជាច្រើនឆ្នាំ ទម្រាំដល់ពេលដែលរដ្ឋាភិបាលអាចមានលទ្ធភាពផ្តល់បុគ្គលិកគ្រប់គ្រាន់ និង ធនធានសុខាភិបាលចាំបាច់នានា ដែលរូបភាពនៃលទ្ធផលមិនគាប់ប្រសើរទាំងអស់នេះហើយដែលត្រូវជៀសវាងបាននៅពេលតាំងទីលំនៅថ្មី) ។ លើសពីនេះទៀត អាចចាំបាច់ត្រូវផ្តល់នូវការបណ្តុះបណ្តាលដល់អ្នកតាំងលំនៅថ្មី ប្រជាសហគមន៍ជាម្ចាស់ និងមន្ត្រីរដ្ឋាភិបាល ដែលជាផ្នែកមួយនៃកម្មវិធីតាំងទីលំនៅថ្មី ដើម្បីឲ្យពួកគេអាចទទួលរ៉ាបរង ក្នុងការប្រតិបត្តិការ និងថែទាំជាចាំបាច់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទាំងនោះ។

៥.៤.២.៦ បន្លាស់ប្រាក់ចំណូល និងយុទ្ធសាស្ត្រក្នុងការធ្វើឲ្យប្រសើរឡើងវិញ

មុនពេលផ្តើមផ្តួចផ្តើមឲ្យមានបន្លាស់ប្រាក់ចំណូល និង យុទ្ធសាស្ត្រក្នុងការធ្វើឲ្យប្រសើរឡើងវិញអង្គភាព ទទួលបន្ទុកកិច្ចការតាំងលំនៅថ្មី គួរបញ្ជាក់ឲ្យច្បាស់ថា យុទ្ធសាស្ត្រទាំងនេះ នៅតែមានលទ្ធភាពធ្វើបាន ហើយជាទូទៅអាចទទួលយកបានសម្រាប់អ្នករងផលប៉ះពាល់ ។ បន្ទាប់ពីនោះមក អាចតម្រូវឲ្យមានសកម្មភាព ដូចខាងក្រោម ៖

- វាជាការសំខាន់ក្នុងការផ្តួចផ្តើមឲ្យមានសកម្មភាពចិញ្ចឹមជីវភាព កាន់តែឆាប់កាន់តែល្អ។ ការធ្វើបែបនេះ ដោយសារយុទ្ធសាស្ត្រធ្វើឲ្យប្រសើរនូវប្រាក់ចំណូលមួយចំនួន តួយ៉ាងដូចជា ការអភិវឌ្ឍ សាកវប្បកម្ម ឬ ប្រព័ន្ធធារាសាស្ត្រ ឬ ការផ្តល់ការងារធ្វើ ភាគច្រើនតម្រូវឱ្យមានការលើកកម្ពស់ ជំនាញ និងសមត្ថភាព ឬអាចចំណាយពេលវេលាច្រើនគួរសមទម្រាំតែអាចចាប់ផ្តើមរកប្រាក់ចំណូលបាន ។ នៅក្នុងករណីបែបនេះ គួរតែចាប់ផ្តើមឲ្យមានវិធានការត្រៀមរៀបចំឲ្យបានល្អ មុនពេលដែលប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវខាតបង់ប្រភពប្រាក់ចំណូលបច្ចុប្បន្នរបស់ខ្លួន។
- អង្គភាពទទួលបន្ទុកកិច្ចការតាំងលំនៅថ្មី ចាំបាច់ត្រូវផ្តល់នូវមធ្យោបាយគ្រប់យ៉ាងដែលតម្រូវឲ្យមានសម្រាប់ជាយុទ្ធសាស្ត្រ ក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រាក់ចំណូល ដែលមានច្រើនប្រភេទ ។ ការផ្តល់មធ្យោបាយទាំងនេះ គួរតែអនុវត្តជាក់ស្តែងកាន់តែឆាប់កាន់តែល្អ ព្រោះថាប្រជាពលរដ្ឋរង ផលប៉ះពាល់អាចមានពេលវេលាគ្រប់គ្រាន់ ក្នុងការអនុវត្តយុទ្ធសាស្ត្រ ដែលបានជ្រើសរើស ។ ការផ្តល់មធ្យោបាយជាច្រើន ដូចជាការផ្តល់ជំនួយជាប្រាក់ ការផ្តល់ដីធ្លីជំនួសវិញ ម៉ាស៊ីនបូមទឹក គ្រាប់ពូជ ការផ្តល់ជី អាចនឹងមានភាពស្មុគស្មាញ និងការប្រើប្រាស់ពេលវេលាយូរ។ ដូច្នេះគួរតែពិនិត្យរៀបចំគម្រោងពេលវេលាឡើងវិញ មុនពេលចាប់ផ្តើមអនុវត្តហើយចំណាត់ការទាំងអស់ ដែលតម្រូវឲ្យមានត្រូវតែបញ្ចប់ឲ្យបានទាន់ពេលវេលា ។
- នៅពេលជាមួយគ្នានេះដែរ ការរៀបចំការអនុវត្តសកម្មភាពផ្សេង។ គួរតែត្រូវបានធ្វើឡើង ដូចជាការផ្តល់ការបណ្តុះបណ្តាល ការផ្តល់ឥណាន និងដំបូន្មានផ្នែកទីផ្សារ ក៏ដូចជាការធ្វើទីផ្សារលើ

ទំនិញ និងសេវាកម្មដែលបានផលិតដោយអ្នកតាំងលំនៅថ្មី។ សកម្មភាពទាំងនេះ ភាគច្រើនត្រូវចំណាយពេលយូរ និង ទាមទារឲ្យមានកិច្ចសម្របសម្រួលជាមួយភ្នាក់ងារ ដែលមានជំនាញជាច្រើនទៀត។ គួរកំណត់ដោយប្រុងប្រយ័ត្ននូវគោលជំហរ ដែលទាក់ទងនឹងសកម្មភាពទាំងនេះរបស់គ្រោង ដោយផ្អែកលើកាលវិភាគសម្រាប់ការអនុវត្តយុទ្ធសាស្ត្រធ្វើឲ្យប្រសើរឡើងនូវប្រាក់ចំណូល និងត្រូវចាប់ផ្តើមសកម្មភាពទាំងនេះឲ្យទាន់ពេលវេលាសមស្រប ។

- ប្រសើនបើការស្វែងរកប្រាប់ចំណូលមិនអាចរំពឹងថាបានដូចដើមវិញ ក្នុងពេលបំលាំទីលំនៅនោះទេ គួរតែផ្តល់ការគាំទ្រអន្តរកាលទៅដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងនោះ។ សហគមន៍ដែលមានរបរចិញ្ចឹមជីវិតល្មមតែមួយរស់ គួរតែទទួលបានស្បៀងអាហារជាមូលដ្ឋានក្នុងការរៀបចំអន្តរកាលជាធម្មតា ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋ ដែលប្រកបរបរជំនួញផ្នែកកសិកម្ម ឬ រស់នៅតាមទីប្រជុំជន អាចត្រូវការប្រាក់ជំនួយច្រើនជាង។ ការបញ្ចប់ការផ្តល់ជំនួយអន្តរ-កាល គួរមានការជាប់ទាក់ទងជាមួយសញ្ញាដែលអាចត្រួតពិនិត្យបាន ដូចជាការការអភិវឌ្ឍពេញលេញនៃសក្តានុពលហូចផល នៃទ្រព្យសម្បត្តិដែលបានពីការប្រាក់ចំណូល ឬ ការសម្រេចបានដល់កម្រិតប្រាក់ចំណូលដែលបានព្រមព្រៀង ។ គួរតែអនុវត្តការផ្តល់ជំនួយដែលមានចំនួនថយចុះជាបណ្តើរៗ ដើម្បីកុំឲ្យប្រជាពលរដ្ឋទាំងនោះយល់ថាការផ្តល់ជំនួយនោះជះឥទ្ធិពលលើប្រាក់ចំណូលជាគោល ហើយដើម្បីកុំឲ្យពួកគាត់ប្រឈមនឹងការបញ្ចប់ជំនួយភ្លាមៗដោយកំបុតនៅក្នុងជំហានអន្តរកាលចុងក្រោយ ។ ប្រសិនបើមានបញ្ហា ឬ ការពន្យាពេលលើការអនុវត្តវិធានការស្តារប្រាក់ចំណូល ការគាំទ្រអន្តរកាលគួរតែបន្តរហូតដល់វិធីសាស្ត្រជំនួសត្រូវបានបង្កើតឡើង និងអនុវត្តតាម និងការចាប់ផ្តើមទទួលបានប្រាក់ចំណូលប្រកប-ដោយនិរន្តរភាព។

ប្រអប់អត្ថបទ៥.១៩ ប្រទេសចិនចាត់ទុកការតាំងទីលំនៅថ្មី ជាឱកាសនៃការអភិវឌ្ឍន៍មួយ

គំរូឧទហរណ៍ទំនប់វារីអគ្គិសនីចំនួនពីរនៅប្រទេសចិន គឺទំនប់ Shuikou និង ទំនប់ Yantan បង្ហាញពីរបៀបអនុវត្តការតាំងលំនៅថ្មី ដែលនាំទៅដល់ការស្តារប្រាក់ចំណូលដោយជោគជ័យ និងឆាប់រហ័សសម្រាប់គ្រួសារដែលទទួលរងផលប៉ះពាល់ ទោះបីជាចំនួនមនុស្សដ៏ច្រើន ដែលត្រូវបានផ្លាស់ទីទៅភូមិសាស្ត្រថ្មី មិនសូវជាមានលក្ខខ័ណ្ឌល្អប្រសើរសម្រាប់ការប្រកបរបរស្រែចំការ ដូចតំបន់ដែលពួកគេធ្លាប់រស់នៅក្តី ។

ទឹកបានចាក់បំពេញទំនប់ទាំងពីរនេះ តាមជ្រលងទន្លេដែលព័ទ្ធជុំវិញទៅដោយភូនភ្នំតូចៗ ដែលមានសណ្ឋានចោត បានបង្ខំឱ្យអ្នកតាំងទីលំនៅថ្មីបោះបង់ការប្រកបរបរស្រែចំការលក្ខណៈជាប្រពៃណីទៅជាការដាំដុះបន្លែបង្ការបែបកសិកម្មអតិផល ដំណាំហុចឯកការងារក្រៅពីស្រែចំការ ។

នៅក្នុងករណីមួយចំនួន ជាពិសេសនៅក្នុងតំបន់ទំនប់ Yantan ប្រជាពលរដ្ឋជាច្រើនគ្រួសារបានធ្វើចំណាកស្រុកទៅតំបន់ផ្សេងទៀត ដើម្បីរកការងារធ្វើ ។ បើទោះបីជាតម្រូវឱ្យមានការផ្លាស់ប្តូររបៀបរបបរស់នៅបែបនេះក្តី ក៏ប្រាក់ចំណូលរបស់ក្រុមគ្រួសារភាគច្រើន ត្រូវបានគេមើលឃើញថាកើនឡើងយ៉ាងខ្លាំង។ ការសង់លំនៅដ្ឋាន និងសេវាកម្ម គឺមានលក្ខណៈល្អប្រសើរជាងមុន ហើយអ្នកតាំងលំនៅថ្មី ជាពិសេសនៅក្នុងតំបន់ទំនប់ Shuikou បង្ហាញឲ្យឃើញពីអារម្មណ៍ពេញចិត្តនឹងស្ថានភាពរស់នៅរបស់ខ្លួន។ ភាពប្រសើរឡើងនៃសេដ្ឋកិច្ចតាមគ្រួសាររបស់ប្រជាពលរដ្ឋរស់នៅតំបន់ទំនប់ Shuikou មានស្ទុះដោយសារ មានកំណើនយ៉ាងខ្លាំងនៅក្នុងតំបន់ ដែលនេះគឺជាស្ថានភាពមួយមិនបានយកទៅអនុវត្ត

តាមចំពោះតំបន់ដាច់ស្រយាល Yantan ឡើយ ។ យ៉ាងណាក៏ដោយ គ្រួសារតាំងទីលំនៅថ្មីនៅក្នុងតំបន់វារីអគ្គិសនីទាំងពីរនេះ ភាគច្រើនបំផុតអាចស្តារយ៉ាងឆាប់រហ័សនូវកម្រិតប្រាក់ចំណូល ក្នុងគ្រួសាររបស់ខ្លួនបានយ៉ាងច្រើនគួរឲ្យភ្ញាក់ផ្អើល ។

ការអនុវត្តការងារគម្រោងទាំងពីរនេះ ក្នុងប្រទេសចិន គឺជាការអនុវត្តដ៏គួរឲ្យចាប់អារម្មណ៍ ។ នៅពេលដែលមានកង្វះការផ្តល់មូលនិធិ និងការពន្យាពេលក្នុងការប្រតិបត្តិ ដែលជាបរាជ័យនៃការអនុវត្តមិនស្រមតាមគ្រោងពេលវេលាសម្រាប់ការបំលាស់ទីគ្រួសារប្រជាពលរដ្ឋ ជាហេតុធ្វើឲ្យភ្នាក់ងារប្រតិបត្តិនានាបានបានកំណត់ថាត្រូវតែយកចិត្តទុកដាក់ចំពោះបញ្ហានេះដោយជៀសមិនផុតឡើយ។ ការសង្កត់ធ្ងន់លើការងារ និងប្រាក់ចំណូល និង ដំណើការចូលរួមយ៉ាងហ្មត់ចត់ពីសំណាក់គ្រួសារប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ត្រូវបានកំណត់ចូលទៅក្នុងការធ្វើផែនការ និងការអនុវត្ត តំណាងឱ្យ " ការអនុវត្តដ៏បំផុត" សម្រាប់កិច្ចខិតខំប្រឹងប្រែងនៃការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។

ទិដ្ឋភាពដ៏គួរអោយចាប់អារម្មណ៍ភាគច្រើនក្នុងរឿងនេះ គឺថាប្រទេសចិនចាត់ទុកថាការស្តារប្រាក់ចំណូល និងការអភិវឌ្ឍន៍ គឺជាបញ្ហាធ្ងន់ធ្ងរ ដូចជាការបំលាស់ទីលំនៅជារូបវន្តដូច្នេះដែរ ។ រដ្ឋាភិបាលប្រទេសចិន និងអាជ្ញាថ្នាក់ខេត្ត បានចាត់ទុកយ៉ាងខ្លាំងថា ការតាំងលំនៅថ្មីគឺជាឱកាសមួយសម្រាប់លើកកម្ពស់ការអភិវឌ្ឍនៅក្នុងតំបន់។

ជាការគួរឲ្យចាប់អារម្មណ៍ ដែលប្រទេសចិនបានកំណត់យកស្តង់ដារខ្ពស់ ដែលមានលក្ខណៈល្អប្រសើរ សម្រាប់លក្ខខ័ណ្ឌជាអប្បបរមាលើការងារ និងកំពុងព្យាយាមបង្កើតការងារឲ្យបានច្រើនជាងនេះទៀត ។ ប្រទេសចិនមានគោលដៅផ្តល់មូលដ្ឋានរកប្រាក់ចំណូល និងសុខមាលភាពដែលមានស្ថិរភាពសម្រាប់ក្រុមគ្រួសារប្រជាពលរដ្ឋទាំងឡាយ ។ ប្រទេសចិន មិនបានចាត់ទុកថាមុខរបរជាប្រពៃណី ដូចជាការដាំដុះពឹងផ្អែកលើទឹកភ្លៀងសម្រាប់ដោះស្រាយជីវភាព គឺជាលទ្ធផលដែលអាចទទួលយកបានឡើយ ។

គោលនយោបាយប្រាក់ចំនូលរបស់ទំនប់ Shuikou ត្រូវបានជម្រុញយ៉ាងយកចិត្តទុកដាក់ តាមរយៈឧស្សាហូបនីយកម្មដ៏ឆាប់រហ័សនៃតំបន់ឆ្នេរសមុទ្រភាគអាគ្នេយ៍នៃប្រទេសចិន ។ ការរីកចម្រើនខាងវិស័យ ការងារ និងការស្តារប្រាក់ចំណូលនៅក្នុងតំបន់ទំនប់Yantan មានសភាពយឺតជាង ប៉ុន្តែអាជ្ញាធរនៅតំបន់Yantan បានធ្វើសកម្មភាពមួយចំនួនដែលអអាជ្ញាធរ នៅតំបន់ Shuikou មិនបានធ្វើ ដូចជា ៖ ការរៀបចំចំណាកស្រុករបស់ពលករ ទៅកាន់តំបន់ដែលមានដីបង្កបង្កើនផលដ៏ច្រើនលើសលុប ។ សម្រាប់គម្រោងទាំងពីរនេះ ក៏មានចំណាកស្រុកដែលធ្វើឡើងតាមចិត្តខ្លួនឯងរបស់ពលករដែរ ហើយក៏អាចជួយបង្កើនមូលដ្ឋានប្រាក់ចំណូលរបស់ពួកគាត់បានផងដែរ ។ ការលើកកម្ពស់ចំណាកស្រុកដោយមានការរៀបចំ និងតាមចិត្តខ្លួនឯង ដើម្បីពង្រឹងគោលនយោបាយប្រាក់ចំណូលសម្រាប់ការតាំងទីលំនៅថ្មី គឺជាដំណោះស្រាយប្រកបដោយការច្នៃប្រឌិតមួយ នៅពេលដែលឱកាសការងារដែលអាចផ្តល់កម្រៃដល់ជនចំណាកស្រុកទាំងនោះ ឈានទៅដល់កម្រិតមួយដែលត្រូវតែធ្វើ ។

នៅក្នុងប្រទេសចិន មានការអនុវត្តតាមមធ្យោបាយជាច្រើន ។ ភាពជាប់លាប់នៃការរៀបចំផែនការ ភាពជាម្ចាស់សមូហភាពលើ និងធនធានផ្សេងទៀតនៅតាមជនបទ ព្រមទាំងសារៈសំខាន់របស់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើឲ្យការវិនិយោគលេចចេញជារូបរាងឡើង គឺសុទ្ធសឹងមានសារៈប្រយោជន៍ដែលអាចមានលទ្ធភាពនាំចេញបាន។ ដូច្នេះ ទោះបីជាយ៉ាងហោចណាស់ ក៏ប្រទេសចិនបានអនុវត្តតាមរូបមន្ត ៤យ៉ាង ដែលប្រទេសដទៃទៀតគួរអនុវត្តតាម ៖

- ការអនុត្តគំនិតនៃការឈានទៅដល់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដោយចាត់ទុកថាការតាំងទីលំនៅនោះ គឺជាឱកាសមួយសម្រាប់ការអភិវឌ្ឍ និងជាឱកាសត្រៀមឧបករណ៍ ជាច្រើនសម្រាប់អនុវត្ត។
- An imaginative exploration of micro-opportunities, propelled by the conviction that any but the most hostile environment offers a multitude of options. The ability to force the expansion of fish farming from cages and pens, of pearl culture from these and similar pens, of stone cutting, of exotic fruits when the traditional ones fail, and even of polished golf club heads, is an acquired skill, not unique to the Chinese.
- អាចបត់បែនបានក្នុងការកែតម្រូវយុទ្ធសាស្ត្រនានា នៅពេលយុទ្ធសាស្ត្រដែលមានពីមុនត្រូវបរាជ័យ តាមរយៈការផ្លាស់ប្តូរការកំណត់ឱកាសការងារផ្សេងទៀត ប្រសិនបើចាំបាច់ ឬតាមរយៈការបោះជំហានត្រឡប់ទៅរកការស្តារឡើងវិញ ឬ ការរៀបចំឡើងវិញនូវរចនា- សម្ព័ន្ធសមត្ថភាពជំនាញដែលបរាជ័យ ។
- ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសការចូលរួមរបស់ថ្នាក់ដឹកនាំដែលបានជ្រើសតាំង ។ គោលបំណងនៃការចូលរួមនេះ មិនត្រឹមតែអាចធានាសុវត្ថិភាព ភាពជាម្ចាស់កម្មសិទ្ធិតែប៉ុណ្ណោះទេ ប៉ុន្តែអាច “ ផ្សាភ្ជាប់ផលប្រយោជន៍របស់អ្នកទាំងនោះ និងប្រជាពលរដ្ឋអ្នកស្រុក ” ។

យកលំនាំតាមនាយកដ្ឋានប្រតិបត្តិការ និងវាយតម្លៃ នៃធនាគារពិភពលោក (ឆ្នាំ២០០០) ។ ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត : បទពិសោធន៍ទំនប់ខ្នាតធំ។

៥.៤.២.៧ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យកម្មវិធីតាំងទីលំនៅថ្មី គួរចាប់ផ្តើមក្នុងពេលនៃការអនុវត្ត និង បន្តពេញអំឡុងពេលនៃជំហានអនុវត្ត ។ ប្រសិនបើជាការតាមដានត្រួតពិនិត្យខាងក្រៅវិញ ភ្នាក់ងារតាមដានឯករាជ្យត្រូវចូលរួមពាក់ព័ន្ធដែរ ហើយការរៀបចំកិច្ចសន្យាគួរតែបញ្ចប់ឲ្យបានរួចរាល់ មុនពេលចាប់ផ្តើមអនុវត្ត។ បន្ទាប់មកភ្នាក់ងារនោះអាចតាមដានត្រួតពិនិត្យការតាំងទីលំនៅថ្មីឲ្យបានជាមុន នៅពេលលេចចេញនូវបញ្ហានៃការផ្តល់ជូនអត្ថប្រយោជន៍ដែលទាមរទារឲ្យមានតាមពេលវេលា និងសេវាកម្មផ្សេងៗ ។ ចំណែកការរៀបចំការតាមដានត្រួតពិនិត្យខាងក្នុងវិញ គួរតែបញ្ចប់ឲ្យបានរួចរាល់ភ្លាមៗផងដែរ។ ដំណើរការមួយគួរតែបង្កើតឡើង សម្រាប់រៀបរៀងជាតារាងមានលក្ខណៈជាប្រព័ន្ធនូវលទ្ធផល នៃការតាមដានត្រួតពិនិត្យផ្នែកខាងក្រៅ និងផ្នែកខាងក្នុង នៅក្នុងកិច្ចប្រជុំសម្របសម្រួលរបស់អង្គភាពអនុវត្តការតាំងទីលំនៅថ្មី ។ កិច្ចប្រជុំសម្របសម្រួលនីមួយៗ គួរមានការពិភាក្សាអំពីការបន្តតាមដានលើបញ្ហា ដែលបានរកឃើញតាមរយៈការតាមដានត្រួតពិនិត្យខាងក្នុង និងខាងក្រៅ។

៥.៤.២.៨ ការដោះស្រាយបណ្តឹងសារទុក្ខ

នៅក្នុងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី គួរមានមានយន្តការមួយសម្រាប់ដោះស្រាយ-សារទុក្ខនានា ។ ដោយសារអនុវត្តការតាំងទីលំនៅថ្មីមានភាពស្មុគស្មាញ និង មានបញ្ហាប្រឈម ទើបប្រជាពលរដ្ឋរងផលប៉ះពាល់ ជៀសមិនផុតពីការមានអារម្មណ៍មិនសុខចិត្ត ចំពោះការសម្រេចចិត្ត និង/ឬ ចំណាត់ការ ផ្សេងៗ (តាមពិត គួរតែមានការត្រួតពិនត្យយ៉ាងប្រុងប្រយ័ត្នចំពោះភាពខ្វះខាតទាំងស្រុងលើសារទុក្ខ ពីព្រោះវាអាចជាសន្ទស្សន៍មួយនៃភាពមិនគ្រប់គ្រាន់នៃយន្តការស្តីពីសារទុក្ខ)។ មុនការចាប់ផ្តើម

អនុវត្តការតាំងទីលំនៅថ្មី មន្ត្រីទទួលខុសត្រូវលើការដោះស្រាយសារទុក្ខ គួរមាននីតិវិធីរួចរាល់សម្រាប់កត់ត្រាទុក និង ជ្រើសរើសសារទុក្ខ ព្រមទាំងកត់ត្រាការឆ្លើយតបជាផ្លូវការនានា។

៥.៤.៣ ការកត់ត្រា

វាជាការសំខាន់ណាស់ក្នុងការរក្សាយ៉ាងសុក្រិត និងធ្វើបច្ចុប្បន្នភាពលើកំណត់ត្រាទិន្នន័យ ក្នុងពេញអំឡុងពេលនៃការអនុវត្តកម្មវិធីតាំងទីលំនៅថ្មី។ កំណត់ត្រាទាំងនោះ (ប៉ុន្តែមិនមែនជាការដាក់កំហិតទេ) រួមមាន ៖

- ជំរឿន (ប្រជាសាស្ត្រ) ការអង្កេតសិក្សាសង្គមសេដ្ឋកិច្ច និងការប្រើប្រាស់ដីធ្លី។
- ផែនទី និងរូបភាពថតបានពីអាកាស (on which field-generated GPS coordinates can be plotted)។
- លិខិតបញ្ជាក់ការចុះឈ្មោះ
- សារពើភ័ណ្ឌទ្រពសម្បត្តិ
- លិខិតបញ្ជាក់ការទូទាត់សំណង
- កំណត់ត្រាជារូបថត
- កំណត់ហេតុកិច្ចប្រជុំ
- ចំណាត់ការលើនីតិវិធីសារទុក្ខ

កំណត់ត្រាទាំងនេះ គួរត្រូវបានប្រមូលផ្តុំទុកនៅក្នុងកូនសៀវភៅ និង ប្រព័ន្ធឯកសារអេឡិកត្រូនិក ដែលបានរៀបចំយ៉ាងត្រឹមត្រូវ ដើម្បីងាយស្រួលរក។

៥.៤.៤ ការរៀបចំផែនការត្រៀមបង្ការជាមុន/ផែនការ

ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី គឺជាផែនការមួយ ។ ទោះយ៉ាងណាបរិស្ថានសង្គមមានលក្ខណៈផ្លាស់ប្តូរជានិច្ច ដូច្នេះគួរចាត់ទុកផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ជាឯកសារស្តីពីការវាយតម្លៃ និងជាគោលការណ៍ណែនាំជាជាងផែនការលម្អិត ។ ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ត្រូវបានរំពឹងថានឹងត្រូវធ្វើឲ្យស្របដោយការឆ្លើយតបដោយគាំទ្រ និងសកម្មចំពោះការប្រែប្រួលកាលៈទេសៈ និងលក្ខខ័ណ្ឌនានា ។

កិច្ចការជាច្រើនទាក់ទងនឹងការតាំងទីលំនៅថ្មី មានលក្ខណៈស្មុគ្រស្មាញដែលជាប់ជាមួយ ។ ការស្តារសេដ្ឋកិច្ច គឺជាឧទាហរណ៍ជាក់ស្តែង ជាពិសេសនៅពេលដែលប្រជាពលរដ្ឋរងផលប៉ះពាល់ តម្រូវឲ្យផ្លាស់ប្តូរសកម្មភាពរកប្រាក់ចំណូលថ្មី និងជួនកាលជាសកម្មភាពរកប្រាក់ចំណូល ដែលមិនធ្លាប់ដឹងពីមុនមក ។ តាមពិតផលប៉ះពាល់ទាំងនេះជាធម្មតាអាចប្រមើលមើលជាមុនបាន ដោយការផ្តល់មធ្យោបាយដែលអាចអនុវត្តបានសម្រាប់ការស្តារសេដ្ឋកិច្ច ដែលជាធាតុសំខាន់ក្នុងការរៀបចំផែនការតាំងទីលំនៅថ្មី។ ទោះយ៉ាងណា ការអនុវត្តប្រកបដោយប្រសិទ្ធភាព ជារឿយៗទាមទារឲ្យមានការសម្របសម្រួលយ៉ាងជិតស្និតពីភាគីជាច្រើន និងជារឿយៗពឹងផ្អែកលើភាពងាយឆ្លើយតបចំពោះឱកាស និង កាលៈទេសៈរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពត្រូវរងឥទ្ធិពលផងដែរ ពីភាពកន្លងទៅនៃពេលវេលា ។ ជាទូទៅការអនុវត្តការតាំងទីលំនៅថ្មីមិនអាចកើតឡើង ក្នុងលក្ខណៈទទេស្អាតឡើយ ពីព្រោះរយៈពេលអនុវត្តកាន់តែយូរ ការចិញ្ចឹមជីវិតមានលក្ខណៈផ្លាស់ប្តូរកាន់តែប្រសើរនៅក្នុងតំបន់គម្រោង។

ភាពស្មុគស្មាញនៃការសម្របសម្រួល ការឆ្លើយតបយ៉ាងរហ័សរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងការប្រែប្រួលនានាដែលកើតមាននៅក្នុងតំបន់គម្រោង មិនអាចត្រូវបានប្រមើលមើលជាមុនទាំងស្រុង ដោយអ្នករៀបចំផែនការតាំងទីលំនៅថ្មីឡើយ។ ដូច្នេះប្រជាពលរដ្ឋដែលទទួលខុសត្រូវលើការអនុវត្តការតាំងទីលំនៅថ្មី លើការតាមដានត្រួពិនិត្យ លើការពិនិត្យសង្កេត និងលើការវាយតម្លៃ ត្រូវតែប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួនក្នុងលក្ខណៈពិបាកបំផុត ។ ការរៀបចំផែនការតាំងទីលំនៅយ៉ាងពិស្តារ គឺជាប្រការ ចាំបាច់ក្នុងការអនុវត្តដោយជោគជ័យ ប៉ុន្តែការត្រៀមបង្ការជាមុនក្នុងបរិយាកាសអនុវត្តជាក់ស្តែង អាចបង្កជាគម្លាតយ៉ាងសំខាន់រវាងផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី និងទិដ្ឋភាពជាក់ស្តែង។ ទោះជាយ៉ាងណា នៅក្នុងករណីច្រើនបំផុត សូម្បីតែផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី បានរួមបញ្ចូលនូវវិធានការដើម្បីធ្វើឲ្យប្រសើរឡើងនូវការឆ្លើយតបយ៉ាងរហ័សចំពោះការត្រៀមបង្ការ ជាមុនទាំងនេះក្តី ។

ការត្រៀមបង្ការជាមុន រួមមាន ៖

- មូលនិធិការត្រៀមបង្ការជាមុន ដើម្បីឆ្លើយតបចំពោះការចំណាយដែលចេះតែកើនឡើង ឬ ការចំណាយដែលមិនបានគ្រោងទុកជាមុន។
- រូបមន្ត (ក្នុងករណីខ្លះ) សម្រាប់ធ្វើបច្ចុប្បន្នភាពលើអត្រាទូទាត់សំណងតាមសម័យកាលចំពោះប្រភេទផ្សេងៗនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ ។
- ក្រុមសម្របសម្រួលលើការតាំងលំនៅថ្មី ឬ ក្រុមអ្នកធ្វើកិច្ចការរដ្ឋបាលដែលបានចាត់តាំងឡើងដើម្បីទទួលខុសត្រូវលើការដោះស្រាយបញ្ហាដែលមិនបានគ្រោងទុកជាមុន។
- ការតាមដានត្រួតពិនិត្យផ្នែកខាងក្រៅ រួមជាមួយនឹងល័ក្ខខ័ណ្ឌការងារ ដើម្បីកំណត់ឲ្យបានច្បាស់ពីបញ្ហានានា ដែលកើតចេញពីការរៀបចំផែនការមិនបានល្អិតល្អន់។
- នីតិវិធីស្តីពីសារទុក្ខ ដែលប្រជាពលរដ្ឋរងផលប៉ះពាល់អាចស្វែងរកបាន ដើម្បីដោះស្រាយលើបញ្ហាដែលបង្កផលប៉ះពាល់ដល់ពួកគាត់ជាពិសេស ប៉ុន្តែមិនត្រូវបានគិតទុកជាមុនដោយអ្នករៀបចំផែនការ។
- ការពិនិត្យសារឡើងវិញជាមុន លើការអនុវត្តការតាំងទីលំនៅថ្មី ដែលរួមបញ្ចូលការពិនិត្យសារជាថ្មីលើផែនការដែលមានលក្ខណៈសមស្រប ឬ ប្រកបដោយប្រសិទ្ធភាព។

រាល់កត្តាទាំងអស់ដែលអាចបង្ហាញពីការជាប់ពាក់ព័ន្ធគ្នា ក្នុងអំឡុងពេលអនុវត្តការតាំងទីលំនៅថ្មី មិនមែនចេះតែអាចកំណត់បានជាមុននោះឡើយ ។ ថ្វីបើជានិច្ចជាកាលតែងតម្រូវឲ្យមានការធ្វើវិនិច្ឆ័យមួយក៏ពិតមែន ក៏នៅតែមានគោលការណ៍ជាទូទៅ៣យ៉ាង ដែលត្រូវមានឥទ្ធិពលលើការសម្រេចចិត្តទាំងអស់ សំដៅចាប់ផ្តើមចេញពីបញ្ញត្តដែលបានព្រមព្រៀងនៅក្នុងផែនការសកម្មភាព ស្តីពីការតាំងទីលំនៅថ្មី ៖

- ការផ្តល់ជំនួយដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ គឺជាគោលបំណងជាមូលដ្ឋានគ្រឹះ ។ ការប្រែប្រួលបរិយាកាសគម្រោង អាចបង្កជាការដាក់បន្ទុកផ្នែករដ្ឋបាល ដែលមិនបានគ្រោងទុកជាមុន ឬ ជាការបង្កើននូវការចំណាយលើការតាំងទីលំនៅថ្មី ។ ការធ្វើឲ្យសម្រេចបាននូវប្រសិទ្ធភាពអាចធ្វើទៅរួច តាមរយៈការផ្លាស់ប្តូរគម្រោងផែនការ នៃការរៀចចំចំណាត់ថ្នាក់ ឬ យន្តការនៃការផ្តល់សេវាកម្ម ប៉ុន្តែដើម្បីធ្វើឲ្យប្រសើរឡើង ឬ ស្តារឡើងវិញនូវប្រាក់ចំណូល និង កម្រិតជីវភាពរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវចាំបាច់រក្សាឲ្យបាននូវគោលបំណងជាមូលដ្ឋានគ្រឹះ។

- ភាពជាដៃគូជាមួយអ្នកខ្ចីប្រាក់ គឺជាការចាំបាច់សម្រាប់ការអនុវត្តការតាំងទីលំនៅថ្មីប្រកបដោយជោគជ័យ។ ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី មិនអាចដើរតួនាទីជាផែនការលម្អិតឡើយ ដូចនេះចាំបាច់ត្រូវធ្វើការកែប្រែសម្រួលជាធម្មតា។ នៅក្នុងប្រតិបត្តិការនៃការតាំងទីលំនៅថ្មីដែលមានលក្ខណៈស្មុគ្រស្មាញ ដោយការលាតត្រដាងឲ្យឃើញពីពេលវេលារឿយៗតែងបង្កឲ្យមានស្ថានភាពហួសពីការគ្រប់គ្រងផ្ទាល់របស់ក្រុមអនុវត្តគម្រោង ដូចជាការរិបត្តិសេដ្ឋកិច្ចជាទូទៅ ឬ ការប្រែប្រួលមិនល្អក្នុងក្របខ័ណ្ឌនៃសកម្មភាពជំនួញ។ ស្ថិតក្នុងកាលៈទេសៈបែបនេះ គួរតែធ្វើឲ្យសម្រេចបាននូវលទ្ធផលល្អប្រសើរជាងនេះ តាមរយៈកិច្ចខិតខំសហការរួម ដើម្បីកែតម្រូវវិធីសាស្ត្រក្នុងការតាំងទីលំនៅថ្មី ឬ បង្កើតឲ្យមានជាវិធីសាស្ត្រថ្មីទាំងស្រុងមួយតែម្តង ។ នៅពេលស្ថានភាពបែបនេះកើតឡើង គួរតែធ្វើការកែប្រែផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ដើម្បីពណ៌នាពីវិធីសាស្ត្រថ្មីចំពោះការតាំងទីលំនៅ។
- ភាពជាដៃគូជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ គឺជាការចាំបាច់សម្រាប់ការអនុវត្តការតាំងទីលំនៅថ្មីប្រកបដោយជោគជ័យ។ ផ្អែកតាមបទពិសោធន៍អនុវត្ត ការផ្តល់ព័ត៌មានពាក់ព័ន្ធស្តីពីការផ្លាស់ប្តូរវិធីសាស្ត្រដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ គឺជាកត្តាសំខាន់ ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើការផ្លាស់ប្តូរការរៀបចំផែនការ មានគោលដៅធ្វើឲ្យធូរស្បើយនូវកង្វល់ដែលបានលើកឡើងពីសំណាក់ពលរដ្ឋរងផលប៉ះពាល់ (ជារឿយៗបំផុត ប្រជាពលរដ្ឋទាំងនេះ គឺជាមនុស្សដំបូងដែលអាចកំណត់បានច្បាស់ថាបញ្ហាដែលមានកើតចេញពីណា ឬ ថាការអន្តរាគមន៍ដែលបានកំណត់ក្នុងផែនការ មិនអាចទទួលបានលទ្ធផលគាប់ប្រសើរ) ប្រការនេះមិនអាចទទួលបានជោគជ័យ ដោយគ្មានការគាំទ្រយ៉ាងសកម្មពីប្រជាពលរដ្ឋទាំងនោះបានឡើយ។ ប្រការនេះទាមទារឲ្យមានការបន្តការទំនាក់ទំនង និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់។

៥.៤.៤.១ កាលៈទេសៈដែលនាំទៅដល់ការផ្លាស់ប្តូរផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី

មានកត្តាជាច្រើន ដែលបណ្តាលឲ្យមានតម្រូវការក្នុងការកែប្រែផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី។ តួយ៉ាងមានដូចជា ៖

- អាចនឹងមានការផ្លាស់ប្តូរទីតាំងគម្រោង ។
- អាចនឹងមានផលប៉ះពាល់មិនល្អដែលមិនបានគ្រោងទុកជាមុន ដែលតម្រូវឲ្យដំណោះស្រាយកែតម្រូវ ។
- អាចនឹងមានការផ្លាស់ប្តូររូបសណ្ឋានគម្រោង ឬ សម្របតាមសមាសភាគនៃហេដ្ឋារចនាសម្ព័ន្ធគម្រោង ។
- អាចនឹងមានតម្រូវការក្នុងការផ្លាស់ប្តូរអត្រាទូទាត់សំណង ជាពិសេសប្រសិនបើការអនុវត្តការតាំងទីលំនៅថ្មី កើតឡើងក្នុងរយៈកាលយូរ។
- វិធានការក្នុងការដោះស្រាយកែតម្រូវ អាចនឹងមិនផ្តល់លទ្ធផលគាប់ប្រសើរជានិច្ចនោះទេ តែត្រូវការចាំបាច់នូវការផ្លាស់ប្តូរលើអ្វីដែលត្រូវអនុវត្ត ឬ ផ្លាស់ប្តូររបៀបដែលអនុវត្ត ។

៥.៤.៤.២ ការចងក្រងការផ្លាស់ប្តូរទុកជាឯកសារ

រាល់ការផ្លាស់ប្តូរចំពោះផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី គួរតែចងក្រងទុកជាឯកសារ រួមជាមួយនឹងឯកសារយោងគ្រប់ប្រភេទ ឧទាហរណ៍ កំណត់ហេតុកិច្ចប្រជុំ (ជាមួយក្រុមអនុវត្តគម្រោង សហគមន៍រងផលប៉ះពាល់ និងរដ្ឋាភិបាល ជាដើម)។ នៅទីកន្លែងណាដែលមានការចូលរួមពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុខាងក្រៅ (បរទេស) ការផ្លាស់ប្តូរគួរតែបញ្ចប់ដោយចុះហត្ថលេខាពីសំណាក់ស្ថាប័នទាំងនេះ (ធ្វើឡើងមុនពេលការផ្លាស់ប្តូរត្រូវចូលជាធរមាននៅមូលដ្ឋាន) ។

៥.៤.៥ ការគាំទ្រក្រោយការតាំងទីលំនៅ

ការតាំងទីលំនៅមិនច្របាច់បញ្ចូលគ្នារវាងសកម្មភាពដាច់ៗពីគ្នានោះទេ នៅពេលវាត្រូវបានបញ្ចប់រួចរាល់នោះ គ្រាន់តែបញ្ចប់ដោយការចុះហត្ថលេខាឲ្យស្របទៅតាមតម្រូវការជាចាំបាច់នៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ឬ កិច្ចព្រមព្រៀងផ្តល់មូលនិធិដល់គម្រោង និង/ឬ កិច្ចខិតខំប្រឹងប្រែងនានា ។ ផ្ទុយទៅវិញការតាំងទីលំនៅថ្មី គឺជានីតិវិធីដែលរួមមានសកម្មភាពជាច្រើន និង មានលក្ខណៈខុសៗគ្នា ដែលភាគច្រើនទាមទារឲ្យមានទម្រង់នៃការបន្តការគាំទ្រដល់អ្នកតាំងទីលំនៅ និង សហគមន៍ជាម្ចាស់ផ្ទះក្រោយពីការបញ្ចប់សកម្មភាពនៃការតាំងទីលំនៅថ្មី ។ ការគាំទ្រក្រោយការតាំងទីលំនៅថ្មី អាចដំណើរការលើសពីការតាមដានត្រួតពិនិត្យតែមួយមុខលើលទ្ធផលនៃការតាំងទីលំនៅថ្មី តែវាក៏ជាប់ពាក់ព័ន្ធនឹងការគាំទ្រដោយសកម្មមុន និងពេញទំហឹងចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់។ នៅក្នុងករណីភាគច្រើនបំផុត ការគាំទ្រក្រោយការតាំងទីលំនៅថ្មី ត្រូវទាមទារឲ្យមានជាចាំបាច់ក្នុងអំឡុងពេលសម្ពោធជាសាធារណៈលើផលប្រយោជន៍ និង យុទ្ធសាស្ត្រក្នុងការស្តារជីវភាពឡើងវិញ ជាពិសេសនៅទីកន្លែងណា ដែលយុទ្ធសាស្ត្រទាំងនេះ ទាមទារឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់អនុវត្តតាមរបៀបរស់នៅថ្មី និងរៀនសូត្រពីសកម្មភាពរកប្រាក់ចំណូលបែបថ្មី។

កម្មវិធីគាំទ្រក្រោយការតាំងទីលំនៅថ្មី ត្រូវតែបូកបញ្ចូលជាមួយផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី និងផែនការអភិវឌ្ឍន៍សង្គម។ កម្មវិធីទាំងនេះនឹងត្រូវអនុវត្តតាមស្ថានភាពដាច់ដោយឡែក ប៉ុន្តែត្រូវមានធាតុចាំបាច់ជាធម្មតា ដែលពណ៌នាអំពីគោលដៅ គោលបំណង វិធីសាស្ត្រ ការទទួលខុសត្រូវជាលក្ខណៈស្ថាប័ន ថវិកាចំណាយ និងកម្មវិធីនានា។

វាច្បាស់ណាស់ថា កម្មវិធីគាំទ្រ មិនអាចបន្តដោយគ្មានទីកំណត់នោះឡើយ ដូចនេះជាការចាំបាច់ត្រង់ថា វិធីសាស្ត្រក្នុងការគាំទ្រ គឺជាមធ្យោបាយដែលជួយដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ឲ្យសម្រប-សម្រួលខ្លួនទៅតាមកាលៈទេសៈ ដោយមិនបណ្តាលឲ្យមានការពឹងអាស្រ័យ ។ ប្រការនេះត្រូវធ្វើឲ្យសម្រេចជោគជ័យបាន តាមរយៈការកាត់បន្ថយបន្តិចម្តងៗ លើការគាំទ្រក្នុងអំឡុងពេលមួយ ឲ្យដូចនឹងការធ្វើឲ្យសម្រេចបាននូវគោលបំណងជាក់លាក់នៃកម្មវិធីគាំទ្រដូច្នេះដែរ ។ ប្រការនេះត្រូវតាមដានត្រួតពិនិត្យ ដើម្បីឲ្យការគាំទ្រមិនត្រូវបានដកចេញឆាប់រហ័សពេក (ដោយភាពស្មើគ្នា ធាតុចាំបាច់នៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី អាចត្រូវបានចុះហត្ថលេខាបញ្ចប់ ដោយគ្មានការទន្ទឹងរង់ចំជាចាំបាច់ ចំពោះការចប់រួចរាល់នៃកម្មវិធីការតាំងទីលំនៅថ្មីជារួម)។ បន្ថែមពីលើនេះ ត្រូវវាស់វែងពីតម្រូវការសម្រាប់ការគាំទ្រ ក្នុងក្របខ័ណ្ឌបរិបទនៃបរិយាកាសនៅជុំវិញ ដើម្បីធានាថាតម្រូវការនៃការគាំទ្រដល់ប្រជាពលរដ្ឋរងផលប៉ះពាល់

មានជាប់ទាក់ទិននឹងគម្រោងដែលនាំឲ្យមានការតាំងទីលំនៅថ្មី ជាជាងកាល:ទេស:ដទៃ ដែលអាចបង្ក ផលប៉ះពាល់ដល់ចំនួនប្រជាពលរដ្ឋច្រើនជាងនេះ។

៥.៤.៦ ការបិទបញ្ចប់

ការអន្តរាគមន៍ការតាំតទីលំនៅ មិនអាចបន្តដោយគ្មានការកំណត់នោះឡើយ ដូចនេះផែនការ សកម្មភាពស្តីពីការតាំងទីលំនៅ និង ផែនការអភិវឌ្ឍន៍សង្គម ចាំបាច់តម្រូវឲ្យមានការកំណត់គោលដៅ ច្បាស់លាស់ និងអាចវាស់វែងបាន រួមនឹងកម្មវិធីគាំទ្រ និងដោយមានការយល់ព្រមពីប្រជាពលរដ្ឋ/សហ-គមន៍រងផលប៉ះពាល់ នៅពេលបិទបញ្ចប់កម្មវិធីតាំងទីលំនៅថ្មី ។ គោលដៅទាំងនេះ ត្រូវតែស្របជាមួយ កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលអាចសម្រេចជាសាធារណៈបាននៅក្នុងសហគមន៍ដោយឡែក នៅ ក្នុងគ្រាណាមួយ ចំពោះការពន្លឿនសង្គមសេដ្ឋកិច្ចឲ្យរីកចម្រើនទៅមុខ និង ផលប្រយោជន៍របស់ប្រជា-ពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋាន ឬ ក្នុងទីតាំងគម្រោង ។

គួរកត់សម្គាល់ដែរថា ការប្រកាសបិទកម្មវិធីតាំងទីលំនៅថ្មីពិតជាមានការលំបាកខ្លាំណាស់ ជាពិសេស បំណង និងគោលដៅរបស់សហគមន៍ ឬ រដ្ឋាភិបាល ដើម្បីដកចេញឲ្យដាច់ពីគ្នារវាងតម្រូវការទាក់ទាញ គម្រោង និង បំណងប្រាថ្នានៃការអភិវឌ្ឍធម្មតា ។ លក្ខណៈនេះទាមទារឲ្យមានការពិចារណាយ៉ាងប្រុង-ប្រយ័ត្នរវាងភាគីពាក់ព័ន្ធសំខាន់ៗ (គម្រោងរដ្ឋាភិបាល ប្រជាពលរដ្ឋរងផលប៉ះពាល់ អង្គការសង្គមស៊ីវិល និងស្ថាប័នដទៃទៀត) ដើម្បីសម្រេចឲ្យបាននូវការព្រមព្រៀងគ្នា ជាពិសេសមិនត្រូវបិទបញ្ចប់ឆាប់រហ័ស ពេក ឬ យឺតយ៉ាវពេក (ដោយហេតុនេះអាចជាការបង្កើតឲ្យមានការខូចខាតជំងឺចិត្តរបស់អ្នកពឹងអាស្រ័យ ឬ សហគមន៍ដែលទទួលផលពីស្ថានការណ៍មួយ ដើម្បីធ្វើឲ្យខូចប្រយោជន៍ដល់សហគមន៍ជិតខាងរៀងៗ ខ្លួន។ អាស្រ័យហេតុនេះ នៅពេលដែលគណៈកម្មការពិភពលោកទទួលបន្ទុបទំនប់វារីអគ្គិសនី បានគូស បញ្ជាក់ពីការទទួលស្គាល់សិទ្ធិ និង ការវាយតម្លៃលើហានិភ័យនានា វាក៏ជាការសំខាន់ដូចគ្នានេះដែរក្នុង ការគូសបញ្ជាក់ថា ជាមួយនឹងសិទ្ធិនិងការទទួលខុសត្រូវនេះ ប្រជាពលរដ្ឋរងផលប៉ះពាល់ពីការអភិវឌ្ឍន៍ ក៏ត្រូវតែទទួលខុសត្រូវសម្រាប់សុខមាលភាព និង ស្ថិរភាពជីវភាពរបស់ខ្លួនដោយខ្លួនឯងផងដែរ ។ ជា រឿយៗបំផុត នេះគឺជា " ជំហានដ៏ធំ" ដែលត្រូវអនុវត្ត (មិនមែនដោយសារប្រជាពលរដ្ឋមិនមានឆន្ទៈអនុវត្ត ជំហាននេះនោះទេ ប៉ុន្តែនៅក្នុងប្រទេសភាគច្រើន វាជាជំហានដែលមានភាពរុញរា ដោយសារមានភាព មិនច្បាស់លាស់ជាច្រើន) ។

ដើម្បីបិទបញ្ចប់កម្មវិធីតាំងទីលំនៅថ្មី គួរអនុវត្តទៅតាមការព្រមព្រៀងភាគច្រើន ពីសំណាក់ភាគី ពាក់ព័ន្ធ និងប្រកាសឲ្យបានទូលំទូលាយទៅដល់សហគមន៍រងផលប៉ះពាល់ និងទៅដល់ប្រជាពលរដ្ឋទូ-ទៅ។ ការបិទបញ្ចប់ គឺជាព្រឹត្តិការណ៍ផ្លូវការមួយដែលត្រូវតែមានការចុះហត្ថលេខាបញ្ចប់ ដោយបញ្ជាក់ថា ជាសកម្មភាពចុងក្រោយនៃកម្មវិធីតាំងទីលំនៅថ្មី។

ប្រអប់អត្ថបទ ៥.៨ ការអនុវត្តការតាំងទីលំនៅថ្មីមិនមែនជាការស្មើគ្រចិត្ត-ទិដ្ឋភាពគន្លឹះ
• ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ដើរតួនាទីជាគោលការណ៍ណែនាំសម្រាប់ការអនុវត្ត។ ការផ្លាស់ប្តូរអាចនឹងកើតមានក្នុងអំឡុងពេលដាក់ឲ្យអនុវត្តជាសាធារណៈលើកម្មវិធីតាំងទីលំនៅថ្មី។ • នៅមានជំហានគន្លឹះជាច្រើន ក្នុងការអនុវត្តកម្មវិធីតាំងទីលំនៅថ្មីមិនមែនជាការស្មើគ្រចិត្ត ៖ ° ការត្រៀមរៀបចំ ៖

- ការធានាឲ្យប្រាកដថា ក្រុមអនុវត្តគម្រោងបានយល់ពីផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី និងយល់ពីអ្វីដែលទាមទារឲ្យមានចាំបាច់ក្នុងពេលវេលាខុសៗគ្នា ក្នុងអំឡុងពេលសម្ពោធជាសាធារណៈ។
- ការធានាឲ្យប្រាកដថាបុគ្គលិកទទួលខុសត្រូវ មានវត្តមាននៅក្នុងពេលវេលាដ៏ត្រឹមត្រូវសម្រាប់ដាក់ឲ្យអនុវត្តជាសាធារណៈផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។
- ការធានាឲ្យប្រាកដថាបុគ្គលិកមានធនធានចាំបាច់ដើម្បីអនុវត្តតាមការទទួលខុសត្រូវរបស់ខ្លួន។
- ការបន្តការពិគ្រោះយោបល់ជាមួយអ្នកដែលត្រូវផ្លាស់ទីជម្រក និងម្ចាស់សហគមន៍។
- ប្រសិនជាមានការចង្អុលបង្ហាញពីសេចក្តីត្រូវការ តួយ៉ាងដូចជារយៈពេលក្រោយការកំណត់រវាងការត្រៀមរៀបចំ និងការអនុវត្តផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពលើទិន្នន័យ និងព័ត៌មានដែលផែនការសកម្មភាពនៃការតាំងទីលំនៅថ្មីពឹងលើជាមូលដ្ឋាន។

° ការអនុវត្ត ៖

- ការទូទាត់សំណង។
- ការទទួលរ៉ាប់រងលើការតាំងទីលំនៅជាលក្ខណៈរូបវន្ត (ត្រូវធ្វើឲ្យប្រាកដថា ទីតាំងសម្រាប់ការតាំងទីលំនៅត្រូវបានត្រៀបរៀបចំរួចជាស្រេចជាមុន និង បញ្ចប់រួចរាល់ជាមុន មុនអ្នកតាំងទីលំនៅថ្មីមកដល់លំនៅដ្ឋានថ្មីរបស់ផងខ្លួន) ។
- ការធ្វើឲ្យសកម្មភាពតាំងទីលំនៅស្របជាមួយនឹងកម្មវិធីសាងសង់របស់គម្រោងជារួម។
- ការផ្តល់ជូននូវហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មផ្សេងៗនៅទីតាំងលំនៅថ្មី សម្រាប់ជាការប្រើប្រាស់ និងជាផលប្រយោជន៍សម្រាប់អ្នកតាំងទីលំនៅ និងម្ចាស់សហគមន៍ ។
- ការអនុវត្តលើការដាក់ជំនួសការរកប្រាក់ចំណូល និងយុទ្ធសាស្ត្រធ្វើឲ្យប្រសើរឡើង។
- ការបន្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ។
- ការដោះស្រាយលើសារទុក្ខ។

° ការកត់ត្រាទុក ៖

- ចាំបាច់ត្រូវរក្សាកំណត់ត្រាយ៉ាងសុក្រិត និង ពេញលេញ ចំពោះរាល់សកម្មភាពតាំងទីលំនៅថ្មីដែលគួរតែអាចស្វែងរកបាននៅពេលត្រូវការ។

° ការរៀបចំផែនការគ្រោងទុកជាមុន/ផែនការនានា ៖

- ការផ្លាស់ប្តូរកាលៈទេសៈ អាចជាការនាំទៅដល់ការផ្លាស់ប្តូរផែនការសកម្មភាព នៃការតាំងទីលំនៅថ្មី។
- សំខាន់ត្រូវចងក្រងទុកជាឯកសារ និងត្រូវចុះហត្ថលេខាបញ្ចប់លើការផ្លាស់ប្តូរផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី។

° ការគាំទ្រក្រោយការតាំងទីលំនៅថ្មី

° ការបិទបញ្ចប់

ប្រធានបទពិភាក្សា	ចូរពិភាក្សាអំពីរចនាសម្ព័ន្ធរៀបចំការតាំងទីលំនៅថ្មី និង គ្រោងថវិកាចំណាយជាពិសេស អំពីឥទ្ធិពលនៃរចនាសម្ព័ន្ធទាំងនោះ ទៅលើការអនុវត្តដោយជោគជ័យនៃផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី។

	…… …… តាមរយៈការប្រើប្រាស់គំរូឧទាហរណ៍នៃការតាំងទីលំនៅថ្មីនៅក្នុងប្រទេសរបស់អ្នក ចូរពិភាក្សាពីធាតុសំខាន់ៗនៃផែនការសកម្មភាព ស្តីពីការតាំងទីលំនៅថ្មី ដែលមិនបានផ្តល់លទ្ធផលគាប់ប្រសើរ ព្រមទាំងពិភាក្សាលើការផ្លាស់ប្តូរដែលបានធ្វើឡើង ដើម្បីកែតម្រូវស្ថានការណ៍ ។ ចូររៀបរាប់ឲ្យបានលម្អិតអំពីភាពជោគជ័យ ឬ បរាជ័យនៃការអនុវត្តចំណាត់ការសម្រាប់បង្ការទាំងនេះ។ …… ចូរពិភាក្សាអំពីយន្តការគាំទ្រដែលអាចអនុវត្តបានសម្រាប់សហគមន៍ដែលតាំងទៅលំនៅថ្មីក្នុងចំងាយ៣០គីឡូម៉ែត្រ ពីលំនៅដ្ឋានចាស់ ដោយទាមទារឲ្យអ្នកតាំងទីលំនៅត្រូវកសាងជីវភាពរបស់ផងខ្លួនឲ្យបានចប់រួចរាល់ ដោយការអនុវត្តតាមយុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិតថ្មី។
លំហាត់	តាមរយៈការប្រើពេលវេលាកំណត់មួយ និងគំរូឧទាហរណ៍នៃការតាំងទីលំនៅថ្មីនៅក្នុងប្រទេសរបស់អ្នក ចូរសង្កេតតាមដានពីការអនុវត្តការតាំងទីលំនៅថ្មីជាមួយនឹងទស្សនៈមួយដើម្បីកំណត់ឲ្យបានច្បាស់ពីបញ្ហានានាដែលលេចចេញ និងពីរបៀប ដែលបញ្ហានោះបង្កផលប៉ះពាល់លើគម្រោងកម្មវិធី នៃការតាំងទីលំនៅថ្មី។ …… ចូររៀបចំបង្កើតកូនសៀវភៅសាមញ្ញមួយ និង ប្រព័ន្ធរក្សាទិន្នន័យអេឡិចត្រូនិកសម្រាប់កម្មវិធីតាំងទីលំនៅថ្មី ដែលរួមមានជាមួយការតាំងទីលំនៅថ្មីជាលក្ខណៈរួបរួនរបស់១០គ្រួសារ (មានមនុស្ស៥០នាក់)។ …… ចូររៀបរាប់ឲ្យបានល្អិតល្អន់ពីសន្ទស្សន៍ដែលអាចវាស់វែងបាន ហើយដែលអាចយកមកប្រើប្រាស់បាន សម្រាប់បិទបញ្ចប់ជាផ្លូវការនូវកម្មវិធីតាំងទីលំនៅថ្មី។

ចប់ការបកប្រែខគ្គទី១

៦ -គោលនយោបាយស្តីពីការទូទាត់សំណង និងការបែងចែកផលប្រយោជន៍

កាលពីអតីតកាល ទំនប់វារីអគ្គិសនីដែលមានទំហំធំៗ ជាញឹកញាប់បានបន្សល់ទុកនូវភាពជិតដាមនៃអយុត្តិធម៌ជាច្រើននៅក្នុងសង្គមមានដូចជា ការបំលាស់ទីលំនៅ ការតាំងទីលំនៅថ្មីរបស់មនុស្សដ៏ច្រើនរាប់លាននាក់ និងការខូចខាតដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការខូចខាតដល់បរិស្ថាន មានដូចជាការបាត់បង់ និងការបំផ្លេចបំផ្លាញប្រព័ន្ធអេកូឡូស៊ី និងការលំបាកផ្នែកសេដ្ឋកិច្ច (បន្ទុកបំណុល) ដែលមានកម្រិតធ្ងន់ធ្ងរជាងការទទួលបានផលប្រយោជន៍[យោង១៤] ។ ក្នុងករណីជាច្រើន ការទូទាត់សំណងភាគច្រើន ដើម្បីទទួលបានអត្ថប្រយោជន៍ពីទំនប់វារីអគ្គិសនី មិនអាចទទួលយកបាននិងមានលក្ខណៈមិនចាំបាច់ជាពិសេសក្នុងលក្ខខ័ណ្ឌសង្គម និងបរិស្ថាន ។ ពីរបីទសវត្សរ៍មកហើយ ដើម្បីដោះស្រាយចំពោះបញ្ហានេះ ទីភ្នាក់ងារអន្តរជាតិ បានបង្កើតឲ្យមានជាបទដ្ឋានជានិយាមនានា ដើម្បីយកមកអនុវត្តនៅពេលមានការរៀបចំផែនការ ពេលអនុវត្ត និង ពេលប្រតិបត្តិការគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗដូចជា ទំនប់វារីអគ្គិសនី ជាដើម ។ ចំពោះបញ្ហាបរិស្ថាន និងសង្គមវិញ ត្រូវបានគេកំណត់ឃើញច្បាស់ និងត្រូវបានវាយតម្លៃ រីងដំណើរការវិញ ត្រូវបានរៀបចំឡើងជាមួយសហគមន៍រងផលប៉ះពាល់ សំដៅដោះស្រាយចំពោះផលប៉ះពាល់ និងប្រើប្រាស់ឱកាសនៃការអភិវឌ្ឍឲ្យអស់ពីលទ្ធភាព។ ដោយសារតែការលេចចេញជាបញ្ហាបែបនេះ ទើបនៅពេលមានភាពខ្វះខាតលើការកាត់បន្ថយ ចាំបាច់តម្រូវឲ្យមានការចូលរួមពាក់ព័ន្ធរយៈពេលវែង ជាមួយសហគមន៍ដែលបំលាស់ទី។

នៅក្នុងបរិបទនៃការអភិវឌ្ឍ ការទូទាត់សំណង[យោង១៥] និងការបែងចែកផលប្រយោជន៍ ប្រកបដោយនិរន្តរភាព[យោង១៣] អាចជួយដោះស្រាយចំពោះបញ្ហាដែលញែកដាច់ពីគ្នាជាញឹកញាប់ រវាងការអភិវឌ្ឍនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ការបែងចែកផលប្រយោជន៍ ដែលត្រូវបានធ្វើឡើងស្របតាមគោលការណ៍នៃបទដ្ឋានជានិយាម គឺជាឧបករណ៍គ្រប់គ្រងតែមួយគត់ដែលមានអនុភាព មានភាពជាក់ស្តែង និងដែលអាចអនុវត្តបាន និងជាឧបករណ៍ដែលមានតួនាទីសម្រាប់ពង្រឹងភាពជាដៃគូដ៏ចាំបាច់ ក្នុងការអនុញ្ញាតឲ្យប្រជាពលរដ្ឋបានចូលរួមសម្រេចចិត្តលើការអភិវឌ្ឍដែលជះឥទ្ធិពលដល់ពួកគេ។ ការបែងចែកផលប្រយោជន៍ក៏អាចជួយគាំទ្រផងដែរដល់ការអនុវត្តជាក់ស្តែងទៅលើការគ្រប់គ្រងធនធានទឹកចម្រុះ។

[យោង១៤] ត្រូវទទួលស្គាល់ថា ការវាយតម្លៃ និងវិនិច្ឆ័យលើគម្រោងមួយដែលទាក់ទងនឹង ផលប្រយោជន៍ជាតិ មានភាពពិបាកណាស់ (តួយ៉ាងដូចជាទំនប់វារីអគ្គិសនីខ្នាតធំ និងសំណង់អគារវារីអគ្គិសនី ត្រូវទាមទារឲ្យមានជាចាំបាច់ សម្រាប់ផ្គត់ផ្គង់អគ្គិសនីទៅដល់ក្រុមហ៊ុនឧស្សាហកម្ម សំខាន់ៗនៅក្នុងប្រទេសមួយ) ប៉ុន្តែការតម្រូវឲ្យមាននេះ អាចបង្កជាផលវិបាកអវិជ្ជមានសម្រាប់សហគមន៍មូលដ្ឋាន/ក្នុងតំបន់ (ដែលសហគមន៍ទាំងនោះតម្រូវឲ្យតាំងទីលំនៅថ្មី ហើយកែប្រែទាំងស្រុងនូវជីវិតរស់នៅ និងរបៀបរបបចិញ្ចឹមជីវិតរបស់ខ្លួន) នៅក្នុងឧទាហរណ៍នេះ ផលវិបាកជាអវិជ្ជមានសុទ្ធសឹងជាបទពិសោធន៍ដែលកើតមាននៅតាមទីតាំងគម្រោង/តំបន់ ខណៈដែលការទទួលបានផលប្រយោជន៍ សុទ្ធសឹងជាបទពិសោធន៍បន្ថែមជាលក្ខណៈជនបទស្រែចំការ។ ដូច្នេះ ជាការចាំបាច់ក្នុងការដោះស្រាយប្រកបដោយភាពត្រឹមត្រូវចំពោះផលវិបាកជាអវិជ្ជមាន និងដោះស្រាយដោយមានតុល្យភាពប្រកបដោយសមធម៌ និងការបែងចែកផលប្រយោជន៍ (ជាលក្ខណៈមូលដ្ឋាន តំបន់ និងជាតិ)។

[យោង១៥] ដូចមានបញ្ជាក់នៅក្នុងផ្នែកទី៥ ប្រការសំខាន់ គឺមិនត្រូវបូកបញ្ចូល ឬមានការយល់ច្រឡំថា មូលនិធិទទួលខុសត្រូវសង្គម (CSR) (ដែលជាធម្មតាជាការស្ម័គ្រចិត្ត) ប៉ុន្តែជួនពេលខ្លះត្រូវបានកំណត់ដោយច្បាប់ តួយ៉ាងដូចជានៅអាហ្វ្រិកខាងត្បូង ដែលជាផ្នែកមួយនៃគម្រោងផ្តួចផ្តើមគំនិតរបស់រដ្ឋាភិបាលផ្នែកលើការផ្តល់សិទ្ធិអំណាចទូលំទូលាយដល់សេដ្ឋកិច្ចពណ៌ខ្មៅរបស់រដ្ឋាភិបាលអាហ្វ្រិកខាងត្បូង រួមជាមួយនឹងការទូទាត់សំណង និងការបែងចែកផលប្រយោជន៍ (ដែលជាកាតព្វកិច្ច) ។ នៅក្នុងបណ្តាប្រទេសជាច្រើន និង បរិបទជាច្រើន មូលនិធិទទួលខុសត្រូវសង្គមត្រូវចំណាយលើសពីការទូទាត់សំណង និងការបែងចែកផលប្រយោជន៍ទៅទៀត ដើម្បីបន្ថែមគុណតម្លៃដែលអាចលេចចេញពីឱកាសនៃគម្រោង និងការបន្ថែមផលដល់សហគមន៍អ្នកទទួលផល ឬសហគមន៍ដែលទទួលរងផលប៉ះពាល់។

៦.១ សារតា

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការលើកកម្ពស់ការយល់ដឹងអំពី គោលនយោបាយអន្តរជាតិ និងគោលការណ៍ណែនាំដែលទាក់ទងនឹងការទូទាត់សំណង និង ការបែងចែកផលប្រយោជន៍ ក្នុងបរិបទនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ (ទំនប់វារីអគ្គិសនី)។
ទិសដៅ	ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីការទូទាត់សំណង និងគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការបែងចែកផលប្រយោជន៍ និងសារៈសំខាន់ជាលក្ខណៈអន្តរជាតិនៃគោលការណ៍ទាំងនេះ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007) ។ ទំនប់វារីអគ្គិសនីនិងការអភិវឌ្ឍ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន។ ផ្នែកទី៥ ៖ គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់លើយន្តការនៃការបែងចែកផលប្រយោជន៍) www.unep.org/dams …… គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD ឆ្នាំ២០០០) ការពិនិត្យលើគោលអត្ថបទខ្លីៗ I.3 : ការបំលាស់ទីលំនៅ ការតាំងទីលំនៅថ្មី ការស្តារនីតិសម្បទាឡើងវិញ ការជួសជុលសងឡើងវិញ និងការអភិវឌ្ឍ។
	Susanna Price (2008) ការទូទាត់សំណង ការស្តារឡើងវិញ និងឱកាសនៃការអភិវឌ្ឍន៍: គំរូស្តង់ដារថ្នាក់ជាតិស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត នៅក្នុង Cernea, M., M និង Hari Mohan Mathur (eds.) តើការទូទាត់សំណងអាចបង្ការមិនឲ្យមានភាពក្រីក្រដុនដាបបានដែរឬទេ? ការធ្វើកំណែទម្រង់លើការតាំងទីលំនៅថ្មី តាមរយៈការវិនិយោគ និងការបែងចែកផលប្រយោជន៍ (មាននៅទំព័រ១៤៧ដល់១៧៩) ការបោះពុម្ពផ្សាយរបស់សកលវិទ្យាល័យ Oxford។

៦.១.១ តម្រូវការចំពោះការទូទាត់សំណងប្រកបដោយលក្ខណៈល្អប្រសើរ សម្រាប់ការតាំងទីលំនៅ ថ្មីមិនមែនជាការស្ម័គ្រចិត្ត

ចំនុចគន្លឹះមួយក្នុងចំណោមចំនុចគន្លឹះនានា ដែលត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាថ្មីៗនេះស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត គឺថា " ទំនប់វារីអគ្គិសនីនានាបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍមនុស្ស និងបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ " (ប្រភព WCD ឆ្នាំ ២០០០)។

ផលប្រយោជន៍ទាំងនោះ មានលក្ខណៈផ្សេងៗគ្នារួមមាន ការបង្កបង្កើតថាមពលអគ្គិសនី ការគ្រប់គ្រងលើទឹកជំនន់ ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ផ្នែកឧស្សាហកម្ម និងការប្រើប្រាស់ទឹកក្នុងមូលដ្ឋាន នាវាចរណ៍ ក៏ដូចជាការលំហែកំសាន្ត។

ទោះជាយ៉ាងណា ទំនប់វារីអគ្គិសនីត្រូវបានចាត់ទុកថាជាប្រភពនៃផលប៉ះពាល់ដ៏ធំ ទាំងទៅលើផ្នែកបរិស្ថាន និងផ្នែកសង្គម ដោយជៀសមិនផុត។ ផលប៉ះពាល់ដ៏ធំបំផុតដែលមិនអាចជៀសផុតនោះគឺជាទូទៅទាក់ទងទៅនឹងការជន់លិចនៃដីជុំវិញតំបន់បង្ហាំងទឹកផ្នែកខាងលើនៃទំនប់ និង ការផ្លាស់ប្តូរនៃលំហូរទឹក ព្រមទាំងកម្រិតទឹកផ្នែកខាងក្រោមនៃទំនប់។ ផលប៉ះពាល់នេះ ជាញឹកញាប់ បណ្តាលឲ្យកើតមាននូវការខូចខាតផ្ទះសម្បែង ដីធ្លី ធនធានហូចផលនានា និង/ឬប៉ះពាល់ដល់សេវា សហគមន៍នៃប្រជា-ពលរដ្ឋមូលដ្ឋាន ដែលរងផលប៉ះពាល់នេះ។ ផលប៉ះពាល់នេះទៀតសោត គឺជាករណីដែលបានកើតមាននាពេលកន្លងមក និងជាករណីដែលគេរំពឹងថាអាចនឹងកើតមានជាបន្តទៀតនៅពេលអនាគត ។ គម្រោងទំនប់វារីជាច្រើនបានបោះបង់ដំណើរការរបស់ខ្លួន ឬ ត្រូវពន្យារពេលដំណើរការ ដោយផ្អែកលើហេតុផលផ្សេងៗ រួមមានភាពកំសោយនៃការចាត់ចែងការបំលាស់ទីមិនមែនជាការស្ម័គ្រចិត្ត និង ការធ្វើឲ្យខាតបង់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងវង្វង់ ឬ ផ្នែកខាងក្រោមនៃតំបន់បង្ហាំងទឹក។ ហេតុផលបន្ថែមទៀតរួមមាន ការបាត់បង់មធ្យោបាយដើម្បីទ្រទ្រង់លើរបៀបរបបរស់នៅតាមបែបប្រពៃណី ជាពិសេសតាមបែបវប្បធម៌របស់ជនជាតិដើម ឬ ជនជាតិភាគតិច ឬ ក្រុមមនុស្សភាគតិចដែលជាអ្នកប្រតិបត្តិតាមបែបសាសនា ដែលភាគច្រើនសុទ្ធសឹងជាអ្នកពឹងផ្អែកលើដីធ្លី និង ធនធានធម្មជាតិ ដែលមានស្រាប់នៅក្នុងមូលដ្ឋានរបស់ពួកគេ។

ស្ថាប័នស្រាវជ្រាវសង្គមដ៏សំខាន់មួយ បានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេល២០ទៅ៣០ឆ្នាំកន្លងមក បានសន្និដ្ឋានថា គម្រោងទំនប់វារីអគ្គិសនីមានចំនួនយ៉ាងច្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានបង្កជាបញ្ហាលើការទូទាត់សំណងមិនសមស្រប និង បានធ្វើឲ្យប្រជាពលរដ្ឋមូលដ្ឋានដែលរងផលប៉ះពាល់ចុះក្រដុនដាប។ បញ្ហានេះ បានកើតឡើងចាប់តាំងពី ដើមទសវត្សរ៍ទី៨០មកម្លេះ បើទោះជាមានការគូសបញ្ជាក់នៅក្នុងគំរូស្តង់ដារអន្តរជាតិនានាក្តី ឲ្យមានការគោរពតាមចំពោះការតាំងលំនៅថ្មី និង ការអភិវឌ្ឍន៍ សម្រាប់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងទំនប់វារីអគ្គិសនី ដែលទាមទារឲ្យមានការទូទាត់សំណងប្រកបដោយលក្ខណៈសមភាពទៅដល់ភាគីរងផលប៉ះពាល់ទាំងអស់ ។ ការស្តារឡើងវិញនៃសហគមន៍ដែលរងផលប៉ះពាល់ និង ការគាំទ្រដល់ការអភិវឌ្ឍលើជីវភាពរស់នៅរបស់ភាគីរងផលប៉ះពាល់ដោយស្មើភាពគ្នា ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់លាស់ ។

មានការលើកឡើងជាសំនួរថា ៖ តើអ្វីដែលបានដំណើរទៅដោយមិនត្រឹមត្រូវ ? ប្រការសំខាន់ត្រូវតែទទួលស្គាល់ថា ការផ្តល់មូលនិធិ និងការគ្រប់គ្រងកម្មវិធីតាំងទីលំនៅថ្មី គឺមានភាពពិបាកសម្រាប់រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងប្រទេសដែលមានកម្រិតចំណូលទាប ដែលត្រូវប្រឈមមុខជាមួយកង្វះខាតដីធ្លី តម្រូវការនៃប្រកួតប្រជែង ហើយធនធាននៅមានកម្រិត ក៏ដូចជាឧបសគ្គធ្ងន់ធ្ងរផ្នែកសមត្ថភាពស្ថាប័ន ។ លើសពីនេះទៅទៀត នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន អវត្តមាននៃដំណើរការគ្រប់គ្រងដីធ្លី និងគ្មានទីផ្សារការងារប្រកបដោយប្រសិទ្ធភាព កង្វះខាតនៃប្រព័ន្ធទូទាត់សំណង

ចំពោះទ្រព្យសម្បត្តិដែលបម្រុងទុកដោយរដ្ឋ និងអវត្តមាននៃសំណាញ់សុវត្ថិភាពសង្គម។ ចំនុចទាំងបីនេះ ហើយ គឺជាមូលហេតុគន្លឹះធ្វើឲ្យមានការចោទជាសំនួរថា ហេតុអ្វីបានជាការទូទាត់សំណងដែលមានលក្ខណៈសាមញ្ញចំពោះការខូចខាតទ្រព្យសម្បត្តិ ក្រោមក្របខ័ណ្ឌនៃច្បាប់ស្តីពីសិទ្ធិសាធារណៈ បែរជាមិនអាចរំពឹងឲ្យប្រាកដ ដើម្បីផ្តល់នូវលទ្ធផលគួរជាទីពេញចិត្តសម្រាប់ប្រជាពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅទៅវិញ។

តាមព័ត៌មានពីគម្រោងទំនប់វារីអគ្គិសនីនៅប្រទេសកំពុងអភិវឌ្ឍន៍ ក៏បានបង្ហាញផងដែរថា មធ្យោបាយដែលយកមកអនុវត្តជាក់ស្តែងដើម្បីធ្វើឲ្យសម្រេចបានតាមតម្រូវការស្តង់ដារ មិនមែនមានលក្ខណៈគ្រប់គ្រាន់តែទាំងអស់ទេ ។ ជាញឹកញាប់ ទំហំវិសេសវិសាល និងភាពស្មុគស្មាញនៃការតាំងលំនៅថ្មី ត្រូវស្ថិតនៅក្រោមការប៉ាន់ស្មានទាំងអស់។ ប្រការនេះហើយដែលបណ្តាលឲ្យមានការផ្តល់មូលនិធិរយៈពេលយូរសម្រាប់ការតាំងទីលំនៅថ្មី ហើយមិនមានសកម្មភាពអភិវឌ្ឍន៍គ្រប់គ្រាន់ ។ ការព្រួយបារម្ភដែលបានលើកឡើងជាញឹកញាប់រួមមាន ការពន្យាពេលនៅក្នុងការអនុវត្តម្រោង និងផលប្រយោជន៍ដែលជៀសមិនរួច កម្រិតខ្ពស់នៃភាពទីទ័លក្រក្នុងចំណោមអ្នកដែលទទួលរងផលប៉ះពាល់ពីគម្រោង ដែលបង្កបង្កើតជាការខាតបង់យ៉ាងធំទៅលើសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាការបង្កើនការព្រួយបារម្ភអំពីបញ្ហាសិទ្ធិជាមូលដ្ឋានរបស់មនុស្សនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

តម្រូវការជាចាំបាច់ដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវចំពោះបញ្ហាទាំងនេះ ត្រូវបានគូសបញ្ជាក់តាមរយៈបទដ្ឋានមួយដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ សម្រាប់កំណត់គោលដៅ បទដ្ឋានគោលការណ៍ជាវិធាន និងគំរូស្តង់ដារជាសកល។ មូលដ្ឋានគ្រឹះនៃបទដ្ឋាននេះ គឺសំដៅលើធម្មនុញ្ញនៃអង្គការសហប្រជាជាតិ (១៩៤៥ឆ្នាំ) និង សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៤៧) ។ នៅពីរទសវត្សរ៍ចុងក្រោយនៃសតវត្សទី២០ កិច្ចប្រជុំជាសកលនៃអង្គការសហប្រជាជាតិ បានជួយពង្រឹងបន្ថែមលើបទដ្ឋាននេះ រួមជាមួយនឹងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិទទួលបានការអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (ឆ្នាំ១៩៨៦) និង សេចក្តីថ្លែងការណ៍ទីក្រុងរីយ៉ូស្តីពីបរិស្ថាននិងការអភិវឌ្ឍន៍ (ឆ្នាំ១៩៩២) របាយការណ៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកផ្នែកទំនប់វារីអគ្គិសនី (WCD ឆ្នាំ២០០០) ដែលបានលើកឡើងជាករណីថា វិធីសាស្ត្រស្តីពី " តុល្យការ " ដែលមានជាប្រពៃណីយូរមកហើយលើការវាយតម្លៃការចំណាយនិងផលប្រយោជន៍នៃគម្រោង គឺជាឧបករណ៍ដែលមានលក្ខណៈមិនគ្រប់គ្រាន់សម្រាប់កសាងផែនការអភិវឌ្ឍនិងការធ្វើសេចក្តីសម្រេចចិត្ត " ដោយយល់ឃើញពីសារៈសំខាន់នៃបញ្ហាទាក់ទងនឹងសិទ្ធិ ក៏ដូចជាចរិកលក្ខណៈ និង ទំហំនៃហានិភ័យដែលអាចកើតមានចំពោះភាគីពាក់ព័ន្ធទាំងអស់ ទើបគណៈកម្មការពិភព-លោកទទួលបន្ទុកផ្នែកទំនប់វារីអគ្គិសនី បានស្នើឲ្យមានការបង្កើតជាវិធីសាស្ត្រមួយផ្នែកលើ " ការទទួលស្គាល់សិទ្ធិ "និង " ការវាយតម្លៃហានិភ័យ" (ជាពិសេសសិទ្ធិ និងហានិភ័យ) សម្រាប់ធ្វើជាឧបករណ៍ណែនាំដល់ការកសាងផែនការ និងការធ្វើសេចក្តីសម្រេចចិត្តនាពេលអនាគត ។ វិធីសាស្ត្រមួយនេះ គួរតែធ្វើឲ្យមានតុល្យភាពស្របតាមតម្រូវការ និងស្ថិតនៅលើគេទាំងអស់នៃ " តម្រូវការក្នុងការកាត់បន្ថយភាពក្រីក្រ" ដែលពាក់ព័ន្ធជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (ប្រភព Gagnon , Klimpt និង Seelos ឆ្នាំ២០០២)។

ការស្រាវជ្រាវផ្នែកសង្គមថ្មីៗនេះ បានចង្អុលបង្ហាញថា ចាំបាច់តម្រូវឲ្យមានគោលនយោបាយទូទាត់សំណង ដើម្បីកំណត់បានច្បាស់ពីយន្តការដែលត្រូវយកមកអនុវត្តជាក់ស្តែង សំដៅសម្រេចឲ្យបាន

នូវគោលបំណងរបស់គោលនយោបាយដែលអាចស្វែងរកបានក្រោមបទដ្ឋានជាលក្ខណៈអន្តរជាតិ។ នៅក្នុងការត្រៀមគោលនយោបាយ គេត្រូវកំណត់ឲ្យបានយ៉ាងច្បាស់នូវធាតុសំខាន់ៗ ដែលត្រូវតែយកចិត្តទុកដាក់ ដើម្បីធានាឲ្យប្រាកដថា ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត និងដំណើរការអភិវឌ្ឍ ពិតជាបានផ្តល់លទ្ធផលល្អប្រសើរដល់ការចិញ្ចឹមជីវិត និង ធ្វើឲ្យល្អប្រសើរដល់កម្រិតជីវភាពរស់នៅ ព្រមទាំងឱកាសល្អផ្សេងៗទៀត។ លើសពីនេះទៅទៀតគួរតែរួមបញ្ចូលបទប្បញ្ញត្តិជាក់លាក់នានាទៅក្នុងធាតុសំខាន់ៗ ដើម្បីផ្តល់នូវសំណងគ្រប់គ្រាន់លើការខូចខាតទ្រព្យសម្បត្តិ សម្រាប់អ្នកដែលរងផលប៉ះពាល់ក្រីក្របំផុត ក៏ដូចជាដើម្បីបែងចែកផលប្រយោជន៍រួម (រួមបញ្ចូលទាំងអ្នកដែលគ្មានសិទ្ធិស្របច្បាប់ ក្នុងការកាន់កាប់ទ្រព្យម្បត្តិ មេគ្រួសារជាស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងទៀត ដូចជាជនជាតិដើមភាគតិច)។

គោលការណ៍ទាំងនេះ ត្រូវបានគាំទ្រនៅក្នុងសេចក្តីប្រកាសទីក្រុងប៉េកាំងស្តីពីថាមពលវារីអគ្គិសនី និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព (អង្គការសហប្រជាជាតិឆ្នាំ២០០៤) ៖ " ជាមួយនឹងការគោរពតាមទិដ្ឋភាពសង្គម យើងបានធ្វើការកត់សម្គាល់ថាធាតុផ្សំសំខាន់ៗនៃការតាំងទីលំនៅថ្មីប្រកបដោយជោគជ័យ រួមមាន ការធ្វើឲ្យការតាំងទីលំនៅថ្មីនៅមានកម្រិតតិចតួច ការប្តេជ្ញាចិត្តដើម្បីសម្រេចគោលបំណងនៃការតាំងទីលំនៅថ្មីដោយអ្នកអភិវឌ្ឍ ការធ្វើផែនការតាំងទីលំនៅថ្មីយ៉ាងហ្មត់ចត់ ដោយមានការចូលរួមពេញលេញពីសហគមន៍រងផលប៉ះពាល់ ដោយមានការយកចិត្តទុកដាក់ជាពិសេសដល់សហគមន៍ ដែលងាយរងគ្រោះ។ យើងទាំងអស់គ្នាត្រូវបានជម្រុញទឹកចិត្តតាមរយៈនិន្នាការរបស់រដ្ឋាភិបាលមួយចំនួន លើសពីគោលការណ៍អនុវត្តល្អស្តីពីការតាំងទីលំនៅថ្មី តាមរយៈការផ្តល់នូវការបែងចែកផលប្រយោជន៍ជាមួយសហគមន៍ជាម្ចាស់មូលដ្ឋាន និងបានអំពាវនាវដល់រដ្ឋាភិបាល ឲ្យពិចារណាចំពោះការរួមបញ្ចូលគ្នានូវវិធីសាស្ត្រទាំងនេះទៅ ក្នុងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ លើសពីនេះទៀត យើងបន្ថែមការអំពាវនាវដល់រដ្ឋាភិបាល និង អាជ្ញាធរក្នុងតំបន់និងមូលដ្ឋានឲ្យគិតពិចារណាជាពិសេសចំពោះតំបន់វប្បធម៌សំខាន់ៗនានា" ។

៦.១.២ បទដ្ឋានជានិយាម

គម្រោងបណ្តាលឲ្យមានការតាំងទីលំនៅថ្មី ត្រូវអនុវត្តក្នុងក្របខ័ណ្ឌបទដ្ឋានជានិយាមចម្រុះដែលរួមមានសមាសភាពដូចជា៖

- គោលនយោបាយ និងច្បាប់អន្តរជាតិ
- ច្បាប់ជាតិ
- ច្បាប់រដ្ឋ ឬ ខេត្ត-ក្រុង
- ច្បាប់និងគោលនយោបាយផ្អែកតាមវិស័យ (ដូចជា វិស័យថាមពល ដឹកជញ្ជូន កសិកម្ម ជាដើម)
- ច្បាប់ទាក់ទងនឹងសកម្មភាពនៃការកសាងទំនប់វារី និងភ្នាក់ងារប្រតិបត្តិការ (តួយ៉ាងដូចជាគោលនយោបាយដែលបានបង្កើតឡើងដោយសមាគមវារីអគ្គិសនីអន្តរជាតិ)។

គោលនយោបាយស្តីពីការតាំងទីលំនៅថ្មី និង ការទូទាត់សំណង ដែលបានអនុម័តដោយភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិ ត្រូវបានអនុវត្តក្នុងបរិបទនៃក្របខ័ណ្ឌបទដ្ឋានរួមនេះ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បានចាប់ផ្តើមអនុវត្តការទូទាត់សំណង និង បទដ្ឋានជានិយាមស្តីពីការតាំងទីលំនៅថ្មី ដែលមានលក្ខណៈទូលំទូលាយ។ ជាលទ្ធផល ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ គោលការណ៍ណែនាំនៃភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ បានដើរតួយ៉ាងសំខាន់នៅក្នុងកម្មវិធីអភិវឌ្ឍជាច្រើនដែលបណ្តាលឲ្យមានការតាំងទីលំនៅថ្មី។ ថ្មីៗជាងនេះទៅទៀត ស្ថាប័នផ្តល់ហិរញ្ញប្បទានអន្តរជាតិ ដូចជា ក្រុមធនាគារពិភពលោក ក៏បានដើរតួនាទីសំខាន់នៅក្នុងការបង្កើតឲ្យមានបទដ្ឋានជានិយាមស្តីពីការទូទាត់សំណងថ្នាក់ជាតិ និង ការតាំងលំនៅថ្មីផងដែរ ។ រដ្ឋាភិបាលនៃប្រទេសកាន់តែច្រើនបាននិងកំពុងរៀបចំបង្កើតនូវគោលការណ៍ណែនាំមួយចំនួនស្តីពីការតាំងទីលំនៅថ្មី ដូចជាប្រទេសចិនបានយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ចំពោះគោលការណ៍ណែនាំទាំងនេះ នៅពេលរៀបចំផែនការ និងពេលកំពុងអនុវត្តកម្មវិធីនៃគម្រោងដែលបណ្តាលឲ្យមានការតាំងទីលំនៅថ្មីនៅក្នុងប្រទេសរបស់ខ្លួន។

បទដ្ឋានគោលនយោបាយ/បទដ្ឋានជានិយាមរបស់ក្រុមធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត បានជះឥទ្ធិពលជាពិសេសលើការធ្វើឲ្យលេចចេញជារូបរាងឡើង នូវគោលនយោបាយនានារបស់ម្ចាស់ជំនួយដទៃទៀត និង គោលការណ៍ណែនាំរបស់ក្រុមធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (រួមទាំងគោលនយោបាយនៃក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ) ត្រូវបានវិនិយោគិនវិស័យសាធារណៈ និងឯកជនដ៏មានសក្តានុពលខាងវិស័យគម្រោងទំនប់វារីអគ្គិសនី បានប្រើប្រាស់ជាញឹកញាប់ដើម្បីធ្វើជាបង្អែក។ គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មី ត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ចាប់តាំងពីឆ្នាំ១៩៨០ (ឧ. នៅក្នុងឆ្នាំ១៩៩០ ឆ្នាំ១៩៩៤ ឆ្នាំ១៩៩៨ និងឆ្នាំ២០០៤) ប៉ុន្តែដោយឡែកគោលការណ៍ជាមូលដ្ឋាន ដែលសំដៅបង្ការភាពចុះក្រីក្រដូនជាបនិងកសាងជីវភាពប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវរក្សាឲ្យនៅដដែល ។ ទោះជាយ៉ាងណា ទិដ្ឋភាពមួយចំនួននៃបទដ្ឋានជានិយាមរបស់ធនាគារពិភពលោក សម្រាប់កម្មវិធីតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ត្រូវបានចោទជាសំនួរឡើងថ្មីៗនេះ ទាក់ទងនឹងវិធីសាស្ត្រពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៃទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិជាច្រើន ដោយគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (ឆ្នាំ២០០០) និងដោយភ្នាក់ងារម្ចាស់ជំនួយទ្វេភាគី អង្គការអន្តរជាតិនានា និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន។

ភ្នាក់ងារអង្គការសហប្រជាជាតិមួយចំនួន ទទួលអាណត្តិរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហានានាទាក់ទងនឹង " ការបណ្តេញចេញដោយបង្ខំ " (ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត) ឬ " ការបំលាស់ទីខាងក្នុង "។ ក្នុងនោះ ភ្នាក់ងារដែលសំខាន់ជាងគេ គឺគណៈកម្មការទទួលបន្ទុកផ្នែកតាំងទីជម្រកនៃអង្គការសហប្រជាជាតិ (UNCHS/Habitat) គណៈកម្មការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (UNCHR) និងអង្គការស្បៀងអាហារ និងកសិកម្ម (FAO)។ សម្រាប់សកម្មភាពភាគច្រើនរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ ការតាំងទីលំនៅថ្មីដែលបណ្តាលឲ្យកើតមានជាជម្លោះ ជាទូទៅត្រូវបានយកចិត្តទុកដាក់ជាពិសេសធំជាងការអភិវឌ្ឍន៍ដែលបណ្តាលឲ្យមានការតាំងទីលំនៅថ្មី។ ទោះជាយ៉ាងណាក្នុងអំឡុងទសវត្សឆ្នាំ១៩៩០ បញ្ហានៃការអភិវឌ្ឍដែលបណ្តាលឲ្យមានការតាំងលំនៅថ្មីបានក្លាយជាវិស័យអភិវឌ្ឍន៍មួយដែលបង្កើនការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ។ បញ្ហានេះបានផ្សារភ្ជាប់ទៅនឹងការងារកំពុងបន្តអនុវត្តនិងការផ្លូចផ្តើមគោលនយោបាយស្តីពីសិទ្ធិមនុស្សដែលបានអនុវត្តនៅក្រោមកិច្ចឧបត្ថម្ភនៃអង្គការសហប្រជាជាតិ។

បច្ចុប្បន្ននេះ មានការទទួលស្គាល់ថា រាល់ការអភិវឌ្ឍន៍ដែលបណ្តាលឲ្យមានការបំលាស់ទីប្រជាពលរដ្ឋ អាចត្រូវបានចាត់ថ្នាក់ជាក្រុមខុសគ្នានៃក្រុមមនុស្សដែលតម្រូវឱ្យមានការការពារនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ ក្នុងឆ្នាំ១៩៩៥ បណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ ត្រូវបានទទួលស្គាល់ថារំលោភសិទ្ធិមនុស្ស ដែលបានកំណត់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំស្តីពីការបំលាស់ទីលំនៅ ដែលមានបង្ហាញនៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៧ ដែលបានចែងអំពី " ការអនុវត្តដោយការបណ្តេញចេញដោយបង្ខំ គោលការណ៍សិទ្ធិមនុស្សទូលំទូលាយស្តីពីការអភិវឌ្ឍន៍ពឹងផ្អែកលើការបំលាស់ទីលំនៅ " ។ " គោលការណ៍ណែនាំស្តីពីការបំលាស់ទីខាងក្នុង " ត្រូវបានបង្កើតឡើងនៅកម្រិតនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ គោលការណ៍ទាំងនេះ កំណត់ឲ្យឃើញច្បាស់ពីសិទ្ធិ និងការធានាដល់ការការពារប្រជាពលរដ្ឋពីការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ។ គោលការណ៍ទាំងនេះ ក៏បានកំណត់ឲ្យឃើញច្បាស់ពីសិទ្ធិ និងការធានាដល់ការការពារប្រជាពលរដ្ឋ និងការផ្តល់ជំនួយដល់ប្រជាពលរដ្ឋក្នុងអំឡុងពេលបំលាស់ទីលំនៅ និងពេលតាំងទីលំនៅថ្មី។

ជាគោលការណ៍ ម្ចាស់ជំនួយទ្វេភាគីនៃប្រទេសជាសមាជិកអង្គការ ដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ត្រូវអនុវត្តតាម " គោលការណ៍OECD-គណៈកម្មការផ្តល់ជំនួយអភិវឌ្ឍ (DAC) " គោលការណ៍លេខ៣ " ទីភ្នាក់ងារផ្តល់ជំនួយលើការបំលាស់ទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត និងការតាំងទីលំនៅថ្មីនៅក្នុងគម្រោងអភិវឌ្ឍន៍ " ដោះស្រាយជាពិសេសចំពោះបញ្ហាទូទាត់សំណង និងការតាំងទីលំនៅថ្មី ។ គោលការណ៍នេះផ្តល់នូវការទូទាត់សំណងសម្រាប់ការខូចខាតលើការចំណាយ ក្នុងការសងជំនួសវិញ និងការផ្តល់ជំនួយក្នុងកំឡុងពេលអន្តរកាល។ គួរផ្តល់ជំនួយដល់អ្នកដែលត្រូវបំលាស់ទីសម្រាប់ការខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីអាចធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ពួកគេបានប្រសើរដូចកាលពីមុន ឬ យ៉ាងហោចណាស់ដើម្បីស្តារជីវភាពរបស់ពួកគេឲ្យបានប្រសើរឡើងវិញ។ ទាំងអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) និងបទដ្ឋានជានិយាមនៃធនាគារពិភពលោក មានសេចក្តីសំអាង ស្រដៀងគ្នា ដែលមានខ្លឹមសារថា ៖ " ប្រសិនបើអាចធ្វើទៅបាន គួរជៀសវាងការតាំងទីលំនៅថ្មី ការធ្វើផែនការ និងការអនុវត្តការតាំងទីលំនៅថ្មីដោយសារគម្រោងអភិវឌ្ឍន៍មួយ និងត្រូវយកចិត្តទុកដាក់ជាបន្ទាន់ចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការការពារបរិស្ថាន " ។

កំណត់ត្រាលើការអនុវត្តនៃគោលនយោបាយស្តីពីការរក្សាការពាររបស់ធនាគារពិភពលោក រួមទាំង គោលនយោបាយស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្តរបស់ធនាគារ បានក្លាយទៅជាកម្មវត្ថុនៃភាពចម្រូងចម្រាស់ដែលចេះតែបន្តកើនឡើងជាលំដាប់ ។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលមួយចំនួន កំណត់ត្រាបានចង្អុលបង្ហាញយ៉ាងច្បាស់ថា គោលនយោបាយរបស់ធនាគារពិភពលោកបច្ចុប្បន្នមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពារសិទ្ធិមនុស្ស ការចិញ្ចឹមជីវិត និងបរិស្ថានរបស់សហគមន៍រងផលប៉ះពាល់ឡើយ។ ដោយសារមានការរិះគន់ទៅលើប្រសិទ្ធភាពនៃគំរូស្តង់ដាររបស់ធនាគារពិភពលោក បាននាំឲ្យធនាគារនេះឈានទៅដល់ការរួមចំណែកបង្កើតគណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD)។ អាណត្តិរបស់គណៈកម្មការនេះ គឺដើម្បីបង្កើតនូវការពិនិត្យឡើងវិញយ៉ាងទូលំទូលាយ និងស្នើឲ្យមានបទដ្ឋានមួយនៃការសម្រេចចិត្ត សម្រាប់គម្រោងទំនប់វារីអគ្គិសនី

តាមរយៈដំណើរការមួយ នាពេលអនាគត ។ ក្នុងចំណោមរបាយការណ៍ផ្សេងទៀត របាយការណ៍របស់ WCD ដែលបានចេញផ្សាយនៅក្នុងឆ្នាំ២០០០ បានគាំទ្រនិងបានពង្រឹងគំរូស្តង់ដារសម្រាប់ការទូទាត់សំណង និងការតាំងទីលំនៅថ្មី ក្នុងគោលបំណងដើម្បីបញ្ចៀសភាពចុះក្រដុនដាប របស់ប្រជាពលរដ្ឋរងផលប៉ះពាល់។ WCD បានស្នើឡើងថា ត្រូវផ្តល់ការគ្រាំផ្នែកច្បាប់ដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ក្នុងការចរចាឲ្យមានការឯកភាពគ្នាទៅវិញទៅមកលើការបន្ធូរបន្ថយដែលបានព្រមព្រៀង ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី និងការអភិវឌ្ឍន៍។

WCD ក៏បានផ្តល់អនុសាសន៍ផងដែរថា មិនត្រូវអនុញ្ញាតដល់គម្រោងទំនប់វារីអគ្គិសនីណាមួយឱ្យបន្តធ្វើនៅលើទឹកដីរបស់ជាតិដើមភាគតិច និង កុលសម្ព័ន្ធ ដោយគ្មានការទទួលបានពីប្រជាពលរដ្ឋទាំងនោះនូវការយល់ព្រមដោយយុត្តិធម៌ និងដោយផ្តល់ពត៌មានជាមុនឡើយ ។ ជាការឆ្លើយតបទៅនឹងរបាយការណ៍របស់ WCD ធនាគារពិភពលោកបានចង្អុលបង្ហាញថា " ... ប្តេជ្ញាដើម្បីធានាឲ្យប្រាកដថា ទស្សនៈរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវបានចងក្រងទុកជាឯកសារ ដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ពីសំណាក់អ្នកធ្វើសេចក្តីសម្រេចចិត្តរបស់គម្រោង ដោយគ្មានការរំលោភលើសិទ្ធិរបស់រដ្ឋ ដើម្បីឈានដល់ការសម្រេចចិត្តនានា ដែលបានវិនិច្ឆ័យឲ្យមានដំណោះស្រាយដ៏ល្អបំផុតសម្រាប់សហគមន៍ទាំងមូល (ប្រភពធនាគារពិភពលោក ឆ្នាំ២០០០) " ។ អនុសាសន៍របស់ WCD បានណែនាំបង្ហាញពីបទដ្ឋានថ្មីមួយសម្រាប់ដោះស្រាយលើបញ្ហានៃការតាំងទីលំនៅថ្មី និងការទូទាត់សំណង។ ចាប់តាំងពីនោះមក អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការសង្គមស៊ីវិលមួយចំនួន បានជួយគាំទ្រដល់ការអនុវត្តតាមអនុសាសន៍របស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងភ្នាក់ងារផ្តល់ឥណទាននាំចេញនានា ។ ចំណែកទីភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគីអឺរ៉ុបក៏បានយកអនុសាសន៍របស់ WCD នេះមកអនុវត្តផងដែរ ។

ការទូទាត់សំណង និង ការបែងចែកផលប្រយោជន៍ ក៏មានភាពស្របគ្នាផងដែរទៅនឹងគោល-នយោបាយអភិវឌ្ឍន៍ជាតិរបស់គណៈកម្មការទន្លេមេគង្គ លើការកាត់បន្ថយភាពក្រីក្រ និង គម្លាតប្រកៀកប្រកិតរវាងអ្នកមាន និងអ្នកក្រីក្រ។ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងរបស់គណៈកម្មការទន្លេមេគង្គ ការបែងចែកផលប្រយោជន៍ គឺជាគន្លឹះដ៏សំខាន់ដើម្បីធ្វើឲ្យវារីអគ្គិសនីប្រកបដោយនិរន្តរភាពបានជឿនលឿនទៅមុខ តាមរយៈការផ្លាស់ប្តូរលើសពីការស្តារប្រាក់ចំណូល និងដំណើរការទូទាត់សំណង។

មានការទទួលស្គាល់ថា នៅពេលដែលគម្រោងផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនីប្រកបដោយចីរភាពរបស់គណៈកម្មការទន្លេមេគង្គ ត្រូវបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌនៃដំណើរការព្រមព្រៀងគ្នារវាងពហុភាគីឆ្នាំ២០០៨-២០០៩ ការបែងចែកផលប្រយោជន៍ គឺជាធាតុផ្សំដ៏មានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយចីរភាព។ ហេតុដូច្នេះហើយ ការបែងចែកផលប្រយោជន៍ ត្រូវបានរួមបញ្ចូលទៅក្នុងផែនការសកម្មភាពនៃគម្រោងផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនីប្រកបដោយចីរភាព ISH (ឧ. លទ្ធផលនេះ)។

- ច្បាស់ណាស់ដែលថា គោលការណ៍នៃការបែងចែកផលប្រយោជន៍ ត្រូវបានបំពេញបញ្ចូលទៅក្នុង គោលនយោបាយ និងច្បាប់នៃបណ្តាប្រទេសទន្លេមេគង្គ ដែលបានកំណត់អត្តន័យពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ៖

- តួយ៉ាងនៅក្នុងប្រទេសវៀតណាម ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ត្រូវបានកំណត់អត្ថន័យដោយស្របច្បាប់ដូច្នេះថា " ជាការអភិវឌ្ឍន៍ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សម័យកាលបច្ចុប្បន្ន ដោយគ្មានការធ្វើខូចខាតដល់លទ្ធភាពរបស់អ្នកជំនាន់ក្រោយ ដើម្បីបំពេញតាមតម្រូវការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃការរួមបញ្ចូលគ្នាយ៉ាងជិតស្និទ្ធ និងដោយសុខដុមនីយកម្មនៃកំណើនសេដ្ឋកិច្ច ការធានាដល់ការរីកចម្រើនជឿនលឿនដល់សង្គមជាតិ និងការការពារបរិស្ថាន។ "
- យន្តការនៃការបែងចែកផលប្រយោជន៍ (BSM) ជួយបង្កលក្ខណៈឲ្យមាន " ការធានាការរីកចម្រើននៃសង្គមជាតិ " មិនមែនគ្រាន់តែសម្រាប់ក្រុមមនុស្សមួយចំនួននោះទេ ប៉ុន្តែសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ។
- នៅពេលជាមួយគ្នានេះដែរ យន្តការនៃការបែងចែកផលប្រយោជន៍ ជួយនាំមកនូវការរួមបញ្ចូលគ្នានៃសសរស្តម្ភសំខាន់ទាំងបី ដោយសារតែទិដ្ឋភាពទាំងនេះ ជាញឹកញាប់មិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដែលមានទឹកទន្លេ។
- នៅបណ្តាប្រទេសទន្លេមេគង្គផ្សេងទៀត មាននិយមន័យផ្លូវច្បាប់ស្រដៀងគ្នានេះដែរ ដែលឆ្លុះបញ្ចាំងពីនិយមន័យដែលទទួលស្គាល់ជាអន្តរជាតិ ដែលមានចែងនៅក្នុងអនុសញ្ញានៃអង្គការសហប្រជាជាតិ ដែលប្រទេសទន្លេមេគង្គ គឺជាភាគីហត្ថលេខី (ឧ. របៀបវារៈទី២១) ។

• តាមទស្សនៈរបស់សកលលោក ក៏បានយល់ឃើញថា ការបែងចែកផលប្រយោជន៍ទៅដល់ភាគីពាក់ព័ន្ធទាំងអស់ គឺជាផ្នែកទាំងស្រុងមួយនៃវារីអគ្គិសនីប្រកបដោយនិរន្តរភាព។ នេះត្រូវបានគេមើលឃើញយ៉ាងច្បាស់ពីសារៈសំខាន់នៃមូលបទចែករំលែកផលប្រយោជន៍ នៅក្នុងសម័យបច្ចុប្បន្នកាលថ្មី ទៅលើឧបករណ៍ការវាយតម្លៃនិរន្តរភាពវារីអគ្គិសនី ដែលបានបង្កើតឡើងក្នុងក្របខ័ណ្ឌដំណើរការពហុភាគី នៅកម្រិតអន្តរជាតិ ដូចដែលបានពិភាក្សានៅក្នុងផ្នែកទី២.៣។

- នៅកម្រិតតំបន់ គណៈកម្មការទន្លេមេគង្គជួយដល់បណ្តាប្រទេសជាសមាជិកឲ្យកំណត់ឲ្យបានច្បាស់លាស់ពីវិធានការនិងការត្រួតពិនិត្យជំហាននានា ដើម្បីកែលម្អលទ្ធផលប្រកបដោយនិរន្តរភាពនៅក្នុងវិស័យវារីអគ្គិសនី។ ការផ្តួចផ្តើមមួយជាគន្លឹះ គឺការអភិវឌ្ឍដោយមានកិច្ចសហការនៃឧបករណ៍វាយតម្លៃឆាប់រហ័ស លើនិរន្តរភាពវារីអគ្គិសនីតាមអាងទន្លេធំ (RSAT)។ ឧបករណ៍នេះ កំពុងត្រូវបានអនុវត្តក្រោមគម្រោងសាកល្បងនៅមូលដ្ឋាន ដែលជាចំណុះអាងនៅក្នុងបណ្តាប្រទេសទន្លេមេគង្គ ក្រោមការសម្របសម្រួលពីគណៈកម្មការទន្លេមេគង្គ។
  - ឧបករណ៍វាយតម្លៃនិរន្តរភាពវារីអគ្គិសនីតាមអាង/អនុអាង គឺជាលទ្ធផលនៃការយល់ដឹងជាច្រើនឆ្នាំ និងជាការត្រៀមរៀបចំ ក្រោមការផ្តួចផ្តើមគំនិតភាពជាដៃគូ ដែលគេហៅថា លក្ខណៈវិនិច្ឆ័យផ្នែកបរិស្ថានសម្រាប់ការអភិវឌ្ឍន៍វារីអគ្គិសនី

ប្រកបដោយចីរភាព (ECSHD) ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី គណៈកម្មការទន្លេមេគង្គ និងអង្គការមូលនិធិសត្វព្រៃពិភពលោក (WWF)។

- ឧបករណ៍វាយតម្លៃឆាប់រហ័សលើនិរន្តរភាពវារីអគ្គិសនីតាមអាងទន្លេធំ (RSAT) ត្រូវបានបង្កើតឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ NMCS និងស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃដំណើរការដែលដឹកនាំដោយគម្រោងផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនី ប្រកបដោយចីរភាព (ISH) បំពេញការងារជាមួយនាយកដ្ឋានបរិស្ថាននៃគណៈកម្មការទន្លេមេគង្គ។
- RSAT ចាត់ទុកថាទោះជាតម្រូវការអ្វីក៏ដោយ គឺត្រូវតែយកចិត្តទុកដាក់នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃរយៈកាលអនុវត្តគម្រោង ដែលកើតចេញពីការធ្វើផែនការ និង ការរៀបចំគោលបំណង តាមរយៈកិច្ចប្រតិបត្តិការ ។ ប្រភេទនៃប្រធានបទ និងលក្ខណៈវិនិច្ឆ័យនៅក្នុង RSAT សុទ្ធតែបានផ្តល់ការគាំទ្រដល់ចរិកលក្ខណៈក្បួនខ្នាតចម្រុះ ដែលមានជាប់ជាមួយនៃបញ្ហាប្រឈមទាក់ទងនឹងនិរន្តរភាពវារីអគ្គិសនី។
- ការបែងចែកផលប្រយោជន៍ គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទទាំង១១ ក្នុង RSAT ដែលមានឈ្មោះថា "ប្រធានបទទី៨: ការចែករំលែកផលប្រយោជន៍ និងការប្រើប្រាស់វិធានការក្នុងការផ្តល់ហិរញ្ញប្បទានដោយមានការផ្លាស់ប្តូរ ដើម្បីនិរន្តរភាព (ថ្នាក់មូលដ្ឋាន និងថ្នាក់ព្រំប្រទល់ដែន)។
  - ប្រធានបទទី១១ បង្ហាញពីការបែងចែកដោយស្មើភាពលើផលប្រយោជន៍គម្រោងទៅដល់ក្រុមមនុស្សខុសៗគ្នា ក្នុងក្របខ័ណ្ឌនៃអាងទន្លេ និងក្របខ័ណ្ឌយុត្តាធិការ។
  - នៅក្នុង RSAT វិធីសាស្ត្រនៃការវាយតម្លៃ គឺត្រូវបានធ្វើឡើងពីវត្តមាននៃយន្តការស្តីពីការបែងចែកផលប្រយោជន៍ (BSM) ឬឱកាសមិនជាក់លាក់សម្រាប់ (BSM) នៅក្នុងក្រមខ័ណ្ឌនៃ (i)លទ្ធភាពទទួលបានសេវាអគ្គិសនីប្រកបដោយសមធម៌ (ii)ការទទួលបានសិទ្ធិស្របច្បាប់មិនមែនជារូបិយវត្ថុចំពោះការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានធនធាន និង(iii)ការបែងចែកប្រាក់ចំណូល។
  - RSAT មិនមែនជាឧបករណ៍ដាក់បញ្ញត្តឡើយ។ ប៉ុន្តែវារួមបញ្ចូលប្រជាពលរដ្ឋឲ្យចូលរួមពិភាក្សាជាលក្ខណៈគ្រោង និង ជាលក្ខណៈផ្តល់ព័ត៌មានលើចំនុចទាំងនេះ ចំពោះទីតាំងដែលភាគីពាក់ព័ន្ធអាចយល់ស្របថាមានវិសាលភាពសម្រាប់ធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នៅក្នុងការអនុវត្តនាពេលបច្ចុប្បន្ន។

○ ស្ថាប័នផ្តល់ហិរញ្ញប្បទានពហុភាគីសម្រាប់ការអភិវឌ្ឍន៍ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក (WB) គាំទ្រយ៉ាងសកម្មដល់ការបែងចែកផលប្រយោជន៍

ដែលជាទិដ្ឋភាពគន្លឹះមួយ ដើម្បីជម្រុញឲ្យមានការរីកចម្រើនដល់និរន្តរភាពនៃវារីអគ្គិសនី នៅក្នុងការផ្តល់ប្រាក់កម្ចីរបស់ខ្លួនសម្រាប់គម្រោងនានា។

- កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ គឺមានសារៈសំខាន់បំផុតក្នុងការបែងចែកផលប្រយោជន៍ជុំវិញទំហំនៃព្រំប្រទល់ដែន និងវិសាលភាពខុសៗគ្នា (ពីថ្នាក់តំបន់ ទៅថ្នាក់ជាតិ ពីថ្នាក់ជាតិ ទៅថ្នាក់មូលដ្ឋាន)។
- គោលការណ៍នៃការបែងចែកផលប្រយោជន៍ព្រំប្រទល់ដែន ត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ដែលទាក់ទងទៅនឹងខច្បាប់ ដូចជា ៖
  - ការប្រើប្រាស់ប្រកបដោយសមធម៌ និងសមហេតុផល
  - គ្មានការបង្កគ្រោះថ្នាក់ និង
  - សេរីភាពខាងផ្នែកនាវាចរណ៍។
  - ថ្មីៗនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ (MRC) បានបញ្ចាក់ពីវិធីសាស្ត្រ ដើម្បីពិភាក្សាអំពីការបែងចែកផលប្រយោជន៍ ដែលជាផ្នែកមួយនៃចន្លោះឱកាសនៃការអភិវឌ្ឍ (DOS)។ នៅក្នុងសេចក្តីអធិប្បាយពីអាទិភាពសម្រាប់ MRC ដើម្បីជួយធ្វើឲ្យប្រសើរឡើងដល់ការអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយនិរន្តរភាព។
    - BDS កត់សម្គាល់ថា "DOS ក៏អាចត្រូវបានប្រើជា "ចន្លោះកិច្ចសហប្រតិបត្តិការ" ឬ "ចន្លោះនៃការចរចា" ដើម្បីស្វែងរកជម្រើសផលប្រយោជន៍ទៅវិញទៅមក។
    - ពេលពិភាក្សាអំពីវារីអគ្គិសនី BDS បានកត់សម្គាល់ឃើញអំពីផលប្រយោជន៍ដោយប្រយោល និង បន្ថែមជាច្រើនដែលបានលេចចេញមក ព្រមទាំងតម្រូវការនានាសម្រាប់ការយកចិត្តទុកដាក់ទៅលើ "ការកំណត់ឲ្យបានលម្អិតពីផលប៉ះពាល់ និងវិធានការក្នុងការកាត់បន្ថយ និង ការបែងចែកផលប្រយោជន៍ ក៏ដូចជាការសម្របសម្រួលរវាងប្រទេសទន្លេមេគង្គក្រោមស្តីពីប្រតិបត្តិការ ទំនប់វារីអគ្គិសនីនៅតាមដៃទន្លេជាមួយប្រទេសចិនស្តីពីប្រតិបត្តិការលើទំនប់ Lancang "។
    - ដើម្បីផ្លាស់ប្តូរឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវារីអគ្គិសនី នៅលើដៃទន្លេ BDS បានកត់សម្គាល់ឃើញពីតម្រូវការសម្រាប់ " វាយតម្លៃជម្រើសនៃការបែងចែកផលប្រយោជន៍ ដូចជាការអភិវឌ្ឍនិងការគ្រប់គ្រងតំបន់ទីជម្រាល ដែលផ្តល់នូវអត្ថប្រយោជន៍ដល់ការផលិតវារីអគ្គិសនី និង បានផ្តល់ជាមូលនិធិបានពីប្រាក់ចំណូលវារីអគ្គិសនី" ។

រាល់ចំនុចខាងលើនេះ សុទ្ធតែបានបង្ហាញពីសារៈសំខាន់នៃយន្តការស្តីពីការបែងចែកផលប្រយោជន៍ (BMS) សំដៅធានានិរន្តរភាពនៃទម្រង់អភិវឌ្ឍ និងការគ្រប់គ្រងវារីអគ្គិសនី ពោលគឺទាក់ទងទៅនឹងវិសាលភាព (ឧ. ការបែងចែកផលប្រយោជន៍ចាប់ពីថ្នាក់ប្រទេសដែលជាប់ព្រំប្រទល់ដែន ដល់ថ្នាក់ជាតិ ពីថ្នាក់ជាតិ ទៅថ្នាក់មូលដ្ឋាន)។

ប្រអប់អត្ថបទ ៦.១ សាវតា និងបទដ្ឋានជានិយាម -ទស្សនៈគន្លឹះ

គោលនយោបាយស្តីពីការទូទាត់សំណង សម្រាប់គម្រោងទំនប់វារីអគ្គិសនី នៅក្នុងបណ្តាប្រទេសកំពុង អភិវឌ្ឍន៍ គួរតែធានាឲ្យបាននូវការធ្វើឱ្យប្រសើរឡើងឆាប់រហ័ស និងជាវិធានការចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍ដែលរងផលប៉ះពាល់។ ប្រការនេះ អាចធ្វើឲ្យសម្រេចបានតាមរយៈ ៖

- ជម្រុញឲ្យមានការអនុវត្តតាមបទដ្ឋានជានិយាមសមស្រប។ ទិដ្ឋភាពដែលមានលក្ខណៈជាបទ-បញ្ញត្តិ និងជាលក្ខណៈស្ថាប័ន ដែលជាប់ទាក់ទងជាមួយនឹងការតាំងទីលំនៅថ្មី ជារឿយៗ ពិតជាមានការពិបាកក្នុងការដោះស្រាយ។ ការផ្លាស់ប្តូរបទដ្ឋានគតិយុត្តិ ឬបទដ្ឋានស្ថាប័ន ទាមទារឲ្យមានការចូលរួមយ៉ាងសកម្ម និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលពាក់ព័ន្ធ។ ត្រូវទាមទារឲ្យមានការកសាង សមត្ថភាពស្ថាប័ន។ ការកសាងសមត្ថភាពស្ថាប័ន អាចដោះស្រាយចំពោះតម្រូវការសម្រាប់ដំណើរការធ្វើផែនការគម្រោង ដែលមានលក្ខណៈស្ថាប័ន តម្រូវការចាំបាច់ដើម្បីធានាឲ្យមានការចូលរួម ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ពីគ្រប់ភាគីទាំងអស់ដែលរងផលប៉ះពាល់ដោយសារគម្រោង ព្រមទាំងតម្រូវការក្នុងការពង្រឹងសមត្ថភាពលើការគ្រប់គ្រងដីធ្លីក្នុងមូលដ្ឋាន។
- ការធ្វើផែនការ និង ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះរយៈពេលវែង ។ ការខូចខាតដែលកើតឡើងចំពោះបុគ្គល និងសហគមន៍ ដែលជាលទ្ធផលនៃសកម្មភាពគម្រោង គួរតែត្រូវបានទូទាត់សងជំនួសដោយផ្ទាល់ ហើយបើអាចធ្វើទៅបានការទូទាត់សំណងទាំងអស់ គួរតែធ្វើឡើងជាសំណងមិនមែនជាសាច់ប្រាក់ ។ និរន្តរភាពខាងផ្នែកសេដ្ឋកិច្ច តម្រូវឱ្យមានភាពកៀកគ្នានឹងទីផ្សារ ការគ្រប់គ្រងធនធានធម្មជាតិដោយត្រឹមត្រូវ និង រួមទាំងម្ចាស់សហគមន៍ដែលជាអ្នកទទួលផលពីគម្រោងសកម្មភាពនៃការតាំងទីលំនៅថ្មី ។ ត្រូវតែផ្តល់នូវជំនួយអភិវឌ្ឍន៍ដូចជាការត្រៀមរៀបចំដីធ្លី ការផ្តល់ឥណទាន ការបណ្តុះបណ្តាល ឬឱកាសការងារ។

ប្រធានបទពិភាក្សា	មានបទដ្ឋានជានិយាមជាច្រើន (ទាំងជាតិ និងអន្តរជាតិ) ដែលគ្របដណ្តប់លើការវាយតម្លៃហេតុផលប៉ះពាល់សង្គម ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ការទូទាត់សំណង និងការបែងចែកផលប្រយោជន៍។ បទដ្ឋានទាំងនេះមិនមែនស្របគ្នាទាំងអស់ជានិច្ចនោះទេ។ តាមរយៈការប្រើប្រាស់បទដ្ឋានជានិយាមពីប្រទេសផ្ទាល់ខ្លួនរបស់អ្នក ចូរកំណត់ឲ្យបានច្បាស់ពីចរិកលក្ខណៈសំខាន់ៗ និង ធ្វើការប្រៀបធៀបលើលក្ខណៈសំខាន់ៗទាំងនេះនៃបទដ្ឋានជានិយាមអន្តរជាតិ (តួយ៉ាងបទដ្ឋានរបស់ធនាគារពិភពលោក ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងសមាគមវារីអគ្គិសនីអន្តរជាតិ) ។ ……

	តាយរយ:ការប្រើឧទាហរណ៍នានានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗនៅក្នុងប្រទេសរបស់អ្នក ចូរពិភាក្សាអំពីការអនុវត្តបទដ្ឋានជានិយាមជាតិ និងអន្តរជាតិ ដោយផ្តោតលើផលប៉ះពាល់នៃការអនុវត្តនោះ ទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។ ..... តាមរយ:ការទាញយកលទ្ធផល នៃប្រធានបទពិភាក្សាទាំងពីរខាងលើនេះ ចូរពិភាក្សាអំពីវិធីសាស្ត្រដ៏មានសក្តានុពល និង អំពីវិធានការដែលអាចយកមកពិចារណាបាន ដើម្បីកែលម្អគោលនយោបាយទូទាត់សំណងទាក់ទងនឹងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត។
លំហាត់	ចូររៀបចំតារាងជាពីរជួរ ហើយនៅក្រោមតារាងជួរនីមួយៗ ត្រូវរៀបចំជាតារាងយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ និងមិនមែនជារូបិយវត្ថុ។

៦.២ គោលនយោបាយទូទាត់សំណង - គោលការណ៍ណែនាំ

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីគោលការណ៍គន្លឹះ ដែលបង្កើតជាមូលដ្ឋានសម្រាប់ទ្រទ្រង់ គោល-នយោបាយ ទូទាត់សំណង។
ទិសដៅ	• ដើម្បីពន្យល់ឲ្យសិក្ខាកាមយល់អំពីគោលការណ៍គន្លឹះ ដែលបង្កើតជាមូលដ្ឋានសម្រាប់ទ្រទ្រង់គោលនយោបាយទូទាត់សំណង។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP2007) ។ ទំនប់វារីអគ្គិសនីនិងការអភិវឌ្ឍ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន។ ផ្នែកទី៥: គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់ទៅលើការលើយន្តការនៃការបែងចែកផលប្រយោជន៍) www.unep.org/dams

ធាតុសំខាន់ៗជាទូទៅនៃគោលនយោបាយទូទាត់សំណងជាលក្ខណៈអន្តរជាតិ និងគោលការណ៍ណែនាំនានា ដែលអនុវត្តចំពោះការបំលាស់ទីលំនៅនិងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ មានដូចជាទំនប់វារីអគ្គិសនី និងសំណង់អគារវារីអគ្គិសនី ត្រូវបានសង្ខេបនៅក្នុងផ្នែកខាងក្រោមនេះ។ ធាតុសំខាន់ៗដែលមានជាទូទៅទាំងនេះ អាចត្រូវបានរកឃើញនៅក្នុងគោលនយោបាយរក្សាឧបត្ថម្ភគាំពារ ដែលបានជម្រុញឆ្ពោះទៅមុខដោយក្រុមធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍ពហុភាគីផ្សេងទៀត តាមរយៈគំរូស្តង់ដារនៃគោលនយោបាយ និង ការអនុវត្តថ្មីបំផុតរបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង តាមរយៈអនុសាសន៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិ-សនី។ ធាតុសំខាន់ៗទាំងនេះ ត្រូវបានសំដៅតាមរយៈភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងស្ថាប័នផ្តល់ហិរញ្ញប្បទាន

អន្តរជាតិ និង ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ដូចជាប្រទេសប្រេស៊ីល ប្រទេសកូឡុំប៊ី ប្រទេសចិន និងប្រទេសឥណ្ឌា ជាដើម។

៦.២.១ ការធានាឲ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់

គោលនយោបាយ និង គោលការណ៍ណែនាំស្តីពីការទូទាត់សំណង បានគូសបញ្ជាក់យ៉ាងច្បាស់ពីតម្រូវការដើម្បីធានាឲ្យមានភាពល្អប្រសើរនៃជីវភាពរបស់ប្រជាពលរដ្ឋទាំងអស់ ដែលរងផលប៉ះ-ពាល់ដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាទំនប់វារីអគ្គិសនីនិងសំណង់អគារវារីអគ្គិសនីនានា។ ស្រដៀងគ្នាទៅនឹងបែបទនៃស្ថានប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀតដែរ គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត (op/ BP4.12) និងគំរូស្តង់ដាលេខ៥របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីការផ្តល់សម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត បានតម្រូវថា ការតាំងទីលំនៅថ្មីត្រូវតែផ្តល់នូវលទ្ធផល " ល្អប្រសើរ ឬ យ៉ាងហោចណាស់ផ្តល់នូវការស្តារឡើងវិញលើរបរចិញ្ចឹមជីវិត និងកម្រិតជីវភាពរស់នៅរបស់អ្នកដែលត្រូវបំលាស់ទី " ។

គោលការណ៍ប្រតិបត្តិការរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត បានគូសបញ្ជាក់ថា " គួរតែផ្តល់ជំនួយដល់អ្នកដែលត្រូវបំលាស់ទីចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីជាការលើកកម្ពស់ការចិញ្ចឹមជីវិត និង កម្រិតជីវភាពរស់នៅរបស់ពួកគេ ឬ យ៉ាងហោចណាស់ធ្វើយ៉ាងណាក៏ដោយឲ្យតែអាចស្តារជីវភាពរស់នៅរបស់ពួកគេឲ្យស្ថិតក្នុងកម្រិតខ្ពស់ជាងមុន ពេលបំលាស់ទី ឬក្នុងកម្រិតប្រសើរជាងមុនពេលចាប់ផ្តើមអនុវត្តគម្រោង។ គោលបំណងបន្ថែមនៃគំរូស្តង់ដាលេខ៥របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីការផ្តល់សម្បទានដី និងការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត គឺធ្វើយ៉ាងណាឲ្យកម្មវិធីតាំងទីលំនៅថ្មី អាចផ្តល់នូវលទ្ធផល " ល្អប្រសើរដល់កម្រិតជីវភាពរស់នៅក្នុងចំណោមអ្នកដែលត្រូវបំលាស់ទី តាមរយៈការផ្តល់លំនៅដ្ឋានសមរម្យរួមជាមួយនឹងការធានាសិទ្ធិកាន់កាប់លើតំបន់តាំងទីលំនៅថ្មីនោះ " ។

៦.២.២ ការអនុវត្តន៍វិធីសាស្ត្រអភិវឌ្ឍ

គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង បានគូសបញ្ជាក់ពីតម្រូវការនៃការរៀបចំផែនការ និងការអនុវត្តចំពោះកម្មវិធីតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត ឲ្យដូចទៅនឹងគម្រោងអភិវឌ្ឍន៍ ដែលដំណើរការពេញលេញ ។ ការតាំងទីលំនៅថ្មីដែលជាគោលនយោបាយអភិវឌ្ឍន៍ដោយមានការគាំទ្រផ្នែកច្បាប់ (ដូចជាច្បាប់តាំងទីលំនៅថ្មីនៅតំបន់អាងស្តុកទឹករបស់ប្រទេសចិន និងច្បាប់ស្តីពីការផ្តល់មូលនិធិមុនការតាំងលំនៅថ្មី និងមូលនិធិស្តារនីតិសម្បទា) ជាប់ពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃដី និង កញ្ចប់គាំទ្រជីវភាពរស់នៅ ប្រកបដោយចីរភាពដោយមិនពឹងផ្អែកលើដី ដោយមានការចូលរួមយ៉ាងសកម្មរបស់សហគមន៍ (ទាំងសហគមន៍ដែលបំលាស់ទី និងសហគមន៍ជាម្ចាស់) និងគណនេយ្យភាព ព្រមទាំងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនិងម្ចាស់គម្រោងអភិវឌ្ឍន៍។

គោលការណ៍ប្រតិបត្តិការរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត បានកំណត់ថា នៅទីកន្លែងដែលមិនអាចជៀសវាងបាននូវការតាំងលំនៅថ្មី សកម្មភាពនៃការតាំងទីលំនៅថ្មី ត្រូវតែអនុវត្តឡើងឲ្យដូចនឹងកម្មវិធីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តាមរយៈការផ្តល់នូវ

ធនធានវិនិយោគគ្រប់គ្រាន់ ដើម្បីធានាឲ្យប្រាកដថា អ្នកដែលបំលាស់ទីដោយសារគម្រោង អាចបែងចែកគ្នាទៅវិញទៅមកនូវផលប្រយោជន៍ដែលបានពីគម្រោងនោះ ។ គួរតែផ្តល់ការប្រឹក្សាយោបល់យ៉ាងពេញលេញដល់អ្នកដែលបំលាស់ទី និងបើកឱកាសឲ្យពួកគេបានចូលរួមក្នុងការធ្វើផែនការនិងការអនុវត្តកម្មវិធីតាំងលំនៅថ្មី។

យុទ្ធសាស្ត្រជាមូលដ្ឋានចំនួនពីរ អាចអនុវត្តបន្តបាននៅពេលដែលមានការរៀបចំកម្មវិធីតាំងលំនៅថ្មី នោះគឺយុទ្ធសាស្ត្រដែលផ្អែកលើដី និង យុទ្ធសាស្ត្រដែលមិនពឹងផ្អែកលើដី ។ យុទ្ធសាស្ត្រដែលផ្អែកលើដីជាប់ពាក់ព័ន្ធនឹងការកសាងសកម្មភាពដែលទទួលបានមូលនិធិពីគម្រោង ដោយឡែកមួយចំនួនដូចជាគម្រោងរានដី គម្រោងធារាសាស្ត្រ កសិកម្មប្រពលវប្បកម្ម ការដាំដុះរុក្ខជាតិហូបផ្លែ ជលផល ពាណិជ្ជកម្ម ឬ វិទ្យាសាស្ត្រព្រៃឈើ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារក្រៅពីស្រែចម្ការ និង ប្រភេទសកម្មភាពរកប្រាក់ចំណូលយូរអង្វែងដទៃទៀត។ ការកសាងឡើងវិញនូវជីវភាពរស់នៅ ផ្អែកលើមូលដ្ឋាននៃយុទ្ធសាស្ត្រពឹងផ្អែកលើដី គឺអាស្រ័យលើឆន្ទៈរបស់រដ្ឋាភិបាល និង ម្ចាស់គម្រោងការអភិវឌ្ឍ សំដៅទទួលបានមកនូវដីនិងកំណត់ដោយឡែកនូវដី ដែលមានបរិមាណនិងគុណភាពគ្រប់គ្រាន់ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រទាំងនេះ។

សូម្បីតែនៅពេលដែលដីមានស្រាប់មានបរិមាណ និងគុណភាពគ្រប់គ្រាន់ហើយក្តី ក៏ត្រូវការឲ្យមានជម្រើសជាយុទ្ធសាស្ត្រដែលមិនពឹងផ្អែកលើដី ដែលអាចជំនួសបានសម្រាប់អ្នកដែលត្រូវបំលាស់ទីដែរ ។ គោលការណ៍ប្រតិបត្តិការរបស់ធនាគារពិភពលោក ស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តបានលើកឡើងថា " ប្រសិនបើដីនោះមិនមែនជាជម្រើសពេញចិត្តរបស់អ្នកដែលត្រូវបំលាស់ទីនោះទេ ការផ្តល់ដីអាចនឹងបង្កជាផលប៉ះពាល់មិនល្អដល់និរន្តរភាពនៃឧទ្យាន ឬ តំបន់ការពារ ឬ មិនមានដីគ្រប់គ្រាន់ក្នុងតម្លៃសមរម្យ នោះត្រូវតែផ្តល់ជម្រើសណាដែលមិនពឹងផ្អែកលើដី ដោយការផ្តល់ឱកាសការងារ ឬ ការងារធ្វើដោយខ្លួនឯង បន្ថែមទៅលើការទូទាត់សំណងជាសាច់ប្រាក់សម្រាប់ការខូចខាតដីធ្លី និង ទ្រពសម្បត្តិនានា" ។

អ្នកដែលត្រូវផ្លាស់ទីដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដោយការបង្ខិតបង្ខំគួរតែមានលទ្ធភាពទទួលបានអចលនទ្រព្យផ្សេងៗ ដូចជា សិទ្ធិលំនៅដ្ឋាន ដីធ្លី និង សេវាសាធារណៈបានទទួលឱកាសសេដ្ឋកិច្ច (ដូចជាការងារនៅជិតៗផ្ទះ តំបន់នេសាទ ការងារ ស្រោចស្រព ដំណាំដាំដុះ និងព្រៃឈើ) ក៏ដូចជាទ្រពសម្បត្តិមិនមែនសេដ្ឋកិច្ច ដូចជា (ទីសក្ការបូជា ទីបញ្ចុះសព អគារសាលាឃុំ តំបន់ព្រៃឈើរួមទីកន្លែងដែលមានគុណតម្លៃសម្រាប់ព្រលឹងវិញ្ញាណ [យោង១៦] ជាដើម) ។ ដូច្នេះកម្មវិធីតាំងទីលំនៅថ្មី ជាធម្មតាត្រូវតែរួមបញ្ចូលទាំងការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មផ្សេងៗ ដើម្បីធានាបាននូវចីរភាពរយៈពេលវែងសម្រាប់អ្នកដែលត្រូវផ្លាស់ទី និងម្ចាស់សហគមន៍។

[យោង១៦] ត្រូវកត់សម្គាល់ថានៅក្នុងករណីជាច្រើនគេមិនអាចធ្វើការទូទាត់សំណងសម្រាប់ទ្រពសម្បត្តិមិនមែនសេដ្ឋកិច្ច ដូចជាទីកន្លែងដែលមានគុណតម្លៃខាងព្រលឹងវិញ្ញាណ ដែលជាកន្លែងគ្មានចំនួនទឹកប្រាក់ និង/ឬទីតាំងសម្រាប់សងជំនួសទីតាំងដើម ដែលត្រូវបាត់បង់ទៅដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងទ្រង់ទ្រាយធំ ។ នេះគឺជាដែនកំណត់នៃការទូទាត់សំណងដែលត្រូវតែដោះស្រាយឲ្យបានសមស្រប និងដោយមានការឯកភាពពីប្រជាពលរដ្ឋ/សហគមន៍ដែលរងផលប៉ះពាល់។

គោលការណ៍ប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងលំនៅថ្មីមិនមែនជាស្ម័គ្រចិត្ត បញ្ជាក់ថា " ត្រូវតែផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗតាមការចាំបាច់ដល់តំបន់តាំងទីលំនៅថ្មី ឬ នៅក្នុងសហគមន៍ថ្មី ដើម្បីធ្វើឱ្យប្រសើរឡើង ដើម្បីស្តារឡើងវិញ ឬរក្សាបាននូវមធ្យោបាយងាយស្រួល និងកម្រិតនៃសេវាសម្រាប់អ្នកដែលត្រូវផ្លាស់ទី និង ម្ចាស់សហ-គមន៍នោះ ។ ត្រូវផ្តល់នូវជម្រើសដែលអាចជំនួសបាន ឬធនធានស្រដៀងគ្នានេះ ដើម្បីទូទាត់សងចំពោះការបាត់បង់នូវលទ្ធភាពទទួលបានធនធានសហគមន៍ តំបន់នេសាទ តំបន់វាលស្មៅ ឥន្ធនៈ ឬ ចំណីសម្រាប់គោ ក្របីជាដើម)។

ត្រូវធ្វើការកត់សម្គាល់ឲ្យបានច្បាស់ថា ការអនុវត្តការតាំងទីលំនៅថ្មីនៅក្នុងក្របខ័ណ្ឌនៃគំរូអភិវឌ្ឍមួយ ត្រូវទាមទារឱ្យម្ចាស់គម្រោងអភិវឌ្ឍន៍ និង រដ្ឋាភិបាល គិតគូរពិចារណាដល់សហគមន៍ទូលំ-ទូលាយក្នុងរង្វង់សហគមន៍ដែលនឹងមានការតាំងទីលំនៅថ្មី។ ខណៈដែលមានការយកចិត្តទុកដាក់បែបនេះ ការតាំងទីលំនៅថ្មីនឹងដំណើរការបានកាន់តែទូលំទូលាយ មិនត្រឹមតែចំពោះម្ចាស់សហគមន៍ណាមួយឡើយ។ នេះមានន័យថាសហគមន៍ទូលំទូលាយ គួរតែទទួលបានផលប្រយោជន៍ពីការវិនិយោគ និងការអនុវត្តកិច្ចអភិវឌ្ឍន៍ដែលបានគ្រោងទុក។

៦.២.៣ ការទូទាត់សំណងជំនួសដោយការផ្តល់សំណងជាសាច់ប្រាក់

គោលនយោបាយនិងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង បានគូសបញ្ជាក់ពីតម្រូវការសម្រាប់ការទូទាត់សំណងមិនមែនជាសាច់ប្រាក់ ជាជាងការផ្តល់សំណងជាសាច់ប្រាក់ទៅដល់ប្រជាពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាទំនប់វារីអគ្គិសនី និង សំណង់អគារវារីអគ្គិសនីជាដើម។ តាមទ្រឹស្តី ការផ្តល់សំណងជាសាច់ប្រាក់ដោយការសងជំនួសលើការចំណាយអាចឲ្យអ្នកដែលត្រូវបំលាស់ទីអាចស្តារប្រាក់ចំណូលនិងស្តារកម្រិតជីវភាពរស់នៅរបស់ពួកគេបាន។ តាមការអនុវត្តជាក់ស្តែង នៅមានឧបសគ្គជាច្រើនបានធ្វើឲ្យអាក់ខានដល់ការផ្លាស់ប្តូរពីសាច់ប្រាក់ ទៅជាការសងជំនួសដោយទ្រព្យសម្បត្តិជំនួសវិញ (ឬជាវិធានការស្តារប្រាក់ចំណូលដែលជាជម្រើសជំនួស)។ តាមការជាក់ស្តែងបំផុត សំណងដែលត្រូវផ្តល់ឲ្យ មិនមានចំនួនគ្រប់គ្រាន់ទេ ។ ពេលវេលានៃការផ្តល់សំណងទៀតសោត (ជួនឆាប់រហ័សពេក ឬជួនយឺតយ៉ាវពេក) ក៏អាចកាត់បន្ថយលទ្ធភាពនៃការស្តារប្រាក់ចំណូលឡើងវិញផងដែរ។ សាច់ប្រាក់នឹងមិនអាចបម្លែងទៅជាទ្រព្យដែលហុចផលបានទេ ប្រសិនបើពុំសូវមានទីផ្សារ ឬពុំមានឱកាស។ លើសពីនេះទៀត តាមបទពិសោធន៍អនុវត្តនៅមូលដ្ឋាន វាក៏អាចជម្រុញឲ្យមានការប្រើ-ប្រាស់ប្រាក់សំណងនោះយកទៅចំណាយលើការសងប្រាក់បំណុល ឬ បដិភាពសង្គម ជាជាងការទិញសម្ភារៈជំនួស។

ស្រដៀងគ្នាទៅនឹងបែបទនៃស្ថានប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត គោលនយោបាយប្រតិបត្តិការរបស់ធនាគារពិភពលោក ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត បានលើកឡើងថា " គួរផ្តល់សិទ្ធិជាអាទិភាពចំពោះយុទ្ធសាស្ត្រនៃការតាំងលំនៅថ្មីពឹងផ្អែកលើដី សម្រាប់អ្នកដែលបំលាស់ទីទាំងឡាយណា ដែលជីវភាពរស់នៅរបស់ខ្លួនត្រូវពឹងផ្អែកលើដីជាមូលដ្ឋាន។ យុទ្ធសាស្ត្រទាំងនេះអាចរួមបញ្ចូលទាំងការតាំងលំនៅថ្មីនៅលើដីសាធារណៈ ឬ នៅលើដីឯកជនដែលបានទិញសម្រាប់តាំងលំនៅដ្ឋាន។ នៅពេលណាមានការផ្តល់សំណងជាដីជំនួសវិញ ត្រូវផ្តល់ដល់អ្នកតាំងលំនៅថ្មីនូវដីដែលរួមផ្សំទៅដោយ

អត្ថប្រយោជន៍ហូចផលដ៏សំខាន់ ជាទីតាំងដែលមានផលប្រយោជន៍ និងកត្តាផ្សេងៗទៀតដែលយ៉ាងហោចណាស់សមមូលទៅនឹងអត្ថប្រយោជន៍នៃដីដែលបានបាត់បង់ទៅនោះ ។ ការទូទាត់សំណងជាសាច់ប្រាក់ចំពោះការខូចខាតទ្រព្យសម្បត្តិ អាចជាប្រការសមស្រប នៅក្នុងកាល:ទេស:ជាក់ស្តែងមួយចំនួន តួយ៉ាងដូចជា ៖

- នៅកន្លែងណាដែលជីវភាពរស់នៅរបស់អ្នកផ្លាស់ទីពឹងផ្អែកលើដីធ្លី ប៉ុន្តែដីដែលគម្រោងបានដកហូតគឺជាដីដែលមានទំហំតូចទៅតាមទំហំទ្រព្យសម្បត្តិដែលខូចខាត ហើយទ្រព្យដែលនៅសេសសល់គឺជាទ្រព្យដែលអាចសម្រេចផលសដ្ឋកិច្ចបាន។
- នៅទីកន្លែងណាដែលមានការលក់ដូរអ៊ូអរ មានលំនៅដ្ឋានច្រើន និងមានការងារធ្វើច្រើន ជាទីកន្លែងដែលអ្នកផ្លាស់ទីពឹងផ្អែកលើការលក់ដូរ និង ជាទីកន្លែងដែលមានការផ្គត់ផ្គង់ដីធ្លី និងមានលំនៅដ្ឋានគ្រប់គ្រាន់។
- នៅកន្លែងណាដែលជីវភាពរស់នៅរបស់អ្នកផ្លាស់ទីមិនពឹងផ្អែកលើដីធ្លី។ ការផ្តល់សំណងជាសាច់ប្រាក់ គួរមានកម្រិតគ្រប់គ្រាន់ដើម្បីសងជំនួសលើការបាត់បង់ដីនិងការខូចខាតទ្រព្យសម្បត្តិដទៃទៀតក្នុងតម្លៃសងជំនួសពេញលេញស្របទៅតាមតម្លៃទីផ្សារក្នុងស្រុក”។

៦.២.៤ ការទូទាត់សំណងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយមិនមានការចេញកម្មសិទ្ធិដីធ្លីជាផ្លូវការ

គោលនយោបាយនិងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង បានបញ្ជាក់ពីសិទ្ធិទូទាត់សំណងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយមិនមានការចេញកម្មសិទ្ធិដីធ្លីជាផ្លូវការ ។ ដូចមានការទទួលស្គាល់ ក្នុងចំនុច OP 4.12 (គោលការណ៍ប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មី មិនមែនជា ការស្ម័គ្រចិត្ត (ផលប៉ះពាល់ដែលធ្វើឲ្យខូចខាតដោយសារការបំលាស់ទីលំនៅ អាចជះឥទ្ធិពលដល់បុគ្គល ឬ ក្រុម ដែលពឹងអាស្រ័យលើលទ្ធភាពទទួលបានន្ធវធនធានជាលក្ខណៈបើកចំហ ដែលសិទ្ធិមានជាប្រពៃណីរបស់ខ្លួន មិនត្រូវបានទទួលស្គាល់ ឬ ដែលការប្រើប្រាស់ធនធាន មានភាពខុសប្លែកគ្នាពីលំនាំ នៃការគ្រប់គ្រងដោយប្រើអំណាចគាបសង្កត់។

នៅក្នុងរបៀបស្រដៀងគ្នាទៅនឹងស្តាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត និងគំរូស្តង់ដាអនុវត្តទី៥ស្តីពីការផ្តល់សម្បទានដីធ្លី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានតម្រូវថា ត្រូវតែទូទាត់សំណងស្របច្បាប់ទៅដល់អ្នកដែលត្រូវបំលាស់ទី ពោលគឺ “i)អ្នកដែលមានកម្មសិទ្ធិស្របច្បាប់ជាផ្លូវការលើដីដែលពួកគេកាន់កាប់ ii) អ្នកដែលគ្មានកម្មសិទ្ធិដីស្របច្បាប់ជាផ្លូវការ ប៉ុន្តែមានការអះអាងបញ្ជាក់ពីការទទួលស្គាល់ ឬដែលអាចទទួលស្គាល់ជាផ្លូវការបាន យោងតាមច្បាប់របស់រដ្ឋ និង iii) អ្នកគ្មានសិទ្ធិដែលត្រូវបានទទួលស្គាល់ ឬ គ្មានការអះអាងបញ្ជាក់ចំពោះដីដែលពួកគេកាន់កាប់ ។ **អ្វីដែលសំខាន់ គឺការទូទាត់សំណងឬការផ្តល់ជំនួយ មិនត្រូវបានផ្តល់ឲ្យសម្រាប់អ្នកទាំងឡាយណា ដែលចូលទន្ទ្រានលើតំបន់គម្រោងនេះក្រោយពីកាលបរិច្ឆេទប្រកាសបិទការទូទាត់សំណង (ដែលជាធម្មតា វាស្របគ្នាទៅនឹងកាលបរិច្ឆេទដែលបានកំណត់សម្រាប់ធ្វើជំរឿននៃប្រជាពលរដ្ឋដែលរងផលប៉ះពាល់) ។**

អ្នកដែលត្រូវបំលាស់ទីជារូបវន្ត ដែលគ្មានសិទ្ធិត្រូវបានទទួលស្គាល់ ឬ គ្មានការអះអាងបញ្ជាក់ពីដីធ្លីដែលពួកគេកាន់កាប់ " ត្រូវតែផ្តល់ឲ្យពួកគេនូវជម្រើសមួយសម្រាប់ការសាងសង់លំនៅដ្ឋានគ្រប់គ្រាន់ រួមជាមួយនឹងសិទ្ធិកាន់កាប់ដីធ្លី ដើម្បីឲ្យពួកគេអាចតាំងទីលំនៅដោយស្របច្បាប់ដោយគ្មានការប្រឈមមុខនឹងហានិភ័យនៃការបណ្តេញចេញដោយបង្ខំ ។ ត្រូវផ្តល់ឱ្យពួកគេនូវជំនួយគ្រប់គ្រាន់ក្នុងការរុះរើលំនៅដ្ឋាន ដើម្បីស្តារជីវភាពរស់នៅរបស់ពួកគេនៅក្នុងទីតាំងសមស្របដែលជាជម្រើសជំនួស " ។ ជាលក្ខណៈសេដ្ឋកិច្ច អ្នកដែលត្រូវបំលាស់ទី " គួរតែទទួលបាននូវសំណងលើការខូចខាតទ្រព្យសម្បត្តិក្នុងតម្លៃដោះដូរពេញលេញ (ដូចជា ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងការកែច្នៃដីឲ្យមានលក្ខណៈល្អប្រសើរ) ក៏ដូចជាត្រូវផ្តល់ការគាំទ្រ និងការផ្តល់ជំនួយចំគោលដៅបន្ថែមទៀត (ឧទាហរណ៍ដូចជា ការផ្តល់មូលដ្ឋានឥណទាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ ឱកាសការងារជាដើម) ព្រមទាំងផ្តល់ឱកាសដើម្បីលើកកម្ពស់ ឬ យ៉ាងហោចណាស់ដើម្បីស្តារលទ្ធភាពក្នុងការរកប្រាក់ចំណូលរបស់ពួកគេ ស្តារកម្រិតផលិតកម្ម និងកត្តាជីវភាព " ។

៦.២.៤.១ ការលើកកម្ពស់វិធីសាស្ត្រនៃការចូលរួម

គោលនយោបាយ និង គោលការណ៍ណែនាំស្តីពីការទូទាត់សំណងផ្តោតជាសំខាន់លើតម្រូវការដើម្បីលើកកម្ពស់វិធីសាស្ត្រនៃការចូលរួម និង ដើម្បីអនុញ្ញាតឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់អាចចូលរួម ធ្វើផែនការ និងអនុវត្តផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDPs) (ផ្នែកទី៨)។

ក្នុងរបៀបស្រដៀងគ្នាទៅនឹងស្ថានប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត បានតម្រូវថា " ត្រូវផ្តល់ព័ត៌មានយ៉ាងទាន់ពេលវេល ដល់អ្នកដែលត្រូវបំលាស់ទី និងសហគមន៍របស់ពួកគេ ក៏ដូចជាសហគមន៍ជាម្ចាស់ទីតាំងដែលត្រូវទទួលអ្នកចំណូលថ្មី ត្រូវពិភាក្សាលើជម្រើសនៃការតាំងទីលំនៅថ្មី និង ត្រូវបានផ្តល់ឱកាសឱ្យចូលរួមធ្វើផែនការអនុវត្ត និងពិនិត្យតាមដានលើការតាំងទីលំនៅថ្មី ។ ត្រូវរៀបចំបង្កើតយន្តការនៃបណ្តឹងសារទុក្ខដែលមានលក្ខណៈសមស្រប និង ដែលអាចទទួលយកបានសម្រាប់ក្រុមទាំងនេះ " ។ គោលការណ៍ប្រតិបត្តិរបស់ធនាគារពិភពលោក (OP) 4.12 បានតម្រូវបន្ថែមទៀតថា " អ្នកដែលត្រូវបំលាស់ទី គឺ...ត្រូវបានពិភាក្សា ផ្តល់ជូននូវជម្រើសមួយក្នុងចំណោមជម្រើសនានា និងត្រូវបានផ្តល់ជម្រើសជំនួសស្តីពីការតាំងទីលំនៅថ្មីសមរម្យតាមលក្ខណៈបច្ចេកទេស និងសេដ្ឋកិច្ច " ។

បើយោងទៅតាមគោលការណ៍ប្រតិបត្តិរបស់ធនាគារពិភពលោក (OP) 4.12 ផែនការនៃការចូលរួមរបស់អ្នកតាំងទីលំនៅថ្មី និងម្ចាស់សហគមន៍ ត្រូវតែរួមបញ្ចូល៖

- ការពិពណ៌នាអំពីយុទ្ធសាស្ត្រសម្រាប់ការពិគ្រោះយោបល់ជាមួយ និងការចូលរួមរបស់អ្នកតាំងទីលំនៅថ្មី និងម្ចាស់សហគមន៍ ក្នុងការរៀបចំ និងការអនុវត្តសកម្មភាពនៃការតាំងទីលំនៅថ្មី។
- សេចក្តីសង្ខេបអំពីទស្សនៈដែលបានសម្តែងចេញ និង អំពីរបៀបដែលទស្សនៈទាំងនោះត្រូវបានយកទៅគិតពិចារណានៅពេលរៀបចំផែនការតាំងទីលំនៅថ្មី។

- ការពិនិត្យឡើងវិញលើជម្រើសជំនួសស្តីពីការតាំងទីលំនៅថ្មីដែលបានបង្ហាញ និងជម្រើសដែលបានធ្វើឡើងដោយអ្នកដែលត្រូវបំលាស់ទីលំនៅ ទាក់ទងនឹងជម្រើសដែលមានស្រាប់សម្រាប់ពួកគេ រួមបញ្ចូលទាំងជម្រើសនានាទាក់ទងទៅនឹងទម្រង់នៃការទូទាត់សំណង និងការផ្តល់ជំនួយអភិវឌ្ឍ លើការបំលាស់ទីជាលក្ខណៈរូបវន្តបុគ្គល គ្រួសារ ឬជាផ្នែកមួយនៃសហគមន៍ដែលមានពីមុន ឬ ក្រុមសាច់ញាតិ ដើម្បីគាំទ្រលំនាំនៃការរៀបចំក្រុមដែលមានស្រាប់ និង ដើម្បីរក្សានូវលទ្ធភាពទទួលបានទ្រព្យសម្បត្តិវប្បធម៌ (ឧទាហរណ៍ កន្លែងសក្ការៈបូជា មជ្ឈមណ្ឌលមធ្យាត្រា ទីបញ្ចុះសព)។
- ការរៀបចំជាលក្ខណៈស្ថាប័ន ដែលជាមធ្យោបាយអាចឲ្យប្រជាពលរដ្ឋដែលបំលាស់ទីបានផ្តល់ព័ត៌មានអំពីការព្រួយបារម្ភរបស់ពួកគេ ទៅកាន់អាជ្ញាធរគម្រោងជុំវិញការរៀបចំផែនការ និងការអនុវត្ត ព្រមទាំងវិធានការនានាដើម្បីធានាថា ក្រុមដែលងាយរងគ្រោះ ដូចជា ជនជាតិដើម ជនជាតិភាគតិច អ្នកគ្មានដីធ្លី និងស្ត្រីត្រូវបានចាត់ទុកជាតំណាងដោយស្មើភាពគ្នា។

៦.២.៤.២ ការផ្តល់អាទិភាពខ្ពស់ចំពោះក្រុមជនងាយរងគ្រោះ (យោង១៧)

គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង ផ្តោតជាសំខាន់លើតម្រូវការនៃការផ្តល់អាទិភាពដល់ក្រុមជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ។ បើយោងតាមរបាយការណ៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី បានឲ្យដឹងថា " ការចាត់ថ្នាក់ជាគោលការណ៍ ត្រូវបានបំបែកចេញពីការវាយតម្លៃ (លើប្រជាពលរដ្ឋដែលផ្លាស់ទីលំនៅដោយសារទំនប់វារីអគ្គិសនី) រួមទាំងអ្នកដែលគ្មានដីធ្លី (ឧទាហរណ៍ អ្នកដែលគ្មានដីធ្លីគ្មានកម្មសិទ្ធិ ឬ សិទ្ធិស្របច្បាប់) សហគមន៍រស់នៅផ្នែកខាងក្រោម និងជនជាតិដើមភាគតិច។ របាយការណ៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី ក៏បានឲ្យបង្ហាញឲ្យឃើញផងដែរពីករណីដែលប្រជាជនក្រីក្រ ស្ត្រី និងតំណាងរបស់ជនជាតិភាគតិច ឬសហគមន៍ជនជាតិដើម ត្រូវទទួលរងផលលំបាក ដែលកើតចេញពីការចែករំលែកមិនស្មើភាពគ្នានៃហេតុប៉ះពាល់សង្គមដោយសារទំនប់វារីអគ្គិសនីធំៗក្នុងពេលកន្លងទៅ ៖ "ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរដល់ជនក្រីក្រមួយភាគធំ និងជនងាយរងគ្រោះ ជាងក្រុមប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពគ្រាន់បើជាង។ តារាយៈបទពិសោធន៍គម្រោងធនាគារពិភពលោកបានបង្ហាញថា អ្នកក្រីក្រ ស្ត្រី កុមារ ជនពិការ មនុស្សចាស់ និងក្រុមជនជាតិដើម គឺជាញឹកញាប់ងាយនឹងទទួលរងការលំបាក និង អាចមានលទ្ធភាពតិចតួចជាងក្រុមរងគ្រោះផ្សេងទៀតក្នុងការកសាងជីវភាពរស់នៅរបស់ខ្លួនឡើងវិញ បន្ទាប់ពីការតាំងទីលំនៅថ្មី ។ ទោះជាយ៉ាងណាវិសាលភាព ចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរនៃភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋទាំងនោះអាចមានការប្រែប្រួលយ៉ាងខ្លាំង។ ដូច្នេះ គោលការណ៍អនុវត្តល្អ ទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងពេលត្រួតពិនិត្យលើការរៀបចំគម្រោង និងការតាំងលំនៅថ្មីដោយយកចិត្តទុកដាក់ ដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវជីវភាពរបស់ក្រុមជនងាយរងគ្រោះ ឬ យ៉ាងហោចណាស់អាចកែលម្អឡើងវិញនូវជីវភាព និងការចិញ្ចឹមជីវិតរបស់ពួកគេ " ។

ក្នុងរបៀបស្រដៀងគ្នាទៅនឹងស្ថានប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត បានកំណត់ថា: " ដើម្បីសម្រេចបាននូវគោលបំណងនៃគោលនយោបាយនេះ ទាមទារឲ្យមានការយកចិត្តទុកដាក់ជាសំខាន់ ចំពោះតម្រូវការនានារបស់ក្រុមជនងាយរងគ្រោះក្នុងចំណោមអ្នកដែលផ្លាស់ទីលំនៅ ជាពិសេសអ្នកដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ អ្នកដែលគ្មានដីធ្លី មនុស្សចាស់ ស្ត្រី កុមារ ជនជាតិដើម ជនជាតិភាគតិច ឬអ្នកដែលត្រូវផ្លាស់ទីដទៃទៀតដែលប្រហែលជាមិនត្រូវបានការពារ តាមរយៈច្បាប់ស្តីពីការផ្តល់សំណងដីរបស់រដ្ឋ " ។

បើយោងទៅតាមរបាយការណ៍គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី បានបង្ហាញឲ្យឃើញថា " ការស្រាវជ្រាវយ៉ាងទូលំទូលាយបានចងក្រងទុកជាឯកសារអំពីវិសមភាពយេនឌ័រ [យោង១៨] នៅក្នុងការទទួលបាន និងការគ្រប់គ្រងលើធនធានសេដ្ឋកិច្ច និង ធនធានធម្មជាតិ ។ ឧទាហរណ៍ នៅក្នុងតំបន់អាស៊ី និងអាហ្វ្រិក ស្ត្រីអាចមានសិទ្ធិលើការប្រើប្រាស់ដីធ្លី និងព្រៃឈើ ប៉ុន្តែកម្រនឹងអនុញ្ញាតិឲ្យធ្វើជាម្ចាស់កម្មសិទ្ធិ និង/ឬស្នងមតិកលើដីដែលពួកគេកំពុងប្រើប្រាស់...។ នៅទីកន្លែងណាដែលមានការផ្តល់សេវាសង្គមកិច្ច ដែលជាផ្នែកមួយនៃកម្មវិធីតាំងទីលំនៅថ្មី នោះសេវាសង្គមកិច្ចទាំងនោះអាចតំណាងឱ្យការធ្វើឱ្យប្រសើរឡើងសម្រាប់ស្ត្រី បើប្រៀបធៀបទៅនឹងស្ថានភាពមុនការតាំងទីលំនៅថ្មីរបស់ពួកគេ...។ ទំនប់វារីអគ្គិសនីធំៗ និងប្រព័ន្ធធារាសាស្ត្រពាក់ព័ន្ធ អាចជាតំណាងឱ្យឱកាសតែមួយគត់សម្រាប់កំណែទម្រង់នៅក្នុងតំបន់ ដូចជាកំណែទម្រង់លើការកាន់កាប់ដីធ្លីជាដើម " ។ តាមរយៈការអនុញ្ញាតឱ្យនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីដើម្បីឱ្យក្លាយទៅជាម្ចាស់ដីធ្លី កំណែទម្រង់បែបនេះ អាចឈានទៅរកការធ្វើឱ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ស្ត្រីក្នុងរយៈពេលវែង។

[យោង១៧] ការបន្ថែមដោយលក្ខណៈប្រៀបធៀបថ្មីៗនេះ ទៅលើក្រុមជនងាយរងគ្រោះ មានដូចជាក្រុមគ្រួសារដែលមានកុមារជាមេគ្រួសារ ឬ ដែលមានមនុស្សចាស់ជាមេគ្រួសារដែលត្រូវទទួលបន្ទុកថែរទាំកុមារវ័យជំទង់។ បញ្ហានេះ តាមធម្មតា គឺជាផលវិបាកនៃជម្លោះ ឬ នៅក្នុងករណីជាច្រើនដែលឪពុកម្តាយមានផ្ទុកមេរោគអេដស៍/មានជំងឺអេដស៍។ ប្រភេទនៃគ្រួសារទាំងនេះ បានក្លាយជាចំនួនប្រភ៉ាឡង់ដ៍ច្រើននៅក្នុងតំបន់Sub-Sahara ក្នុងទ្វីបអាហ្វ្រិក ។

[យោង១៨] បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដ៏ទូលំទូលាយ និងល្អិតល្អន់ក្តី ប៉ុន្តែផ្ទុយទៅវិញ នៅតែកើតមានវិសមភាព និងអ-តុល្យភាពនៃយេនឌ័រនៅក្នុងបណ្តាប្រទេសជាច្រើនលើពិភពលោក ។ សម្រាប់គម្រោងដាច់ដោយឡែកណាមួយ ត្រូវទាមទារឲ្យមានការកំណត់ឲ្យបានច្បាស់ពីវិសម-ភាព និងអតុល្យភាពទាំងនេះ ហើយត្រូវដោះស្រាយក្នុងក្របខ័ណ្ឌនៃកម្មវិធីណាមួយ ឬផែនការដែលបានរៀបរៀងឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងដើម្បីប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវឱកាសដែលលេចចេញពីគម្រោងដែលបានស្នើឡើង ។ នេះគឺមិនមែនចេះតែងាយស្រួលដូចប្រភេទនៃការអន្តរាគមន៍ទាំងនេះទេ តែអាចប៉ះទង្គិចជាមួយការអនុវត្តតាមបែបប្រពៃណី និងតាមទម្លាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ការយល់ដឹងពីយេនឌ័រ ពិតជាមានសារៈសំខាន់ណាស់ ប្រៀបបាននឹងទង្វើនៃការប្រកាន់ខ្ជាប់លើរបៀបនៃការគិតរបស់ប្រជាពលរដ្ឋចំពោះបញ្ហាយេនឌ័រនេះ។ ការយល់ដឹងនេះ ផ្តោតជាសំខាន់ទៅលើការធានាថា ការសន្មត់ដែលមានឫសគល់ក្នុងជំនឿបែបប្រពៃណី ឬជំនឿលើប្រវត្តិសាស្ត្រអំពីតួនាទីរបស់ស្ត្រី និងបុរសមិនមានអធិកភាពឡើយ។ ការរៀបចំផែនការស្តីពីការយល់ដឹងពីយេនឌ័រ ត្រូវប្រើវិធីសាស្ត្រនិងឧបករណ៍ដើម្បីផ្តល់ឱកាសបន្ថែមទៀតដល់ស្ត្រីក្នុងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ និងដើម្បីវាស់ស្ទង់ពីផលប៉ះពាល់នៃសកម្មភាពដែលបានកំណត់ក្នុងផែនការស្តីពីស្ត្រី និងបុរស។

៦.២.៤.៣ ការធានាឲ្យមានភាពស្របគ្នាតាមកិច្ចព្រមព្រៀងនានា

គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង ផ្តោតជាសំខាន់អំពីតម្រូវការសម្រាប់ធានាឲ្យមានភាពស្របគ្នា [ឃោង១៩] តាមកិច្ចព្រមព្រៀងនិងការប្តេជ្ញាចិត្តដែលមានរួមបញ្ចូលនៅក្នុងការផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAPs) និង ផែនការអភិវឌ្ឍន៍ជនជាតិដើម (IPDPs) ។ ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មីផ្តល់ជាបទដ្ឋានសម្រាប់ការប្រព្រឹត្តិស្របតាមច្បាប់ រួមជាមួយនឹងតួនាទីនិងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនានាដែលបានព្រមព្រៀងគ្នា ជាពិសេសរបស់អង្គភាពអនុវត្តការតាំងទីលំនៅថ្មី។ ផែនការនេះត្រូវតែរៀបចំឲ្យបានរួចរាល់ជាមុន និងមានភាពងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់។ ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី ត្រូវបានពិពណ៌នា ដូចខាងក្រោម៖

- ព័ត៌មានលម្អិតនៃផលប៉ះពាល់នៃការផ្តល់សម្បទានដី និងការតាំងទីលំនៅថ្មី។ បទប្បញ្ញត្តិសម្រាប់ការទូទាត់សំណង។ ការរៀបចំការបំលាស់ទីលំនៅជាលក្ខណៈរូបវន្ត និងការស្តារនីតិសម្បទាផ្នែកសេដ្ឋកិច្ច។
- ការរៀបចំជាលក្ខណៈស្ថាប័នសម្រាប់ការផ្តល់លទ្ធភាពទទួលបាននិងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ដទៃទៀត។
- កាលវិភាគនៃការអនុវត្តនិងការភ្ជាប់ទំនាក់ទំនងជាមួយការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។
- ការបើកឱកាសឲ្យអ្នកត្រូវផ្លាស់ទីបានចូលរួមបន្តនៅក្នុងដំណើរការនៃតាំងទីលំនៅថ្មី។
- ការចំណាយនិងគ្រោងថវិកា និងការផ្តល់មូលនិធិ។
- សូចនាករលើការអនុវត្តការតាំងទីលំនៅថ្មី ។ ការរៀបចំឲ្យមានការត្រួតពិនិត្យតាមដានផ្ទៃក្នុង និងខាងក្រៅ។
- យន្តការសម្រាប់ដោះស្រាយលើបណ្តឹងសារទុក្ខ។

[ឃោង១៩] ការប្រព្រឹត្តិស្របតាមច្បាប់ គឺជាទិដ្ឋភាពដ៏សំខាន់បំផុតរបស់គម្រោងទាំងអស់ ហើយគឺជាប្រធានបទនៃសៀវភៅបណ្តុះ-បណ្តាលដាច់ដោយឡែកមួយដែលត្រូវបានផលិតឡើងជាផ្នែកមួយនៃMRC-កម្មវិធីកិច្ចសហប្រតិបត្តិអង្គការ GIZ បណ្តាញសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយចីរភាពនៅក្នុងបណ្តាប្រទេសទន្លេមេគង្គ។

ក្នុងរបៀបស្រដៀងគ្នាទៅនឹងស្ថានប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត បានកំណត់ថា ៖ " ត្រូវកំណត់កាតព្វកិច្ចរបស់អ្នកខ្ចីស្របតាមកិច្ចព្រមព្រៀងជាផ្លូវច្បាប់សម្រាប់គម្រោង ដើម្បីអនុវត្តឧបករណ៍តាំងទីលំនៅថ្មី និងដើម្បីផ្តល់ព័ត៌មានដល់ធនាគារអំពីវឌ្ឍនភាពនៃការអនុវត្ត.... យន្តការលើកកម្ពស់ការប្រព្រឹត្តស្របតាមច្បាប់ រួមជាមួយនឹងកិច្ចព្រមព្រៀងនៃការតាំងទីលំនៅថ្មី និង ការប្រើប្រាស់ក្រុមអ្នកជំនាញការឯករាជ្យ ត្រូវបានគ្របដណ្តប់នៅក្នុងគោលនយោបាយតាំងទីលំនៅថ្មីរបស់ធនាគារ និង ត្រូវបានសម្រេចចិត្តយ៉ាងទៀងទាត់នៅក្នុងគម្រោងទំនប់វារីអគ្គិសីដែលគាំទ្រដោយធនាគារ ។ ទោះជាយ៉ាងណារដ្ឋាភិបាល គឺជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះការអនុវត្ត ការសម្របសម្រួល និងការត្រួតពិនិត្យលើកម្មវិធីតាំងទីលំនៅថ្មី។ គោលការណ៍អនុវត្តល្អក៏បានស្នើឡើងផងដែរអំពីការប្រើប្រាស់មូលនិធិទទួលខុសត្រូវ (trust funds) ដើម្បីផ្តល់ហិរញ្ញប្បទានដល់កាតព្វកិច្ចដែលកំពុងអនុវត្តសម្រាប់កិច្ចត្រួតពិនិត្យតាមដាននិងសវនកម្ម ក៏ដូចជាសកម្មភាពដែលត្រូវបន្តរហូតចប់គម្រោង។ ការបង់តម្លៃសិទ្ធិពីទំនប់វារីអគ្គិសនីផ្ទាល់អាចផ្តល់ជាមូលនិធិដល់គម្រោងផ្លូចផ្តើមគំនិតជាបន្តទៀត។ ប្រសិនបើទំនប់ត្រូវបានសាងសង់ដោយអ្នកអភិវឌ្ឍន៍វិស័យឯកជន អ្នកអភិវឌ្ឍន៍និងរដ្ឋាភិបាលត្រូវឈានទៅដល់កិច្ចព្រមព្រៀងលើការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍន៍នោះ សម្រាប់ការអនុវត្តការតាំងទីលំនៅថ្មីប្រកបដោយការពេញចិត្ត និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលទាក់ទងនឹងការផ្តល់ការគាំទ្រ ដើម្បីផ្តល់សម្បទានដីធ្លី និង ដើម្បីផ្តល់បុគ្គលិកសម្រាប់សាលានិងសំណង់អគារផ្សេងទៀតដែលបានធ្វើកិច្ចសន្យាក្រោមក្របខ័ណ្ឌនៃកម្មវិធីតាំងទីលំនៅថ្មី។

គោលការណ៍អនុវត្តល្អ ដែលប្រែប្រួលជាបន្តបន្ទាប់ បានស្នើឡើងថាកិច្ចព្រមព្រៀងរវាងអ្នកអភិវឌ្ឍន៍និងរដ្ឋាភិបាល គួររួមបញ្ចូលទាំងអនុឥណទេយ្យប័ណ្ណ ដែលគាំទ្រដោយការធានាផ្នែកហិរញ្ញវត្ថុ ដើម្បីធ្វើឲ្យដំណើរការប្រសិនបើអ្នកអភិវឌ្ឍន៍មិនបានបំពេញលើការទទួលខុសត្រូវរបស់ខ្លួនគ្រប់ជ្រុងជ្រោយក្នុងការតាំងទីលំនៅថ្មីទេនោះ។

ការតាំងទីលំនៅថ្មីមិនមែនជាការស្មុគ្រចិត្តមានបង្ហាញយ៉ាងលម្អិតនៅក្នុងផ្នែកទី៥ ។

ប្រអប់អត្ថបទ ៦.២ គោលការណ៍នៃគោលនយោបាយស្តីពីការទូទាត់សំណង - ទិដ្ឋភាពគន្លឹះ

គោលនយោបាយទូទាត់សំណងសម្រាប់ទំនប់ និងគម្រោងវារីអគ្គិសនីនៅក្នុងប្រទេសកំពុងអភិវឌ្ឍគួរតែធានាបាននូវការធ្វើឱ្យប្រសើរឡើងជាបន្ទាន់ និងជាវិធានការចំពោះជីវិតភាពរស់នៅរបស់ប្រជាពលរដ្ឋនិងសហគមន៍ដែលទទួលរងផលប៉ះពាល់ តាមរយៈ ៖

- ការធានាឲ្យបាននូវជីវភាពរស់នៅប្រកបដោយលក្ខណៈល្អប្រសើររបស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់។
- ការអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍។
- ការទូទាត់សំណងជារូបភាពផ្សេងជំនួសដោយការផ្តល់សំណងជាសាច់ប្រាក់។
- ការផ្តល់សំណងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ដែលពុំមានកម្មសិទ្ធិដីធ្លីជាផ្លូវការ។
- ការពង្រឹងវិធីសាស្ត្រនៃការចូលរួម។
- ការធានាឲ្យបាននូវការប្រព្រឹត្តិស្របតាមច្បាប់ដោយមានកិច្ចព្រមព្រៀង។

ប្រធានបទពិភាក្សា	គោលនយោបាយនិងគោលការណ៍ណែនាំស្តីពីការទូទាត់សំណង បញ្ហាក់ពីតម្រូវការសម្រាប់ការផ្តល់សំណងជារូបភាពផ្សេង ជាជាងការផ្តល់សំណងជាសាច់ប្រាក់ចំពោះប្រជាពលរដ្ឋរងផលប៉ះពាល់មិនល្អដោយសារទំនប់ ។ ចូរពិភាក្សាអំពីឧបសគ្គ ដែលអាចកើតមាន ហើយដែលកំណត់ព្រំដែននៃសារៈប្រយោជន៍នៃការផ្តល់សំណងជាសាច់ប្រាក់នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យសម្រេចបាននូវការបម្លែងសាច់ប្រាក់ទៅជាការជំនួសដោយទ្រព្យសម្បត្តិ ឬ ជម្រើសជំនួសដោយការស្តារប្រាក់ចំណូល។ …… ចូរពិភាក្សាអំពីសមត្ថភាពស្ថាប័ននៅក្នុងប្រទេសរបស់អ្នក និង វិធានការនានាដែលត្រូវការជាចាំបាច់ ហើយដែលសមត្ថភាព និងវិធានការទាំងនោះអាចឬគួរតែមានជាក់ស្តែង ដើម្បីគ្រប់គ្រងឲ្យមានប្រសិទ្ធភាពលើការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ។
លំហាត់	តាមរយៈការប្រើប្រាស់ករណីសិក្សាដែលបានជ្រើសរើស ចូរបង្ហាញថាតើការអនុវត្តតាមគោលការណ៍នៃការបង្កើតជាមូលដ្ឋានទ្រទ្រង់គោលនយោបាយផ្តល់សំណង មាន ឬ គ្មានប្រសិទ្ធិភាពដោយរបៀបណា។ …… ចូរកំណត់ឲ្យបានច្បាស់ពីស្ថានភាព ដែលអាចកើតឡើងពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលមានទំហំធំដែលការផ្តល់សំណងជាសាច់ប្រាក់ពិតជាល្អត្រឹមត្រូវ និង សមតែទទួលបានការគិតគូរពិចារណាក្នុងក្របខ័ណ្ឌនៃកញ្ចប់រួមនៃការផ្តល់សំណងដែលប្រើបានចំពោះគម្រោងមួយ។

៦.៣ ប្រភេទនៃយន្តការទូទាត់សំណង

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញដល់សិក្ខាកាមអំពីលក្ខណៈទូទៅនៃប្រភេទយន្តការផ្តល់សំណងដែលមានស្រាប់ និង កំពុងត្រូវបានអនុវត្ត។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់ពីលក្ខណៈនៃយន្តការផ្តល់សំណង។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិ-សនីនិងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំនប់វារីអគ្គិសនី និង ជម្រើសជំនួស ។ ផ្នែកទី៥ ៖ គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់លើយន្តការនៃការបែងចែកផលប្រយោជន៍) ។ www.unep.org/dams

យន្តការផ្តល់សំណងដែលអាចអនុវត្តបាន ចំពោះទំនប់ និងគម្រោងវារីអគ្គិសនីនានា អាចត្រូវបានកំណត់អត្តន័យថា ជាយន្តការដែលមានគោលបំណងដើម្បី ៖

- ទូទាត់សំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់លទ្ធភាពទទួលបាននូវធនធានផ្សេងៗរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ។
- ស្តារនិងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ឬ ដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនី ដែលជាប្រជាពលរដ្ឋរស់ជុំវិញតំបន់ទំនប់ (តាមរយៈការស្តារឡើងវិញនិងផែនការលើកកម្ពស់ជីវភាពរស់នៅ ផែនការអភិវឌ្ឍសហគមន៍ ផែនការអភិវឌ្ឍតំបន់ទីជម្រាល និង/ឬផែនការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ)។

យន្តការផ្តល់សំណង រួមមាន ៖

- ការទូទាត់សំណងដោយរបៀបផ្សេង ឬជាសាច់ប្រាក់ចំពោះការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់លទ្ធភាពទទួលបាននូវធនធានផ្សេងៗ។
- យន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ និងជារូបិយវត្ថុ។

យន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ ជាទូទៅបានផ្តល់ជាបទដ្ឋានជានិយាម ដែលទាក់ទងទៅនឹងការផ្តល់សំណង ។ ឧទាហរណ៍ យន្តការខាងក្រោមនេះត្រូវបានកំណត់នៅក្នុងគោលការណ៍ណែនាំទី២០នៃរបាយការណ៍របស់ WCD (ឆ្នាំ២០០០) ដែលរួមមាន ៖

- យន្តការទាំងឡាយណាដែលទាក់ទងនឹងផលប្រយោជន៍របស់គម្រោង (ការទទួលបានផ្ទៃដីស្រោចស្រព ឬ ទឹកសម្រាប់ស្រោចស្រព ការទទួលបានថាមពល ឬ ការផ្គត់ផ្គង់ទឹកជាដើម)។
- យន្តការទាំងឡាយណាដែលទាក់ទងនឹងការសាងសង់ និង ប្រតិបត្តិការរបស់គម្រោង (ឱកាសការងារ ឬការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការបណ្តុះបណ្តាល ជាដើម)។
- យន្តការទាំងឡាយណាដែលទាក់ទងនឹងធនធានធម្មជាតិ (ភាពងាយទទួលបាននូវធនធានផ្សេងៗ ឬភាពជាម្ចាស់លើការថែរក្សាការពារធនធានផ្សេងៗ និងធនធានតំបន់ទីជម្រាល ជាដើម)។
- យន្តការទាំងឡាយណាដែលទាក់ទងនឹងសេវាសហគមន៍ (លទ្ធភាពទទួលបានដោយលក្ខណៈល្អប្រសើរនូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មសហគមន៍ ការទ្រទ្រង់ប្រាក់ចំណូល ជាដើម)។
- យន្តការទាំងឡាយណាដែលទាក់ទងនឹងគ្រួសារ (ការកែលម្អលំនៅដ្ឋាន ការផ្តល់ឥណទានខ្នាតតូច ជាដើម)។

លើសពីនេះ យន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុផ្សេងៗជាច្រើនទៀត ត្រូវបានបង្កើតឡើងនិងអនុវត្តដោយជោគជ័យចំពោះគម្រោងទំនប់វារីអគ្គិសនីនានា ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍។

ប្រភេទនៃយន្តការទូទាត់សំណងដូចខាងក្រោម ត្រូវបានអនុវត្តចំពោះការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ៖

- **ការផ្តល់សំណងជារូបភាពផ្សេង ឬ ជាសាច់ប្រាក់សម្រាប់ការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់លទ្ធភាពទទួលបាននូវធនធានផ្សេងៗ។**
- ការទូទាត់សំណងប្រភេទនេះ ត្រូវបានគ្របដណ្តប់ក្រោមច្បាប់អស្សាមិករណ៍ជាតិ និងត្រូវបានឆ្លើយតបជាពិសេសនៅក្នុងក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋាននានារបស់ក្រុមធនាគារពិភពលោកដែរ ។ គោលការណ៍ណែនាំជាលក្ខណៈអន្តរជាតិ ជាធម្មតាតម្រូវឱ្យមានការទូទាត់សំណងស្របតាមតម្លៃទីផ្សារចំពោះរាល់ទ្រព្យសម្បត្តិដែលខូចខាត ឬ បាត់បង់លទ្ធភាពទទួលបាននូវធនធានផ្សេងៗ ហើយដែលអ្នកប្រើប្រាស់ដីធ្លីទាំងអស់មានសិទ្ធិទទួលបានសំណងដោយមិនគិតពីស្ថានភាពនៃការកាន់កាប់ដីធ្លីរបស់អ្នកទាំងនោះ ។ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ការទូទាត់សំណងនិយមធ្វើឡើងដោយ'ការសងក្នុងរូបភាពផ្សេង ″ តាមរយៈយុទ្ធសាស្ត្រ

នៃ " ការផ្តល់សំណងដីធ្លីដោយការផ្តល់ដីធ្លីជំនួសវិញ " ជាជាងយុទ្ធសាស្ត្រនៃការផ្តល់សំណងជារូបិយវត្ថុ។

- **ការស្តារ និងលើកកម្ពស់ជីវភាពរស់នៅឡើងវិញ។**
- ការទូទាត់សំណងប្រភេទនេះ កម្រត្រូវបានអនុវត្តក្រោមច្បាប់អស្សាមិករណ៍ជាតិណាស់ ប៉ុន្តែត្រូវបានឆ្លើយតបជាពិសេសនៅក្នុងក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋាននានារបស់ក្រុមធនាគារពិភពលោកដែរ ។ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ការកំណត់ឲ្យមានការស្តារជីវភាពរស់ឡើងវិញ និងយុទ្ធសាស្ត្រនៃការលើកកម្ពស់ជីវភាពរស់នៅ រួមមាន ៖
  - ការលើកកម្ពស់ការប្រកបរបរកសិកម្មប្រកបដោយនិរន្តភាព ដែលពឹងផ្អែកលើជម្រើសដីសម្រាប់ដី ការរៀបចំប្រព័ន្ធធារាសាស្ត្រ រួមទាំងលទ្ធភាពទទួលបានទឹកបូមពីអាងស្តុកទឹក ការរៀបចំលូបង្ហូរទឹក ការដាំដុះនៅក្នុងតំបន់ផ្ទៃកខាងក្រោម ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀតដែលបានមកពីលំហូរទឹក និង ទឹកជំនន់ក្រោមការគ្រប់គ្រង និង/ឬសេវាកសិកម្មប្រពលវប្បកម្ម រួមទាំងសម្ភារសម្រាប់ការដាំដុះ និងឧបករណ៍ផ្សេងៗទៀត ។
  - ការលើកកម្ពស់ការប្រកបមុខរបរមិនមែនកសិកម្មប្រកបដោយនិរន្តរភាព ដែលពឹងផ្អែកលើឱកាសការងារនៅក្នុងមូលដ្ឋានក្នុងអំឡុងពេលសាងសង់ និងពេលប្រតិបត្តិគម្រោង ការងារផ្នែកសេវាកម្មនិងឧស្សាហកម្ម ការរនេសាទតាមអាងស្តុកទឹក និង/ឬ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។
- **ការអភិវឌ្ឍសហគមន៍។**
- ការទូទាត់សំណងប្រភេទនេះ កម្រត្រូវបានអនុវត្តក្រោមច្បាប់អស្សាមិករណ៍ជាតិណាស់ ប៉ុន្តែត្រូវបានអនុវត្តជាទូទៅចំពោះការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនានា។ ការទូទាត់សំណងប្រភេទនេះ ត្រូវបានឆ្លើយតបជាពិសេសនៅក្នុងក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋាននៃក្រុមធនាគារពិភពលោកដែរ ។ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ គេនិយមប្រើប្រាស់យុទ្ធសាស្ត្រនៃការអភិវឌ្ឍសហគមន៍ រួមមាន៖ ការផ្តល់លំនៅដ្ឋានថ្មីដីដែលមានកម្មសិទ្ធិ លទ្ធភាពទទួលបានសេវាកម្មបឋម (ការផ្តល់ជាសាលារៀន ការផ្តល់សេវាថែទាំសុខភាពនិងសេវាសង្គមកិច្ច ដូចជាការគាំពារដល់ក្រុមគ្រួសារ និងការទ្រទ្រង់ប្រាក់ចំណូលជាដើម) លទ្ធភាពទទួលបានសេវាហិរញ្ញប្បទាន (ដូចជា ប្រាក់កម្ចីដោយមិនគិតការប្រាក់ ឬការផ្តល់ឥណទានខ្នាតតូច) ការផ្គត់ផ្គង់ទឹកស្អាតក្នុងមូលដ្ឋាន ផ្លូវថ្នល់និងការដឹកជញ្ជូនសាធារណៈ អគ្គិសនីយកម្មតាមតំបន់ជនបទ ទីផ្សារ និងកន្លែងជួបជុំជាសាធារណៈ និងជាលក្ខណៈសាសនា និងលទ្ធភាពទទួលបាននូវធនធានផ្សេងៗ (ព្រៃឈើ តំបន់វាលស្មៅ។ល។)។

- **ការអភិវឌ្ឍន៍តំបន់ទីជម្រាល។**

  នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការទូទាត់សំណងប្រភេទនេះ កម្រត្រូវបានអនុវត្តក្រោមច្បាប់អស្សាមិករណ៍ជាតិណាស់ ប៉ុន្តែត្រូវបានឆ្លើយតបជាពិសេសនៅក្នុងក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ ដូចជាបទដ្ឋាននានារបស់ក្រុមធនាគារពិភពលោកដែរ ។ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ គេនិយមប្រើប្រាស់យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍តំបន់ទីជម្រាល ដោយរួមមានភាពជាម្ចាស់លើការថែរក្សាការពារ ឬ ការគ្រប់គ្រងធនធាននៅតំបន់ទីជម្រាល ការដាំដើមឈើឡើងវិញ និងការដាំដុះរុក្ខជាតិហូបផ្លែ និងការលើកកម្ពស់បរិស្ថានសម្រាប់ធនធាន សត្វព្រៃ។

- **ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ។**

  ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ អាស្រ័យលើការសន្មត់ថាទំនប់ និងគម្រោងនានា ជាពិសេសគម្រោងវារីអគ្គិសនី អាចបង្កលក្ខណៈឲ្យមានការបែងចែកថ្លៃឈ្នួលសេដ្ឋកិច្ច ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ។ តម្លៃឈ្នួលសេដ្ឋកិច្ចនេះ គឺជាផលលើសដែលបានត្រឡប់ពីការលើសនៃផលធម្មតាលើដើមទុន ។ តម្លៃឈ្នួលនេះ កើតឡើងដោយសារតែក្រុមហ៊ុនបានធ្វើអាជីវកម្មលើធនធានធម្មជាតិ ដែលការអភិវឌ្ឍត្រូវពឹងអាស្រ័យលើ ស្របតាមលក្ខខ័ណ្ឌតំបន់ជលសាស្ត្រ ហានលេខាសាស្ត្រ និងភូគព្ភសាស្ត្រជាក់លាក់។ នៅក្នុងបណ្តាប្រទេសមួយចំនួន យន្តការការបែងចែកផលប្រយោជន៍ជារូបិយវត្ថុបានផ្តល់ជាមូលនិធិដល់ស្ថាប័នមូលដ្ឋាន និងនៅក្នុងតំបន់សម្រាប់គោលបំណងកសាងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ។ យន្តការបែបនេះបានផ្តល់ជាប្រភពមូលនិធិរយៈពេលវែង ដែលបង្កលក្ខណៈឲ្យស្ថាប័នថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ អាចកំណត់ពីអាទិភាពរបស់ខ្លួន និងអាចកាត់បន្ថយការពឹងអាស្រ័យរបស់ខ្លួនទៅលើអ្នកអភិវឌ្ឍន៍ និងរដ្ឋាភិបាល ក៏ដូចជាអាចជួយសម្រួលដល់ការគ្រប់គ្រងដែលអាចផ្លាស់ប្តូរបាន ។ ប្រអប់អត្ថបទ៦.៣ បានសង្ខេបពីយន្តការសំខាន់ៗដែលត្រូវយកមកពិចារណាក្នុងក្របខ័ណ្ឌជារួមនៃគោលនយោបាយស្តីពីការទូទាត់សំណងចំពោះការតាំងទីលំនៅថ្មីមិនមែនជាស្ម័គ្រចិត្ត។

គួរកត់សម្គាល់ថា ផែនការអភិវឌ្ឍតំបន់ទីជម្រាល ត្រូវបន្តអនុវត្តស្របទៅតាមគោលបំណងផ្នែកសង្គមកិច្ច និងបរិស្ថាន (ឧបមាដូចជា ការស្តារជម្រកនានា ដូចជាដីសើមដែលតំណាងឱ្យអត្ថប្រយោជន៍នៃវិស័យអេកូឡូស៊ី និង អត្ថប្រយោជន៍សម្រាប់ការបរបាញ់សត្វជាលក្ខណៈប្រពៃណី សម្រាប់អ្នកប្រកបរបរដាក់អន្ទាក់សត្វ និងអ្នកនេសាទ)។ តាមវិធានជាទូទៅ ជាមួយនឹងការលើកលែងដែលគួរឲ្យកត់សម្គាល់នៃផែនការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ការផ្តល់មូលនិធិសម្រាប់យន្តការទូទាត់សំណងសម្រាប់ទំនប់ សំណង់អគារវារីអគ្គិសនី ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការចំណាយរបស់គម្រោង ។ ចំពោះគម្រោងទំនប់ និងថាមពលវារីអគ្គិសនីដែលមានទំហំធំ ត្រូវបានណែនាំឲ្យមានគោលនយោបាយ ដើម្បីញែកឲ្យដាច់ រវាងការផ្តល់

មូលនិធិ និងការគ្រប់គ្រងលើយន្តការទូទាត់សំណង ចេញពីការចំណាយដើមទុនផ្សេងទៀតដើម្បីជៀសវាងការជ្រាបចេញដើមទុននោះពីចំណាត់ថ្នាក់មួយទៅចំណាត់ថ្នាក់មួយផ្សេងទៀត ក្នុងអំឡុងពេលអនុវត្តគម្រោង។

នៅក្នុងបណ្តាប្រទេសមួយចំនួន ការផ្តល់មូលនិធិលើយន្តការទូទាត់សំណង អាចត្រូវបានចែករំលែករវាងអ្នកអភិវឌ្ឍន៍ និងរដ្ឋាភិបាលនៃប្រទេសនោះ។ ឧបមាដូចជាការរួមបញ្ចូលការផ្តល់មូលនិធិដោយរដ្ឋចំពោះលទ្ធភាពទទួលបានផ្លូវឆ្ពោះទៅកាន់ទំនប់ ឬ មណ្ឌលសុខភាពនៅជុំវិញតំបន់ទំនប់នោះ (ដែលជាករណីអនុវត្តជាទូទៅនៅក្នុងប្រទេសឥណ្ឌា ឬ ប្រទេសស្រីលង្កា) ឬការផ្តល់មូលនិធិផ្សេងទៀតដល់សហគមន៍ពីសំណាក់អ្នកគាំទ្រគម្រោង ឬការផ្តល់មូលនិធិសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលជាការគាំទ្រដល់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ដែលជាករណីអនុវត្តជាទូទៅនៅក្នុងប្រទេសប្រេស៊ីលនិងប្រទេសកាណាដា)។ ស្របពេលដែលអ្នកគាំទ្រគម្រោង ឬរដ្ឋាភិបាលអាចនឹងស្វាគមន៍ចំពោះការចែករំលែកការចំណាយបែបនេះ ជាញឹកញាប់តែងតែកើតមានទំនាស់យុត្តាធិការដែលទាក់ទងទៅនឹងការថែទាំ ឬប្រតិបត្តិការរយៈពេលវែងនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលបានឧបត្ថម្ភមូលនិធិដោយរដ្ឋាភិបាល ឬអ្នកអភិវឌ្ឍន៍។

អត្ថបទប្រអប់៦.៣ យន្តការគោលការណ៍គន្លឹះនៃគោលការណ៍ទូទាត់សំណងសម្រាប់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត

ការផ្តល់សំណងជាប្រភេទផ្សេង ឬជារូបិយវត្ថុចំពោះការខូចខាតទ្រព្យសម្បត្តិ និងការបាត់បង់លទ្ធភាពទទួលបាននូវធនធានផ្សេងៗ

ការស្តារឡើងវិញ និងការលើកកម្ពស់ជីវភាពរស់នៅ
◇ការប្រកបរបរកសិកម្មប្រកបដោយចីរភាព
◇ការប្រកបរបរមិនមែនកសិកម្មប្រកបដោយចីរភាព

ការស្តារឡើងវិញ និងការលើកកម្ពស់ជីវភាពរស់នៅ
◇ការប្រកបរបរកសិកម្មប្រកបដោយចីរភាព
◇ការប្រកបរបរមិនមែនកសិកម្មប្រកបដោយចីរភាព

ការអភិវឌ្ឍសហគមន៍
◊ការសាងសង់លំនៅឋាន
◊លទ្ធភាពទទួលបានសេវាកម្មបឋម(សាលារៀន ការថែទាំសុខភាពជាដើម)
◊លទ្ធភាពទទួលបានសេវាហិរញ្ញប្បទាន
◊ការផ្គត់ផ្គង់ទឹកក្នុងមូលដ្ឋាន
◊ផ្លូវថ្នល់ និងការដឹកជញ្ជូនសាធារណៈ
◊អគ្គិសនីយកម្មតាមតំបន់ជនបទ
◊ទីផ្សារនិងទីកន្លែងជួបប្រជុំ
◊លទ្ធភាពទទួលបានធនធានរួម (ព្រៃឈើជាដើម)



ប្រអប់អត្ថបទ៦.៤ ប្រភេទនៃយន្តការទូទាត់សំណង - ទិដ្ឋភាពគន្លឹះ

- យន្តការផ្តល់សំណងដែលអាចអនុវត្តបានចំពោះទំនប់ និង គម្រោងវារីអគ្គិសនីនានា អាចត្រូវបានកំណត់
- អត្ថន័យថា ជាយន្តការដែលមានគោលបំណង ដើម្បីទូទាត់សំណងចំពោះការខូចខាតទ្រព្យសម្បត្តិ
- និងការបាត់បង់លទ្ធភាពទទួលបានន្ូវធនធានផ្សេងៗ របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ក៏ដូចជាដើម្បីស្តារ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ដែលជាប្រជាពលរដ្ឋរស់ជុំវិញតំបន់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានទំហំធំ។

យន្តការផ្តល់សំណង រួមមាន ៖

- ការទូទាត់សំណងជាសាច់ប្រាក់ចំពោះការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់លទ្ធភាពទទួលបានន្ូវធនធានផ្សេងៗ។
- ការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ (ការស្តារនិងលើកកម្ពស់ជីវភាពរស់នៅឡើងវិញ ការអភិវឌ្ឍសហគមន៍ ការអភិវឌ្ឍន៍តំបន់ទីជម្រាល)។
- ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ។

ប្រធានបទពិភាក្សា	ចូរពិភាក្សាអំពីយន្តការទូទាត់សំណងផ្សេង សម្រាប់ការស្តារនិងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅសម្រាប់សហគមន៍ដែលទទួលរងផលប៉ះពាល់ពីគម្រោង។ …… គោលនយោបាយផ្តល់សំណង ដែលត្រូវអនុវត្តចំពោះគម្រោងទំនប់វារីត្រូវបានអនុវត្តជាញឹកញាប់តាមរយៈយន្តការដែលមានគោលបំណងដើម្បី ៖ • ទូទាត់សំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និង ការបាត់បង់លទ្ធភាពទទួល បាននូវធនធានផ្សេងៗរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង ។ • ការស្តារនិងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយ-សារគម្រោង។ • ចូរពិភាក្សាអំពីប្រភេទផ្សេងៗ នៃយន្តការសម្រាប់ការដោះស្រាយបញ្ហាទាក់ទងនឹងការផ្តល់សំណងចំពោះការខូចខាតទ្រព្យសម្បត្តិ និងការស្តារនិងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង។
លំហាត់	តាមរយៈការប្រើប្រាស់ករណីសិក្សាក្នុងប្រទេសរបស់អ្នក ចូរធ្វើការវាយតម្លៃពីរបៀបដែលប្រភេទផ្សេងៗនៃយន្តការផ្តល់សំណងត្រូវបានអនុវត្តដោយជោគជ័យ ឬមិនជោគជ័យ។ …… តាមរយៈការប្រើប្រាស់ករណីសិក្សាក្នុងប្រទេសរបស់អ្នក ចូរធ្វើការវាយតម្លៃពីលទ្ធផលនៃប្រភេទយន្តការផ្តល់សំណងផ្សេងៗដែលត្រូវបានអនុវត្ត។

៦.៤ យន្តការនៃការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ

គោលបំណង	គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីលក្ខណៈ និង ទម្រង់នៃយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់ដឹងអំពីលក្ខណៈ និងទម្រង់នៃយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិ-សនីនិងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំនប់វារីអគ្គិសនី និង ជម្រើសជំនួស។ ផ្នែកទី៥ ៖ គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់លើយន្តការបែងចែកផលប្រយោជន៍) ។ www.unep.org/dams

ការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ សំដៅដល់លទ្ធភាពទទួលបានធនធានផ្សេងៗជាច្រើនដែលជាឯកសិទ្ធិត្រូវផ្តល់ឲ្យសហគមន៍មូលដ្ឋាន ដើម្បីធ្វើយ៉ាងណាឲ្យពួកគេអាចលើកកម្ពស់ជីវភាព ដែលពឹងផ្អែកលើធនធាន និងសុខមាលភាពសង្គមតាមរយៈចំណាត់ការថ្នាក់មូលដ្ឋាន។ គោលបំណងមួយ គឺដើម្បីទប់ស្កាត់ ឬ សងជំនួសវិញ នូវការបាត់បង់លទ្ធភាពទទួលបានធនធានទាំងឡាយដោយសារគម្រោងថាមពលវារីអគ្គិសនី។ ជារឿយៗ ការបែងចែងផលប្រយោជន៍តម្រូវឱ្យមានសំណុំបែបបទផ្លូវច្បាប់ដែលចេញដោយរដ្ឋាភិ-បាល ឬលិខិតអនុញ្ញាតជាក់លាក់ដែលចេញដោយថ្នាក់មូលដ្ឋាន ថ្នាក់ខេត្តឬក្រុង។

- វិធានការមិនមែនជារូបិយវត្ថុ រួមមានលទ្ធភាពក្នុងការទទួលបាននូវធនធានសម្រាប់ក្រុមគ្រួសារ សហគមន៍ ឬក្រុម ដែលអាចនឹងរងផលប៉ះពាល់មិនល្អដោយសារគម្រោងថាមពលវារីអគ្គិសនី។ វិធានការដែលសមស្របបំផុត គឺអាស្រ័យលើស្ថានភាពជាក់ស្តែងនៅតាមតំបន់។ វិធានការទាំងនោះត្រូវផ្អែកលើចំណង់ចំណូលចិត្តរបស់សហគមន៍មូលដ្ឋានផ្ទាល់។ នៅពេលមានការរួមផ្សំជាមួយការគាំទ្រផ្អែកហិរញ្ញវត្ថុដែលបានពីការបែងចែកប្រាក់ចំណូល នោះសហគមន៍នឹងអាចស្តារ និង ពង្រីកជីវភាពរស់នៅរបស់ខ្លួនបានល្អប្រសើរជាងមុន។
- ដើម្បីបង្ហាញពីវិធានការសម្រាប់លើកកម្ពស់លទ្ធភាពទទួលបានធនធានធម្មជាតិនៅ ក្នុងតំបន់គម្រោង ត្រូវរួមបញ្ចូលការពង្រីកលទ្ធភាពទទួលបានការអនុញ្ញាត ឬ ការផ្តល់សិទ្ធិជាការចាំបាច់ ដើម្បី ៖
  - ពង្រីក ឬធ្វើប្រពលវប្បកម្មកសិរុក្ខកម្ម និងការសត្វចិញ្ចឹម។

- ធ្វើឱ្យប្រសើរឡើងដល់លទ្ធភាពទទួលបានផលព្រៃឈើ និង ការការគ្រប់គ្រងព្រៃឈើដោយសហគមន៍។
- ជួយសម្រួលដល់ការរៀបចំរវាងសហគ្រាសព្រៃឈើ សហគមន៍មូលដ្ឋាននិងរដ្ឋ សម្រាប់ប្រមូលអនុផលព្រៃឈើប្រកបដោយនិរន្តភាព ដូចដែលមានចែងជារឿយៗនៅក្នុងច្បាប់ព្រៃឈើ ប៉ុន្តែមិនសូវជាបានអនុវត្តឡើយ ។
- បង្កើតកម្មវិធីជលផលតាមអាងស្តុកទឹក និងសកម្មភាពនានាដូចជា ការល្បាតព្រៃ ការស្តុកទុកជាដើម ដោយមានការយល់ព្រមពីសហគ្រាសវារីអគ្គិសនី រួមជាមួយនឹងសិទ្ធិទទួលបានដីធ្លី និងទឹកសម្រាប់ប្រើប្រាស់។
- បង្កើតសកម្មភាពវារីវប្បកម្ម នៅតាមតំបន់ដែលអាចមានលទ្ធភាពធ្វើបាន។

- ដូចគ្នានេះដែរ វិធានការសម្រាប់លើកកម្ពស់ជីវភាពរស់នៅឲ្យមានលក្ខណៈល្អប្រសើរ ត្រូវរួមបញ្ចូលទាំងការពង្រីកលទ្ធភាពទទួលបាន ការអនុញ្ញាត ឬការផ្តល់សិទ្ធិជាការចាំបាច់ដើម្បី ៖
  - ពង្រីកការបណ្តុះបណ្តាវិជ្ជាជីវៈសម្រាប់ការចិញ្ចឹមជីវិតថ្មី ជំនាញការងារថ្មី និងពិពិធកម្មប្រាក់ចំណូល។
  - ចាប់ផ្តើមមុខរបរ និង អាជីវកម្មក្នុងមូលដ្ឋានដោយពឹងផ្អែកលើវិស័យអេកូទេសចរណ៍ និងឱកាសផ្សេងទៀតដែលបានពីការបង្កើតអាងស្តុកទឹក និងតំបន់ដីសើមថ្មី។
  - ជម្រុញឲ្យមានសេវាកម្មបរិស្ថាន ដែលផ្តល់ផលប្រយោជន៍ដល់និរន្តរភាពនៃវារីអគ្គិសនី និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
  - ជួយស្វែងរកទីផ្សារឲ្យកសិករអាចលក់ផលិតផល និងអាចលក់សេវាកម្មរបស់ខ្លួននៅក្នុងមូលដ្ឋាន។
  - បើមិនដូច្នេះទេ ត្រូវជួយសម្របសម្រួល និង គាំទ្រ ដល់ចំណាត់ការថ្នាក់មូលដ្ឋាន ដែលធ្វើឡើងដោយសហគមន៍ សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ពួកគេទាំងនោះ។
- ផលប្រយោជន៍មិនមែនជារូបិយវត្ថុ មានសារៈសំខាន់ជាពិសេសសម្រាប់ប្រជាជន ដែលរស់នៅក្នុងស្ថានភាពល្មមតែអាចចិញ្ចឹមជីវិត និង មានចំណូលទាបដែលពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ខ្លួន ពឹងផ្អែកលើសុខភាព និងការដាំដុះ។ តាមរយៈការរៀបចំយន្តការបែងចែកផលប្រយោជន៍ (BSM) ប្រជាពលរដ្ឋទាំងនោះ អាចរស់ក្នុងស្ថានភាពល្អប្រសើររយៈពេលវែង (ជាអចិន្ត្រៃយ៍តាមធម្មជាតិ)។

- តាមរយៈព័ត៌មានអន្តរជាតិ បានបង្ហាញថាបណ្តាប្រទេសជាច្រើន មានរួចជាស្រេចទៅហើយនូវច្បាប់ និង បទប្បញ្ញត្តិ ដើម្បីជួយដល់សហគមន៍មូលដ្ឋានឲ្យមានលទ្ធភាពទទួលបាននូវធនធាន ដែលមានលក្ខណៈល្អប្រសើរ។ ប៉ុន្តែច្បាប់ និងបទបញ្ញត្តិទាំងអស់នោះជារឿយៗមិនត្រូវបានអនុវត្តនៅក្នុងមូល-

ដ្ឋាន ឬមិនបានផ្តល់ការគាំទ្រជាលក្ខណៈប្រព័ន្ធឡើយ។ ប្រការនេះកើតឡើងដោយសារហេតុផលជាច្រើន រួមមានការខ្វះការយល់ដឹង ខ្វះការត្រួតពិនិត្យនិងតាមដាន ឬសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាននៅមានកម្រិតនៅឡើយ។

យន្តការនៃការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ ឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ នៃគោលនយោបាយមួយស្តីពីការទូទាត់សំណង ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានចាប់ផ្តើមអនុវត្តបទដ្ឋានជានិយាម ដែលតម្រូវឲ្យមានជាចាំបាច់ សម្រាប់ការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត និងការទទួលបានសំណង។ ដូច្នេះហើយទើបប៉ុន្មានឆ្នាំចុងក្រោយនេះ គោលការណ៍ណែនាំរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងកម្មវិធីជាច្រើនស្តីពីការតាំងលំនៅថ្មីដោយសារការអភិវឌ្ឍន៍។ ថ្មីនេះៗទៅទៀត ស្ថាប័នផ្តល់ហិរញ្ញប្បទានអន្តរជាតិ ដូចជាក្រុមធនាគារពិភពលោក ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឲ្យមានបទដ្ឋានជានិយាម និងជាគោលនយោបាយស្តីពីការទូទាត់សំណងថ្នាក់ជាតិ និងការតាំងទីលំនៅថ្មីផងដែរ ។ បទដ្ឋានជានិយាមស្តីពីការតាំងទីលំនៅថ្មីរបស់ធនាគារពិភពលោកបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ការធ្វើឲ្យលេចចេញជារូបរាងឡើងនូវគោលនយោបាយនានា របស់ម្ចាស់ជំនួយដទៃទៀត ចំណែកឯគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មីរបស់ធនាគារពិភពលោកវិញ (រួមទាំងគោលការណ៍ណែនាំរបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិផងដែរ) ជារឿយៗត្រូវបានអ្នកវិនិយោគខាងវិស័យសាធារណៈនិងឯកជន ពាក់ព័ន្ធនឹងទំនប់និងគម្រោងថាមពលវារីអគ្គិសនី យកមកប្រើប្រាស់ធ្វើជាឯកសារយោង (ទោះបីជាមានការកត់សម្គាល់ថា គោលការណ៍ណែនាំទាំងនេះ ទទួលនូវការរិះគន់ និងនៅមានភាពខ្វះចន្លោះក្តី)។

៦.៤.១ គំរូតាមទ្រឹស្តី/បញ្ញត្តិ

ប្រភេទនិងឧទាហរណ៍នៃផលប្រយោជន៍ដែលកើតឡើងពីខ្សែទឹកហូរ (watercourse) ឬអាងទន្លេមានបង្ហាញនៅក្នុងតារាងគំនូសសម្គាល់៦.១ ដែលជា " ផលប្រយោជន៍រិលជុំ' មួយមានលក្ខណៈជាបញ្ញត្តិ រួមមានផប្រភេទនៃផលប្រយោជន៍ ហើយដែលផ្តល់ជាអត្ថប្រយោជន៍ជារួមដែលអាចកើតចេញជា ៖

- លក្ខណៈរូបវន្ត តួយ៉ាងដូចជាសុខាមាលភាពជារូបវន្តនៃខ្សែទឹកហូរ។
- លក្ខណៈពាណិជ្ជកម្ម តួយ៉ាងដូចជាការធ្វើពាណិជ្ជកម្មខាងផ្នែកផលិតផលកសិកម្មនៅក្នុងរង្វង់អាងទន្លេមួយជាមួយដៃគូដែលនៅផ្នែកខាងក្រៅអាងទន្លេ។
- លក្ខណៈសេដ្ឋកិច្ច តួយ៉ាងដូចជាកំណើនសេដ្ឋកិច្ចដែលបានផលពីវិស័យកសិកម្មនៅក្នុងរង្វង់អាងទន្លេមួយ និងនៅផ្នែកខាងក្រៅអាងទន្លេ។
- លក្ខណៈបរិស្ថាន តួយ៉ាងដូចជាវិធានការការពារដើម្បីអភិរក្សបូរណភាពបរិស្ថាននៃខ្សែទឹកហូរនិងអាងទន្លេ។

- លក្ខណៈកសិកម្ម តួយ៉ាងដូចជាការប្រើប្រាស់ទឹកជាប្រយោជន៍សម្រាប់បង្កបង្កើនផល និងសម្រាប់ប្រយោជន៍សកម្មភាពកសិកម្មដែលមានលក្ខណៈនិរន្តរភាព។
- លក្ខណៈសង្គម តួយ៉ាងដូចជាលក្ខខណ្ឌសេដ្ឋកិច្ចសង្គមដែលមានលក្ខណៈល្អប្រសើរ និងសន្តិសុខស្បៀង តាមរយៈការប្រើប្រាស់ទឹកដែលមានស្រាប់សម្រាប់ជាប្រយោជន៍។
- លក្ខណៈនយោបាយ តួយ៉ាងដូចជាស្ថិរភាពនយោបាយ និង សុឆន្ទៈរវាងប្រទេសប្រើប្រាស់អាងទន្លេរួមគ្នា តាមរយៈការបែងចែកផលប្រយោជន៍ដែលបានមកពីខ្សែទឹកហូរ/អាងទន្លេប្រើប្រាស់រួមគ្នា។
- លក្ខណៈជលសាស្ត្រ តួយ៉ាងដូចជារបបលំហូរជលធារសាដែលមានលក្ខណៈល្អប្រសើរ សម្រាប់ជាប្រយោជន៍ដល់ប្រទេសដែលប្រើប្រាស់អាងទន្លេរួមគ្នា។



គំនូសសម្គាល់៦.១ ប្រភេទនិងឧទហរណ៍នៃផលប្រយោជន៍ដែលលេចចេញពីគម្រោងទំនប់ខ្នាតធំ (ប្រភពSADC គ្មានកាលបរិច្ឆេទ)

" ផលប្រយោជន៍វិលជុំ " ដែលមានលក្ខណៈជាទ្រឹស្តី អាចអនុវត្តបាននៅកម្រិតខុសៗគ្នាក្នុងក្របខ័ណ្ឌនៃខ្សែទឹកហូរ ឬអាងទន្លេរួមគ្នា តួយ៉ាងដូចជានៅតាមតំបន់អាងទន្លេ អនុអាង ឬតំបន់ភូមិសាស្ត្រតូចជាងនេះ។ ផលប្រយោជន៍នេះជម្រុញឲ្យមានការរៀបចំយុទ្ធសាស្ត្រជាជាន់ថ្នាក់ ដើម្បីវិភាគពីការប្រើប្រាស់ទឹកស្អាត ដែលមានសារៈប្រយោជន៍ជាពិសេសក្នុងការពង្រឹង និងរឹតចំណងទំនាក់ទំនងស្មុគស្មាញ ដែលបន្សល់មានជុំវិញនិងចន្លោះជាន់ថ្នាក់នោះ។ ចំនុចនេះត្រូវបានសង្កត់ធ្ងន់ថាជាគំរូតាមទ្រឹស្តី ឬជាបញ្ញត្តិ ឬ ការបរិយាយអំពីការ

ទំនាក់ទំនង។ ទោះជាយ៉ាងណា វាជាការផ្តល់នូវយន្តការតាមរយៈប្រទេសផ្សេងគ្នា តាមវិស័យ និងតាមភាគីពាក់ព័ន្ធដែលអាចមើលឃើញនិងយល់អំពីតម្រូវការ ផលប៉ះពាល់និងឱកាសផ្សេងៗទៀត។ ត្រង់ចំនុចនេះមានបង្ហាញនៅក្នុងគំនូសសម្គាល់ទី៦.២ ដែលបង្ហាញពីការអនុវត្តជាទ្រឹស្តីនៃ " ផលប្រយោជន៍រំលុំ " នៅកម្រិតអាងទន្លេ និងអនុអាង។ អ្វីដែលបានលេចឡើងជាក់ស្តែង គឺថាវិស័យ ខុសៗគ្នានៅតាមជាន់ថ្នាក់ផ្សេងគ្នា មានតម្រូវការខុសគ្នា ផលប៉ះពាល់និងឱកាសក៏ខុសគ្នា ពោលគឺ តុល្យភាពមិនមានលក្ខណៈដូចគ្នានោះទេនៅជាន់ថ្នាក់អាងទន្លេ និងអនុអាងនីមួយៗ ហើយក៏មិនដូចគ្នាដែរវាងអនុអាងផ្នែកខាងលើ និងផ្នែកខាងក្រោម។ ប្រការបង្ហាញនេះត្រូវបានរំពឹង និងឆ្លុះបញ្ចាំងឲ្យឃើញពីឱកាស ជាច្រើនដែលធនធានទឹកបានផ្តល់ឲ្យ ក៏ដូចជាអត្ថប្រយោជន៍ជាច្រើនទៀតដែលអាចត្រូវបានចែករំលែក ក្នុងក្របខ័ណ្ឌខ្សែទឹកហូរ ឬ ក្របខ័ណ្ឌអាងទន្លេ ដោយគ្មានតម្រូវការ ឬឱកាសចាំបាច់ក្នុងការទាញយកសិទ្ធិជាម្ចាស់លើការយល់ដឹងអំពីតម្រូវការ និងឱកាសផ្សេងឡើយ។ ដូចគ្នានេះដែរ តាមរយៈការធ្វើផែនការពិគ្រោះយោបល់ អាចកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានចំពោះវិសាលភាពដែលថាពួកគេ មិនត្រូវទាញយកសិទ្ធិជាម្ចាស់លើឱកាសដទៃទៀតក្នុងក្របខ័ណ្ឌខ្សែទឹកហូរ ឬអាងទន្លេបានឡើយ។ ការបង្កើតជាមូលដ្ឋានសម្រាប់ទ្រទ្រង់ចំនុចទាំងអស់ដែលបានរៀបរាប់ខាងលើនេះ គឺជាឆន្ទៈមួយរវាងប្រទេស តាមវិស័យនិងតាមភាគីពាក់ព័ន្ធដើម្បីចរចារកដំណោះស្រាយ 'ឈ្នះឈ្នះ'។

៦.៤.២ គំរូឧទហរណ៍លើករណីសិក្សា

តារាង៦.១ រាយជាគំរូឧទហរណ៍នៃយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុដែលបានអនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតធំនានា។

ការពិនិត្យឡើងវិញលើគំរូឧទាហរណ៍នៃយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ ដែលបានអនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតធំៗ បានបង្ហាញពីចំនុចគួរឱ្យចាប់អារម្មណ៍ជាច្រើន ។ ឧទាហរណ៍ដូចជា ករណីសិក្សាយូរចំណាស់ជាងគេលើទំនប់ Arenal នៅកូស្តារីកាដែលត្រូវបានបិទបញ្ចប់នៅក្នុងឆ្នាំ១៩៨០ ដែលមិនបានទទួលផលប្រយោជន៍ចេញពីបទដ្ឋានជានិយាម ដែលមានលក្ខណៈស្មុគស្មាញសម្រាប់កំណត់អត្ថន័យលើការទូទាត់សំណង និង តម្រូវការជាចាំបាច់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចឡើងវិញ ។ ដោយជំនួសវិញ គម្រោងនេះបានទទួលប្រយោជន៍ចេញពីការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជាបានពីការគាំទ្រពីដៃគូធនាគារអភិវឌ្ឍន៍អន្តរអាមេរិក។ អ្នករៀបចំផែនការតាំងលំនៅថ្មីបានរៀបចំធ្វើពិសោធន៍ និងព្យាយាមស្វែងរកដំណោះស្រាយផ្សេងៗគ្នាចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង សំដៅធានាឲ្យប្រាកដថាអ្នកដែលបំលាស់ទីលំនៅត្រូវរស់ ក្នុងជីវភាពល្អប្រសើរជាងមុនបន្ទាប់ពីបិទគម្រោង។

នៅចុងបញ្ចប់នៃវិសាលគម ករណីសិក្សាថ្មីៗជាច្រើន នៅអាមេរិកឡាទីន ពាក់ព័ន្ធនឹងទំនប់ Salto Caxias នៅក្នុងប្រទេសប្រេស៊ីល (បិទបញ្ចប់នៅឆ្នាំ១៩៩៨) និងទំនង់ Urra1 នៅក្នុងប្រទេសកូឡុំប៊ី (បិទបញ្ចប់នៅឆ្នាំ២០០០) បានលាតត្រដាងឲ្យឃើញពីអត្ថប្រយោជន៍ ដែលបានផ្តល់ដោយបទដ្ឋានជានិយាមជាតិច្បាស់លាស់ និងកំពុងសំឡឹងឃើញ សម្រាប់ការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តនៅក្នុងវិស័យអគ្គិសនីនៅក្នុងប្រទេសទាំងពីរ ។ គម្រោងទាំងពីរនេះបានផ្តល់ជាលទ្ធផលជោគជ័យសម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយមិនតម្រូវឱ្យមានការចូលរួមជាចាំបាច់ពីភាគីខាងក្រៅ ដូចជាធនាគារអភិវឌ្ឍន៍អន្តរជាតិនោះទេ។ នៅក្នុងករណីគម្រោងវារីអគ្គីសនី Salto Caxias កម្មវិធីទូទាត់សំណងនិងការតាំងលំនៅថ្មីត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋាននៃវេទិកាពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធ ដែលជាវិធីសាស្ត្រមួយត្រូវបានអនុវត្តដោយជោគជ័យផងដែរ នៅពេលក្រោយមក សម្រាប់គម្រោងវារីអគ្គីសនី Ghazi Barotha នៅក្នុងប្រទេសប៉ាគីស្តាន។

អាងទន្លេទាំងមូល



- ផលិតផលព៉ែកើតចេញពីអនុអាងភាគខាងលើ រួមជាមួយនឹងដំណាំកសិកម្មនៅភាគខាងក្រោម ទៅដល់ខ្សែទឹកហូរ
- ការរុករកព៉ែនៅអនុអាងភាគខាងលើបាន ត្រូតត្រាលើផ្នែកសេដ្ឋកិច្ចនៃអាងទន្លេទាំងមូល
- ជលសាស្ត្រនៅអាងទន្លេមានសក្តានុពលខ្ពស់ ប៉ុន្តែច្រើនតែស្ថិតនៅភាគខាងក្រោម
- មិនឃើញមានសកម្មភាពវិស័យទេសចរណ៍នៅ ភាគខាងលើអនុអាងទេ ប៉ុន្តែនៅភាគខាង ក្រោមទៅដល់ខ្សែទឹកហូរ ឃើញមានសត្វព្រៃ
- អាងទន្លេត្រូវបិត រួមទាំងទឹកទាំងអស់កំពុងប្រើ ប្រាស់។ នេះបញ្ជាក់ថា ផ្នែកជលសាស្ត្រមាន ចំណែកធំ និងមានសារៈសំខាន់
- វិស័យកសិកម្មបានរួមចំណែកជាពិសេសទៅ ដល់កំណើនផលិតផលក្នុងស្រុក (GDP) ជុំវិញ អាងទន្លេ ជាពិសេសពីភាគខាងក្រោម
- ស្ថិរភាពនយោបាយនៅអាងទន្លេអាចជាការគួរ ឲ្យសង្ស័យ ដោយហេតុកើតមានបញ្ហាសង្គម មួយចំនួន
- ភាពក្រីក្រ និងគ្រោះអត់ឃ្លានរីករាលដាលពេញ តំបន់អាងទន្លេ រួមនឹងកំណើនផលិតផលក្នុង ស្រុក (GDP)ទាប

អនុអាងផ្នែកខាងលើ



- ផលិតផលព៉ែកើតចេញពីអនុអាងភាគខាងលើ អាចផ្តល់ជាផលប្រយោជន៍ច្រើន
- ការរុករកព៉ែនៅអនុអាងភាគខាងលើបាន ត្រូតត្រាលើផ្នែកសេដ្ឋកិច្ចនៃអាងទន្លេទាំងមូល
- ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីនឹងក្លាយជា មូលដ្ឋានទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃអាង ទន្លេទាំងមូល
- មិនឃើញមានសកម្មភាពវិស័យទេសចរណ៍នៅ ភាគខាងលើអនុអាងទេ
- ការសាងសង់ទំនប់នៅភាគខាងលើអាងទន្លេ ត្រូវគិតដល់តម្រូវការនៃលំហូរទឹកនៅភាគខាង ក្រោម
- វិស័យកសិកម្មមានសារៈសំខាន់ណាស់ នៅភាគខាងលើនៃអាង
- ភាពក្រីក្រនឹងត្រូវកាត់បន្ថយតាមរយៈការ បែងចែកប្រាក់ចំណូលបានពីវិស័យរុករកព៉ែ
- ស្ថិរភាពនយោបាយពឹងផ្នែកយ៉ាងខ្លាំងទៅលើ ការអភិវឌ្ឍន៍អាងភាគខាងលើ ដើម្បីធ្វើឲ្យល្អ ប្រសើរដល់ផ្នែកសេដ្ឋកិច្ច



គំនូសសម្គាល់៦.២ ការអនុវត្តតាមទ្រឹស្តីនៃផលប្រយោជរិជុំនៅកម្រិតអាងទន្លេ និងអនុអាង (ប្រភព SADC គ្មានកាលបរិច្ឆេទ)

តារាងទី៦.១ យន្តការនៃការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ

បទដ្ឋានជានិយាម (គោលនយោបាយ /ច្បាប់)	ឧទាហរណ៍លើការអនុវត្ត	ការស្តារ និងលើកកម្ពស់ជីវភាពរស់នៅ	ការអភិវឌ្ឍសហគមន៍	ការអភិវឌ្ឍទីជម្រាល
ច្បាប់អស្សាមិករណ៍ នៅកូស្តារីកា តម្រូវការជាចាំបាច់ របស់ធនាគារអភិវឌ្ឍន៍អន្តរអាមេរិកាំង សម្រាប់គម្រោងអភិវឌ្ឍន៍ក្នុងអំឡុងទសវត្សរ៍ទី៧០	ទំនប់ Arenal កូស្តារីកា (១៩៨០)	ការប្រកបរបរកសិកម្ម ប្រកបដោយនិរន្តរភាព		
ច្បាប់ស្តីពីបរិស្ថាននៃប្រទេសប្រេស៊ីល (ឆ្នាំ១៩៨១ កែប្រែជាថ្មីក្នុងឆ្នាំ១៩៨៦ និងឆ្នាំ១៩៨៨) និងផែនការមេស្តីពីការការពារ និងធ្វើឲ្យប្រសើរឡើងនូវការងារ និងសេវាកម្មពាក់ព័ន្ធវិស័យថាមពល (ឆ្នាំ១៩៩០)	ទំនប់ Salto Caxias ប្រទេសប្រេស៊ីល (១៩៩៨)	ការប្រកបរបរកសិកម្ម និងមិនមែនកសិកម្ម ប្រកបដោយនិរន្តរភាព		
គោលនយោបាយតាំងទីលំនៅថ្មីដោយសារវិស័យអគ្គិសនីនៅកូឡុំប៊ី (១៩៩២)	ទំនប់ Urra1 កូឡុំប៊ី (២០០០)	ការប្រកបរបរកសិកម្ម ប្រកបដោយនិរន្តរភាព		
Opimiscow-La Grande កិច្ច (១៩៩២) ព្រមព្រៀងរវាង Hydro-Québec and the Grand Council of the Crees-Eeyou Ischtee, the Cree Regional Authority and the Cree Nations of Chisasibi and Wemindji	ទំនប់Laforge-1 ប្រទេសកាណាដា (១៩៩៤)			ការលើកកម្ពស់បរិស្ថាននៃធនធានទីជម្រាល
កម្មវិធីលើកកម្ពស់មានលក្ខណៈសមាហារណកម្មសម្រាប់ប្រជាពលរដ្ឋ នៃ Hydro-Québec (១៩៩៤) និងយុទ្ធសាស្ត្រនៃការចូលរួមស្តីពីភាពជាដៃគូជាមួយសហគមន៍ជនជាតិដើម	ទំនប់Sainte-Marguerite3 ប្រទេសកាណាដា (២០០២)	ភាពមានការងារធ្វើនៅមូលដ្ឋានក្នុងអំឡុងពេលសាងសង់ និងប្រតិបត្តិការគម្រោង		
ច្បាប់អស្សាមិករណ៍នៃប្រទេសឥណ្ឌូណេស៊ី (១៩៦១) និងសៀវភៅបណ្តុះ-បណ្តាលប្រតិបត្តិការរបស់ធនាគារពិភពលោក ស្តីពីបញ្ហាសង្គមពាក់ព័ន្ធនឹងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (១៩៨០)	ទំនប់Saguling and Cirata នៅWest Java ប្រទេសឥណ្ឌូនេស៊ី (១៩៨៨)	សកម្មភាពនេសាទនៅតាមអាងស្តុកទឹក		

សេចក្តីព្រាងច្បាប់នៃប្រទេសចិនស្តីពីការផ្តល់សម្បទានដីធ្លី និង ការតាំងទីលំនៅថ្មីសម្រាប់គម្រោងសាងសង់និងរក្សាទឹកខ្ពាតធំ និងមធ្យម(១៩៩១)	ទំនប់ Shuikou ប្រទេសចិន (១៩៩៦)	ការប្រកបរបរកសិកម្ម និងមិនមែនកសិកម្ម ប្រកបដោយនិរន្តរភាព		
ច្បាប់ស្តីពីការផ្តល់សម្បទានដីធ្លីនៃប្រទេសឥណ្ឌា (១៨៩៤) NHPC កញ្ចប់តាំងទីលំនៅថ្មី និង ស្ពារនីតិសម្បទា (គ្មានការចុះកាលបរិច្ឆេទ) តម្រូវការចាំបាច់នៃ CIDA និង SIDA សម្រាប់គម្រោងអភិវឌ្ឍន៍ផ្តល់មូលនិធិទ្វេភាគីអំឡុងទសវត្សរ៍ទី៩០	ទំនប់Chamera (១៩៩៤) and Uri (១៩៩៧) ប្រទេសឥណ្ឌា			
សន្ធិសញ្ញារួមអភិវឌ្ឍន៍ និង ការប្រើប្រាស់ធនធានអាងទន្លេកូម៉ាទិ(Komati Basin) រវាងប្រទេសស្វាស៊ីឡែន និងអាហ្វ្រិកខាងត្បូង(១៩៩២) និងឯកសារគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី និង ការទូទាត់សំណងម៉ាងហ្គុយកា ១៩៩៦ (Maguga)	ទំនប់Maguga ប្រទេសស្វាស៊ីឡែន (២០០២)	កសិកម្មរួមផ្សំបែបជំនួញ	ផ្លូវថ្នល់ សាលារៀន និង សេវាសុខភាព	
ច្បាប់ ស្តីពីការផ្តល់សម្បទានដីធ្លី នៃប្រទេសប៉ាគីស្តាន (១៨៩៤) និងសារាចរណែនាំប្រតិបត្តិករនៃធនាគារពិភពលោក OD 4.30 ស្តីពី ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (១៩៩០)	ទំនប់Ghazi Barotha ប្រទេសប៉ាគីស្តាន (២០០៣)	ការប្រកបរបរកសិកម្ម និងមិនមែនកសិកម្ម ប្រកបដោយនិរន្តរភាព	ផ្លូវថ្នល់ សាលារៀន និង សេវាសុខភាព	
គន្លឹះ				
ការអនុវត្តយន្តការគោលនយោបាយផ្តល់សំណង				
សេចក្តីពន្យល់សមហេតុផលបំផុតនៃយន្តការគោលនយោបាយផ្តល់សំណង				

ប្រអប់អត្ថបទ៦.៥ ទំនប់ Salto Caxias ប្រទេសប្រេស៊ីល

រោងចក្រថាមពលវារីអគ្គីសនី Salto Caxias ត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុន Companhia Paranaese de Energia (COPEL) រវាងឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៩ នៅលើដងទន្លេ Iguacu ។ ការបង្ហាំងទឹកទុកក្នុងអាងស្តុក បណ្តាលឲ្យមានការជន់លិចទ្រពសម្បត្តិនៅតាមជនបទចំនួន១១២០ នៅក្នុង៩ក្រុង និងការបំលាស់ទី១២០០គ្រួសារក្នុងចំណោម៩០០គ្រួសារដែលជាម្ចាស់ទ្រពសម្បត្តិតូចតាច ឬ ជាគ្រួសារគ្មានដីធ្លី។ បន្ទាប់ពីការប្រឆាំងនឹងគម្រោងពីសំណាក់ប្រជាពលរដ្ឋក្នុងតំបន់នេះនាឆ្នាំ ១៩៩២ ក្រុមហ៊ុន COPEL បានបង្កើតក្រុមសិក្សាស្រាវជ្រាវមួយ (GEM CX) ដែលមានសមាសភាពនៃអាជ្ញាធរកម្រិតផ្សេងៗគ្នា និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តល់ជាវេទិកាប្រជាធិបតេយ្យមួយដើម្បីពិភាក្សាអំពីសិទ្ធិរ៉ាប់រងលើសំណង និងការតាំងលំនៅថ្មី ។ ការពិភាក្សារបស់ GEM CX ឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអ្នកតំណាងនៃប្រជាពលរដ្ឋរងផលប៉ះពាល់។ កិច្ចព្រមព្រៀងឆ្នាំ១៩៩៣ បានកំណត់អត្ថន័យពីគោលការណ៍ណែនាំ និងវិធីសាស្ត្រនៃការធានារ៉ាប់រងសង និង កម្មវិធីការតាំងលំនៅថ្មី ដែលត្រូវបានបង្កើតឡើង។ កិច្ចពិគ្រោះយោបល់ត្រូវបានសហការរៀបចំជាមួយតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ និង ត្រូវបានចងក្រងឡើងដោយឈរលើពីរទិដ្ឋភាព ៖

- ការធានារ៉ាប់រងសងទៅម្ចាស់ដីស្របតាមតម្លៃទីផ្សារ ដូចដែលបានរៀបចំឡើង បន្ទាប់ពីគណៈកម្មការចម្រុះមួយបានធ្វើការអង្កេតសិក្សារួចមក។
- ត្រូវផ្តល់កម្មវិធីតាំងលំនៅថ្មីមួយដល់កសិករតូចតាច និង កម្មករដែលអត់ដីធ្លី ដែលត្រូវផ្តល់នូវការតាំងទីលំនៅថ្មីរួមគ្នា ឬផ្តល់នូវលិខិតបញ្ជាក់មួយ សម្រាប់ការតាំងលំនៅថ្មីឯកត្តជន។

ការអនុវត្តនេះបានផ្តល់ជាលទ្ធផលជោគជ័យក្នុងការបំលាស់ទី និង ការស្តារជីវភាពរស់នៅរបស់ក្រុមគ្រួសារសរុបចំនួន ៦២៦។ ចំណែកគ្រួសារចំនួន២៣២ទៀត ទទួលបានសិទ្ធិស្របច្បាប់ក្នុងការតាំងទីលំនៅសម្រាប់គម្រោងឯកត្តជន។ ការអនុវត្តនេះ ជាតំណាងឱ្យផលប៉ះពាល់ដ៏ធំមួយលើផ្នែកសេដ្ឋកិច្ចនៃតំបន់ទីក្រុងទាំង៨ ដែលបានបញ្ឈប់ដំណើរការជាបន្តបន្ទាប់ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ ។ ក្រុមហ៊ុនCOPEL បានបញ្ចុះបញ្ចូលក្រុងដែលរងផលប៉ះពាល់ ឲ្យបរិច្ចាគ១0% លើការបង់តម្លៃសិទ្ធិដែលក្រុងទាំងនោះទទួលបានពីគម្រោងក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ។ នៅឆ្នាំ ២000 មូលនិធិអភិវឌ្ឍន៍ក្រុង បានជួយបង្កើតឲ្យមានអាជីវកម្មថ្មីខ្នាតតូចចំនួន៥0បន្ថែមទៀត រួមជាមួយនឹងការបង្កើតឲ្យមានការងារធ្វើដោយផ្ទាល់ចំនួនជាង៣00ទៀត។

ឧទាហរណ៍ទាំងពីរក្នុងប្រទេសកាណាដា ឧទាហរណ៍នៃទំនប់ Laforge-1 និងទំនប់ Saint-Marguerite-3 នៅQuébec (បានបញ្ចប់រៀងៗខ្លួននៅក្នុងឆ្នាំ១៩៩៤ និងឆ្នាំ២00២) មានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីតាមទម្លាប់បែបប្រពៃណីនៃសហគមន៍ជនជាតិដើមសម្រាប់ការបរបាញ់សត្វ ការដាក់អន្ទាក់សត្វ និង សកម្មភាពនេសាទ។ ដូចដែលមានកំណត់នៅក្នុងទម្រង់នៃការផ្តល់សំណងលើការខូចខាតទីជម្រក និងធនធានសត្វព្រៃគម្រោងទំនប់ទាំងពីរនេះ នាំទៅដល់ការចរចារលើកិច្ចព្រមព្រៀងមួយដែលបានអនុញ្ញាតឲ្យសហគមន៍ជនជាតិ

ដើមចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំធ្វើផែនការ និងការអនុវត្តសកម្មភាពបង្ការ និងលើកកម្ពស់បរិស្ថានជាពិសេសការអភិរក្សសត្វព្រៃនៅក្នុងតំបន់ទីជម្រាលនៃលទំនប់ ។ ទំនប់ Saint-Marguerite-3 ក៏បានអនុវត្តផងដែរនូវកម្មវិធីលើកកម្ពស់រួមផ្សំមួយ ក៏ដូចជាការអនុវត្តគម្រោងប្រកបដោយភាពច្នៃប្រឌិត ដើម្បីប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និង ការបណ្តុះបណ្តាល ព្រមទាំងការផ្តល់ការងារធ្វើសម្រាប់សហគមន៍មូលដ្ឋាន។

ប្រអប់អត្ថបទ៦.៦ ស្ថានីយ៍បង្កើតវារីអគ្គិសនី Laforge-1 ក្នុងប្រទេសកាណាដា

គម្រោងវារីអគ្គីសនី Laforge-1 គឺជាផ្នែកមួយនៃគម្រោង La Grande Complex ដែលបានបង្កើតឡើងពីទសវត្សឆ្នាំ១៩៧០ ដល់ទសវត្សឆ្នាំ១៩៩០ ដោយ Hydro-Québec នៅក្នុងទឹកដី James Bay នៅ Québec ភាគខាងជើង។ ការអភិវឌ្ឍន៍គម្រោង La Grande Complex បានឈានទៅដល់ការចុះហត្ថលេខាក្នុងឆ្នាំ ១៩៧៥ ទៅលើកិច្ចព្រមព្រៀង James Bay និង Québec ភាគខាងជើង (JBNQA) រវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍ជនជាតិដើមCree ដែលរស់នៅក្នុងតំបន់នោះ។ កិច្ចព្រមព្រៀងនានាបន្ទាប់ក្រោយមកទៀត ត្រូវបានចុះហត្ថលេខាជាបន្តបន្ទាប់ ដូចជាកិច្ចព្រមព្រៀង Opimiscow-La Grande (ឆ្នាំ១៩៩២) ដែលបានអនុញ្ញាតឲ្យមានការសាងសង់គម្រោងទំនប់ Laforge-1 (ក្នុងចំណោមគម្រោងដទៃទៀត)។ ទំនប់ Laforge-1 មានទីតាំងនៅលើដងទន្លេ Laforge ដែលត្រូវបានកសាងឡើងរវាងឆ្នាំ១៩៨៩ និងឆ្នាំ១៩៩៤ ដោយក្រុមហ៊ុន សាជីវកម្មថាមពល James Bay (JBEC)។ គម្រោងនេះមិនជាប់ពាក់ព័ន្ធនឹងការផ្តល់សម្បទានដីឯកជននោះទេ ប៉ុន្តែបាននាំឲ្យមានការជន់លិចតំបន់បរបាញ់សត្វ និង ដាក់អន្ទាក់សត្វដ៏ធំចម្បង ព្រមទាំងបង្កើតឲ្យមានបញ្ហាលំបាកខាងនាវាចរណ៍ និង បង្កជាបញ្ហាសម្រាប់គ្រួសារជនជាតិដើម Cree ក្នុងការទទួលបានលទ្ធភាពប្រើប្រាស់តំបន់នោះ។ កិច្ចព្រមព្រៀងឆ្នាំ១៩៩២ បានផ្តល់នូវ ៖

- មូលនិធិសហគមន៍ សម្រាប់សម្រួលដល់ការប្រើប្រាស់របស់សហគមន៍ជនជាតិដើមCree។
- មូលនិធិសម្រាប់វិធានការបង្ការដើម្បីអនុវត្តការងារបង្ការផ្សេងៗ។
- មូលនិធិដែលមានគោលបំណងជួយគាំទ្រដល់សកម្មភាពបរបាញ់សត្វ និង ការដាក់អន្ទាក់សត្វ ដែលជាសកម្មភាពវប្បធម៌ដ៏មានសារៈសំខាន់សម្រាប់ជនជាតិដើមCree ។ ការងារបង្ការត្រូវបានអនុវត្តដោយក្រុមហ៊ុន JBEC និងក្រុមហ៊ុន Opimiscow-Sotrac Companee ដែលជាអង្គការរួមសហការគ្នាមិនរកប្រាក់ចំណេញ។

ក្រុមហ៊ុន Opimiscow-Sotrac Companee បានបង្កើតបទដ្ឋានគម្រោងអភិវឌ្ឍដ៏មានប្រសិទ្ធិភាពមួយឆ្លងតាមកិច្ចពិគ្រោះយោបល់ជាមួយអ្នកដែលរងផលប៉ះពាល់ ។ ការសិក្សាត្រួតពិនិត្យបានបង្ហាញថាការកែលម្អលទ្ធភាពទទួលបានដីធ្លី បានផ្តល់ជាលទ្ធផលនៃកំណើនចំនួនបោះជំរុំរបស់ជនជាតិដើម Cree នៅក្នុង

តំបន់ ហើយភាពជោគជ័យនៃវិធានការដែលមានគោលបំណងកែលម្អជម្រកសត្វព្រៃ គឺមានលក្ខណៈផ្លាស់ប្តូរ ចំណែកសត្វបក្សីទឹកមានចំនួនកើនឡើងយ៉ាងខ្លាំងនៅក្នុងតំបន់នេះ។

ករណីសិក្សាលើទំនប់ទាំងពីនៅប្រទេសឥណ្ឌូនេស៊ី គឺទំនប់ Saguling និងទំនប់ Cirata នៅក្នុងរដ្ឋ West Java បានបិតបញ្ចប់នៅក្នុងឆ្នាំ១៩៨៨ បានបង្កើតជាគំរូឧទាហរណ៍សិក្សាយ៉ាងទូលំទូលាយលើ ការអនុវត្តន៍ជាជំហានដំបូងនៃគោលការណ៍ណែនាំ ស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត របស់ធនាគារពិភពលោក (ឆ្នាំ១៩៨០) និងបានផ្តល់ជាឧទាហរណ៍មួយនៃការប្រើប្រាស់ អាងស្តុកទឹកសម្រាប់សកម្មភាពនេសាទ ដែលជាជម្រើសជំនួសមួយសំដៅស្តារឡើងវិញនូវប្រាក់ចំណូលក្នុងសហគមន៍ដែលបានផ្លាស់ទី។

ករណីសិក្សាលើទំនប់ Shuikou នៃប្រទេសចិនដែលបានបិតបញ្ចប់នៅក្នុងឆ្នាំ១៩៩៦ បានបង្កើតឲ្យមានជាឧទាហរណ៍មួយនៃការអនុវត្តប្រកបដោយជោគជ័យទាំងទៅលើបទប្បញ្ញត្តិថ្មី ស្តីពីការតាំងទីលំនៅថ្មីសម្រាប់ទំនប់ខ្នាតធំ និងមធ្យម (១៩៩១ឆ្នាំ) និងមានវិសាលភាពគ្របដណ្តប់តិចតួចលើគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តរបស់ធនាគារពិភពលោក (ឆ្នាំ១៩៩០) ការស្តារឡើងវិញនូវប្រាក់ចំណូលដោយជោគជ័យនៅក្នុងសហគមន៍ដែលបានផ្លាស់ទីដោយសារទំនប់ Shuikou ភាគច្រើនកើតឡើងដោយសារឆន្ទៈរបស់អាជ្ញាធរចិន ក្នុងការជម្រុញការបង្កើតឱកាសទទួលបានមុខរបរកសិកម្ម និង មិនមែនកសិកម្ម ប្រកបដោយនិរន្តរភាពនៅក្នុងតំបន់គម្រោង តាមរយៈដំណើរការមួយដែលអាចបត់បែនបាន និង ដែលអាចយកលំនាំតាមបាន។

អត្ថបទប្រអប់៦.៧ ទំនប់ Shuikou ក្នុងប្រទេសចិន

ទំនប់វារីអគ្គីសនីស៊ុយគូ (Shuikou) ដែលមានទីតាំងស្ថិតនៅលើដងទន្លេមីងជាង (Min Jiang) ត្រូវបានសាងសង់ឡើងដោយការិយាល័យថាមពលអគ្គិសនីខេត្តហ្វូជាន (FPEPB) រវាងឆ្នាំ១៩៨៧ និងឆ្នាំ១៩៩៦។ ការរៀបចំផែនការតាំងទីលំនៅថ្មីសម្រាប់ទំនប់ Shuikou បានធ្វើឡើងនៅក្នុងទសវត្សឆ្នាំ ១៩៨០ ក្នុងបរិបទនៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលកំពុងរីកដុះដាលនៅក្នុងប្រទេសចិន។ បន្ទាប់ពីមានការកើនឡើងនូវសម្ពាធពីអ្នកបំលាស់ទីលំនៅដោយសារការសាងសង់ទំនប់ចំនួនប្រហែល ៧០០០០ទំនប់ រួមទាំងទំនប់ខ្នាត ឲធំចំនួន៣០០ ក្នុងរយៈពេល៤០ឆ្នាំរួចមក គោលនយោបាយថ្មីត្រូវបានបង្កើតឡើងដោយបានផ្តល់ការស្តារឡើងវិញនូវប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។

គម្រោងទំនប់ Shuikou បណ្តាលឲ្យមានការបំលាស់ទីគ្រួសារតាមជនបទប្រមាណ១៥៦០០ (ស្មើនឹងចំនួន ៦៧,២៣៩នាក់) និងប្រជាពលរដ្ឋរស់នៅទីប្រជុំជនចំនួន ២០,០០០គ្រួសារ ដែលភាគច្រើនប្រជា-ពលរដ្ឋនៅណានពីងNanping) ។ ក្រុមរៀបចំផែនការតាំងទីលំនៅថ្មីនៃទំនប់ Shuikou ត្រូវបានបង្កើតឡើងដោយការិយាល័យថាមពលអគ្គិសនីខេត្តហ្វូជាន (FPEPB) ដើម្បីរៀបចំជាផែនការតាំងទីលំនៅថ្មី បន្ទាប់ពី

មានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយអ្នកតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់រួចមក ។ ផែនការតាំងលំនៅថ្មីនេះត្រូវបានអនុវត្តហួសរយៈពេលនៃបទប្បញ្ញត្តិថ្មី បទបញ្ញត្តិស្តីពីការតាំងលំនៅថ្មីនៃប្រទេសចិនមានលក្ខណៈរួមផ្សំ និង មានវិសាលភាពគ្របដណ្តប់តិចតួចលើគោលការណ៍ណែនាំ ស្តីពីការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តរបស់ធនាគារពិភពលោក ឆ្នាំ១៩៩០។ ផែនការតាំងលំនៅថ្មីបានផ្តល់ជាការបំលាស់ទីនៅតាមភូមិជាលក្ខណៈសាមគ្គី ឬជាការតាំងទីលំនៅថ្មីដែលមានលក្ខណៈរប៉ាត់រប៉ាយ។ អ្នកដែលត្រូវបំលាស់ទីត្រូវបានផ្តល់ការណែនាំជាច្រើន និងជាអ្នកទទួលខុសត្រូវក្នុងការសាងសង់លំនៅដ្ឋានថ្មីរបស់ខ្លួនដោយប្រើប្រាស់ប្រាក់ដែលបានពីការទូទាត់សំណង។ ការផ្តល់សំណងសម្រាប់ការសាង់សង់នេះត្រូវផ្អែកលើការសងជំនួសលើការចំណាយ និង ទទួលបានសំណង សម្រាប់ខូចខាតការបង្កបង្កើនផលស្របតាមអត្រាតម្លៃមុនសាងសង់ ។ ផែនការតាំងលំនៅថ្មីនេះក៏រួមបញ្ចូលទាំងផែនការស្តារនីតិសម្បទាសេដ្ឋកិច្ចផងដែរ ក្នុងគោលបំណងបង្កើតប្រព័ន្ធបង្កបង្កើផលថ្មី សម្រាប់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់។

ការអនុវត្តផនការតាំងលំនៅថ្មីនៃទំនប់ Shuikou នេះស៊ីសង្វាក់គ្នាគ្នាជាមួយនឹងរយៈពេលមួយនៃការអភិវឌ្ឍ សេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅក្នុងខេត្តហ្វុយជាន។ប្រការនេះបានជួយសម្រួលដល់ការស្តារសេដ្ឋកិច្ចរបស់អ្នកតាំងលំនៅថ្មី ប៉ុន្តែស្ថានភាពអតិផរណា ចាំបាច់តម្រូវឲ្យមានការត្រួពិនត្យឡើងវិញលើថវិកាសម្រាប់ការតាំងទីលំនៅថ្មី។

ករណីសិក្សានៅប្រទេសឥណ្ឌាលើទំនប់Chamera-ដំណាក់កាលទី១ និងទំនប់Uri-ដំណាក់កាលទី១ នៅឥណ្ឌាភាគខាងជើង (បានបិតបញ្ចប់ក្នុងឆ្នាំ១៩៩៤ ដោយមានការផ្តល់មូលនិធិពីCIDAក្នុងឆ្នាំ១៩៩៧ និងការផ្តល់មូលនិធិពី SIDA) បង្កើតបានជាឧទាហរណ៍នៃការអនុវត្តបទដ្ឋានតាំងលំនៅថ្មី និង ការស្តារនីតិសម្បទា នៃសាជីវកម្មថាមពលវារីអគ្គីសនីជាតិ ដែលសង្កត់ធ្ងន់លើការអភិវឌ្ឍសេវាសហគមន៍) សាលារៀន មណ្ឌលសុខភាព និង ផ្លូវថ្នល់) ព្រមទាំងការងារនៅតាមមូលដ្ឋានដើម្បីជួយសម្រួលដល់ការស្តារប្រាក់ចំណូលរបស់សហគមន៍ដែលបានបំលាស់ទី។

ករណីសិក្សាលើទំនប់ Maguga នៅក្នុងប្រទេសស្វាស៊ីឡែន (បានបិតបញ្ចប់ក្នុងឆ្នាំ២០០០) ដែលការអភិវឌ្ឍបានផ្សារភ្ជាប់ទៅនឹងការចុះហត្ថលេខាលើសន្ធិសញ្ញាមួយសម្រាប់ការអភិវឌ្ឍន៍ និង ការប្រើប្រាស់ធនធានរួមគ្នានៃអាងទន្លេកូម៉ាទិ (Komati Basin) រវាងប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសស្វាស៊ីឡែន (ឆ្នាំ ១៩៩២) ដែលទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយសារវាជាប់ពាក់ព័ន្ធនឹងទំនប់ធារាសាស្ត្រ ដែលបានស្ថាបនាឡើង ដើម្បីទ្រទ្រង់ដល់ហានិភ័យនៃកសិកម្មបែបពាណិជ្ជកម្ម សម្រាប់ជាមធ្យោបាយមួយ ដើម្បី

រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ជនបទ ។ ការអនុវត្តដោយជោគជ័យនៃគោលនយោបាយតាំងលំនៅថ្មី និងការទូទាត់សំណងនៃទំនប់ (ឆ្នាំ១៩៩៦) ត្រូវបានពឹងផ្អែកយ៉ាងទូលំទូលាយទៅលើការបង្កើតឲ្យមានការប្រកបរបរកសិកម្មប្រកបដោយនិរន្តរភាព។

អត្ថបទប្រអប់៦.៨ ទំនប់ Maguga ក្នុងប្រទេសស្វាស៊ីឡែន

ការតាំងទីលំនៅថ្មី និង ការទូទាត់សំណងសម្រាប់ទំនប់ Maguga ត្រូវបានណែនាំជាគោលការណ៍ដោយឯកសារគោលនយោបាយតាំងទីលំនៅថ្មី និងការទូទាត់សំណងដែលបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩៦ ដោយប្រទេសទាំងពីរ និងបានអនុវត្តតាមរយៈការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន/ ផែនការគ្រប់គ្រងការទូទាត់សំណង។ ទំនប់ Maguga ត្រូវបានសាងសង់ឡើងដោយអាជ្ញាធរទឹកអាងទន្លេកូម៉ាទិ (KOBWA) រវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០២។ ទំនប់ Maguga បានបង្កផលប៉ះពាល់ដល់គ្រួសារចំនួន១២៥ ដែលក្នុងនោះ ៣៥%ត្រូវធ្វើបំលាស់ទី។ គោលនយោបាយផ្តល់សំណងជាប់ពាក់ព័ន្ធកញ្ចប់តាំងទីលំនៅថ្មី៣ប្រភេទ ៖ ការតាំងលំនៅថ្មីតាមជម្រើសដោយសេរី ការតាំងលំនៅថ្មីនៅក្នុង resettlement in the same chiefdom chiefdomដដែល និង ការតាំងលំនៅថ្មីនៅក្នុងតំបន់ដែលមានម្ចាស់សហគមន៍ស្រាប់។ ការផ្តល់សំណងសម្រាប់ការខូចខាតរចនាសម្ព័ន្ធផ្សេងៗ ត្រូវបានគណនាតាមតម្លៃសងជំនួសបូកនឹង១០ទៅ២០% អាស្រ័យលើប្រភេទនៃការផ្តល់សំណងនោះ។ កញ្ចប់សំណងទាំងពីរចុងក្រោយមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណងជាដីជំនួសដោយដី ។ ដូចដែលមានកំណត់នៅក្នុងផែនការគ្រប់គ្រងសំណង អាជ្ញាធរទឹកអាងទន្លេកូម៉ាទិ (KOBWA) បានចាប់អនុវត្តជាក់ស្តែងចំពោះរចនាសម្ព័ន្ធនៃការចូលរួមដោយមានគណៈកម្មការតាំងទីលំនៅថ្មី Ekuvinjelweni (ERC) ធ្វើជាតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់។

នៅក្នុងតំបន់ដែលមានម្ចាស់សហគមន៍ស្រាប់ (ទីតាំងថ្មី) អាជ្ញាធរទឹកអាងទន្លេកូម៉ាទិ (KOBWA) បានផ្តល់ជាផ្លូវថ្មល់ អគ្គិសនី និងសេវាអប់រំ និងសុខាភិបាលភាគច្រើននៃប្រជាពលរដ្ឋដែលរងផលប៉ះពាល់ មិនមានលទ្ធភាពទទួលបានសេវាអប់រំ និង សុខាភិបាលល្អសមរម្យ មុនពេលដែលមានគម្រោងឡើយ ។ ដើមឈើ ហូបផ្លែឈើ ត្រូវបានសងជំនួសដោយការដាំដុះកូនឈើឡើងវិញ ហើយចំការអំពៅមានទំហំ៩៧ហិចតា ត្រូវបានដាំដុះស្តុរអំពៅពេញនៅទីនោះ។ វិធានការផ្សេងទៀត ត្រូវបានផ្តល់ឱ្យផងដែរ ដើម្បីលើកកម្ពស់ការបង្កបង្កើនផលការចិញ្ចឹមសត្វនៅទីតាំងថ្មី។ គ្រួសារសរុបចំនួន៦៥គ្រួសារបានសាងសង់លំនៅដ្ឋាន របស់ខ្លួននៅក្នុងទីតាំងថ្មីនេះ ។ តាមសំណើរបស់ ERC ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ត្រូវបានដាក់បន្ទុក ឲ្យបញ្ចប់ការសាងសង់លំនៅដ្ឋានតាមជម្រើសដោយសេរី ផ្អែកតាមកញ្ចប់ទីតាំងថ្មីដែលបានអនុវត្តដោយជោគជ័យ ។ ប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវបានផ្តល់ជាកិច្ចសន្យា ក្នុងការធ្វើរបងការពារ និងកិច្ចសន្យាដាំដុះស្តុរអំពៅ ក៏ដូចជាការសាងសង់ព្រះវិហារសហគមន៍ និងសំណង់អាគារកសិកម្ម។ អាជ្ញាធរទឹកអាងទន្លេកូម៉ាទិ (KOBWA) បានផ្តល់ឲ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់នូវការបណ្តុះបណ្តាល និងការគាំទ្រ ផ្អែក

បច្ចេកទេសសម្រាប់រយៈពេលបីឆ្នាំ បន្ទាប់ពីការបញ្ចប់គម្រោង។ ការជួលកម្លាំងពលកម្ម សម្រាប់ទំនប់ ត្រូវបានដាក់កម្រិតចំពោះអ្នកស្រុកនៃតំបន់គម្រោង ហើយហេដ្ឋារចនាសម្ព័ន្ធជាច្រើនប្រភេទត្រូវបានគេ គ្រោងជាផែនការ ដើម្បីបង្កើនផលិតកម្មចិញ្ចឹមសត្វនៅក្នុងតំបន់ទំនប់នោះ។

ករណីសិក្សាលើគម្រោងវារីអគ្គីសនី Ghazi Barotha នៅក្នុងប្រទេសប៉ាគីស្ថានដែលបានបិតបញ្ចប់ នៅក្នុងឆ្នាំ ២០០៣ បានបង្កើតជាឧទាហរណ៍មួយទៀតនៃការអនុវត្តកំណែថ្មីមួយនៃគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មីរបស់ធនាគារពិភពលោក (ឆ្នាំ១៩៩០) ។ ឧទាហរណ៍នេះ ទទួលបាននូវការចាប់អារម្មណ៍ ផងដែរ ដោយសារមានជាប់ពាក់ព័ន្ធនឹងតម្រូវការដើម្បីដោះស្រាយលើបណ្តឹងតវ៉ាពីការទូទាត់សំណង ដែលនៅមិនទាន់បានដោះស្រាយរួចពីទំនប់ Tarbela ដែលបានកសាងរួចមានចម្ងាយ៧គីឡូម៉ែត្រពីខ្សែទឹក ខាងលើទន្លេអាំងដុយ (Indus River)។

ជាការសំខាន់គួរកត់សម្គាល់ផងដែរថា ករណីសិក្សាមួយចំនួនដែលបានត្រួតពិនិត្យរួចមិនបានផ្តល់លទ្ធផល ដែលចង្អុលបង្ហាញឲ្យឃើញពីលទ្ធផលវិជ្ជមានជារួមទាក់ទងនឹងការផ្តល់សំណង សម្រាប់ការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (ទំនប់ Chamera-ដំណាក់កាលទី ១ និងទំនប់ Uri ដំណាក់កាលទី១ នៅក្នុងប្រទេសឥណ្ឌា ទំនប់ Saguling និងទំនប់ Cirata នៅក្នុងប្រទេសឥណ្ឌូនេស៊ី និងទំនប់ Ghazi Barotha នៅក្នុងប្រទេសប៉ាគីស្ថាន)។ ត្រង់ចំនុចនេះបង្ហាញឲ្យឃើញច្បាស់ថា នៅតែមានផ្លូវវែងឆ្ងាយទៀតក្នុងការអនុវត្តន៍ការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត ដែលអាចសម្រេចបានគោលបំណងដូចដែលបានគ្រោងទុក នៅក្នុងបទដ្ឋានជានិយាម។

ប្រអប់អត្ថបទ៦.៩- យន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ - ទិដ្ឋភាពគន្លឹះ
ប្រភេទនៃយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ អាចអនុវត្តបានសម្រាប់ការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តដែលទាក់ទងទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ រួមមាន ៖ •ការស្តារ និងលើកកម្ពស់ជីវភាពរស់ឲ្យប្រសើរឡើងវិញ។ - ការប្រកបរបរកសិកម្មប្រកបដោយចីរភាព។ - ការផ្តល់ជម្រើសដីជំនួសដោយដី។ - ប្រព័ន្ធធារាសាស្ត្ររួមទាំងលទ្ធភាពទទួលបានបណ្តាញទឹកសម្រាប់ស្រោចស្រពបានពីអាងស្តុកទឹក។ - លូបង្ហូរទឹក។ - ការដាំដុះនៅក្នុងតំបន់ភាគខាងក្រោម និងអត្ថប្រយោជន៍ផ្សេងៗទៀតពីលំហូរទឹក និងការគ្រប់គ្រងទឹកជំនន់។

- សេវាកសិកម្មប្រពលវប្បកម្ម រួមទាំងសម្ភារសម្រាប់ការដាំដុះ និងឧបករណ៍ផ្សេងទៀត។

•ការប្រកបរបរមិនមែនជាកសិកម្មប្រកបដោយចីរភាព។

- ភាពមានការងារធ្វើក្នុងមូលដ្ឋានក្នុងអំឡុងពេលសាងសង់និងប្រតិបត្តិការគម្រោង។
- ភាពមានការងារធ្វើផ្នែកសេវាកម្ម និងឧស្សាហកម្ម។
- សកម្មភាពនេសាទនៅតាមអាងស្តុកទឹក។
- ការបណ្តុះបណ្តាលជំនាញ។

•ការអភិវឌ្ឍសហគមន៍។

- ការសង់លំនៅឋាននៅលើដីកម្មសិទ្ធិ។
- លទ្ធភាពទទួលបានសេវាកម្មបឋម: ការអប់រំ ការថែទាំសុខភាព និងសេវាសង្គមកិច្ច (ដូចជា ការទ្រទ្រង់ដល់ក្រុមគ្រួសារ និងការទ្រទ្រង់ប្រាក់ចំណូល)។
- លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ (ដូចជាប្រាក់កម្ចីដោយមិនគិតការប្រាក់ និងការផ្តល់ឥណទានខ្នាតតូច)។
- ការផ្គត់ផ្គង់ទឹកស្អាតក្នុងមូលដ្ឋាន។
- ផ្លូវថ្នល់ និងការដឹកជញ្ជូនសាធារណៈ។
- លទ្ធភាពទទួលបានអគ្គិសនីនៅជនបទ។
- ទីផ្សារ និងទីសាធារណៈ និងកន្លែងជួបជុំបែបសាសនា។
- លទ្ធភាពទទួលបានធនធានប្រើប្រាស់រួម (ព្រៃឈើ តំបន់វាលស្មៅ ជាដើម) ។

•ការអភិវឌ្ឍន៍ទីជម្រាល។

- ភាពជាម្ចាស់ត្រួតត្រា ឬគ្រប់គ្រងលើធនធានទីជម្រាល។
- ការដាំដើមឈើឡើងវិញ និងការដាំកូនឈើហូបផ្លែ។
- ការលើកកម្ពស់បរិស្ថានសម្រាប់ធនធានសត្វព្រៃ។

ប្រធានបទពិភាក្សា	ចំណាត់ថ្នាក់សំខាន់នៃយន្តការបែងចែងផលប្រយោជន៍មិនមែនជារូបិយវត្ថុ មានរួមបញ្ចូលទាំងការស្តារនិងលើកកម្ពស់ជីវភាពរស់នៅឲ្យបានល្អប្រសើរឡើងវិញ ការអភិវឌ្ឍន៍សហគមន៍ និង ការអភិវឌ្ឍទីជម្រាល។ ចូរពិភាក្សាអំពីវិធីសាស្ត្រ ដើម្បីធានាឲ្យប្រាកដថាការសម្រេចចិត្តលើយន្តការបែងចែកផលប្រយោជន៍មិនមែនជារូបិយវត្ថុ ត្រូវស្ថិតក្នុងបរិបទនៃដំណើរការអភិវឌ្ឍន៍ដែលពាក់ព័ន្ធ និងសមត្ថភាពស្ថាប័ន។ ……

	ឧទាហរណ៍បានបង្ហាញថា យន្តការបែងចែងផលប្រយោជន៍មិនមែនជារូបិយវត្ថុ ជាញឹកញាប់ផ្តល់ដល់ប្រជាសហគមន៍រងផលប៉ះពាល់ពី គម្រោង នូវលទ្ធភាពទទួលបានតាមការនិយមពេញចិត្តចំពោះធនធានផ្សេងៗ ដូចជា កិច្ចសន្យា ភាពមានការងារធ្វើ និងធនធានទីជម្រាលនានា ។ ចូរពិភាក្សា អំពីបញ្ហាប្រឈមលើការប្រើប្រាស់គំនិតទស្សន:របស់សហគមន៍ ដែលរង ផលប៉ះពាល់ពីគម្រោង ក្នុងការជួយកំណត់អត្តន័យពីប្រទេសដែលមានព្រំ ប្រទល់ដែនជាប់គ្នា ដែលជាប្រទេសមានសិទ្ធិទទួលបាននូវធនធានផ្សេងៗ តាមការនិយមពេញចិត្ត។
លំហាត់	ចូរបរិយាយឲ្យបានល្អិតល្អន់លើករណីយន្តការបែងចែងផលប្រយោជន៍ មិនមែនជារូបិយវត្ថុដែលមានលក្ខណ:មិនសមស្របចំពោះគម្រោងហេដ្ឋា រចនាសម្ព័ន្ធមួយដែលមានទំហំធំ។ ..... តាមរយ:ការប្រើប្រាស់ឧទាហរណ៍ នៅក្នុងប្រទេសរបស់អ្នកពាក់ព័ន្ធនឹង ខ្សែទឹកហូរ ឬ អាងទន្លេរួមគ្នា ចូររៀបចំបង្កើតនូវ " ផលប្រយោជន៍រិលជុំ " មួយដែលមានលក្ខណ:បញ្ញត្តិ ដែលអត្ថប្រយោជន៍អាចកើនឡើង នៅក្នុង អាងទន្លេភាគខាងលើ និងភាគខាងក្រោម ។ ចូរបរិយាយឲ្យបានលម្អិតពី ឧបសគ្គដែលអាចកើតមានលើការទទួលបាននូវផលប្រយោជន៍ រួមគ្នា និង យន្តការដែលអាចធ្វើឲ្យឧបសគ្គទាំងនេះអាចសម្រេចជោគជ័យបាន។

៦.៥ យន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ

គោលបំណង	គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីលក្ខណៈ និង ទម្រង់នៃយន្តការនៃការបែងចែកផលប្រយោជន៍ ជារូបិយវត្ថុ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់ដឹងអំពីយន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុដែលមានស្រាប់ជាផ្នែកមួយនៃកញ្ចប់ទូទាត់សំណង និងបន្ទុរបន្តុយ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និង ការអភិវឌ្ឍ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និង ជម្រើសជំនួស។ ផ្នែកទី៥: គោលនយោបាយស្តីពីការទូទាត់សំណង (ដោយផ្តោតសំខាន់លើយន្តការនៃការបែងចែកផលប្រយោជន៍)។ www.unep.org/dams

យន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ជាប់ពាក់ព័ន្ធនឹងសហគមន៍រងផលប៉ះពាល់ដោយសារការបែងចែកលំហូររូបិយវត្ថុដែលបានពីប្រតិបត្តិការនៃគម្រោងទំនប់វារីអគ្គិសនី។ វាជាការសំខាន់ណាស់ដែលថាយន្តការបែងចែកផលប្រយោជន៍ ត្រូវតែស្របគ្នានឹងមធ្យោបាយម្យ៉ាងដែលយន្តការទាំងនេះ ផ្តល់ជាផលប្រយោជន៍ដល់អ្នកដែលទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងមួយ ។ យន្តការទាំងនេះអាចប្រើប្រាស់ជាមធ្យោបាយសម្រាប់អ្នកអភិវឌ្ឍដើម្បីបង្កើតភាពជាដៃគូរជាមួយប្រជាពលរដ្ឋមូលដ្ឋាន រួមទាំងប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ។ យន្តការទាំងនេះក៏អាចជាមធ្យោបាយ ដើម្បីបង្កើតជាមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ផងដែរ។ ដូចនេះ យន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ នៅតែអាចអនុវត្តបានបើទោះបីជាក្នុងករណីមិនមានប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងក្តី។ អត្ថប្រយោជន៍នៃយន្តការបែបនេះ កើតចេញពីសក្តានុពលរបស់វា ដើម្បីគាំទ្រភាពជាដៃគូរយៈពេលវែងដ៏មានអត្ថប្រយោជន៍រវាងអ្នកអភិវឌ្ឍន៍និងសហគមន៍ដែលពាក់ព័ន្ធ។

ប្រព័ន្ធបែងចែកផលប្រយោជន៍ជារូបិយវត្ថុ មានគោលបំណងសំខាន់៣ គឺ ៖

- ផ្តល់សំណងរយៈពេលវែងបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយគម្រោង។
- បង្កើតជាមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងតំបន់សម្រាប់រយៈពេលវែង។
- បង្កើតភាពជាដៃគូររវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។

ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ មានន័យថាជាការចែករំលែកផលចំនេញផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីវារីអគ្គិសនី ដែលជាធម្មតាមានកំណើននៅកម្រិតជាតិ រួមជាមួយនឹងសហគមន៍ និងអ្នកមូលដ្ឋាន

ដែលរស់នៅតាមអាងទន្លេនានា។ ក្នុងន័យសេដ្ឋកិច្ច ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុមានន័យថាជាការចែករំលែកចំណែកនៃ "ថ្លៃឈ្នួលសេដ្ឋកិច្ច" ដែលបានពីការវិនិយោគលើវិស័យវារីអគ្គិសនី [យោង២០] ។ ដូចដែលបានកត់សម្គាល់ពីខាងដើម ការចែករំលែកប្រាក់ចំណូលអាចជាទម្រង់មួយត្រូវបានទទួលស្គាល់បំផុតសម្រាប់ការចែករំលែកផលប្រយោជន៍រូបិយវត្ថុក្នុងវិស័យវារីអគ្គិសនី ក៏ដូចជាវិស័យដទៃទៀត ដូចជាការរុករករ៉ែ និងវិស័យព្រៃឈើ [យោង២១]។

- យន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ អាចផ្ទេរចំណែកនៃផលប្រយោជន៍ជារូបិយវត្ថុទៅដល់ថ្នាក់ខេត្ត ក្រុង ឬ តាមមូលដ្ឋាន។ វិធីសាស្ត្រខុសៗគ្នា ត្រូវបានប្រើប្រាស់ដើម្បីប្រែក្លាយលុយឲ្យទៅជាផលប្រយោជន៍ពិតប្រាកដ ។ វិធីសាស្ត្រសំខាន់ៗចំនួនពីរគឺ ៖
  - ការផ្តល់មូលនិធិដល់ការដំឡើងថវិកាប្រចាំឆ្នាំ សម្រាប់អភិវឌ្ឍមូលដ្ឋានរបស់សហគមន៍នៅក្នុងតំបន់គម្រោង (ឧទាហរណ៍ គំរូម៉ូឌែលប្រទេសនេប៉ាល់) និង
  - ការផ្តល់មូលនិធិដល់មូលនិធិ បែងចែងផលប្រយោជន៍មូលដ្ឋាន ឬ មូលនិធិអភិវឌ្ឍន៍សហគមន៍ (CDF) ឬ មូលនិធិអភិវឌ្ឍន៍តំបន់មូលដ្ឋាន ដោយពាក្យនេះប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ (ឧទាហរណ៍គំរូម៉ូឌែលប្រទេសឥណ្ឌា និងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងប្រទេសជាច្រើនទូទាំងពិភពលោក។

[យោង២០] តម្លៃឈ្នួលសេដ្ឋកិច្ច គឺជាពាក្យដែលអ្នកសេដ្ឋកិច្ចបានប្រើ។ ចំពោះវិស័យវារីអគ្គីសនី ពាក្យនេះអាចត្រូវបានកំណត់អត្ថន័យថាជា " ការដកតម្លៃអគ្គិសនីដែលបានកំណត់ដោយមានការប្រកួតប្រជែង ចេញពីការចំណាយបន្ទាប់បន្សំលើការផលិតថាមពលវារីអគ្គីសនី"។ ដើម្បីធ្វើឲ្យសម្រេចបាននូវការបែងចែកប្រាក់ចំណូល ត្រូវមានអតិរេកសេដ្ឋកិច្ច ដែលការចំណាយលើកត្តាទាំងអស់នៃការផលិតអគ្គិសនីគឺមានចំនួនតិចជាងតម្លៃអគ្គិសនី។ នៅក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលនៃប្រទេសទន្លេមេគង្គ បានកំណត់តម្លៃអគ្គិសនី (ជារឿយៗក្នុងកម្រិតតម្លៃខ្ពស់បំផុត)។

[យោង២១] យន្តការបែងចែកប្រាក់ចំណេញ គឺជាវិធានការពឹងផ្អែកលើតម្លៃដ៏មានសារៈសំខាន់ដែលបានដោយផ្ទាល់ (ឬដោយប្រយោល) ពីចរន្តប្រាក់ចំណូលនៃគម្រោងវារីអគ្គិសនី ។ ដូចដែលបានបង្ហាញនៅក្នុងផ្នែកខាងដើម ការបែងចែកប្រាក់ចំណូលមានលក្ខណៈជាមូលដ្ឋាននៃការទំនាក់ទំនងរវាងអ្នកប្រើប្រាស់អគ្គីសនី (អ្នកបង់ថ្លៃអគ្គិសនី) និងសហគមន៍មូលដ្ឋាន និងម្ចាស់មូលដ្ឋានដែលរស់នៅតាមអាងទន្លេ (អ្នកទទួលគម្រោង)។ ការបែងចែកប្រាក់ចំណេញ ឆ្លុះបញ្ចាំងពីគោលការណ៍ដែលអ្នកប្រើត្រូវបង់ថ្លៃ ក្នុងផ្នែកគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលធ្វើប្រព្រឹត្តកម្មទឹកឲ្យទៅជាផលប្រយោជន៍មួយខាងផ្នែកសេដ្ឋកិច្ច។

- យន្តការផ្សេងទៀតត្រូវបានប្រើប្រាស់ជាទូទៅដើម្បីទាញយក និងពង្រីកផលប្រយោជន៍ជារូបិយវត្ថុរួមបញ្ចូលទាំងការបែងចែកដោយស្មើភាពគ្នា។ សហគមន៍ ក្រុង ឬខេត្តនេះអាចទទួលបាននូវការចែករំលែកដោយសមធម៌នៅក្នុងក្រុមគម្រោងដាច់ដោយឡែក ដែលរៀបចំបង្កើត និងប្រតិបត្តិការគម្រោងនេះ។

- នៅក្នុងបណ្តាប្រទេសមួយចំនួន ការបែងចែកដោយស្មើភាពនេះអាចជាការផ្តល់ហិរញ្ញប្បទានដោយខ្លួនឯង ដូចជាតាមបណ្តាខេត្ត ជាដើម។ ក្នុងករណីផ្សេងទៀត រដ្ឋាភិបាលកណ្តាលអាចផ្តល់ហិរញ្ញប្បទានសមធម៌ ក្នុងនាមជាសហគមន៍មូលដ្ឋាន ឬឧទាហរណ៍ ការផ្តល់មូលនិធិសម្រាប់អ្នកស្រុកដែលរស់នៅតាមអាងទន្លេ។

- ការបែងចែកនេះកើតចេញមកពីប្រាក់ចំណូលប្រចាំឆ្នាំពីគ្រប់ទឹកន្លែងចំនួនប្រហែល១០ ទៅ ២០% បានត្រឡប់មកពីការបែងចែកដោយសមភាព ដែលអាចត្រូវចំណាយវិញទៅតាមកម្មវិធីដោយការប្រើលក្ខណៈវិនិច្ឆ័យចំពោះសហគមន៍ដែលបង្កើតឡើងដោយខ្លួនឯង (ឧទាហរណ៍ យន្តការផ្តល់ហិរញ្ញប្បទានមួយ ក្នុងចំណោមយន្តការជាច្រើនស្តីពីមូលនិធិអាងទន្លេកូឡុំប៊ី នៅក្នុងប្រទេសកាណាដា)។

- បណ្តាប្រទេសនានា ជាញឹកញាប់បានជ្រើសយកចំណែកនៃប្រាក់ចំណូលដែលបានពីវារីអគ្គិសនីនៅកម្រិតផ្សេងគ្នារបស់រដ្ឋាភិបាល ធ្លាក់ចុះដល់កម្រិតសហគមន៍។

- ដំណើរទស្សនកិច្ចបច្ចេកទេសរបស់គណៈកម្មការទន្លេមេគង្គ នាអំឡុងខែវិច្ឆិកា ឆ្នាំ២០១០ នៅអាងទន្លេ La Plata នៃអាមេរិកឡាទីន មន្ត្រីគណៈកម្មការដែលបានចូលរួមក្នុងទស្សនកិច្ចនោះបានមើលឃើញជាលើកដំបូងពីរបៀបដែលប្រទេសប្រើស្ទីលបែងចែកប្រាក់ចំណូលរបស់ខ្លួន ក្នុងចំណោមរដ្ឋាភិបាលកណ្តាល បណ្តាខេត្ត និងក្រុងនានា ដែលជាកន្លែងមានគម្រោងវារីអគ្គិសនី (យោង២២) ។

- ភាគរយដែលបានកំណត់ផ្លាស់ប្តូរទៅតាមកម្រិតនីមួយ។ ភាគរយនេះត្រូវបានអនុវត្តចំពោះគម្រោងថាមពលវារីអគ្គិសនីទាំងអស់ដែលមានស្រាប់ និងទើបដំណើរការថ្មី។

(យោង២២) របាយការណ៍ទស្សនកិច្ចសិក្សារបស់គណៈកម្មការទន្លេមេគង្គ នៅតំបន់ព្រំប្រទល់ដែនអាងទន្លេ និងគម្រោង Binacional នៅក្នុងអាងទន្លេ La Plata ក្នុងអាមេរិកឡាទីន នាខែវិច្ឆិកា ឆ្នាំ២០១០ MRC គម្រោងផ្តួចផ្តើមគំនិតសម្រាប់និរន្តរភាពវារីអគ្គិសនី ខែធ្នូ ឆ្នាំ ២០១០។

- នៅក្នុងករណីសិក្សាក្នុងប្រទេសអាហ្សង់ទីន ប្រាក់ចំណូលទាំងអស់បានមកពីគម្រោងវារីអគ្គិសនីទ្វេភាគី ត្រូវបានផ្តល់ទៅឱ្យបណ្តាខេត្តនានាដែលមានគម្រោងតាំងនៅ ដោយការយកចិត្តទុកដាក់ចំពោះវិសាលភាពនៃអាងស្តុកទឹក ។ ប្រាក់ចំណូលនេះមិនបានផ្តល់ទៅឲ្យរដ្ឋាភិបាលកណ្តាលទេ។

- ផលប្រយោជន៍ជាតិ ក្នុងករណីសិក្សានៅអាហ្សង់ទីន ត្រូវបានគេមើលឃើញថា (i) កាន់តែមានសុវត្ថិភាពដោយការចំណាយថាមពលទាបសម្រាប់អ្នកប្រើប្រាស់អគ្គិសនីក្នុងប្រទេស និង (ii) ប្រទេសជាតិ ត្រូវជៀសវាងការនាំចេញឥន្ធនៈសម្រាប់ការបង្កើតថាមពលកម្តៅ ដែលជាតម្រូវការចាំបាច់។

- ការប៉ាន់ប្រមាណធ្វើឡើងដោយមន្ត្រីអាហ្សង់ទីន ក្នុងពេលដំណើរទស្សនកិច្ចរបស់គណៈកម្មការទន្លេមេគង្គនៅទំនប់វារីអគ្គិសនី Salto Grande នៅលើដងទន្លេអ៊ុយរ៉ាហ្គាយ (Uruguay) ដែលមានកម្លាំងផលិត១៨៩០មេហ្គាវ៉ាត់ (បង្កើតជាព្រំដែនអន្តរជាតិរវាងប្រទេសអាហ្សង់ទីន និង អ៊ុយរ៉ាហ្គាយ) បានបង្ហាញថាប្រទេសអាហ្សង់ទីនបានបញ្ឈៀសការទិញប្រេងឥន្ធនៈនាំចូល ដែលមានទឹកប្រាក់ ៥០កោដដុល្លារ ចាប់តាំងពីឆ្នាំ១៩៧៩ ដោយប្រើប្រាស់ភាគហ៊ុន៥០%នៃទិន្នផលរបស់ខ្លួនបានពីគម្រោង Salto Grande [(យោង២៣)] ។

- នៅក្នុងប្រទេសនេប៉ាល់ពីឆ្នាំ១៩៩៩ ច្បាប់ជាតិបានចែងថា និយ័តករអគ្គិសនីថ្នាក់ជាតិ ត្រូវប្រមូលប្រាក់ចំណូលឲ្យបាន១% ពីគម្រោងនានាក្រោមកម្រិត១មេហ្គាវ៉ាត់ (នាយកដ្ឋានអភិវឌ្ឍន៍អគ្គីសនី) និងត្រូវគាំពារដល់ការបង់ថ្លៃសម្រាប់អគ្គិសនីយកម្ម ។ ភាគរយនៃសិទ្ធិបង់ថ្លៃ ត្រូវរៀបចំចាត់ចែងជាថវិកាសម្រាប់អភិវឌ្ឍន៍ស្រុក និងសហគមន៍ ដែលគម្រោងវារីអគ្គិសនីតាំងនៅ។ ចំនួនទឹកប្រាក់ ត្រូវបានកើនឡើងជាលំដាប់ចាប់តាំងពីពេលនោះមក [(យោង២៤)]។

[(យោង២៣)] ការប៉ាន់ប្រមាណពីកំណើនផលប្រយោជន៍សេដ្ឋកិច្ចជាតិ ពឹងផ្អែកលើការសន្សំឥន្ធនៈនាំចូលដែលចេះបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ពីភាគហ៊ុន៥០នៃទិន្នផលបាន%ពីគម្រោងSalto Grande នៃប្រទេសអាហ្សង់ទីន ដោយបានទទួលស្គាល់ផងដែរថា រាល់បំណុលទាំងអស់របស់គម្រោង Salto Grande ត្រូវបានសងរួចអស់តាមកាលកំណត់ត្រឹមឆ្នាំ១៩៩៥ និងទៅតាមតម្លៃថាមពលពីមួយឆ្នាំទៅមួយឆ្នាំ។

[(យោង២៤)] សូមមើលនៅក្នុងការពិភាក្សាលើច្បាប់ប្រទេសនេប៉ាល់នៅក្នុងផ្នែក២.២.១ និងនៅក្នុងអត្ថបទចុះផ្សាយលេខ៥ ក្នុងស៊ីឌីផ្តល់ចំណេះដឹង ក្នុងកម្មវិធីគម្រោងផ្តួចផ្តើមគំនិតស្តីពីវារីអគ្គិសនី (ISH)របស់គណៈកម្មការទន្លេមេគង្គ។

ចំណុចចុងក្រោយ គឺថាផលប្រយោជន៍ជារូបិយវត្ថុមួយចំនួន បានបង្ហាញឲ្យដឹងនៅកម្រិតជាតិថា មានលក្ខណៈជាបរិមាណងាយស្រួល។ ផលប្រយោជន៍ផ្សេងទៀត គឺកាន់តែមានការលំបាកក្នុងការវាស់បរិមាណឲ្យបានជាក់លាក់។ ផលប្រយោជន៍កម្រិតជាតិជាទូទៅ រួមមាន ៖

▪ ផលប្រយោជន៍ ដែលទទួលស្គាល់ដោយអ្នកប្រើប្រាស់អគ្គិសនីតភ្ជាប់នឹងខ្សែបណ្តាញចរន្តអគ្គិសនី ដែលមើលឃើញថាមានតម្លៃបេរៈយៈពេលវែង (ឧ. ជៀសវាងការពឹងផ្អែកលើការនាំចូលប្រេងពីទីផ្សារថាមពលអន្តរជាតិដែលមានលក្ខណៈមិនបិតបេរ លើកលែងតែប្រេង ឧស្ម័ន ឬធ្យូងថ្មដែលត្រូវនាំចូល គឺជាជម្រើសជំនួសសម្រាប់ការផ្គត់ផ្គង់ក្នុងចំនួនច្រើន-ដូចករណីនៅប្រទេសអាហ្សង់ទីន)។

▪ តម្លៃអគ្គិសនីទាបជាងរយៈពេលវែង ជាពិសេសបន្ទាប់ពីគម្រោងបានសងបំណុលរួចអស់ ដោយមិនគិតពីថាតើគម្រោងនេះបានផ្តល់ហិរញ្ញប្បទានដោយកម្ចីពីវិស័យសាធារណៈ ឬឯកជន ឬបញ្ហាឥណទេយ្យប័ណ្ណក្តី។

- លំហូរប្រាក់ចំណូលទៅក្នុងគណនីជាតិ ដូចជាបានពីការបង់តម្លៃសិទ្ធិ បានពីការប្រើប្រាស់ទឹក ឬ ថ្លៃផ្សេងទៀត ក៏ដូចជាពន្ធលើប្រាក់ចំណូល ពន្ធអាករ ដែលក្រុមហ៊ុនវារីអគ្គិសនីមានកាតព្វកិច្ចត្រូវបង់ ដូចជាសហគ្រាសផលិតកម្មទាំងអស់ដែរ។
- សម្រាប់គម្រោងវារីអគ្គិសនីរកប្រាក់ចំណូលពីការនាំចេញ ផលចំណេញផ្នែកសេដ្ឋកិច្ចជាតិមានកំណើនខ្ពស់អាស្រ័យលើតុល្យភាពនៃប្រាក់ចំណូលផ្នែកពាណិជ្ជកម្ម និង អត្រាប្តូរប្រាក់បរទេស។
- ផលប្រយោជន៍ដែលមានបរិមាណតិចតួច ដូចជាគុណតម្លៃសេដ្ឋកិច្ចលើសេវាដែលគ្រាន់តែជាជំនួយតែមួយគត់សម្រាប់វារីអគ្គិសនី ដែលធ្វើឲ្យតម្រូវការវិនិយោគជាតិ មានកម្រិតទាបក្នុងការផលិតអគ្គិសនី និង បង្កើតខ្សែបណ្តាញចរន្តអគ្គិសនី (តម្លៃខ្ពស់បំផុតសម្រាប់អ្នកប្រើប្រាស់) គុណតម្លៃនៃនិរភ័យថាមពល (ដោយការប្រើប្រាស់ធនធានថាមពលកកើតឡើងវិញក្នុងមូលដ្ឋាន) ហើយផលប្រយោជន៍សេដ្ឋកិច្ចផ្នែកខាងក្រៅ ត្រូវជៀសវាងការបំភាយឧស្ម័ន GHG ពីការបង្កើតកម្តៅ និងជៀសវាងការបំពុលបរិយាកាសពីថាមពលកម្តៅ លាយឡំជាមួយនឹងផលប៉ះពាល់លើសុខភាពមនុស្ស លើអាគារផ្សេងៗ តាមរយៈសារធាតុស៊ុលហ្វឺអុកស៊ីត (SO2) ដែលបង្កជាផលប៉ះពាល់លើទិន្នផលដំណាំ និងគុណភាពបរិស្ថាន។

កត្តាទាំងអស់នេះសុទ្ធតែមានតម្លៃជារូបិយវត្ថុ និងផ្តល់ជាអត្ថប្រយោជន៍រួមដល់សង្គមជាតិ។

៦.៥.១ ការផ្តល់សំណងរយៈពេលវែងបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីគម្រោង

" ការបង្កើតឲ្យមានឡើងវិញយ៉ាងត្រឹមត្រូវនូវសេដ្ឋកិច្ចសង្គម-មិនត្រឹមតែតម្រូវឱ្យបង់សំណងស្របតាមតម្លៃទីផ្សារពេញលេញនៃដីដែលបានដកហូតនោះទេ ចរន្តនៃផលប្រយោជន៍ ដែលបង្កើតឡើងដោយគម្រោង ក៏ត្រូវយកមកប្រើ ដើម្បីផ្តល់ជាប្រយោជន៍ដោយផ្ទាល់ និង ធនធានផ្សេងៗទៀតសម្រាប់អ្នកតាំងលំនៅថ្មី " (ប្រភព Wiclin ១៩៩៩) ។

តាមការស្រាវជ្រាវបានបង្ហាញថា នៅក្នុងករណីដែលមានការជម្លៀសប្រជាពលរដ្ឋ ដោយបង្ខំបណ្តាលមកពីទំនប់ នោះការផ្តល់សំណងសម្រាប់ការខូចខាតទ្រព្យសម្បត្តិតែមួយមុខមិនគ្រប់គ្រាន់ទេក្នុងការធានាការបង្កើតឲ្យមានឡើងវិញដោយមានលក្ខណៈផ្លែផ្កា និងបិតបៀរសម្រាប់អ្នកដែលបានបំលាស់ទីទាំងនោះ។

ត្រូវបទាមទារឱ្យមានយន្តការបែងចែកផលប្រយោជន៍ ជាពិសេសក្នុងការយល់ដឹងអំពីបរាជ័យតាមរយៈគោលការណ៍ដែលមានស្រាប់ ដើម្បីចាប់យកការចំណាយផ្នែកសង្គមកិច្ចពេញលេញលើផលប៉ះពាល់ដែលទាក់ទងនឹងការជម្លៀសប្រជាពលរដ្ឋ ។ យន្តការបែបនេះត្រូវបានគេចាត់ទុកថាជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏សំខាន់បំផុត សម្រាប់បង្គប់សាច់ប្រាក់សំណង និងវិធានការផ្សេងទៀត ដែលកើតមានឡើង ក្នុងក្របខ័ណ្ឌនៃគោលនយោបាយទូទាត់សំណង។ ប្រការបែបនេះ គេត្រូវយកចិត្តទុកដាក់ទៅលើធាតុគន្លឹះមួយនៃគោលនយោបាយទូទាត់សំណង នោះគឺការបែងចែកចំណែកផលប្រយោជន៍ដែលបានពីទំនប់ ឬ ប្រតិបត្តិការវារីអគ្គិសនីឬគម្រោងជាមួយសហគមន៍ដែលរងផលប៉ះពាល់។ វិធានការនេះត្រូវបានផ្តល់អនុ-សាសន៍ដោយ WCD គោលការណ៍ណែនាំស្តីពីវារីអគ្គិសនី និងបរិស្ថានរបស់ទីភ្នាក់ងារថាមពលអន្តរជាតិ និងគោលការណ៍ណែនាំស្តីពីនិរន្តរភាពវារីអគ្គិសនីរបស់សមាគមវារីអគ្គិសនីអន្តរជាតិ។

តម្រូវការក្នុងការផ្តល់សំណងបន្ថែមទៀត ដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ ស្តីពីការផ្ទេរប្រាក់ចំណូលបានមកពីគម្រោងវារីអគ្គិសនី នៅក្នុងប្រទេសនានាដូចជាប្រទេសន័រវែស ប្រទេសនេប៉ាល់ និងប្រទេសប្រេស៊ីល។

ប្រអប់អត្ថបទ៦.១.០ ច្បាប់ពាក់ព័ន្ធនឹងពន្ធនិងកម្រៃអាជ្ញាប័ណ្ណនៃប្រទេសន័រវែស
ច្បាប់ន័រវែសមានសមាសភាពយន្តការជាច្រើន ដែលធានាដល់ការបែងចែកផលប្រយោជន៍បានពីការគ្រប់គ្រងទឹក និងគម្រោងវារីអគ្គិសនីក្នុងតំបន់ និងជាមួយសហគមន៍មូលដ្ឋាន។ យន្តការទាំងនេះចែកចេញជា៣ប្រភេទ ៖ (ក) បញ្ញត្តិដែលបានរួមបញ្ចូលនៅក្នុងការអនុលោមតាមអាជ្ញាប័ណ្ណនៃបទបញ្ញត្តិច្បាប់ឆ្នាំ ១៩៧១ (ខ) ពន្ធដែលត្រូវបង់ទៅឱ្យអាជ្ញាធរក្នុងតំបន់និងមូលដ្ឋាន និង (គ) ប្រាក់ចំណូលដែលបានទទួលពីរដ្ឋអាជ្ញា និងសាលាក្រុងនៅក្នុងទម្រង់នៃភាគលាភ ។ យន្តការបែបនេះ ត្រូវបានទទួលស្គាល់ទាំងស្រុងថា

ប្រជាពលរដ្ឋ រងផលប៉ះពាល់ពីគម្រោងដែលជាផ្នែកមួយនៃប្រជាជនក្នុងទីក្រុង ដែលបានធ្វើអាជីវកម្មលើធនធានទឹក ត្រូវតែទទួលបានការចែករំលែកផលប្រយោជន៍នៃគម្រោងសម្រាប់ជាវិធានការបន្ទុរបន្តយ និងក្រោមវិធានការបន្ទុរបន្តយនិងទូទាត់សំណង ដែលត្រូវបានរួមបញ្ចូលនៅក្នុងការរចនាគម្រោង។ ទោះយ៉ាងណា យ៉ាងហោចណាស់ក៏នៅក្នុងតំបន់ Glomma-Laagen ចំណូលបែបនេះតំណាងឱ្យភាគរយតូចមួយនៃប្រាក់ចំណូលរបស់សាលាក្រុងផងដែរ។ លើសពីនេះទៀតប្រព័ន្ធពន្ធដារនៅក្នុងប្រទេសន័រវែស មិនត្រូវបានទទួលស្គាល់ទាំងស្រុងទេថា ជាមួយនឹងការដំឡើងវារីអគ្គិសនីនៅក្នុងទឹកដីរបស់ខ្លួន នោះសាលាក្រុងគួរតែទទួលបានប្រាក់ចំណូលពន្ធបន្ថែមទៀតពីក្រុមហ៊ុនអគ្គិសនី ចាប់តាំងពីប្រាក់ចំណូលពន្ធមានចំនួនច្រើនជាងត្រូវបានទូទាត់សង តាមរយៈការបន្ធាបប្រាក់ឧបត្ថម្ភធនរបស់រដ្ឋ។

៦.៥.២ ការបង្កើតមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចយូរអង្វែងនៅក្នុងតំបន់

នៅក្នុងតំបន់ក្រីក្រដែលមានធនធានទឹកមិនអាចយកមកប្រើប្រាស់បាន នោះគម្រោងទំនប់វារីអគ្គិសនីអាចរៀបចំជាផែនការរបស់ខ្លួន ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ។ ផែនការបែបនេះអាចយកចិត្តទុកដាក់ចំពោះសក្តានុពលនៃធនធានទាំងអស់ដែលមាននៅក្នុងតំបន់ ក៏ដូចជាឱកាសដែលបានពីអាងស្តុកទឹក ព្រមទាំងតាមរយៈលទ្ធភាពទទួលបានផ្លូវដែលសាងសង់ឡើង សម្រាប់ការស្ថាបនាទំនប់ ឬស្ថានីយអគ្គសិនី។ ឱកាសទាំងនេះអាចរួមបញ្ចូលទាំងសកម្មភាពនេសាទតាមអាងស្តុកទឹក ការស្រោចស្រពកសិកម្ម លទ្ធភាពទទួលបានទីផ្សារនិង/ឬនាវាចរណ៍ដែលមានលក្ខណៈល្អប្រសើរជាងមុន។

ជាផ្នែកមួយនៃការផ្តល់មូលនិធិដើម្បីអនុវត្តផែនការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ អាចត្រូវបានផ្តល់តាមរយៈការបញ្ជូនសមាមាត្រនៃផលប្រយោជន៍បានពីគម្រោងទំនប់វារីអគ្គិសនី ទៅដល់សហគមន៍មូលដ្ឋាននិងក្នុងតំបន់ ឧទាហរណ៍តាមមធ្យោបាយនៃមូលនិធិអភិវឌ្ឍន៍មួយ។ មូលនិធិអភិវឌ្ឍន៍ ក៏អាចត្រូវបានបង្កើតឡើងផងដែរ ដើម្បីផ្តល់នូវការទូទាត់សំណងរយៈពេលវែងដល់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីគម្រោង។

អត្ថបទប្រអប់៦.១១ ច្បាប់ស្តីពីមូលនិធិសម្រាប់ក្រោយការតាំងលំនៅថ្មី និងការស្តារនីតិសម្បទានៃប្រទេសចិន

នៅឆ្នាំ១៩៩១ ប្រទេសចិនបានបង្កើតច្បាប់ស្តីពីមូលនិធិសម្រាប់ក្រោយការតាំងលំនៅថ្មី និង ការស្តារនីតិសម្បទា (ត្រូវបានកែប្រែឡើងវិញនៅឆ្នាំ១៩៩៦) ដោយបានទទួលស្គាល់ថា ទោះបីជាការតាំងលំនៅថ្មីរៀបចំជាផែនការបានល្អក៏ដោយ ក៏ត្រូវមានវិធានការប៉ះប៉ូវលើសពីពេលបញ្ចប់រយៈកាលតាំងទីលំនៅថ្មីផងដែរ ដើម្បីដោះស្រាយចំពោះបញ្ហាទាំងឡាយ ដែលមិនទាន់បានដោះស្រាយសមរម្យ ។ នៅក្រោមច្បាប់នេះ គម្រោងវារីអគ្គិសនីនិងគម្រោងរក្សាទឹក ត្រូវតែបង្កើតឡើងនូវមូលនិធិគាំទ្រនៅដំណាក់កាលបន្ទាប់ទៀត

ដើម្បីជួយដល់អ្នកតាំងទីលំនៅថ្មីឲ្យរៀបចំប្រព័ន្ធបង្កបង្កើតផល និង ដោះស្រាយបញ្ហាធំៗមួយចំនួនទៀត។ មូលនិធិនេះ ត្រូវបានបង្កើតឡើងសម្រាប់រយៈពេល១០ឆ្នាំ និង ត្រូវបានផ្តល់ហិរញ្ញវត្ថុពីការលក់ថាមពលជាមួយនឹងមូលនិធិដែលផ្តល់ជូនឈរលើមូលដ្ឋាននៃអត្រាអតិបរមាដែលបានអនុញ្ញាត។

បទបញ្ជាការចុងក្រោយបំផុតស្តីពីការគាំទ្រចំពោះក្រោយការតាំងលំនៅថ្មី ត្រូវបានចេញនៅក្នុងឆ្នាំ២០០៦។ ចំពោះអ្នកដែលបានតាំងទីលំនៅថ្មីមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ អាចទទួលបានឧបត្ថម្ភចំនួន៦០០យ៉ុន ក្នុងមួយនាក់ ក្នុងមួយឆ្នាំ (ប្រហែល១០០ដុល្លារសហរដ្ឋអាមេរិក) សម្រាប់រយៈពេល២០ឆ្នាំ។ ចំនួននៃអ្នកតាំងទីលំនៅមុនកាលបរិច្ឆេទនេះនឹងត្រូវបានបញ្ជាក់ជាថ្មីម្តងដោយរដ្ឋាភិបាល និង ត្រូវបានរៀបចំទុកដាក់។ អាជ្ញាធរមូលដ្ឋាននឹងកំណត់អត្តសញ្ញាណបុគ្គលដែលមានសិទ្ធិទទួលបានការឧបត្ថម្ភធននេះ ។ ចំពោះអ្នកតាំងទីលំនៅដែលបានផ្លាស់ទីក្រោយថ្ងៃទី១ ខែកក្កដាឆ្នាំ២០០៦ នឹងទទួលបានការឧបត្ថម្ភធនក្នុងតម្លៃដូចគ្នាសម្រាប់រយៈពេល២០ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ទីរបស់ពួកគេ ។ ឧបត្ថម្ភធនក៏អាចត្រូវបានប្រើសម្រាប់គម្រោងអភិវឌ្ឍន៍ រួមជាមួយនឹងការរៀបចំផែនការល្អិត សម្រាប់ទ្រទ្រង់ក្រោយការតាំងលំនៅថ្មី ដោយផ្អែកលើការពិគ្រោះយោបល់យ៉ាងទូលំទូលាយ។

៦.៣.៥ ការបង្កើតភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន

សំណុំបែបបទនៃការបែងចែងផលប្រយោជន៍ដែលអាចធ្វើទៅបានប្រកបដោយភាពច្នៃប្រឌិតបំផុត គឺការបង្កើតឲ្យមានការមានភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ កិច្ចព្រមព្រៀងភាពជាដៃគូអាចធ្វើឡើងក្នុងទម្រង់ជាច្រើនដោយអាស្រ័យលើអាទិភាពនៃការអភិវឌ្ឍសហគមន៍មូលដ្ឋាន។ កិច្ចព្រមព្រៀងនេះ អាចពាក់ព័ន្ធជាផ្នែក ឬទាំងស្រុងជាមួយភាពជាម្ចាស់របស់សហគមន៍នៃទំនប់ ឬគម្រោង វារីអគ្គិសនី ឬមូលនិធិអភិវឌ្ឍន៍សហគមន៍។

សម្រាប់អ្នកអភិវឌ្ឍ ភាពជាដៃគូមួយអាចផ្តល់នូវការធានាលើការយល់ព្រមពីសហគមន៍មូលដ្ឋានលើគម្រោងនោះ ដោយហេតុថាអាចកាត់បន្ថយកម្រិតនៃហានិភ័យ និងថ្លៃចំណាយលើការសិក្សាស្រាវជ្រាវដែលអូសបន្លាយពេល និងការចំណាយលើដំណើរការនៃលិខិតអនុញ្ញាត។ សម្រាប់សហគមន៍កមូលដ្ឋាន ភាពជាដៃគូ គឺជាការទទួលស្គាល់សិទ្ធិទទួលបានរបស់ពួកគេ ចំពោះការបែងចែកតម្លៃឈ្នួលសេដ្ឋកិច្ច ដែលបានពីទំនប់ ក៏អំណាចចរម្រេចលើការគ្រប់គ្រងធនធានទឹកក្នុងមូលដ្ឋាន។

- ភាពជាដៃគូ៖
  - ផ្តល់ប្រភពមូលនិធិរយៈពេលវែង។
  - ជម្រុញឲ្យអង្គភាពមូលដ្ឋាន និងតំបន់ទទួលអាចកំណត់អាទិភាពរបស់ខ្លួន និងអាចកាត់បន្ថយការពឹងអាស្រ័យរបស់ខ្លួនលើអ្នកអភិវឌ្ឍ និងលើរដ្ឋ។
  - ជួយសម្របសម្រួលដល់ការគ្រប់គ្រងដែលអាចផ្លាស់ប្តូរបាន។

ប្រអប់អត្ថបទ ៦.១២ គម្រោងវារីអគ្គីសនី Minashtuk: យុទ្ធសាស្ត្រភាពជាដៃគូរបស់ Hydro-Québec ជាមួយសហគមន៍អ្នកស្រុកដើម

Hydro-Québecគឺក្រុមហ៊ុនផលិតអគ្គិសនីមួយ និងជាក្រុមចែកចាយដ៏ធំរបស់អាមេរិចខាងជើង ដែលគ្រប់គ្រងដោយរដ្ឋាភិបាល Quebec នៃប្រទេសកាណាដា។ នៅក្រោមផែនការយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ឆ្នាំ១៩៩៨-២០០២ Hydro-Québec បានកំណត់ល័ក្ខខ័ណ្ឌចាំបាច់ចំនួន៣ ដែលត្រូវតែធ្វើឲ្យសម្រេចបាន ដើម្បីអនុវត្តគម្រោងថ្មីណាមួយ ៖

(ក) គម្រោងនោះត្រូវតែបានផលចំណេញនៅក្រោមល័ក្ខខ័ណ្ឌទីផ្សារ (ខ) គម្រោងនោះត្រូវតែអនុវត្តស្របតាមលក្ខណៈបរិស្ថាន ផ្អែកតាមគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិង (គ) គម្រោងនោះត្រូវតែត្រូវបានទទួលបានយ៉ាងល្អពីសហគមន៍មូលដ្ឋាន។ គម្រោងវារីអគ្គីសនី Minashtuk ត្រូវបានអនុវត្តនៅលើទន្លេ Mistassibi និងត្រូវបានបិតបញ្ចប់ក្នុងឆ្នាំ២០០០។គម្រោងនេះ ត្រូវបានបង្កើតឡើងក្នុងគោលដៅចម្បងគឺសម្រាប់បង្កើតវារីអគ្គិសនី ។ គម្រោងនេះបានបង្កើតជាប្រភេទនៃយន្តការបែងចែកផលប្រយោជន៍សមធម៌ ដែលត្រូវបានប្រើប្រាស់នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងភាពជាដៃគូមួយរវាងសហគមន៍ម៉ុតាញ៉ាដែលរស់នៅតាមតំបន់ LAC Saint Jean និងតំបន់គម្រោង Hydro-Québec ។ កត្តាកំណត់ជោគជ័យមួយសម្រាប់ប្រភេទនៃយន្តការនេះ គឺជាសមត្ថភាពរបស់សហគមន៍មូលដ្ឋានក្នុងការបណ្តាក់ទុន និងការខ្ចីមូលនិធិ។ នៅក្នុងករណីគម្រោង Minashtuk ទម្រង់នៃភាពជាដៃគូដែលមានកម្រិតរបស់ក្រុមហ៊ុនដែលត្រូវបានប្រើប្រាស់ដើម្បីអភិវឌ្ឍគម្រោង និងការប្តេជ្ញាចិត្តរបស់ Hydro-Québec ក្នុងការទិញអគ្គិសនីទាំងអស់ដែលផលិតបានពីគម្រោងក្រោមកិច្ចសន្យារយៈពេល២០ឆ្នាំ ដែលបានផ្តល់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់សហគមន៍មូលដ្ឋាន ក្នុងការខ្ចី និងបណ្តាក់ទុន។

៦.៥.៣.១ ប្រភេទនៃយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ

ប្រភេទនៃយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ រួមបញ្ចូលទាំងការចែករំលែកប្រាក់ចំណូលមូលនិធិអភិវឌ្ឍន៍ ការចែករំលែកដោយសមភាព (រួមបញ្ចូលទាំងភាពជាម្ចាស់ពេញលេញ) ពន្ធអចលនទ្រព្យ និងអត្រាតម្លៃអគ្គិសនីដែលនិយមពេញចិត្ត។

ការចែករំលែកប្រាក់ចំណូល

ការចែករំលែកប្រាក់ចំណូលតាមរយៈពន្ធលើប្រាក់ចំណូលឬការបង់តម្លៃសិទ្ធិ ត្រូវបានគេអនុវត្តជាញឹកញាប់ដើម្បីចាប់យកតម្លៃឈ្នួលសេដ្ឋកិច្ចមួយចំនួនដែលបានពីទំនប់ និងគម្រោងវារីអគ្គិសនី។ ដោយសារការវាស់វែងពិតប្រាកដលើតម្លៃឈ្នួលបែបនេះជារឿយៗមានការលំបាក ទើបការចែករំលែកប្រាក់ចំណូលមានគោលដៅត្រឹមតែចាប់យកយ៉ាងហោចណាស់តម្លៃឈ្នួលមួយចំនួន ដោយគ្មានការវាស់វែងជាក់លាក់នោះទេ។

យន្តការចែករំលែកប្រាក់ចំណូលអាចហុចផលពីការចរចារវាងអាជ្ញាធរមូលដ្ឋាន ឬក្នុងតំបន់ និងស្ថានិកទំនប់ /ឬអ្នកគាំទ្រឬប្រតិបត្តិករវារីអគ្គិសនី។ យន្តការនេះក៏អាចត្រូវបានកំណត់ក្នុងច្បាប់ផងដែរ។ នៅក្នុងករណីក្រោយមកទៀត ភាគរយនៃប្រាក់ចំណូលដែលបានផ្ទេរទៅឱ្យអ្នកទទួលផលក្នុងតំបន់ឬក្នុងមូលដ្ឋាន និងទិសដៅនៃការដំណើរការនេះ ជាទូទៅត្រូវបានបញ្ជាក់រួចជាស្រេចហើយ។

មូលនិធិអភិវឌ្ឍន៍

មូលនិធិអភិវឌ្ឍន៍ ឧទាហរណ៍មូលនិធិបានពីហិរញ្ញប្បទានពីការលក់ថាមពល និងការយកកម្រៃពីទឹក អាចត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រាក់ធ្វើជាដើមទុនសម្រាប់ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ពីគម្រោង។

ការបែងចែកដោយសមធម៌ ឬភាពជាម្ចាស់ពេញលេញ

យន្តការខុសគ្នាៗមួយចំនួន អាចអនុញ្ញាតឱ្យសហគមន៍មូលដ្ឋាន ឬ ថ្នាក់តំបន់ធ្វើជាម្ចាស់មួយផ្នែកឬយ៉ាងពេញលេញទៅលើទំនប់ ឬគម្រោងវារីអគ្គិសនី។ ដូចនេះ អាជ្ញាធរមូលដ្ឋាន ត្រូវចែករំលែកគ្នាទាំងហានិភ័យនានា និងប្រាក់ចំណេញបែបយថាការណ៍។ លើសពីនេះទៀត នៅក្នុងករណីខ្លះ អាជ្ញាធរមូលដ្ឋានអាចនឹងទទួលបាននូវការត្រួតពិនិត្យមួយកម្រិតលើការរចនា និងប្រតិបត្តិការនៃគម្រោងមួយ។

ពន្ធអចលនទ្រព្យ

គួរពិចារណាចំពោះពន្ធពីរប្រភេទសំខាន់ដែលត្រូវបង់ទៅឱ្យអាជ្ញាធរក្នុងតំបន់ ឬ តាមមូលដ្ឋាន។ នៅក្នុងប្រទេសមួយចំនួន រដ្ឋអនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋាន ឬ ថ្នាក់តំបន់យកពន្ធដោយផ្អាល់ពីម្ចាស់ទំនប់លើតម្លៃអចលនទ្រព្យនៃទំនប់ ឬតាមគោលការណ៍ផ្សេងទៀត។ ពន្ធដែលត្រូវបង់ទៅអាជ្ញាធរក្នុងតំបន់ និងមូលដ្ឋានក៏អាចត្រូវបានកំណត់ក្នុងច្បាប់រដ្ឋ ជួនពេលខ្លះត្រូវបង់ជាភាគរយលើការលក់គម្រោង ឬលើប្រាក់ចំណូលសុទ្ធសាធ។ នៅក្នុងករណីក្រោយមក យន្តការនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងការចែករំលែកប្រាក់ចំណូលដែរ។

អត្រាតម្លៃអគ្គីសនីដែលជាការនិយមពេញចិត្ត

យន្តការនេះគឺជាទម្រង់នៃការចែករំលែកប្រាក់ចំណូលមួយ នៅពេលដែលការរកប្រាក់ចំណូលបានតិចតួចសម្រាប់ម្ចាស់ទំនប់ និងនៅក្នុងលក្ខណៈនៃការចំណាយដែលអាចជៀសវាងសម្រាប់អ្នកទទួលផល។

ដើម្បីធ្វើឲ្យការបែងចែកផលប្រយោជន៍មានប្រសិទ្ធភាពប្រកបដោយយុត្តិធម៌ និងដោយតម្លាភាព ត្រូវកំណត់ឲ្យបានច្បាស់ពីអត្តសញ្ញាណភាគីពាក់ព័ន្ធ នៅមុនដំណើរការរៀបចំជាផែនការ និងការព្រមព្រៀងលើការអភិវឌ្ឍ ព្រមទាំងទទួលស្គាល់ពីផលប្រយោជន៍ស្របច្បាប់របស់ភាគីពាក់ព័ន្ធទាំងនោះ ក៏ដូចជាការយកចិត្តទុកដាក់នៅក្នុងដំណើរការវាយតម្លៃផ្នែកហិរញ្ញវត្ថុ និង សេដ្ឋកិច្ច ។ ប្រការនេះតម្រូវឱ្យមានចំនុចដូចខាងក្រោម ៖

- កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានតុល្យភាព ក្នុងករណីនៃគម្រោងផ្តល់មូលនិធិជាលក្ខណៈឯកជន។

- ការផ្តល់ត្រឡប់វិញដោយសមរម្យលើសមធម៌ ស្របជាមួយនឹងទម្រង់បែបហានិភ័យ និងបទដ្ឋានអន្តរជាតិ។
- តម្លាភាពក្នុងដំណើរការលទ្ធកម្ម។
- កិច្ចសន្យាដោយមានការចរចាគ្នាដោយផ្ទាល់ អាស្រ័យលើសវនកម្មឯករាជ្យ។
- ការបន្តធ្វើសវនកម្ម/ការត្រួតពិនិត្យលើដំណើរការសេដ្ឋកិច្ចផ្ទាល់នឹងអត្ថប្រយោជន៍របស់គម្រោង។ (ប្រភព ៖ សមាគមវារីអគ្គិសនីអន្តរជាតិ គោលការណ៍ណែនាំស្តីពីនិរន្តរភាព ខែកុម្ភៈ ឆ្នាំ ២០០៤) ។

៦.៥.៣.២ ករណីសិក្សាលើយន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ

តារាងទី៦.២ មានបង្ហាញពីឧទហរណ៍ ដែលពន្យល់អំពីយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ដែលបានអនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកធំៗមួយចំនួន ។ ប្រអប់នៅក្នុងតារាងនោះរួមមានមតិយោបល់ឆ្លើយតបចំពោះឧទាហរណ៍នានាដោយមានការពន្យល់ជាពិសេសឲ្យបានដឹងជាព័ត៌មាន។

ប្រអប់អត្ថបទ 6,13 យន្តការទទួលបានអត្ថប្រយោជន៍ការចែករំលែក-រូបិយវត្ថុ - ទិដ្ឋភាពសោ
យន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ជាប់ទាក់ទងជាមួយសហគមន៍រងផលប៉ះពាល់ក្នុងការចែករំលែកចំណែកនៃលំហូររូបិយវត្ថុដែលបានពីប្រតិបត្តិការទំនប់។ ប្រព័ន្ធបែងចែកផលប្រយោជន៍រូបិយវត្ថុ មានគោលបំណងសំខាន់៣យ៉ាង គឺដើម្បី ៖ • ផ្តល់សំណងរយៈពេលវែងបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង។ បង្កើតជាមូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលវែងនៅក្នុងតំបន់។ • បង្កើតភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។

ប្រធានបទពិភាក្សា	ចូរពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ …….. ចូរពិភាក្សាអំពីឱកាស និងឧបសគ្គនានាដែលបានផ្សារភ្ជាប់ជាមួយនឹងការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ។ …… ចូរធ្វើការវិភាគលើច្បាប់របស់ប្រទេសអ្នក និង ពិភាក្សាអំពីថាតើត្រូវ ឬ មិនត្រូវឲ្យមានបទប្បញ្ញត្តិ ដែលនឹងអនុញ្ញាតឱ្យការបែងចែកផលប្រយោជន៍ ជា

	រូបិយវត្ថុកើតមានឡើងនៅក្នុងប្រទេសរបស់អ្នក និងស្ថិតនៅក្រោមកាល:ទេស: បែបណា។
លំហាត់	តាមរយៈប្រព័ន្ធបែងចែកផលប្រយោជន៍ជារូបិយវត្ថុដែលបានបង្ហាញនៅក្នុងម៉ូឌុលនេះ ចូរជ្រើសរើសឧទហរណ៍ចំនួន៣ និងពិពណ៌នាអំពី លក្ខណៈរបស់វា។

តារាងទី៦.២ ករណីសិក្សាលើយន្តការនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ

ក្របខ័ណ្ឌបទដ្ឋាន	**គម្រោងទំនប់វារីអគ្គិសនី**	**ការចែករំលែកប្រាក់ចំណូល**	**មូលនិធិអភិវឌ្ឍន៍**	**ការចែករំលែកដោយសមធម៌**	**ពន្ធអចលនទ្រព្យ**	**អត្រាអគ្គីសនីតាមការនិយមចង់បាន**
ច្បាប់ស្តីពីការផ្ទេរប្រាក់ចំណូល (ប្រេស៊ីល)	អ៊ីតៃពុ (Itaipu) ទសវត្សទី៨០					
ច្បាប់ស្តីពីការផ្ទេរប្រាក់ចំណូល (កូឡុំប៊ី)	អ៊ុយរ៉ា១ Urra1 (២០០០ឆ្នាំ)					
PROHA (Ecuador)	ជិនដាឈិ (Jondachi) ផែនការជាជំហាន					
ច្បាប់ស្តីពីប្រភពធនធានថាមពលនិងទឹក (ប្រទេសន័រវែស)	ក្លូម៉ា និងឡាហ្គិន Glomma and Laagen (ទសវត្សរ៍ទី៧០) Tokke (ឆ្នាំ១៩៦០)	យន្តការច្រើនយ៉ាង: កម្រៃអាជ្ញាប័ណ្ណ ពន្ធលើប្រាក់ចំណេញ។ល។				ការបែងចែកចំណែកផលិតផលអគ្គិសនីទៅដល់អាជ្ញាធរមូលដ្ឋានតាមតម្រូវការដោយមិនគិតប្រាក់ចំណេញ
អង្គភាពគ្រប់គ្រងអាងទន្លេកូឡុំប៊ី (ប្រទេសកាណាដា)	ដាន់កាន់ Duncan (១៩៦៨) គីលីសាយ		វិធានការដែលមានចែងជាក់លាក់ស្តីពី			

	Keenleyside (ឆ្នាំ ១៩៦៩) និង មីកា Mica (ឆ្នាំ១៩៧៥)		តម្លៃឈ្នួលសេដ្ឋកិច្ច។ ការចូលរួមរបស់សហគមន៍ ឬអង្គការនានា			
Hydro-Québec វិធីសាស្ត្រ ស្តីពីភាពជាដៃគូ (ប្រទេសកាណាដា)	មីណាស្តុគ Minashtuk (ឆ្នាំ ២០០០)			សហគមន៍មូលដ្ឋាន គឺជាម្ចាស់ភាគហ៊ុនសំខាន់។ កិច្ចព្រមព្រៀងជាវអគ្គិសនីរយៈពេលវែង		
Hydro-Québec វិធីសាស្ត្រ ស្តីពីភាពជាដៃគូ (ប្រទេសកាណាដា)	ទូលនុយស្តូក (Toulnustouc) (២០០៥)					
កិច្ចព្រមព្រៀង Paix des Braves (Québec ប្រទេសកាណាដា)	Eastmain-1, Eastmain-1A និង Rupert Diversion (ឆ្នាំ ២០១១)					
មូលនិធិអភិវឌ្ឍន៍ក្រោយការតាំងលំនៅថ្មី (ប្រទេសចិន)	ទំនប់ស៊ុយគូ (Shuikou) ឆ្នាំ១៩៩៦		ច្បាប់ចូលជាធរមានចាប់តាំងពីឆ្នាំ ១៩៨១			
កម្មវិធីអភិវឌ្ឍន៍តំបន់ភាគខាងលិច (ប្រទេសចិន)	ដុងពីង ខេត្តណាជីតាន់សុងស៊ុយលីង និងស៊ាវគូ ក្រុមទី១: (ឆ្នាំ២០០៥)					
ច្បាប់ស្តីពីការផ្ទេរប្រាក់ចំណូល (ប្រទេស	ហ្គាលីកាន់ដាគី Kali Gandaki (២០០២)					

នេប៉ាល់)						
មូលនិធិLesotho សម្រាប់ការអភិវឌ្ឍន៍សហគមន៍	គម្រោងទឹកនៅតំបន់មានភ្នំខ្ពស់ Lesotho (ឆ្នាំ២០០៥)					
គន្លឹះ ៖						
ការអនុវត្តយន្តការគោលនយោបាយផ្តល់សំណង						
សេចក្តីពន្យល់ សមហេតុផលបំផុតនៃយន្តការ គោលនយោបាយផ្តល់សំណង						

៦.៦ តម្លៃឈ្នួលសេដ្ឋកិច្ច និងឧបសគ្គផ្នែកហិរញ្ញវត្ថុ

គោលបំណង	គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីទាញចំណាប់អារម្មណ៍ សិក្ខាកាមទៅលើទិដ្ឋភាពទាក់ទងនឹងតម្លៃឈ្នួលសេដ្ឋកិច្ច និងឧបសគ្គ ហិរញ្ញវត្ថុ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់ដឹងអំពីរបៀបដែលតម្លៃឈ្នួលសេដ្ឋកិច្ច លេចចេញនៅក្នុងកាល:ទេស:ជាក់លាក់ និងរបៀបដែលនាំឲ្យស្គាល់ពីឧបសគ្គសេដ្ឋកិច្ច។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ។ ឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសដែលអាចជំនួសបាន។ ផ្នែកទី៥: គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់លើយន្តការនៃការបែងចែកផលប្រយោជន៍)។ www.unep.org/dams
	Égré, Dominique, Vincent Roques និង Carine Durocher (២០០៨) ការចែករំលែកផលប្រយោជន៍ដើម្បីបន្តែមសំណងនៅក្នុងសកម្មភាពរុករកធនធាន ៖ ករណីនៃទំនប់នានា នៅសៀនៀ)Cernea(, M. , M និង Hari Mohan Mathur (eds.) តើការទូទាត់សំណងអាចទប់ស្កាត់ភាពក្រីក្រ ដុនដាបដែរឬទេ? ការធ្វើកំណែទម្រង់ការតាំងលំនៅថ្មីតាមរយៈ: ការវិនិយោគនិងការបែងចែកផលប្រយោជន៍ (ទំព័រទី៣១៧ ដល់៣៥៦)។ ការបោះពុម្ពផ្សាយរបស់សកលវិទ្យាល័យអ័កស្វ័ត Oxford។

ការបែងចែងផលប្រយោជន៍ជារូបិយវត្ថុ គឺអាស្រ័យលើការសន្និដ្ឋានថាទំនប់ និងគម្រោងផ្សេងទៀតអាច រកប្រាក់កម្រៃឈ្នួលសេដ្ឋកិច្ចបានច្រើនដែលអាចចែករំលែកគ្នាបានជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ។ ប្រាក់ឈ្នួលសេដ្ឋកិច្ចនេះ គឺជាផលលើសបានត្រឡប់វិញពីការលើសនៃផលទុនជាធម្មតាដែលបានត្រឡប់មកវិញ ។ ប្រាក់ឈ្នួលនេះលេចឡើង ដោយសារតែក្រុមហ៊ុននេះបានធ្វើអាជីវកម្មលើធនធានធម្មជាតិ ដែលជាទីពឹងអាស្រ័យរបស់ការអភិវឌ្ឍស្របតាមល័ក្ខខ័ណ្ឌទីតាំងជាក់លាក់ផ្នែកធារាសាស្ត្រ ហានលេខសាស្ត្រ និងភូមិសាស្ត្រ។ នៅទីកន្លែងណាដែលធនធានធម្មជាតិទាំងនេះ ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈ នោះរដ្ឋាភិបាលត្រូវដើរតួនាទីជំនួសឲ្យសាធារណជន ដែលអាចព្យាយាមចាប់យកប្រាក់

ឈ្នួលតាមរយៈការបង់ថ្លៃសិទ្ធិ ការបង់ថ្លៃផ្សេងៗ ឬ យន្តការផ្សេងទៀត រួចផ្តល់ត្រឡប់វិញនូវផលប្រយោជន៍ទៅដល់សាធារណជន។

ប្រាក់ឈ្នួលសេដ្ឋកិច្ច គឺជាការអនុវត្តទូទៅនៅក្នុងវិស័យប្រេងនិងឧស្ម័ន ព្រៃ ព្រៃឈើ និងការនេសាទ ប៉ុន្តែកម្រអនុវត្តនៅក្នុងវិស័យថាមពលវារីអគ្គីសនីណាស់ ។ នៅក្នុងវិស័យនេះ រដ្ឋាភិបាលជាធម្មតា ត្រូវដាក់ចេញនូវតារាងតម្លៃពន្ធនៅក្នុងលក្ខណៈដែលលំហូរប្រាក់ឈ្នួល ដែលបានផលពីអ្នកប្រើប្រាស់ភ្លើងអគ្គិសនីក្នុងទម្រង់ជាតារាងតម្លៃពន្ធដែលមានចំនួនទាបជាងនេះ ។ អ្នកដែលប្រើប្រាស់ភ្លើងអគ្គិសនីកាន់តែច្រើននឹងត្រូវបង់ថ្លៃឈ្នួលកាន់តែច្រើនបន្ថែមទៀត។ ដោយឡែកលក្ខខ័ណ្ឌនៅក្នុងទីផ្សារ ការនាំចេញ ទំនិញ ការបង់ថ្លៃឈ្នួលមួយចំនួន ក៏ត្រូវអនុវត្តចំពោះអតិថិជនជាជនបរទេសផងដែរ។

ស្ថានភាពស្រដៀងគ្នានេះដែរ គឺការអនុវត្តចំពោះករណីនៃការប្រើទឹកស្អាតផ្សេងទៀត ដែលអាចធ្វើទៅបានតាមរយៈទំនប់។ ការស្រោចស្រព ការផ្គត់ផ្គង់ទឹក និងថ្លៃឈ្នួលលើវិស័យនាវាចរណ៍ ឆ្លុះបញ្ចាំងពីការចំណាយ ជាក់ស្តែងដ៏សមរម្យបំផុតនៃទំនប់នោះ។ នៅក្នុងករណីនៃការគ្រប់គ្រងទឹកជំនន់ ប្រជាពលរដ្ឋដែលទទួលផលពីអាងស្តុកទឹក ជាទូទៅមិនចាំបាច់បង់ប្រាក់សម្រាប់ផលប្រយោជន៍នោះទេ។

ការពិចារណាដែលប្រព្រឹត្តិតាមក្រមសីលធម៌ អាចផ្តល់ត្រឹមត្រូវថា ចំណែកនៃថ្លៃឈ្នួលត្រូវបានគេបញ្ជូនទៅកាន់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ។ ជាការពិតណាស់ នៅក្នុងករណីជាច្រើន ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង បានលះបង់នូវលទ្ធភាពទទួលបាន និង លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីរួមចំណែកដល់ការអភិវឌ្ឍគម្រោង។

ការបែងចែកថ្លៃឈ្នួលសេដ្ឋកិច្ច ក៏អាចត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់មូលនិធិអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែងនៅក្នុងតំបន់ និងដើម្បីបង្កើតភាពជាដៃគូរវាងអ្នកអភិវឌ្ឍន៍ និងសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោង។ ក្នុងវិធីនេះ ការចែករំលែកថ្លៃឈ្នួលសេដ្ឋកិច្ច បានក្លាយជាការផ្តល់សំណងបន្ថែមសម្រាប់ប្រើ ដោយជៀសមិនរួចនូវធនធានធម្មជាតិពីសំណាក់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីគម្រោង។

ថ្លៃឈ្នួលសេដ្ឋកិច្ចដែលបានពីគម្រោងទំនប់ គឺមានការលំបាកក្នុងការវាស់វែង ហើយយន្តការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ជាទូទៅចាប់យកបានតែថ្លៃឈ្នួលមួយចំនួនដោយមិនមានការវាស់វែងឡើយ។ ទោះជាយ៉ាងណា អ្វីដែលត្រូវការចាំបាច់ដើម្បីចែករំលែកប្រយោជន៍ ថ្លៃសេដ្ឋកិច្ចជាអត្ថិភាព ដែលមានទាំងអប្បាមាណ គឺជាការវាស់វែងលើទម្រង់ជាមូលដ្ឋានសម្រាប់កំណត់ពីអ្វី ដែលអាចចែករំលែកបានខ្លះជាមួយប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីគម្រោងនេះ ។ ទោះបីជាអត្ថិភាពថ្លៃឈ្នួលសេដ្ឋកិច្ចអាចត្រូវបានបង្ហាញឲ្យឃើញ និង ត្រូវបានវាស់វែងក៏ពិតមែន ក៏មិនមែនមានន័យថាលំហូររូបិយប័ណ្ណពីការប្រតិបត្តិការទំនប់អាចបើកឱកាសឲ្យមានការបែងចែកផលប្រយោជន៍សារជាថ្មី ដោយឯករាជ្យទៅតាមស្ថានភាពហិរញ្ញវត្ថុខ្លះនោះដែរ។ ប្រការនេះអាចកើតឡើងនៅក្នុងស្ថានភាពដូចជាអត្រាតម្លៃអគ្គិសនីមិនបានគ្របដណ្តប់លើការ

ផ្គត់ផ្គង់ការចំណាយពិតប្រាកដនៃថាមពលផលិតបាន ដែលជាហេតុធ្វើឲ្យការផ្ទេរផលប្រយោជន៍ត្រូវផ្អែកលើចំនួនភាគរយនៃប្រាក់ចំណូលដែលជាលទ្ធផលនៃការខាតបង់ផ្អែកហិរញ្ញវត្ថុសម្រាប់ម្ចាស់ទំនប់ ឬ ថ្លៃឈ្នួលប្រព័ន្ធធារាសាស្ត្រដែលមិនបានទូទាត់មកវិញលើការចំណាយដើមទុន។ ឧបត្ថម្ភធនរបស់រដ្ឋាភិបាល អាចត្រូវបានប្រើ ដើម្បីធ្វើឲ្យមានតុល្យភាពនៃលំហូរហិរញ្ញវត្ថុនៅពេល ដែលឧបត្ថម្ភធនទាំងនោះមានហេតុផលត្រឹមត្រូវដោយឈរលើមូលដ្ឋាននៃការវិភាគសេដ្ឋកិច្ចមួយ ជាឧទាហរណ៍នៅពេលមានការបង្ហាញថា ផលប្រយោជន៍នៃការគ្រប់គ្រងទឹកជំនន់មានចំនួនលើសពីផលទុន និង ការចំណាយលើការប្រតិបត្តិរបស់ទំនប់ (ដែលមិនមានចំនួនកើនឡើងសម្រាប់ម្ចាស់ទំនប់ទេ ប៉ុន្តែផលប្រយោជន៍ទាំងនោះគឺមានពិតប្រាកដសម្រាប់សង្គម និងអាចជាផលប្រយោជន៍ធំទៀតផង) ។ ចំនួនទឹកប្រាក់ចំណេញសរុបដែលកើនឡើងសម្រាប់ម្ចាស់ទំនប់ និងចំនួនផលប្រយោជន៍ដែលកើនឡើង ឬ ប្រាក់ឈ្នួលនៃការប្រើប្រាស់ទឹក ដែលប្រមូលបានដោយរដ្ឋាភិបាលមិនត្រូវមានចំនួនលើសពីថ្លៃឈ្នួលសេដ្ឋកិច្ចឡើយ។ នៅក្នុងការអនុវត្តជាក់ស្តែង មានឧទាហរណ៍មួយចំនួនដែលបង្ហាញអំពីការវាស់វែង ដែលមានចែងយ៉ាងចែងយ៉ាងជាក់លាក់អំពីថ្លៃឈ្នួលសេដ្ឋកិច្ច ។ ការផ្ទេរប្រាក់ចំណូលតាមរយៈពន្ធលើប្រាក់ចំណូល ឬ របបនៃការបង់ថ្លៃលើសិទ្ធិដែលពេញលេញ ឬការទទួលស្គាល់ជាក់ស្តែងអំពីអត្ថិភាពនៃថ្លៃឈ្នួលសេដ្ឋកិច្ច។ ការចែករំលែកត្រឡប់វិញដោយស្មើភាពគ្នា មិនតម្រូវឱ្យមានការវាស់វែងជាក់លាក់លើថ្លៃឈ្នួលសេដ្ឋកិច្ចនោះទេ ប៉ុន្តែការរៀបចំឲ្យមានយន្តការនៃការបែងចែកនេះ គឺផ្អែកលើការសន្មត់ថាគម្រោងនេះនឹងអាចរកប្រាក់ចំណេញ ដែលឆ្លុះបញ្ចាំងយ៉ាងហោចណាស់ក៏ជាចំណែកមួយនៃការបែងចែកនោះដែរ។

ប្រអប់អត្ថបទ៦.១៤ ថ្លៃឈ្នួលសេដ្ឋកិច្ច និងឧបសគ្គផ្អែកហិរញ្ញវត្ថុ - ទិដ្ឋភាពគន្លឹះ
• ថ្លៃឈ្នួលសេដ្ឋកិច្ច គឺជាការត្រឡប់នៃផលលើសដែលមានចំនួនលើសពីផលត្រឡប់ជាធម្មតានៃដើមទុន។ • ប្រាក់ឈ្នួលសេដ្ឋកិច្ចនេះ គឺជាផលលើសបានត្រឡប់វិញពីការលើសនៃផលទុនជាធម្មតា ដែលបានត្រឡប់មកវិញ។ ប្រាក់ឈ្នួលនេះលេចឡើងដោយសារតែក្រុមហ៊ុននេះបានធ្វើអាជីវកម្មលើធនធានធម្មជាតិដែលជាទីពឹងអាស្រ័យរបស់ការអភិវឌ្ឍស្របតាមល័ក្ខខ័ណ្ឌទីតាំងជាក់លាក់ផ្នែកធារាសាស្ត្រ ហានលេខ-សាស្ត្រ និងភូមិសាស្ត្រ។ នៅទីកន្លែងណាដែលធនធានធម្មជាតិទាំងនេះត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈ នោះរដ្ឋាភិបាលត្រូវដើរតួនាទីជំនួសឲ្យសាធារណជន ដែលអាចព្យាយាមចាប់យកប្រាក់ឈ្នួលតាមរយៈការបង់ថ្លៃសិទ្ធិ ការបង់ថ្លៃផ្សេងៗ ឬ យន្តការផ្សេងទៀត រួចផ្តល់ត្រឡប់វិញនូវផលប្រយោជន៍ទៅដល់សាធារណជន។ • ការពិចារណាដែលប្រព្រឹត្តិតាមក្រមសីលធម៌ អាចផ្តល់ត្រឹមត្រូវថា ចំណែកនៃថ្លៃឈ្នួលត្រូវបានគេបញ្ជូនទៅកាន់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង។ ជាការពិតណាស់ នៅក្នុងករណីជាច្រើន ប្រជា-

ពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង បានលះបង់នូវលទ្ធភាពទទួលបាន និង លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីរួមចំណែកដល់ការអភិវឌ្ឍគម្រោង។

ប្រធានបទពិភាក្សា	ថ្លៃឈ្នួលសេដ្ឋកិច្ចលេចឡើង ដោយសារតែក្រុមហ៊ុននេះបានធ្វើអាជីវកម្មលើធនធានធម្មជាតិ ដែលជាទីពឹងអាស្រ័យរបស់ការអភិវឌ្ឍស្របតាមល័ក្ខខ័ណ្ឌទីតាំងជាក់លាក់ផ្នែកធារាសាស្ត្រ ហានលេខសាស្ត្រ និងភូមិសាស្ត្រ។ នៅទីកន្លែងណា ដែលធនធានធម្មជាតិទាំងនេះត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈ នោះរដ្ឋាភិបាលត្រូវដើរតួនាទីជំនួសឲ្យសាធារណជនដែលអាចព្យាយាមចាប់យកប្រាក់ឈ្នួលតាមរយៈការបង់ថ្លៃសិទ្ធិ ការបង់ថ្លៃផ្សេងៗ ឬយន្តការផ្សេងទៀត រួចផ្តល់ត្រឡប់វិញនូវផលប្រយោជន៍ទៅដល់សាធារណជន ។ ចូរពិភាក្សាអំពីភាពខុសគ្នារវាងការផ្តល់ផល-ប្រយោជន៍ "ត្រឡប់ទៅសាធារណជន" និង "ការបែងចែកផលប្រយោជន៍ជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ពីគម្រោង " ។ តើអ្វីទៅជាការជាប់ទាក់ទិនគ្នានៃការគូសបញ្ជាក់ពីវិធីសាស្ត្រមួយទៅវិធីសាស្ត្រមួយទៀត ?
លំហាត់	ចូរកំណត់ឲ្យបានឃើញច្បាស់អំពីឧទាហរណ៍ពីប្រទេសរបស់អ្នក ដែលថ្លៃឈ្នួលសេដ្ឋកិច្ច អាចត្រូវបានអនុវត្តចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធមួយដែលមានទំហំធំ។

៦.៧ ប្រសិទ្ធភាព ការចូលរួម និងគណនេយ្យភាព

គោលបំណង	គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីបង្ហាញពីចំនុចសំខាន់ៗនៃ ប្រសិទ្ធភាព ការចូលរួម និង គណនេយ្យភាព រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាទំនប់វារីអគ្គិសនីនិងសំណង់អគារវារីអគ្គិសនី។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមយល់ដឹងអំពីគោលការណ៍គ្រប់គ្រងចម្បងទាក់ទងនឹង ការទូទាត់សំណង និង ការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ ផ្នែកទី៥ ៖ គោលនយោបាយស្តីពីការទូទាត់សំណង (ផ្តោតសំខាន់លើយន្តការនៃការបែងចែកផលប្រយោជន៍)។ www.unep.org/dams

គោលការណ៍ណែនាំទី២០របស់WCDស្តីពី " យន្តការបែកចែកផលប្រយោជន៍របស់គម្រោង' ចែងថា យន្តការទាំងនេះត្រូវបានសន្មត់ជាគោលការណ៍ថា ប្រជាពលរដ្ឋរងផលប៉ះពាល់មិនល្អ ត្រូវមានសិទ្ធិទទួលបានការបែងចែកផលប្រយោជន៍ពីគម្រោង។ ក្នុងន័យនេះ គោលការណ៍អភិបាលកិច្ច អាចបង្កើតជាមូលដ្ឋានទ្រទ្រង់តម្រូវការនៃការបែងចែកផលប្រយោជន៍ ដើម្បីធានាដល់ចំនុច ដូចខាងក្រោម ៖

- ការធ្វើឲ្យមានភាពស្រុះស្រួលគ្នាលើគោលដៅរបស់ភាគីពាក់ព័ន្ធនានា។
- ប្រសិទ្ធភាពនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុសារជាថ្មី។
- ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការកំណត់បទប្បញ្ញត្តិនៃយន្តការបែងចែកផលប្រយោជន៍។
- គណនេយ្យភាពនៃអង្គភាពទទួលបន្ទុកលើការបែងចែកផលប្រយោជន៍ទាំងនេះ។

៦.៧.១ ការធ្វើឲ្យមានភាពស្រុះស្រួលគ្នាលើគោលដៅរបស់ភាគីពាក់ព័ន្ធនានា

ការកំណត់អត្តន័យពីយន្តការបែងចែកផលប្រយោជន៍ គឺជាភារកិច្ចដ៏សុគស្មាញដែលជាប់ពាក់ព័ន្ធនឹងការសម្រុះសម្រួលផលប្រយោជន៍ គោលដៅ និង គុណតម្លៃរបស់ភាគីពាក់ព័ន្ធទាំង៤ប្រភេទ ដូចខាងក្រោម ៖

- **អ្នកអភិវឌ្ឍន៍។** អ្នកអភិវឌ្ឍន៍នាំមកជាមួយនូវដើមទុន ក៏ដូចជាជំនាញការបច្ចេកទេសនិងការគ្រប់គ្រង ដើម្បីសាងសង់ និងប្រតិបត្តិគម្រោង។ គម្រោងវារីអគ្គីសនីតម្រូវឱ្យមានការវិនិយោគកម្រិតខ្ពស់។ អ្នកអភិវឌ្ឍន៍ត្រូវការពេលវេលានាំមុខមួយរយៈពេលយូរ មុនពេលចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន ហើយរយៈពេលនៃការប្រើប្រាស់ជាធម្មតាពន្យាររហូតដល់ច្រើនទសវត្សរ៍ (៥០ឆ្នាំ ទៅ១០០ឆ្នាំ)។ ដូច្នេះ រយៈពេលសងត្រឡប់វិញ អាចមានរយៈពេលយូរជាងគម្រោងផលិតអគ្គិសនីភាគីច្រើនដទៃទៀត ។ នៅក្រោមល័ក្ខខ័ណ្ឌបែបនេះ យន្តការបែងចែកផលប្រយោជន៍អាចបន្តយហានិភ័យលើកោលាហលសង្គម ស្ថាប័ន និងនយោបាយ នៅក្នុងរយៈពេលវែងដែលនឹងត្រូវបានវាយតម្លៃខ្ពស់ដោយអ្នកអភិវឌ្ឍន៍។ អ្នកអភិវឌ្ឍន៍ក៏នឹងបានពេញចិត្តចំពោះការទទួលយល់ព្រមមួយជាមួយអ្នកចូលរួមគម្រោង ក្នុងពេលកសាងគម្រោង និង ផលប្រយោជន៍គម្រោង នៅមុនពេលដំណើរការកសាងផែនការ ក៏ដូចជាដើម្បីជៀសវាងនូវការចំណាយ និងការខិតខំប្រឹងប្រែងដែលមិនចាំបាច់។
- **អ្នកទទួលផលគម្រោង។** គម្រោងទំនប់ ជារឿយៗគឺជាគម្រោងដែលមានបំណងច្រើនដែលបង្កើតបានជាផលប្រយោជន៍សំខាន់ៗលើសពីបញ្ហា ដែលទាក់ទងទៅនឹងការបែងចែកផលប្រយោជន៍ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ។ អ្នកទទួលផលគម្រោងភាគច្រើនរស់នៅ នៅឆ្ងាយពីតំបន់ទំនប់ និងរំពឹងថានឹងទទួលបានផលប្រយោជន៍ពីសេវាដែលផ្តល់ដោយទំនប់នៅតម្លៃទាបបំផុត ឬកម្រៃសេវាតាមលទ្ធភាព ឬសេវាដោយឥតគិតថ្លៃ។ អ្នកទទួលផលភាគច្រើន មានចំណេះដឹងតិចតួច ឬ គ្មានចំណេះដឹងទាល់តែសោះអំពីផលប៉ះពាល់ក្នុងមូលដ្ឋាន និងក្នុងតំបន់ទាក់ទងទៅនឹងការសាងសង់ និងប្រតិបត្តិការទំនប់។
- **សហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋដែលបំលាស់ទី និងដែលរងផលប៉ះពាល់ពីគម្រោង។** ការសាងសង់ និងប្រតិបត្តិការទំនប់ បានបង្កជាផលប៉ះពាល់ក្នុងកម្រិតច្រើនយ៉ាងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ និងក្នុងមូលដ្ឋាន ដូចជាការប្រើប្រាស់ធនធានទឹក និងធនធានផ្សេងៗទៀត។ លើសពីនេះទៀត វាបានបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋមកពីក្រុមខុសៗគ្នា ដូចជាទាក់ទងនឹងមុខរបរ ប្រាក់ចំណូល គុណតម្លៃ ការអប់រំ ការរៀបចំបង្កើតជាសង្គម។ល។ ដូច្នេះ ប្រភេទរងមួយចំនួនអាចត្រូវបានកំណត់អត្តន័យអាស្រ័យលើការរំពឹងទុក និងអាស្រ័យលើបញ្ហានានាដែលលេចឡើងដោយសារទំនប់ ឬ គម្រោងវារីអគ្គិសនីនោះ ។ ប្រជាសហគមន៍មូលដ្ឋានអាចទាមទារសិទ្ធិទទួលបានការចែករំលែកផលប្រយោជន៍ពីគម្រោង ដោយហេតុថាប្រជាសហគមន៍ទាំងនោះបានរួមចំណែកដល់ការអភិវឌ្ឍគម្រោងដោយការលះបង់ចោល (ដោយស្ម័គ្រចិត្ត ឬមិនមែនស្ម័គ្រចិត្ត) នូវសិទ្ធិទទួលបាន ឬលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់រងផលប៉ះពាល់ពីគម្រោង។

- **រដ្ឋ ។** មានស្ថាប័នជាច្រើនត្រូវជាប់ពាក់ព័ន្ធជាមួយគម្រោងទំនប់វារីអគ្គិសនី ឧទាហរណ៍ ទាក់ទងនឹងការគ្រប់គ្រងលើការប្រើប្រាស់ដី និងធនធាន កម្លាំងពលកម្ម ភ្នាក់ងារសុខាភិបាល ឬ ភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ច ។ លើសពីនេះទៅទៀតរដ្ឋត្រូវទទួលខុសត្រូវដើម្បីបង្កើតឲ្យមានជាគោលការណ៍គតិយុត្តិសម្រាប់ប្រើប្រាស់ធនធានធម្មជាតិ ហើយនៅពេលដែលចាំបាច់ រដ្ឋត្រូវដោះស្រាយចំពោះទុក្ខកង្វល់ដែលកើតមានដោយសារការធ្វើអាជីវកម្មលើធនធានទាំងនេះពីសំណាក់គម្រោង។

៦.៧.២ ការធានាប្រសិទ្ធភាពនៃការបែងចែកផលប្រយោជន៍ជារូបិយវត្ថុសារជាថ្មី

ទាក់ទិនដោយឡែកនឹងច្បាប់ ក្នុងការបង្កើតយន្តការបែងចែកប្រាក់ចំណូលតាមរយៈពន្ធអាករ ឬការបង់តម្លៃសិទ្ធិនានា នីតិវិធីដែលត្រូវប្រើ ដើម្បីផ្ទេរប្រាក់ចំណូលដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង អាចមានជាជំហានៗ មានជាបទប្បញ្ញត្តិ និងការរក្សាការពារ ដើម្បីធានាការសម្រេចបាននូវគោលដៅនៃយន្តការនោះ។ ប្រការនេះអនុវត្តដោយឡែកចំពោះយន្តការដែលសំដៅផ្តល់នូវសំណងរយៈពេលវែងបន្ថែមដល់ប្រជា-ពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។

- ត្រូវបញ្ជាក់ឲ្យបានច្បាស់ពីគោលដៅ ដែលអាចជួយកំណត់បានពីអត្ថន័យលើការប្រើប្រាស់មូលនិធិ។
- ត្រូវបំបែកថវិកាចំណាយ ដែលអាចត្រូវបានបង្កើតឡើងសម្រាប់ប្រភេទនីមួយៗនៃការប្រើប្រាស់។
- ត្រូវផ្តល់ជាជំនួយក្នុងការពង្រឹងសមត្ថភាពស្ថាប័នដល់អាជ្ញាធរ ក្នុងសហគមន៍មូលដ្ឋានដែលពេលខ្លះពុំមានបរិក្ខារគ្រប់គ្រាន់ក្នុងការគ្រប់គ្រងចំនួនថវិកាដ៏ច្រើន និង មិនបានយល់ដឹងពីនីតិវិធីដែលមានលក្ខណៈស្មុគស្មាញ។
- ក្នុងការអនុវត្តជាក់ស្តែង ច្បាប់ស្តីពីការផ្ទេរប្រាក់ចំណូលមិនអាចធានាថា អ្នកដែលទទួលរងផលប៉ះពាល់ដោយសារទំនប់ ពិតជាទទួលបានផលប្រយោជន៍ពីការបង់ប្រាក់ផ្ទេរនោះឡើយ ដោយសារតែមិនអាចឆ្លើយតបជារឿយៗចំពោះលក្ខខ័ណ្ឌចាំបាច់មួយចំនួន។ ចំណែកមូលនិធិ Lesotho សម្រាប់ការអភិវឌ្ឍសហគមន៍ គឺជាឧទាហរណ៍មួយ ។ ផ្ទុយទៅវិញ អង្គភាពគ្រប់គ្រងអាងទន្លេកូឡុំប៊ី ផ្តល់ជាឧទាហរណ៍លើវិធីសាស្ត្រជាច្រើន ដែលអាចបង្កើនប្រសិទ្ធភាពនៃយន្តការចែករំលែកផលប្រយោជន៍ ។ យន្តការទាំងនេះពាក់ព័ន្ធជាពិសេសទៅនឹងគោលបំណងធំទូលាយនៃផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម ដែលផ្នែកទាំងអស់នេះរួមចំណែកដល់ការអភិវឌ្ឍ ប្រកបដោយនិរន្តរភាពនៅក្នុងតំបន់រងផលប៉ះពាល់ពីគម្រោង។ ប្រសិទ្ធភាពនៃយន្តការចែករំលែកផលប្រយោជន៍ ឬការចែករំលែកដោយស្មើភាពគ្នា ជាទូទៅអាស្រ័យលើអត្ថិភាពនៃប្រព័ន្ធរដ្ឋបាលដ៏រឹងមាំ និងប្រព័ន្ធរដ្ឋបាលសាធារណៈដែលជឿនលឿន ដូចជាក្នុងករណីច្បាប់ ទាក់ទងនឹងពន្ធអាករ និងកម្រៃអាជ្ញាប័ណ្ណនៃប្រទេសន័រវេស។

ប្រអប់អត្ថបទ៦.១៥ អង្គភាពគ្រប់គ្រងអាងទន្លេកូឡុំប៊ី ក្នុងប្រទេសកាណាដា

អង្គភាពគ្រប់គ្រងអាងទន្លេកូឡុំប៊ី ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដើម្បីដោះស្រាយលើបញ្ហាសង្គម និងបរិស្ថានដែលបង្កឡើងដោយសារទំនប់ ដែលកំពុងប្រតិបត្តិការនៅក្នុងផ្នែកខ្លះនៃអាងទន្លេកូឡុំប៊ី ក្នុងប្រទេសកាណាដា។ អង្គភាពនេះត្រូវបានបង្កើតឡើងបន្ទាប់ពីមានការប្តឹងតវ៉ាម្តងហើយម្តងទៀតពីសំណាក់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង និង ត្រូវបានបង្កើតឡើងតាមលទ្ធភាពដោយអត្ថិភាពនៃថ្លៃឈ្នួលសំខាន់មួយដែលរកបានពីគម្រោងដែលសាងសង់ឡើងក្រោមក្របខ័ណ្ឌនៃសន្ធិសញ្ញាទន្លេកូឡុំប៊ី ដែលបានចុះហត្ថលេខារវាងប្រទេសកាណាដា និងសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៦១។ ថ្លៃឈ្នួលមួយចំណែកត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់អង្គភាពគ្រប់គ្រងអាងទន្លេកូឡុំប៊ីនេះ។ អង្គភាពនេះផ្តល់ជាឧទាហរណ៍លើវិធីសាស្ត្រជាច្រើន ដែលអាចបង្កើនប្រសិទ្ធភាពនៃយន្តការចែករំលែកផលប្រយោជន៍ ជាពិសេសបទប្បញ្ញត្តិមួយចំនួនសម្រាប់ផ្តល់ការចូលរួមយ៉ាងសកម្មពីអង្គការសហគមន៍នៅក្នុងតំបន់ ដែលរងផលប៉ះពាល់ពីគម្រោង។

គំនូសសម្គាល់៦.២ បង្ហាញពីរបៀបដែលប្រទេសវៀតណាមបានកំណត់ដាក់ចេញនូវការផ្សព្វផ្សាយការយល់ដឹងជាលក្ខណៈប្រព័ន្ធ អំពីការចែករំលែកផលប្រយោជន៍ជាមួយសហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់មិនល្អពីគម្រោងវារីអគ្គិសនី ដោយមានការគាំទ្របច្ចេកទេសពីធនាគារពិភពលោក (ADB) ក្នុងឆ្នាំ២០០៦។ ការផ្សព្វផ្សាយនេះបានឆ្លើយតបចំពោះចម្ងល់នានា ដូចជា (i) តើអ្វីខ្លះជាបទពិសោធន៍លក្ខណៈអន្តរជាតិដែលអាចផ្តល់ជាមេរៀនសម្រាប់ប្រទេសវៀតណាម ? (ii) តើគោលនយោបាយ និង ច្បាប់នាពេលបច្ចុប្បន្នមានវិសាលភាពបែបណាដែលអាចបង្កលក្ខណៈឲ្យមានការចែករំលែកផលប្រយោជន៍ ? និង (iii)តើអ្វីខ្លះដែលត្រូវការជាចាំបាច់ដើម្បីឈានឆ្ពោះទៅមុខទៀត?



ការធ្វើឲ្យមានរចនាសម្ព័ន្ធលើផ្សព្វផ្សាយការយល់ដឹងជុំវិញសកម្មភាព សំដៅធ្វើឲ្យមានលទ្ធផលច្បាស់លាស់ ដូចជាការពិនិត្យឡើងវិញលើគោលនយោបាយ គឺពិតជាមានសារៈសំខាន់សម្រាប់ហេតុផលមួយចំនួន។ នៅក្នុងករណីប្រទេសវៀតណាម ការពិនិត្យឡើងវិញបានបង្ហាញថា ៖

- ច្បាប់ជាតិនៅក្នុងប្រទេសវៀតណាម បានអំពាវនាវរួចទៅហើយសម្រាប់ការបែងចែកផលប្រយោជន៍ទៅតាមវិស័យដទៃទៀត ដូច្នេះហើយទើបបណ្តាលឲ្យមានជាករណីជាយុទ្ធសាស្ត្រផ្នែកច្បាប់ ជាពិសេសសម្រាប់ការចែករំលែកប្រាក់ចំណូល ។ វាមិនមែនជារឿង " ថ្មី " ទេនៅក្នុងន័យនេះ ។
- ការណែនាំបង្ហាញឲ្យស្គាល់ពីការចែករំលែកផលប្រយោជន៍ គឺមានលក្ខណៈស្របដោយឡែកជាមួយនឹងច្បាប់ជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យថាមពល (ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីអគ្គីសនីនិងអន្តរយោងនៅក្នុងច្បាប់ផ្សេងទៀត) ។
- វិធីដ៏ល្អបំផុតដើម្បីណែនាំឲ្យស្គាល់ពីការចែករំលែកផលប្រយោជន៍នោះ គឺការបង្កើតជាច្បាប់អនុក្រឹត្យ (ដែលមានរយៈពេលវែង) មានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងរចនាសម្ព័ន្ធទៅនឹងច្បាប់អនុក្រឹត្យស្តីពីការទូទាត់សំណងសម្រាប់ការតាំងទីលំនៅថ្មី (រយៈពេលខ្លី)។
- ការរៀបចំជាស្តាប័ន ដើម្បីផ្តល់នូវផលប្រយោជន៍ដែលត្រូវការដើម្បីដាក់នៅក្រោមយុត្តាធិការ នៃ គណៈកម្មការប្រជាជនថ្នាក់ខេត្តថ្នាក់ រួមជាមួយនឹងគោលការណ៍ណែនាំពីកម្រិតក្រសួង និង

- វិធីសាស្ត្រដ៏ល្អបំផុតត្រូវបានបញ្ជាក់ ដើម្បីគ្រប់គ្រងការចែករំលែកផលប្រយោជន៍លើទន្លេ ដែលប្រើប្រាស់រួមគ្នារវាងពីរឬច្រើនខេត្តនៅក្នុងប្រទេសវៀតណាម ដោយផ្អែកលើករណីជាយុទ្ធសាស្ត្រតាមវិស័យដទៃទៀត។

ការពិនិត្យឡើងវិញលើគោលនយោបាយ ត្រូវបានបង្ហាញទៅគណៈកម្មការអធិប្បែយ័អន្តរដ្ឋាភិបាលបន្ទាប់មកទៅកាន់កម្រិតសិក្ខាសាលាថ្នាក់ជាតិពហុភាគីពាក់ព័ន្ធ ។ ជំហានទាំងនេះពិតជាបានប្រព្រឹត្តិទៅដើម្បីផ្សព្វផ្សាយការយល់ដឹងមិនត្រឹមតែទៅលើឱកាសនោះទេ ប៉ុន្តែថែមទាំងលើការព្រមព្រៀងមតិលើរបៀបដើម្បីដំណើរការផងដែរ។ លទ្ធផលមួយត្រូវបានជំនួសវិញដោយការបង្កើតជាគោលការណ៍ណែនាំទូទៅសម្រាប់យន្តការបែងចែកផលប្រយោជន៍ នៅក្នុងដំណាក់កាលជាបន្តបន្ទាប់ដែលជា " គោលការណ៍ " ជំនួយបច្ចេកទេស ដែលមានទម្រង់ជាសេចក្តីព្រាងអនុក្រឹត្យ។

៦.៧.៣ ការធានាការចូលរួមរបស់សហគមន៍មូលដ្ឋាន

ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង តម្រូវឲ្យចូលរួមពាក់ព័ន្ធជាពិសេសក្នុងការកំណត់អត្តន័យបទប្បញ្ញត្តិនៃយន្តការបែងចែកផលប្រយោជន៍ ។ បទប្បញ្ញត្តិទាំងនេះត្រូវបានគេពិនិត្យឃើញថាមានលក្ខណៈល្អគ្រប់គ្រាន់សម្រាប់អ្នកដែលទទួលរងផលប៉ះពាល់ ។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងត្រូវបានយកចិត្តទុកដាក់យ៉ាងល្អបំផុតដើម្បីអាចសម្រេចចិត្តបានថា អ្វីដែលអាចធ្វើឱ្យប្រសើរឡើងដល់គុណភាពនៃជីវិតរបស់ពួកគេ ដោយហេតុថាប្រជាជនទាំងនេះមានការយល់ដឹងអំពីសក្តានុពល ក៏ដូចជាឧបសគ្គនៅមូលដ្ឋាន និង នៅក្នុងតំបន់ ។

- ដូច្នេះ ការបែងចែកផលប្រយោជន៍ តម្រូវឲ្យមានការបើកឱកាសឲ្យមានការចូលរួមពីប្រជាពលរដ្ឋពាក់ព័ន្ធ ក្នុងការរៀបចំយន្តការនៃការបែងចែកផលប្រយោជន៍ ។
- ការបែងចែកផលប្រយោជន៍ក៏តម្រូវឲ្យមានការបើកឱកាសឲ្យមានការចូលរួមពីប្រជាពលរដ្ឋពាក់ព័ន្ធ ក្នុងការសម្រេចចិត្តលើការប្រើប្រាស់ចំណែកនៃផលប្រយោជន៍ដែលបានពីគម្រោងទំនប់។
- ការចូលរួមដ៏មានអត្តន័យនៅក្នុងការសម្រេចចិត្តពីសំណាក់ភាគីពាក់ព័ន្ធ អាចរួមចំណែកដល់ការធានាឲ្យប្រាកដថា គម្រោងពិតជាទទួលបានការគាំទ្រពីសាធារណជន។

៦.៧.៤ ការធានាគណនេយ្យភាពរបស់ភ្នាក់ងារទទួលបន្ទុកលើការចែកចាយផលប្រយោជន៍

ចំនួនទឹកប្រាក់សន្ធឹកសន្ធាប់ អាចជាប់ពាក់ព័ន្ធនឹងការបែងចែកផលប្រយោជន៍ជាមួយសហគមន៍មូលដ្ឋាន។ ប្រការនេះលេចចេញជាការព្រួយបារម្ភ ថាលុយទាំងនោះអាចមិនត្រូវបានប្រើប្រាស់ក្នុងលក្ខណៈបម្រុងទុកតាមរយៈកិច្ចព្រមព្រៀងឬ ច្បាប់ដែលពាក់ព័ន្ធ។ លទ្ធភាពនៃការកេងប្រវ័ញ្ច និងអំពើពុករលួយ ក៏ជា

ការព្រួយបារម្ភមួយផងដែរ ។ ដូចនេះ គណនេយ្យភាពរបស់ភ្នាក់ងារទទួលបន្ទុកលើការអនុវត្តការបែងចែកផលប្រយោជន៍សារជាថ្មី គឺជាមូលដ្ឋានមួយដែលតម្រូវឲ្យមានជាចាំបាច់។

ដំណើរការប្រកបដោយតម្លាភាពត្រូវជាប់ពាក់ព័ន្ធនឹងភាគីទាំងអស់ ជាមួយនឹងការប្រកាសបិទជាសាធារណៈលើផលប្រយោជន៍ដែលបានបណ្តាក់ទុន និងសវនកម្មដោយឯករាជ្យ នឹងផ្តល់ជាការធានាអះអាងបន្ថែមទៀតថាដំណើរការរបស់គម្រោងបានប្រព្រឹត្តិទៅយ៉ាងមានប្រសិទ្ធិភាព ត្រង់ថាពិតជាបានផ្តល់ផល-ប្រយោជន៍ទៅដល់សហគមន៍ដែលរងផលប៉ះពាល់ប្រាកដមែន។

អត្ថបទប្រអប់៦.១៦ ប្រសិទ្ធភាព ការចូលរួម និងគណនេយ្យភាព - ទិដ្ឋភាពគន្លឹះ
• គោលការណ៍ណែនាំទី២០របស់WCDស្តីពី " យន្តការបែកចែកផលប្រយោជន៍របស់គម្រោង " ចែងថា យន្តការទាំងនេះត្រូវបានសន្មត់ជាគោលការណ៍ថា ប្រជាពលរដ្ឋរងផលប៉ះពាល់មិនល្អ ត្រូវមានសិទ្ធិទទួលបានការបែងចែកផលប្រយោជន៍ពីគម្រោង។ • ការបែងចែកផលប្រយោជន៍ គឺជាការទទួលខុសត្រូវរបស់ការិយាល័យទទួលបន្ទុកកាត់បន្ថយ និងអភិវឌ្ឍន៍។ • ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង តម្រូវឲ្យចូលរួមពាក់ព័ន្ធជាពិសេសក្នុងការកំណត់អត្តន័យបទប្បញ្ញត្តិនៃយន្តការបែងចែកផលប្រយោជន៍ ។ • ចំនួនទឹកប្រាក់សន្ទឹកសន្ធាប់ អាចជាប់ពាក់ព័ន្ធនឹងការផ្ទេរផលប្រយោជន៍ ទៅឲ្យសហគមន៍មូលដ្ឋានដែលអាចលេចចេញជាការព្រួយបារម្ភ ចំពោះលទ្ធភាពនៃការប្រើប្រាស់លុយមិនបានត្រឹមត្រូវ ដោយសារកើតមាននូវការកេងប្រវ័ញ្ច និងអំពើពុករលួយ ។ ដូចនេះ គណនេយ្យភាពរបស់ភ្នាក់ងារទទួលបន្ទុកលើការអនុវត្តការបែងចែកផលប្រយោជន៍សារជាថ្មី គឺជាតម្រូវការមូលដ្ឋានចាំបាច់មួយ។

ប្រធានបទពិភាក្សា	តាមរយៈការយល់ដឹងពីការព្រួយបារម្ភ លើការប្រើប្រាស់ពុំត្រឹមត្រូវ ឬដោយសារកើតមានការកេងប្រវ័ញ្ចនូវចំណែកថវិកាយ៉ាងក្រាសក្រៃ ដែលបានផ្ទេរទៅឲ្យសហគមន៍មូលដ្ឋាន ក៏ដូចជាលទ្ធភាពនៃការកើតមានអំពើពុករលួយ ចូរពិភាក្សាអំពីអ្វីដែលត្រូវការជាចាំបាច់ និងបញ្ហាប្រឈម ជាពិសេសក្នុងការរីកចម្រើននៃសេដ្ឋកិច្ច ដើម្បីធានាគណនេយ្យភាពរបស់ភ្នាក់ងារអនុវត្តការបែងចែកផលប្រយោជន៍សារជាថ្មី នៅកម្រិតមូលដ្ឋាន។
លំហាត់	• ជាគោលការណ៍គន្លឹះនៃអភិបាលកិច្ច គឺថាប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង តម្រូវឲ្យចូលរួមពាក់ព័ន្ធជាពិសេសក្នុងការកំណត់អត្តន័យបទប្បញ្ញត្តិនៃយន្តការចែករំលែកផលប្រយោជន៍។ ចូរកំណត់ឲ្យឃើញ

	និងកត់ត្រាក្នុងបញ្ជីមួយនៃបញ្ហាប្រឈមជាក់ស្តែង ដើម្បីធានាពីការដឹងឮពីទស្សន:យោបល់របស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោង។

៦.៨ បទពិសោធនៃការបែងចែកផលប្រយោជន៍នៅក្នុងបណ្តាប្រទេសទន្លេមេគង្គ

បច្ចុប្បន្ននេះ មានបទពិសោធមួយចំនួនទាក់ទងនឹងទម្រង់នៃការបែងចែកផលប្រយោជន៍ពីថ្នាក់ជាតិទៅថ្នាក់មូលដ្ឋាន សម្រាប់បណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ហើយវាមានសារៈប្រយោជន៍ដើម្បីចាប់ផ្តើមឲ្យមានការផ្លាស់ប្តូរផលប្រយោជន៍ទាំងនោះ ។ ខាងក្រោមនេះគឺជាពិនិត្យឡើងវិញយ៉ាងឆាប់រហ័សលើស្ថានភាពពេលបច្ចុប្បន្នលើការបែងចែកផលប្រយោជន៍ជារូបិយវត្ថុ ទៅតាមប្រទេសនីមួយៗ ។ ចំនុចនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងកិច្ចពិភាក្សាជាមួយបណ្តាប្រទេសជាសមាជិក។

ប្រទេសកម្ពុជា និងប្រទេសឡាវ

- បច្ចុប្បន្ននេះ គ្មានព័ត៌មានស្តីពីការគិតគូជាផ្លូវការលើសេចក្តីព្រាងច្បាប់ ឬ បទបញ្ញត្តិស្តីពីយន្តការបែងចែកផលប្រយោជន៍នោះទេ ទាំងនៅប្រទេសកម្ពុជា និងប្រទេសឡាវ ។ ដូចបានកត់សម្គាល់ឃើញពីខាងដើមនៅក្នុងផ្នែកទី១.២.២ ដែលរៀបរាប់អំពីប្រភេទនៃការបែងចែកផលប្រយោជន៍ ប្រទេសកម្ពុជា និងប្រទេសឡាវបាននិងកំពុងអនុវត្តដោយប្រយោលលើទម្រង់នៃការបែងចែកផល-ប្រយោជន៍នៅថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ (មានន័យថាក្នុងតំបន់នៃប្រទេសនេះ) ហើយអនុវត្តជា ជំហានៗដើម្បីបង្កើនផលប្រយោជន៍បន្ថែមទៀតពីគម្រោងវារីអគ្គិសនី។
- ទោះជាយ៉ាងណានៅមិនទាន់មានបទដ្ឋានជារួមនៅឡើយទេ ហើយគោលបំណងរៀបចំបទដ្ឋាននេះត្រូវទាមទារការចរចាដោយគម្រោងនិងគម្រោង។ នៅមានបទពិសោធន៍ជាច្រើនទៀតជាមួយវិធានការផ្សេងៗ ដែលអាចជាផ្នែកមួយនៃវិធីសាស្ត្របែងចែកផលប្រយោជន៍ដ៏ទូលំទូលាយ លើគម្រោងដែលជាប់ពាក់ព័ន្ធជាមួយដៃគូអភិវឌ្ឍន៍នៃក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ។
- បច្ចុប្បន្ននេះប្រទេសឡាវ បានអនុវត្តការសិក្សាស្រាវជ្រាវរបស់ខ្លួនក្រោមជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យវារីអគ្គិសនី និងរុករករ៉ែ ។ ដូចដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍វាយតម្លៃរបស់ធនាគារពិភពលោក (PAD) សម្រាប់ធាតុផ្សំសំខាន់ទាក់ទងនឹងការដោះស្រាយជាមួយវារីអគ្គិសនី ជំនួយបច្ចេកទេសនេះ ផ្តល់ជាការកសាងសមត្ថភាពនៅក្នុងការគាំទ្រសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសឡាវ និង ជាពិសេសបានកត់សម្គាល់ពីការយកចិត្តទុកដាក់បន្ថែមទៀតចំពោះការបែងចែកផលប្រយោជន៍នៅថ្នាក់មូលដ្ឋាន។

ប្រទេសថៃ

- ប្រទេសថៃបានផ្លាស់ប្តូរឆ្ពោះទៅរកការបែងចែកផលប្រយោជន៍ ដោយការដាក់ចេញនូវមូលនិធិអភិវឌ្ឍន៍សហគមន៍ (CDFs) លើគម្រោងផលិតអគ្គិសនីទាំងអស់ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអគ្គិសនីថៃ (EGAT)។ សេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែមិថុនាឆ្នាំ២០០៧ បានព្រមព្រៀងបង្កើតឲ្យមានប្រព័ន្ធCDFថ្នាក់ទី៣ នៅក្នុងប្រទេសថៃដែលមានគោលបំណងបង្កើនដើមទុនដើម្បីបង្កើនគុណភាពជីវិតរបស់មនុស្ស និងបរិស្ថាននៅក្នុងតំបន់ជុំវិញរោងចក្រថាមពល។ តាមរយៈការព្យួរការបង្កើតមូលនិធិនេះ សេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧ បានចែងថាអាជ្ញាធរអគ្គិសនីថៃ (EGAT) ត្រូវទទួលខុសត្រូវសម្រាប់ការបង់ប្រាក់ចូលទៅក្នុងមូលនិធិនិងសម្រាប់ស្តារឡើងវិញក្រោយមកទៀតនូវការចំណាយដែលបានមកពីប្រាក់ចំណូល។
- ព័ត៌មានដែលមានស្រាប់ស្នើឡើងថា មូលនិធិអភិវឌ្ឍន៍សហគមន៍ គួរតែមានសម្រាប់អំឡុងរយៈពេលថេរនិងមានកំណត់មួយ។ មូលនិធិនេះ បង្កើតគោលការណ៍នៃការបែងចែកប្រាក់ចំណូលក្នុងមូលដ្ឋាននិងក្នុងតំបន់ដែលបានពីគម្រោងវារីអគ្គិសនីនៅក្នុងប្រទេសថៃ។
- ឯកសារយុទ្ធសាស្ត្រមួយដែលរៀបចំដោយការិយាល័យគោលនយោបាយថាមពល និង ផែនការរបស់ប្រទេសថៃ (EPPO) នៃក្រសួងថាមពលបានបង្ហាញថាអាជ្ញាធរអគ្គិសនីថៃ (EGAT) គឺជាអ្នកទទួលខុសត្រូវលើការអនុវត្តមូលនិធិអភិវឌ្ឍន៍សហគមន៍ CDFs នៅក្នុងតំបន់ជុំវិញគម្រោងអគ្គិសនី។ ឯកសារនេះបង្ហាញពីប្រាក់ដើម្បីដាក់ទុនធ្វើមូលធនកម្មមូលនិធិអភិវឌ្ឍន៍សហគមន៍ ដែលនឹងបានមកពីការហូតពន្ធលើក្រុមហ៊ុនអគ្គិសនីដែលមានកម្លាំងផលិតធំជាង ១.០ មេហ្គាវ៉ាត់ឡើងទៅ ។ ក្របខ័ណ្ឌសម្រាប់ការអនុញ្ញាតិលើការចំណាយដោយយន្តការមូលនិធិ CDD ត្រូវបានចែកចេញជា៣ប្រភេទឬកម្រិត ដូចតទៅ ៖

    - ប្រភេទទី១ ៖ សម្រាប់ការអភិវឌ្ឍជារួមលើគុណភាពជីវិតនិងបរិស្ថាន ការអនុញ្ញាតិត្រូវស្ថិតនៅក្រោមការសម្រេចចិត្តរបស់គណៈកម្មការទទួលបន្ទុងមូលវិធិអភិវឌ្ឍន៍សហគមន៍ (នៅថ្នាក់ជាតិ) ។
    - ប្រភេទទី២ ៖ សម្រាប់ការអភិវឌ្ឍលើគុណភាពជីវិតនិងបរិស្ថានរបស់ប្រជាពលរដ្ឋនៅតាមខេត្តដែលមានគម្រោងវារីអគ្គិសនីតាំងនៅទីនោះ ការអនុញ្ញាតិ (ចំណាយ) ត្រូវសម្រេចដោយ គណៈកម្មការខេត្តរៀងខ្លួន។
    - ប្រភេទទី៣ ៖ សម្រាប់ការអភិវឌ្ឍលើគុណភាពជីវិតនិងបរិស្ថានរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលមានគម្រោងអគ្គិសនីតាំងនៅ ការអនុញ្ញាតិ (ចំណាយ) ត្រូវសម្រេចដោយគណៈ-កម្មការសហគមន៍រៀងខ្លួន។

ក្រាហ្វិកខាងក្រោមនេះបង្ហាញពីប្រព័ន្ធ៣ថ្នាក់ (ដកស្រង់ចេញពីឯកសារយុទ្ធសាស្ត្រ EPPO នៅក្នុងស៊ីឌីផ្តល់ចំណេះដឹង ភាគទី២ នៃកម្មវិធីគម្រោងផ្លូចផ្តើមគំនិតស្តីពីវារីអគ្គិសនីប្រកបដោយនិរន្តរភាព (ISH) របស់គណៈកម្មការទន្លេមេគង្គ)។



- នៅឆ្នាំ២០០៨ ឯកសាររបស់អាជ្ញាធរអគ្គិសនីថៃ (EGAT) បានរាយការណ៍ថារោងចក្រអគ្គិសនីចំនួនសរុប១០២កន្លែងដែលមានទីតាំងស្ថិតនៅក្នុងខេត្តចំនួន ៣៩ រួមទាំងរោងចក្រអគ្គិសនីរបស់អាជ្ញាធរអគ្គិសនីថៃចំនួន២៦កន្លែង ដែលនឹងត្រូវបង់ថវិកាចូលទៅក្នុងមូលនិធិអភិវឌ្ឍន៍សហគមន៍។
- អាជ្ញាធរអគ្គិសនីថៃ បានកត់សម្គាល់ថាអ្នកទទួលផលពីមូលនិធិនេះសំដៅដល់សហគមន៍ ដែលរស់នៅក្នុងរង្វង់ចម្ងាយ៥គីឡូម៉ែត្រជុំវិញរោងចក្រអគ្គិសនីនិងនៅក្បែរតំបន់ដទៃទៀត តាមការគូសបញ្ជាក់ ពីគណៈកម្មការគ្រប់គ្រងមូលនិធិ។

- ថវិកាដែលកើតចេញពីមូលនិធិ នឹងត្រូវបានបម្រុងទុកសម្រាប់សហគមន៍ ក្នុងគោលបំណងអភិវឌ្ឍជីវភាពរស់នៅនិងគុណភាពជីវិត ដោយការគាំទ្រដល់សកម្មភាពដែលទាក់ទងទៅនឹងវិស័យអប់រំ សាសនា វប្បធម៌ កីឡា និងតន្ត្រី ។
- រួមទាំងសុខភាពសាធារណៈ និង សកម្មភាពបរិស្ថាន ការអភិវឌ្ឍថាមពលកកើតឡើងវិញជំនួយសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយការខូចខាតដែលបណ្តាលមកពីផលប៉ះពាល់ណាមួយដោយសាររោងចក្រអគ្គិសនី និងមូលហេតុផ្សេងៗទៀតដូចដែលបានគូសបញ្ជាក់ពីគណៈកម្មការគ្រប់គ្រងមូលនិធិ។

- ក្នុងចំណោមមូលនិធិអភិវឌ្ឍន៍សហគមន៍សំខាន់ៗទាំង៥ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ (ដោយការធ្វើមូលធនកម្ម) រួមមាន ៖
  - មូលនិធិអភិវឌ្ឍន៍សហគមន៍ក្នុងខេត្តឡាំប៉ាង (Lampang) (មានចំនួន៣២៨លានបាតក្នុងមួយឆ្នាំ)។
  - មូលនិធិអភិវឌ្ឍន៍សហគមន៍របស់ក្រុមហ៊ុនអចលនទ្រព្យឧស្សាហកម្មម៉ាប់តាភុត (Mab Ta Phut) (មានចំនួន២៦១លានបាតក្នុងមួយឆ្នាំ)។
  - មូលនិធិអភិវឌ្ឍន៍សហគមន៍របស់ក្រុមហ៊ុនផលិតអគ្គិសនីរ៉ាត់ឆាបុរី (Ratchaburi) (មានចំនួន២៨០លានបាតក្នុងមួយឆ្នាំ)។
  - មូលនិធិអភិវឌ្ឍន៍សហគមន៍របស់ក្រុមហ៊ុនផលិតអគ្គិសនីឈូងសមុទ្រ (មានចំនួន៩៩លានបាតក្នុងមួយឆ្នាំ)។
  - មូលនិធិអភិវឌ្ឍន៍សហគមន៍របស់រោងចក្រអគ្គិសនីបាងប៉ាគង់ (Bang Pakong) (មានចំនួន៩៧លានបាតក្នុងមួយឆ្នាំ)។
- នៅក្នុងឆ្នាំ២០០៩ អត្ថបទព័ត៌មានថៃបានស្នើថា បទពិសោធនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍សហគមន៍មានការរីកលូតលាស់ខ្លាំង។ ឧទហរណ៍ សារព័ត៌មានឌឺណេសិន (The Nation) បានផ្តល់សេចក្តីរាយការណ៍ព័ត៌មានថា នៅក្នុងខែធ្នូ ឆ្នាំ២០០៩ រយៈពេលពីរឆ្នាំដំបូងនៃការប្រើប្រាស់មូលនិធិដែលបានពីគម្រោងអគ្គិសនីរ៉ាត់ឆាបុរី (Ratchaburi) ដែលមានខ្លឹមសារ ដូចខាងក្រោ ៖
  - " មូលនិធិអភិវឌ្ឍន៍សហគមន៍ក្នុងរយៈពេលពីរឆ្នាំ សម្រាប់តំបន់ជុំវិញរោងចក្រអគ្គិសនី បានបង្ហាញឲ្យឃើញពីជោគជ័យដ៏ល្អ ទោះបីជាការវាស់វែងនៅមានកម្រិតនៅឡើងក្តី។ ចំណែកនៃមូលនិធិអភិវឌ្ឍន៍សហគមន៍របស់ក្រុមហ៊ុនផលិតអគ្គិសនីរ៉ាត់ឆាបុរី (Ratchaburi) ត្រូវបានរាយការណ៍ថា ជាមូលនិធិធំជាងគេទីពីរនៅក្នុងប្រទេសថៃ.... និងមានចំនួន២៨០ លានបាតក្នុងមួយឆ្នាំ " ។

- (នេះមានន័យថាថវិកាក្រោម១០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ត្រូវបានទុកបម្រុង ដើម្បីបែងចែកលើប្រាក់ចំណូលបានមកពីគម្រោង)។
- រ៉ាត់ឆាបុរី (Ratchaburi) គឺជារោងចក្រថាមពលឧណ្ហវារីធំជាងគេទីពីររបស់ប្រទេសថៃ (មានកម្លាំងផលិត៣,៦២៥មេហ្គាវ៉ាត់) ដែលមានទីតាំងស្ថិតនៅភាគនិរតីនៃទីក្រុងបាងកក ។ ក្រុមហ៊ុននេះមានរោងចក្រចំនួន២ គឺទីមួយរោងចក្រផលិតឥន្ធន:មិនមែននុយក្លេអ៊ែរ (ប្រេងកាតនិងឧស្ម័ន) រោងចក្រឧណ្ហវារី (មានកម្លាំងផលិត៣២,១២៥មេហ្គាវ៉ាត់) ត្រូវបានបិទបញ្ចប់ក្នុងឆ្នាំ ២០០២ និង ទីពីររោងចក្រអគ្គិសនីដែលមានកម្លាំងផលិត១៤០០មេហ្គាវ៉ាត់ រោងចក្រវិលជុំរួមបញ្ចូលគ្នា (ពីរគ្រុម) ត្រូវបានបិទបញ្ចប់ក្នុងឆ្នាំ២០០៨។

- សេចក្តីរាយការព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយកាលពីឆ្នាំ ២០១០ បានបង្ហាញថាការសម្រេចចិត្តលើអនាគតនៃមូលនិធិអភិវឌ្ឍន៍សហគមន៍ ត្រូវបានរង់ចាំការសម្រេចពីការិយាល័យគោលនយោបាយថាមពល និងផែនការរបស់ប្រទេសថៃ (EPPO)។
- ជាផ្នែកមួយនៃការងាររបស់គណៈកម្មការទន្លេមេគង្គ គឺការជួយផ្សៀងផ្ទាត់លើស្ថានភាពនៃមូលនិធិអភិវឌ្ឍន៍សហគមន៍ ថាតើមូលនិធិទាំងនោះត្រូវបានបង្កើតឡើង ចំពោះវារីអគ្គិសនីកំពុងដំណើរការស្រាប់ និងជាការជាប់ទាក់ទិនណាមួយលើគម្រោងនាំចូលថាមពលអគ្គិសនីនានា ឬយ៉ាងណា។

ប្រទេសវៀតណាម

- ប្រទេសវៀតណាបានបង្កើតឲ្យមាន និង បានសាកល្បងអនុវត្តយន្តការបែងចែកផលប្រយោជន៍សម្រាប់សហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់មិនល្អពីគម្រោងវារីអគ្គិសនី ចាប់តាំងពីឆ្នាំ ២០០៦ តាមរយៈគម្រោងផ្តល់ជំនួយបច្ចេកទេសជាបន្តបន្ទាប់ (TA) ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ សេចក្តីព្រាងអនុក្រឹត្យមួយស្តីពីការបែងចែកផលប្រយោជន៍ ត្រូវបានរៀបចំរួចជាស្រេចហើយ។ ប្រសិនបើច្បាប់នោះត្រូវបានអនុម័តជាផ្លូវការ វានឹងអនុវត្តចំពោះរាល់គម្រោងវារីអគ្គិសនីទាំងអស់ដែលកំពុងដំណើរការស្រាប់ ដែលនឹងតម្រូវឲ្យមានការអនុវត្តស្របតាមច្បាប់លើវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)។ ប្រការនេះនឹងអាចបង្កើតនូវមូលនិធិអភិវឌ្ឍន៍មូលដ្ឋានបានចំនួន២០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលបានពីគ្រប់គម្រោងវារីអគ្គិសនីទាំងអស់ ដែលកំពុងដំណើរការស្រាប់នៅក្នុងប្រទេសវៀតណាម និង គម្រោងទាំងឡាយណាដែលនឹងដំណើរការជាបន្តបន្ទាប់។

- ជំនួយបច្ចេកទេសលើយន្តការបែងចែកផលប្រយោជន៍ កំពុងត្រូវបានអនុវត្តដោយអាជ្ញាធរនិយតកម្ម អគ្គិសនីវៀតណាម (ERAV) និង ត្រូវរាយការណ៍ទៅកាន់ក្រសួងឧស្សាហកម្ម ពាណិជ្ជកម្ម និង ទូរគមនាគមន៍ (MOITT)។
- ការពិនិត្យលើគោលនយោបាយជារួម ដែលបានចាប់ផ្តើមដំបូងលើដំណើរការនៅក្នុងប្រទេសវៀត-ណាមនៅចុងឆ្នាំ២០០៦ បានបង្ហាញរួចមកហើយនៅខាងដើមនៅក្នុងក្រាហ្វិកក្នុងផ្នែក១.៤.១ នៃរ៉ូលីមនេះ។ វាបានចាប់ផ្តើមជាមួយនឹងសំណួរចំនួន៣ (i)តើអ្វីខ្លះជាបទពិសោធន៍លក្ខណៈអន្តរជាតិដែលអាចផ្តល់ជាមេរៀនសម្រាប់ប្រទេសវៀតណាម? (ii)តើគោលនយោបាយ និងច្បាប់នាពេលបច្ចុប្បន្នមានវិសាលភាពបែបណាដែលអាចបង្កលក្ខណៈឲ្យមានការចែករំលែកផលប្រយោជន៍ និង (iii)តើអ្វីខ្លះដែលត្រូវការជាចាំបាច់ដើម្បីឈានឆ្ពោះទៅមុខទៀត?
- ខាងក្រោមនេះ គឺជាចំនុចសំខាន់ដែលត្រូវកត់សម្គាល់លើការពិនិត្យគោលនយោបាយដើម្បីផ្តើមឲ្យមានជាដំបូងនូវការពិភាក្សាលើយន្តការបែងចែកផលប្រយោជន៍ ដោយការពិចារណាទៅលើគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសវៀតណាម ចំនួន៩ប្រភេទ ដូចជា ៖

  - ច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋ
  - វិស័យថាមពល
  - វិស័យធនធានទឹក
  - វិស័យបរិស្ថាន
  - វិស័យព្រៃឈើ
  - វិស័យជលផល
  - វិស័យហិរញ្ញវត្ថុ រួមទាំងរដ្ឋបាលដីធ្លី) ឧ. គោលនយោបាយស្តីពីការតាំងលំនៅថ្មី)
  - វិស័យសង្គមកិច្ច រួមទាំងក្រុមជនជាតិភាគតិច
  - អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ដែលផ្តល់សច្ចាប័នដោយប្រទេសវៀតណាម
- ជំនួយបច្ចេកទេសជារួម) ដែលបានបញ្ចប់នាខែធ្នូ ឆ្នាំ២០០៨) បានរៀបចំឲ្យមានជាកំណែដំបូងនៃសេចក្តីព្រាងអនុក្រឹត្យ និង ផែនការអនុវត្តសាកល្បង លើបទបញ្ញត្តិនៅក្នុងសេចក្តីព្រាងអនុក្រឹត្យនោះ ចំពោះគម្រោងវារីអគ្គិសនីវុង (Vuong hydropower project) ស្ថិតនៅតំបន់ខ្ពង់រាបភាគកណ្តាលនៃខេត្តក្វាងណាម (Quang Nam) ដែលមានកម្លាំងផលិត២១០មេហ្គាវ៉ាត់។
- ក្រោយមកទៀត ដំណាក់កាលដំបូងនៃគម្រោងសាកល្បងនោះ (ផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការWWF) ត្រូវបានបញ្ចប់នៅឆ្នាំ២០១០ ។

គម្រោងសាកល្បងនោះត្រូវបានអនុវត្តដោយ អាជ្ញាធរនិយតកម្មអគ្គិសនីវៀតណាម (ERAV) ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការប្រជាជនខេត្ត (PPC) នៃខេត្ត ក្វាងណាម (Quang Nam) ដែលជាស្ថាប័នចាត់តាំងក្រុមប្រឹក្សាទទួលបន្ទុកបែងចែកផលប្រយោជន៍ (BCS) និងក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិ (FMB)។ ការរៀបចំជារួមនេះ (ដែលមាន ERAV នៅកម្រិតរដ្ឋ និង PCCនៅកម្រិតខេត្ត) បានឆ្លុះបញ្ចាំងពីបែងចែកតាមសេចក្តីព្រាងអនុក្រឹត្យ លើការទទួលខុសត្រូវ ដូចតទៅ ៖

១. អាជ្ញាធរនិយតកម្មអគ្គិសនីវៀតណាម (ERAV) និង ក្រសួងឧស្សាហកម្ម ពាណិជ្ជកម្ម និងទូរគមនាគមន៍ (MOITT) ដែលមានមូលដ្ឋាននៅថ្នាក់ខេត្តត្រូវជួយសម្របសម្រួលលើការទំនាក់ទំនងរវាងវិស័យថាមពល (ជាពិសេស លើយន្តការផ្ទេរប្រាក់ចំណូល ដើម្បីដាក់ថវិកាបានពីប្រាក់ចំណូល ដែលប្រមូលបានពីតម្លៃពន្ធលើអតិថិជន ចូលទៅក្នុងមូលនិធិបែងចែកផលប្រយោជន៍) និង

២. គណៈកម្មការប្រជាជនខេត្ត (PPC) នៃខេត្តក្វាងណាម (Quang Nam) ត្រូវទទួលខុសត្រូវចម្បងលើការអភិវឌ្ឍនៅក្នុងខេត្តនេះ (តាមរយៈក្រុមប្រឹក្សាទទួលបន្ទុកបែងចែកផលប្រយោជន៍ (BSC) ដែលចាត់តាំងដោយPPC ។ PPC ត្រូវត្រួតពិនិត្យមើលលើការអនុវត្តមូលនិធិដែលធ្វើឡើងស្រមតាមយន្តការរបស់ERAV/MOITT ក៏ដូចជាការអនុវត្តន៍លើទិដ្ឋភាពផ្សេងទៀត នៃយន្តការបែងចែកផលប្រយោជន៍ប្រកបដោយលក្ខណៈទូលំទូលាយមួយ (ឧ. លទ្ធភាពទទួលបានធនធាន ការចែករំលែកប្រកបដោយសមធម៌ឈរលើទិដ្ឋភាពសេវាគម្រោង ដោយផ្តោតសំខាន់លើការគាំទ្រដល់គោលដៅកាត់បន្ថយភាពក្រីក្រ។ល។

- នៅក្នុងជំហានទីមួយនៃការផ្តល់ជំនួយបច្ចេកទេស (TAs) កាលពីឆ្នាំ២០០៧-២០០៨ ERAV បានប្រើប្រាស់នីតិវិធីពិភាក្សាជាមួយពហុភាគីពាក់ព័ន្ធដើម្បីឡើងទទួចសុំទស្សនៈយោបល់ និងគំនិតនានាទៅលើសេចក្តីព្រាងអនុក្រឹត្យ។ នីតិវិធីនេះ ចូលរួមពាក់ព័ន្ធដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការធំៗមួយចំនួន ស្ថាប័នក្រសួងផ្សេងៗ អ្នកតំណាងថ្នាក់ខេត្ត និង ដៃគូអភិវឌ្ឍន៍ក្នុងប្រទេស វៀតណាម តាមរយៈសិក្ខាសាលារយៈមួយថ្ងៃចំនួន៣ ក្នុងរយៈពេលប្រហែល១៥ខែ ។ ការពិគ្រោះយោបល់ទាំងនេះមានសារៈសំខាន់និងមានភាពចាំបាច់យ៉ាងខ្លាំង ដោយសារភាគីពាក់ពន្ធទាំងនេះបានគាំទ្រយ៉ាងទូលំទូលាយលើការបែងចែកផលប្រយោជន៍ និងជាពិសេសទទួលបានការគាំទ្រពីបណ្តាខេត្តនានា និងអង្គការធំៗមួយចំនួន (អង្គការសង្គមស៊ីវិល) នៅក្នុងប្រទេសវៀតណាមទាំងមូល។
- ERAV គឺជាអ្នកចាត់ចែងដំណើរការកម្មវិធី/ជាម្ចាស់ សម្រាប់ការងារទាក់ទងនឹងយន្តការបែងចែកផលប្រយោជន៍ ដែលត្រូវបានគាំទ្រដោយគណៈកម្មកម្មការអចិន្ត្រៃយ៍អន្តររដ្ឋាភិបាល ដែលមាន

សមាសភាពពីភ្នាក់ងារពាក់ព័ន្ធថ្នាក់ជាតិ និងអ្នកតំណាងEVN។ សេចក្តីព្រាងអនុក្រឹត្យ ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ដែលជាផ្នែកមួយនៃគម្រោងសាកល្បងវារីអគ្គិសនីវុង (Vuong) ក្នុងឆ្នាំ២០១០។ សេចក្តីព្រាងអនុក្រិតនេះត្រូវបានប្រើប្រាស់ សម្រាប់ជំហានទីពីរនៃគម្រោងសាកល្បងវារីអគ្គិសនីវុង ដែលត្រូវបានកំណត់ឲ្យបន្តដំណើរការក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងឆ្នាំ២០១១។

- នៅក្នុងនីតិវិធីនៃប្រទេសវៀតណាម ការយល់ស្របយ៉ាងទូលំទូលាយទៅលើគោលបំណងនៃការបែងចែកផលប្រយោជន៍ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រាទី៤នៃសេចក្តីព្រាងអនុក្រឹត្យ ។ គោល-បំណងទាំងនោះ មានដូចជា ៖

  ១. ដើម្បីធ្វើឲ្យរីកចម្រើនដល់ការរក្សាឲ្យមានជាទម្រង់លើការអភិវឌ្ឍ និងគ្រប់គ្រងវារីអគ្គិសនី។

  ២. ដើម្បីផ្តល់ស្ថិរភាពលើយន្តការ និង មានរយៈពេលវែង ដើម្បីបង្កើនការចូលរួមចំណែកក្នុងសង្គមសេដ្ឋកិច្ចពីសំណាក់គម្រោងវារីអគ្គិសនីសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ដែលស្ថិតក្នុងបន្ទាត់គោលនយោបាយអភិវឌ្ឍន៍អគ្គិសនីរបស់រដ្ឋ ។

  ៣. ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីធ្វើឲ្យមានគម្លាតតិចតួចលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅតាមទីប្រជុំជន និងតាមទីជនបទ នៅក្នុងអំឡុងពេលដែលមានកំណើនឆាប់រហ័ស និងទំនើបភាវូបនីយកម្ម ព្រមទាំងការជម្រុញការអភិវឌ្ឍនៅមូលដ្ឋាននៃតំបន់ជនជាតិភាគតិច និង តំបន់ដែលជួបការលំបាកផ្នែកល័ក្ខខ័ណ្ឌសង្គមសេដ្ឋកិច្ច ឬ ជួបការលំបាកខ្លាំងបំផុត ដែលជាកន្លែងមានគម្រោងវារីអគ្គិសនីជាច្រើនតាំងនៅ ។

  ៤. ដើម្បីគាំទ្រដល់ការអនុវត្តន៍ច្បាប់ពាក់ព័ន្ធនៅក្នុងប្រទេស និងការប្តេជ្ញាចិត្តជាលក្ខណៈអន្តរជាតិ ដើម្បីធ្វើឲ្យនិរន្តរភាពនៃការគ្រប់គ្រងដីបានចម្រើនទៅមុខ និង ការអនុវត្តន៍លើការគ្រប់គ្រងធនធានទឹក ដែលជាកន្លែងដែលការគ្រប់គ្រងលើគម្រោងវារីអគ្គិសនី គឺជាការពិចារណាមួយដ៏សំខាន់។

  ៥. ដើម្បីធានាឲ្យបាននូវការការពារផលប្រយោជន៍របស់រដ្ឋ និង សិទ្ធិនិងផលប្រយោជន៍នានារបស់អង្គភាព និងបុគ្គលដែលពាក់ព័ន្ធ ព្រមទាំងបរិស្ថានអេកូឡូស៊ីនៅក្នុងតាមតំបន់ជនបទ។

  ៦. ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានភ្លើងអគ្គីសនីប្រកបដោយសមធម៌ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ជនបទនានាដែលទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍវារីអគ្គិសនី រួមទាំងមួយផ្នែកធំនៃជនជាតិដើមភាគតិច និង

៧. ដើម្បីលើកកម្ពស់សិទ្ធិទទួលបាននូវធនធានធម្មជាតិ និង ដើម្បីធានាឲ្យប្រាកដថា សហគមន៍មូលដ្ឋានទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីទាញយកគុណប្រយោជន៍ពីការអភិវឌ្ឍនៅមូលដ្ឋាន និងឱកាសប្រកបមុខរបរដែលផ្តល់ដោយគម្រោងវារីអគ្គិសនី។

- ប្រទេសវៀតណាម បានចាប់អនុវត្តការយកថ្លៃលើការប្រើប្រាស់ធនធានទឹកអស់រយៈពេលប៉ុន្មានឆ្នាំរួចមកហើយ (២%នៃប្រាក់ចំណូលសរុបបានពីគម្រោងវារីអគ្គិសនី) ត្រៀមបម្រុងទុកសម្រាប់ថវិកាចំណាយរបស់ខេត្ត។ នៅក្នុងខែមិថុនា ឆ្នាំ២០១០ ប្រទេសវៀតណាម ក៏បានអនុម័តលើច្បាប់មួយស្តីពីការទូទាត់សំណងសម្រាប់សេវាអេកូឡូស៊ី ឬ ការទូទាត់សេវាកម្មបរិស្ថាន (PES) ដែលតម្រូវឲ្យសហគ្រាសសេដ្ឋកិច្ចផ្សេងៗ (ឧ. សហគ្រាសធ្វើអាជីវកម្មព្រៃឈើ ឧស្សាហកម្មអេកូ-ទេសចរណ៍ និងគម្រោងវារីអគ្គិសនី ជាដើម) ត្រូវចូលរួមចំណែកនូវប្រាក់ចំណូលរបស់ខ្លួនសម្រាប់ (PES) រួមទាំងការបែងចែក ថវិកាបង់ថ្លៃទៅដល់គ្រួសារ ដែលបានចូលរួមក្នុងសកម្មភាពគ្រប់គ្រងសេវាអេកូឡូស៊ីនៅមូលដ្ឋាន (ការទូទាត់សេវាកម្មបរិស្ថាន)។ PES មានរូបមន្តផ្សេងគ្នាសម្រាប់វិស័យនីមួយៗ។ កម្រិតនៃការទូទាត់សេវាកម្មបរិស្ថាន (PES) សម្រាប់រោងចក្រថាមពលវារីអគ្គិសនីដោយប្រើទឹកសម្រាប់ផលិតជាផលអគ្គិសនី ត្រូវបានកំណត់ឲ្យបង់ថ្លៃនៅទឹកប្រាក់២០ដុង (0.១២៥ សេន ដុល្លារអាមេរិក) ក្នុងមួយគីឡូវ៉ាត់ម៉ោងអគ្គិសនី។ ដែលផលិតបាន។ ចំណែកក្រុមហ៊ុនផ្គត់ផ្គង់ទឹកវិញ ត្រូវបានកំណត់ឲ្យបង់ថ្លៃ៤0ដុង(0.២៥ សេនដុល្លាអាមេរិក)ក្នុងមួយម៉ែត្រគូបទឹកដែលផ្គត់ផ្គង់។
- នៅមានភាពច្របូកច្របល់មួយចំនួន ក្នុងចំណោមមូលនិធិនានា ដែលត្រូវបានអនុវត្តកាន់តែច្រើនឡើងចំពោះការគ្រប់គ្រងធនធានធម្មជាតិ។ ជាប្រការសំខាន់ គេត្រូវធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធលើទម្រង់ នៃការបែងចែកប្រាក់ចំណូលទាំងនេះ ដែលសម្រាប់បំពេញបន្ថែមលើគោលបំណងផ្សេង ដូចជា ការការពារធនធានទឹក ការពារបរិស្ថាន ស្តារជីវភាពរស់នៅ ឬ ការបែងចែកផលប្រយោជន៍។

ប្រទេសចិន

ចាប់តាំងពីទសវត្សឆ្នាំ ១៩៨0 ប្រទេសចិនបានណែនាំឲ្យមានការប្រើប្រាស់ទម្រង់ផ្សេងៗនៃការបែងចែកផលប្រយោជន៍ ហើយក្នុងពេលថ្មីៗនេះ បានពង្រឹង និងរួមបញ្ចូលគ្នាឲ្យមានការប្រើប្រាស់យន្តការបែងចែកផលប្រយោជន៍រួមជាមួយគោលនយោបាយនានា ដើម្បីលើកកម្ពស់វារីអគ្គិសនីប្រកបដោយនិរន្តរភាព។

នៅក្នុងដំណើរទស្សនកិច្ចរបស់គណៈកម្មការទន្លេមេគង្គទៅកាន់គម្រោងវារីអគ្គិសនីក្នុងMekong-Lancang នៅក្នុងខែមិថុនា ឆ្នាំ២០១0 ទិដ្ឋភាពទាំងនេះត្រូវបានពិភាក្សាជាមួយ ESCIR របស់ប្រទេសចិន និងក្រុមហ៊ុនថាមពលវារីអគ្គិសនី HydroLancang Power Company។

ដោយមានសាវតា ដូចខាងក្រោម ៖

- ប្រទេសចិនបានកសាងឡើងនូវគម្រោងវារីអគ្គិសនីធំៗ ស្ទើរតែពាក់កណ្តាលពិភពលោក (ជាង ២២,០០០ទំនប់ធំ) ។ តាមប្រវត្តិសាស្ត្រប្រទេសចិនធ្លាប់ជាអ្នកត្រួសត្រាយផ្លូវលើការណែនាំវិធីសាស្ត្រថ្មីសម្រាប់ការបែងចែកផលប្រយោជន៍ជាមួយសហគមន៍មូលដ្ឋាន។
- ពីទសវត្សឆ្នាំ១៩៨០ មួយចំណែកនៃប្រាក់ចំណូលវារីអគ្គិសនីបានពីទំនប់ Danjiangkou ដែលបានបង្កើតជាបឹងដ៏ធំបំផុតធ្វើឡើងដោយមនុស្សនៅតំបន់អាស៊ី នៅពេលដែលវាត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩៦៦ ត្រូវបានគេដាក់នៅក្នុងមូលនិធិដោះស្រាយ "បញ្ហាដែលនៅសេសសល់" ។ មូលនិធិនេះបានផ្តល់ជាហិរញ្ញប្បទាន សម្រាប់ការស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលរស់នៅជុំវិញបរិវេណអាងស្តុកទឹកដែលបានជួបប្រទះការលំបាកនៅពីក្រោយការអភិវឌ្ឍនៅក្នុងតំបន់ផ្សេងទៀត ។ វិធានការដើម្បីដោះស្រាយបញ្ហាសង្គមនានា ដែលជាប់ទាក់ទងជាមួយ ដំណាក់កាលគម្រោងមុនៗ ត្រូវបានណែនាំឲ្យប្រើប្រាស់ បន្ទាប់ពីមានសម្ពាធនយោបាយក្នុងមូលដ្ឋាន។
- មូលនិធិថែទាំអាងស្តុកទឹក សម្រាប់គម្រោងវារីអគ្គិសនីត្រូវបានកំណត់ឡើងជាលើកដំបូង នៅក្នុងប្រទេសចិននាឆ្នាំ១៩៨១ (ជាង៣០ឆ្នាំកន្លងទៅ) នៅពេលដែលក្រសួងហិរញ្ញវត្ថុ និងក្រសួងថាមពលអគ្គិសនី បានសហការចេញក្រឹត្យរួមគ្នា ដើម្បីបង្កើតឲ្យមានជាគោលការណ៍ណែនាំសម្រាប់មូលនិធិនេះដោយការប្រើប្រាស់ប្រាក់ចំណូលពីការលក់ភ្លើងអគ្គីសនី។ គោលបំណងគឺដើម្បីជួយដល់ប្រជាជនដែលតាំងលំនៅថ្មីទាំងអស់ នៅក្នុងតំបន់អាងស្តុកទឹក នៅលើគម្រោងដែលមានស្រាប់ ហើយជាប្រជាពលរដ្ឋជនបទ ដែលមានប្រាក់ចំណូលមធ្យមខ្សោយជាងគេ។ សម្ពាធនយោបាយបានកើតមាននៅក្នុងមូលដ្ឋានដើម្បីដោះស្រាយ "បញ្ហាដែលនៅសេសសល់" លើទំនប់ជាច្រើន ហើយតាមបទពិសោធន៍ពីទំនប់ Danjiangkou បានបង្ហាញថាមានសក្តានុពលវិជ្ជមាន។ ថវិកាទាំងនេះត្រូវបានផ្តល់ជាហិរញ្ញប្បទានដោយឈរលើមូលដ្ឋាននៃទឹកប្រាក់ចំនួន ០.០០១ យន់ក្នុងមួយគីឡូវ៉ាត់ម៉ោង (ឬ ០.០១២សេនដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង) រហូតដល់រោងចក្រវារីអគ្គិសនីត្រូវបញ្ចប់ដំណើរការ។
- តាមការរៀបចំនៅក្នុងប្រទេសចិន មូលនិធិទាំងនេះត្រូវគ្រប់គ្រងដោយការិយាល័យទទួលបន្ទុកការតាំងលំនៅថ្មីក្នុងមណ្ឌលមូលដ្ឋាន និង អាជ្ញាធររោងចក្រវារីអគ្គិសនី ។ យោងតាមច្បាប់បានកំណត់ថា មូលនិធិនេះត្រូវប្រើសម្រាប់ ៖

- ថែរក្សាសំណង់អាគារអាងស្តុកទឹក។
- ថែរក្សាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការស្រោចស្រព និងទឹកសម្រាប់បរិភោគនិងហេដ្ឋារចនា-សម្ព័ន្ធដឹកជញ្ជូន ដែលផ្តល់ជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋដែលបានតាំងលំនៅថ្មី។
- ការផ្តល់ការគាំទ្រផ្នែកសដ្ឋកិច្ចដល់ប្រជាពលរដ្ឋ ដែលបានបានបំលាស់ទីដោយសារការសាងសង់អាងស្តុកទឹក ។

- មានការបញ្ចូលរបៀបថ្មី និងការលៃតម្រូវមួយចំនួនជាពេលកន្លងមក ហើយក៏មានវិធីសាស្ត្រថ្មីមួយចំនួនទៀតផងដែរ ។ តាមរយៈឧទាហរណ៍មួយ ដែលអាជ្ញាធរអភិវឌ្ឍន៍វារីអគ្គិសនីហ៊ុយប៊ី (Hubei) (ក្នុងឆ្នាំ២០០២) បានបង្កើតឡើងនូវកិច្ចព្រមព្រៀងភាពជាដៃគូជាមួយ ដោយផ្អែកលើការបែងចែកផលប្រយោជន៍ដោយសមធម៌ជាមួយនឹងអាជ្ញាធរមូលដ្ឋាន បូកបន្ថែមលើការចែករំលែកប្រាក់ចំណូលដើម្បីសម្រេចឲ្យបានដល់គោលដៅ ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់គម្រោង ។ នៅក្នុងការធ្វើបច្ចុប្បន្នភាពសំខាន់មួយលើគោលនយោបាយនានា ក្នុងឆ្នាំ២០០៧ ប្រទេសចិន បានណែនាំឲ្យប្រើបទប្បញ្ញត្តិដើម្បីផ្តល់នូវភាពដូចគ្នា ក្នុងការគ្រប់គ្រងប្រាក់ចំណូលនិងការផ្ទេរប្រាក់ចំណូលបានមកពីវិស័យថាមពល ទៅឲ្យអាជ្ញាធរក្នុងតំបន់ និងនៅមូលដ្ឋាន។ គោលនយោបាយដែលបានកំណត់នៅពេលនោះ មានគោលបំណង ដូចជា ៖
  - ដើម្បីជម្រុញការអភិវឌ្ឍក្នុងតំបន់ តាមរយៈគម្រោងវារីអគ្គិសនី។
  - ដើម្បីផ្តល់ហិរញ្ញប្បទានលើហេដ្ឋារចនាសម្ព័ន្ធ រយៈពេលវែងសម្រាប់តំបន់អាងស្តុកទឹក រួមទាំងតំបន់ដែលទំនប់បានបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលបានតាំងលំនៅថ្មី និង
  - ដើម្បីផ្តល់សំណងរយៈពេលវែង និងជាលក្ខណៈប្រតិសកម្ម ផងដែរ ទៅដល់ប្រជាពលរដ្ឋដែលបានតាំងទីលំនៅថ្មី។
- ចំនុចសំខាន់ពីរគឺ (i)ការបង្កើតមូលនិធិជាតិសម្រាប់ការតាំងទីលំនៅថ្មី ដែលមានរយៈពេលទូទាត់សំណង២០ឆ្នាំសមាជិកគ្រួសារនីមួយៗបានទទួលប្រាក់ចំនួន៦០០យន់ក្នុងមួយឆ្នាំ។ ការផ្តល់ជូននេះអាស្រ័យលើការកំណត់ដោយច្បាប់ស្តីពីនៃការទូទាត់សំណងតែមួយដងចំពោះដីធ្លី ឬអចលនទ្រព្យដែលស្តាឡើងវិញដោយរដ្ឋ និង(ii)ការធ្វើបច្ចុប្បន្នភាព និងការធ្វើឲ្យស្របតាមគំរូស្តង់ដារនៃមូលនិធិ សម្រាប់ធ្វើឲ្យប្រសើរឡើងនូវតំបន់ហេដ្ឋារចនាសម្ព័ន្ធអាងស្តុកទឹករយៈពេលវែង (និងជាអចិន្ត្រៃយ៍) សម្រាប់គម្រោងវារីអគ្គិសនីដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៨១។
- វិធានការទាំងនេះត្រូវបានទទួលការឧបត្ថម្ភថវិកាដោយចំណូលពីវារីអគ្គិសនី ។ មូលនិធិរយៈពេលវែងដែលមានឈ្មោះ ថាមូលនិធិអភិវឌ្ឍន៍និងការស្តារឡើងវិញនៅតំបន់អាងស្តុកទឹក ត្រូវ

បានអនុវត្តចំពោះគម្រោងវារីអគ្គិសនី Lancang-Mekong ដោយអាជ្ញាធរខេត្តយុនណាន និងដោយផ្អែកលើគោលការណ៍ណែនាំថ្នាក់ជាតិ។

- ថវិកាដែលបានដាក់នៅក្នុងមូលនិធិនេះ ត្រូវបានយកទៅប្រើប្រាស់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានជាច្រើន និងសម្រាប់ការវិនិយោគលើការអភិវឌ្ឍនៅក្នុងតំបន់អាងស្តុកទឹក ទោះបី ជាមូលនិធិនេះ មិនមែនសម្រាប់គាំទ្រដល់សហគមន៍ក្នុងតំបន់ផ្នែកខាងក្រោមអាងក្តី ។ គួរកត់សម្គាល់ផងដែរថា ប្រទេសចិនក៏នៅមានយន្តការហិរញ្ញវត្ថុផ្សេងទៀតជាច្រើន រួមទាំងពន្ធរបស់សាលាក្រុងដែលបានអនុវត្ត ចំពោះគម្រោងវារីអគ្គិសនីសម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍នៅតំបន់អាងស្តុកទឹក និងតំបន់ផ្សេងៗទៀត។ ការសម្រេចចិត្តថាតើមូលនិធិទាំងនេះត្រូវយកទៅជួយគាំទ្រដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់នៅផ្នែកខាងលើ ឬ នៅផ្នែកក្រោម ត្រូវធ្វើឡើងនៅតាមមូលដ្ឋានជាក់ស្តែង តាមការត្រួតពិនិត្យរបស់ថ្នាក់ខេត្ត។

៧ បញ្ហាសង្គមនានាដែលមិនទាន់បានដោះស្រាយ

ទោះបីមិនមានទំនងលើការយល់ដឹងរួមអំពីអ្វីដែលបានបង្កើតជា " បញ្ហាសង្គមមិនទាន់បានដោះស្រាយ " ក៏គេអាចកំណត់អត្ថន័យថាជាបញ្ហាសង្គម ដែលទាក់ទងទៅនឹង ៖

- និរន្តរភាពសេដ្ឋកិច្ច ស្ថាប័ន និងសង្គមវប្បធម៌នៃការតាំងលំនៅថ្មីជាលក្ខណៈរូបវន្ត និងសេដ្ឋកិច្ច។
- ការខូចខាតទ្រព្យសម្បត្តិបេតិកភ័ណ្ឌវប្បធម៌។
- កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាពលរដ្ឋនៅទីក្រុង រួមទាំងបញ្ហាទាក់ទងទៅនឹងការធ្វើសមាហរណកម្មនៃវិស័យសំណង់នៅទីប្រជុំជនតូចៗ ចូលទៅក្នុងក្របខ័ណ្ឌការអភិវឌ្ឍក្នុងតំបន់ទូលំទូលាយ។
- ការទទួលខុសត្រូវរយៈពេលវែង។
- ការផ្លាស់ប្តូរដែលបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋផ្នែកខាងក្រោម។
- បញ្ហាផ្សេងទៀត។

ដែលត្រូវបាន ៖

- ដោះស្រាយនៅក្នុងបទដ្ឋានគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) នៃគម្រោងដាច់ដោយឡែក ដែលមានមូលដ្ឋានលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ផែនការសកម្មភាពស្តីពីការតាំងលំនៅថ្មីនៃគម្រោងដាច់ដោយឡែក ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ផែនការអភិវឌ្ឍន៍សហគមន៍ ។ល។ ប៉ុន្តែនៅពេលដែលវិធានការបន្ធូរបន្ថយមិនបានសម្រេចនូវលទ្ធផល ដែលចង់បាន។
- ដែលមិនត្រូវបានដោះស្រាយនៅក្នុងបទដ្ឋានគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) នៃគម្រោងដាច់ដោយឡែក ប៉ុន្តែត្រូវបានទាមទារដោយផ្អែកលើភស្តុតាង។

- ដែលមិនត្រូវបានដោះស្រាយនៅក្នុងបទដ្ឋានគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) នៃគម្រោងដាច់ដោយឡែក ប៉ុន្តែត្រូវបានទាមទារដោយគ្មានការផ្តល់នូវភស្តុតាង។
- ដែលមិនត្រូវបានដោះស្រាយ និងមិនត្រូវបានទាមទារ ប៉ុន្តែអាចត្រូវបានផ្សៀងផ្ងាត់ឡើងវិញ។

តាមការជាប់ពាក់ព័ន្ធគ្នានេះ ប្រធានបទនេះគ្របដណ្តប់លក្ខណៈធំទូលាយ។

៧.១ ការណែនាំអំពីបញ្ហាសង្គមដែលមិនទាន់បានដោះស្រាយ

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការណែនាំបង្ហាញពីប្រធានបទនៃការដោះស្រាយដោយសមស្របចំពោះបញ្ហាសង្គមនានាដែលនៅសេសសល់ ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមបានយល់ដឹង និងវាយតម្លៃខ្ពស់អំពីថាតើហេតុអ្វី បានជាការដោះស្រាយលើបញ្ហាសង្គមដែលនៅសេសសល់ មានសារៈសំខាន់?
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និង ការអភិវឌ្ឍ ។ ឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ ផ្នែកទី៤ ៖ ការដោះ-ស្រាយលើទិដ្ឋភាពសង្គម (ផ្នែកទី៤.២- ដំណោះស្រាយលើបញ្ហា សង្គមដែលសេសសល់)។ www.unep.org/dams

៧.១.១ មូលហេតុដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់

មានមូលហេតុចម្បង៣យ៉ាងដែលទាំងក្រុមហ៊ុនឯកជន ទាំងរដ្ឋាភិបាល និង ស្ថាប័នហិរញ្ញវត្ថុនានាត្រូវចំណាយមូលនិធិ និងកិច្ចខិតខំដ៏សម្បើមរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ ក្នុងក្របខ័ណ្ឌដើម ឬជាបញ្ហាដែលទើបតែអាចមើលឃើញនៅដំណាក់កាលក្រោយមក មានដូចជា ៖

- ការទទួលយកជាសាធារណៈ។

អ្នកដើរតួនាទីសំខាន់បំផុត គឺក្រុមហ៊ុនឯកជន រដ្ឋាភិបាល ធនាគារអភិវឌ្ឍន៍ និងភ្នាក់ងារដោយគ្មានកាតព្វកិច្ចផ្លូវច្បាប់ណាមួយដើម្បីធ្វើដូច្នេះទេ ប៉ុន្តែភាគីទាំងនេះអាចចូលរួមដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ ក្នុងគោលបំណងដើម្បីកាត់បន្ថយហានិភ័យ នៃការកសាងផែនការគម្រោងរយៈពេលវែងនិងមានតម្លៃខ្ពស់ ការផ្តល់ការអនុញ្ញាត និងដំណើរការផ្តល់អាជ្ញាប័ណ្ណ ដែលជាញឹកញាប់កើតឡើង ដោយសារ ភាពមិនពេញចិត្តរបស់សហគមន៍ ដែលជាលទ្ធផលនៃបញ្ហាសង្គមសេសសល់ជាប់ទាក់ទងជាមួយគម្រោងមុនៗនិង /

ឬ អវត្តមាននៃយន្តការដើម្បីដោះស្រាយបញ្ហាសង្គមបន្ថែមទៀតដែលជាប់ទាក់ទងជាមួយនឹងគម្រោងថ្មីនេះ។ មានពីរវិធីសាស្ត្រចម្បង គឺ ៖

○ មូលនិធិប៉ះប៉ូវទូលំទូលាយ។

មូលនិធិនេះត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ឬទៅដល់អាជ្ញាធរមូលដ្ឋាន ជាមួយនឹងមធ្យោបាយដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ក្រោមការគ្រប់គ្រងផ្ទាល់ខ្លួនរបស់ខ្លួន។ មធ្យោបាយមានប្រសិទ្ធិភាពត្រង់ថាវាជាការផ្ទេរការទទួលខុសត្រូវ ដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ សម្រាប់សហគមន៍រងផលប៉ះពាល់ និង ផ្តល់ឱ្យពួកគេនូវមូលនិធិដើម្បីដោះស្រាយបញ្ហាទាំងនេះ ដោយត្រូវផ្តល់សិទ្ធិអំណាចដល់សហគមន៍បែបអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន ។ មូលនិធិប៉ះប៉ូវទូលំទូលាយ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកាណាដា ប្រទេសន័រវែស និងសាធារណរដ្ឋប្រជាមានិតចិន។

○ ការិយាល័យតំណាងប្រជាពលរដ្ឋ។

ការិយាល័យតំណាងប្រជាពលរដ្ឋអាចលើកកម្ពស់ និងធ្វើឲ្យមានគុណសម្បត្តិដល់ការទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ និង ជួយដល់ប្រជាពលរដ្ឋ និងសហគមន៍រងផលប៉ះពាល់ឲ្យមានសម្លេងនៃការមិនពេញចិត្ត (ការសម្តែងមតិសារទុក្ខ) របស់ពួកគេនៅក្នុងបែបបទត្រឹមត្រូវ និង នៅតាមស្ថានប័នដែលពាក់ព័ន្ធ ។ តួនាទីរបស់ការិយាល័យតំណាងប្រជាពលរដ្ឋ គឺការដោះស្រាយនៅពេលដែលមានបញ្ហាទំនាស់កើតឡើងលើបញ្ហាអណ្តូងរ៉ែធ្យូងថ្មនៅ Garzweiler នៅក្នុងប្រទេសអាល្លឺម៉ង់។ ត្រង់ចំនុចនេះ បានជួយលើកកម្ពស់ឱកាសដើម្បីទទួលស្គាល់ និង ការដោះស្រាយបញ្ហាសង្គម ដែលនៅសេសសល់នៅដំណាក់កាលដំបូង ជូនពេលខ្លះនៅមុនពេលដែលបញ្ហាទាំងនោះមានអាយុកាល ដែលត្រូវបានគេចាត់ទុកថាជាបញ្ហា " នៅសេសសល់ " ដែលបានបន្ថែមជាប្រយោជន៍ដល់ការកាត់បន្ថយការរិះគន់ទៅលើគម្រោង។

- ការអនុលោមទៅតាមសិទ្ធិក្នុងការទទួលបានមូលនិធិប៉ះប៉ូវ។

សិទ្ធិក្នុងការទទួលបានមូលនិធិប៉ះប៉ូវ មានបង្ហាញនៅក្នុងផ្នែកទី៨ នៃ " សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស " ដែលចែងថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានមូលនិធិដោះស្រាយមួយដ៏មានប្រសិទ្ធិភាពតាមរយៈតុលាការជាតិ ចំពោះអំពើទាំងឡាយណាដែលរំលោភលើសិទ្ធិជាមូលដ្ឋាន ដែលបានធានាដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ជាតិ " ។ សិទ្ធិនេះក៏ត្រូវបានបញ្ជាក់បន្ថែមទៀតនៅក្នុង " កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ " ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន១៣២ ដែល

បានចែង និងប្រកាសថា "រដ្ឋជាភាគីនីមួយៗត្រូវព្រមព្រៀងធានាឲ្យប្រាកដថាមនុស្សម្នាក់ៗ ដែលត្រូវគេរំលោភបំពានលើសិទ្ធិ និងសេរីភាពដែលត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញានេះ មានសិទ្ធិទទួលបាននូវមូលនិធិប៉ះប៉ូវណាមួយប្រកបដោយប្រសិទ្ធិភាព ទោះបីថាការរំលោភបំពាននោះ ត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលដែលមានតំណែងមុខងារផ្លូវរដ្ឋក្តី"។

នៅក្នុងប្រទេសមួយចំនួននៃទន្លេមេគង្គ ដូចជានៅក្នុងប្រទេសវៀតណាមជាដើម ភាពខ្វះខាតដីធ្លីសម្រាប់ក្រុមជនជាតិដើម នៅតែជាបញ្ហាសេសសល់មួយ ដូចមានបង្ហាញនៅក្នុងប្រអប់អត្ថបទខាងក្រោមនេះ ៖

ប្រអប់អត្ថបទ៧.១ ការខ្វះដីធ្លីសម្រាប់បង្កបង្កើនផល

ការរៀបចំផែនការតាំងទីលំនៅថ្មី មិនបានធានាចំពោះបញ្ហាដីធ្លី (មានការខ្វះខាតធ្ងន់ធ្ងរផ្នែកដីធ្លី) សម្រាប់ការដាំដុះរបស់ប្រជាពលរដ្ឋ ឬមានដីគ្រប់គ្រាន់ហើយ ប៉ុន្តែមិនអាចដាំដុះអ្វីបាន ។ ឧទាហរណ៍ គម្រោងវារីអគ្គិសនីបាន់វេ (Ban Ve) ប្រជាពលរដ្ឋភូមិគីមលាន (Kim Lien) ដែលតាំងទីលំនៅថ្មីរយៈពេល៣ឆ្នាំទៅហើយ នៅក្នុងភូមិថាញ់ជួង ភូមិញេអាន នៅតែពុំមានដីធ្លីសម្រាប់ការដាំដុះដដែល។ នៅក្នុងភូមិនេះ មានប្រជាជនមួយចំនួនចូលទៅក្នុងព្រៃដើម្បីរកឫស្សី ខ្លះទៀតជំពាក់បំណុលគេដើម្បីស្វែងរកប្រាក់ចំណូល ។ ចំណែកប្រជាពលរដ្ឋមកពីភូមិហួងលីញ (គម្រោង Rao Quan) និង ភូមិឡុកប៊ុន (គម្រោងតាត្រាច) ត្រូវបានផ្តល់ដីចំនួន១ហិចតាក្នុងមួយគ្រួសារ ប៉ុន្តែនៅតែមិនអាចដាំដុះអ្វីបាន រហូតដល់ធ្វើឲ្យប្រជាពលរដ្ឋកាន់តែច្រើនឡើងសរុបជាង៣០% នៃប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង បានវិលត្រឡប់ទៅរស់នៅផ្នែកខាងលើអាងស្តុកទឹក រីឯប្រជាពលរដ្ឋចំនួន៣០%ទៀតបានផ្លាស់ទៅរស់នៅទីកន្លែងផ្សេង ហើយប្រជាពលរដ្ឋដែលនៅសេសសល់ទំងប៉ុន្មានបានចេញទៅរកការងារធ្វើនៅតំបន់ផ្សេងៗ។

ទំនាស់រវាងប្រជាជនជាម្ចាស់មូលដ្ឋាន និងប្រជាជនដែលទើបមកតាំងទីលំនៅថ្មី ៖

ការតាំងលំនៅថ្មីនៅទីកន្លែងមួយចំនួន បានបង្កជាជម្លោះ និងភាពតានតឹង រវាងប្រជាជនទើបមកតាំងលំនៅថ្មី និងប្រជាជនម្ចាស់មូលដ្ឋាន ដោយសារតែមានតម្រូវការប្រកួតប្រជែងលើធនធានផ្សេងៗ។ នេះជាករណីកើតឡើងនៅឃុំហាងឡុង (Hien Luong) ស្រុកដាបាក់ (Da Bac) ក្នុងខេត្តហ័រប៊ិញ (Hoa Binh)។ ដំបូងឡើយ អ្នកភូមិជិតខាងមានចិត្តសន្តោះប្រណៃ និងបានទទួលស្វាគមន៍ ដោយបានជួយអ្នកចំណូលថ្មីឲ្យបានផ្លាស់ទីទៅកាន់ភូមិឡុងភុង (Luong Phong)។ ទោះជាយ៉ាងណាចំនួនប្រជាពលរដ្ឋបានកើនឡើង បង្កជាផលប៉ះពាល់កាន់តែខ្លាំងដល់ភូមិម៉ៃ (Mai) និងភូមិញុយ (Ngu) ដោយសារធនធានព្រៃឈើ និង ដីធ្លីដែលមានស្រាប់សម្រាប់ប្រកបរបរកសិកម្ម ត្រូវស្ថិតក្នុងស្ថានភាពមានសម្ពាធលើការធ្វើអាជីវកម្ម និងប្រើប្រាស់ជ្រុលហួស។ នៅក្នុងភូមិម៉ៃ ការប្រើប្រាស់អស់នូវធនធានព្រៃឈើ បានបណ្តាលឱ្យមានភាពខ្វះខាតម្ហូបអាហារបន្ថែម និងប្រភពចំណូលនានា ហើយភូមិនោះបានឆ្លើយតបចំពោះតម្រូវការផ្សេងៗដោយការប្រមូលផលពី

ព្រៃឈើហូសកម្រិត ក្នុងគោលបំណងដើម្បីទទួលបានផលច្រើនតាមដែលអាចធ្វើទៅបាន នៅមុនពេលដែលអ្វីត្រូវអស់គ្មានសល់ ។ ការទំនាក់ទំនងរវាងប្រជាពលរដ្ឋនៅភូមិ ឡុងផុង (Luong Phong) និងប្រជាពលរដ្ឋនៅក្នុងភូមិម៉ៃ (Mai) និង ភូមិញុយ (Ngu) ចាប់ផ្តើមល្អក់កករដោយសារធនធានផ្សេងៗកាន់តែខ្សត់ទៅៗ ព្រោះតែកំណើនប្រជាជនដែលមកតាំងទីលំនៅថ្មីនៅក្នុងភូមិឡុងភុង មានចំនួនច្រើនមិននឹកស្មាន។ អ្នកភូមិម៉ៃថែមទាំងបានបាញ់សម្លាប់ សូម្បីតែសត្វក្របីដែលបានដើរឆ្លងកាត់មកស៊ីផលដំណាំរបស់អ្នកភូមិ និងដែលបានដើរវង្វេងចូលក្នុងដីស្រែចម្ការរបស់អ្នកភូមិទៀតផង។

នៅក្នុងករណីគម្រោងទំនប់ដែលមានទំហំធំ និងសំណង់អាគារវារីអគ្គិសនីធំៗ ត្រូវមានកាតព្វកិច្ចអនុវត្តលើកិច្ចព្រមព្រៀងផ្តល់មូលនិធិពីគម្រោងនោះ ដែលជាញឹកញាប់ស្ថិតក្នុងស្ថានភាពនៃកិច្ចព្រមព្រៀងជាកិច្ច-សន្យា និងឬជាកិច្ចព្រមព្រៀងអន្តរជាតិ/ ដែលបានបង្កើតជាការទទួលខុសត្រូវខាងផ្លូវច្បាប់សម្រាប់ផ្តល់ជាមូលនិធិប៉ះប៉ូវ។

មូលនិធិប៉ះប៉ូវ/ ការជួសជុលសងត្រូវបានកំណត់អត្ថន័យដោយច្បាប់អន្តរជាតិ ថាជាសកម្មភាពមួយ ឬដំណើរការមួយសម្រាប់ធ្វើការជួសជុលសង ធ្វើឱ្យមានការកែប្រែ ឬ ផ្តល់សំណងសម្រាប់ការខូចខាតផ្សេងៗ ។ ទម្រង់នៃការផ្តល់សំណងដែលត្រូវបានទទួលស្គាល់ជាទូទៅមាន៣ទម្រង់ គឺ៖

- សំណងបដិទាន។

សំណងនេះ គឺត្រូវបានរចនាឡើងដើម្បីកំណត់ឲ្យភាគីប្រព្រឹត្តិអាចត្រឡប់មកទទួលខុសត្រូវវិញចំពោះអ្វីដែលបានកើតឡើង ប្រសិនបើការរំលោភបំពានមិនបានកើតឡើង ។ តួយ៉ាងជាផ្នែកមួយនៃកំណែទម្រង់ដីធ្លីនៅអាហ្វ្រិកខាងត្បូង ជាពិសេសសម្រាប់ជានីតិវិធីនៃសំណងបដិទានសហគមន៍ម៉ាគុលិកេ (Makuleke) ដែលត្រូវបានផ្លាស់ទីលំនៅពីឧទ្យានជាតិKruger កាលពីឆ្នាំ១៩៦៩ បានទទួលមកវិញនូវដីធ្លីទាំងមូលរបស់ពួកគេ (ទោះបីជាមានកិច្ចព្រមព្រៀងជុំវិញការប្រើប្រាស់ដី និងការអភិវឌ្ឍវិស័យទេសចរណ៍សមស្របយ៉ាងណាក្តី)។

- ការធានាសង/ការទូទាត់សំណង។

- ចំនុចនេះជាប់ពាក់ព័ន្ធនឹងការទូទាត់ជាសាច់ប្រាក់របស់ភាគី ដែលបានធ្វើឲ្យខូចខាតដល់ផលចំណេញ គុណតម្លៃ ឬ ទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋ ។ នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ការទូទាត់សំណង ជាធម្មតាសំដៅដល់ការទូទាត់ទៅឱ្យប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីសម្រាប់ទូទាត់សងលើការខូចខាតទុនសកម្ម ឬទ្រព្យសម្បត្តិផ្សេងៗ ។ គម្រោង ភ្នាក់ងារ ឬ រដ្ឋ ក៏អាចនឹងផ្តល់ផងដែរនូវថវិកាសំណងដើម្បីដោះស្រាយបញ្ហាសង្គមសេសសល់ ទាក់ទងនឹងភាពមិនអនុលោមតាមគោលការណ៍ណែនាំ និង/ឬអន្តរជាតិច្បាប់ ឧទាហរណ៍ដើម្បីដោះស្រាយចំពោះប្រជាពលរដ្ឋដែលបានបំលាស់ទី ខណៈពេលប្រព្រឹត្តិហូសលើសនីតិវិធី និង គោលការណ៍ដែលបានព្រមព្រៀងគ្នារួច

ហើយ។ នៅសាធារណរដ្ឋប្រជាមានិតចិន នៅហ្គាតឺម៉ាឡា (Guatemala) នៅប្រទេសប៉ាគីស្តាន និង នៅប្រទេសថៃ ធនាគារពិភពលោក (រួមគ្នាជាមួយនឹងដៃគូរបស់ខ្លួន ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារអភិវឌ្ឍន៍អន្តរអាមេរិក និងរដ្ឋាភិបាលថ្នាក់ជាតិ ដែលបានអនុម័តលើគោលនយោបាយ របស់ធនាគារពិភពលោក ស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត សម្រាប់គម្រោងដាច់ដោយ ឡែកមួយនៅក្នុងទិដ្ឋភាពដើម្បីធ្វើមានលក្ខណៈចាំបាច់ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ សុទ្ធតែបានត្រៀម រៀបចំរួចជាស្រេចនូវមូលនិធិប៉ះប៉ូវដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ពីគម្រោងមុនៗ។

○ ការជម្រះឲ្យរួច (បំណុល)។

• ប្រការនេះរួមបញ្ចូលស្នើរតែគ្រប់ទម្រង់ការជួសជុលសង និង ដើម្បីដោះស្រាយចំពោះការខូចខាតមិនមែនជាសម្ភារៈ តាមរយៈការសុំទោសជាផ្លូវការ។ល។ នៅក្នុងករណីគម្រោងទំនប់ និងគម្រោងវារីអគ្គិសនីធំៗ មិនបានឆ្លើយតបតាមកាតព្វកិច្ចឡើយ ដោយសារតែការបម្រុងថវិកាមិនបានត្រឹមត្រូវ ដែលជាហេតុធ្វើឲ្យការជម្រះបំណុលអាចនឹងរួមបញ្ចូលទាំងនីតិវិធីព្រហ្មទណ្ឌ ការទទួលសារភាពជាសាធារណៈ និង ការសុំទោសជាផ្លូវការដល់អ្នកទាំងឡាយណា ដែលបានទទួលរងនូវផលអាក្រក់ទាំងឡាយ។ ការធន់ទ្រាំ និង/ឬការទាមទារតវ៉ាចំពោះសំណងបដិទាន និងការទូទាត់សំណង ប្រកបដោយជោគជ័យ ក៏ជាទម្រង់ជាក់ស្តែងនៃការជម្រះឲ្យរួចបំណុលផងដែរ [(យោង២៥)]។

ដើម្បីផ្តល់នូវការជួសជុលសំណង ដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ តម្រូវឱ្យមានការពិចារណាមិនត្រឹមតែខាងផ្នែកនយោបាយពីសំណាក់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសំណាក់ភ្នាក់ងារអន្តរជាតិ និងស្ថានប័នហិរញ្ញវត្ថុផ្សេងៗ។ នៅពេលដែលមានការទាមទារជាច្រើនលើការជួសជុលសំណង ការទូទាត់សំណងប្រតិសកម្ម និងសំណងប៉ះប៉ូវ ឧទាហរណ៍ដូចជាការទាមទារដែលមានបញ្ហាក់យ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ Manibeli កាលពីឆ្នាំ១៩៩៤ សេចក្តីថ្លែការណ៍Curitiba កាលពីឆ្នាំ១៩៩៧ និងសេចក្តីថ្លែការណ៍ចុងក្រោយនៃសវនាការអាប្រ៊ិកខាងត្បូង ចំពោះសហគមន៍រងផលប៉ះពាល់ពីគម្រោងទំនប់កាលពីខែវិច្ឆិកា ឆ្នាំ ១៩៩៩ សវនាការអាប្រ៊ិកខាងត្បូងសម្រាប់សហគមន៍រងផលប៉ះពាល់ពីទំនប់ ប៉ុន្តែការឆ្លើយតបមិនមានច្រើនទេ ៖

[(យោង២៥)] ក្នុងបរិបទនេះ ការថែទាំត្រូវតែជាប់ទាក់ទងនឹងកម្រិតនៃការជម្រះឲ្យរួចបំណុល: ជាការពិតណាស់ មានសំណួរលើកឡើងថាតើគួរតែកាត់ទោសប្រហារជីវិតចំពោះមន្ត្រីរដ្ឋាភិបាលរបស់ប្រទេសចិន ដែលបានអនុវត្តមិនត្រឹមត្រូវចំពោះមូលនិធិសម្រាប់ការតាំងលំនៅថ្មីក្នុងអំឡុងដំណើរការគម្រោងទន្លេបី (Three Gorges Project) ដែលត្រូវបានចាត់ទុកថាជាការជម្រះឲ្យរួច។

- ប្រទេសចិនធ្លាប់ជាប្រទេស ដំបូងគេដែលបានអនុវត្តនីតិវិធីភ្ជាប់កាតព្វកិច្ចជាផ្លូវច្បាប់ ដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់ជាប្រព័ន្ធ តាមរយៈមូលនិធិសម្រាប់ការតាំងលំនៅថ្មី និង ការស្តារនីតិសម្បទាសម្រាប់គម្រោងធារាសាស្ត្ររបស់ខ្លួននៅឆ្នាំ ១៩៨៦ ដែលមានគោលដៅធ្វើឲ្យប្រសើរឡើងនូវលក្ខខ័ណ្ឌជីវភាពរបស់អ្នកតាំងទីលំនៅថ្មីប្រមាណជា ៥លាននាក់នៅជុំវិញតំបន់តាំងទីលំនៅថ្មីចំនួន៤៦កន្លែង។
- នៅក្នុងឆ្នាំ១៩៩៤ កិច្ចប្រជុំសភានៃសហរដ្ឋអាមេរិកបានឆ្លើយតបចំពោះ ការទាមទារការជួសជុលសំណងដែលបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៥១ ដោយសហព័ន្ធនៃជនជាតិដើមកំណើតអាមេរិក ដែលបានបាត់បង់ផ្ទះសម្បែង ដីធ្លី និងត្រីសាល់ម៉ុងដែលរត់ចេអពីទន្លេអស់ ដោយសារតែការសាងសង់ទំនប់Grand Coulee និង នៅតាមអាងទន្លេកូឡុំប៊ី ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បន្ទាប់ក្រោយមកតុលាការបានសម្រេចរឿងក្តីនេះ ដោយមានការពេញចិត្តពីជនជាតិដើមទាំងនោះ។

- សម្ពាធរបស់អ្នជំនាញខាងហិរញ្ញវត្ថុ។

កើតចេញពីការជជែកពិភាក្សាគ្នានៅជុំវិញបញ្ហាទំនប់ និងសំណង់អាគារវារីអគ្គិសនីដែលមានទំហំធំ គឺមានភាពរសើបជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដើម្បីកំណត់ថា "ត្រូវធ្វើអ្វីតាមវិធីត្រឹមត្រូវ ហើយអ្វីដែលបានធ្វើត្រូវតែមើលទៅឃើញថាបានធ្វើក្នុងវិធីត្រឹមត្រូវ " ។ តាមរយៈបរិបទនេះ ការអនុវត្តចំពោះការផ្តល់ជំនួយហិរញ្ញវត្ថុ និង/ឬការផ្តល់ប្រាក់កម្ចីត្រូវបានប៉ាន់ស្មាន និងវាយតម្លៃនៅក្នុងបរិបទនៃគម្រោងមុនៗ។ នេះអាចនាំឱ្យស្ថាប័នហិរញ្ញវត្ថុដាក់សម្ពាធលើរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីឲ្យដោះស្រាយលើបញ្ហាសង្គម ដែលសេសសល់ពីគម្រោងមុនៗ ក្នុងក្របខ័ណ្ឌនៃគម្រោងកំពុងដំណើរការបច្ចុប្បន្ន ។ ករណីបានកើតឡើងនៅអាហ្វ្រិកខាងត្បូង ដែលរដ្ឋាភិបាលបានស្វែងរកជំនួយហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និង ខ្សែបណ្តាញបញ្ជូនចរន្តអគ្គិសនី ក៏ដូចជាប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលមានលក្ខខ័ណ្ឌលើការដោះ-ស្រាយបញ្ហាសង្គមនៅសេសសល់ឃ្លរអង្វែងដែលបានកើតឡើងដោយសារគម្រោងទំនប់វារីធំៗពីមុន។

ប្រអប់អត្ថបទ៧.៣ មូលនិធិទ្រទ្រង់ដំណាក់កាលបន្ទាប់សម្រាប់គម្រោងវារីអគ្គិសនីទើបចាប់ផ្តើមថ្មី និងគម្រោងរក្សាទឹកទើបដំណើរការថ្មី នៅសាធារណរដ្ឋប្រជាមានិតចិន

ប្រទេសចិនជាប្រទេសដែលមានទំនប់វារីអគ្គិសនីធំៗជាង ២២,០០០ទំនប់ធំ និងជាប្រទេសសកម្មបំផុតក្នុងការសាងសង់ទំបន់នានា ។ មានប្រជាពលរដ្ឋប្រមាណជា១២លាននាក់ ត្រូវបានផ្លាស់ទីលំនៅថ្មីចេញពីអាងស្តុកទឹក និងតំបន់សាងសង់ទំនប់។ នៅមុនឆ្នាំ១៩៨០ ប្រជាពលរដ្ឋបានតាំងលំនៅថ្មីរបស់ខ្លួនដោយគ្មានការរៀបចំជាផែនការសមរម្យ ឬដោយគ្មានចូលរួមឡើយ រួមជាមួយនឹងការផ្តល់សំណងមិនគ្រប់គ្រាន់ កង្វះដីធ្លីសម្រាប់ប្រកបរបរកសែចម្ការ និង ជាញឹកញាប់ ត្រូវបានបំលាស់ទីទៅកាន់តំបន់តាំងទីលំនៅថ្មី ដែលមិនអំណោយផល។ នៅក្នុងឆ្នាំ១៩៨៩ ការិយាល័សង្គ្រោះជនក្រីក្របានទទួលស្គាល់ថាតាមការប៉ាន់ ស្មានមានអ្នកតាំងលំនៅថ្មីដែលបានផ្លាស់ទីពីអាងស្តុកទឹកប្រមាណជា៧០% កំពុងរស់នៅក្នុងស្ថានភាពក្រីក្រយ៉ាងខ្លាំងនៅឡើយ។

ចាប់តាំងពីឆ្នាំ១៩៨០ បទប្បញ្ញត្តិស្តីពីការតាំងលំនៅថ្មី បានវិវត្តរីកចម្រើនបន្តិចម្តងៗ ហើយបានផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើបញ្ហាសង្គម និងបរិស្ថាន។ គម្រោងផ្តួចផ្តើមគំនិតថ្មីបំផុតរបស់រដ្ឋាភិបាលនៅក្នុងបញ្ហានេះ គឺសំដៅដល់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលដីធ្លីនៃសាធារណរដ្ឋប្រជាមានិតចិន)បានកែសម្រួលឡើងវិញនៅឆ្នាំ១៩៨៦ និងឆ្នាំ១៩៩៦)។ ច្បាប់នេះបានធានាថា ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងមិនត្រឹមតែអាចទទួលបានការទូទាត់សំណងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានឧបត្ថម្ភធនគ្រប់គ្រាន់សម្រាប់ការស្តារជីវភាពរស់នៅឡើងវិញទៀតផង ។ ច្បាប់នេះតម្រូវឱ្យក្រុមប្រឹក្សារដ្ឋអនុម័តលើគំរូស្តង់ដានៃផែនការទូទាត់សំណង និង ការផ្តល់សិទ្ធិឲ្យភាគីពាក់ព័ន្ធបានចូលរួមក្នុងការរៀបចំបង្កើតវិធានការបន្ទូរបន្ថយ។ បើទោះបីជាមានការកែលម្អជាទូទៅក៏ដោយ ក៏នៅមានបញ្ហាសង្គមជាច្រើនបានបន្តលេចឡើងក្នុងក្របខ័ណ្ឌគម្រោង (ដីនៅក្នុងតំបន់តាំងទីលំនៅថ្មីមិនសូវមានជីវជាតិ ការលំបាកដល់កសិករក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅតំបន់ទីប្រជុំជន ហើយបង្កជាការប៉ះពាល់ដល់បណ្តាញទំនាក់ទំនងសង្គមបៃបប្រពៃណីរបស់ពួកគេ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះដែលបានកើតឡើងស្ទើរតែគ្រប់គម្រោងទាំងអស់ បើទោះជាមានផែនការតាំងលំនៅថ្មីរួមនិងក្របខណ្ឌសង្គមក្តី ប៉ុន្តែបញ្ហាទាំងនេះនៅតែមិនអាចកាត់បន្ថយបាន ដូច្នេះហើយទើបការគណៈកម្មការផែនការរបស់រដ្ឋបានសម្រេចចិត្តប្រើប្រាស់នូវក្របខ័ណ្ឌជាគោលនយោបាយចំនួនពីរ ដូចខាងក្រោម ៖

- បញ្ហាសង្គមដែលមិនទាន់បានដោះស្រាយនៅតាមគម្រោងដែលកំពុងដំណើរការ ត្រូវតែដោះស្រាយតាមរយៈមូលនិធិសម្រាប់ក្រោយការតាំងលំនៅថ្មី និងពេលតាំងទីលំនៅថ្មី ចំពោះគម្រោងស្រោច-ស្រពនៅថ្នាក់ជាតិ។

- ចំពោះគម្រោងថ្មី ត្រូវតែដោះស្រាយបញ្ហាសង្គមដែលសេសសល់ តាមរយៈមូលនិធិទ្រទ្រង់ដំណាក់កាលបន្ទាប់ (LSSF) នៅកម្រិតគម្រោង ដែលមិនអាចប្រមើលឃើញជាមុនបានក្នុងពេលរៀបចំផែនការរួម ប៉ុន្តែអាចនឹងលេចឡើងបន្ទាប់ពីដំណាក់កាលសាងសង់រួច។

មូលនិធិទ្រទ្រង់ដំណាក់កាលបន្ទាប់ (LSSFs) តម្រូវឲ្យមានជាចាំបាច់ចំពោះគម្រោងវារីអគ្គិសនីទាំងអស់ដែលត្រូវបានបិទបញ្ចប់ចន្លោះឆ្នាំ១៩៨៦ និងឆ្នាំ១៩៩៥ ក៏ដូចជាចំពោះគម្រោងវារីអគ្គិសនីថ្មីទាំងអស់ ព្រមទាំងគម្រោងរក្សាទឹកដែលបានអនុញ្ញាតនៅក្រោយឆ្នាំ១៩៩៦ ។ មូលនិធិទ្រទ្រង់នេះ ត្រូវបានបង្កើតឡើងជាទូទៅសម្រាប់រយៈកាល១០ឆ្នាំ និងបានផ្តល់ហិរញ្ញប្បទាន តាមរយៈការលក់ថាមពលអគ្គិសនី។ ថវិការបស់មូលនិធិ (LSSFs) នេះ ត្រូវបានកំណត់ទៅតាមចំនួនអ្នកតាំងលំនៅថ្មីដោយគុណនឹងចំនួនទឹកប្រាក់ដែលអ្នកតាំងទីលំនៅម្នាក់ៗត្រូវទទួលបានក្នុងមួយឆ្នាំពី៣០ដុល្លារសហរដ្ឋអាមេរិក ទៅ ៥០ដុល្លារសហរដ្ឋអាមេរិក ។ បទបញ្ជាត្តិប្រមើលទុកជាមុនថា គម្រោងនេះគួរតែបម្រុងទុកថវិការវាងពី0,0001៥ដុល្លារ ទៅ0,0005 ក្នុងមួយគីឡូវ៉ាត់ម៉ោងនៃអគ្គិសនីដែលផលិតបាន សម្រាប់ទុកជាមូលនិធិទ្រទ្រង់ (LSSFs)។ មូលនិធិទាំងអស់នៅក្នុងខេត្ត ត្រូវបានគ្រប់គ្រងដោយការិយាល័យទទួលបន្ទុកការតាំងលំនៅថ្មីរបស់ថ្នាក់ខេត្ត ។ ដោយមានការរួមបញ្ចូលគ្នាជាមួយនឹងការផ្តោតកាន់តែខ្លាំងនៅលើការតាំងលំនៅថ្មីជាការធិសោធន៍សាកល្បង ការបណ្តុះណ្តាលកសិករ ការកើនឡើងនៃការពិភាក្សានិងការចូលរួមរបស់ភាគីពាក់ព័ន្ធ និង ការអនុវត្តន៍តាមបែបវិមជ្ឈការកាន់តែមានចំនួនច្រើន នោះមូលនិធិសំណងប៉ះប៉ូវសម្រាប់គម្រោងថ្មីៗ គួរតែអាចកាត់បន្ថយបញ្ហាសង្គមដែលមិនបានប្រមើលឃើញជាមុន។

ប្រអប់អត្ថបទ៧.៤ ការណែនាំបង្ហាញពីបញ្ហាសង្គមដែលនៅសេសសល់ - ទិដ្ឋភាពគន្លឹះ

បញ្ហាសង្គមដែលនៅសេសសល់ ជាពិសេសបញ្ហាទាំងឡាយណា ដែលកើតឡើងពីការអភិវឌ្ឍមុនៗដែលមិនដែលត្រូវបានដោះស្រាយ ដោយសារហេតុផលអ្វីក៏ដោយ ប៉ុន្តែទោះយ៉ាងណាត្រូវតែដោះស្រាយជាចាំបាច់។ ចំនុចនេះមានការប្រែប្រួលដោយសារមូលហេតុផ្សេងៗ រួមមាន ៖

- ការទទួលយកជាសាធារណៈ តាមរយៈ:
  - o មូលនិធិប៉ះប៉ូវទូលំទូលាយ។
  - o ការិយាល័យតំណាងប្រជាពលរដ្ឋ។
- ការអនុលោមទៅតាមសិទ្ធិក្នុងការទទួលបានមូលនិធិប៉ះប៉ូវ តាមរយៈ:
  - o សំណងបដិទាន។
  - o ការធានាសង/ការទូទាត់សំណង។

o ការជម្រះឲ្យរួច (បំណុល) o សម្ភាធរបស់អ្នជំនាញខាងហិរញ្ញវត្ថុ។

ប្រធានបទពិភាក្សា	នៅក្នុងប្រទេស កំពុងអភិវឌ្ឍន៍ខាងសេដ្ឋកិច្ចជាច្រើន រដ្ឋាភិបាលត្រូវជួបនឹងបញ្ហាប្រឈម ក្នុងការអភិវឌ្ឍជាច្រើនដែលតម្រូវឱ្យមានការវិនិយោគហិរញ្ញវត្ថុជាពិសេស ដែលភាគច្រើនបានមកពីប្រភពថវិកាជាតិមួយផ្នែក។ ចូរពិភាក្សាអំពីលទ្ធភាពទទួលបានមូលនិធិ ដើម្បីដោះស្រាយបញ្ហាសង្គមនៅសេសសល់ដែលរដ្ឋាភិបាលពេលខ្លះជឿថាបញ្ហាសង្គមទាំងនេះ គ្រាន់តែតំណាងឱ្យបញ្ហាប្រឈមនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដែលមិនគួរតម្រូវឲ្យមានការគិតគូរពិចារណាពិសេសឡើយ។ ..... ចូរពិភាក្សាអំពីរបៀបមួយដែលប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវជៀសវាងពីការទទួលយកផលប្រយោជន៍ពីគម្រោង ដោយការបង្កើនសេចក្តីត្រូវការលើការអភិវឌ្ឍដែលគ្រោង ក្នុងក្របខ័ណ្ឌនៃការដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់។
លំហាត់	ចូរកំណត់ឲ្យឃើញ ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗ នៅក្នុងប្រទេសរបស់អ្នកដែលការអភិវឌ្ឍន៍នោះមានបន្សល់ទុកនូវបញ្ហាសង្គមនានាដែលចាំបាច់ត្រូវដោះស្រាយ ។ តើបញ្ហាសង្គមដែលនៅសេសសល់ទាំងនោះមានអ្វីខ្លះ ហើយគួរដោះស្រាយដោយរបៀបណា? ..... ចូរបរិយាយឲ្យបានល្អិតល្អន់ថាតើគម្រោងគួរ ឬ មិនគួរកែសម្រួលលើពេលវេលាកំណត់ នៅពេលកាលបរិច្ឆេទត្រូវផុតកំណត់ ហើយដែលគ្មានផលប៉ះពាល់គម្រោងណាបន្ថែមទៀតនឹងត្រូវពិចារណាសម្រាប់ការទូទាត់សំណង ឬសម្រាប់ការកែតម្រូវឡើយ។ តើអ្វីខ្លះជាគុណសម្បត្តិ និងគុណវិបត្តិ?

៧.២ តើបញ្ហាសង្គមដែលនៅសេសសល់ត្រូវបានដោះស្រាយរបៀបណា?

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺផ្តល់នូវចំនុចសំខាន់ៗស្តីពីយន្តការដែលមានបច្ចុប្បន្នសម្រាប់ដោះស្រាយចំពោះបញ្ហាសង្គមដែលនៅសេសសល់។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីយន្តការណ៍សំខាន់ៗ ដែលមានស្រាប់ដើម្បីដោះស្រាយចំពោះបញ្ហាសង្គមដែលនៅសេស សល់។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តី-សម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ ផ្នែកទី៥ ៖ ការដោះស្រាយលើទិដ្ឋភាពសង្គម (ផ្នែកទី៥.២-ដំណោះស្រាយលើបញ្ហាសង្គមដែលសេសសល់) ។ www.unep.org/dams

មានឧបករណ៍សំខាន់ៗចំនួន៥ ដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាសង្គមដែលនៅសេសសល់។

៧.២.១ មូលនិធិប៉ះប៉ូវ និងទម្រង់ផ្សេងៗទៀតនៃការទូទាត់សំណង

មានឧបករណ៍ដែលអាចផ្តល់ភាពងាយស្រួលបំផុត និង ដែលសមទំនងបំផុត ដោយសារតែឧបករណ៍ទាំងនោះលាតត្រដាងឲ្យឃើញពីការធានាស្តារជីវភាពរស់នៅឡើងវិញ ដូចដែលបានព្រមព្រៀងគ្នានៅក្នុងផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មីជាបណ្តោះអាសន្ន ហើយដែលបញ្ហានានាមិនត្រូវបានដោះស្រាយឲ្យរួចរាល់តាំងពីដើមនៅក្នុងផែនការនោះឡើយ ។ ដោយសារតែភាគីទាំងអស់បានព្រមព្រៀងគ្នាថាគ្មានបុគ្គលណាម្នាក់ត្រូវទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីទំនប់ ឬ ពីគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដែលមានទំហំធំ ប៉ុន្តែជាការសមទំនងបំផុតក្នុងការផ្តល់មូលនិធិជាចាំបាច់ដើម្បីធានា ចំនុចនេះក៏ជាករណីនៃការព្រមព្រៀងដោះស្រាយចំពោះបញ្ហាទាំងឡាយដែលមិនបានដោះស្រាយ នៅក្នុងផែនស្តីពីការទូទាត់សំណង និងផែនការកាត់បន្ថយផងដែរ។

ចំនុចខ្វះខាតដែលលើកឡើងដោយប្រជាពលរដ្ឋរងផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ត្រង់ថាប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវទាមទារសំណងពីមូលនិធិនានា និងដើម្បីផ្តល់ជាភស្តុតាងដើម្បីទទួលបានសំណងប៉ះប៉ូវ ។ នៅក្នុងបរិបទនេះតម្រូវឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ស្នើសុំអ្វីមួយពីគម្រោងឧទាហរណ៍ដូចជាក្នុងខណៈពេលដែលអ្វីមួយដែលបានដាក់ស្នើរសុំពីគម្រោងរួចហើយ ប៉ុន្តែមិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួន ។ ដូច្នេះអង្គការក្រៅរដ្ឋាភិបាលបានលើកឡើងថា ការដោះស្រាយលើបញ្ហាសង្គមដែលនៅសេសសល់ មិនគួរត្រូវដាក់បានកំណត់ ឬ ផ្អែកលើទាមទារតវ៉ារបស់ប្រជាពលរដ្ឋរងផលប៉ះពាល់នោះទេ ប៉ុន្តែគួរតែផ្អែកលើការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពបន្ថែមទៀត និងលើប្រព័ន្ធវាយតម្លៃ ដែល

អាចផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ថាតើការអនុលោមតាមច្បាប់ត្រូវបានសម្រេចបានដែរឬទេ ឬថាតើបញ្ហាសង្គមបន្តសេសសល់បន្ថែមទៀត ចាំបាច់ត្រូវដោះស្រាយមុនពេលដំណើរការសាងសង់គម្រោងត្រូវបានបិទជាផ្លូវការដែរឬទេ។ មូលនិធិប៉ះប៉ូវត្រូវបានអនុវត្តតាម៣ទម្រង់ ៖

- សំណងជាសាច់ប្រាក់ (ការបូកសរុបរួម)។

ការទូទាត់សងជាកញ្ចប់បូកសរុបរួម មានភាពងាយស្រួលជាងក្នុងការគ្រប់គ្រង មានការចំណាយ ទាបលើការដោះស្រាយការងារ និងផ្តល់ឲ្យអ្នកទទួលមានសេរីភាពដើម្បីប្រើប្រាស់ថវិកាទាំងនោះទៅតាមឆន្ទៈរបស់ពួកគេ។ ទោះយ៉ាងណានៅមានហានិភ័យត្រង់ថាថវិកាទាំងនោះអាចត្រូវបានប្រើប្រាស់ដោយគ្មាននិរន្តរភាព និង/ឬប្រហែលជាមិនអាចធានា សុខុមាលភាពសេដ្ឋកិច្ច និងសង្គមរយៈពេលវែងរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង (ដែលបញ្ហាស់មកវិញ អាចបង្កឲ្យមានបញ្ហាសង្គមនៅសេសសល់) ។ ការបង់ប្រាក់សំណងបូកសរុបរួមមួយចំនួនត្រូវប្រគល់ទៅឲ្យបុគ្គលម្នាក់ៗ មួយចំនួនទៀតប្រគល់ទៅឲ្យស្ថាប័នអង្គការជាអ្នកបែងចែងឲ្យប្រជាពលរដ្ឋរងផលប៉ះ-ពាល់ពីគម្រោងប្រគល់ទៅឲ្យគណៈកម្មការតំណាងភាគីពាក់ព័ន្ធ ទៅឲ្យអាជ្ញាធរមូលដ្ឋាន ឬទៅឲ្យរដ្ឋាភិបាល ។ អ្វីដែលសំខាន់ គឺករណីនីមួយៗមានភាពខុសគ្នា ហើយត្រូវបានទាមទារឲ្យមានវិធីសាស្ត្រ និងដំណោះស្រាយតាមទម្លាប់ធ្លាប់ធ្វើ។

នៅក្នុងករណីទំនប់ម៉ុនប៉ាក (Mun Pak) នៅពេលដែលសេដ្ឋកិច្ចប្រទេសថៃបានរីកដុះដាលឡើង ការទូទាត់សំណងបូកសរុបរួមបានប្រព្រឹត្តិទៅយ៉ាងល្អ សម្រាប់ដោះស្រាយចំពោះការធ្លាក់ចុះនៃប្រាក់ចំណូលរប់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារការ ការស្តុកត្រីត្រូវធ្លាក់ចុះ ប៉ុន្តែត្រូវបានរិះគន់យ៉ាងខ្លាំងនៅពេលការបណ្តាក់ទុនត្រូវធ្វើឡើងជាមួយនឹងសំណងជាសាច់ប្រាក់ ដែលមិនបានផ្តល់នូវប្រាក់ចំណូលរយៈពេលវែង។ នេះជាហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗដែលធ្វើឲ្យគោលនយោបាយ និងបទដ្ឋានច្បាប់ភាគច្រើន ផ្តល់ដំបូន្មានប្រឆាំងនឹងការផ្តល់សំណងបូកសរុបរួម។ ទោះជាយ៉ាងណាហានិភ័យនេះអាចត្រូវបន្ធូរបន្ថយបាន ឧទាហរណ៍ តាមរយៈការពង្រីកការទូទាត់សំណងបូកសរុបរួម តាមរយៈការបង់រម្លស់ប្រចាំឆ្នាំ ដើម្បីធ្វើឲ្យបញ្ហាសង្គមដែលមិនទាន់បានដោះ-ស្រាយបង្កឡើងដោយមូលនិធិសំណង អាចត្រូវបានដោះស្រាយ នៅជំហានបន្ទាប់ជាមួយមូលនិធិថ្មី។

- សំណងជាសាច់ប្រាក់ (ការបង់រម្លស់ប្រចាំឆ្នាំ) ។

មូលនិធិសំណងប៉ះប៉ូវតាមទម្រង់នេះ ភាគច្រើនគឺជា ការតាមដាននិងបន្ថែមពីលើសំណងបូកសរុបរួម ការចែករំលែកផលប្រយោជន៍នៃការទូទាត់ការបូកសរុបរួម ការបែងចែកផលប្រយោជន៍នៃការទូទាត់សំណងបូកសរុបរួម ប៉ុន្តែអាចកាត់បន្ថយហានិភ័យដែលថា មូលនិធិនេះមិនអាចយកទៅដោះស្រាយបញ្ហាសង្គមទាំងអស់ដែលនៅសេសសល់ ។ វិធីដ៏សាមញ្ញបំផុតនៃការស្តុកមូលនិធិ

ទុក គឺអាចបានតាមរយៈយន្តការនៃការបែងចែកផលប្រយោជន៍ ។ "សាធារណរដ្ឋប្រជាមានិតចិន បានណែនាំពីប្រព័ន្ធសាមញ្ញមួយ ដោយការធ្វើឱ្យប្រាកដថា រាល់មួយគីឡូវ៉ាត់ភ្លើងដែលផលិតបាន គឺជាចំនួនពិតប្រាកដដែលត្រូវតែផ្ទេរចូលទៅក្នុងមូលនិធិប៉ះប៉ូវ ។ វិធីសាស្ត្រមួយស្រដៀងគ្នានេះដែរ ត្រូវបានប្រើប្រាស់នៅក្នុងប្រទេសន័រវែស ខណៈដែលនៅសហរដ្ឋអាមេរិក និង ប្រទេសកាណាដា ហាក់ដូចជាបានឯកភាពចំពោះការបង់ប្រាក់រម្លស់ប្រចាំឆ្នាំចូលទៅក្នុងមូលនិធិប៉ះប៉ូវ ។ ទិដ្ឋភាពអវិជ្ជមានទាក់ទងនឹងការបង់រម្លស់ប្រចាំឆ្នាំ គឺជាតម្រូវការចាំបាច់ដើម្បីបង្កើតរចនាសម្ព័ន្ធមួយក្នុងការគ្រប់គ្រងមូលនិធិសំណងប៉ះប៉ូវនេះ។ នៅមានជម្រើសជាច្រើនស្តីពីរបៀប និងថាតើនរណាជាអ្នកគ្រប់គ្រងលើមូលនិធិទាំងនេះ (សមាគមរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង អាជ្ញាធរមូលដ្ឋាន គណៈកម្មការតំណាងភាគីពាក់ព័ន្ធ ក្រុមហ៊ុនធានារ៉ាប់រង និង ស្ថាប័នប្រហាក់ប្រហែលដទៃទៀត) ដែលជម្រើសទាំងអស់សុទ្ធតែមានគុណសម្បត្តិ និង ចំនុចខ្វះខាត។ ជាថ្មីម្តងទៀត គឺមិនមានដំណោះស្រាយតែមួយណា និងដំណោះស្រាយជាទម្លាប់ណា ត្រូវបានរកឃើញថា បានបំពេញតាមតម្រូវការជាក់លាក់នៃការកំណត់ផ្សេងគ្នាលើសង្គមនិងប្រជាជនឡើយ។

- ការគាំទ្រដល់ប្រព័ន្ធជីវភាពរស់នៅ។

គោលនយោបាយ និង បទដ្ឋានច្បាប់ស្តីពីការតាំងលំនៅថ្មីមិនមែនជាការស្មុគ្រចិត្ត ផ្តោតសំខាន់ពីតម្រូវការលើការស្តារជីវភាពឡើងវិញ ដោយការនិយមពេញចិត្តទៅលើមូលដ្ឋានសំណងជាដីសម្រាប់ដី។ គោលការណ៍ដូចគ្នានេះ ត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាសង្គមនានា ដែលនៅសេសសល់។ ទោះជាយ៉ាងណា បញ្ហាសង្គមច្រើនជាងគេបំផុតបានកើតឡើង នៅពេលដែលគម្រោងមួយ ឬ រដ្ឋាភិបាលមិនមានលទ្ធភាពក្នុងការផ្តល់សំណងជាដីសម្រាប់ដី ការសងលើឡូនេសាទ/ទីកន្លែងសម្រាប់ការបរបាញ់ ជាឡូនេសាទ/ទីកន្លែងសម្រាប់ការបរបាញ់ ជាដើម ។ បញ្ហានេះកើតឡើងដោយសារតែមានការលំបាកកាន់តែខ្លាំងឡើងៗក្នុងការស្វែងរក និង/ឬ ទទួលបានដីធ្លីជំនួសវិញ ដើម្បីស្តារជីវភាពរស់នៅរបស់កសិករ អ្នកបរបាញ់សត្វ និងអ្នកនេសាទ ដោយមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ប្រជាពលរដ្ឋដទៃទៀត។ ការគាំទ្រដល់ប្រព័ន្ធជីវភាពរស់នៅ អាចប្រែក្រឡប់ការស្តារជីវភាពរស់នៅពីបញ្ហាបច្ចេកទេសមួយ(ពីរបៀបស្វែងរកទ្រព្យសម្បត្តិប្រហាក់ ប្រហែល) ទៅជាបញ្ហាស្មុគស្មាញមួយបន្ថែមទៀត ដោយសារវាជាការតម្រូវឱ្យប្រជាពលរដ្ឋរង ផលប៉ះពាល់ពីគម្រោង ដើម្បីផ្លាស់ប្តូរជីវភាពរបស់ពួកគេ ។ តាមគំរូឧទាហរណ៍បានបង្ហាញថា ប្រការនេះគឺមិនមែនងាយស្រួលនោះទេ ហើយវាជាមូលហេតុចម្បងនៃបញ្ហាសង្គមដែលនៅសេសសល់។

បន្ថែមពីលើនេះទៀត នៅក្នុងប្រទេសមានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច វិធីសាស្ត្រនេះហាក់បីដូចជាប៉ះទង្គិចគ្នាជាមួយផលប្រយោជន៍ផ្សេងៗរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។ នៅ

ក្នុងប្រទេសន័រវែស សំណងជាសាច់ប្រាក់ដោយស្ម័គ្រចិត្ត បានជំនួសទាំងស្រុងនូវការស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងនៅក្នុងប្រទេសអាល្លឺម៉ង់ ត្រូវអំពាវនាវទៅកាន់គណៈកម្មការមួយ ប្រសិនបើពួកគេមិនចង់បានផល-ប្រយោជន៍ពីវិធានការបន្ធូរបន្ថយសមូហភាព ហើយចង់បានការទូទាត់សំណងជាសាច់ប្រាក់ដល់បុគ្គលម្នាក់ៗជាង។

អត្ថបទប្រអប់៧.៥ ទំនប់ប៉ាកមុន (Pak Mun) ក្នុងប្រទេសថៃ

ទំនប់ប៉ាកមុន ស្ថិតនៅជាប់ព្រំប្រទល់រវាងប្រទេសថៃ និងប្រទេសឡាវ ត្រូវបានសាងសង់នៅក្នុងទីតាំងខុសគ្នាមួយ ដែលមានចម្ងាយប្រហែល១,៥គីឡូម៉ែត្រ ពីទីតាំងដែលមានគោលបំណងដើមនៃទំនប់នេះ។ បើយោងទៅតាមផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី គ្រួសារចំនួន១,៧០០គ្រួសារ មកពីភូមិចំនួន៣១ បានបាត់បង់ផ្ទះសម្បែង ដីធ្លី ឬ បាត់បង់ទាំងផ្ទះសម្បែង និងដីធ្លីរបស់ពួកគេ (ប៉ុន្តែបើតាមការសិក្សាផ្សេងទៀត បានរាយការណ៍ថាតួលេខខ្ពស់ជាងនេះ)។ ផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មីដែលមានពីដើមត្រូវបានរៀបចំឡើងដោយអនុលោមតាមគោលនយោការណ៍ណែនាំនិងនីតិវិធីគ្រប់គ្រងការតាំងលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្តរបស់ធនាគារពិភពលោក (ដើម្បីអនុញ្ញាតឲ្យរដ្ឋាភិបាលថៃ មានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការផ្តល់មូលនិធិដោយធនាគារពិភពលោក) ដោយផែនការនោះត្រូវបានធ្វើបច្ចុប្បន្នភាពយ៉ាងប្រញាប់ប្រញាល់ដើម្បីរៀបចំផ្តល់ទីតាំងថ្មីសម្រាប់ទំនប់វារីអគ្គិសនី។ ផលវិបាកមួយដែលបានកើតឡើង គឺភាពខ្វះចន្លោះក្នុងការដោះស្រាយបញ្ហាសង្គមនានា ដោយមិនបានផ្តល់ជាលទ្ធផលគាប់ប្រសើរ ហើយថែមទាំងបានបន្សល់ទុកនូវបញ្ហាសង្គមជាច្រើនដែលមិនបានដោះស្រាយ ដែលមូលហេតុទាំងអស់នេះបានបង្កឲ្យមានចំនួននៃការមិនពេញចិត្តជាច្រើនចំពោះគម្រោងមួយនេះ។

គោលការណ៍ផ្តល់សំណងទៅតាមតម្លៃសងជំនួស និង ការស្តារជីវភាពរស់នៅត្រូវបានអនុវត្តដោយរដ្ឋាភិបាលថៃ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការផ្តល់មូលនិធិពីធនាគារពិភពលោក ហើយក៏ត្រូវបានអនុវត្តផងដែរចំពោះទីតាំងទំនប់ថ្មី ក៏ដូចជាចំពោះប្រជាពលរដ្ឋទាំងអស់ដែលទទួលរងផលប៉ះពាល់ពីគម្រោង ។ ដូច្នេះ អ្នកគាំទ្រគម្រោង អាជ្ញាធរអគ្គិសនីថៃ (EGAT) " បានប្តេជ្ញាចិត្ត ធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់គ្រួសាររងផលប៉ះពាល់ពីគម្រោង តាមរយៈការផ្តល់នូវជម្រើសមួយចំនួន និងការអនុវត្តការតាំងលំនៅថ្មីដោយមានការចូលរួមពីប្រជាពលរដ្ឋរងផលប៉ះពាល់។ បញ្ហានៅត្រង់ថា តើត្រូវបង្កើតឲ្យមានការទូទាត់សំណងដោយយុត្តិធម៌ដោយរបៀបណា " ទោះបីជាដឹងច្បាស់ហើយថាបញ្ហាសង្គមនៅសេសសល់មានចំនួនច្រើនជាងផលប៉ះពាល់សង្គម ដែលបានប៉ាន់ស្មានទុកជាមុនរួចហើយក្តី។

បើគិតជាទស្សនវិស័យខាងបច្ចេកទេស បញ្ហាជាគន្លឹះមួយ គឺការខ្វះខាតមូលដ្ឋានទិន្នន័យតែម្តង។

EGAT បានលើកកម្ពស់ការផ្តល់សំណងជាច្រើនដងរួចមកហើយ រួមទាំងការបង្កើនអត្រា៥ដងនៃទូទាត់សំណងដីធ្លី។ ធនាគារពិភពលោកបានពញ្ជាក់ស្មារតីពីតួនាទីរបស់ខ្លួន ហើយបានបញ្ជាក់ថាការលើកកម្ពស់កញ្ចប់ទូទាត់សំណង " ភាគច្រើនធ្វើឡើងដោយសារតែមានការតវ៉ាដ៏ធំទូលាយពីសំណាក់អ្នកតាំងលំនៅថ្មី និងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រឆាំងនឹងអត្រាសំណងតាមគោលនយោបាយជាមូលដ្ឋាន ។ ដូច្នេះហើយទើប EGAT បានសម្រេចយកជម្រើសនៃការទូទាត់សំណងដោយផ្តល់អត្រាខ្ពស់ជាងនេះច្រើនដើម្បីបញ្ឈប់កុំឲ្យមានការប្តឹងតវ៉ាប្រឆាំងនឹងគម្រោងសាងសង់ទំនប់ប៉ាកមុន ។ យុទ្ធសាស្ត្រនេះទទួលបានជោគជ័យនៅក្នុងការទប់ស្កាត់ការប្រឆាំងតវ៉ានានា។

បញ្ហាសង្គមទីមួយនៅសេសសល់ ដែលទទួលបានការទទួលស្គាល់យ៉ាងច្រើនគឺការទូទាត់សំណងសម្រាប់ការខាតបង់ប្រាក់ចំណូលលើការនេសាទ នៅខាងក្រៅតំបន់តាំងទីលំនៅថ្មី នៅក្នុងកំឡុងពេលសាងសង់ទំនប់។ ការខាតបង់នេះ មិនត្រូវបានដោះស្រាយនៅក្នុងផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី ឬបានការទទួលស្គាល់ជាផ្លូវការ មុនពេលចុងបញ្ចប់នៃដំណាក់កាលសាងសង់ឡើយ ។ នៅពេលដែលទំនប់នេះបានចាប់ដំណើរការកាលពីឆ្នាំ១៩៩៤ បញ្ហានេះមិនត្រូវបានដោះស្រាយទេ ហើយបានអូសបន្លាយរហូតពេញមួយឆ្នាំ ទម្រាំតែសម្រេចបាននូវកិច្ចព្រមព្រៀងមួយ។ ការទូទាត់សំណងនៅជុំទីមួយក្នុងឆ្នាំ១៩៩៦ បានផ្តល់ជូនប្រជាពលរដ្ឋចំនួន៣,000គ្រួសារ ហើយក្រោយមកទៀតនៅឆ្នាំ១៩៩៩ បានផ្តល់ជូនប្រជាពលរដ្ឋចំនួន៣,000គ្រួសារបន្ថែមទៀត។

បញ្ហាសង្គមទីពីរនៅសេសសល់ គឺការធ្លាក់ចុះនៃប្រាក់ចំណូលដែលបានពីការនេសាទ ដោយសារតែការធ្លាក់ចុះនូវការធ្វើចរាចររបស់ត្រី ហើយដែលជាលទ្ធផលបណ្តាលឲ្យការស្តុកត្រីត្រូវធ្លាក់ចុះ។ ដោយឈរលើមូលដ្ឋាននៃគោលនយោបាយ និងនីតិវិធីរបស់ធនាគារពិភពលោក EGAT បានបរិយាយយ៉ាងលម្អិតពីយុទ្ធសាស្ត្រទូទាត់សំណងដែលពឹងផ្អែកលើដីធ្លី ដោយសារ EGAT មិនអាចមានលទ្ធភាពស្វែងរកទីកន្លែងដែលអាចនេសាទជំនួសបាន។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងឆ្នាំ១៩៩៧ EGAT បានសម្រេចចិត្តក្នុងការផ្តល់នូវសំណងជាសាច់ប្រាក់ដ៏សន្ធឹកសន្ធាប់សម្រាប់ក្រុមគ្រួសារ ដែលទទួលរងផលប៉ះពាល់ពីទំនប់ ប៉ុន្តែក្នុងឆ្នាំ១៩៩៨ ការទូទាត់សំណងត្រូវបានពន្យារទៅវិញ ដោយសារនាយករដ្ឋមន្ត្រីថៃបានប្រកាសដកហូតការផ្តល់ជូនសំណងទាំងអស់ ដោយបានអះអាងថាការទូទាត់សំណងមិនអាចធ្វើឡើងដោយគម្រោងដែលបានបញ្ចប់រួចរាល់ហើយនោះទេ (ជាការនិយាយដែលនាំឲ្យមានការចាប់អារម្មណ៍ថា បញ្ហាសង្គមនានានៅសេសសល់មិនអាចត្រូវបានដោះស្រាយទេ)។

ការនិយាយបែបនេះ បាននាំទៅដល់លទ្ធផលនៃការប្រឆាំងតវ៉ាជាថ្មីមួយក្នុងកម្រិតខ្ពស់បំផុត ក្នុងអំឡុងពេលដែលក្រុមអ្នកតវ៉ាចំនួន៥ពាន់នាក់ បានបង្ហាញនូវអារម្មណ៍ហឹង្សាចំពោះទំនប់ប៉ាកមុននាខែមីនា ឆ្នាំ១៩៩៩ ហើយទំនប់នោះត្រូវបានផ្អាកដំណើរការរហូតដល់ឆ្នាំ២00១។ នៅខែមិថុនា ឆ្នាំ២00១ ទើបរដ្ឋា-

ភិបាលថៃ បានបើកច្រកទ្វារសន្ទះទប់ទឹករបស់ទំនប់សម្រាប់រយៈពេលមួយឆ្នាំ ដើម្បីធ្វើការសិក្សាលើវិស័យជលផល ផលប៉ះពាល់សង្គម និងការពាក់ព័ន្ធដទៃទៀតនៃទំនប់សម្រាប់ការផ្គត់ផ្គង់វារីអគ្គិសនី ។ ផ្អែកលើលទ្ធផលនៃការសិក្សានេះ ក្រោយពីបានយកមកពិភាក្សាតទាល់គ្នារួចមក រដ្ឋាភិបាលក៏បានសម្រេចចិត្តបិទច្រកទ្វាសន្ទះទប់ទឹក និង ឲ្យទំនប់នោះអាចត្រឡប់ជាដំណើរការឡើងវិញ នាខែមិថុនាឆ្នាំ២០០២។ ដើម្បីបន្ធូរបន្ថយបញ្ហាសង្គមនៅសេសសល់ EGAT បានយល់ព្រមបើកច្រកទ្វារសន្ទះទប់ទឹកសម្រាប់រយៈពេល៤ខែក្នុងមួយឆ្នាំ ដើម្បីអនុញ្ញាតឱ្យត្រីអាចធ្វើចរាចរទៅមកតាមធម្មតា។ ទោះយ៉ាងណា ការបន្ធូរបន្ថយនេះនៅតែមានជំទាស់តវ៉ា។

បញ្ហាសង្គមទីបីនៅសេសសល់ ដែលរិតតែមានការជំទាស់តវ៉ាខ្លាំងឡើង គឺករណីប្រជាពលរដ្ឋរងផលប៉ះពាល់ពីទំនប់បានបណ្តាក់ទុនលើសំណងជាសាច់ប្រាក់របស់ពួកគេ ដោយមិនចេះប្រមាណទាល់តែសោះ ហើយប្រជាពលរដ្ឋភាគច្រើន បានខាតបង់ទ្រព្យសម្បត្តិផ្សេងៗរបស់ខ្លួន ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចកើតឡើងនៅទូទាំងអាស៊ីអាគ្នេយ៍នៅចុងទសវត្សឆ្នាំ១៩៩០។ ដោយសារតែអ្នកតាំងលំនៅថ្មី និងអង្គការមិន-មែនរដ្ឋាភិបាលមួយចំនួនបានចាត់ទុកថាវិបត្តិនេះជាបញ្ហាសង្គមមួយនៅសេសសល់ពីទំនប់ប៉ាកមុន ទើប EGAT ដែលមានគោលជំហរស្របនឹងរដ្ឋាភិបាលថៃ ក៏ដូចជាធនាគារពិភពលោក បានបដិសេធការទទួលខុសត្រូវ ហើយគ្មានសំណងណាបន្ថែមទៀតត្រូវបានទូទាត់ឡើយ។

ការចំណាយជារួមរបស់គម្រោងមួយនេះ ត្រូវបានគេប៉ាន់ប្រមាណនៅឆ្នាំ១៩៩៩ ថាបានចំណាយថវិកាចំនួន២៦០លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះថវិកាចំណាយលើការទូទាត់សំណង និងការតាំងទីលំនៅថ្មីមានចំនួន៥៤លានដុល្លារសហរដ្ឋអាមេរិក (ស្មើនឹង១៧%នៃចំណាយសរុប)។ នេះគឺជាចំណាយមួយយ៉ាងធំធេងមានចំនួនច្រើនជាងគម្រោងភាគច្រើន។ ជាមធ្យម " ប្រាក់ចំណូលតាមគ្រួសារ បានកើនឡើងជាចម្បងដោយសារចំណាត់ការដែលកើតឡើងដោយគ្មានជំនួយ នៅលើផ្ទៃមួយរបស់អ្នកតាំងលំនៅថ្មី ជាជាងដោយសារជម្រើសដែលបានរៀបចំឡើងដោយ EGAT ដោយរដ្ឋាភិបាលថៃ ឬ ដោយធនាគារពិភពលោក។ ប្រាក់ចំណូលតាមគ្រួសារ អាចកើនឡើងតាមលទ្ធភាពនៃកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសថៃ " ។ លទ្ធផលជាវិជ្ជមាននេះត្រូវបានសន្មតថាដោយសារឈរលើកត្តា៣ជាចម្បង ៖

- ការរីកចម្រើនមួយនៃសេដ្ឋកិច្ចរបស់ប្រទេសថៃនៅក្នុងដើមទសវត្សឆ្នាំ១៩៩០ ដែលបានបង្កលក្ខណៈងាយស្រួលដល់អ្នកតាំងលំនៅថ្មីជាច្រើន អាចស្វែងរកការងារធ្វើក្រៅពីវិស័យការងារជាប្រពៃណីរបស់ពួកគេ។
- ការត្រៀមរៀបចំផ្នែកនយោបាយ និង លទ្ធភាពផ្នែកហិរញ្ញវត្ថុដើម្បីដោះស្រាយបញ្ហាសង្គមនានានៅសេសសល់ក្នុងលក្ខណៈទាន់ពេលវេលា។

- មានភាពបត់បែនតាមរយៈ EGAT ដោយការឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកតាំងលំនៅថ្មី ដោយការគ្រប់គ្រងការកែតម្រូវស្ថានការណ៍ ដែលអាចឲ្យប្រជាពលរដ្ឋបានពេញចិត្តយ៉ាងទូលាយ ជាមួយនឹងលទ្ធផលនៅទីបំផុតនៃការតាំងលំនៅថ្មី។

ជាសង្ខេប ដោយសារតែឥទ្ធិពល ព្រមទាំងគោលនយោបាយ និងនីតិវិធីនៃធនាគារពិភពលោក ទើបធ្វើឲ្យគម្រោងនេះអាចដោះស្រាយបានយ៉ាងច្រើនបំផុតលើបញ្ហាសង្គមដែលនៅសេសសល់។

៧.២.២ នីតិវិធីបណ្តឹងសារទុក្ខ

នៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃការគ្រប់គ្រងបទដ្ឋាន និងគោលនយោបាយគោលបំណងនៃនីតិវិធីបណ្តឹងសារទុក្ខ គឺដើម្បីផ្តល់នូវយន្តសម្រាប់គម្រោងដាច់ដោយឡែក ដើម្បីដោះស្រាយលើបណ្តឹងសារទុក្ខ។ នេះគឺដោយសារតែជាក់ស្តែងវាបានក្លាយទៅជាក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈយឺតយ៉ាវ និង ស្មុគស្មាញពេកក្នុងការផ្តល់នូវលទ្ធផលទាន់ពេលវេលា ។ ទោះជាយ៉ាងណា វាគឺជាការពិតណាស់ដែលថាគម្រោងភាគច្រើនមិនមានសមត្ថភាព ដើម្បីឆ្លុះបញ្ចាំងយ៉ាងជិតដល់ពីការងារផ្ទាល់ខ្លួនរបស់គម្រោងទាំងនោះ និង គ្មានសមត្ថភាព ដើម្បីផ្តល់នូវការវិនិច្ឆ័យមួយដែលយុត្តិធម៌ចំពោះពាក្យបណ្តឹងផ្សេងៗនោះទេ ។ ដូច្នេះវាជាការសំខាន់ដែលត្រូវមានការចូលរួមពាក់ព័ន្ធពីភាគីឯករាជ្យនៅក្នុងនីតិវិធីបណ្តឹងសារទុក្ខ តួយ៉ាងដូចជាការចូលរួមពីសំណាក់ការិយាល័យតំណាងប្រជាពលរដ្ឋជាដើម។ ការិយាល័យតំណាងប្រជាពលរដ្ឋអាចជួយឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង បានសម្តែងចេញនូវបណ្តឹងសារទុក្ខរបស់ខ្លួនក្នុងបែបបទជាតម្រូវការ និងក្នុងលក្ខណៈជារចនាសម្ព័ន្ធពាក់ព័ន្ធ។ ការិយាល័យនេះ ជាស្ថាប័នឯករាជ្យ ជាអ្នកលើកទឹកចិត្ត សម្របសម្រួល និងពន្លឿនរាល់ការដោះស្រាយលើបញ្ហាសង្គមដែលនៅសេសសល់ និង លើកកម្ពស់ការទំនាក់ទំនង និងស្វែងយល់របស់ភាគីពាក់ព័ន្ធផ្សេងៗគ្នា។ បញ្ហាប្រឈមជាគន្លឹះ គឺការស្វែងរកមនុស្សដែលមានសមត្ថភាពក្នុងការបំពេញភារកិច្ចក្នុងមុខតំណែងដែលត្រូវការនេះ ដោយការចំណាយសមហេតុផល។

៧.២.៣ សំណងបដិទាន

ចំពោះគម្រោងទំនប់ និង វារីអគ្គិសនីធំៗមួយចំនួន សំណងបដិទានអាចធ្វើបានក្រោយពីការបិតបញ្ចប់ហេដ្ឋារចនាសម្ព័ន្ធ ។ ប្រការនេះក៏ទាមទារឱ្យមានឆន្ទៈយ៉ាងមុតមាំពីរដ្ឋាភិបាល ដើម្បីអនុវត្តសំណងបដិទានដោយសារនៅក្នុងករណីជាច្រើនវាជាការលំបាកណាស់ ក្នុងការបង្កើតខ្សែបន្ទាត់កាត់ផ្តាច់ច្បាស់លាស់។ ជាមួយគ្នានេះផងដែរ ក៏តម្រូវឱ្យមានការប្តេជ្ញាចិត្តពីរដ្ឋាភិបាលដើម្បីប្រកាសជាសាធារណៈថាការសម្រេចចិត្តពីមុននោះគឺមិនត្រឹមត្រូវទេ។ ទោះយ៉ាងណានៅមានចំណាត់ការផ្សេងទៀតដែលអាចអនុវត្តបាន ឧទាហរណ៍ ប្រជាពលរដ្ឋរងផលប៉ះពាល់គម្រោង អាចទទួលបានប្រាក់ឈ្នួលពីដីដែលបានដកហូត ឬបានយកទៅអភិវឌ្ឍដោយការទទួលបានដីរបស់ខ្លួនមកវិញ នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធនោះត្រូវបានបិតបញ្ចប់។

៧.២.៤ នីតិវិធីផ្អែកច្បាប់

ឧបាស្រ័យលើប្រព័ន្ធច្បាប់របស់ប្រទេសមួយគឺអាចប្រើបាន តែទោះជាយ៉ាងណាតាមបទពិសោធន៍បង្ហាញថានីតិវិធីមានភាពយឺតយ៉ាវ ។ ចំនុចនេះគឺជាការធ្វើឲ្យខាតប្រយោជន៍របស់ប្រជាពលរដ្ឋរងផលប៉ះ-ពាល់ពីគម្រោង ក៏ដូចជាផលប្រយោជន៍របស់គម្រោងផងដែរ ហើយប្រសិនបើវាអូសបន្លាយយូរពេក អាចបង្កជាលទ្ធផលលំបាកធ្ងន់ធ្ងរដល់សង្គម និងអាចកើតជាជម្លោះថែមទៀតផង។ ទោះជាបែបនេះក្តី នៅក្នុងប្រទេសភាគច្រើន ឧបាស្រ័យលើប្រព័ន្ធច្បាប់ ដែលបានដោះស្រាយលើបញ្ហាសង្គមនានានៅសេសសល់ គឺជាការដួលរលំត្រឡប់មកវិញនៃបរាជ័យលើមធ្យោបាយផ្សេងៗ។

ប្រអប់អត្ថបទ៧.៦ តើបញ្ហាសង្គមដែឡនៅសេសសល់ ត្រូវបានដោះ ស្រាយដោយរបៀបណា- ទិដ្ឋភាពគន្លឹះ
មានឧបករណ៍សំខាន់ចំនួន៤ដែលអាចប្រើបាន ដើម្បីដោះស្រាយបញ្ហាសង្គមនានានៅសេសសល់ ៖ • មូលនិធិសំណងប៉ះប៉ូវ និងទម្រង់ដទៃទៀតនៃការទូទាត់សំណង។ ◦ការទូទាត់សំណងជាសាច់ប្រាក់ (ថវិកាបូកសរុបរួម)។ ◦ការទូទាត់សំណងជាសាច់ប្រាក់ (ការបង់រម្លស់ប្រចាំឆ្នាំ)។ ◦ការគាំទ្រដល់ប្រព័ន្ធជីវភាពរស់នៅ។ • នីតិវិធីបណ្តឹងសារទុក្ខ។ • សំណងបដិទាន។ • ដំណើរការផ្អែកច្បាប់។

ប្រធានបទពិភាក្សា	ចូរពិភាក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការទូទាត់សំណងជាសាច់ប្រាក់ជាថវិកាបូកសរុបរួម ឬ ជាការបង់រម្លស់ប្រចាំឆ្នាំ។ …….. ចូរពិភាក្សាអំពីលទ្ធភាពអនុវត្តបាននៃនីតិវិធីបដិទានលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដែលមានវិសាលគមសេដ្ឋកិច្ចយូរអង្វែង ហើយដែលកម្រនឹងត្រូវបិទបញ្ចប់។
លំហាត់	តាមរយៈការប្រើប្រាស់ករណីសិក្សាពីប្រទេសរបស់អ្នកផ្ទាល់ ចូរបញ្ជាក់លម្អិតអំពីវិធីសាស្ត្រល្អបំផុត ដើម្បីដោះស្រាយបញ្ហាសង្គមនៅសេសសល់នៅក្នុងលក្ខណៈមួយដែលអាចជួយយ៉ាងសំខាន់ដល់សហគមន៍រងផលប៉ះពាល់ពីគម្រោងដើម្បីស្តារនិងកែលម្អជីវភាពរស់នៅរបស់សហគមន៍ទាំងនោះ។ ……

	ចូររៀបចំ និង បង្ហាញពីយន្តការបណ្តឹងសារទុក្ខ ដែលគ្រាន់តែជាការបង្ក្រប់កិច្ច។

៨ ការចូលរួមពីភាគីពាក់ព័ន្ធ

៨.១ សាវតា និយមន័យ និងទស្សនៈគន្លឹះ

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺផ្តល់នូវចំនុចសំខាន់ៗស្តីពីសាវតា និងនិយមន័យនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីទស្សនៈគន្លឹះទាក់ទងនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនីនិងការអភិវឌ្ឍ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើ ការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើស ជំនួស។ ផ្នែកទី ៣: ការចូលរួមរបស់ភាគីពាក់ព័ន្ធ www.unep.org/dams
	www.iap2.org

៨.១.១ ការកំណត់និយមន័យ និងការពិភាក្សាលើទស្សនៈនានា

ដូចបានឃើញច្បាស់រួចហើយនៅផ្នែកមុនៗនៃសៀវភៅបណ្តុះបណ្តាលនេះ ការចូលរួមរបស់ភាគីពាក់ព័ន្ធ (ឬការចូលរួមជាសាធារណៈ/ការចូលរួម) គឺចំនុចគន្លឹះនៃការអនុវត្តដំណើរការនានា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់សង្គម កម្មវិធីតាំងទីលំនៅថ្មី ការបង្កើតគោលនយោបាយ ទូទាត់ សំណង និងកញ្ចប់សំណង និងការបែងចែកផលប្រយោជន៍។

IAP2 ជាសមាគមអន្តរជាតិសម្រាប់ការចូលរួមជាសាធារណៈ។ សមាគមនេះ កំណត់ពីអត្ថន័យលើការ ចូលរួមរបស់អ្នកពាក់ព័ន្ធថា ជាដំណើរការនៃការចូលរួមទាំងឡាយណាពីអ្នកចូលរួមពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហា ឬ ការធ្វើសេចក្តីសម្រេចចិត្ត និងការប្រើប្រាស់មតិចូលរួមយោបល់របស់អ្នកពាក់ព័ន្ធ ដើម្បីធ្វើឱ្យការសម្រេចចិត្តណាមួយនោះដំណើរការទៅបានល្អប្រសើរជាងមុន " ។ ដោយសារមានការជាប់ពាក់ព័ន្ធនេះហើយ ទើបធ្វើឲ្យការចូលរួមរបស់អ្នកពាក់ព័ន្ធក្លាយជាដំណើរការមួយ ឬជាស៊េរីនៃចំណាត់ការជាជាងចំណាត់ការដែលមានតែមួយប្រភេទ។

គោលបំណងជាសារវន្តនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺដើម្បីធ្វើឲ្យការសម្រេចចិត្តដំណើរការទៅបានល្អប្រសើរជាងមុន ពោលគឺជាការសម្រេចចិត្តដោយការផ្តល់ព័ត៌មានគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាពល្អប្រសើរជាងមុន ដែលជាការសម្រេចចិត្តរបស់អ្នកពាក់ព័ន្ធ និងដែលអាចអនុវត្តបាន។ ក្នុងន័យនេះ ការចូលរួមរបស់អ្នកពាក់ព័ន្ធ ថ្វីដ្បិតតែមិនអាចសម្រេចបាននូវការមូលមតិគ្នាក៏ដោយ ក៏ការចូលរួមនេះ អាចកសាងគំនិតយោបល់ផ្សេងៗជាច្រើនដើម្បីសម្រេចបាននូវការសម្រេចចិត្តនានាដែលមានលក្ខណៈល្អប្រសើរជាងមុន។

ជាពិសេស ការចូលរួមរបស់អ្នកពាក់ព័ន្ធមិនជាប់ទាក់ទងជាមួយ ឬ ផ្តល់ជាលទ្ធផលក្នុងការកាត់បន្ថយតួនាទីនៃការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលឡើយ ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធច្រើនតែផ្តោតសំខាន់លើការផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធបានចូលរួមពាក់ព័ន្ធ និង បានប្រើប្រាស់មតិយោបល់ដែលបានលើកឡើង ដើម្បីផ្តល់ជាការគាំទ្រដល់រដ្ឋាភិបាលតាមរយៈការសម្រេចចិត្តដែលជះឥទ្ធិពលដល់មនុស្សគ្រប់ៗគ្នា។

ជាផ្នែកបន្ថែមនៃការកំណត់និយមន័យនេះ IAP2 កំណត់មូលដ្ឋានចំនួន៣ ដែលអាចកសាងបាននូវប្រសិទ្ធភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ៖

- **គុណតម្លៃដែលមានមូលដ្ឋាន ។** ការចូលរួមរបស់អ្នកពាក់ព័ន្ធគឺមានប្រសិទ្ធិភាពបំផុតប្រសិនបើអ្នកគាំទ្រគម្រោង (ទោះជារដ្ឋាភិបាលក្តី ឬវិស័យឯកជនក្តី) និងអ្នកអនុវត្តគម្រោងត្រូវទទួលស្គាល់ និងផ្តល់សុពលភាពលើគុណតម្លៃ របស់អ្នកពាក់ព័ន្ធ នៅពេលរៀបចំដំណើរការមួយនៃការចូលរួម។ ខណៈពេលដែលទិន្នន័យ ជាក់លាក់មានភាពចាំបាច់សម្រាប់ការធ្វើការសម្រេចចិត្តដោយការផ្តល់ព័ត៌មានបានត្រឹមត្រូវនោះ ការសម្រេចចិត្តល្អនឹងបូកបញ្ចូលទាំងទិន្នន័យជាក់ស្តែង និងពាក់ព័ន្ធ ក៏ដូចជាគុណតម្លៃ គោលការណ៍ ឬ បទដ្ឋានស្តង់ដាររបស់ភាគីពាក់ព័ន្ធនៅក្នុងការសម្រេចចិត្តនោះ។
- **សេចក្តីសម្រេចដែលមានការតម្រង់ទិស។** ការចូលរួមរបស់អ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធិភាពជួយគាំទ្រដល់ការធ្វើការសម្រេចចិត្តដ៏រឹងមាំ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធមិនត្រូវបានអនុវត្តនៅក្នុងភាពទទេស្អាតឡើយ សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ជាវិធីមួយដើម្បី "លក់" ការសម្រេចចិត្តមួយដែលបានធ្វើរួចទៅហើយនោះទេ ប៉ុន្តែជាពិសេសដើម្បីធ្វើឲ្យមានឥទ្ធិពលលើការសម្រេចចិត្ត និងធ្វើឲ្យការសម្រេចចិត្ត មានលក្ខណៈល្អប្រសើរ។ "ការសម្រេចចិត្តមានលក្ខណៈល្អប្រសើរ " គឺជាការសម្រេចចិត្តទាំងឡាយណាដែលមាន ការផ្តល់ព័ត៌មានល្អប្រសើរជាងមុន បានយល់ដឹងល្អប្រសើរជាងមុនប្រកបដោយនិរន្តរភាព ឬ ដែលអាចអនុវត្តបានកាន់តែប្រសើរជាងមុន ដោយសារការសម្រេចចិត្តទាំងនោះជះឥទ្ធិពលដល់លទ្ធផល ឬ ជាការសម្រេចចិត្តដែលមានផលប្រយោជន៍។

- **គោលបំណងដែលមានការជម្រុញ។** វាជាការសំខាន់ដើម្បីគ្រប់គ្រងការរំពឹងទុកនៃដំណើរការនៃការចូលរួម និង មានភាពច្បាស់លាស់អំពីតួនាទីរបស់ភាគីពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តនានា។ នៅពេលដែលការចូលរួមរបស់អ្នកពាក់ព័ន្ធ ត្រូវបានគ្រោងទុកដើម្បីធ្វើឲ្យសម្រេចបាននូវគោលបំណងជាក់លាក់ និង ដែលមានលក្ខណៈចែករំលែក ដូចជាការផ្តល់ព័ត៌ប្រកបដោយមានតុល្យភាពនិងមានកម្មវត្ថុ ឬដើម្បីបង្កើតនិងរក្សាបាននូវទំនាក់ទំនង ឬដើម្បីប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ ឬដើម្បីស្វែងរកគំនិតថ្មីៗ ឬ ដើម្បីសម្របសម្រួលដល់ការធ្វើការសម្រេចចិត្តដោយមានការចូលរួមមាន។ គួរតែមានយន្តការ ឬបច្ចេកទេសដែលនឹងត្រូវជ្រើសរើសនិងត្រូវអនុវត្តតាមមធ្យោបាយមួយនេះ ដើម្បីសម្រេចឲ្យបាននូវគោលដៅទាំងនេះ។ មានបច្ចេកទេសនៃការចូលរួមជាច្រើនដែលអាចត្រូវបានប្រើដោយអ្នកអនុវត្ត ។ ដើម្បីជ្រើសរើសបច្ចេកទេសសមរម្យបំផុត ត្រូវតម្រូវឱ្យមានការយល់ដឹងច្បាស់លាស់ពីអ្វីដែលការចូលរួមពីភាគីដែលពាក់ព័ន្ធត្រូវធ្វើឲ្យសម្រេចបាន។

៨.១.២ ទស្សនៈសមាគមន៍អន្តរជាតិសម្រាប់ការចូលរួមជាសាធារណៈ (IAP2)

ទស្សនៈរបស់ IAP2 រួមមានគុណតម្លៃស្នូល ក្រមសីលធម៌ និងវិសាលគមនៃការចូលរួមជាសាធារណៈ។

គុណតម្លៃស្នូល ពណ៌នាអំពីគុណលក្ខណៈទាំង៧យ៉ាងនៃដំណើរការនៃការចូលរួមពីភាគីពាក់ព័ន្ធដែលសមាគមបានស្នើឡើងថា គឺជាគំរូបទដ្ឋានអប្បបរមា ដែលនឹងផ្តល់នូវដំណើរការប្រកបដោយយុត្តិធម៌និងក្រមសីលធម៌។ គុណលក្ខណៈទាំង៧យ៉ាង រួមមាន ៖

- អ្នកពាក់ព័ន្ធត្រូវតែមានសម្លេងរបស់ខ្លួនក្នុងការសម្រេចចិត្តអំពីចំណាត់ការដែលប៉ះពាល់ដល់អាយុជីវិតរបស់ពួកគេ។
- ការរួមចំណែកអ្នកពាក់ព័ន្ធ ត្រូវតែមានឥទ្ធិពលលើការសម្រេចចិត្តយ៉ាងពិតប្រាកដ។
- ដំណើរការនេះ ត្រូវតែមានបំណងដើម្បីសម្រេចឲ្យបាននូវការសម្រេចចិត្តប្រកបដោយនិរន្តរភាពដោយការបំពេញតម្រូវការរបស់អ្នកចូលរួមទាំងអស់ រួមទាំងអ្នកធ្វើការសម្រេចចិត្តផង។
- ដំណើរការនេះ ត្រូវតែស្វែងរកឲ្យបាន និង ជួយសម្រួលដល់ការចូលរួមពាក់ព័ន្ធរបស់អ្នកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគម្រោង។
- ដំណើរការនេះ ត្រូវតែផ្តល់លទ្ធភាពដល់អ្នកចូលរួម នៅក្នុងការកំណត់អត្តន័យអំពីរបៀបដែលពួកគេបានចូលរួម។
- តាមរយៈអ្នកអនុវត្តដំណើរការនេះ ត្រូវផ្តល់ឲ្យភាគីពាក់ព័ន្ធនូវពត៌មានដែលពួកគេត្រូវការក្នុងលក្ខណៈដែលងាយស្រួលយល់បាន ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងរបៀបមួយដ៏មានន័យ។
- ដំណើរការនេះត្រូវតែជូនព័ត៌មានដល់ភាគីពាក់ព័ន្ធ អំពីរបៀបដែលមតិយោបល់របស់ពួកគេមានឥទ្ធិពលលើការសម្រេចចិត្ត ដែលជាលទ្ធផលនៃការចូលរួមនេះ។

វិសាលគមនៃការចូលរួមជាសាធារណៈរបស់ IAP2 បានផ្តល់អនុសាសន៍ថាការចូលរួមអាចមានប្រសិទ្ធិភាពនៅក្នុងកម្រិត៥យ៉ាង មានដូចជា កម្រិតនៃការផ្តល់ព័ត៌មាន កម្រិតនៃការផ្តល់ប្រឹក្សាយោបល់ កម្រិតនៃការចូលរួមពាក់ព័ន្ធ កម្រិតនៃការសហការ និងកម្រិតនៃការផ្តល់សិទ្ធិអំណាច។ គោលដៅនៃការចូលរួមនេះ " ការសន្យាធានា " ដល់សាធារណជន ចំណែកបច្ចេកទេសនានាត្រូវបានប្រើទៅតាមកម្រិតនីមួយៗខុសៗគ្នា។

- កម្រិតនៃ**ការផ្តល់ព័ត៌មាន**។
  - គោលដៅ គឺដើម្បីផ្តល់ព័ត៌មានប្រកបដោយតុល្យភាពនិងដោយមានកម្មវត្តុទៅដល់ភាគីពាក់ព័ន្ធ។
  - ការសន្យាធានា គឺដើម្បីជូនដំណឹងទៅដល់ភាគីពាក់ព័ន្ធ ជុំវិញដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។
  - បច្ចេកទេសទំនងជាត្រូវបានប្រើសម្រាប់ជាឧបករណ៍ទំនាក់ទំនង ដូចជាព័ត៌មានសំណេរឬគេហ៍ទំព័រ ហើយសកម្មភាពទំនាក់ទំនង ដូចជាកិច្ចប្រជុំផ្តល់ព័ត៌មាន ទស្សនកិច្ចតាមតំបន់គេហ៍ទំព័រនិងកិច្ចពិភាក្សាជាចំហ។

នៅកម្រិតនេះ ភាគីពាក់ព័ន្ធមានឥទ្ធិពលជាអ្នកសង្កេតការណ៍លើដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្តដោយមានតម្លាភាព ដែលអាចអនុញ្ញាតឱ្យភាគីទាំងនោះក្តោបក្តាប់បានលើអ្នកធ្វើសេចក្តីសម្រេចចិត្តឲ្យប្រកបដោយគណនីភាពក្នុងការសម្រេចចិត្តរបស់ខ្លួន។

- កម្រិតនៃ**ការផ្តល់ប្រឹក្សាយោបល់**។
  - គោលដៅ គឺដើម្បីស្វែងរកការផ្តល់មតិត្រឡប់វិញពីអ្នកពាក់ព័ន្ធលើសំណើនានា។
  - ការសន្យាធានា គឺដើម្បីស្តាប់ពីសេចក្តីព្រាថ្នា ក្តីកង្វល់ និងបញ្ហាផ្សេងៗ និងដើម្បីផ្តល់នូវមតិត្រឡប់ទៅវិញពអំពីរបៀប ដែលមតិយោបល់របស់អ្នកពាក់ព័ន្ធមានឥទ្ធិពល លើការសម្រេចចិត្តមួយ។
  - បច្ចេកទេសគឺការស្ទង់មតិ ការធ្វើសំភាសន៍ ការប្រជុំ ការដាក់ស្នើ និងសវនាការជាសាធារណៈ

នៅកម្រិតនេះ អ្នកធ្វើការសម្រេចចិត្តត្រូវស្វែងរកការផ្តល់មតិត្រឡប់វិញពីអ្នកពាក់ព័ន្ធ ដើម្បីទទួលព័ត៌មានដែលប្រមូលបាន លក្ខណៈវិនិច្ឆ័យដែលបង្កើតបាន និង ជម្រើសជំនួសដែលបានពិចារណា

អាចត្រូវបានត្រួតពិនិត្យឡើងវិញ និងត្រូវបានធ្វើអធិប្បាយដោយអ្នកពាក់ព័ន្ធ។

- កម្រិតនៃ**ការចូលរួមពាក់ព័ន្ធ**។
  - គោលដៅ គឺដើម្បីចូលរួមជាមួយភាគីពាក់ព័ន្ធដើម្បីបង្កើតគំនិតថ្មីៗ តាមរយៈការជជែកពិភាក្សា។

- ការសន្យាធានា គឺដើម្បីធ្វើការដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធ ក្នុងអំឡុងពេលដំណាក់កាលនីមួយៗនៃដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត សំដៅធានាឲ្យប្រាកដថាសេចក្តីព្រាម្នា និង ការព្រួយបារម្ភផ្សេងៗ ត្រូវបានឆ្លុះបញ្ចាំងដោយផ្ទាល់ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនោះ។
- បច្ចេកទេស គឺកិច្ចប្រជុំ សិក្ខាសាលា និងយន្តការនៃការសម្រេចចិត្ត។

នៅកម្រិតនេះ អ្នកធ្វើការសម្រេចចិត្តត្រូវស្វែងរកព័ត៌មាននិងគំនិតផ្សេងៗពីអ្នកពាក់ព័ន្ធ ខណៈពេលធ្វើសេចក្តីសម្រេចចិត្តជាក់ស្តែង។

- កម្រិតនៃ**ការសហការ។**
  - គោលដៅ គឺដើម្បីធ្វើជាដៃគូជាមួយភាគីពាក់ព័ន្ធនៅក្នុងទិដ្ឋភាពនីមួយៗ នៃការសម្រេចចិត្តមួយ ដោយរួមទាំងលក្ខណៈវិនិច្ឆ័យលើការអភិវឌ្ឍ និងជម្រើសជំនួស និងការកំណត់ឲ្យបានច្បាស់ពីដំណោះស្រាយមួយតាមការនិយមពេញចិត្ត។
  - ការសន្យាធានា នេះគឺដើម្បីស្វែងរកការផ្តល់ដំបូន្មាន និង គំនិតថ្មីៗពីភាគីពាក់ព័ន្ធ និងដើម្បីរួមបញ្ចូលគ្នានូវដំបូន្មាន និងគំនិតថ្មីៗទាំងនេះ ទៅក្នុងការសម្រេចចិត្តឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។
  - បច្ចេកទេស គឺក្រុមប្រឹក្សាផ្តល់យោបល់ ក្រុមភាគីពាក់ព័ន្ធ និងការសម្រេចចិត្តដោយមានការចូលរួម។

នៅកម្រិតនេះ អ្នកធ្វើការសម្រេចចិត្តត្រូវស្វែងរកការចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា លើសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការសម្រេចចិត្ត។

- កម្រិតនៃ**ការផ្តល់សិទ្ធិអំណាច**។
  - គោលដៅគឺ ដើម្បីប្រគល់តួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅឲ្យអ្នកពាក់ព័ន្ធនានា។
  - ការសន្យាធានា គឺដើម្បីអនុវត្តនូវអ្វីដែលភាគីពាក់ព័ន្ធបានសម្រេចចិត្តរួច។
  - បច្ចេកទេស គឺជាធម្មតាគឺក្រុមប្រឹក្សាតុលាការប្រជាជន មតិសំអាង និង ការសម្រេចចិត្តដោយមានកិច្ចបែងសិទ្ធិ។

កម្រិតនេះ គឺមិនទំនងជាសមរម្យឡើយសម្រាប់គម្រោងវារីអគ្គិសនីជាតិនិងអន្តរជាតិដែលមានតែរដ្ឋាភិបាលមួយប៉ុណ្ណោះដែលជាអ្នកមានសិទ្ធិសម្រេចចិត្តខ្ពស់បំផុត។

ការគ្រប់គ្រងការរំពឹងទុករបស់អ្នកធ្វើការសម្រេចចិត្ត និងអ្នកពាក់ព័ន្ធគឺជាការប្រឈមមួយ ។ នៅពេលដែលអ្នកធ្វើការសម្រេចចិត្តមានបំណងតែមួយគត់ ដើម្បី**ផ្តល់ដំណឹង**ឬ**ពិគ្រោះយោបល់** ជាមួយអ្នកពាក់

ព័ន្ធដែលជាញឹកញាប់ករណី នៅក្នុងការធ្វើការសម្រេចចិត្តលើគម្រោងទំនប់ដែលមានទំហំធំ រួមទាំងសំណង់អគារវារីអគ្គិសនី ប៉ុន្តែភាគីពាក់ព័ន្ធស្វែងរក**ការសហការ** គឺមិនមានភាពស៊ីសង្វាក់គ្នានៃការរំពឹងទុក។

ដូច្នេះ វាជាការសំខាន់ដើម្បីទទួលបានការបំភ្លឺពីសំណាក់អ្នកធ្វើសេចក្តីសម្រេចចិត្តអំពីការដើរតួនាទី និងការប្តេជ្ញាចិត្តក្នុងតួនាទីរបស់ភាគីពាក់ព័ន្ធក្នុងការធ្វើការសម្រេចចិត្ត។ ពេលដែលមានការបំភ្លឺលើចំនុចនេះរួចមក ចាំបាច់តម្រូវមានជូនព័ត៌មាន និងការពន្យល់ឲ្យបានច្បាស់លាស់ ដល់អ្នកពាក់ព័ន្ធនានា។ គោលដៅនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ បន្ទាប់មកអាចបង្កើតបានយ៉ាងច្បាស់ថាជាមគ្គុទេសក៍សម្រាប់អ្នកអនុវត្ត និងអ្នកធ្វើការសម្រេចចិត្ត ហើយជា**ការសន្យាជានា**មួយចំពោះអ្នកពាក់ព័ន្ធដោយមានការបញ្ជាក់យ៉ាងច្បាស់។

៨.១.៣ គំរូនៃការសម្រេចចិត្ត ប្រកាស ការពារ (DAD)

IAP2 ក៏បានទទួលស្គាល់ផងដែរថាមានគំរូម៉ូដែលមួយនៃការទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធ ដែលជាញឹកញាប់ត្រូវបានយល់ច្រឡំ ជាមួយការចូលរួមរបស់អ្នកពាក់ព័ន្ធ។ IAP2 ប្រើអក្សរកាត់DAD ដើម្បីពណ៌នាពីម៉ូដែលនេះ ដែលមានអក្សរពេញថា **សម្រេចចិត្ត ប្រកាស ការពារ**។ នៅពេលប្រើគំរូម៉ូដែលនេះ អ្នកគាំទ្រគម្រោងត្រូវធ្វើការសម្រេចចិត្ត និងត្រូវប្រកាសប្រាប់ដល់សាធារណជន ហើយបន្ទាប់ត្រូវការពារ ហើយអ្នកពាក់ព័ន្ធត្រូវឆ្លើយតបចំពោះការសម្រេចចិត្តដែលមានលក្ខណៈអវិជ្ជមាន។ ពេលខ្លះ បើសិនជាភាពអវិជ្ជមានត្រូវបានបញ្ជាក់យ៉ាងច្បាស់គ្រប់គ្រាន់ ឬជាប់ជំពាក់ផ្នែកនយោបាយ ការសម្រេចចិត្តនេះត្រូវតែធ្វើការផ្លាស់ប្តូរ។ សំខាន់ត្រូវកត់សម្គាល់ថា ចំនុចនេះមិនស្របទៅនឹងការកំណត់និយមន័យរបស់ IAP2 លើការចូលរួមរបស់អ្នកពាក់ព័ន្ធឡើយ។

គំរូម៉ូដែលកម្រនឹងផ្តល់លទ្ធផលក្នុងការសម្រេចចិត្តបានល្អប្រសើរណាស់ ដោយសារវាគ្រាន់តែជាលទ្ធផលនៃការពិភាក្សានិងការពិចារណាលើទស្សនវិស័យជាច្រើនតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ គំរូម៉ូដែលនេះច្រើនតែ ផ្តល់ជាលទ្ធផលនៅក្នុង in 'knee-jerk' reactions ដែលអាចមានតម្លៃខ្ពស់ និងបន្ថែមការចំអកឡកឡឺយរបស់អ្នកពាក់ព័ន្ធអំពីតម្លាភាពនិងភាពស្របច្បាប់នៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

៨.១.៤ ការធ្វើការសម្រេចចិត្ត ក្នុងអំឡុងពេលរយៈកាលដំណើរការគម្រោង

ទាក់ទងនឹងគម្រោងវារីអគ្គិសនី រយៈកាលដំណើរការគម្រោងរួមមានដំណាក់កាលជាច្រើន ដូចជា ៖ ការធ្វើផែនការគោលនយោបាយ និងយុទ្ធសាស្ត្រ។

- ការធ្វើផែនការជាគោលនយោបាយ និងជាយុទ្ធសាស្ត្រ។
- ការធ្វើផែនការអាងទន្លេរួមបញ្ចូលគ្នា។
- ការធ្វើផែនការគម្រោងទំនប់/គម្រោងវារីអគ្គិសនី។
- សាងសង់ទំនប់/សំណង់អាគារវារីអគ្គិសនី។
- ប្រតិបត្តិការទំនប់/សំណង់អាគារវារីអគ្គិសនី។

- ការបិតបញ្ចប់ដំណើរការទំនប់/សំណង់អាគារវារីអគ្គិសនី។

លទ្ធភាពក្នុងការចូលរួមលើការសម្រេចចិត្តរបស់ភាគីពាក់ព័ន្ធ អាចទំនងជាខុសគ្នាទៅតាមដំណាក់កាលផ្សេងៗគ្នា ។ ក្នុងអំឡុងពេល**ធ្វើផែនការ** (រួមទាំងការធ្វើផែនការជាគោលនយោបាយ និង ជាយុទ្ធសាស្ត្រ ការធ្វើផែនការអាងទន្លេ និងការធ្វើផែនការគម្រោង) អ្នកពាក់ព័ន្ធអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តជាច្រើន។ ជាការពិតណាស់ គណៈកម្មការពិភពលោកទទួលបន្ទុកលើទំនប់ បានស្នើឡើងថា មានធាតុសំខាន់ៗនៃនិរន្តរភាពចំនួន៦ដែលត្រូវពិចារណា ដូចជាផ្នែកវិស្វកម្ម ផ្នែកបរិស្ថាន ផ្នែកសង្គមកិច្ច សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងការសម្រេចចិត្ត។ សម្រាប់ធាតុនីមួយៗទាំងនេះត្រូវមានកត្តាមួយចំនួនដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានទឹក ឬបទដ្ឋានជានិយាម ហើយទាមទារឲ្យមានការសម្រេចចិត្តលើធាតុនីមួយៗទាំងនេះ។

ក្នុងអំឡុងពេលនៃ**ការគ្រប់គ្រង** (រួមទាំងការសាងសង់ទំនប់/សំណង់អាគារវារីអគ្គិសនី ប្រតិបត្តិការ និងការបិទបញ្ចប់ (ការសម្រេចចិត្តនឹងបន្តធ្វើឡើងទាក់ទងនឹងបទដ្ឋានជានិយាម។

តារាង ៨.១ ផ្តល់ឱ្យនូវឧទាហរណ៍នៃសំនួរបែបចង្អុលបង្ហាញដែលអាចនឹងតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ។

តារាង ៨.១ ឧទាហរណ៍នៃសំនួរបែបចង្អុលបង្ហាញ ដែលអាចនឹងតម្រូវឱ្យមានការធ្វើសេចក្តីសម្រេចចិត្តតាមជំហានខុសៗគ្នានៃរយៈកាលដំណើរការគម្រោង។

ដំណាក់កាលនៃរយៈពេលប្រតិបត្តិគម្រោង	ការសម្រេចចិត្តជាឧទាហរណ៍ ដែលភាគីពាក់ព័ន្ធអាចចូលរួមបាន
ការធ្វើផែនការជាគោលនយោបាយ និងជាយុទ្ធសាស្ត្រ	ចក្ខុវិស័យសម្រាប់ការផ្តល់ទឹក និងថាមពល ដើម្បីឱ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ឬនៅតាមសហគមន៍ និងយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ។

ការធ្វើផែនការអាងទន្លេរួមបញ្ចូលគ្នា	តើធនធានក្នុងតំបន់អាងទន្លេមួយ ត្រូវបានប្រើប្រាស់ដោយរបៀបណាដើម្បីផ្តល់នូវទឹក និងថាមពលសម្រាប់ប្រជាសហគមន៍ ខណៈមានការថែរក្សាសុខភាព និង លំហូរនៃទន្លេ និងដៃទន្លេ។
ការធ្វើផែនការគម្រោង	តើមានជម្រើសជំនួសអ្វីខ្លះនៅក្នុងតំបន់ទីជម្រាល ដើម្បីផ្គត់ផ្គង់ទឹកនិងថាមពលដល់សហគមន៍? ការស្តុកទឹកនៃទំនប់វារីអគ្គិសនីគឺជាជម្រើស ដែលមាននិរន្តរភាពបំផុត ដើម្បីសម្រេចបានលទ្ធផលដែលចង់បានដែរឬទេ? អ្វីដែលនឹងក្លាយជាផលប៉ះពាល់សង្គម បរិស្ថាននិងសេដ្ឋកិច្ច ហើយតើផលប៉ះពាល់ទាំងនោះមានប្រសិទ្ធភាព និងត្រូវកាត់បន្ថយបានយ៉ាងត្រឹមត្រូវដោយរបៀបណា? តើមានដំណើរការមួយ ដើម្បីធានាបាននូវការទូទាត់សំណងគ្រប់គ្រាន់ដែរឬទេ?
ការសាងសង់	តើទំនប់វារីអគ្គិសនីមួយអាចត្រូវបានសាងសង់ដោយការចំណាយមានប្រសិទ្ធិភាព ដោយរបៀបណា ដើម្បីផ្តល់នូវការផ្គត់ផ្គង់ទឹក ឬថាមពលប្រកបដោយនិរន្តរភាព សម្រាប់រយៈ៥០ ឆ្នាំខាងមុខ ខណៈមានការការពារបរិស្ថានធម្មជាតិ និងការធ្វើអោយប្រសើរឡើងនូវសុខុមាលភាពរបស់សហគមន៍នៅតំបន់គម្រោងនិងនៅផ្នែកខាងក្រោម?
ប្រតិបត្តិការ	តើទំនប់វារីអគ្គិសនីមួយអាចប្រតិបត្តិការបានដោយរបៀបណាដើម្បីផ្តល់នូវទឹក ឬការផ្គត់ផ្គង់ថាមពលប្រកបដោយនិរន្តរភាព ក៏ដូចជាដើម្បីឆ្លើយតបលើតម្រូវការខាងផ្នែកពាណិជ្ជកម្ម ការងារ ការកំសាន្ត និងតម្រូវការសង្គមនៃសហគមន៍ ខណៈមានការការពារសុខភាពសាធារណៈ និងបរិស្ថានធម្មជាតិ?
ការបិទបញ្ចប់	តើទំនប់វារីអគ្គិសនីមួយអាចត្រូវបានបិទបញ្ចប់ដោយលក្ខណៈ នៃការចំណាយមានប្រសិទ្ធភាពដោយរបៀបណា និង តំបន់ដែលបានស្តារនីតិសម្បទា ដើម្បីបំពេញតាមតម្រូវការរបស់សហគមន៍មូលដ្ឋាននិងដើម្បីដាក់ជម្រកធម្មជាតិសម្រាប់រុក្ខជាតិ និង សត្វព្រៃឲ្យនៅតាមកន្លែងដើមវិញ?

វាជាការសំខាន់ដើម្បីទទួលស្គាល់ថា ការសម្រេចចិត្តត្រូវបានធ្វើឡើងនៅដំណាក់កាលមួយពេលក្រោយមក គឺអាស្រ័យទៅលើការសម្រេចចិត្តដែលបានធ្វើរួចនៅក្នុងដំណាក់កាលមុន ។ ការសម្រេចចិត្តពីខាងដើម ជាញឹកញាប់ក្លាយទៅជា " ការផ្តល់ផ្តល់ឱ្យ " ឬ "មិនអាចចរចាបាន" សម្រាប់ការសម្រេចចិត្តបន្ទាប់ក្រោយមកទៀត។ ឧទាហរណ៍ ការសម្រេចចិត្តមួយអាចធ្វើបាន ដើម្បីសាងសង់អាគារវារីអគ្គីសនីមួយ ដោយមិនគិតពីផលប៉ះពាល់ដែលបានស្វែងយល់រួច ដោយផ្អែកលើផលប្រយោជន៍ជាតិធំទូលាយដែលបានដឹងដែលបន្ទាប់មកវាមានការជាប់ទាក់ទិនដែលកើតមានតាមមក សម្រាប់វិសាលភាពនៃការពិភាក្សាលើវិធានការបន្ធូរបន្ថយនិងការទូទាត់សំណង។ ដូចគ្នានេះដែរ ការសម្រេចចិត្តមិនឱ្យសហគមន៍បានចូលរួមនៅមុនដំណើរការមួយ អាចនាំទៅរកការខ្វះការយល់ដឹងអំពីមូលហេតុសមស្របនៃការសម្រេចចិត្តកាលពីដើមឡើយ នាំឲ្យខ្វះខាតទិន្នន័យសម្រាប់ធ្វើជាមូលដ្ឋានដល់សម្រេចចិត្ត នាំឲ្យមានការចំអកឡកឡឺយនិងការមិនទុកចិត្តពីសហគមន៍។ ពេលខ្លះភាគីពាក់ព័ន្ធចូលរួមក្នុងការសម្រេចចិត្តនៅពេលក្រោយ មិនបានដឹងពីមូលហេតុនៅពីក្រោយការសម្រេចចិត្តពីមុន ហើយមានបំណងចង់ត្រួតពិនិត្យការសម្រេចចិត្តទាំងនោះឡើងវិញ ឬចង់ចរចា

លើការសម្រេចចិត្តទាំងនោះសារជាថ្មី ។ ចំនុចនេះអាចបណ្តាលឱ្យមានការយល់ច្រឡំ និងបង្កើតជាជម្លោះទៀតផង។

ដូច្នេះភាពច្បាស់លាស់លើការសម្រេចចិត្តដែលបានធ្វើ ក្នុងបរិបទបានធ្វើឡើង អ្នកដែលត្រូវធ្វើការសម្រេចចិត្ត និង តួនាទីរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត គឺសុទ្ធសឹងជាចំណុចចាប់ផ្តើមដ៏សំខាន់មួយក្នុងការធ្វើផែនការលើការចូលរួមរបស់ភាគីពាក់ព័ន្ធ និង ការអនុវត្តន៍យ៉ាងមានប្រសិទ្ធិភាពលើផែនការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងនោះ។

អត្ថបទប្រអប់៨.១ ការចូលរួមជាសាធារណៈនៅក្នុងគម្រោងទ្រុងសុន ប្រទេសវៀតណាម (ដោយការផ្តល់មូលនិធិពីធនាគារពិភពលោក)

ការពិគ្រោះយោបល់ស្តីពីផែនការបរិស្ថាននិងការតាំងទីលំនៅថ្មី ត្រូវបានធ្វើឡើងជាមួយសហគមន៍រង-ផលប៉ះពាល់ បានចាប់ផ្តើមនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១០។ កិច្ចពិគ្រោះយោបល់ទាំងនេះ គេបានទទួលមតិចូលរួមជាច្រើនរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន អ្នកតំណាងគណៈកម្មការប្រជាជន និងមតិយោបល់ត្រឡប់ពីអ្នកដទៃទៀត រួមទាំងអ្នកសង្កេតការណ៍ឯករាជ្យផងដែរ។ សេចក្តីព្រាងច្បាប់ EAI / EMP / RLDP អាចរកបាននៅមជ្ឈមណ្ឌលព័ត៌មាននៅក្នុងប្រទេសវៀតណាម និងនៅទីក្រុងវ៉ាស៊ីនតោន ក៏ដូចជានៅលើគេហទំព័រ និងនៅEVN ។

ដើម្បីលើកកម្ពស់ការចូលរួមជាវិជ្ជមាន របស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងគម្រោងនេះ ធនាគារពិភពលោកបានចូលរួមក្នុងសិក្ខាសាលាមួយតាមការស្នើសុំរបស់បណ្តាញទន្លេវៀតណាម នៅក្នុងខែកញ្ញា និងបានអញ្ជើញអង្គការមិនមែនរដ្ឋាភិបាលនានាដើម្បីចូលរួមក្នុងកិច្ចពិភាក្សាអំពីការធ្វើបច្ចុប្បន្នភាពគម្រោងនៅចុងខែតុលា ។ កិច្ចប្រជុំមួយរវាងតំណាងក្រុមប្រឹក្សាគ្រប់គ្រងគម្រោងវារីអគ្គិសនីទ្រុងស៊ុន (TSHMPB) និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រារព្ធឡើងនៅក្នុងខែធ្នូ បន្ទាប់ពីតំណាងអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមក្នុងការពិគ្រោះយោបល់ភូមិរួចមកក្នុងនាមជាអ្នកសង្កេតការណ៍។

កិច្ចពិគ្រោះយោបល់នៅទីក្រុងហាណូយ ៖

ក្រុមប្រឹក្សាគ្រប់គ្រងគម្រោងវារីអគ្គិសនីទ្រុងស៊ុន (TSHMPB) និង ធនាគារពិភពលោកបានជួបប្រជុំគ្នានៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារឡាថាញ់ នាទីក្រុងហាណូយ ដោយការចូលរួមពីសមាជិកជាងមួយរយនាក់មកពីបណ្តា អង្គការសង្គមស៊ីវិល វិទ្យាស្ថានជំនាញ និងវិទ្យាស្ថានសិក្សាជាន់ខ្ពស់ ដើម្បីពិគ្រោះយោបល់ជាសាធារណៈមួយលើគម្រោងថាមពលវារីអគ្គិសនីទ្រុងស៊ុននៅក្នុងខេត្តថាញ់ហារ។ កិច្ចប្រជុំនោះក៏បានការចូលរួមពីតំណាងអាជ្ញាធរស្រុកនិងភូមិ រួមទាំងក្រុមស្ត្រីជនជាតិភាគតិចមកពីតំបន់រងផលប៉ះពាល់ពីគម្រោង ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចពិភាក្សានេះ។

នាយកមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងធនធានទឹកនិងបរិស្ថាននៃទន្លេអាង បានរៀបចំធ្វើការពិភាក្សាជាក្រុមរយៈពេលជិត៣ម៉ោង ដែលអមដោយបទបង្ហាញស្តីពីផែនការតាំងទីលំនៅថ្មី និងការអភិវឌ្ឍន៍ជីវភាពរស់នៅ ធ្វើផែនការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន ។ អ្នកចូលរួមបានទទួលរបាយការណ៍ ស្តីពីការពិគ្រោះយោបល់ដែលបានអនុវត្តដោយ PMB នៅក្នុងភូមិចំនួន៥៣ នៅក្នុងខែមករាដល់ខែកុម្ភៈ ឆ្នាំ២០១០។ កិច្ច-ពិភាក្សានេះអមដោយបទបង្ហាញពីក្រុមអង្គការក្រៅរដ្ឋាភិបាលវៀតណាម ដឹកនាំក្រុមពិភាក្សាដោយលោកស្រីងុយធីខាញ់ (Nguy Thi Khanh) ដែលជាតំណាងមជ្ឈមណ្ឌលសម្រាប់ការអភិរក្សនិងអភិវឌ្ឍន៍ធនធានទឹក (Warecod) និងបណ្តាញទន្លេវៀតណាម (VRN)។ កាលពីមុន ក្រុមនេះក៏បានចូលរួមផងដែរក្នុងការពិគ្រោះយោបល់ភូមិ ក្នុងនាមជាអ្នកសង្កេតការណ៍ឯករាជ្យ។

៨.១.៥ ការទទួលបានការយល់ព្រមជាសាធារណៈ គឺជាលទ្ធផលមួយនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ

ការទទួលយល់ព្រមជាសាធារណៈ គឺជាអាទិភាពជាយុទ្ធសាស្ត្រមួយរបស់គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់វារីអគ្គិសនី (WCD)។ ទោះជាយ៉ាងណា ការចូលរួមយ៉ាងល្អរបស់អ្នកពាក់ព័ន្ធ មិនចាំបាច់ត្រូវស្មើទៅនឹងការព្រមទទួលយកជាសាធារណៈឡើយ។ ការទទួលយល់ព្រមជាសាធារណៈមិនផ្តល់លទ្ធផលល្អគ្រាន់តែពីដំណើរការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធនោះទេ ហើយការថែទាំត្រូវតែបានអនុវត្តមិនឱ្យស្មើនឹងការចូលរួមដោយមានការទទួលយល់ព្រមនោះដែរ។ ការផ្តល់ពត៌មានត្រឹមត្រូវដើម្បីកំណត់ដោយប្រុងប្រយ័ត្នពីអត្តសញ្ញាណភាគីពាក់ព័ន្ធ និងការលើកទឹកចិត្ត ចំពោះការផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធពីការចូលរួមក្នុងការសម្រេចចិត្ត អាចឈានទៅដល់ការទទួលយល់ព្រមជាសាធារណៈ ប្រសិនបើអត្ថប្រយោជន៍នានាចំពោះអ្នកពាក់ព័ន្ធមានចំនួនច្រើនលើសពីគុណវិបត្តិទាំងឡាយ។ ទោះជាបែបនេះក្តី វាក៏អាចនាំឱ្យមានជម្លោះរវាងមហាជន និងអ្នកធ្វើការសម្រេចចិត្ត ដោយសារតែភាគីពាក់ព័ន្ធមិនបានមើលឃើញពីផលប្រយោជន៍សម្រាប់ពួកគេនៅក្នុងសំណើនេះឡើយ ។ តាមលក្ខណៈជាជម្រើសជំនួស វាអាចនាំឱ្យមានការព្រមព្រៀងគ្នាពីភាគីទាំងអស់ រួមទាំងអ្នកអភិវឌ្ឍន៍ផងដែរ ថាគម្រោងនេះ គឺជាគម្រោងមួយមិនអាចទទួលយកបានទេ។

ប្រអប់អត្ថបទ៨.២ គម្រោងទំនប់វារីអគ្គិសនីអាក្វា (Aqua) នៅប្រទេសណូវែលសេឡង់

ជាឧទាហរណ៍មួយនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលនាំឱ្យមានការមិនទទួលយកនៃគម្រោង ទើបគម្រោងទំនប់វារីអគ្គិសនីមួយនៅប្រទេសណូវែលសេឡង់ ដែលគេស្គាល់ថាជាគម្រោងទំនប់វារីអគ្គិសនីអាក្វា ដែលទំនប់នេះត្រូវបានស្នើឡើង និងនៅក្រោមក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងធនធាននៃប្រទេសណូវែលសេឡង់ ឆ្នាំ១៩៩១ ដែលជាប្រធានបទនៃដំណើរការពិគ្រោះយោបល់ជាសាធារណៈ ។ គម្រោងនេះ បានបង្កើតឲ្យមានជា កិច្ចជជែកពិភាក្សា និងការពិគ្រោះយោបល់យ៉ាងច្រើនសន្ធឹកសន្ធាប់ ជាមួយអ្នកពាក់ព័ន្ធ

ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ ក្នុងឆ្នាំ២០០៥ អ្នកគាំទ្រគម្រោង Meirdian Energy បានសម្រេចចិត្តបញ្ឈប់ដំណើរការ។

នៅពេលនោះ Keith Turner នាយកប្រតិបត្តិនៃគម្រោង Meridian Energy បាននិយាយថា ការរួមបញ្ចូលគ្នានៃកាល:ទេស:មួយ គឺមានន័យថា វាមិនមែនជាការប្រុងប្រយ័ត្ន ឬ ការទទួលខុសត្រូវចំពោះក្រុមហ៊ុនតទៅទៀតទេ ដើម្បីបន្តជាមួយនឹងគម្រោងនេះ។ កាល:ទេស:ពាក់ព័ន្ធមានរួមបញ្ចូលទាំងព័ត៌មានភូគព្ភបច្ចេកទេស (ឬភូមិសាស្ត្របច្ចេកទេស???) ដែលបង្កជាផលប៉ះពាល់មិនល្អដល់សេដ្ឋកិច្ចរបស់គម្រោង ការសម្រេចចិត្តដែលបានធ្វើនៅក្នុងតុលាការកំពូលជុំវិញធម្មជាតិនៃ " សិទ្ធិទឹក " រយៈនៃពេលវេលាដែលនឹងត្រូវចំណាយដើម្បីដោះស្រាយភាពមិនប្រាកដប្រជាទាក់ទងនឹងការព្រមព្រៀងគ្នាលើធនធា ការចំណាយនៃការអនុលោមតាមតម្រូវការនៃការព្រមព្រៀងគ្នា រួមទាំងសហគមន៍និងបន្ទុរបន្តុយផលប៉ះពាល់បរិស្ថាន និង តម្រូវការសម្រាប់ការសម្រេចចិត្ត និងការកាត់បន្តុយភាពមិនច្បាស់លាស់។ របាយការណ៍ប្រចាំឆ្នាំ២០០៤ របស់ក្រុមហ៊ុន Meridian Energy បានបង្ហាញថា ដោយសារគម្រោងនេះ ក្រុមហ៊ុនបានខាតបង់អស់ថវិកា៣៨,៧ លានដុល្លារណ្លាវែលសេឡង់។

៨.១.៦ បញ្ហាពាក់ព័ន្ធដទៃទៀត

បញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការទទួលយល់ព្រមជាសាធារណៈរួមមាន ៖

- ឆន្ទៈរបស់អ្នកធ្វើការសម្រេចចិត្តក្នុងការប្រើប្រាស់មតិយោបល់របស់អ្នកពាក់ព័ន្ធ ដែលមិនបានផ្តល់ឱ្យ។ អ្នកធ្វើការសម្រេចចិត្តជាច្រើនមិនព្រមទទួលយល់ព្រមថា ភាគីពាក់ព័ន្ធអាចផ្តល់មតិយោបល់ ដែលមានប្រយោជន៍ ជាពិសេសប្រសិនបើពួកគេមិនមានការអប់រំខ្ពស់ ឬ ពួកគេសម្រេចចិត្តថា " សហគមន៍មានការអប់រំកាន់តែច្រើន នាំឲ្យសង្គមជាតិបានល្អប្រសើរ " ពីទស្សនៈរបស់ពួកគេគួរតែមានប្រៀបជាង។
- ឆន្ទៈរបស់អ្នកជំនាញបច្ចេកទេសគឺដើម្បីចូលរួមជាមួយនិងស្តាប់ភាគីពាក់ព័ន្ធ ជាពិសេសក្រុមងាយរងគ្រោះ។ ក្រុមអ្នកជំនាញបច្ចេកទេសជាច្រើនជឿថាមានដំណោះស្រាយមួយ " ត្រឹមត្រូវ " មិនត្រូវសំឡឹងមើលភាពពាក់ព័ន្ធ ឬ គុណតម្លៃនៃទស្សនវិស័យផ្សេងទៀត ឬ ត្រូវបានដាក់កំហិតលើការពិចារណាពីជម្រើសជំនួសផ្សេង។។

- ដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអ្នកធ្វើសេចក្តីសម្រេចចិត្តត្រូវតែមានលក្ខណៈតម្លាភាព។ អ្នកធ្វើការសម្រេចចិត្តជាច្រើន មិនមានគំនិតច្បាស់លាស់អំពីដំណើរការ ដែលត្រូវប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តឡើយ ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធចាំបាច់ត្រូវជួនដំណឹងពីការ

សម្រេចចិត្តរបស់ពួកគេ ។ ដូច្នេះប្រសិនបើដំណើរការនេះមិនមានលក្ខណៈច្បាស់លាស់ទេ អាចនឹងមានការចូលរួមរបស់អ្នកពាក់ព័ន្ធ ប៉ុន្តែហាក់ដូចជាមិនធ្វើឲ្យប្រែប្រួលដល់ការចិត្តទេ។

- តម្រូវការក្នុងការវិនិយោគលើការកសាងសមត្ថភាព (ប្រអប់អត្ថបទ៨.២) សម្រាប់ភាគីពាក់ព័ន្ធ ឬការផ្តល់ការគាំទ្រ ដើម្បីបើកឲ្យមានការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ឧទាហរណ៍ ប្រសិនបើមិនមែនជាកម្រិតខ្ពស់ផ្នែកអក្ខរកម្ម ឬលទ្ធភាពទទួលបានបច្ចេកវិទ្យា។
- តម្រូវការក្នុងការប្រើប្រាស់បច្ចេកទេស ដែលរៀបចុះសម្រាប់ភាគីពាក់ព័ន្ធនានា ជាពិសេសដើម្បីជួយសម្រួលដល់ការចូលរួមរបស់ " ថ្នាក់មូលដ្ឋាន " (ប្រអប់អត្ថបទ ៨.៣) ។
- តម្រូវការសម្រាប់ស្តង់ដារអនុវត្តល្អប្រសើរដោយអ្នកធ្វើការសម្រេចចិត្ត សម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ពិសេសសម្រាប់តំណាងទើបជាប់ឆ្មោតថ្មី។ តថភាពនយោបាយជះឥទ្ធិពលលើមធ្យោបាយដែលការសម្រេចចិត្តត្រូវធ្វើឡើង ។ តថភាពនយោបាយ ក៏អាចជះឥទ្ធិពលលើសក្តានុពលសម្រាប់ការគិតគូរ ការឲ្យតម្លៃ និងការប្រើប្រាស់នូវមតិយោបល់របស់អ្នកពាក់ព័ន្ធ។ ក្នុងករណីជាច្រើន ភ័យន្តរាយផ្នែកយោបាយ ជាញឹកញាប់អាចកាត់បន្ថយបានតាមរយៈការចូលរួមរបស់អ្នកពាក់ព័ន្ធ។

ទីបំផុត ភាគីពាក់ព័ន្ធ ជាពិសេសការចូលរួមពីសហគមន៍ និង ការពិគ្រោះយោបល់បានជម្រុញឲ្យសម្រេចបាន នូវដំណើរការ និងលទ្ធផលជាច្រើនរបស់គម្រោង ដូចមានបង្ហាញនៅក្នុងគំនូសសម្គាល់ទី៨.១ ។

ប្រអប់អត្ថបទ៨.៣ ការកសាងសមត្ថភាព

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានឲ្យនិយមន័យ "សមត្ថភាព" ថាជា "បំណិនរបស់បុគ្គល ស្ថាប័ន និងសង្គមក្នុងការអនុវត្តមុខងារ ដោះស្រាយបញ្ហានិងកំណត់ពីគោលបំណង និង ធ្វើឲ្យសម្រេចបាននូវគោល

បំណងក្នុងលក្ខណៈមួយប្រកបដោយចីរភាព ។ ដូច្នេះ " កសាងសមត្ថភាព " ឬ " ការអភិវឌ្ឍសមត្ថភាព " ពិពណ៌នាអំពីភារកិច្ចនៃការបង្កើតសមត្ថភាពមនុស្ស និងស្ថាប័ន ។ ឧទាហរណ៍មានដូចជាការបណ្តុះបណ្តាលបុគ្គលិកសហគមន៍ ការពង្រឹងការប្រគល់ឲ្យរបស់រដ្ឋាភិបាលក្នុងស្រុក និងការបង្កើតស្ថាប័នស្រាវជ្រាវ និងកសាងគោលនយោបាយ។ ក្នុងរយៈពេលចុងក្រោយនេះការកសាងសមត្ថភាពមិនញែកដាច់ពីគ្នាពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍបានឡើយ ។

" ជាពិសេស ការកសាងសមត្ថភាពត្រូវបូករួមជុំវិញសមត្ថភាពរបស់មនុស្សវិទ្យាសាស្ត្រ បច្ចេកវិទ្យា អង្គការស្ថាប័ន និងធនធានរបស់ប្រទេសជាតិមួយ ។ គោលដៅជាមូលដ្ឋាននៃការកសាងសមត្ថភាព គឺដើម្បីលើកកម្ពស់សមត្ថភាព ក្នុងការវាយតម្លៃនិងឆ្លើយតបនឹងបញ្ហាចោតសំខាន់ៗ ដែលទាក់ទងនឹងជម្រើសគោលនយោបាយ និងរបៀបនៃការអនុវត្ត ក្នុងចំណោមជម្រើសការអភិវឌ្ឍនានាដោយពឹងផ្អែកលើការយល់ដឹងពីសក្តានុពលបរិស្ថាននិងដែនកំណត់ និងតម្រូវការនៃការយល់ឃើញពីសំណាក់ប្រជាពលរដ្ឋពាក់ព័ន្ធនៅក្នុងប្រទេស " (ការកសាងសមត្ថភាព-និយមន័យរបៀបវារៈទី២១ ជំពូកទី៣៧ UNCED ឆ្នាំ១៩៩២)។ ការកសាងសមត្ថភាព រួមមាន៖

- ការអភិវឌ្ឍធនធានមនុស្ស–ដំណើរការនៃការបំពាក់បរិក្ខាដល់បុគ្គលទាំងឡាយ ដែលមានការយល់ដឹងជំនាញនិងលទ្ធភាពទទួលបានព័ត៌មាន ចំណេះដឹងនិងការបណ្តុះបណ្តាលដែលអាចជួយពួកគេឱ្យបំពេញការងារប្រកបដោយប្រសិទ្ធិភាព។
- ការរៀបចំរបៀបចាត់ចែង-ការតាក់តែងរចនាសម្ព័ន្ធគ្រប់គ្រងដំណើរការ និងនីតិវិធីផ្សេងៗ។
- ការរៀបចំស្ថាប័ននិងក្របខ័ណ្ឌច្បាប់-ធ្វើការផ្លាស់ប្តូរច្បាប់ និង បទប្បញ្ញត្តិដើម្បីជួយដល់អង្គការស្ថាប័ននិងភ្នាក់ងារនានានៅគ្រប់កម្រិតនិងគ្រប់វិស័យ ដើម្បីលើកកម្ពស់សមត្ថភាពរបស់ខ្លួន។

ប្រអប់អត្ថបទ៨.៤ ការចូលរួមពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន

ការចូលរួមរបស់សហគមន៍សំដៅទៅលើដំណើរការ ដែលអង្គការអាចទទួលបានផលប្រយោជន៍ពីសហគមន៍និងពីបុគ្គលដែលបន្តកសាងឡើង ទំនាក់ទំនងជាអចិន្ត្រៃយ៍សម្រាប់គោលបំណងនៃការអនុវត្តតាមចក្ខុវិស័យរួមដើម្បីជាប្រយោជន៍នៃសហគមន៍មួយ។ ការរៀបចំសហគមន៍មួយទាក់ទងនឹងដំណើរការនៃការកសាងចលនាថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធនឹងសហគមន៍ ស្របពេលដែលការចូលរួមរបស់សហគមន៍

អាចប្រឈមដោះស្រាយជាបឋម លើការជួយដល់សហគមន៍ឲ្យដំណើរការទៅមុខតាមរយៈរបៀបមួយនៃការផ្លាស់ប្តូរ។

នៅក្នុងប្រទេសជាច្រើន មានមនុស្សដែលបានបាត់បង់ឱកាស។ បញ្ហានេះកើតឡើងដោយសារបញ្ហាជាច្រើន រួមមាន ៖ កម្រិតនៃការអប់រំទាប ភាពក្រីក្រ រួមនឹងកម្រិតនៃលទ្ធភាពទទួលបានធនធានផ្សេងៗ

ពិការភាព ចាស់ជរា មានជំងឺ ការរស់នៅក្នុងតំបន់ដាច់ស្រយាល បទដ្ឋានសង្គមដែលមានលក្ខណៈគៀបសង្កត់ ឧបសគ្គខាងភាសា និងមូលហេតុផ្សេងៗទៀត។ ក្នុងករណីជាច្រើន លទ្ធភាពទទួលបានព័ត៌មាននិងធនធានផ្សេងៗរបស់ប្រជាពលរដ្ឋនិងសហគមន៍ដែលបាត់បង់ឱកាសនៅមានកម្រិតនៅឡើយ។ ជាញឹកញាប់បំផុត ប្រការនេះបានរារាំង ឬបង្អាក់ពួកគាត់ពីការចូលរួមក្នុងកិច្ចពិភាក្សា ឬកិច្ចពិគ្រោះយោបល់ជាសាធារណៈ ដូចជាការចូលរួមពិភាក្សា ឬពិគ្រោះយោបល់ទាក់ទងនឹងគម្រោងទំនប់វារីអគ្គិសនីធំៗជាដើម។ មិនត្រឹមតែប្រជាសហគមន៍ទាំងនេះទេដែលបាត់បង់ឱកាសដើម្បីរួមចំណែកដល់ការអភិវឌ្ឍ សូម្បីតែសំណើនៃអភិវឌ្ឍក៏ត្រូវខាតបង់ផងដែរ ដោយសារមិនបានយកមកប្រើប្រាស់នូវចំណេះដឹងមូលដ្ឋាន ដែលអាចជួយលើកកម្ពស់បាននូវអ្វីដែលបានស្នើឡើង។ ដូច្នេះវាជាការសំខាន់ដើម្បីកំណត់អត្តសញ្ញាណសហគមន៍ដែលបាត់បង់ឱកាស និងត្រូវទទួលស្គាល់ពីឧបសគ្គទូទៅ ដើម្បីអាចឲ្យអ្នកអនុវត្តការចូលរួមជាសាធារណៈ អាចបង្កើតកិច្ចប្រឹងប្រែងពិសេសក្នុងចំណោមសហគមន៍មូលដ្ឋាន ដើម្បីជួយសម្រួលដល់ការចូលរួមរបស់សហគមន៍ទាំងនោះនៅក្នុងដំណើរការនៃការទំនាក់ទំនង។

មានមធ្យោបាយជាច្រើនដើម្បីជួយសម្រួលដល់ការចូលរួមពីថ្នាក់មូលដ្ឋាន ដែលមធ្យោបាយទាំងអស់នេះចាប់ផ្តើមជាមួយនឹង ការកំណត់ពីតម្រូវការសម្រាប់ការចូលរួមនេះ រួមមាន ការកសាងការទំនាក់ទំនងដោយផ្អែកលើការជឿទុកចិត្តជាមួយមនុស្សឬសហគមន៍ដោយឡែក ការអនុវត្តការកសាងសមត្ថភាពដើម្បីជាជំនួយដល់ការយល់ដឹង និង ការរៀបចំចាត់ចែងប្រជាពលរដ្ឋ ឬ សហគមន៍ចូលជាក្រុម តាមរយៈមធ្យោបាយណាដែលពួកគេអាចចូលរួមបាន។ការចូលរួមពាក់ព័ន្ធមានន័យថាជាការចូលរួមក្នុងកិច្ចពិភាក្សាដែលមានទាំងការស្តាប់ និងយល់ពីអ្វីដែលប្រជាពលរដ្ឋបានលើកឡើង ក៏ដូចជាការចែករំលែកពត៌មានជាដើម ។ ចំនុចនេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងតាំងពីដើមដល់ចប់ ដើម្បីបើកឱកាសឲ្យសហគមន៍ដែលបាត់បង់ឱកាសអាចចូលរួមពិភាក្សាជាមុន មុននឹងការចូលរួមជាក់ស្តែងក្នុងការពិភាក្សាលើប្រធានបទជាក់លាក់នានា ដូចជាសំណើសាងសង់ទំនប់ និងសំណើរអភិវឌ្ឍវារីអគ្គិសនី។ ជាការពិតណាស់ចំនុចនេះគួរតែត្រូវបានណែនាំបង្ហាញតែម្តងប៉ុណ្ណោះនៅពេលដែលមានទំនាក់ទំនងលើការទុកចិត្ត ហើយត្រូវជួយឲ្យប្រជាពលរដ្ឋឬសហគមន៍បានយល់ដឹងអំពីខ្លឹមសារសំខាន់ដែលពួកគេត្រូវបានលើកទឹកចិត្តឱ្យចូលរួម។

ការចូលរួមនេះតម្រូវឲ្យ " អនុវត្តចំពោះប្រជាពលរដ្ឋ " ដែលជាជួបប្រជុំមួយបន្តធ្វើយ៉ាងទៀងទាត់ពីម្នាក់ទៅម្នាក់ ឬជាកិច្ចប្រជុំជាក្រុម ។ កិច្ចប្រជុំទាំងនេះចាំបាច់ត្រូវគោរពដល់ប្រពៃណីមូលដ្ឋាន ទំនៀមទម្លាប់

និងភាសារបស់អ្នកស្រុក ដែលកិច្ចប្រជុំនេះត្រូវរៀបចំធ្វើសមស្របតាមពេលវេលារបស់សហគមន៍នៅតាមមូលដ្ឋាន ដោយមានការសម្របសម្រួលក្នុងលក្ខណៈយេនឌ័រ (ឧទាហរណ៍ ប្រសិនបើមានការចូលរួមពីក្រុមរបស់ស្ត្រី នោះអ្នកសម្របសម្រួលគួរតែជាបុរស) ដោយត្រូវគិតដល់ ភាពស្វាហាប់របស់សហគមន៍ និងគ្មានការរំខានដល់កិច្ចការងារប្រចាំថ្ងៃរបស់គ្រួសារសហគមន៍ ដែលជាធម្មតាពួកគេត្រូវប្រកបកិច្ចការងារជាច្រើន

ម៉ោងក្នុងមួយថ្ងៃៗ។ ជាការចាំបាច់ ព័ត៌មានពីគម្រោងត្រូវឲ្យរៀបចំយ៉ាងសាមញ្ញ ដើម្បីជួយសម្រួលដល់ការយល់ពីគំនិត ទំហំ និងការជាប់ទាក់ទិននានា។

មិនមានអ្វីដែលអាចដាក់ជំនួសឱ្យការបន្តការចូលរួមបានឡើយ ៖ គម្រោងដែលមានទំហំធំដូចជាគម្រោងទំនប់ និងគម្រោងថាមពលវារីអគ្គិសនី មានរយៈពេលអនុវត្តយូរអង្វែង។ ប្រសិនបើគ្មានការចូលរួមនេះទេ ប្រជាពលរដ្ឋអាចនឹងបំភ្លេចគម្រោងនេះឬពួកគាត់នឹងទៅជាព្រួយបារម្ភអន្ទះសារ ធ្វើឲ្យរាំងស្ទះដល់ការរីកចម្រើនរបស់គម្រោង និងការបង្កឱ្យមានភាពតានតឹងដែលមិនចាំបាច់ ។ ដូច្នេះ ទោះបីជាការរីកចម្រើនរបស់គម្រោងមានលក្ខណៈយឺតយ៉ាវក្តី ក៏វាជាការសំខាន់ក្នុងការរក្សាការប្រាស្រ័យទាក់ទងនេះដែរ។



គំនូសសម្គាល់៨.១ ដំណើរការ និងលទ្ធផលរបស់គម្រោងបានពីការចូលរួមរបស់អ្នកពាក់ព័ន្ធ/សហគមន៍

ប្រអប់អត្ថបទ៨.៥ សាវតា និយមន័យ និងទស្សនៈ:គន្លឹះ-ទិដ្ឋភាពគន្លឹះ

- IAP2 កំណត់និយមន័យលើការចូលរួមរបស់អ្នកពាក់ព័ន្ធថាជា " ដំណើរការដែលបើកឱកាសដល់ភាគីពាក់ព័ន្ធបានចូលរួមក្នុងការដោះស្រាយបញ្ហា ឬការធ្វើសេចក្តីសម្រេចចិត្ត និងប្រើប្រាស់មតិយោបល់របស់អ្នកពាក់ព័ន្ធទាំងនោះដើម្បីធ្វើឱ្យការសម្រេចចិត្តបានល្អប្រសើរជាងមុន " ។

- IAP2 កំណត់មូលដ្ឋានចំនួន៣ ដែលអាចកសាងបាននូវប្រសិទ្ធភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ៖ គុណតម្លៃដែលមានមូលដ្ឋាន សេចក្តីសម្រេចដែលមានការតម្រង់ទិស និងគោលបំណងដែលមានការជម្រុញ។
- វិសាលគមនៃការចូលរួមជាសាធារណៈរបស់ IAP2 បានផ្តល់អនុសាសន៍ថាការចូលរួមអាចមានប្រសិទ្ធិភាពនៅក្នុងកម្រិត៥យ៉ាង មានដូចជា កម្រិតនៃការផ្តល់ព័ត៌មាន កម្រិតនៃការផ្តល់ប្រឹក្សាយោបល់ កម្រិតនៃការចូលរួមពាក់ព័ន្ធ កម្រិតនៃការសហការ និងកម្រិតនៃការផ្តល់សិទ្ធិអំណាច។ គោលដៅនៃការចូលរួមនេះ " ការសន្យាធានា " ដល់សាធារណជន ចំណែកបច្ចេកទេសនានាត្រូវបានប្រើទៅតាមកម្រិតនីមួយៗខុសៗគ្នា។
- ត្រូវជៀសវាងគំរូម៉ូឌែល DAD (សម្រេចចិត្ត ប្រកាស ការពារ) ដែលមិនមានការការចូលរួមពីអ្នកពាក់ព័ន្ធ។
- គួរមានការចូលរួមពីអ្នកពាក់ព័ន្ធនៅគ្រប់ដំណាក់កាលទាំងអស់ ដែលបង្កើតឡើងជារយៈកាលនៃដំណើរការគម្រោង (នៅកម្រិតខុសគ្នានៃសកម្មភាព)។
- ការទទួលបានការយល់ព្រមពីសាធារណជន លើគម្រោងដែលបានស្នើឡើង ស្របពេលដែលគួរឱ្យចង់បាន គឺមិនមែនជាគោលដៅនៃការចូលរួមរបស់អ្នកពាក់ព័ន្ធទេ (ភាពចម្រុះនៃគំនិតយោបល់នាំឱ្យមានការសម្រេចចិត្តបានល្អប្រសើរជាងនិងមាននិរន្តរភាពជាង)។
- ការពិចារណាផ្សេងៗទៀតលើការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន ៖
  - ឆន្ទៈរបស់អ្នកធ្វើការសម្រេចចិត្តក្នុងការប្រើប្រាស់មតិយោបល់របស់អ្នកពាក់ព័ន្ធ ដែលមិនបានផ្តល់ឱ្យ។
  - ឆន្ទៈរបស់អ្នកជំនាញបច្ចេកទេសគឺដើម្បីចូលរួមជាមួយនិងស្តាប់ភាគីពាក់ព័ន្ធនានា។
  - ការបើកឱកាសឲ្យសហគមន៍មូលដ្ឋានបានចូលរួមពាក់ព័ន្ធ។
  - ដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ត្រូវតែមានលក្ខណៈតម្លាភាព។
  - តម្រូវការក្នុងការវិនិយោគលើការកសាងសមត្ថភាព សម្រាប់ភាគីពាក់ព័ន្ធ ឬ ការផ្តល់ការគាំទ្រដើម្បីបើកឲ្យមានការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
  - តម្រូវការក្នុងការប្រើប្រាស់បច្ចេកទេសដែលរៀបចុះសម្រាប់ភាគីពាក់ព័ន្ធនានា។
  - តម្រូវការសម្រាប់ស្តង់ដារអនុវត្តល្អប្រសើរដោយអ្នកធ្វើការសម្រេចចិត្ត សម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ពិសេសសម្រាប់តំណាងទើបជាប់ឆ្នោតថ្មី។

ប្រធានបទពិភាក្សា	ការកំណត់និយមន័យរបស់ IAP2 ស្តីពីការចូលរួមរបស់អ្នកពាក់ព័ន្ធ លេចឡើងជាពិសេសពីបណ្តាប្រទេស ដែលមានការអភិវឌ្ឍន៍ខាងវិស័យសេដ្ឋកិច្ច។

	ចូរពិភាក្សាអំពីភាពអាចអនុត្តបាន និង លទ្ធភាពក្នុងការអនុវត្តការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងបរិបទនេះនៅក្នុងប្រទេសរបស់អ្នក។ ..... ចូរបរិយាយលម្អិតថាតើការចូលរួមរបស់សហគមន៍ នៅក្នុងប្រទេសរបស់អ្នកអាចជៈឥទ្ធិពល ឬមិនអាចជៈឥទ្ធិពល និង ជៈឥទ្ធិពលដោយរបៀបណា ដើម្បីធ្វើឲ្យការធ្វើសេចក្តីសម្រេចចិត្តបានល្អប្រសើរជាងមុន។
លំហាត់	• ចូរកំណត់ឧទាហរណ៍នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលមានទំហំធំ កំពុងដំណើរការនៅក្នុងប្រទេសរបស់អ្នក ដែលគម្រោងនោះមានការចូលរួមពីអ្នកពាក់ព័ន្ធឬសហគមន៍ ហើយចូរធ្វើការវាយតម្លៃពីការចូលរួមចំណែករបស់ភាគីពាក់ព័ន្ធក្នុងការសម្រេចចិត្តប្រកបដោយលក្ខណៈល្អប្រសើរ។ ..... • នៅក្នុងប្រទេសរបស់អ្នក តើមានអ្វីខ្លះជាឧបសគ្គក្នុងការចូលរួមរបស់ភាគីពាក់ព័ន្ធ ឬសហគមន៍ ហើយតើត្រូវជំនះលើឧបសគ្គទាំងនេះដោយរបៀបណា?

៨.២-យន្តការនៃការចូលរួម

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការបរិយាយលម្អិតលើយន្តការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ។
ទិសដៅ	•ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីយន្តការនានានៃការចូលរួមរបស់ភាគីពាក់ព័ន្ធដែលមានស្រាប់ និង របៀបនៃការអនុវត្តតាមយន្តការទាំងនោះ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តីសម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ (ផ្នែកទី៣ ៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធ) www.unep.org/dams
	www.iap2.org

	ប្រអប់អត្ថបទវិទ្យាសាស្ត្រពលរដ្ឋ http://www.coastal.crc.org.au/toolbox/index.asp.

ខាងក្រោមនេះគឺជាទិដ្ឋភាពដ៏សំខាន់ សម្រាប់ធ្វើការពិចារណា ៖

- ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ។
- របៀបដើម្បីកំណត់អត្តសញ្ញាណ និង ធ្វើឲ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ការសម្រេចចិត្ត ឬដែលមានចំណាប់អារម្មណ៍នៅក្នុងលទ្ធផលនៃការសម្រេចចិត្ត។
- លទ្ធភាពទទួលបានព័ត៌មាន។
- របៀបដើម្បីផ្តល់នូវលទ្ធភាពទទួលបានព័ត៌មានដល់ភាគីពាក់ព័ន្ធដែលបានកំណត់។
- ការចូលរួមក្នុងការធ្វើការសម្រេចចិត្តដោយមានការផ្តល់ព័ត៌មាន។
- របៀបជួយសម្រួលដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធលើដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។

IAP2 បានបង្កើតទស្សន:ដើម្បីកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ ដើម្បីកំណត់និងផ្តល់ព័ត៌មានពីសារសំខាន់ៗ ដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ និងដើម្បីធ្វើដំណើរការលើទិន្នន័យដើម្បីផ្តល់ព័ត៌មានដែលមានប្រយោជន៍ទៅដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។ វាក៏ជាការលើកទឹកចិត្តឱ្យអ្នកអនុវត្តនិងអ្នកធ្វើការសម្រេចចិត្តអាចពង្រីកវិសាលភាពនៃដំណើរការរបស់ខ្លួន សំដៅធានាថាភាគីពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានពីរបៀបដែលមតិយោបល់របស់ពួកគេមានឥទ្ធិពលលើការសម្រេចចិត្តណាមួយនោះ។

ការពិភាក្សាខាងក្រោមនេះ គឺជាបង្ហាញលក្ខណ:ពិសេសនៃការចូលរួមរបស់អ្នកពាក់ព័ន្ធដោយផ្អែកលើទស្សន:របស់ IAP2 ដែលជាគាំទ្រអន្តរជាតិនាំមុខគេលើការចូលរួមរបស់ភាគីដែលពាក់ព័ន្ធ។ ការពិភាក្សាទាក់ទងជាមួយយន្តការនិងវិធីសាស្ត្រជាលក្ខណ:ស្តាប់ន ជាការផ្តល់ហិរញ្ញប្បទាន ជាការកំណត់ពេលវេលាជាកម្រិត និងជាវិសាលភាពនៃការចូលរួមនិងផែនការនៃការចូលរួម។ សម្រាប់គោលបំណងនៃសៀវភៅបណ្តុះបណ្តាលនេះ ធាតុដ៏សំខាន់ៗសំដៅដល់យន្តការសម្រាប់ការចូលរួម និងវិធីសាស្ត្រជាលក្ខណ:ស្តាប់ន ដើម្បីអនុវត្តធាតុសំខាន់ៗទាំងនោះ។

៨.២.១ ការវិភាគរបស់ភាគីពាក់ព័ន្ធ និងផែនការចូលរួម

អ្វីដែលនាំមុខក្នុងការសម្រេចចិត្តលើយន្តការសម្រាប់ការពិគ្រោះយោបល់ គឺការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ ការវិភាគចំណាប់អារម្មណ៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធ និងប្រសិនបើអាចគឺការបើកឱកាសឲ្យភាគីពាក់ព័ន្ធបានចូលរួមក្នុងការកំណត់ពីយន្តការ ដែលជាការនិយមពេញចិត្តសម្រាប់ជារបៀបដែលពួកគេចង់ចូលរួម។

តារាង៨.១: ប្រទេសថៃ - បច្ចេកទេសនៃការចូលរួមជាសាធារណ:ក្នុងដំណាក់កាលអភិវឌ្ឍន៍គម្រោង

	ការផ្តួចផ្តើមគម្រោង	ការរៀបចំគម្រោង	ការធ្វើផែនការគម្រោង	ការត្រួតពិនិត្យគម្រោង	ការវាយតម្លៃគម្រោង	ការសម្រេចចិត្តរបស់គម្រោងសម្រាប់ពេលអនាគត
វេទិកាសាធារណៈ	•					
កិច្ចប្រជុំក្រៅផ្លូវការ	•			•	•	•
ក្រុមការងារសម្រាប់ផ្លាស់ប្តូរទិន្នន័យ	•		•		•	
សិក្ខាសាលា	•	•	•	•	•	•
ក្រុមប្រឹក្សាយោបល់	•	•	•	•	•	•
បទសម្ភាសន៍បុគ្គល	•				•	•
ក្រុមគោលដៅ	•	•	•		•	•
មតិតាមរយៈគេហទំព័រ	•			•	•	•
ការស្វង់មតិមតិ	•		•	•	•	•
សង្ក្រោះបន្ទាន់/ខ្សែទូរស័ព្ទផ្ទាល់	•			•	•	
សវនាការជាសាធារណៈ	•				•	•
ឯកសារជាភស្តុតាង	•		•	•	•	•
ព្រឹត្តិប័ត្រព័ត៌មាន	•			•	•	
របាយការណ៍សិក្សា	•	•	•		•	
ខ្សែវីដេអូ	•		•	•	•	
មជ្ឈមណ្ឌលព័ត៌មាន	•		•	•	•	•
ការបោះពុម្ពផ្សាយព័ត៌មាន	•	•			•	•
វេទិកាបទបង្ហាញពត៌មាន	•		•	•	•	•
ការទំនាក់ទំនងវិទ្យុ	•			•	•	

សិក្ខាសាលាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ	•		•	•	•	
ប៉មចាក់ផ្សាយសហគមន៍ដំណើរទស្សនកិច្ចសិក្សា	•			•	•	
បទបង្ហាញ	•	•	•	•	•	•
សេចក្តីរាយការណ៍នៅក្នុងកិច្ចប្រជុំជាផ្លូវការ	•	•	•	•	•	•

ប្រភព: កូនសៀវភៅស្តីពីការចូលរួមជាសាធារណៈ: មូលនិធិប្រតិបត្តិរដ្ឋបាលសាធារណៈ: សាកលវិទ្យាល័យធម្មសាត ឆ្នាំ២០០៣ (ជាភាសាថៃ)។

ជាឧទាហរណ៍ អ្នកពាក់ព័ន្ធដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់អាចមានបំណងចង់ចូលជាសមាសភាពគណៈកម្មាធិមួយដែលអាចចូលរួមនៅជុំវិញដំណើរការនេះ ។ អ្នកពាក់ព័ន្ធផ្សេងទៀតអាចមានការចាប់អារម្មណ៍ជាទូទៅដើម្បីមើលថាមានការអនុវត្តតាមដំណើរការសមស្រប ឬ ត្រូវពិចារណា ចំពោះទេពកោសល្យល្អ ដូច្នេះហើយប្រហែលជាចង់តែព្រឹត្តិបត្រព័ត៌មាន ជាមួយនឹងបដិញ្ញាថាដំណើរការទាំងនោះប្រហែលជាអាចទាក់ទងជាមួយអ្នកគ្រប់គ្រងលើអ្នកចូលរួម ឬមន្ត្រីទំនាក់ទំនង ប្រសិនបើពួកគេមានការព្រួយបារម្ភ ឬមានព័ត៌មានដែលត្រូវចូលរួមចែករំលែក។

ផែនការពិគ្រោះយោបល់មួយគួរតែត្រូវបានបង្កើតឡើងនៅមុនដំណើរការ ដោយការដាក់បញ្ចូលទ្ធផលនៃការវិភាគលើអ្នកពាក់ព័ន្ធ។ លទ្ធផលទាំងនោះអាចត្រូវបានប្រើសម្រាប់ ដូចខាងក្រោម ៖

- ដើម្បីទទួលបាននូវកិច្ចព្រមព្រៀងពីអ្នកធ្វើការសម្រេចចិត្ត អំពីដំណាក់កាលនីមួយៗ អំពីគោលបំណង និងរយៈពេលសម្រាប់ការចូលរួម។
- ដើម្បីធ្វើឱ្យមានតម្លាភាពលើដំណើរការធ្វើការសម្រេចចិត្តសម្រាប់អ្នកចូលរួម។
- ដើម្បីកំណត់ឲ្យឃើញច្បាស់ពីបច្ចេកទេសសមស្របសម្រាប់ប្រភេទផ្សេងគ្នានៃអ្នកពាក់ព័ន្ធ។
- ដើម្បីកំណត់ធនធានដែលត្រូវការ និង រយៈពេលសម្រាប់ដំណាក់កាលនីមួយនៃដំណើរការនេះ។

ផែនការពិគ្រោះយោបល់មួយអាចត្រូវបានផ្តល់ជូនដល់អ្នកចូលរួម ដើម្បីបានត្រឡប់វិញនូវរបៀបដែលពួកគេចង់ចូលរួម និងថាតើអ្នកដែលពាក់ព័ន្ធត្រូវបានគេមើលរំលងដែរឬទេ។ ការស្វែងរកមតិត្រឡប់វិញលើផែនការពិគ្រោះយោបល់ គឺសំខាន់ណាស់ព្រោះអាចជាការចូលរួមចំណែកជាលើកដំបូងរបស់អ្នកពាក់ព័ន្ធ

ចំពោះដំណើរការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ។ ក្នុងករណីខ្លះ ផែនការពិគ្រោះយោបល់អាចត្រូវបានចុះហត្ថលេខាបញ្ចប់តាមកិច្ចព្រមព្រៀងបិទជាផ្លូវការរវាងភាគីទាំងអស់។

មានជំហានសំខាន់៥យ៉ាង ក្នុងការរៀបចំនិងគ្រោងផែនការស្តីពីដំណើរការចូលរួមគឺ ៖

- ការទទួលបានការប្តេជ្ញាចិត្តខាងក្នុង។
- ការសិក្សារៀនសូត្រពីសាធារណជនឬអ្នកពាក់ព័ន្ធនានា។
- ការសម្រិតសម្រាំងលើកម្រិតនៃការចូលរួមនិងការគូសបញ្ជាក់ពីគោលដៅ គោលបំណង និងការសន្យាធានាលើការចូលរួម។
- ការគូសបញ្ជាក់យ៉ាងច្បាស់ពីដំណើរការនៃការសម្រេចចិត្តនិងគោលបំណងនៃការចូលរួមនៅក្នុង ជំហាននីមួយៗ។
- ធ្វើការផែនការលើការចូលរួម។

នៅក្នុងចំនុចខាងលើនេះ សុទ្ធសឹងជាតម្រូវការចាំបាច់ដើម្បីបញ្ជាក់ពីវិសាលភាពនៃសេចក្តីសម្រេចនេះ និងដំណើរការនៃការសម្រេចចិត្ត ដែលត្រូវប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកសម្រេចចិត្ត និង កម្រិតនៃឥទ្ធិពលរបស់ភាគីពាក់ព័ន្ធ និងដើម្បីយល់ពីភាគីពាក់ព័ន្ធនិងបញ្ហាទំនងរបស់ពួកគេ មុនពេលកំណត់វិធីសាស្ត្រនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងឧបករណ៍ផ្សេងៗ ។ ផែនការចូលរួម គួរតែចាប់ដំណើរការនៅពេលចាប់ផ្តើមដំណើរការនៃការចូលរួមនេះ ហើយគួរតែអាចបត់បែនបានគ្រប់គ្រាន់ ដើម្បីឲ្យផែនការទាំងអស់នេះអាចឆ្លើយតបបានទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធនានា។ ចំនុចនេះតម្រូវឱ្យមានវិធីសាស្ត្រជាប្រព័ន្ធនិងធ្វើឡើងជាច្រើនដង។

៨.២.២ បច្ចេកទេស និងឧបករណ៍នានា

មានយន្តការជាច្រើនសម្រាប់ឲ្យមានការចូលរួមភាគីពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ IAP2 បានបង្ហាញថាមានទម្រង់៣យ៉ាងត្រូវបានប្រើប្រាស់ជាទូទៅដើម្បីសម្រេចបាននូវគោលបំណងនេះ៖

- មានបច្ចេកទេសនិងឧបករណ៍ជាច្រើនប្រភេទ ដែលអនុញ្ញាតឱ្យមានការចែករំលែកព័ត៌មានដោយ តុល្យភាពនិងដែលមិនលំអៀង។
- នៅមានបច្ចេកទេសជាច្រើនប្រភេទទៀត ដែលជួយគាំទ្រដល់ការប្រមូលផ្តុំទិន្នន័យពីអ្នកពាក់ព័ន្ធដែលត្រូវការសរុបបញ្ចូលគ្នា និងដាក់ឲ្យដំណើរការទៅជាព័ត៌មានដ៏មានសារៈប្រយោជន៍សម្រាប់អ្នកធ្វើការសម្រេចចិត្ត។
- ជាចុងក្រោយនៅមានបច្ចេកទេសផ្សេងៗ សម្រាប់គៀងគរប្រជាពលរដ្ឋឲ្យចូលរួមជាមួយគ្នាក្នុងការចែករំលែកព័ត៌មាន ការផ្តល់នូវមតិត្រឡប់ ការបង្កើតគំនិតថ្មីៗ ការទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ឬការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនេះ។

ត្រូវធ្វើការជ្រើសរើសបច្ចេកទេស[យោង២៦] ដោយផ្អែកលើគោលបំណងនៃការចូលរួមរបស់អ្នកពាក់ព័ន្ធនិងចំណង់ចំណូលចិត្តរបស់អ្នកពាក់ព័ន្ធភាសា និងវប្បធម៌របស់អ្នកពាក់ព័ន្ធ ធនធានដែលមានស្រាប់ (រួមទាំងថវិកា ពេលវេលា និងជំនាញ) និងទំហំនិងភាពស្មុគស្មាញនៃគម្រោង។ ជម្រើសបច្ចេកទេស ឬយន្តការមិនត្រូវធ្វើឲ្យរំខានដល់ដំណើរការនេះទេ។ ផ្ទុយទៅវិញ បច្ចេកទេសនេះ ត្រូវតែជ្រើសរើសដោយមានការសម្រេចចិត្តដែលបានធ្វើឡើងជាលើកដំបូង និងដោយមានការគិតគូរដល់គោលបំណងនៃការចូលរួមផងដែរ។

ជាធម្មតា ឧបករណ៍ដែលត្រូវបានប្រើជាញឹកញាប់បំផុតដោយអ្នកស្នើសុំគម្រោងធំៗ (ដូចជាទំនប់និងសំណង់អគារវារីអគ្គិសនី) រួមជាមួយនឹងការកំណត់ពីផលប៉ះពាល់ដ៏ធំទៅលើ បរិស្ថាននិងសហគមន៍មូលដ្ឋាន នៅក្នុងតារាង៨.២ និងត្រូវបានបរិយាយលម្អិតនៅខាងក្រោម ដោយមានឧទាហរណ៍ជាក់ស្តែង។

- **ខិត្តបណ្ណព័ត៌មាន ផ្ទាំងរូបភាពបង្ហាញ ព្រឹត្តិប័ត្រព័ត៌មាន និងគេហទំព័រ។**

ឧបករណ៍ទាំងនេះ គឺជាមធ្យោបាយទូទៅនៃការផ្តល់ព័ត៌មានដល់សហគមន៍ អំពីគម្រោង ការវិវត្តន៍នៃគម្រោង ដំណាក់កាលនៃការពិគ្រោះយោបល់ និងរបៀបនៃការប្រើប្រាស់មតិត្រឡប់របស់អ្នកពាក់ព័ន្ធ។

- **ការស្ទង់មតិដើម្បីប្រមូលព័ត៌មាននិងទស្សនៈយោបល់ផ្សេងៗ។**

បច្ចេកទេសទាំងនេះត្រូវបានអនុវត្តនៅលើគម្រោងនានាដូចជា ការតាំងទីលំនៅថ្មីនៅផ្នែកខាងលើ Kotmale (ស្រីលង្កា) Andhikhola (ប្រទេសនេប៉ាល់) អាងទន្លេ Ribble (ចក្រភពអង់គ្លេស) និងThai Baan (ប្រទេសថៃ) ការវាយតម្លៃដែលដឹកនាំដោយសហគមន៍។ គម្រោង Andhikhola បានចាប់ផ្តើមឲ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធ ជាមួយនឹងការស្ទង់មតិ " ជាមូលដ្ឋាន " ដើម្បីធ្វើឲ្យប្រាកដពីតម្រូវការ និងឥរិយាបថរបស់ភាគីពាក់ព័ន្ធ។ គម្រោង Thai Baan បានប្រើប្រាស់ " ការស្រាវជ្រាវរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន " ដើម្បីកំណត់ពីបញ្ហា និងឯកសារនានាដែលមានការពិត។ សម្រាប់គម្រោងតាំងទីលំនៅថ្មីនៅផ្នែកខាងលើ Kotmale ការស្ទង់មតិលើផ្នែកសង្គមសេដ្ឋកិច្ច ត្រូវបានធ្វើឡើងជាមួយសហគមន៍ដែលរងផលប៉ះពាល់ ។

[យោង២៦] ការជ្រើសរើសបច្ចេកទេសសមស្របសម្រាប់ក្រុមអ្នកពាក់ព័ន្ធជាពិសេស ពិតជាមានសារៈសំខាន់ណាស់ ចំណែកបុគ្គលិកសមស្របនៃក្រុមអ្នកចូលរួមពីភាគីពាក់ព័ន្ធត្រូវបានជួលឲ្យធ្វើការលើសកម្មភាពដាច់ដោយឡែក ។ ឧទាហរណ៍ អ្នកចុះឈ្មោះជាស្ត្រីទំនងជាអាចជម្រុញឲ្យក្រុមស្ត្រីបានចូលរួមប្រកបដោយលក្ខណៈស្ថាបនា និងផ្លែផ្កាជាងអ្នកចុះឈ្មោះជាបុរស នៅជុំវិញខ្លឹមសារដែលជាប្រយោជន៍ និងសារៈសំខាន់ដល់ស្ត្រី។ ស្រដៀងគ្នានេះដែរ អ្នកចុះឈ្មោះជាបុរស ទំនងជាអាចជម្រុញឱ្យមានការចូលរួមពីក្រុមបុរស បានដោយជោគជ័យ ជាងអ្នកចុះឈ្មោះជាស្ត្រី តួយ៉ាងដូចជាសមាជិករបស់សមាគមកសិករតាមឃុំ។

ផែនការគ្រប់គ្រងអាងទន្លេ Ribble បានផ្តល់ជាកម្រងសំនួរសម្រាប់ការស្ទង់មតិលើទស្សនៈយល់ដឹងផ្សេងៗ ។ ការផ្តល់នូវកម្រងសំណួរត្រឡប់វិញ ដែលជាកម្រងសំនួរត្រូវបានយកមកប្រើប្រាស់ជាទូទៅសម្រាប់ជាផ្នែកមួយនៃកញ្ចប់ព័ត៌មាន ដើម្បីទទួលបានមតិយោបល់នៅក្នុង

គម្រោង Coquitlam ។ គួរកត់សម្គាល់ផងដែរថា ទិន្នន័យនៃការចូលរួមជាច្រើនដែលប្រមូលផ្តុំដោយវិធីសាស្ត្រដែលមាន (ឧទាហរណ៍ ការវាយតម្លៃការចូលរួមនៅតាមជនបទ) ហើយទិន្នន័យទាំងនោះអាចផ្តល់នូវការចុះទិន្នន័យដែលមានប្រយោជន៍ដល់ការចូលរួមរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់។

- **បច្ចេកវិទ្យាដែលផ្តល់ជំនួយដោយកុំព្យូទ័រ។**

នៅពេលដែលមានការបង្ហាញឱ្យឃើញថាការពិគ្រោះយោបល់ TVA ពិជាមានប្រយោជន៍អាចនឹងប្រើការមិនបាន ឬ ដែលមិនគ្រប់គ្រាន់នៅក្នុងស្ថានភាពផ្សេងទៀត ។ ដំណើរការនេះទាមទារឱ្យមានការប្រើប្រាស់ក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាន (IT) ដើម្បីបង្កើតនិងគ្រប់គ្រងឧបករណ៍ទំនាក់ទំនងទៅវិញទៅមកដើម្បីទទួលមតិយោបល់ពីអ្នកចូលរួម និងសម្ភារៈកុំព្យូទ័រមួយឈុត។ វិធីសាស្ត្រនេះមានលក្ខណៈសមស្របទៅនឹងគម្រោង TVA ដោយសារតែដំណើរការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធមានទ្រង់ទ្រាយធំ។

តារាង៨.២ ឧបករណ៍ដែលបានប្រើញឹកញាប់ដោយគម្រោងធំៗដែលបានស្នើ (ដូចជាគម្រោងទំនប់ សំណង់អគារវារីអគ្គិសនី)

ឧបករណ៍ចែករំលែកព័ត៌មាន	ឧបករណ៍ដើម្បីប្រមូលផ្តុំនិងឫកសរុបទិន្នន័យ	ឧបករណ៍ដើម្បីបើកឱកាសឲ្យមានការទំនាក់ទំនង
ការផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយ	ការអង្កេតសិក្សា	សិក្ខាសាលា
ខិត្តប័ណ្ណផ្សព្វផ្សាយ	ទម្រង់ផ្តល់មតិ	កិច្ចពិភាក្សា/ក្រុមគោលដៅ
កិច្ចប្រជុំបើកចំហ និងការតាំងបង្ហាញ	កិច្ចសម្ភាសន៍	កិច្ចប្រជុំជាសាធារណៈ
គេហ៍ទំព័រ	ក្រុមការគោលដៅ	គណៈកម្មការភាគីពាក់ព័ន្ធ
ខ្លឹមសារព័ត៌មានខ្លី	វេទិកាជាសាធារណៈ	កិច្ចប្រជុំតាមសហគមន៍
ការតាំងពិពណ៌ជាសាធារណៈ	ក្រុមត្រួតពិនិត្យ	បុគ្គលិកទំនាក់ទំនងរបស់គម្រោងដែលមានចរិកលៈបង់ខ្ពស់
ការិយាល័យគម្រោង/ធនធានក្នុងមូលដ្ឋាន/ឬមណ្ឌលព័ត៌មាន		

- **គណៈកម្មការ និងក្រុមការងារ។**

គណៈកម្មការ និង ក្រុមការងារទាំងនេះត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការទំនាក់ទំនងរបស់អ្នកតំណាងសម្រាប់រយៈពេល ឬ ដំណាក់កាលទីមួយនៃគម្រោង។ ក្រុមនេះមានអត្ថប្រយោជន៍សម្រាប់ការកសាងជំនឿទុកចិត្ត ការផ្លាស់ប្តូរគំនិត ការប្រមូលផ្តុំនិងការវិភាគរួមគ្នាលើទិន្នន័យ កិច្ចសហប្រតិបត្តិការ និងកិច្ចសហការ។ ក្រុមនេះជាញឹកញាប់ត្រូវបានបង្កើតឡើងសម្រាប់គម្រោងតាំងទីលំនៅថ្មី ដែលមានដូចជា គម្រោងទំនប់ន់វារីអគ្គិសណាំធឿន២ (Nam Theun2) ទំនប់Kotmaleភាគខាងលើ និងទំនប់ Salto Caxias។ សម្រាប់គម្រោងផ្សេងទៀត វិសាលភាពនៃក្រុមការងារនេះត្រូវបានពង្រីកដើម្បីរួមបញ្ចូលការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពឧ តួយ៉ាងដូចជានៅ Eastmain A1/Rupert ជាដើម។ នៅទំនប់ Andhikhola វិសាលភាពនេះត្រូវបានពង្រីក ដើម្បីបើកឱកាសឲ្យអ្នកប្រើប្រាស់អង្គការអាចចូលរួមពាក់ព័ន្ធជាអចិន្ត្រៃយ៍នៅក្នុងការធ្វើផែនការ ការរៀបចំ និងការគ្រប់គ្រងលើការចូលរួម ។ នៅពេលដែលក្រុមនេះមានមធ្យោបាយគ្រប់គ្រាន់ និងមានប្រសិទ្ធិភាពក្នុងការបើកឱកាសឲ្យអ្នកតំណាងដែលមានចំណេះដឹង បានចូលរួមក្នុងកិច្ចពិភាក្សា ដោយអ្នកតំណាង ឬក្រុមគម្រោងមិនត្រូវប្រើកិច្ចប្រជុំនេះជំនួសឲ្យការចូលរួមឲ្យបានទូលំទូលាយរបស់សហគមន៍ឡើយ។

- **មន្ត្រីពិគ្រោះយោបល់ដែលមានការប្តេជ្ញាចិត្តខ្ពស់។**

មន្ត្រីពិគ្រោះយោបល់ដែលមានការប្តេជ្ញាចិត្តខ្ពស់ ត្រូវបានគេប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពនៅក្នុង គម្រោងCoquitlam, Wivenhoe, Eastmain Al/Rupert, TVA និងគម្រោង Olifants ដែលមន្ត្រីទាំងនោះបានរួមចំណែកដល់ភាពជោគជ័យជារួមនៃផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ។ ចរិកលក្ខណៈនៃដំណើរការដោយប្រើធនធានតិចតួចបានល្អ គឺអាស្រ័យលើប្រធានគម្រោងដែល ត្រូវទទួលខុសត្រូវជាបឋមលើការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលគ្មានជំនាញលើការពិគ្រោះយោបល់ជាក់លាក់ តួយ៉ាងដូចជាគម្រោងណាំធឿន២ ដែលបន្ទាប់មកបានព្យាយាមដោះស្រាយនូវភាពខ្វះខាតតាមរយៈវិធីសាស្ត្រកសាងសមត្ថភាព។

- **មជ្ឈមណ្ឌលធនធាននៅមូលដ្ឋាន។**

គឺជាទីតាំងនៃការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធក្នុងគម្រោង Coquitlam គម្រោង Nam Theun 2 និងគម្រោង Eastmain Al/Rupert ដែលជាកន្លែងដាក់តាំងបង្ហាញផ្ទាំងរូបភាពនានា និង

ផ្តល់ព័ត៌មានផ្សេងៗ។ នៅក្នុងករណីមួយចំនួន ទីកន្លែងនេះបានក្លាយជាមូលដ្ឋានសម្រាប់មន្ត្រីពិគ្រោះយោបល់ដែលមានចរិកលះបង់ខ្ពស់។

- **លទ្ធភាពដើម្បីបើកឱកាសឲ្យអ្នកចូលរួមប្រើប្រាស់ភាសាមូលដ្ឋានសមស្រប។**

ចំនុចនេះគឺសំខាន់ណាស់សម្រាប់គម្រោងនីមួយៗ ដូចដែលបានបង្ហាញនៅក្នុងគម្រោង Olifants គម្រោង Eastmain Al/Rupert គម្រោង Kotmaleភាគខាងលើ និងគម្រោងNam Theun 2 ។

យន្តការផ្សេងទៀតដែលបានបង្ហាញថាមានប្រយោជន៍លើគម្រោងទំនប់ និងគម្រោងវារីអគ្គិសនីដែលមានទំហំធំ ជាពិសេសនៅក្នុងបរិបទនៃការរីកចម្រើនខាងសេដ្ឋកិច្ច មានដូចខាងក្រោម ៖

- វិទ្យុនិងទូរទស្សន៍។
- ខិត្តប័ណ្ណផ្សព្វផ្សាយ។
- ពត៌មានទាន់ហេតុការណ៍។
- គណៈកម្មការទំនាក់ទំនងសហគមន៍។
- ទស្សនកិច្ចនៅមូលដ្ឋាន។
- ការផ្ញើសារអេឡិចត្រូនិក។
- ការប្រើអ្នកស្រាវជ្រាវនៅមូលដ្ឋាន។

ប្រអប់អត្ថបទ៨.៦ ករណីសិក្សាលើគម្រោងវារីអគ្គិសនី A'Vuong ក្នុងប្រទេសវៀតណាម

ករណីសិក្សាលើគម្រោងវារីអគ្គិសនី A'Vuong ក្នុងប្រទេសវៀតណាម ដែលបានប្រតិបត្តិការនៅឆ្នាំ ២០១០ ត្រូវបានបង្កើតឡើង និងប្រតិបត្តិដោយ EVN ។ នៅក្នុងជំហានទីមួយនៃការផ្តល់ជំនួយបច្ចេកទេស (TAs) កាលពីឆ្នាំ២០០៧-២០០៨ អាជ្ញាធរនិយតកម្មអគ្គិសនីវៀតណាម (ERAV) បានប្រើប្រាស់នីតិវិធីពិភាក្សាជាមួយពហុភាគីពាក់ព័ន្ធដើម្បីឡើងទទួចសុំទស្សនៈយោបល់ និងគំនិតនានាទៅលើសេចក្តីព្រាងអនុក្រឹត្យ។ កិច្ចពិភាក្សានេះ ចូលរួមពាក់ព័ន្ធដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការធំៗមួយចំនួន ស្ថាប័នក្រសួងផ្សេងៗ អ្នកតំណាងថ្នាក់ខេត្ត និងដៃគូអភិវឌ្ឍន៍ក្នុងប្រទេសវៀតណាម តាមរយៈសិក្ខាសាលារយៈមួយថ្ងៃចំនួន៣ ក្នុងរយៈពេលប្រហែល១៥ខែ។ ការពិគ្រោះយោបល់ទាំងនេះមានសារៈសំខាន់និងមានភាពចាំបាច់យ៉ាងខ្លាំង ដោយសារភាគីពាក់ពន្ធទាំងនេះបានគាំទ្រយ៉ាងទូលំទូលាយលើការបែងចែកផលប្រយោជន៍ និងជាពិសេសទទួលបានការគាំទ្រពីបណ្តាខេត្តនានា និងអង្គការធំៗមួយចំនួន (អង្គការសង្គមស៊ីវិល) នៅក្នុងប្រទេសវៀតណាមទាំងមូល។ គម្រោងនេះត្រូវបានកំណត់ឲ្យបន្តដំណើរការក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងឆ្នាំ២០១១។

គំនូសសម្គាល់ខាងក្រោមនេះ បង្ហាញពីការកំណត់ឲ្យឃើញពីដំណើរការនៃការចូលរួម។



១. សហគន៍រងផលប៉ះពាល់ដែលស្ថិតនៅតាមដងទន្លេភាគខាងលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបញ្ជាក់ពីកម្រិតទំហំនៃឃុំ ដែលរងផលប៉ះពាល់ពីការចូលទៅដល់អាងស្តុកទឹក និងប្រាក់រួមវិភាគទានសម្រាប់ការគ្រប់គ្រងទីជម្រាល ដែលផ្តល់ជាប្រយោជន៍ សម្រាប់ការផលិតអគ្គិសនី។

២. ឃុំទាំងអស់ដែលនៅជាប់អាងស្តុកទឹក។

៣. ប្រជាពលរដ្ឋដែលបំលាស់ទី និង សហគមន៍ជាម្ចាស់មូលដ្ឋាននៅគ្រប់ឃុំដែលពាក់ព័ន្ធ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពស្តីពីការតាំងទីលំនៅថ្មី (RAP)។

៤. ឃុំនីមួយៗដែលស្ថិតនៅក្បែរទំនប់ ទីតាំងផ្លូវរាងរបស់ទន្លេ និងក្បែររោងចក្រអគ្គិសនី។

៥. ឃុំដែលរងផលប៉ះពាល់ស្ថិតនៅតាមដងទន្លេភាគខាងក្រោមនៃរោងចក្រអគ្គិសនី។

- កម្រិតចម្ងាយនៃភាគខាងក្រោម (ការកាត់ផ្តាច់)

ដែលបានកំណត់ដោយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផ្អែកលើកម្រិតទំហំនៃលទ្ធភាពទទួលបានធនធានដែលរងប៉ះពាល់។

ប្រអប់អត្ថបទ៨.៦ យន្តការនៃការចូលរួម- ទិដ្ឋភាពគន្លឹះ

- ខាងក្រោមនេះ គឺជាទិដ្ឋភាពដ៏សំខាន់សម្រាប់ការពិចារណា ៖

- ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ (របៀបកំណត់អត្តសញ្ញាណនិងធ្វើឲ្យជ្រួតជ្រាបដល់ប្រជា-ពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយ ឬ មានចំណាប់អារម្មណ៍នៅក្នុងលទ្ធផលនៃការសម្រេចចិត្តមួយ)។
- លទ្ធភាពទទួលបានព័ត៌មាន (របៀបដើម្បីផ្តល់លទ្ធភាពទទួលបានព័ត៌មានដល់ភាគីពាក់ព័ន្ធ ដែលបានកំណត់)។
- ការផ្តល់ព័ត៌មានពីការចូលរួមនៅក្នុងការធ្វើការសម្រេចចិត្ត (របៀបដើម្បីជួយសម្រួលដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត)។

- ការចូលរួមរបស់អ្នកពាក់ព័ន្ធត្រូវបន្តឲ្យដំណើរការតាមរយៈការកំណត់អត្តសញ្ញាណ និងការវិភាគលើអ្នកពាក់ព័ន្ធនិងការបង្កើតផែនការចូលរួមតាមការចង់បាន។
- បច្ចេកទេសនិងឧបករណ៍មួយចំនួន រួមមាន:
  - ខិត្តប័ណ្ណផ្សព្វផ្សាយ ផ្ទាំងរូបភាពបង្ហាញ ការតាំងបង្ហាញ និងគេហទំព័រ។
  - ការស្ទង់មតិដើម្បីប្រមូលព័ត៌មាននិងទស្សនៈយោបល់។
  - បច្ចេកវិទ្យាជំនួយដោយកុំព្យូទ័រ។
  - គណៈកម្មការនិងក្រុមការងារ។
  - មន្ត្រីពិគ្រោះយោបល់ដែលមានការប្តេជ្ញាចិត្តខ្ពស់។
  - មជ្ឈមណ្ឌលធនធានក្នុងមូលដ្ឋាន។
  - លទ្ធភាពដើម្បីបើកឱកាសឲ្យអ្នកចូលរួមប្រើប្រាស់ភាសាមូលដ្ឋានសមស្រប។

ប្រធានបទពិភាក្សា	តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក តើអ្វីខ្លះជាយន្តការនៃចូលរួមរបស់ អ្នកពាក់ព័ន្ធដែលមានប្រសិទ្ធិភាពបំផុតនៅក្នុងប្រទេសរបស់អ្នក ? លើសពីនេះទៀត ចូរ

	បរិយាលម្អិតពីយន្តការណាមួយគួរតែត្រូវបានជៀសវាងនិងហេតុអ្វី។ …….. តើមានមធ្យោបាយណា ដែលអាចផ្តល់អំណាចដល់ភាគីពាក់ព័ន្ធអាចចូលរួមដោយមានប្រសិទ្ធភាពនៅក្នុងដំណើរការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ? …….. ចូរពិភាក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់បុគ្គលិកទំនាក់ទំនងគម្រោងដែលមានការលះបង់ និងបង្កើតការិយាល័យទំនាក់ទំនងគម្រោងនៅក្នុងតំបន់គម្រោងដែលរងផលប៉ះពាល់។
លំហាត់	• ចូររៀបចំក្របខណ្ឌផែនការការចូលរួមរបស់អ្នកពាក់ព័ន្ធ សម្រាប់អនុវត្តលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលមានទំហំធំមួយនៅក្នុងប្រទេសរបស់អ្នក។ • …….. • ចូរធ្វើឲ្យក្របខណ្ឌដែលបានបង្កើតឡើង អាចមានប្រជាប្រិយជាមួយនឹងយន្តការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលសមស្របបំផុតដែលអាចរកបាន ដើម្បីចូលរួមយ៉ាងមានប្រសិទ្ធិភាពជាមួយប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីគម្រោងក្នុងបរិបទនៃប្រទេសរបស់អ្នក។

៨.៣ ក្របខ័ណ្ឌស្ថាប័ន

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺផ្តល់នូវសារតាសំខាន់ៗស្តីពីបទដ្ឋាន ជានិយាមនានា ដែលគ្របដណ្តប់លើការចូលរួមរបស់ភាគីពាក់ព័ន្ធ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីបទដ្ឋានជានិយាម ដែលមានស្រាប់ និង ពីអ្វីដែលទាមទារឲ្យមានសម្រាប់គោលការណ៍អនុវត្តល្អលើការចូលរួមរបស់ភាគីពាក់ព័ន្ធ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តី-សម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ (ផ្នែកទី៣: ការចូលរួមរបស់ភាគីពាក់ព័ន្ធ) www.unep.org/dams

ការវិភាគនេះផ្តោតទៅលើក្របខ័ណ្ឌស្ថាប័ន រួមទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិដែលអាចអនុវត្តបានចំពោះ គម្រោងទំនប់ និងគម្រោងវារីអគ្គិសនី។ ទាំងនេះនឹងត្រូវបកស្រាយលម្អិត នៅក្នុងក្របខ័ណ្ឌដាច់ដោយឡែកនៃប្រទេស។

៨.៣.១ អន្តរជាតិ

សារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើផែនការធនធានទឹកអន្តរជាតិ បានកើនឡើងពីទសវត្សឆ្នាំ១៩៧០ និងបន្តរហូតដល់ទសវត្សឆ្នាំ១៩៩០ ហើយនៅក្នុងឆ្នាំ២០០០ និងលើសពីនេះ។

" ក្របខ័ណ្ឌអន្តរជាតិ " មួយដែលគួរឱ្យកត់សម្គាល់រួមនឹងមូលដ្ឋានច្បាប់សំដៅដល់ការចូលរួម គឺអនុសញ្ញា Aarhus និង ក្របខ័ណ្ឌសេចក្តីបង្គាប់ របស់សហភាពអឺរ៉ុបស្តីពីទឹកនិងកម្មវិធីសាកល្បង សម្រាប់ជំណើរការនៃការចូលរួម។ ការងាររបស់គណៈកម្មការពិភពលោកទទួលបន្ទុកទំបន់វារីអគ្គិសនី (WCD) និងកម្មវិធីអភិវឌ្ឍន៍ទំនប់របស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ក៏បានផ្តល់នូវក្របខ័ណ្ឌដ៏មានប្រយោជន៍ផងដែរ។

ស្ថាប័នអភិវឌ្ឍនិងផ្តល់មូលនិធិអន្តរជាតិ ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក ក្រុមហ៊ុនសាជីវកម្មវិនិយោគឯកជនក្រៅប្រទេស ធនាគារអភិវឌ្ឍន៍អាហ្វ្រិក ធនាគារអឺរ៉ុបសម្រាប់ការកសាងឡើងវិញនិងការអភិវឌ្ឍន៍ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា និងសមាគមវារីអគ្គិសនីអន្តរជាតិ បានបញ្ចូលនូវការចូលរួមរបស់អ្នកពាក់ព័ន្ធទៅក្នុងរៀបចំគោលនយោបាយ និងនីតិវិធីក្នុងការធ្វើផែនការ សម្រាប់ការវាយតម្លៃលើផលប៉ះពាល់ ការគ្រប់គ្រងតំបន់ទីជម្រាល លំហូរទឹក ទន្លេធនធានទឹក បរិស្ថាននិងការផ្គត់ផ្គង់ថាមពល។ ក្នុងនោះមួយចំនួនរួមមានគោលនយោបាយស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋងាយរងគ្រោះ ឬរបស់ជនជាតិដើមភាគតិច។

ក្នុងករណីជាច្រើន ការផ្តល់មូលនិធិគឺពឹងអាស្រ័យលើការអនុវត្តរបស់ក្រុមហ៊ុនលើគោលការណ៍នៃការចូលរួមដែលមានស្រាប់ ដែលមានឥទ្ធិពលលើរបៀបនៃការចូលរួម ដែលត្រូវបានអនុវត្តនៅក្នុងប្រទេសមួយចំនួន ជាពិសេសនៅបណ្តាប្រទេសដែលមានការប្តេជ្ញាចិត្តតិចតួច ចំពោះការពិគ្រោះយោបល់ក្នុងពេលកន្លងមក (ឧ.គម្រោង Nam Theun 2)។

៨.៣.២ ជាតិ

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាសមាសភាគដែលត្រូវបានទទួលយកកាន់តែខ្លាំងឡើងនៃដំណើរការរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ខាងវិស័យសេដ្ឋកិច្ច។ ទោះជាយ៉ាងណា សូម្បីតែនៅក្នុងប្រទេសអភិវឌ្ឍន៍ខាងវិស័យសេដ្ឋកិច្ចទាំងនេះក៏ដោយ មាននិយមន័យ ផ្លូវច្បាប់តិចតួចណាស់ចំពោះអត្ថន័យនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និង គ្មានស្តង់ដារណាដែលបានកំណត់ពីរបៀបនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលត្រូវធ្វើឲ្យសម្រេចបាន ឬត្រូវបានវាស់វែងឡើយ។

នៅក្នុងប្រទេសកាណាដា ច្បាប់ស្តីពីការវាយតម្លៃបរិស្ថាន គឺច្បាប់សហព័ន្ធមួយដែលទាក់ទងនឹងការអនុម័តគម្រោងដែលមានសក្តានុពលប៉ះពាល់ដល់បរិស្ថាន ។ ច្បាប់នេះរួមបញ្ចូលនៅក្នុងនិយមន័យរបស់វា " ភាគីដែលចាប់អារម្មណ៍ " មានន័យថា " បុគ្គលឬស្ថាប័នណាមួយដែលមានចំណាប់អារម្មណ៍លើលទ្ធផលនៃការវាយតម្លៃបរិស្ថាននេះ សម្រាប់គោលបំណងដែលមិនមែនឥតបានការ ក៏មិនមែននាំឲ្យខាតបង់ដែរ " ។ ច្បាប់នេះបានកំណត់និយមន័យអ្នកស្នើគម្រោងថាជា " បុគ្គល ស្ថាប័ន អាជ្ញាធរសហព័ន្ធ ឬរដ្ឋាភិបាលដែលជាអ្នកស្នើគម្រោង " ។ ច្បាប់នេះមិនមានការផ្តល់និយមន័យនៃពាក្យថា " សាធារណជន " ឬ " អ្នកពាក់ព័ន្ធ " ទេ។ វាតម្រូវឱ្យមាន " ការពិគ្រោះយោបល់ជាសាធារណៈ " " ដែលជាកន្លែងដែល..... អាជ្ញាធរមានសមត្ថភាពត្រូវធានាឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ ដោយការគោរពតាមវិសាលភាពនៃគម្រោងដែលបានស្នើឡើង សម្រាប់គោលបំណងវាយតម្លៃបរិស្ថាន កត្តាដែលបានស្នើឡើងដើម្បីពិចារណានៅក្នុងការវាយតម្លៃរបស់ខ្លួន វិសាលភាពដែលបានស្នើឡើងនៃកត្តាទាំងនោះ និង លទ្ធភាពនៃការសិក្សាទូលំទូលាយក្នុងការដោះស្រាយបញ្ហានានាទាក់ទងនឹងគម្រោង "។ មិនមានសេចក្តីយោងណាបន្ថែមទៀតនៅក្នុងច្បាប់នេះ ចំពោះការទាមទារឲ្យមានដំណើរការនៃការពិគ្រោះយោបល់ជាសាធារណៈ ឬ ចំពោះលទ្ធផលពីការពិគ្រោះយោបល់ជាសាធារណៈណាមួយនោះទេ។ នេះគឺជាតួយ៉ាងនៃចំណែកជាច្រើននៃច្បាប់បរិស្ថាននៅទូទាំងពិភពលោក ហើយវាបានជម្រុញឲ្យអ្នកស្នើគម្រោងត្រូវអនុវត្ត "ការពិគ្រោះយោបល់" ជាអប្បបរមា តាមដែលអាចធ្វើទៅបាន ដោយជាធម្មតាពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មអំពីគម្រោង ការតាំងពិពណ៌ជាសាធារណៈលើរបាយការណ៍វាយតម្លៃបរិស្ថាន និងការទទួលយល់ព្រមលើការស្នើសុំ។

នៅសហរដ្ឋអាមេរិក ការចូលរួមពីភាគីដែលពាក់ព័ន្ធត្រូវបានរៀបចំប្រមូលចងក្រងជាច្បាប់ផែនការបរិស្ថាន ឧទាហរណ៍ដូចជាច្បាប់ស្តីពីនីតិវិធីបែបរដ្ឋាបាល និងច្បាប់គោលនយោបាយបរិស្ថានជាតិ។

នៅក្នុងប្រទេសអូស្ត្រាលី ការធ្វើផែនការនិងការបង្កើតច្បាប់វាយតម្លៃនៅក្នុងប្រទេសភាគច្រើន តម្រូវឱ្យអ្នកស្នើគម្រោងធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ រួមទាំងរដ្ឋាភិបាលនិងសហគមន៍មូលដ្ឋានហើយជាធម្មតារួមបញ្ចូលទាំងរយៈពេលតិចបំផុត សម្រាប់ការពិនិត្យឯកសារឡើងវិញជាសាធារណៈផង ។ ទោះជាយ៉ាងណាជាថ្មីម្តងទៀត មិនមាននិយមន័យផ្តែកច្បាប់លើការពិគ្រោះយោបល់ ដែលមានចែងនៅក្នុងច្បាប់ទាំងច្បាប់សហព័ន្ធ ឬច្បាប់ដ្ឋឬបទដ្ឋានណាមួយដែលត្រូវឆ្លើយតបចំពោះដំណើរការឬលទ្ធផលនោះទេ។

ប្រទេសណូវែលសេឡង់ គឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួន ដែលមាននិយមន័យផ្លូវច្បាប់ទាក់ទងនឹង " ការពិគ្រោះយោបល់ជាសាធារណៈ " ។ និយមន័យនេះបានមកពីករណីដែលបានលើកឡើងដោយសហគមន៍មូលដ្ឋានកាលពីឆ្នាំ១៩៩២ ប្រឆាំងនឹងគម្រោងសាងសង់ព្រលានយន្តហោះ Wellington ។ សំខាន់ទៀតនោះ គឺអ្នកស្នើគម្រោងដែលបានប្រឹក្សាយោបល់ជាសាធារណៈ អំពីសំណើណាមួយត្រូវតែធ្វើដូច្នេះ " ដោយមានគំនិតបើកចំហ " និង ត្រូវបានត្រៀមរៀបចំផ្លាស់ប្តូរសំណើរនេះជាលទ្ធផលបានពីគំនិតយោបល់របស់សាធារណជន ។ ការតាក់តែងច្បាប់ថ្មីៗនេះនៅក្នុងប្រទេសណូវែលសេឡង់ដែលតម្រូវឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ រួមមានច្បាប់ស្តីពីការគ្រប់គ្រងធនធានឆ្នាំ១៩៩១ ច្បាប់ស្តីពីរដ្ឋាភិបាលមូលដ្ឋាន ឆ្នាំ២០០២ និងច្បាប់ស្តីពីការគ្រប់គ្រងការដឹកជញ្ជូនដីធ្លីឆ្នាំ២០០៤។ ចំណែកច្បាប់ស្តីពីការគ្រប់គ្រងធនធាន គឺជាច្បាប់មួយដែលអនុវត្តចំពោះគម្រោងទំនប់វារីអគ្គិសនីនានានៅប្រទេសណូវែលសេឡង់។

នៅអាហ្វ្រិកខាងត្បូង ក៏បានបង្កើតយ៉ាងល្អផងដែរនូវច្បាប់ដែលទាក់ទងនឹងការចូលរួមជាសាធារណៈដែលបង្កើតបានជាមូលដ្ឋានសម្រាប់គាំទ្រដល់ច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូង ឆ្នាំ ១៩៩៦ ដែលនៅក្នុងនោះមានចែងអំពីសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិ ។ ច្បាប់រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេសអាហ្វ្រិកខាងត្បូង ហើយវាផ្តល់នូវក្របខ័ណ្ឌមួយក្នុងរង្វង់ច្បាប់ទាំងអស់ផ្សេងទៀតនៃប្រទេសនេះ រួមទាំងច្បាប់ស្តីពីបរិស្ថាន ដែលត្រូវបានបង្កើតនិងបានបកស្រាយរួចមកហើយ។

សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិ គឺជាមូលដ្ឋានសម្រាប់រដ្ឋធម្មនុញ្ញ ហើយនៅក្នុងជំពូកទី២៤ ច្បាប់បានចែងថា " (ក) មនុស្សម្នាក់ៗមានសិទ្ធិទទួលបានបរិស្ថានដែលមិនមានគ្រោះថ្នាក់ដល់សុខភាពឬសុខុមាលភាពរបស់ខ្លួន និង(ខ) មនុស្សម្នាក់ៗមានសិទ្ធិទទួលបាននូវការការពារបរិស្ថាន ដើម្បីផលប្រយោជន៍របស់មនុស្សជំនាន់បច្ចុប្បន្ននិងទៅអនាគត តាមរយៈច្បាប់និងវិធានការសមហេតុផល ដែល (i) ការពារការបំពុលបរិស្ថាននិងការសិករិចរិលនៃប្រព័ន្ធអេកូឡូស៊ី (ii) លើកកម្ពស់ការអភិរក្ស និង (iii) ធានាដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពផ្តែកប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់ធនធានធម្មជាតិ ដោយការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដែលស្របទៅតាមច្បាប់ " ។

មានការអះអាងថាច្បាប់ស្តីការគ្រប់គ្រងបរិស្ថានជាតិ (NEMA) ឆ្នាំ១៩៩៨ គឺជាច្បាប់ដែលសំខាន់បំផុតទីពីរ ដោយសារច្បាប់នេះ គឺជា "គោលការណ៍ច្បាប់ដែលមានមូលដ្ឋាន" ដែលផ្តល់ដល់អាហ្វ្រិកខាងត្បូង

នូវច្បាប់ទាក់ទងនឹងបរិស្ថាន ។ ច្បាប់នេះមានគោលដៅចម្បង ដើម្បីផ្តល់នូវអភិបាលកិច្ចបរិស្ថានដោយមានកិច្ចសហប្រត្តិបត្តិការដោយការបង្កើតជាគោលការណ៍ សម្រាប់ការធ្វើសេចក្តីសម្រេចលើបញ្ហាប៉ះពាល់ដល់បរិស្ថាន ឬ ប៉ះពាល់ស្តាប័នដែលនឹងលើកកម្ពស់អភិបាលកិច្ចដោយមានកិច្ចសហប្រតិបត្តិការ និងនីតិវិធីនានាសម្រាប់សម្របសម្រួលដល់មុខងារបរិស្ថានដែលបានអនុវត្តដោយស្តាប័នរដ្ឋ។

ច្បាប់នេះបានផ្តល់នូវសិទ្ធិទទួលបានបរិស្ថានមួយ ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋអាហ្រ្វិកខាងត្បូង ការបែងចែកធនធានធម្មជាតិប្រកបដោយសមធម៌ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការពារបរិស្ថាន និងការបង្កើតក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន ។ ច្បាប់ស្តីការគ្រប់គ្រងបរិស្ថានជាតិ (NEMA) រួមមានបណ្តុំគោលការណ៍ដែលទាក់ទងនឹង ការគ្រប់គ្រងបរិស្ថាន និងការប្រឆាំងនឹងតម្រូវការលើផែនការ និងចំណាត់ការលើការគ្រប់គ្រងបរិស្ថានដែលបានអនុវត្តកន្លងមក ។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តម្រូវឱ្យមានការពិចារណាលើកត្តាពាក់ព័ន្ធទាំងអស់ (កត្តាទាំងឡាយណាដែលមានការរួមបញ្ចូលការចូលរួមរបស់អ្នកពាក់ព័ន្ធ) រួមមានដូចខាងក្រោម៖

- ក្នុងការគ្រប់គ្រងបរិស្ថាន គេត្រូវតែលើកយកពីតម្រូវការនានាមកដាក់នៅចំពោះមុខក្តីកង្វល់របស់ប្រជាពលរដ្ឋ និងត្រូវបម្រើផលប្រយោជន៍ដល់រាងកាយ ចិត្តសាស្ត្រ អភិវឌ្ឍ វប្បធម៌ និងសង្គម របស់ប្រជាពលរដ្ឋទាំងនោះប្រកបដោយសមធម៌។
- ត្រូវលើកកម្ពស់ការចូលរួមរបស់ភាគីដែលចាប់អារម្មណ៍និងដែលទទួលរងផលប៉ះពាល់នៅក្នុងអភិបាលកិច្ចបរិស្ថាន ហើយប្រជាពលរដ្ឋទាំងអស់ត្រូវតែមានឱកាសដើម្បីអភិវឌ្ឍការយល់ដឹងជំនាញ និងសមត្ថភាពជាចាំបាច់សម្រាប់សម្រេចបាននូវការចូលរួម ប្រកបដោយសមធម៌ និងដោយមានប្រសិទ្ធិភាព និងធានាឲ្យមានការចូលរួមពីសំណាក់ជនដែលងាយរងគ្រោះ និងជនដែលជួបការលំបាកខ្លាំង។
- រាល់ការសម្រេចចិត្ត ត្រូវតែយោលទៅលើផលប្រយោជន៍ តម្រូវការ និងគុណតម្លៃនៃភាគីដែលចាប់អារម្មណ៍ និង ដែលទទួលរងផលប៉ះពាល់ ហើយនេះរួមបញ្ចូលទាំងការទទួលស្គាល់នូវរាល់ទម្រង់ទាំងអស់នៃចំណេះដឹង រួមទាំងចំណេះដឹងផ្នែកប្រពៃណី និងចំណេះដឹងធម្មតា។
- ត្រូវលើកកម្ពស់សុខមាលភាព និង ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ តាមរយៈការអប់រំបរិស្ថាន ការផ្សព្វផ្សាយការយល់ដឹងពីបរិស្ថាន ការចែករំលែកចំណេះដឹង និងបទពិសោធ និងមធ្យោបាយសមស្របផ្សេងទៀត ។

- ការសម្រេចចិត្តត្រូវតែធ្វើឡើងជាលក្ខណៈបើកចំហ និង ប្រកបដោយតម្លាភាព ហើយត្រូវតែផ្តល់លទ្ធភាពទទួលបានព័ត៌មាន ស្របតាមច្បាប់ដែលបានកំណត់។

- ត្រូវទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់ស្ត្រីនិងយុវជននៅក្នុងការគ្រប់គ្រងបរិស្ថាននិងការអភិវឌ្ឍ និង ត្រូវលើកកម្ពស់ឲ្យពួកគេបានចូលរួមពេញលេញនៅ ក្នុងការគ្រប់គ្រងបរិស្ថាននិងការអភិវឌ្ឍនេះ។

ការធ្វើឲ្យសម្រេចបានពិតប្រាកដនូវគោលការណ៍ទាំងឡាយ គឺអាស្រ័យលើមូលដ្ឋាន ដូចមាននៅខាងក្រោម ដែលត្រូវគាំទ្រដោយច្បាប់ដាច់ដោយឡែក ក្នុងនោះច្បាប់សំខាន់បំផុតមានចំនួនពីរ ដែលជាការចូលរួមលើកកម្ពស់ដល់ច្បាប់រដ្ឋបាលយុត្តិធម៌ ឆ្នាំ២០០០ និង ការលើកកម្ពស់ដល់ច្បាប់ស្តីពីការទទួលបានព័ត៌មានឆ្នាំ២០០០ ៖

- ការទទួលបានព័ត៌មាន។

ជំពូកទី៣២ នៃច្បាប់រដ្ឋធម្មនុញ្ញដែលចែងថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានណាមួយដែលផ្តល់ដោយរដ្ឋ ឬនីតិបុគ្គលណាមួយផ្សេងទៀត ហើយដែលទាមទារឲ្យមានការអនុវត្ត ឬការការពារដល់សិទ្ធិណាមួយ។

- ចំណាត់ការរដ្ឋបាលដោយយុត្តិធម៌។

ជំពូកទី៣៣ នៃច្បាប់រដ្ឋធម្មនុញ្ញដែលចែងអំពីសិទ្ធិទទួលបានការដោះស្រាយតាមផ្លូវច្បាប់ដោយមានហេតុផល និងតាមបែបបទជានីតិវិធីរដ្ឋបាលដោយយុត្តិធម៌។

- ការពង្រឹងការអនុវត្តលើសិទ្ធិ និងការត្រួតពិនិត្យផ្នែករដ្ឋបាល។

ជំពូកទី៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញធានាថា សិទ្ធិក្នុងការដោះស្រាយតាមប្រព័ន្ធតុលាការ និងសិទ្ធិស្វែងរកជំនួយផ្នែកច្បាប់ ក្នុងករណីដែលសិទ្ធិណាមួយ ដែលត្រូវបានការពារនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិត្រូវបាន រំលោភបំពាន ឬត្រូវបានគម្រាមកំហែង។

រដ្ឋាភិបាលអាហ្វ្រិកខាងត្បូងធានាថា ច្បាប់របស់ប្រទេសខ្លួនត្រូវបានអនុវត្តដោយវិធី នៃបទប្បញ្ញត្តិដែលចែងពីអ្វីដែលត្រូវតែធ្វើ របៀបនិងអ្វីដែលត្រូវតែធ្វើឲ្យសម្រេចបាន។ ជាការគាំទ្រដល់ចំនុចនេះ នាយកដ្ឋាននានាបង្កើតជាគោលការណ៍ណែនាំផ្សេងៗ ដូចជានាយកដ្ឋានកិច្ចការបរិស្ថាន គោលការណ៍ទី៥ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA): ដំណើរការចូលរួមជាសាធារណៈ (ឆ្នាំ២០០៦)។

ខណៈដែលសេចក្តីលម្អិតនៃការចូលរួម ជាធម្មតាមិនបានសរសេរលម្អិតនៅក្នុងនីតិកម្ម បណ្តាប្រទេសជាច្រើននៅអាហ្វ្រិកខាងត្បូងសុទ្ធតែមានគោលការណ៍ណែនាំទូលំទូលាយដែលបានចែងពីរបៀបនៃការរៀបចំឲ្យមានការចូលរួម។

នៅក្នុងអាងទន្លេមេគង្គ ការសម្តែងមតិផ្សេងៗត្រូវបានលើកឡើងរួមជាមួយនឹងកម្រិតនៃសកម្មភាពកើនឡើងជាច្រើនទសវត្សរ៍កន្លងមកអំពីលក្ខណៈក្រោមលទ្ធិប្រជាធិបតេយ្យ និង ដែលមិនអាចពន្យល់បកស្រាយបាននៃការគ្រប់គ្រង ធនធានទឹកអាងទន្លេនេះ។ លើសពីនេះទៀត ការចូលរួមត្រូវបានលើកកម្ពស់បាន

យ៉ាងច្រើននៅក្នុងក្របខ័ណ្ឌរចនាសម្ព័ន្ធរបស់គណៈកម្មការទន្លេមេគង្គផ្ទាល់ និងប្រទេសជាសមាជិក ហើយមិនត្រូវបានបន្តពង្រីកដល់ការចូលរួមពាក់ព័ន្ធដ៏មានអត្ថន័យជាមួយអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗ ឬសហគមន៍មូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ កម្រិតនៃការចូលរួមរបស់សង្គមស៊ីវិល និងសហគមន៍ត្រូវប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ នៅក្នុងប្រទេសដែលស្ថិតនៅជាប់ដងទន្លេមេគង្គ ដែលក្នុងនោះប្រទេសថៃមានក្រុមការងារ និង បណ្តាញគាំទ្រដែលសកម្ម និង មានប្រសិទ្ធភាពបំផុត ចំណែកនៅប្រទេសឡាវ និងប្រទេសវៀតណាម អង្គការសង្គមស៊ីវិលមានឱកាសតិចតួចណាស់សម្រាប់ការចូលរួមគាំទ្រ។ នៅក្នុងប្រទេសជាសមាជិកទាំងបួន មានការព្យាយាមពុះពារប្រឆាំងចំពោះគម្រោងអភិវឌ្ឍន៍ធំៗទាក់ទងនឹងទឹក (ឧ. ភាពចម្រូងចម្រាសលើទំនប់វារីអគ្គិសនីប៉ាកម៉ុននៅក្នុងប្រទេសថៃ លើទំនប់សេកុង សេសាន និងស្រែពកនៅក្នុងប្រទេសកម្ពុជា ទំនប់ស៊ុនឡានៅក្នុងប្រទេសវៀតណាម និងទំនប់ណាំធឿន២នៅក្នុង ប្រទេសឡាវ)។ ការពុះពារប្រឆាំងទាំងនេះ មានគោលដៅបង្កើនដំណើរការចូលរួមកាន់តែច្រើនជាមួយនឹងការជម្រុញបន្ថែម ដល់អង្គការសង្គមស៊ីវិលទាំងនោះ ពីភ្នាក់ងារផ្តល់ជំនួយ ឬម្ចាស់ជំនួយ (Dore and Kate 2009 [យោង២៧])។

ការអនុម័តជាចុងក្រោយនៃ PNCP ក៏បានទាមទារផងដែរដល់បណ្តាប្រទេសស្ថិតនៅជាប់ដងទន្លេមេគង្គឲ្យចូលរួមពិភាក្សា និង ផ្តល់ព័ត៌មានអំពីគម្រោងអភិវឌ្ឍដែលបានស្នើឡើង និងអំពីផលប៉ះពាល់ដែលអាចកើតមាន ព្រមទាំងដើម្បីស្វែងរកកិច្ចព្រមព្រៀងគ្នា មុនឈានដល់ការសាងសង់គម្រោងនានាទាក់ទងនឹងទឹកទន្លេមេគង្គភាគខាងលើ និងនៅតាមដៃទន្លេមេគង្គ ។ លើសពីនេះទៀត នៅក្រោមក្របខ័ណ្ឌគតិយុត្ត ឬគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏បានទាមទារឱ្យមានការចូលរួមជាសាធារណៈផងដែរ។

[យោង២៧] Dore and Kate (2009) De-marginalizing the Mekong River Commission, In Molle, F., Tira.F., and Mira.K (Eds.) Contested Waterscapes in the Mekong Region: វារីអគ្គិសនី ការចិញ្ចឹមជីវិត និងអភិបាលកិច្ច។ Earthscan, UK.

៨.៣.៣ ស្ថាប័នក្រុមហ៊ុន

កត្តាសំខាន់សម្រាប់ជម្រុញ និងអនុវត្តលើការពិគ្រោះយោបល់មានលក្ខណៈល្អប្រសើរ គឺគោលនយោបាយរបស់ភ្នាក់ងារ ឬ ក្រុមហ៊ុនជាក់លាក់ដែលបានចូលរួមនៅក្នុងការសាងសង់ទំនប់ និងគម្រោងវារីអគ្គិសនីនានា។ នៅត្រង់ចំណុចនេះ សំដៅដល់ក្រុមហ៊ុនវារីអគ្គិសនីទីក្រុងកេបិច Hydro Quebec ក្រុមហ៊ុន BC Hydro ក្រុមហ៊ុនSEQ Water អង្គការGIZ TVA និងក្រហ៊ុន Meridian Energy។ គោលការណ៍អនុវត្តល្អស្តីពីការចូលរួមនឹងមិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការប្តេជ្ញាចិត្តរបស់ស្ថាប័នទាំងនេះ ក្នុងការកសាងទំនាក់ទំនងល្អជាមួយសហគមន៍ទេនោះ។ ស្ថាប័នទាំងនេះ បានរកឃើញពីបទពិសោធថា ការចូលរួមជាសាធារណៈអាចផ្តល់នូវអត្ថប្រយោជន៍រយៈពេលវែងសម្រាប់ស្ថាប័នរបស់ខ្លួន។ នៅក្នុងករណីជាច្រើន ស្ថាប័នទាំងនេះ បានបង្កើតគោលការណ៍រៀងៗខ្លួនសម្រាប់ការចូលរួម។

គោលការណ៍អេក្វាទ័រ គឺផ្អែកលើគំរូស្តង់ដារអនុវត្តរបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC។ ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០១២ គំរូស្តង់ដារអនុវត្តរបស់ IFC ដែលបានពិនិត្យកែប្រែរួច ក៏ត្រូវបានចូលជាធរមានសម្រាប់សមាជិកសមាគមគោលការណ៍អេក្វាទ័រ។

គោលការណ៍អេក្វាទ័ (EPs) គឺជាក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានសម្រាប់ការកំណត់ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យបរិស្ថាននិងសង្គមនៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុរបស់គម្រោង ។ ហិរញ្ញវត្ថុគម្រោង ជាញឹកញាប់ត្រូវបានគេប្រើដើម្បីផ្តល់ជាទុនសម្រាប់ការអភិវឌ្ឍ និង ការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងឧស្សាហកម្មធំៗ។ គោលការណ៍អេក្វាទ័ ត្រូវបានអនុម័តដោយស្ថាប័នហិរញ្ញវត្ថុចំនួន ៧៦ នៅក្នុងបណ្តាប្រទេសចំនួន៣២ និង ត្រូវបានអនុវត្តដោយចំណាយដើមទុនសរុបរបស់គម្រោងលើសពី ១០លានដុល្លារសហរដ្ឋអាមេរិក ។ គោលដៅចម្បងនៃគោលការណ៍អេក្វាទ័ គឺការផ្តល់គំរូបទដ្ឋានអប្បបរមាដោយសារការយកចិត្តទុកដាក់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត ប្រកបដោយការទទួលខុសត្រូវទាក់ទងនឹងហានិភ័យ។

គោលការណ៍អេក្វាទ័ ផ្អែកលើគំរូស្តង់ដារអនុវត្តរបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីនិរន្តរភាពផ្នែកបរិស្ថាន និងសង្គម និងក្រុមធនាគារពិភពលោកបរិស្ថានសុខភាពនិងគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព (គោលការណ៍ណែនាំ EHS)។ នៅក្នុងក្របខ័ណ្ឌនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គំរូស្តង់ដារអនុវត្តពាក់ព័ន្ធ មានដូចខាងក្រោម ៖

- គំរូស្តង់ដារអនុវត្តរបស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីនិរន្តរភាពផ្នែកបរិស្ថាន និងសង្គម (ចូលជាធរមាននៅក្នុងខែមករា ឆ្នាំ២០១២)។

- គំរូស្តង់ដារអនុវត្តទី១របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យនិងផលប៉ះពាល់លើសង្គមនិងបរិស្ថាន (២០១២)។

- គំរូស្តង់ដារអនុវត្តទី២របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ លក្ខខណ្ឌពលកម្ម និងការងារ (២០១២)។
- គំរូស្តង់ដារអនុវត្តទី៣របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ ប្រសិទ្ធភាពនៃធនធាន និងការបង្ការការបំពុលបរិស្ថាន (២០១២)។
- គំរូស្តង់ដារអនុវត្តទី៤របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ សុខាមាលភាព សុវត្ថិភាព និងសន្តិសុខរបស់សហគមន៍ (២០១២)។
- គំរូស្តង់ដារអនុវត្តទី៥របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ ការផ្តល់សម្បទានដីធ្លី និងការតាំងទីលំនៅថ្មីមិនមែនជាការស្ម័គ្រចិត្ត (២០១២)។
- គំរូស្តង់ដារអនុវត្តទី៦ របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដែលមានជីវិត ប្រកបដោយនិរន្តរភាព (២០១២)។
- គំរូស្តង់ដារអនុវត្តទី៧របស់ក្រុមហ៊ុនសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ៖ ប្រជាពលរដ្ឋជនជាតិភាគតិច (២០១២)។

ស្ថាប័នហិរញ្ញវត្ថុគោលការណ៍អេក្វាទ័ (EPFIs) ប្តេជ្ញាមិនផ្តល់ប្រាក់កម្ចីដល់គម្រោងទាំងឡាយណាដែលអ្នកខ្ចីនឹងមិនឬមិនអាចអនុវត្តតាមគោលនយោបាយនិងនីតិវិធីសង្គមនិងបរិស្ថានរៀងៗខ្លួន។

ជាសង្ខេប ក្របខ័ណ្ឌច្បាប់ឬបទប្បញ្ញត្តិជាមូលដ្ឋាន បានចែងជាទូទៅអំពីការពិគ្រោះយោបល់ក្នុងកម្រិតអប្បបរមា ។ នៅក្នុងករណីទាំងអស់នៃការអនុវត្ត ការចូលរួមបានប្រព្រឹត្តិទៅបានល្អហួសពីក្របខ័ណ្ឌទាំងនេះទៅទៀត។

ប្រអប់អត្ថបទ៨.៧ បទដ្ឋាននានាសម្រាប់ស្ថាប័ន-ទិដ្ឋភាពគន្លឹះ

- សារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើផែនការធនធានទឹកអន្តរជាតិ គឺមានការកើនឡើងជាលំដាប់។
- "បទដ្ឋានអន្តរជាតិ" មួយគួរឱ្យកត់សម្គាល់ រួមជាមួយនឹងមូលដ្ឋានច្បាប់ដែលសំដៅដល់ការចូលរួម គឺអនុសញ្ញា Aarhus និង ក្របខ័ណ្ឌទិសដៅស្តីពីទឹកនៃសហភាពអឺរ៉ុប។ ការងាររបស់ WCD និង កម្មវិធីទំនប់និងការអភិវឌ្ឍន៍របស់UNEP ក៏បានផ្តល់នូវបទដ្ឋានមានប្រយោជន៍ជាច្រើនផងដែរ។
- ស្ថាប័នផ្តល់មូលនិធិ និង ស្ថាប័នអភិវឌ្ឍអន្តរជាតិបានដាក់បញ្ចូលការចូលរួមរបស់ភាគីពាក់ព័ន្ធទៅក្នុងការធ្វើគោលនយោបាយ និតិវិធីក្នុងការធ្វើផែនការសម្រាប់ការវាយតម្លៃផលប៉ះពាល់ ការគ្រប់គ្រងតំបន់ទីជម្រាល លំហូរទឹកទន្លេ ធនធានទឹក បរិស្ថាន និងការផ្គត់ផ្គង់ថាមពល។

- ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ ក៏ទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនឡើង ប៉ុន្តែជាញឹកញាប់ ការតាក់តែងច្បាប់ និងបទប្បញ្ញត្តិនានាត្រូវបានរៀបចំឡើងមិនបានល្អឡើយ។
- កត្តាសំខាន់សម្រាប់ជម្រុញនិងអនុវត្តលើការពិគ្រោះយោបល់មានលក្ខណៈល្អប្រសើរ គឺគោលនយោបាយរបស់ភ្នាក់ងារ ឬក្រុមហ៊ុនជាក់លាក់ដែលបានចូលរួមនៅក្នុងការសាងសង់ទំនប់ និងគម្រោងវារីអគ្គិសនីនានា ។ ស្តាប័នទាំងនេះ បានរកឃើញពីបទពិសោធថា ការចូលរួមជាសាធារណៈអាចផ្តល់នូវអត្ថ-ប្រយោជន៍រយៈពេលវែងសម្រាប់ស្តាប័នរបស់ខ្លួន។ នៅក្នុងករណីជាច្រើន ស្តាប័នទាំងនេះបានបង្កើតគោលការណ៍រៀងៗខ្លួនសម្រាប់ការចូលរួម។

ប្រធានបទពិភាក្សា	ចូរពិភាក្សាអំពីបទដ្ឋានជានិយាមទាក់ទងនឹងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងបរិបទនៃការតាក់តែងច្បាប់និង/ឬបទប្បញ្ញត្តិនានានៅក្នុងប្រទេសរបស់អ្នក។ …… តើមានតម្រូវការសម្រាប់ធ្វើឲ្យប្រសើរឡើងដល់បទដ្ឋានជានិយាមទាក់ទងនឹងការចូលរួមរបស់អ្នកពាក់ព័ន្ធដែរឬទេ និងហេតុអ្វី?
លំហាត់	• ចូរបរិយាយលម្អិតលើគោលការណ៍គន្លឹះ ដែលបង្កើតជាមូលដ្ឋានសម្រាប់គាំទ្រដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលដើរតួនាទីជាអប្បរមា នៅពេលចាប់ផ្តើមអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានទំហំធំ។

៨.៤ ទិដ្ឋភាព និងចំណាប់អារម្មណ៍ផ្សេងៗ ៖

គោលបំណង	គោលបំណងនៃវគ្គសិក្សានេះ គឺការផ្តល់នូវដំណោះស្រាយ លើទិដ្ឋភាព និងចំណាប់អារម្មណ៍ផ្សេងៗ ដែលមានសារៈសំខាន់ សម្រាប់ការយល់ដឹងក្នុងពេលចាប់ផ្តើមអនុវត្តការចូលរួមរបស់ភាគីពាក់ព័ន្ធ។
ទិសដៅ	• ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីទស្សនៈគន្លឹះទាក់ទងនឹងការកំណត់ពេលវេលា កម្រិត និងវិសាលភាពនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ ចំណាប់អារម្មណ៍ផ្នែកហិរញ្ញវត្ថុ ទស្សនៈគន្លឹះនៃទាក់ទងនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ និងទិដ្ឋភាពដែលរួមចំណែកដល់គោលការណ៍អនុវត្តល្អ។
ការអានតាមលំដាប់លំដោយ	គម្រោងកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន (UNEP 2007)។ ទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ ។ កម្រងឯកសារស្តីពីការអនុវត្តសមស្របលើការធ្វើសេចក្តី

	សម្រេចចិត្តល្អប្រសើរស្តីពីទំបន់វារីអគ្គិសនី និងជម្រើសជំនួស។ (ផ្នែកទី៣: ការចូលរួមរបស់ភាគីពាក់ព័ន្ធ) www.unep.org/dams

៨.៥.១ ការកំណត់ពេលវេលា

យន្តការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ មានជាប់ទាក់ទងនឹងសកម្មភាពសំខាន់៣ ៖

- ការផ្តល់ព័ត៌មានទៅអ្នកដែលពាក់ព័ន្ធ។
- ការប្រមូលផ្តុំ និងបូកសរុបមតិយោបល់របស់ភាគីពាក់ព័ន្ធ។
- ការផ្តល់យោបល់ត្រឡប់ពីរបៀបដែលមតិយោបល់របស់អ្នកពាក់ព័ន្ធមានឥទ្ធិពលទៅលើការសម្រេចចិត្តមួយ។

មានការទទួលស្គាល់រួចជាស្រេចហើយអំពីសារៈសំខាន់នៃការទទួលបានព័ត៌មានជាមុន ពីសំណាក់អ្នកពាក់ព័ន្ធ ។ ទាមទារឲ្យមានរយៈពេលអប្បបរមាយ៉ាងហោច៦ខែ ដើម្បីអាចឲ្យភាគីពាក់ព័ន្ធទទួលបានព័ត៌មាន ក៏ដូចជាទាមទារឲ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីអាចឱ្យប្រជាពលរដ្ឋបានចូលរួមប្រកបដោយប្រសិទ្ធភាព និងពោរពេញដោយអត្ថន័យ។

គោលការណ៍អនុវត្តល្អអាចគាំទ្រដល់ការផ្តល់ជាដំបូងនូវព័ត៌មាន ស្តីពីវិសាលភាពនៃការសម្រេចចិត្តដែលត្រូវធ្វើ។ ប្រការនេះមានប្រសិទ្ធិភាពបន្ថែមទៀតដើម្បីផ្តល់ជាដំបូងនូវពត៌មាន ទោះបីជានៅពេលសេចក្តីលម្អិតនៃសំណើគម្រោងនៅមិនទាន់ពេញលេញក៏ដោយ។ អាចនិយាយបានថា មិនមែនលុះតែមានព័ត៌មានគ្រប់គ្រាន់ត្រឹមត្រូវ ទើបផ្តល់ឲ្យដឹងនោះទេ។ ផ្ទុយទៅវិញវាជាការប្រសើរក្នុងការផ្តល់ព័ត៌មានឲ្យបានកាន់តែឆាប់កាន់តែល្អ ទោះបីជាព័ត៌មាននោះជាដំណឹងដែលមិនទាន់គ្រប់ជ្រុងជ្រោយក៏ដោយ ។ ជារឿយៗ អ្នកអភិវឌ្ឍន៍ និងអ្នកធ្វើការសម្រេចចិត្តខាងនយោបាយ អាចផ្តល់ព័ត៌មានបានលុះណាតែសំណើររបស់ខ្លួនត្រូវបានបញ្ចប់ ដោយមានសមាសភាគទាំងអស់ដែលបានសិក្សាស្រាវជ្រាវរួចរាល់ និងបានបញ្ចប់សព្វគ្រប់។ ការអនុវត្តបែបនេះ អាចបង្កើនការថ្នាំងថ្នាក់ពីសំណាក់អ្នកពាក់ព័ន្ធដោយសារតែភាគីទាំងនេះ ជាពិសេសក្រុមជនងាយរងគ្រោះ យល់ឃើញថា មតិយោបល់របស់ពួកគេមិនត្រូវបានយកទៅប្រើប្រាស់នោះទេ ហេតុដូច្នេះហើយពួកគេមិនដែលបានចូលរួម ឬ ក្រោយមកបានដកខ្លួនចេញពីដំណើរការចូលរួមនោះ។ វិធីសាស្ត្រនេះក៏អាចជួយកាត់បន្ថយឱកាសដើម្បីទាញយកប្រយោជន៍លើចំណេះដឹងនៅមូលដ្ឋាន ដែលគួរតែធ្វើការពិចារណាឡើងវិញ។

អ្នកពាក់ព័ន្ធត្រូវការព័ត៌មាននៅជុំវិញរយៈកាលអនុវត្តគម្រោងទាំងមូល។ ពួកគេទំនងជាមានលទ្ធភាពទទួលបានព័ត៌មានខ្លះៗជាទៀងទាត់ ទោះក្នុងបរិមាណតិចតួចក្តី ក៏វាប្រសើរជាងការទទួលបានឯកសារទាំងដុលនៅចុងបញ្ចប់នៃគម្រោងដែរ។

ប្រការសំខាន់ គឺត្រូវផ្តល់ឱកាសគ្រប់គ្រាន់និងទាន់ពេលវេលាដល់ភាគីពាក់ព័ន្ធឲ្យចូលរួមទទួលព័ត៌មាន និងចូលរួមពិភាក្សាជាមួយមនុស្សដែលពួកគេជឿទុកចិត្ត។ ក្របខ័ណ្ឌគតិយុត្ត ឬជាបទប្បញ្ញត្តិនៅក្នុងប្រទេសមួយចំនួន ដូចជាប្រទេសអូស្ត្រាលី ប្រទេសណូវែលសេឡង់ ចក្រភពអង់គ្លេស កាណាដា និងអាហ្វ្រិកខាងត្បូង ជារឿយៗតម្រូវឱ្យមានរយៈពេលអប្បបរមា២៨ថ្ងៃ ដើម្បីអនុញ្ញាតឱ្យភាគីពាក់ព័ន្ធបានចូលរួមផ្តល់មតិយោបល់នានា។ តាមការពិត នៅក្នុងដំណើរការពិគ្រោះយោបល់ភាគច្រើន គួរអនុញ្ញាតឲ្យបានលើសពី២៨ថ្ងៃ ដោយសាររយៈនេះមិនប្រាកដថាជាពេលវេលាគ្រប់គ្រាន់ សម្រាប់ក្រុមជនងាយរងគ្រោះក្នុងការធ្វើការរួមគ្នា ដើម្បីស្វែងយល់ពីព័ត៌មាន និងដើម្បីផ្តល់នូវការឆ្លើយតបយល់ព្រមលើសំណើគម្រោងដែលមានទំហំណាមួយឡើយ។

៨.៤.២ កម្រិតនិងវិសាលភាពនៃការចូលរួម

ការចូលរួមរបស់អ្នកពាក់ព័ន្ធត្រូវបានអនុវត្តជាញឹកញាប់ដោយការប្រើប្រាស់មក្រិត " ផ្តល់ព័ត៌មាន " ឬ " ពិគ្រោះយោបល់ " លើវិសាលគមនៃការចូលរួមជាសាធារណៈ IAP2។ ប្រសិនបើមិនអាចបញ្ជាក់ថាការចូលរួមរបស់ភាគីពាក់ព័ន្ធមិនអាចអនុវត្តបាននៅកម្រិតណាមួយដែល " ល្អប្រសើរ " ជាងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅកម្រិតមួយផ្សេងទៀត អ្នកស្នើគម្រោងត្រូវបានលើកទឹកចិត្តឲ្យបើកឱកាសដល់ភាគីពាក់ព័ន្ធបានចូលរួមនៅកម្រិតណាមួយ ដែលអ្នកធ្វើការសម្រេចចិត្តជឿថានឹងផ្តល់លទ្ធផលនៅក្នុងការសម្រេចចិត្តដ៏ល្អបំផុត និងប្រកបដោយនិរន្តរភាពជាងគេបំផុត។

ជាធម្មតា នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាគម្រោងទំនប់ និងគម្រោងវារីអគ្គិសនីជាដើម ការចូលរួមរបស់អ្នកពាក់ព័ន្ធភាគច្រើនត្រូវបានធ្វើឡើងនៅកម្រិត " ផ្តល់ព័ត៌មាន " ឬ " ពិគ្រោះយោបល់ " នៅដំណាក់កាលភាគច្រើនបំផុតក្នុងដំណើរការអភិវឌ្ឍណាមួយ ។ ការចាត់ចែងទាំងនោះ ត្រូវបានរៀបចំឡើងដើម្បីចំណាយពេលវេលានិងធនធានបន្ថែមទៀត ដើម្បីធ្វើការជាមួយភាគីពាក់ព័ន្ធសំដៅទទួលបានការជឿទុកចិត្តរបស់ពួកគេ ជំនាញរបស់ពួកគេ និងដំបូន្មានរបស់ពួកគេ ដែលជាញឹកញាប់អាចធ្វើឱ្យសម្រេចបាននូវការសម្រេចចិត្តប្រកបដោយនិរន្តរភាព និង ទទួលបានការយល់ព្រមជាសាធារណៈកាន់តែច្រើនឡើងលើការសម្រេចចិត្តទាំងនោះ។

ជាធម្មតា អ្នកធ្វើសេចក្តីសម្រេចចិត្តមិនមានឆន្ទៈក្នុងការស្វែងរកគំនិតថ្មីៗពីមនុស្សដែលមិនមែនជាអ្នកបច្ចេកទេស ដើម្បីជួយពួកគេឲ្យធ្វើសេចក្តីសម្រេចចិត្តណាមួយដែលមានលក្ខណៈបច្ចេកទេសឡើយ។ រឹតតែកម្រទៅទៀតដែលអ្នកសម្រេចចិត្តអនុញ្ញាតឱ្យភាគីពាក់ព័ន្ធ មកអង្គុយក្នុងតុជាមួយគ្នាដើម្បីធ្វើការសម្រេចចិត្ត ដែលមានន័យថាជាការធ្វើការនៅក្នុងកម្រិត " រួមសហការគ្នា " ។

៨.៤.៣ ការផ្តល់ហិរញ្ញប្បទាន

តាមបទពិសោធន៍ធ្វើការជាមួយអង្គការនានា ការអនុវត្តនីតិវិធីនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺមានឧបសគ្គជាច្រើនទៅលើបញ្ហាថវិកាសម្រាប់ការងារនេះ ។ ជាក់ស្តែងទាក់ទងទៅនឹង ភាពអល់ឯករបស់ប្រធានគម្រោងភាគច្រើន ក្នុងការលាតត្រដាងឲ្យដឹងពីការកំណត់ថវិកាសម្រាប់សកម្មភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ។

គម្រោងទំនប់ និងគម្រោងវារីអគ្គិសនីភាគច្រើនបំផុត មានតម្លៃចន្លោះពី ៥៥លានដុល្លារសហរដ្ឋ-អាមេរិក ទៅ ១កោដដុល្លារសហរដ្ឋអាមេរិក ដើម្បីធ្វើការអភិវឌ្ឍ។ ក្នុងករណីជាច្រើន តិចជាង១០%នៃតម្លៃរបស់គម្រោង ត្រូវបានចំណាយលើសកម្មភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលថវិកាមានចំនួនកម្រិតជាធម្មតា រវាងពី៨ពាន់ ទៅ៣៥០ពាន់ ដុល្លារសហរដ្ឋអាមេរិក សម្រាប់រយៈពេលបីឆ្នាំ។ នៅពេលដែលលទ្ធភាពប្រគល់ឲ្យគម្រោងមួយពឹងផ្អែកយ៉ាងខ្លាំងលើគោលការណ៍អនុវត្តល្អស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ បែរជាគួរឱ្យភ្ញាក់ផ្អើលទៅវិញដែលថាថវិកាដែលបានត្រៀមបម្រុងសម្រាប់គោលបំណងនេះ មានចំនួនតិចតួចបំផុត។ ការស្រាវជ្រាវដែលមិនបានផ្សព្វផ្សាយក្នុងចំណោមអ្នកដែលពាក់ព័ន្ធក្នុងការប្រើប្រាស់ថវិកានានា បង្ហាញថាមានវិធីជាច្រើនក្នុងការបង្កើតឲ្យមានថវិកានេះ ៖

- មាននិន្នាការកើនឡើងជាច្រើនក្នុងការបង្កើតថវិកា ជាពិសេសសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាគម្រោងទំនប់ និងគម្រោងវារីអគ្គិសនី ផ្អែកលើភាគរយនៃថវិកាគម្រោងសរុប។ ដូច្នេះ ជាឧទាហរណ៍ ប្រសិនបើគម្រោងមួយមានថវិកាសរុបចំនួន ១00,000,000 ដុល្លារសហរដ្ឋអាមេរិក នោះថវិកាដែលត្រូវបង្កើតសម្រាប់ចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធអាចមានចំនួនប្រហែល១% ទៅ២%នៃថវិកាសរុបរបស់គម្រោង។
- ថវិកាអាចត្រូវបានកំណត់នៅពេលដែលផែនការ ស្តីពីការចូលរួមរបស់អ្នកពាក់ព័ន្ធត្រូវបានរៀបចំឡើងដោយផ្អែកលើចំនួនទឹកប្រាក់ប៉ាន់ប្រមាណ ដែលទាមទារឱ្យមានការកំណត់នៅក្នុងផែនការ។
- ជួនកាលមិនមានថវិកាជាក់លាក់សម្រាប់ចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធទេ ហើយសកម្មភាពទាំងអស់ ត្រូវបានទទួលការឧបត្ថម្ភថវិកាក្រៅពីថវិការបស់គម្រោង ដែលមានន័យថាមានការប្រកួតប្រជែងដើម្បីទទួលបានមូលនិធិរវាងគម្រោងនិងដំណើរការនៃការចូលរួម។
- ជួនកាលមិនមានថវិកាជាក់លាក់ សម្រាប់ចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធទេ ពីព្រោះម្ចាស់ជំនួយអន្តរជាតិបានយល់ព្រមផ្តល់មូលនិធិដល់គម្រោងនៅពេលណាដែលគម្រោងនោះបានអនុម័តរួចរាល់ហើយ ។ ជាលទ្ធផលស្ថាប័នណាមួយត្រូវតែត្រៀមបម្រុងទុកនូវធនធាន

ដែលមានស្រាប់របស់ខ្លួនឲ្យបានទាន់ពេលវេលា សម្រាប់ចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងអំឡុងពេលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និង ក្នុងអំឡុងពេលដំណើរការអនុម័តគម្រោង។

គោលការណ៍អនុវត្តល្អតម្រូវឱ្យមានការកំណត់ថវិកាឲ្យបានពិតប្រាកដ ក្នុងអំឡុងពេលដំណាក់កាលជុំវិញបញ្ហាវិសាលភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំណាមួយ ដែលជាអប្បបរមា ត្រូវគ្របដណ្តប់លើ សកម្មភាព ដូចខាងក្រោម ៖

- ការធ្វើផែនការការចូលរួម។
- ការផលិតនិងការចែកចាយឧបករណ៍ទំនាក់ទំនងដែលមានប្រសិទ្ធិភាព។
- សកម្មភាពមួយចំនួនដែលបើកអាចឲ្យអ្នកពាក់ព័ន្ធបានចូលរួមទទួលព័ត៌មានបច្ចេកទេស។
- ការប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ។
- ការបញ្ចូលទិន្នន័យទៅជាព័ត៌មានដ៏មានប្រយោជន៍សម្រាប់អ្នកធ្វើការសម្រេចចិត្ត។
- ការផ្តល់មតិត្រឡប់វិញជាបន្តដល់ភាគីពាក់ព័ន្ធលើរបៀប ដែលអ្នកធ្វើការសម្រេចចិត្តបានយកទៅប្រើប្រាស់ជាពត៌មាន។

នៅពេលចរចាហិរញ្ញវត្ថុសម្រាប់គម្រោង ជាការសមស្របគេត្រូវធានាឱ្យមានការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់ ដំណើរការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធដែលត្រូវអនុវត្តដោយអ្នកដែលមានជំនាញសមស្របឬដើម្បីរួមបញ្ចូលពេលវេលានិងធនធានដើម្បីកសាងសមត្ថភាពចាំបាច់ ។ គុណសម្បត្តិអាចត្រូវបានគេមើលឃើញ នៅក្នុងករណីគម្រោងទំនប់ណាំធឿន២ ដែលការកសាងសមត្ថភាពនៅក្នុងការចូលរួមបានធ្វើឲ្យប្រសើរដល់ទស្សនវិស័យស្តីពីការតាំងទីលំនៅថ្មី។

ទិន្នន័យមួយចំនួនដែលអាចរកបានពីគម្រោងជាក់លាក់នានា ៖

- គម្រោងទំនប់វារីអគ្គិសនី Wivenhoe Dam Upgrade: ថវិកាចំនួន៩១៣,៨៥០ដុល្លារអូស្ត្រាលី ត្រូវបានចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលបានពីថវិកាគម្រោងសាងសង់មានទឹកប្រាក់សរុប៧០លានដុល្លារអូស្ត្រាលី។
- គម្រោងវារីអគ្គិសនី Manapouri Power Scheme ៖ ការចំណាយថវិកាលើការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺតាមលំដាប់១0%នៃការចំណាយសរុបលើការពិនិត្យឡើងវិញ។
- គម្រោងថាមពលវារីអគ្គិសនី Upper Kotmale Hydropower Project: ការចំណាយលើការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងរយៈពេល៦ឆ្នាំ ត្រូវបានប៉ាន់ថាមានប្រមាណជា៦0,000 ដុល្លារសហរដ្ឋអាមេរិក (0,២៥% នៃថវិកាសរុបរបស់គម្រោង)។

- ការធ្វើផែនការតាំងទីលំនៅថ្មីសម្រាប់រោងចក្រថាមពលវារីអគ្គិសនី Salto Caxias Hydroelectric Power Plant ៖ ថវិកាសរុបនៃគម្រោងនេះ គឺមានចំនួនមួយកោដដុល្លារអាមេរិក ក្នុងនោះទឹកប្រាក់ចំនួន២៥០ លានដុល្លារអាមេរិកបានចំណាយទៅលើការកាត់បន្ថយផលប៉ះពាល់នានាលើសង្គម និងបរិស្ថាន។

៨.៤.៤ លក្ខណៈវិនិច្ឆ័យសម្រាប់គោលការណ៍អនុវត្តល្អស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ

លក្ខណៈវិនិច្ឆ័យសម្រាប់គោលការណ៍អនុវត្តល្អស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ រួមមាន ៖

- យន្តការនិងវិធីសាស្ត្រជាលក្ខណៈស្តាប់ន។
  - ការប្រើប្រាស់បច្ចេកទេសសមស្រប ដែលគាំទ្រការយល់ដឹងពិតប្រាកដពីព័ត៌មាន ដែលទាក់ទងនឹងគម្រោងដែលអាចឱ្យភាគីពាក់ព័ន្ធបានទទួលព័ត៌មានពីការចូលរួម។
  - ក្របខណ្ឌគតិយុត្តិមូលដ្ឋាននៃគោលការណ៍គាំទ្រដោយគោលការណ៍ណែនាំលម្អិត។
  - ការអនុវត្តការចូលរួមរបស់អ្នកពាក់ព័ន្ធដោយតម្លាភាពនៃបំណង ជំនាញនៃការស្តាប់ប្រកបដោយប្រសិទ្ធិភាពនិងការគោរពចំពោះមតិយោបល់ច្រើនយ៉ាង។
  - ឆន្ទៈនិងជំនាញដើម្បីធ្វើការតាមរយៈជម្លោះ [(យោង២៨)] ដែលជាលទ្ធផលបានមកពីទស្សនៈច្រើនយ៉ាង។
  - ដំណើរការមួយដ៏មានប្រសិទ្ធិភាពដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ។
  - ការបូកសរុបយ៉ាងត្រឹមត្រូវលើទិន្នន័យដែលប្រមូលបាន ដើម្បីផ្តល់នូវពត៌មានដែលមានសារៈប្រយោជន៍ដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។
  - អ្នកធ្វើសេចក្តីសម្រេច ប្រើព័ត៌មាននេះដើម្បីបង្កើនចំណេះដឹងរបស់ខ្លួន និងធ្វើការសម្រេចចិត្តបានល្អប្រសើរ។
  - មតិយោបល់ត្រឡប់ដល់អ្នកចូលរួមពីរបៀបដែលការរួមចំណែក របស់ពួកគេមានឥទ្ធិពលលើការសម្រេចចិត្ត។
  - ដំណើរការវាយតម្លៃមួយដ៏មានប្រសិទ្ធិភាព ដែលជួយសម្រួលដល់ការសិក្សារៀនសូត្រថ្មីៗ និង ការអនុវត្តដែលមានលក្ខណៈល្អប្រសើរ។

[(យោង២៨)] ការគ្រប់គ្រងជម្លោះ គឺជាសមាសភាគដ៏សំខាន់មួយនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ។ ការគ្រប់គ្រងជម្លោះ គឺជាដំណើរការនៃការធ្វើផែនការដើម្បីបញ្ចៀសជម្លោះតាមដែលអាចធ្វើទៅបាន និងជាការរៀបចំដោះស្រាយដោយរលូន តាមដែលអាចធ្វើទៅបាននូវរាល់ជម្លោះដែលកើតឡើង។ ការគ្រប់គ្រងជម្លោះ គឺរបៀបប្រកបដោយជំនាញមួយដែលតម្រូវឱ្យមានធនធាននិងសេវាកម្មរបស់អ្នកជំនាញ ដែលទទួលបានការបណ្តុះបណ្តាលជាពិសេសក្នុងការគ្រប់គ្រងជម្លោះ។ អ្នកជំនាញទាំងនេះគួរតែជាផ្នែកមួយនៃក្រុមអ្នកចូលរួមរបស់អ្នកពាក់ព័ន្ធដែលត្រូវបានបំពេញតួនាទីតាមការត្រូវការចាំបាច់។

- ការផ្តល់ហិរញ្ញវត្ថុ។
  - ធនធានគ្រប់គ្រាន់ រួមមានថវិកា ពេលវេលា និង ជំនាញ ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ។
- ការកំណត់ពេលវេលា។
  - ការចូលរួមរបស់អ្នកពាក់ព័ន្ធគួរចាប់ផ្តើមឲ្យបានមុនដំណើរការគម្រោង តាមដែលអាចធ្វើទៅបាន រួមមាន សារមួយចំនួនដែលបានចោទជាសំនួរឡើង និង មិនទាន់បានឆ្លើយនៅឡើយ។
- ការធ្វើផែនការនៃការចូលរួម។
  - ការធ្វើផែនការដោយមានប្រសិទ្ធិភាព និង ការបង្កើតផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធដែលនៅដាច់ដោយឡែកពីផែនការគម្រោង ប៉ុន្តែគាំទ្រដល់ផែនការគម្រោង (រួមបញ្ចូលទាំងការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងការវិភាគ និងមតិយោបល់ពីភាគីពាក់ព័ន្ធលើរបៀបដែលពួកគេចង់ចូលរួមពាក់ព័ន្ធ)។
  - ការប្តេជ្ញាចិត្តរបស់អ្នកធ្វើការសម្រេចចិត្តចំពោះការរាប់បញ្ចូលសរុបក្នុងការចូលរួម។

លក្ខណៈវិនិច្ឆ័យទាំងនេះ អាចត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាបញ្ជីពិនិត្យ នៅពេលរៀបចំការចូលរួម ឬសម្រាប់ជាមូលដ្ឋានសម្រាប់ការវាយតម្លៃចរិកលក្ខណៈជាមូលដ្ឋាននៃដំណើរការនៃការចូលរួម។

ប្រអប់អត្ថបទ៨.៨ ទិដ្ឋភាព និងការពិនិត្យពិច័យផ្សេងៗ- ទិដ្ឋភាពគន្លឹះ
ទិដ្ឋភាព និងការពិនិត្យពិច័យទាំងនេះ រួមមា ៖ • សារៈសំខាន់នៃការកំណត់ពេលវេលាសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនិងសកម្មភាពរបស់ខ្លួន។ • កម្រិតនិងវិសាលភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីឲ្យបានសមរម្យសម្រាប់គម្រោងដាច់ដោយឡែក និងត្រូវបានអនុវត្តតាមរយៈផែនការចូលរួមតាមការចង់បានពីភាគីពាក់ព័ន្ធ។ • ការផ្តល់ហិរញ្ញប្បទាន ជាពិសេសដើម្បីធានាថាផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ មានធនធាននៅក្នុងដៃគ្រប់គ្រាន់សម្រាប់អនុវត្តការងារ និងសកម្មភាពនានា។ • ការកំណត់ឲ្យបានច្បាស់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់គោលការណ៍អនុវត្តល្អស្តីពីការចូលរួមរបស់ អ្នកពាក់ព័ន្ធ។

ប្រធានបទពិភាក្សា	តែងតែមានកិច្ចពិភាក្សាជុំវិញបញ្ហាថវិកានិងចំនួនថវិកាដែលត្រូវចំណាយ ដើម្បីធ្វើឲ្យសម្រេចបានតាមកម្រិតដែលចង់បានលើការចូលរួមពីភាគីដែលពាក់ព័ន្ធ។ ចូរពិភាក្សាថាតើអ្វីដែលធ្វើឲ្យអ្នកមានអារម្មណ៍ថា ជាការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ និងថាតើអ្វីខ្លះជាលទ្ធផលដែលអ្នកចង់បាន គួរតែស្ថិតក្នុងកម្រិតនៃការផ្តល់ធនធាន។
លំហាត់	តាមរយៈការប្រើឧទាហរណ៍ពីប្រទេសផ្ទាល់ខ្លួនរបស់អ្នក ចូរកំណត់ឲ្យបានច្បាស់លើគម្រោងចំនួន៦ និង ធ្វើការវាយតម្លៃពីភាពគ្រប់គ្រាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងបរិបទនៃពេលវេលាដែលគម្រោងទាំងនោះត្រូវបានផ្តួចផ្តើមឲ្យមាន និងរបៀបផ្តល់ធនធានយ៉ាងត្រឹមត្រូវសម្រាប់ដំណើរការនេះ។

៩ ឯកសារយោងសំខាន់ៗ

ចំណាំ ៖ ក្នុងករណីសិក្សាទាំងអស់ ត្រូវបានដកស្រង់ចេញពី UNEP (2007) កម្រងឯកសារស្តីពីទំនប់វារីអគ្គិសនី និងការអភិវឌ្ឍ លើមិនដូចច្នេះទេ លុះត្រាតែមានការរៀបរាប់។

Asian Development Bank. (1998). Summary of the Handbook on Resettlement. A Guide to Good Practice. Asian Development Bank, Manila, Philippines.

Casley, D.J. and Kumar, K. (1987). Project monitoring and evaluation in agriculture. Published for the World Bank. The John Hopkins University Press, Baltimore.

DEAT (2004). Overview of Integrated Environmental Management. Integrated Environmental Management, Information Series 0. Pretoria: Department of Environmental Affairs and Tourism (DEAT).

Gagnon, L., Klimpt, J.E. and Seelos, K. (2002). Comparing recommendations from the World Commission on Dams and the IEA initiative on hydropower. In Energy Policy. November 2002 Issue.

Eastham J., Mpelasoka F., Mainuddin M., Ticehurst C., Dyce P., Hodgson G. and Kirby M. (2008). Mekong River Basin Water Resources Assessment: Impacts of Climate Change. Australian Commonwealth Scientific and Research Organization: Water for a Healthy Country National Research Flagship. Canberra, Australia.

Égré, D. (2006). United Nations Environment Programme – Dams and Development Project. Compendium of Relevant Practices. Benefit Sharing Issue.

Heinsohn, R-D. (2007). United Nations Environment Programme – Dams and Development Project. Compendium of Relevant Practices. Social Impact of Affected People.

International Association of Public Participation. (2007). United Nations Environment Programme – Dams and Development Project. Stakeholder Participation Mechanisms (Eds. V. Twyford and C. Bladwin).

IFC (2002). Handbook for Preparing a Resettlement Action Plan. IFC: Environment and Social Development Department. The World Bank Group, Washington, USA.

IFC Performance Standards on Environmental and Social Sustainability (January 2012): Performance Standard 5: Land Acquisition and Involuntary Resettlement (www.ifc.org).

International Finance Corporation - Policy and Performance Standards on Social and Environmental Sustainability (2006): Performance Standard 5: Land Acquisition and Involuntary Resettlement (www.ifc.org).

International Finance Corporation – Guidance Notes: Performance Standards on Social and Environmental Sustainability (2007): Guidance Note 5: Land Acquisition and Involuntary Resettlement (www.ifc.org).

International Hydropower Association (2004). Sustainability Guidelines (www.hydropower.org).

Molle, F, Tira, F, and Mira,K (eds.). 2009. Contested Waterscaps in the Mekong Region: Hydropower, Livelihoods and Governance. Earthscan, UK and USA.

Moore, D., Dore, J. and Gyawali, D. (2010). The World Commission on Dams + 10: Revisiting the large dam controversy. Water Alternatives 3(2): 3-13. www.water-alternatives.org

International Hydropower Association. (2011). Hydropower Sustainability Assessment Protocol: Background Document.

Roquet, V. (2006). United Nations Environment Programme – Dams and Development Project. Compendium of Relevant Practices. Compensation Policy Issue.

Sawdon, J., Thuon, T., S. Somchanmayong, and P. Wyrwoll (2013), 'Mekong ARCC Task 2: Climate Change and Vulnerability Assessment – Social and Economic Assessment', International Centre for Environmental Management (ICEM) and DAI-A thematic report prepared for USAID

Schmidt-Soltau, K. (2006). United Nations Environment Programme – Dams and Development Project. Compendium of Relevant Practices. Addressing Outstanding Social Issues.

Smits, Mattijs (2012) Hydropower and the Green Economy in Laos: Sustainable Developments in Hezri, A., Hofmeister, W. (Eds.), 2012, Towards a Green Economy: In Search of Sustainable Energy Policies for the Future. Singapore: Konrad Adenauer Stiftung.

South Africa (2010). South Africa. Environmental Assessment Regulations. Government Gazette, 33306, 18 June. (Government Notice R 543). 2010.

Southern African Development Community (SADC). (Undated). SADC Concept Paper on Benefit Sharing and Transboundary Water Management and Development. SADC Secretariat, Gaborone, Botswana.

Tapela, B.N., Matete, M.E. and Heinsohn R-D. A Training Manual on Selected Economic and Social Aspects of Large Water Infrastructure, for the Sustainable Major Water Infrastructure Development Programme in Eastern and Southern Africa. SADC, EAC, UNEP, InWEnt. (2009).

Taylor, C.N., Bryan, C.H. and Goodrich, C.G. (1995). Social Assessment: Theory, Process and Techniques. Second Edition. The Caxton Press, Christchurch, New Zealand.

The World Bank. (2004). Involuntary Resettlement Sourcebook. Planning and Implementation in Development Projects. The World Bank, Washington, USA.

The World Bank Position on the Report of the World Commission on Dams (2000) pp. 3-4. The World Bank's position on this matter was supported, among others, by the International Hydropower Association.

United Nations. The future we want. Resolution adopted by the General Assembly A/RES/66/288, 123rd plenary meeting. (27 July 2012).

United Nations. 2012. International Year of Sustainable Energy for All, 2012: Report of the Secretary General. Report A/67/314. (16 August 2012).

UNEP, (2007). Dams and Development: A Compendium of Relevant Practices for Improved Decision-Making on Dams and their Alternatives. www.unep.org/dams

Note: this UNEP document as well as other related UNEP background studies are also available at the NSHD-website available; see: library

United Nations Symposium on Hydropower and Sustainable Development. Beijing. (October 27-29, 2004). Available online at: www.un.org/esa/sustdev/sdissues/energy/op/. para. 11, p.2.

Vanclay, F. (2003). Social Impact Assessment International Principles. International Association for Impact Assessment Special Publication Series Number 2.

Van Wiclin, I. & Warren W. (1999). Sharing Project Benefits to Improve Resettlers' Livelihoods. In Cernea, M. (Ed). The Economics of Involuntary Resettlement: Questions and Challenges. World Bank.

World Commission on Dams (2000). Dams and Development: A New Framework for Decision Making. Earthscan Publishers: London (UK).

www.businessdictionary.com

www.iap2.org/associations/4748/files/foundations-bro.pdf

១០ សាវតាកម្មវិធីកិច្ចសហប្រតិបត្តិការរវាងអង្គការ MRC-GIZ

អង្គការ GIZ បាននិងកំពុងជួយគាំទ្រដល់គណៈកម្មាការទន្លេមេគង្គ (MRC) នៅក្នុងការងារកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍវារីអគ្គិសនីដោយយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន ក៏ដូចជាក្នុងការការពារប្រជា-ពលរដ្ឋពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម។ អង្គការ GIZ បាននិងកំពុងជួយគាំទ្រដោយផ្ទាល់ដល់អ្នកជំនាញ និង ថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ គណៈកម្មាធិការជាតិទន្លេមេគង្គ និងក្រសួងនានាពាក់ព័ន្ធនឹងការងារទឹក ថាមពលនិងបរិស្ថាននៅក្នុងប្រទេសជាសមាជិក។ កម្មវិធីរបស់អង្គការ GIZ មានគោលបំណងដើម្បីជួយសម្រេចឲ្យបាននូវការធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពរស់នៅប្រជាពលរដ្ឋជាង៦០លាននាក់ ដែលរស់នៅតំបន់អាងទន្លេមេគង្គក្រោម ក្នុងរយៈពេលវែង និងប្រកបដោយនិរន្តរភាព។

កម្មវិធីរបស់អង្គការ GIZ មានសមាសភាគ ដូចខាងក្រោមនេះ (http://www.giz.de/themen/en/30306.htm):

- ការគាំទ្រដល់គណៈកម្មការទន្លេមេគង្គនៅក្នុងកំណែទម្រង់របស់ស្ថាប័ន។
- ការគាំទ្រដល់ការគណៈកម្មការទន្លេមេគង្គ ក្នុងការអភិវឌ្ឍវារីអគ្គិសនីដែលគាំទ្រដល់ជនក្រីក្រប្រកបដោយនិរន្តរភាព។
- ការគាំទ្រដល់ការគណៈកម្មការទន្លេមេគង្គ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ទន្លេមេគង្គ។
- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការគ្រប់គ្រងទឹកជំនន់មានលក្ខណៈស្រួចស្រាល។

ការគាំទ្រដល់គណៈកម្មការទន្លេមេគង្គ ក្នុងការអភិវឌ្ឍវារីអគ្គិសនីដែលគាំទ្រដល់ជនក្រីក្រប្រកបដោយនិរន្តរភាព

អង្គការ GIZ បានជួយផ្តល់ប្រឹក្សាដល់គណៈកម្មការទន្លេមេគង្គ (MRC) លើការអភិវឌ្ឍ និង អនុវត្តឧបករណ៍នានា សម្រាប់ការសាកល្បង និងការធ្វើឱ្យប្រសើរនូវនិរន្តរភាពនៃគម្រោងទំនប់វារីអគ្គិសនី។ ចំនុចនេះរួមមាន ឧទាហរណ៍ដូចជា ឧបករណ៍សម្រាប់ធ្វើការវិភាគពីផលប៉ះពាល់នៃការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងតំបន់ទីជម្រាល ក៏ដូចជាវិធីសាស្ត្រសម្រាប់បង្កើតយន្តការបែងចែកផលប្រយោជន៍ ក្នុងរង្វង់តំបន់ទីជម្រាលនិងឯនាយព្រំដែន។ លើសពីនេះទៀត អង្គការ GIZ បានជួយលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍រវាងគណៈ-កម្មការអាងទន្លេនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព ។ គម្រោងនេះ ក៏បានជួយបង្កើតវិធានបណ្តុះបណ្តាលមូលដ្ឋាននិងមានកម្រិតខ្ពស់ស្តីពីវារីអគ្គីសនី ប្រកបដោយនិរន្តរភាព។

បណ្តាញស្តីពីការអភិវឌ្ឍថាមពលវារីអគ្គិសនីប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសទន្លេមេគង្គ (NSHD-M)

NSHD-M ត្រូវបានរួមបញ្ចូលទៅក្នុងគម្រោង " ការគាំទ្រដល់គណៈកម្មការទន្លេមេគង្គក្នុងការអភិវឌ្ឍ វារីអគ្គិសនីដែលគាំទ្រដល់ជនក្រីក្រប្រកបដោយនិរន្តរភាព" នៃគណៈកម្មការទន្លេមេគង្គ (MRC)-កម្មវិធីសហ ប្រតិបត្តិការនៃអង្គការ GIZ។ បណ្តាញនេះត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ២០១២ ដោយសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវនៅក្នុងបណ្តាប្រទេសទន្លេមេគង្គ រួមមានប្រទេសកម្ពុជា ចិន ឡាវ ថៃ និងវៀតណាម។ បណ្តាញនេះមានគោលបំណងដើម្បី ៖

- បង្កើនចំណេះដឹងនិងជំនាញលើការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយនិរន្តរភាព (SHD) នៅវិទ្យា-ស្ថានសិក្សានិងស្រាវជ្រាវ។
- ចែករំលែកចំណេះដឹងនិងបទពិសោធន៍ស្តីពីការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយនិរន្តរភាព (SHD) នៅក្នុងបណ្តាប្រទេសទន្លេមេគង្គ។
- បង្កើនការយល់ដឹងលើការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយនិរន្តរភាព (SHD) នៅគ្រប់កម្រិតទាំង អស់នៃការធ្វើសេចក្តីសម្រេចចិត្ត។
- ពង្រឹងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ រួមទាំងអ្នករៀបចំផែនការ និងអ្នកធ្វើការសម្រេចចិត្ត ដើម្បី ដោះស្រាយលើបញ្ហាប្រឈមនៃការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយនិរន្តរភាព (SHD)។

បណ្តាញនេះ និងសកម្មភាពរបស់ខ្លួននៅក្នុងតំបន់អាងទន្លេមេគង្គ ទទួលបានការគាំទ្រពីអង្គការ GIZ ក្នុងនាមនៃក្រសួងសហព័ន្ធសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (BMZ)។

សម្រាប់ព័ត៌មានបន្ថែមស្តីពីគោលដៅ សកម្មភាព និង ដៃគូរបស់ NSHD-M សូមចូលទៅកាន់ គេហទំព័រ ៖ www.cdri.org.kh / index.php / nshdmekong

ទំនាក់ទំនង ៖ klaus.sattler @ giz.de និង thomas.petermann @ giz.de

អំពីអ្នកនិពន្ធ

លោក Dieter Heinsohn គឺជានាយកគ្រប់គ្រងក្រុមហ៊ុន Acer (នៅអាហ្វ្រិក) ផ្នែកប្រឹក្សាយោបល់អំពីការគ្រប់គ្រងបរិស្ថាន ដំណើរការពី KwaZulu-Natal អាហ្វ្រិកខាងត្បូង ។ គាត់មានបទពិសោធន៍ជាង២៥ឆ្នាំខាងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និង កម្មវិធីចូលរួមជាសាធារណៈនៅក្នុងវិស័យជាច្រើន ជាពិសេសនៅក្នុងវិស័យទាក់ទងនឹងចំណុះទឹកច្រើន (ទំនប់វារីអគ្គិសនីធំៗ សន្ទះទឹកធំៗ ស្ថានីយ៍បូមទឹក និងបំពង់បង្ហូរជាដើម) និងវិស័យឧស្សាហកម្ម (ឧ. ការរុករករ៉ែ)។ ថ្មីៗជាងនេះទៅទៀត លោកក៏បានចូលរួមក្នុងការងារវិស័យថាមពលកកើតឡើងវិញ ជាពិសេសវិស័យវារីអគ្គីសនី។

លោក Try Thuon គឺជាអ្នកស្រាវជ្រាវជំនាញ ដែលមានបទពិសោធន៍ជាងមួយទសវត្សរ៍នៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសជិតខាងមួយចំនួនទៀត ដោយលោកបម្រើការងារទាក់ទងនឹងអភិបាលកិច្ចធនធានធម្មជាតិ (ដីធ្លី ព្រៃឈើ ទឹក នេសាទ) ប្រព័ន្ធចិញ្ចឹមជីវិតនៅតាមជនបទ និងការផ្លាស់ប្តូរក្បែត្រកសិកម្ម ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការបន្ធូរបន្ថយ កម្មវិធីរ៉ែដ និងការធ្វើជំនួញកាបូន។

អ្នកស្រី Wanpen Wironajagud គឺជាសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Khon Kaen មហាវិទ្យាល័យវិស្វកម្ម។ អ្នកស្រីមានបទពិសោធន៍ការងារផ្នែកវិស្វកម្មបរិស្ថាន និង ជាពិសេសផ្នែកវិស្វកម្មសុខភាពបរិស្ថាន ដែលជាវិស័យការងារជំនាញរបស់អ្នកស្រី ក្នុងចំណោមការងារជាច្រើនទៀតទាក់ទងនឹងការគ្រប់គ្រងបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

លោក Guoqing Shi គឺជាអ្នកជំនាញផ្នែកតាំងទីលំនៅថ្មីអន្តរជាតិ និងការអភិវឌ្ឍសង្គម មកពីវិទ្យាស្ថានអភិវឌ្ឍន៍សង្គម (SDI) នៃសាកលវិទ្យាល័យ Hohai និងមជ្ឈមណ្ឌលជាតិស្រាវជ្រាវសម្រាប់ការតាំងទីលំនៅថ្មី (NRCR) នៃប្រទេសចិន។ ការងារជំនាញរបស់លោក រួមមានការងារផ្តល់ប្រឹក្សាជាច្រើនដែលលោកបានផ្តោតលើគម្រោងតាំងទីលំនៅថ្មី ដែលជាញឹកញាប់ទាក់ទងនឹងការអភិវឌ្ឍវារីអគ្គិសនី។

អ្នកស្រី Silinthone Sacklokham គឺជាព្រឹទ្ធបុរសរងនៅមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យជាតិឡាវ។ បទពិសោធន៍របស់អ្នកស្រី ទាក់ទងនឹងកសិ-សេដ្ឋសាស្ត្រ ដែលអ្នកស្រីទើបបានចូលរួមពាក់ព័ន្ធលើប្រធានបទនៃការអភិវឌ្ឍថាមពលវារីអគ្គិសនី។

លោក Van Sy Nguyen គឺជាអ្នកជំនាញផ្នែកបរិស្ថានដែលបម្រើការនៅសាកលវិទ្យាល័យធនធានទឹក នៅទីក្រុងហាណូយ នៃប្រទេសវៀតណាម។ លោកគឺជាព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យវិទ្យាសាស្ត្រវិស្វកម្មបរិស្ថាន ដែលក្នុងនោះប្រធានបទសំខាន់ៗដែលលោកបានចូលរួមពាក់ព័ន្ធ រួមមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) នៃគម្រោងអភិវឌ្ឍន៍ធនធានទឹក ការគ្រប់គ្រងអាងទន្លេរួម ប្រព្រឹត្តិកម្មទឹក និងការប្រើប្រាស់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងបច្ចេកវិទ្យាប្រព្រឹត្តិកម្មសំណល់ទឹកកខ្វក់។

បោះពុម្ព

ត្រូវបានបោះពុម្ពផ្សាយដោយ
អង្គការសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសអាឡឺម៉ង់ (GIZ) GmbH
គណៈកម្មការទន្លេមេគង្គ-កម្មវិធីសហប្រតិបត្តិការអង្គការ GIZ
ប្រអប់សំបុត្រ: ៩២៣៣
ទីក្រុងវៀងចាន់ ប្រទេសឡាវ
ទូរស័ព្ទ: +856 21 263263 ext 3061
អ៊ីម៉ែល: mrc@giz.de

កម្មវិធី: គាំទ្រដល់គណៈកម្មការទន្លេមេគង្គក្នុងការអភិវឌ្ឍវារីអគ្គិសនីដែលគាំទ្រដល់ជនក្រីក្រ ប្រកបដោយនិរន្តរភាព។
បណ្តាញសម្រាប់ការអភិវឌ្ឍវារីអគ្គិសនី ប្រកបដោយនិរន្តរភាព នៅក្នុងបណ្តាប្រទេសទន្លេមេគង្គ (NSHD-មេគង្គ)
www.cdri.org.kh / nshdmekong
www.giz.de/themen/en/30306.htm

អ្នកទទួលខុសត្រូវ
លោកបណ្ឌិត Philipp Magiera (philipp.magiera@giz.de)

ការិនិពន្ធ
Thomas Petermann (thomas.petermann@giz.de)
Klaus Sattler (klaus.sattler@giz.de)

អ្នកនិពន្ធ
Dieter Heinsohn (អាហ្វ្រិកខាងត្បូង) អ្នកនិពន្ធសំខាន់
លោក Try Thuon (ប្រទេសកម្ពុជា)
អ្នកស្រី Wanpen Wirojanagud (ប្រទេសថៃ)
លោក Guoqing Shi (ប្រទេសចិន)
អ្នកស្រី Silinthone Sacklokham (ប្រទេសឡាវ)
លោក Van Sy Nguyen (ប្រទេសវៀតណាម)

រចនា និងរៀបរៀងដោយ
អង្គការ GIZ

រក្សាសិទ្ធិរូបថត
© GIZ/Lucas Wahl, Thomas Petermann

ការបដិសេធទទួលខុសត្រូវ
អង្គការ GIZ គឺជាអ្នកទទួលខុសត្រូវចំពោះខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ។

ការផលិតសារជាថ្មី
សៀវភៅបណ្តុះបណ្តាលនេះ អាចត្រូវបានផលិតសារជាថ្មីនូវទាំងស្រុង ឬមួយផ្នែកនៅក្នុងទម្រង់ណាមួយសម្រាប់គោលបំណងអប់រំ ដោយមានការស្នើសុំការអនុញ្ញាតជាមុនពីសិទ្ធិអ្នកនិពន្ធ។

ទីកន្លែង និងកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ
ទីក្រុងវៀងចាន់ ខែកញ្ញា ឆ្នាំ២០១៣

បណ្តាញអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី ប្រកបដោយចីរភាព នៃបណ្តាប្រទេសទន្លេមេគង្គ (NSHD-M)